

# ឯកសារបណ្តុះបណ្តាលស្តីពី យេនឌ័រ និង

# ការប្រែប្រួលអាកាសធាតុ

UICN

UNDP

Empowered lives.
Resilient nations.

GGCA
Global Gender and Climate Alliance

ឯកសារនេះត្រូវបានផលិតដោយសហភាពអន្តរជាតិសម្រាប់អភិរក្សធម្មជាតិ (IUCN) និងកម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP) ក្នុងភាពជាដៃគូជាមួយសម្ព័ន្ធភាពយេនឌ័រ និងទឹក បណ្តាញយេនឌ័រនិងថាមពលប្រកបដោយចីរភាព (ENERGIA) សហប្រជាជាតិទទួលបន្ទុកអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (UNESCO) អង្គការស្បៀង និងកសិកម្ម (FAO) និងអង្គការអភិវឌ្ឍ និងបរិស្ថានរបស់ស្ត្រី (WEDO) ដែលជា*ផ្នែកមួយនៃសម្ព័ន្ធភាពយេនឌ័រ និងអាកាសធាតុពិភពលោក* (*GGCA*)។

**អ្នកនិពន្ធចម្បង៖**
Lorena Aguila

**សហការជាមួយ៖**

**ជំពូក១**
Saniye Gülser Corat, UNESCO

**ជំពូក២**
Saniye Gülser Corat, UNESCO
ផ្នែក២.៣ Eva Maria Duer, UNEP &
Cheryl L. Anderson, University of Hawaii
ផ្នែក២.៥ Adel Sasvari, IUCN

**ជំពូក៣**
Saniye Gülser Corat, UNESCO

**ជំពូក៤**
Rebecca Peari, GGCA
Hannie Meesters, UNDP
Lucy Wanjiru, UNDP
Amanda Dentler, WEDO
Lourdes Meyreles

**ជំពូក៥**
ផ្នែក៥.១.២ Gail Karisson, ENERGIA

**ជំពូក៦**
Eva Rathgeber, GWA

**ជំពូក៧**
Mariama Williams & Yves Conze

**ករណីសិក្សា**
Paula Zuniga, IUCN
Yianna Lambrou, FAO
Madhavi Malalgoda Ariyabandu, Intermediate

**ក្រុមអភិវឌ្ឍបច្ចេកទេស**
Elaine Enarson & Betty Hearn Morrow

**សារគន្លឹះ និងការកែសម្រួល**
Adel Sasvari, IUCN
Karla Priego
Mariko Saito, UNDP

**អ្នកកែភាសាអង់គ្លេស**
Tiina Rajamets

**ដំណើរការកែតម្រូវ**
អ្នកជំនាញខាងក្រោមបានចូលរួមក្នុងដំណើរការកែតម្រូវ៖
Xavier Moya, Itza Castañeda, Rose Mwebaza, Jeanne Josette, Adel Sasvari, Rima Abdulhadi Ras, Rose Mensa Kutin, Sandra Freitas, Brigitte Leduc, Nadia Shevchenko, Mariko Saito, Cheryl Anderson, Eva, Maria Duer, Lourdes Meyreles, Natalia Kostus, Andrea, Quesada, Nadia Johnson, Cate Owren, Rebecca Pearl, Hannie Meesters, Lucy Wanjiru, Stacy Alboher, and Aira Kalela.

**អ្នករចនាក្រាហ្វិក**
Laura Montoya Sancho
José María Castro Madriz
Draco Firma Gráfica S.A.
draco@ice.co.cr

**អ្នកមើលការខុសត្រូវបោះពុម្ព**
Eric Hidalgo Valverde
ABSOLUTO S.A.
ejhidalgo@yahoo.com

**បោះពុម្ពដោយ**
Masterlitho S.A.
San José, Costa Rica. Marzo, 2009.

GGCA ដឹកនាំដោយគណៈកម្មការដឹកនាំមួយដែលចូលរួមដោយ UNDP, IUCN, UNEP & WEDO និងមានសមាជិកជាង ២៥រូប មកពីភ្នាក់ងារសហប្រជាជាតិ និងអង្គការសង្គមស៊ីវិល និងដៃគូរបស់ GGCA ដែលមកពីរដ្ឋាភិបាល មូលនិធិ និងស្ថាប័នវិស័យឯកជន។

# ឯកសារបណ្តុះបណ្តាលស្តីពី យេនឌ័រ និង

# ការប្រែប្រួលអាកាសធាតុ

IUCN UNDP GGCA
Global Gender and Climate Alliance

# សេចក្តីផ្តើម

អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដែលគេសន្មតថា ឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ និងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយឥទ្ធិពលទាំងនេះមានផលប៉ះពាល់ប្រហាក់ប្រហែលគ្នាទាំងស្ត្រី និងបុរស។ ទោះបីយ៉ាងណាក៏ដោយ ពិភពលោកកាន់តែទទួលស្គាល់ច្រើនឡើងថា ស្ត្រី និងបុរសជួបប្រទះបទពិសោធន៍ពីការប្រែប្រួលអាកាសធាតុខុសគ្នា ហើយ វិសមភាពយេនឌ័របានធ្វើឱ្យសមត្ថភាពរបស់ស្ត្រីក្នុងការដោះស្រាយបញ្ហាកាន់តែពិបាក។ គេក៏បានទទួលស្គាល់ផងដែរ ថា ស្ត្រីគឺជាតួអង្គសំខាន់នៃការផ្លាស់ប្តូរ មានចំណេះដឹង និងជំនាញគួរឱ្យកត់សំគាល់ទាក់ទងនឹងការបន្សុាំ និងការកាត់បន្ថយហានិភ័យនៅចំពោះមុខនៃការប្រែប្រួលអាកាសធាតុ ដែលធ្វើឱ្យពួកគេជាភ្នាក់ងារសំខាន់នៅក្នុងផ្នែកនេះ។ ហេតុដូច្នេះហើយ បានជាមានតម្រូវការបន្ទាន់មួយដើម្បីទទួលយកនូវវិធីសាស្ត្រដែលឆ្លើយតបនឹងយេនឌ័រចំពោះកម្មវិធីនិងការធ្វើគោលនយោបាយការប្រែប្រួលអាកាសធាតុ។

ការផ្សាភ្ជាប់ការប្រែប្រួលអាកាសធាតុទៅនឹងការអភិវឌ្ឍមនុស្សនៅតែជាបញ្ហាប្រឈមដ៏សំខាន់មួយ ពីព្រោះការប្រែប្រួលអាកាសធាតុត្រូវបានគេគិតជាបញ្ហាបច្ចេកទេសឬវិទ្យាសាស្ត្រសុទ្ធសាធ។ ការបោះពុម្ពនេះ គឺធ្វើឡើងដើម្បីឆ្លើយតបទៅនិងតម្រូវការរបស់អ្នកធ្វើគោលនយោបាយ និងអ្នកវិទ្យាសាស្ត្រផ្នែកប្រែប្រួលអាកាសធាតុឱ្យយល់ដឹង និងដោះស្រាយបានប្រសើរឡើងនូវភាពសំខាន់យេនឌ័រទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។

យើងខ្ញុំមានក្តីសោមនស្សរីករាយ សូមណែនាំនូវឯកសារបណ្តុះបណ្តាល សម្ព័ន្ធភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ជាឧបករណ៍អនុវត្តជាក់ស្តែងមួយដើម្បីបង្កើនសមត្ថភាពអ្នកធ្វើគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត ដើម្បីរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រដែលឆ្លើយតបនឹងយេនឌ័រ។ នៅក្នុងកាលៈទេសៈចាំបាច់នេះ នៅលើវិថីនៃការចរចាយុទ្ធសាស្ត្រនៃការប្រែប្រួលអាកាសធាតុអន្តរជាតិ ការបោះពុម្ពនេះផ្តល់ភាគីពាក់ព័ន្ធនានានូវចំណេះដឹងសំខាន់ៗ និងគោលការណ៍ណែនាំច្បាស់លាស់អំពី ថាតើសកម្មភាពនានារបស់ពួកគេទាក់ទងនឹងការប្រែប្រួលអាកាសធាតុ អាចឆ្លើយតបកាន់តែប្រសើរឡើងបែបណាចំពោះតម្រូវការរបស់ស្ត្រី និងបុរសនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។



**Julia Marton-Lefèvre**
Director General
IUCN (International Union for Conservation of Nature)



**Winnie Byanyima**
Director, Gender Team
UNDP (United Nations Development Program)

# បុព្វកថា

ការប្រែប្រួលអាកាសធាតុ គឺជាការគំរាមកំហែងធ្ងន់ធ្ងរមួយដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងធ្វើឱ្យអន្តរាយដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ប្រសិនបើមិនយកចិត្តទុកដាក់បញ្ហានេះពុំបានស៊ីជម្រៅ។ ការរួមគ្នាកាត់បន្ថយការប្រែប្រួលអាកាសធាតុ គឺផ្សាភ្ជាប់ដោយផ្ទាល់នឹងការកាត់បន្ថយភាពក្រីក្រ។ ដូច្នេះវាមានសារៈសំខាន់ណាស់ ដែលត្រូវសម្រេចនូវកិច្ចព្រមព្រៀងថ្មីទូលំទូលាយមួយស្តីពីការប្រែប្រួលអាកាសធាតុ មុនចុងឆ្នាំ ២០០៩។

វិធានការសំខាន់បំផុតសម្រាប់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ គឺការបង្កើនការប្រើប្រាស់ថាមពលដែលកកើតឡើងវិញ និងការដាំដុះព្រៃឈើ ក៏ដូចជាការបញ្ឈប់អត្រាបាត់បង់ព្រៃឈើ។ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុមានឥទ្ធិពលលើវិស័យកសិកម្ម សន្តិសុខស្បៀង និងការគ្រប់គ្រងទឹកនៅតំបន់ជនបទ។ ការបង្កើតឡើងវិញនូវកសិកម្មធម្មជាតិអាចជាឧបករណ៍កាត់បន្ថយដ៏ល្អមួយ។ ការប្រកបរបរចិញ្ចឹមជីវិតទាំងនេះភាគច្រើន គឺជាការងារប្រពៃណីរបស់ស្ត្រីនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ ឧទាហរណ៍ នៅអាហ្វ្រិក ៨០ភាគរយនៃផលិតកម្មអាហារត្រូវបានគ្រប់គ្រងដោយស្ត្រី។

ការវិភាគរបស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុបង្ហាញថា ឥទ្ធិពលជាច្រើននឹងប៉ះពាល់ខ្លាំងលើតំបន់ក្រីក្របំផុត និងជនងាយរងគ្រោះ ដែលបាននិងកំពុងជួបប្រទះផលប៉ះពាល់នៃការប្រែប្រួល ដូចជាការកើនឡើងនូវភាពរាំងស្ងួត ទឹកជំនន់ ឬព្យុះជាដើម។ ៧០ភាគរយនៃជនងាយរងគ្រោះជាស្ត្រី។

នេះមានន័យថា ស្ត្រីក្រីក្រ នឹងត្រូវពុះពារជាមួយនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ ទោះបីយ៉ាងណា ពួកគេក៏អាចជាភ្នាក់ងារដែលមានថាមពលខ្លាំងចំពោះការផ្លាស់ប្តូរផងដែរ។ ការផ្តល់ភាពអង់អាចដល់ស្ត្រីនៅក្នុងការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេចចិត្ត ក៏ដូចជាវិធានការអនុវត្តដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដែលធ្វើឱ្យកិច្ចប្រឹងប្រែងរួមរបស់យើងកាន់តែមានប្រសិទ្ធភាពខ្ពស់ ជាពិសេសនៅថ្នាក់មូលដ្ឋាន។

ដូច្នេះស្ត្រី និងបុរសត្រូវយល់ដឹងអំពីដំណើរការនៃការប្រែប្រួលអាកាសធាតុ បញ្ហាទាំងអស់នេះ តម្រូវឱ្យស្ត្រី និងបុរសចែករំលែកព័ត៌មានអំពីឥទ្ធិពលអវិជ្ជមានដែលបាននិងកំពុងជួបប្រទះ។ វិធានការអនុវត្តទាំងនេះ តម្រូវឱ្យស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាក្នុងការទទួលបានចំណេះដឹង ធនធាន និងបច្ចេកទេស ដែលចាំបាច់ដើម្បីទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។ ការចូលរួមរបស់ស្ត្រីយ៉ាងសកម្មក្នុងការគាំទ្រស្វែងរកមតិ ដែលស្ត្រីចូលរួមសកម្មថែមទៀតនៅក្នុងស្វែងរកការគាំទ្រមតិ ដើម្បីឆ្លើយតប និងបរិបទសមស្រប និងការប្រែប្រួលអាកាសធាតុមានសារៈសំខាន់ណាស់។

ប្រទេសហ្វាំងឡង់ មានក្តីសោមនស្សរីករាយក្នុងកិច្ចសហការ ប្រតិបត្តិការ និងគាំទ្រជាមួយនឹងសម្ព័ន្ធភាព អាកាសធាតុ និងយេនឌ័រសកល និងគាំទ្រការងារនៅក្នុងការផ្តល់ភាពអង់អាចដល់ស្ត្រី ចូលដោះស្រាយបញ្ហាដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ឯកសារនេះ គឺជាធាតុដ៏សំខាន់មួយក្នុងការលើកកម្ពស់ការយល់ដឹងផលប៉ះពាល់អំពីការប្រែប្រួលអាកាសធាតុ និងទស្សនទានយេនឌ័រ។ យើងសង្ឃឹមថា ការកើនឡើងនូវការយល់ដឹងនេះ នឹងពង្រឹងកិច្ចសហប្រតិបត្តិការរួមទាំងអ្នកពាក់ព័ន្ធផ្សេងដូចជារដ្ឋាភិបាល អង្គការអន្តរជាតិ ស្ថាប័នហិរញ្ញវត្ថុ សង្គមស៊ីវិល និងវិស័យឯកជន។

**Aira Kalela**

តំណាងពិសេស យេនឌ័រ និងការប្រែប្រួលអាកាសធាតុ

ក្រសួងការបរទេស ហ្វាំងឡង់

FORMIN.FINLAND.FI

MINISTRY FOR FOREIGN AFFAIRS OF FINLAND

# អារម្ភកថា

ការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យកសិកម្ម និងធនធានទឹក មានសារៈសំខាន់ក្នុងការលើកកម្ពស់ ជីវភាពរស់នៅរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច និងបង្កើនភាពស្មើគ្នា ដោយពង្រឹងសិទ្ធិស្ត្រីតាមរយៈការផ្តល់ភាពអង់អាចរបស់ស្ត្រី។

នៅក្នុងខែមីនា ឆ្នាំ២០១៤ ក្រសួងកិច្ចការនារីបានធ្វើលិខិតទៅកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ស្នើសុំការប្រែសម្រួលនិងបោះពុម្ពឯកសារបណ្តុះបណ្តាលស្តីពី "**យេនឌ័រ និងការប្រែប្រួលអាកាសធាតុ**" ពីភាសាអង់គ្លេសមកជាភាសាខ្មែរ។

ដោយមានជំនួយឧបត្ថម្ភពីមូលនិធិបរិស្ថានពិភពលោក ( GEF ) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ( UNDP ) ក្រសួងកិច្ចការនារីបានសហការជាមួយក្រុមការងារនៃអង្គភាពគាំទ្រគម្រោង NAPA-FOLLOW UP នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបានសម្របសម្រួលការបកប្រែឯកសារនេះ សម្រាប់ប្រើប្រាស់ជាឯកសារយោងក្នុងការរៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងប្រើប្រាស់ជាឯកសារបណ្តុះបណ្តាលនៅថ្នាក់ក្រោមជាតិផងដែរ។

តាងនាមឱ្យក្រសួងកិច្ចការនារី ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារបញ្ជ្រាបយេនឌ័រ និងការប្រែប្រួលអាកាសធាតុនៃក្រសួងកិច្ចការនារី ក្រុមការងារនៃអង្គភាពគាំទ្រគម្រោង NAPA-FOLLOW UP នៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទក្នុងការរៀបចំការងារនេះ ឱ្យចេញជាស្ថាពរ និងសូមអរគុណដល់ម្ចាស់ជំនួយមានជាអាទិ៍ មូនិធិបរិស្ថានពិភពលោក (GEF), UNDP និងរដ្ឋាភិបាលកាណាដាដែលបានផ្តល់ថវិកាក្នុងការប្រែសម្រួល និងបោះពុម្ពផ្សព្វផ្សាយនូវឯកសារនេះជាភាសាខ្មែរ។

ភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

អ៊ុំ កន្ថាផាវី

សម្របសម្រួលការបកប្រែជាភាសាខ្មែរ និងត្រួតពិនិត្យ
ក្រសួងកិច្ចការនារី និងមានការចូលរួមពីក្រុមការងារអង្គភាពគាំទ្រគម្រោង ក្រសួងកសិកម្ម រុក្ខាប្រមាញ់
និងនេសាទ។

## សម្រាប់ព័ត៌មានបន្ថែម

**ក្រសួងកិច្ចការនារី**
**លោកជំទាវ ស៊ីវណ្ណ បុទុម**
រដ្ឋលេខាធិការទទួលបន្ទុក និងជាប្រធានក្រុមការងារបញ្ជ្រាបយេនឌ័រ
និងការប្រែប្រួលអាកាសធាតុ
ផ្លូវទ្រុងមាន់ ភូមិដំណាក់៣ សង្កាត់ស្ទឹងមានជ័យ
ខណ្ឌមានជ័យ ភ្នំពេញ
ទូរស័ព្ទ៖ +៨៥៥ (០)២៣ ៨៨២០៤៧/+៨៥៥ (០)៨១ ៨២៨៣០៤
អ៊ីម៉ែល៖ sivann_botum@yahoo.com

**អង្គភាពគាំទ្រគម្រោងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF PSU)**
**លោក ហុក គឹមធួន**
ប្រធានគម្រោងថ្នាក់ជាតិ
អគារលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ +៨៥៥ (០)២៣ ២២១ ១២០
អ៊ីម៉ែល៖ kimthourn@gmail.com

ឧបត្ថម្ភការបោះពុម្ពលើកទី១ចំនួន ៣០០ច្បាប់ ដោយគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់លើកកម្ពស់
ការគ្រប់គ្រងធនធានទឹក និងការប្រកបរបរកសិកម្ម ជំហាន២
បោះពុម្ពផ្សាយឆ្នាំ២០១៥

CANADA-UNDP
Climate Change Adaptation Facility

*Empowered lives.*
*Resilient nations.*

# មាតិកា

ពាក្យបំព្រួញ ........ ១
ការណែនាំ ........ ៥
ជំពូក ១៖ យេនឌ័រ និងការបញ្ជ្រាបយេនឌ័រ ........ ១១
១.១ តើអ្វីជាយេនឌ័រ? ........ ១១
១.២ តើអ្វីជាការបញ្ជ្រាបយេនឌ័រ? ........ ១៤
១.៣ លក្ខណៈពិសេសរបស់ស្ត្រី ........ ១៥
ឯកសារស្រាវជ្រាវ ........ ១៦
កិច្ចការសម្រាប់ជំពូកនេះ ........ ១៧
កំណត់ត្រាសម្រាប់អ្នកសម្របសម្រួល ........ ១៨
ករណីសិក្សា ........ ១៩
ករណីសិក្សាទី១៖ ការធ្វើផែនការកសិកម្មប្រកបដោយចីរភាពរបស់ស្ត្រី ........ ១៩
ករណីសិក្សាទី២៖ ផែនការសកម្មភាពយេនឌ័រនៃកម្មវិធីបរិស្ថានសហប្រជាជាតិ ........ ២១
ករណីសិក្សាទី៣៖ ផែនការសកម្មភាពយេនឌ័រនៃអនុសញ្ញាស្តីពីជីវចម្រុះ ........ ២៣
ឧបករណ៍ និងវិធីសាស្ត្រ ........ ២៥
ជំពូក ២៖ លិខិតតូបករណ៍ច្បាប់អន្តរជាតិនានា ជាយន្តការសម្រាប់ការបញ្ជ្រាបយេនឌ័រ នៅក្នុងការប្រែប្រួលអាកាសធាតុ ........ ៣៩
២.១ សិទ្ធិមនុស្សជាចំណុចចាប់ផ្តើម ........ ៤១
២.១.១ អនុសញ្ញាស្តីពីការទប់ស្កាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ CEDAW) ........ ៤១
២.១.២ យេនឌ័រ និងសេចក្តីថ្លែងការណ៍សហប្រជាជាតិស្តីពីជនជាតិដើមភាគតិច ........ ៤៤
២.២ សមភាពយេនឌ័រ ........ ៤៥
២.៣ ការកាត់បន្ថយគ្រោះមហន្តរាយ ........ ៤៦
២.៤ យេនឌ័រ និងការអភិវឌ្ឍប្រកបដោយចីរភាព ........ ៤៨
២.៤.១ របៀបវារៈ២១ ........ ៤៨
២.៤.២ ការអនុវត្តផែនការនៃសន្និសីទកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ........ ៤៩
២.៤.៣ សេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំងនិងវេទិកាសកម្មភាព និងទីក្រុងប៉េកាំង+១០ ........ ៤៩
២.៤.៤ សេចក្តីថ្លែងការណ៍សហស្សវត្សរ៍និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ........ ៥០
២.៤.៥ អនុសញ្ញាទីក្រុងរីយ៉ូ ........ ៥១
២.៥ ការជាប់ទាក់ទងគ្នានៃគោលនយោបាយ ........ ៥៧

ឯកសារស្រាវជ្រាវ ..... ៥៩
កំណត់ត្រាសម្រាប់អ្នកសម្របសម្រួល ..... ៦០
កិច្ចការសម្រាប់ជំពូកនេះ ..... ៦១
ឧបករណ៍ និងវិធីសាស្ត្រ ..... ៧១

**ជំពូក ៣៖ ទិដ្ឋភាពទូទៅនៃបញ្ហាយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ..... ៧៣**
៣.១ មូលហេតុនៃភាពងាយរងគ្រោះ ឬ ស្ថានភាពជាក់លាក់ដែលធ្វើឱ្យស្ត្រី ជាពិសេស ស្ត្រីក្រីក្រ ងាយរងគ្រោះទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ..... ៧៤
៣.២ ការបន្ថែមនូវគ្រោះថ្នាក់ដល់សុខុមាលភាព ..... ៧៥
៣.៣ សមភាពយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍៖ តើមានការពាក់ព័ន្ធគ្នាយ៉ាងដូចម្តេច? ..... ៧៧
ឯកសារស្រាវជ្រាវ ..... ៨២
កិច្ចការសម្រាប់ជំពូកនេះ ..... ៨៣
ករណីសិក្សា ..... ៨៤
ករណីសិក្សាទី១៖ ក្រុម ម៉ាម៉ា វ៉ាតូ ..... ៨៤
ករណីសិក្សាទី២៖ ចំណេះដឹងស្តីពីលទ្ធិប្រជាធិបតេយ្យសម្រាប់ផ្តល់ភាពអង់អាចដល់ថ្នាក់មូលដ្ឋាន ..... ៨៥
ករណីសិក្សាទី៣៖ ការរំលេចនូវយុទ្ធសាស្ត្រត្រូវទៅនឹងគ្រោះរាំងស្ងួត ឧបករណ៍គ្រីស្ទាល៖ ឧបករណ៍នៃការជ្រើសរើសហានិភ័យដោយផ្អែកលើសហគមន៍ ជីវភាពរស់នៅ និងការបន្សាំ ..... ៨៧
ឧបករណ៍ និងវិធីសាស្ត្រ ..... ៩០

**ជំពូក ៤៖ ការបញ្ជ្រាបយេនឌ័រនៅក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើការបន្សាំ ..... ៩៧**
៤.១ ការបន្សាំរបស់មនុស្សទៅនិងការប្រែប្រួលអាកាសធាតុ ..... ៩៧
៤.២ វិសមភាពយេនឌ័រពាក់ព័ន្ធជាមួយហានិភ័យ និងភាពងាយរងគ្រោះ ..... ៩៨
៤.២.១ កត្តាផ្សេងៗដែលជះឥទ្ធិពលឱ្យមានហានិភ័យផ្សេងៗទៅលើស្ត្រីនៅក្នុងគ្រោះមហន្តរាយ ..... ៩៩
៤.២.២ ភាពងាយរងគ្រោះ និងសមត្ថភាព ..... ១០១
៤.២.៣ ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ..... ១០២
៤.៣ តួនាទីរបស់ស្ត្រីនៅក្នុងការបន្សាំការប្រែប្រួលអាកាសធាតុ ..... ១០៧
៤.៣.១ ស្ត្រី និងបុរស ក្នុងនាមជាភ្នាក់ងារនៃការផ្លាស់ប្តូរ ..... ១០៧
៤.៣.២ ទំនាក់ទំនងខុសៗគ្នារវាងស្ត្រី និងបុរសទៅនឹងបញ្ហាបរិស្ថាន ..... ១០៧
៤.៣.៣ តួនាទីរបស់ស្ត្រីនៅក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និង ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ..... ១០៨
៤.៣.៤ ការគ្រប់គ្រងហានិភ័យ និងការផ្តល់ភាពអង់អាចដល់ស្ត្រី ..... ១០៩
៤.៤ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការទទួលបានធនធានដោយស្មើភាព ..... ១១០
៤.៤.១ ទឹក និងអនាម័យ ..... ១១១
៤.៤.២ ជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ..... ១១១

៤.៤.៣ កសិកម្ម និងសន្តិសុខស្បៀង ១១២
៤.៤.៤ តំបន់ឆ្នេរ ១១៣
៤.៤.៥ ការប្រែក្លាយទៅជាវាលខ្សាច់ ១១៣
៤.៤.៦ សុខភាព ១១៤
៤.៤.៧ ផលប៉ះពាល់អវិជ្ជមាននៃការផ្តួចផ្តើមបន្សាំទៅលើវិសមភាពយេនឌ័រ និងដំណោះស្រាយដែលអាចមាន ១១៤
៤.៥ ការធ្វើផែនការជាតិដែលគិតគូរពីយេនឌ័រ ១១៩
៤.៥.១ កម្មវិធីសកម្មភាពជាតិបន្សាំនិងការប្រែប្រួលអាកាសធាតុ (NAPA) ១១៩
៤.៥.២ ផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ១២០
ឯកសារស្រាវជ្រាវ ១២២
កិច្ចការសម្រាប់ជំពូកនេះ ១២៣
ករណីសិក្សាផ្សេងៗ ១២៤
ករណីសិក្សាទី១៖ ស្ត្រីជាអ្នកដឹកនាំនៅក្នុងភាពជន់របស់សហគមន៍ក្នុងទ្វីបអាហ្វ្រិក ១២៤
ករណីសិក្សាទី២៖ តួនាទីយេនឌ័រនៅក្នុងគ្រោះមហន្តរាយនៅក្នុងប្រទេសនានា លើកោះជាប់មហាសមុទ្រប៉ាស៊ីហ្វិក ១២៦
ករណីសិក្សាទី៣៖ យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ៖ ដកស្រង់ចេញពីបទពិសោធន៍កសិករឥណ្ឌា ១២៨
ករណីសិក្សាទី៤៖ ផលប៉ះពាល់នៃគ្រោះថ្នាក់ទៅលើស្ត្រីនិងកុមារ៖ ស្ថានភាពនៅក្នុងអាស៊ីខាងត្បូង ១៣០
ករណីសិក្សាទី៥៖ ស្ត្រីនឹងកសាងម៉ាយអាមីឡើងវិញ៖ ករណីសិក្សារបស់ក្រុមស្ត្រីនិយមដែលឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ១៣១
ឧបករណ៍ និងបច្ចេកទេស ១៣២
**ជំពូក ៥៖ ប្រសិនបើមានពេល ចូរធ្វើការប្រៀបធៀបករណីសិក្សាផ្សេងៗ និង ទាញយកនូវគោលការណ៍វិភាគយេនឌ័រទូទៅ ១៣៦**
៥.១ យេនឌ័រ និងកិច្ចប្រឹងប្រែងក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ៖ ការបង្កើតការទំនាក់ទំនង ១៣៧
៥.១.១ ការចាប់ ការបំពេញ ឬការញែកយកកាបូន ១៤០
៥.១.២. ការកាត់បន្ថយការបំភាយឧស្ម័នតាមរយៈប្រភពថាមពលស្អាត និងបច្ចេកវិទ្យា ១៤៤
៥.១.៣ ការកាត់បន្ថយការបំភាយឧស្ម័ន៖ ការជាប់ទាក់ទងជាមួយយេនឌ័រ ១៤៦
៥.១.៤ ការប្រើប្រាស់៖ បញ្ហាយេនឌ័រ ១៤៨
ឯកសារស្រាវជ្រាវ ១៤៩
កិច្ចការសម្រាប់ជំពូកនេះ ១៥០
ករណីសិក្សា ១៥១
ករណីសិក្សាទី១៖ ការផលិតជីវៈឥន្ធនៈនៅតំបន់ជនបទនៃប្រទេសឥណ្ឌា ១៥១
ករណីសិក្សាទី២៖ ដើមឈើរាប់ពាន់លានដើមសម្រាប់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ១៥៣
ករណីសិក្សាទី៣៖ គម្រោងជីវឧស្ម័នថ្នាក់ជាតិនៃប្រទេសណេប៉ាល់៖ កាត់បន្ថយការបំភាយឧស្ម័នខណៈពេល ដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍ ១៥៥

ឧបករណ៍ និងបច្ចេកទេស ..... ១៥៦

**ជំពូក ៦៖ យុទ្ធសាស្ត្រនៃការយល់ដឹងពីយេនឌ័រទៅលើការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យាដើម្បីគាំទ្រ ដល់សកម្មភាពនៃការកាត់បន្ថយគ្រោះមហន្តរាយនិងភាពបន្សាំ ..... ១៦១**

៦.១ តើបច្ចេកវិទ្យាមានន័យដូចម្ដេច? ..... ១៦១

៦.២ តើបច្ចេកវិទ្យាមានទំនាក់ទំនងអ្វីខ្លះជាមួយនឹងការប្រែប្រួលអាកាសធាតុ? ..... ១៦២

៦.៣ តើបច្ចេកវិទ្យាសម្រាប់ការប្រែប្រួលអាកាសធាតុមានទំនាក់ទំនងអ្វីនឹងយេនឌ័រ? ..... ១៦៤

៦.៤ តំបន់ដែលត្រូវយកចិត្តទុកដាក់សម្រាប់អន្តរាគមន៍នៃបច្ចេកវិទ្យា ..... ១៦៤

៦.៤.១ តម្រូវការបច្ចេកវិទ្យានិងការប៉ាន់ប្រមាណតម្រូវការ ..... ១៦៥

៦.៤.២ ព័ត៌មានអំពីបច្ចេកវិទ្យា ..... ១៦៦

៦.៤.៣ ការជួយដល់បរិស្ថានសម្រាប់ទទួលយកការផ្ទេរបច្ចេកវិទ្យា ..... ១៦៦

៦.៤.៤ ការកសាងសមត្ថភាពសម្រាប់ការផ្ទេរបច្ចេកវិទ្យា ..... ១៦៦

៦.៤.៤ យន្តការសម្រាប់ការផ្ទេរបច្ចេកវិទ្យា ..... ១៦៧

៦.៥ បច្ចេកវិទ្យាកាត់បន្ថយគ្រោះមហន្តរាយ៖ ទិដ្ឋភាពយេនឌ័រ ..... ១៦៧

៦.៦ បច្ចេកវិទ្យាសម្រាប់ការបន្សាំខ្លួន៖ ទិដ្ឋភាពយេនឌ័រ ..... ១៦៩

ឯកសារស្រាវជ្រាវ ..... ១៧១

ករណីសិក្សា ..... ១៧២

ករណីសិក្សាទី ១៖ ការប្រែប្រួលអាកាសធាតុនិងសមភាពយេនឌ័រនៅប្រទេសចិន ..... ១៧២

ករណីសិក្សាទី ២៖ ភាពងាយរងគ្រោះរបស់ស្ត្រីនៅក្នុងសហគមន៍ជនបទនៅកឺ មូស្សា (Keur Moussa) ..... ១៧៣

ករណីសិក្សាទី ៣៖ ការផ្ដល់ពន្លឺនៃក្ដីសង្ឃឹមក្នុងសហគមន៍នៅប្រទេសនីការ៉ាហ្គា ..... ១៧៥

ឧបករណ៍ និងបច្ចេកទេស ..... ១៧៧

**ជំពូក ៧៖ ការបញ្ជ្រាបយេនឌ័រនៅក្នុងយន្តការហិរញ្ញប្បទាននៃការប្រែប្រួលអាកាសធាតុ ..... ១៨១**

៧.១ តើការផ្ដល់ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុគឺជាអ្វី? ..... ១៨១

៧.២ តើការផ្ដល់ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ មានទំនាក់ទំនងដូចម្ដេចជាមួយយេនឌ័រ? ..... ១៨២

៧.៣ តើការផ្ដល់ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុមានឧបករណ៍ យន្តការ និងគំរូបែបបទអ្វីខ្លះ? ..... ១៨៥

៧.៤ ប្រព័ន្ធដោយផ្អែកលើទីផ្សារ និងវិស័យឯកជនសម្រាប់ផ្ដល់ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ ..... ១៨៩

៧.៥ បញ្ហាសង្គម អភិវឌ្ឍ និងយេនឌ័រ និងតួនាទីរដ្ឋក្នុងការធ្វើហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ..... ១៩២

៧.៦ យេនឌ័រ និងតួនាទីរដ្ឋក្នុងការធ្វើហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ ..... ១៩៥

៧.៧ យេនឌ័រ និងរបបហិរញ្ញប្បទានប្រែប្រួលអាកាសធាតុក្រោយឆ្នាំ ២០១២ ..... ១៩៨

កិច្ចការសម្រាប់ជំពូកនេះ ..... ២០១

ករណីសិក្សា ..... ២០២

ករណីសិក្សាទី១៖ ស្ត្រី Amihan និងផលប៉ះពាល់នៃការផ្ដល់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ..... ២០២

ឧបករណ៍ និងបច្ចេកទេស ..... ២០៥

**ឧបសម្ព័ន្ធ ១៖ ឯកសារយោងបន្ថែម ..... ២០៩**

# ពាក្យបំព្រួញ

| | | |
|---|---|---|
| ABC | Atmospheric brown clouds | ពពកប្រផេះក្នុងបរិយាកាស |
| AF | Adaptation Fund | មូលនិធិបន្ស៊ាំ |
| AFB | Adaptation Fund Board | ក្រុមប្រឹក្សាមូលនិធិបន្ស៊ាំ |
| C5 | Canada-China Cooperation in Climate Change | កិច្ចសហប្រតិបត្តិការកាណាដា-ចិនស្តីពីការប្រែប្រួលអាកាសធាតុ |
| CBD | Convention on Biological Diversity | អនុសញ្ញាស្តីពីជីវៈចម្រុះ |
| CCBA | Climate, Community & Biodiversity Alliance | សម្ព័ន្ធភាពអាកាសធាតុ សហគមន៍ និងជីវៈចម្រុះ |
| CCCDF | Canada Climate Change Development Fund | មូលនិធិអភិវឌ្ឍការប្រែប្រួលអាកាសធាតុកាណាដា |
| CCFE | The Chicago Climate Futures Exchange | ទីផ្សារអនាគតសម្រាប់អាកាសធាតុឈីកាកូ |
| CCX | Chicago Climate Exchange | កម្មវិធីផ្លាស់ប្តូរអាកាសធាតុឈីកាកូទីផ្សារសម្រាប់អាកាសធាតុឈីកាកូ |
| CDM | Clean Development Mechanism | យន្តការអភិវឌ្ឍស្អាត |
| CEDAW | Convention on the Elimination of All Forms of Discrimination against Women | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ( ស៊ី-ដ ) |
| CEIF | Clean Energy for Development and Investment Framework | ថាមពលស្អាតសម្រាប់ក្របខ័ណ្ឌអភិវឌ្ឍ និងការវិនិយោគ |
| CER | Certified Emission Reduction | ការកាត់បន្ថយឧស្ម័នដែលបានបញ្ជាក់ |
| CIDA | Canadian International Development Agency | ទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិកាណាដា |
| CIF | Climate Investment Fund | មូលនិធិវិនិយោគអាកាសធាតុ |
| CII | Confederation of Indian Industry | សហព័ន្ធឧស្សាហកម្មឥណ្ឌា |
| COP | Conference of the Parties | សន្និសីទភាគី សន្និសីទបណ្តាភាគី |
| CO2 | Carbon Dioxide | ឧស្ម័នកាបូន |
| CPF | Carbon Partnership Facility | មូលនិធិភាពជាដៃគូកាបូន |
| CRiSTAL | Community-based risk screening tool – adaptation and livelihoods | ឧបករណ៍ពិនិត្យជ្រើសរើសផ្អែកលើសហគមន៍សម្រាប់បន្ស៊ាំ និងការចិញ្ចឹមជីវិត |
| CSD | United Nations Commission on Sustainable Development | គណៈកម្មការសហប្រជាជាតិស្តីពីការអភិវឌ្ឍ ដោយចីរភាព |
| CSW | Commission on the Status of Women | គណៈកម្មការស្តីពីស្ថានភាពស្ត្រី |
| CTF | Clean Technology Fund | មូលនិធិបច្ចេកវិទ្យាស្អាត |
| DAW | Division for the Advancement of Women | នាយកដ្ឋានលើកកម្ពស់ស្ត្រី |
| DECRIPS | United Nations Declaration on the Rights of Indigenous Peoples | ប្រកាសសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច |
| DFID | United Kingdom Department for International Development | នាយកដ្ឋានសម្រាប់ការអភិវឌ្ឍអន្តរជាតិនៃចក្រភពអង់គ្លេស |
| DRR | Disaster Risk Reduction | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |

| | | |
|---|---|---|
| **DSAP** | Development Sustainable Agriculture in the Pacific | ការអភិវឌ្ឍ កសិកម្មដោយចីរភាពនៅតំបន់ប៉ាស៊ីហ្វិក |
| **ECOSOC** | United Nations Economic and Social Council | ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ |
| **ECX** | European Climate Exchange | ការប្រែប្រួលអាកាសធាតុនៅអឺរ៉ុប |
| **ELIAMEP** | Hellenic Foundation for European and Foreign Policy | មូលនិធិហេឡែនសម្រាប់គោលនយោបាយការបរទេស និងអឺរ៉ុប |
| **ENERGIA** | International Network on Gender and Sustainable Energy | បណ្តាញអន្តរជាតិស្តីពីយេនឌ័រ និងថាមពលដោយចីរភាព |
| **ENDA PRONAT** | Environment and Development Action in the Third World | សកម្មភាពអភិវឌ្ឍ និងបរិស្ថាននៅក្នុងតតីលោក |
| **ERPA** | Emissions Reduction Purchase Agree-ment | កិច្ចព្រមព្រៀងទិញការកាត់បន្ថយការបញ្ចេញឧស្ម័ន |
| **EUA** | European Allowance | ឥណទានកាបូន ( សម្រាប់សហគមន៍អឺរ៉ុប ) |
| **FAO** | United Nations Food and Agriculture Organization | អង្គការស្បៀង និងកសិកម្មសហប្រជាជាតិ |
| **FCPF** | Forest Carbon Partnership Facility | កម្មវិធីភាពជាដៃគូសម្រាប់កាបូនដែលបំភាយចេញពីព្រៃឈើ |
| **GDI** | Gender-related Development Index | សន្ទស្សន៍អភិវឌ្ឍទាក់ទងនឹងយេនឌ័រ |
| **GEF** | Global Environment Facility | មូលនិធិបរិស្ថានពិភពលោក |
| **GEF-SGP** | Global Environment Facility Small Grants Programme | កម្មវិធីជំនួយខ្នាតតូចនៃមូលនិធិបរិស្ថានពិភពលោក |
| **GEO** | Global Environment Outlook | ទស្សនទានបរិស្ថានពិភពលោក |
| **Genanet** | Gender, Environment and Sustainabili-ty Network | បណ្តាញយេនឌ័រ បរិស្ថាន និងនិរន្តរភាព |
| **GGCA** | Global Gender Climate Alliance | សម្ព័ន្ធភាពយេនឌ័រ និងអាកាសធាតុពិភពលោក |
| **GHG** | Greenhouse gas | ឧស្ម័នផ្ទះកញ្ចក់ |
| **GRATIS** | Ghana Regional Appropriate Technology Industrial Service | សេវាឧស្សាហកម្មបច្ចេកវិទ្យាសមស្របថ្នាក់តំបន់របស់ ហ្គាណា |
| **GTC** | Giga Tonnes of Carbon | ជីហ្គាតោននៃកាបូន |
| **GTZ** | German Technical Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃប្រទេសអាល្លឺម៉ង់ |
| **HFA** | Hyogo Framework for Action | ក្របខ័ណ្ឌសកម្មភាពយូហ្គោ |
| **HDR** | Human Development Report | របាយការណ៍អភិវឌ្ឍមនុស្ស |
| **ICRAF** | International Centre for Research in Agroforestry | មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការស្រាវជ្រាវកសិ-រុក្ខកម្ម |
| **IEI** | International Energy Initiative | កម្មវិធីថាមពលអន្តរជាតិ |
| **IFAD** | International Fund for Agricultural Development | មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម |
| **ILO** | International Labour Organization | អង្គការពលកម្មអន្តរជាតិ |
| **INCD** | Intergovernmental Negotiating Committee on Desertification | គណៈកម្មការចរចាអន្តររដ្ឋាភិបាលស្តីពីរហោស្ថានកម្ម |
| **INSTRAW** | UN International Research and Training Institute for the Advancement of Women | វិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលអន្តរជាតិសម្រាប់លើកកម្ពស់ស្ត្រី |

| | | |
|---|---|---|
| **Intercoop-eration** | Swiss Foundation for International Development and Cooperation | មូលនិធិស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ |
| **IPCC** | Intergovernmental Panel on Climate Change | ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| **ISDR** | International Strategy for Disaster Reduction | យុទ្ធសាស្ត្រអន្តរជាតិសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ |
| **IUCN** | International Union for the Conservation of Nature | អង្គការអន្តរជាតិដើម្បីការអភិវឌ្ឍ ការអភិរក្សធម្មជាតិ |
| **IWRM** | Integrated Water Resources Manage-ment | ការគ្រប់គ្រងធនធានទឹកចម្រុះ |
| **JI** | Joint Implementation | ការអនុវត្តរួមគ្នា |
| **JLG** | Joint Liaison Group | ក្រុមទំនាក់ទំនងរួមគ្នា |
| **LDC** | Least Developed Countries | ប្រទេសអភិវឌ្ឍតិចតួច |
| **LDCF** | Least Developed Country Fund | មូលនិធិប្រទេសអភិវឌ្ឍតិចតួច |
| **LED** | Liechtenstein Development Service | សេវាអភិវឌ្ឍលៀចតេនស្ទេន |
| **LULUCF** | Land Use, Land Use Change and Forestry | ការប្រើប្រាស់ដី ការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ |
| **MCeX** | The Montreal Climate Exchange | កម្មវិធីផ្លាស់ប្តូរអាកាសធាតុម៉ុងរ៉េអាល់ |
| **MDG** | Millennium Development Goals | គោលដៅអភិវឌ្ឍសហស្សវត្សរ៍ |
| **MEA** | Multilateral Environment Agreements | កិច្ចព្រមព្រៀងបរិស្ថានពហុភាគី |
| **NAP** | National Action Programmes | កម្មវិធីសកម្មភាពជាតិ |
| **NAPA** | National Adaptation Programmes of Action | កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| **NBSAP** | National Biodiversity Strategy and Action Plan | យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ |
| **NSC** | National Steering Committee | គណៈកម្មការគ្រប់គ្រងកម្មវិធីថ្នាក់ជាតិ |
| **NTFPs** | Non-timber forest products | អនុផលព្រៃឈើ |
| **OECD** | Organization for Economic Co-operation and Development | អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ |
| **Oxfam** | Oxford Committee for Famine Relief | គណៈកម្មការអ៊ុកហ្វឺត សម្រាប់ការសង្គ្រោះភាពអត់ឃ្លាន |
| **PES** | Payments for environmental services | ការបង់ថវិកាសម្រាប់សេវាបរិស្ថាន |
| **ppm** | Parts per million | ភាគលាន |
| **PRA** | Participatory Rural Approach | វិធីសាស្ត្រជនបទដោយមានការចូលរួម |
| **REDD** | Reducing Emissions from Deforestation and Forest Degradation | ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់និងរេចរឹលព្រៃឈើ |
| **RGGI** | Regional Greenhouse Gas Initiative | កម្មវិធីផ្តួចផ្តើមឧស្ម័នផ្ទះកញ្ចក់ថ្នាក់តំបន់ |
| **SAGEN** | South African Gender and Energy Network | បណ្តាញយេនឌ័រ និងថាមពលអាហ្វ្រិកខាងត្បូង |
| **SCCF** | Special Climate Change Fund | មូលនិធិពិសេសសម្រាប់ការប្រែប្រួលអាកាសធាតុ |
| **SCF** | Strategic Climate Fund | មូលនិធិអាកាសធាតុជាយុទ្ធសាស្ត្រ |
| **SDC** | Swiss Agency for Development Cooperation | ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍស្វីស |

| | | |
|---|---|---|
| SIDS | Small Island Developing States | បណ្តារដ្ឋកំពុងអភិវឌ្ឍនៃកោះតូចៗ |
| SPA | Strategic Priority on Adaptation | អាទិភាពយុទ្ធសាស្ត្របន្សាំ |
| SPC | Secretariat of the Pacific Community | លេខាធិការដ្ឋានសហគមន៍ប៉ាស៊ីហ្វិក |
| TCX | The Tianjin Climate Exchange | កម្មវិធីផ្លាស់ប្តូរអាកាសធាតុធានជីន |
| UN-HABI-TAT | UN Human Settlements Programme | កម្មវិធីតាំងលំនៅរបស់មនុស្សនៃអង្គការសហប្រជាជាតិ |
| UNCCD | United Nations Convention to Combat Desertification | អនុសញ្ញាសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងវហោស្ថានកម្ម |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNEP | United Nations Environment Programme | កម្មវិធីបរិស្ថានសហប្រជាជាតិ |
| UNESCO | United Nations Educational, Scientific and Cultural Organization | អង្គការសហប្រជាជាតិទទួលបន្ទុកអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ |
| UNFCCC | United Nations Framework Convention on Climate Change | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| UNFPA | United Nations Population Fund | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន |
| UNHCR | United Nations High Commissioner for Refugees | ឧត្តមស្នងការអង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន |
| UNIFEM | United Nations Development Fund for Women | មូលនិធិអភិវឌ្ឍសហប្រជាជាតិសម្រាប់ស្ត្រី |
| USAID | United States Agency for International Development | ទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិសហរដ្ឋអាមេរិក |
| WECF | Women in Europe for a Common Future | ស្ត្រីក្នុងអឺរ៉ុបដើម្បីអនាគតរួមគ្នា |
| WEDO | Women's Environment and Develop-ment Organization | អង្គការអភិវឌ្ឍ និងបរិស្ថានស្ត្រី |
| WEN | Environment Network | បណ្តាញការងារបរិស្ថាន |
| WG ABS | Working Group on Access and Benefit Sharing | ក្រុមការងារស្តីពីការទទួលបាន និងចែករំលែកអត្ថប្រយោជន៍ |
| WG RI | Ad Hoc Open-ended Working Group on Review of Implementation of the CBD | ក្រុមការងារបណ្តោះអាសន្នសម្រាប់ការពិនិត្យតាមដានការអនុវត្តអនុសញ្ញាស្តីពីជីវៈចម្រុះ |
| WHO | World Health Organization | អង្គការសុខភាពពិភពលោក |
| WRI | World Resources Institute | វិទ្យាស្ថានធនធានពិភពលោក |
| WSSD | World Summit on Sustainable Development | ជំនួបកំពូលពិភពលោកស្តីពីការអភិវឌ្ឍ ប្រកបដោយចីរភាព |

# ការណែនាំ



នៅខែវិច្ឆិកា ឆ្នាំ២០០៧ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) សហភាពអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ (IUCN) កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ (UNEP) និងអង្គការអភិវឌ្ឍនិងបរិស្ថានស្ត្រី (WEDO) បានចូលរួមកិច្ចប្រជុំ នៅទីក្រុងតេប៉ូលែន នៃប្រទេសមិចសិចកូ ដើម្បីពិភាក្សាអំពីប្រធានបទ «យេនឌ័រ និងការប្រែប្រួលអាកាសធាតុ»។ នៅអំឡុងពេលកិច្ចប្រជុំអង្គការទាំងនេះបានទទួលស្គាល់ពីតម្រូវការយុទ្ធសាស្ត្រសម្របសម្រួលក្នុងចំណោមស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយនូវប្រធានបទខាងលើ។ជាលទ្ធផលកិច្ចប្រជុំបានបង្កើតនូវសម្ព័ន្ធភាពយេនឌ័រនិងអាកាសធាតុពិភពលោក ដែលបានចាប់ផ្តើមដំណើរការក្នុងសន្និសីទស្តីពីការប្រែប្រួលអាកាសធាតុកាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៧ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី។ បច្ចុប្បន្ននេះ មានស្ថាប័នរបស់អង្គការសហប្រជាជាតិ និងសង្គមស៊ីវិលអន្តរជាតិចំនួន២៥ បានចូលរួមក្នុងសម្ព័ន្ធភាពនេះ។ គោលបំណងចម្បងនៃសម្ព័ន្ធភាពយេនឌ័រ និងអាកាសធាតុពិភពលោក គឺដើម្បីធានាថា គោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុ ការធ្វើការសម្រេចចិត្ត និងគំនិតផ្តួចផ្តើមផ្សេងៗនៅលើសកលលោក ទាំងកម្រិត តំបន់ និងកម្រិតជាតិមានការឆ្លើយតបនឹងយេនឌ័រ។

បច្ចុប្បន្ននេះ អ្នកធ្វើសេចក្តីសម្រេច ដែលពាក់ព័ន្ធនឹងការងារស្តីពីការប្រែប្រួលអាកាសធាតុ ការរៀបចំកម្មវិធី និងការធ្វើគោលនយោបាយផ្សេងៗបានសារភាពថា ពួកគេមិនបានដឹង និងមិនមានចំណេះដឹងគ្រប់គ្រាន់ពីទំនាក់ទំនងរវាងសមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។ ជាទូទៅ គេសង្កេតឃើញថា ឧបសគ្គដំបូងដែលស្ថាប័ន ឬរដ្ឋាភិបាលជួបប្រទះដើម្បីដោះស្រាយនូវវិសមភាពយេនឌ័រ គឺការនៅជាប់ដោយឡែកពីគេ និងកង្វះខាតនូវបទពិសោធន៍។ ឧទាហរណ៍ការអង្កេតរបស់អង្គការសហប្រជាជាតិនៅឆ្នាំ២០០៦ បានបង្ហាញថា ភាគច្រើនក្រសួងបរិស្ថានរបស់រដ្ឋាភិបាលនីមួយៗមានកង្វះខាតផ្នែកសមត្ថភាព និងការយល់ដឹងពី «យេនឌ័រ និងបរិស្ថាន» ជាពិសេសនោះគឺ «យេនឌ័រ និងការប្រែប្រួលអាកាសធាតុ» ដែលជាមូលហេតុធ្វើឱ្យមានការពិបាកបញ្ជ្រាបយេនឌ័រ។

ជាទូទៅ ក្នុងចំណោមស្ថាប័នផ្នែកបរិស្ថាន និងអភិវឌ្ឍន៍ និងក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ តម្រូវឱ្យមានការអភិវឌ្ឍចំណេះដឹងស្តីពីទំនាក់ទំនងរវាងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ជាពិសេសការប្រើប្រាស់ភាសាបច្ចេកទេសសម្រាប់អ្នកធ្វើគោលនយោបាយ និងអ្នកវិទ្យាសាស្ត្រ។ បរិបទយេនឌ័រ និងការប្រែប្រួលអាកាសធាតុ មានវឌ្ឍនភាពអាស្រ័យលើកិច្ចសហការ និងការសហប្រតិបត្តិការក្នុងចំណោមស្ថាប័ននិងវិស័យពាក់ព័ន្ធផ្សេងៗទៀត ព្រមទាំងការបង្កើនសមត្ថភាព និងការប្តេជ្ញាចិត្តផ្នែកនយោបាយក្នុងចំណោមអ្នកធ្វើគោលនយោបាយ ក្រុមអង្គការសហប្រជាជាតិ សង្គមស៊ីវិល និងក្រុមសកម្មជនស្ត្រី។

ដូច្នេះ គោលបំណងសំខាន់នៃយុទ្ធសាស្ត្ររបស់សម្ព័ន្ធភាពយេនឌ័រ និងអាកាសធាតុពិភពលោក (GGCA) គឺការកសាងសមត្ថភាពនៅក្នុងសកលលោក ទាំងកម្រិតតំបន់ និងកម្រិតសហគមន៍ ក្នុងការធ្វើគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនៃការប្រែប្រួលអាកាសធាតុឆ្លើយតបនឹងយេនឌ័រ។

ដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍសមត្ថភាពស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងការកសាងអ្នកបណ្តុះបណ្តាលបន្តនៅក្នុងតំបន់ និងប្រទេសជាសមាជិកសម្ព័ន្ធភាពយេនឌ័រនិងអាកាសធាតុពិភពលោក GGCA បានបង្កើតឯកសារ

មេរៀនបណ្តុះបណ្តាលស្តីពី «យេនឌ័រ និងការប្រែប្រួលអាកាសធាតុ»។ ទស្សនទានដែលបានបង្ហាញនៅក្នុងឯកសារមេរៀននេះ គឺដើម្បីបង្កើនសមត្ថភាពអ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកធ្វើគោលនយោបាយលើកិច្ចខិតខំប្រឹងប្រែងនៃការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុឱ្យមានការឆ្លើយតបនឹងយេនឌ័រ។

ឯកសារបណ្តុះបណ្តាលនេះ បានមកពីការប្រមូលផ្តុំការវិភាគទិន្នន័យស្រាវជ្រាវ និងពីក្របខណ្ឌការងារអន្តរជាតិផ្សេងៗដែលបានបន្សាំ និងដាក់បញ្ចូលនូវករណីសិក្សាថ្មីៗសម្រាប់បង្ហាញនូវទស្សនទាននៅក្នុងជំពូកនីមួយៗ។ ឯកសារនេះបង្ហាញនូវទស្សនទានសំខាន់ៗ និងវិធីសាស្ត្រកម្រិតខ្ពស់ដែលពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។ ប្រធានបទនីមួយៗនៅក្នុងឯកសារនេះ គឺពាក់ព័ន្ធនឹងផែនការសកម្មភាពនៅបាលី។

## របៀបប្រើប្រាស់ឯកសារនេះ៖

ឯកសារនេះចែកចេញជាជំពូកៗ អ្នកសម្របសម្រួលអាចជ្រើសរើសប្រធានបទ និងលំហាត់ទៅតាមក្រុមគោលដៅ និងរយៈពេលនៃការបង្រៀន។ ឯកសារនេះមាន ៧ជំពូក៖

**ជំពូក១៖** យេនឌ័រ និងការបញ្ជ្រាបយេនឌ័រ

**ជំពូក២៖** ឧបករណ៍ច្បាប់អន្តរជាតិដែលជាក្របខណ្ឌបញ្ជ្រាបយេនឌ័រនៅក្នុងការប្រែប្រួលអាកាសធាតុ។

**ជំពូក៣៖** ទស្សនៈទូទៅនៃបញ្ហាយេនឌ័រ និងការប្រែប្រួលអាកាសធាតុ

**ជំពូក៤៖** ការបញ្ជ្រាបយេនឌ័រនៅក្នុងការបន្សាំការប្រែប្រួលអាកាសធាតុ

**ជំពូក៥៖** យុទ្ធសាស្ត្រឆ្លើយតបនឹងយេនឌ័រសម្រាប់កាត់បន្ថយការប្រែប្រួលអាកាសធាតុ

**ជំពូក៦៖** យុទ្ធសាស្ត្រឆ្លើយតបនឹងយេនឌ័រចំពោះកិច្ចអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យាក្នុងការគាំទ្រដល់សកម្មភាពបន្សាំនឹងការកាត់បន្ថយ

**ជំពូក៧៖** ការបញ្ជ្រាបយេនឌ័រក្នុងយន្តការហិរញ្ញវត្ថុនៃការប្រែប្រួលអាកាសធាតុ

**ឧបសម្ព័ន្ធ៖** ការពន្យល់ពីប្រវត្តិឯកសារ

នៅក្នុងជំពូកនីមួយៗមាន៖ ការពិពណ៌នា និងការវិភាគប្រធានបទនីមួយៗ ការសង្ខេបគោលបំណងមេរៀន និងការអនុវត្តលំហាត់ ការពន្យល់ពីសកម្មភាព ដំណើរការបង្រៀន និងការកំណត់ពេលវេលា ព្រមទាំងមានឯកសារ និងលំហាត់សម្រាប់អនុវត្ត។

នៅចុងបញ្ចប់ជំពូកនីមួយៗ អ្នកនឹងទទួលបាននូវឯកសារបន្ថែមដូចជាឯកសារយោង និងឧបសម្ព័ន្ធជាមួយនឹងការពន្យល់នូវប្រភពឯកសារថ្មីៗដែលពាក់ព័ន្ធនឹងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។

## កំណត់ចំណាំសម្រាប់អ្នកសម្របសម្រួល

អ្នកពាក់ព័ន្ធផ្សេងៗ ដែលមានទំនាក់ទំនង និងវគ្គបណ្តុះបណ្តាលដូចជា៖

- អ្នកតំណាងមកពីក្រសួងបរិស្ថាន
- អ្នកតំណាងមកពីក្រសួងរ៉ែ និងថាមពល
- អ្នកតំណាងមកពីគណៈកម្មាធិការកាត់បន្ថយគ្រោះមហន្តរាយ
- អ្នកតំណាងមកពីក្រសួងផ្សេងៗដូចជា កសិកម្ម ហិរញ្ញវត្ថុ ។ល។
- ក្រសួងកិច្ចការនារី
- សមាជិកសភា
- អ្នកស្រាវជ្រាវ និងអ្នកសិក្សា
- ស្ថាប័នអង្គការសហប្រជាជាតិ
- អង្គការសង្គមស៊ីវិល
- ក្រុមស្ត្រី

អ្នកតំណាងទាំងអស់នេះអនុវត្តនូវសកម្មភាពខុសៗគ្នា ហើយក៏ផ្តល់នូវលទ្ធផលបណ្តុះបណ្តាលផ្សេងគ្នាផងដែរ។ ដើម្បីធ្វើឱ្យវគ្គបណ្តុះបណ្តាល «យេនឌ័រ និងការប្រែប្រួលអាកាសធាតុ» ទទួលបានជោគជ័យ អ្នកគួរតែអនុវត្តនូវជំហានទាំង១០ ដូចតទៅ៖

### ១.ក្រុមគោលដៅ

ដំបូងអ្នកត្រូវកំណត់ក្រុមគោលដៅ។ វគ្គបណ្តុះបណ្តាលមានលក្ខណៈខុសគ្នាទៅតាមប្រភេទក្រុមគោលដៅ។ ឧទាហរណ៍ ខ្លឹមសារនៃការបណ្តុះបណ្តាលរវាងសមាជិកក្រុមសកម្មជនស្ត្រីដែលមិនមានចំណេះដឹងពីការប្រែប្រួលអាកាសធាតុ ក្រុមមន្ត្រីមកពីក្រសួងបរិស្ថានដែលមិនមានទស្សនទានអំពីយេនឌ័រ។ អ្នកចូលរួមអាចជាមន្ត្រីរាជរដ្ឋាភិបាលធ្វើការនៅក្រសួងបរិស្ថាន ដែលមិនធ្លាប់ឮពីទស្សនទានយេនឌ័រ ឬឧបករណ៍វិភាគយេនឌ័រ។ ប្រសិនបើចំណេះដឹងនៃក្រុមគោលដៅមានភាពខុសគ្នាខ្លាំង មិនគួរដាក់ពួកគេនៅក្នុងថ្នាក់តែមួយទេ ទោះបីអ្នកបង្រៀនពួកគេនូវប្រធានបទខុសគ្នាៗក៏ដោយ ពីព្រោះអ្នកចូលរួមខ្លះមិនចាប់អារម្មណ៍នឹងប្រធានបទទាំងនោះទេ។

ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីខ្លះវគ្គបណ្តុះបណ្តាលអាចក្លាយជាវេទិកាសម្រាប់ផ្លាស់ប្តូរនូវចំណេះដឹង (ឧទាហរណ៍ រវាងអ្នកជំនាញការយេនឌ័រ និងអ្នកជំនាញការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសរបស់អ្នក) ហើយនៅខណៈនេះ អ្នកគួរដើរតួជាអ្នកសម្របសម្រួលនៃដំណើរការចែករំលែកបទពិសោធន៍ប្រសើរជាជាងអ្នកសម្របសម្រួល។ អ្នកក៏គួរគិតពិចារណាអំពី៖ ភេទ អាយុ ឋានៈក្នុងសង្គមរបស់អ្នកចូលរួម។ ឧទាហរណ៍ អ្នកខ្លះមានអារម្មណ៍មិននឹងនរនៅពេល

ដែលមានវត្តមានប្រធានរបស់ពួកគេចូលរួមយ៉ាងសកម្មនៅក្នុងវគ្គបណ្តុះបណ្តាលជាមួយគ្នា។ ភាពប្រហាក់ប្រហែលគ្នានេះដែរ វប្បធម៌ខ្លះអ្នកចូលរួមមានអារម្មណ៍ស្រួល ឬល្អនៅពេលដែលមានការបែងចែករវាងក្រុមស្ត្រី និងក្រុមបុរសព្រោះពួកគេមានឱកាសអាចនិយាយដោយសេរី។

## ២. ការវាយតម្លៃវគ្គបណ្តុះបណ្តាល

ពេលដែលអ្នកកំណត់ក្រុមគោលដៅសម្រាប់បណ្តុះបណ្តាលបានហើយ អ្នកនឹងទទួលបាននូវអ្វីដែលជាតម្រូវការសំខាន់របស់អ្នកចូលរួម ព្រមទាំងដឹងអំពីអ្វីដែលពួកគេចេះដឹងខ្លះហើយ។ អ្វីដែលពួកគេចង់ដឹងគឺអាស្រ័យលើតួនាទីរបស់ពួកគេនៅក្នុងស្ថាប័ន ឬកន្លែងការងារ ហើយវាមានសារៈសំខាន់ណាស់សម្រាប់អ្នកមុន និងអ្នករៀបចំវគ្គបណ្តុះបណ្តាល។ មធ្យោបាយដែលអាចដឹងពីតម្រូវការចំណេះដឹងរបស់អ្នកចូលរួម គឺការរៀបចំកម្រងសំនួរដែលអ្នកឱ្យពួកគេបំពេញមុនពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាល។

## ៣. គោលបំណងនៃវគ្គបណ្តុះបណ្តាល

ផ្អែកតាមការវាយតម្លៃតម្រូវការវគ្គបណ្តុះបណ្តាល អ្នកត្រូវតែកំណត់នូវគោលបំណងជាក់លាក់នៃវគ្គបណ្តុះបណ្តាល។ វគ្គបណ្តុះបណ្តាលខ្លះ អាចគ្រាន់តែចង់ឱ្យអ្នកចូលរួមយល់ដឹង និងបង្កើនការយល់ដឹង ប្រសិនបើទស្សនទានយេនឌ័រ និងការប្រែប្រួលអាកាសធាតុថ្មី។ ម្យ៉ាងវិញទៀត ប្រសិនបើអ្នកចូលរួមមានចំណេះដឹងខ្លះៗ ដូច្នេះ គោលបំណងនៃមេរៀនអាចឱ្យអ្នកចូលរួមកំណត់នូវដំណើរការ និងលក្ខខណ្ឌសម្រាប់វាស់វែង។ ឧទាហរណ៍ យេនឌ័រត្រូវគេគិតពិចារណានៅក្នុងយន្តការហិរញ្ញវត្ថុ។ អ្នកសម្របសម្រួលក៏ត្រូវការកំណត់ផងដែរ ថាតើសិក្ខាកាមនឹងទទួលបានព័ត៌មាន ឬសារបានក្នុងកម្រិតណា ព្រោះវាធ្វើឱ្យមានភាពងាយស្រួលក្នុងការផ្តល់សារសម្រាប់ពួកគេក្នុងអំឡុងពេលដែលសម្របសម្រួល។

## ៤. ការកំណត់ទំហំ និងរយៈពេលនៃវគ្គបណ្តុះបណ្តាល

អាស្រ័យលើក្រុមគោលដៅ និងគោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ អ្នកត្រូវតែកំណត់ទំហំថ្នាក់រៀន និងរយៈពេលរៀន។ គួរចងចាំថា អ្នកធ្វើសេចក្តីសម្រេចចិត្តខ្លះអាចចូលរួមបានតែផ្នែកសង្ខេបប៉ុណ្ណោះ ហើយអ្នកចូលរួមខ្លះទៀតមានការរវល់នៅក្នុងខែខ្លះនៃឆ្នាំ (ចុងឆ្នាំរវល់ច្រើន)។ ហេតុដូច្នេះ អ្នកត្រូវតែប្រាកដថាអ្នកផ្ទេរព័ត៌មានសំខាន់ៗតាមលក្ខខណ្ឌ និងពេលវេលាសមស្របដោយប្រើប្រាស់វិធីសាស្ត្រ និងបច្ចេកទេសឱ្យបានល្អ។

## ៥. ជ្រើសរើសប្រធានបទដែលពាក់ព័ន្ធយកមកសម្របសម្រួល

ប្រធានបទដែលត្រូវយកមកសម្របសម្រួល អាស្រ័យលើលទ្ធផលនៃការវាយតម្លៃតម្រូវការវគ្គបណ្តុះបណ្តាល គោលបំណង និងទំហំនៃវគ្គបណ្តុះបណ្តាល។ កុំព្យាយាមដាក់ប្រធានបទច្រើននៅក្នុងវគ្គបណ្តុះបណ្តាល ឬអំឡុងពេលសម្របសម្រួល។ អ្នកចូលរួមត្រូវតែមានពេលវេលាគ្រប់គ្រាន់ក្នុងការពិភាក្សាប្រធានបទ និងអនុវត្តលំហាត់។ ករណីអ្នកចង់យកប្រធានបទដែលអ្នកមិនសូវច្បាស់មកសម្របសម្រួល ឧទាហរណ៍ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេស អ្នកគួរតែពិចារណាអញ្ជើញអ្នកជំនាញការផ្នែកនេះមកធ្វើបទបង្ហាញខណៈពេលសម្របសម្រួលមេរៀននេះ ឬសហការជាមួយសហការីរបស់អ្នកដែលមានចំណេះដឹងផ្នែកនេះមកជួយអ្នក។

## ៦. ការកំណត់នូវលំដាប់មេរៀន

នៅពេលដែលអ្នកពង្រាងនូវកម្មវិធី អ្នកត្រូវតែគិតពិចារណាពីលំដាប់នៃប្រធានបទមេរៀនដែលអ្នកចង់បង្ហាញដល់អ្នកចូលរួម។ នៅពេលបង្រៀន ប្រធានបទត្រូវតែមានភាពសហការ ហើយអ្នកត្រូវតែបញ្ចេញសម្លេងឱ្យខ្លាំងហើយច្បាស់ ជាពិសេសការរំកិលពីប្រធានបទមួយទៅប្រធានបទមួយទៀតដែលមានការស្មុគស្មាញ។

## ៧. ការជ្រើសរើសវិធីសាស្រ្តសម្របសម្រួល និងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ

មានវិធីសាស្រ្តសម្របសម្រួល ជាច្រើនដែលត្រូវបានគេប្រើប្រាស់នៅក្នុងជំពូកនីមួយៗ។ អ្នកសម្របសម្រួលគួរតែយកចិត្តទុកដាក់អំពីរយៈពេលនៃបទបង្ហាញ ឬទំហំនៃក្រុមពិភាក្សា។ គួរតែចងចាំថា ការរៀនរបស់មនុស្សម្នាក់ៗមានភាពខុសប្លែកគ្នា។ អ្នកគួរតែប្រើប្រាស់វិធីសាស្រ្តសម្របសម្រួល តាមរយៈពេលនៃវគ្គបណ្តុះបណ្តាលអនុញ្ញាតឱ្យដូចជា៖

- បទបង្ហាញដោយអ្នកសម្របសម្រួល (បទបង្ហាញដោយប្រើ Power Point ស្លាយសម្រាប់បញ្ចាំង។ល។)
- ឯកសារសម្រាប់អាន
- ក្រុមពិភាក្សា
- លំហាត់អនុវត្ត
- ករណីសិក្សា
- ការសំដែងរឿង
- ពិភាក្សាក្រុមតូច ដែលមានរយៈពេលខ្លី
- បទបង្ហាញដោយតំណាងក្រុមពិភាក្សា
- វាគ្មិនកិត្តិយស(អ្នកជំនាញមកចែករំលែកបទពិសោធន៍)
- ខ្សែវីដេអូ

វិធីសាស្រ្តនេះ មានសារៈសំខាន់ដោយហេតុផលផ្សេងៗគ្នា។ ឧទាហរណ៍៖ ក្រុមពិភាក្សា ធ្វើឱ្យអ្នកចូលរួមយល់ដឹងច្បាស់លាស់ពីអ្វីដែលគេពិភាក្សាខណៈពេលដែលធ្វើបទបង្ហាញ និងឯកសារសម្រាប់បង្កើនចំណេះដឹង។ លំហាត់អនុវត្ត ករណីសិក្សា និងការសម្តែងរឿងដែលតម្រូវឱ្យអ្នកចូលរួមធ្វើជាតួសំដែង ព្រមទាំងអាចឱ្យពួកគេអនុវត្តនូវចំណេះដឹងដែលទើបទទួលបានថ្មី ក៏ប៉ុន្តែត្រូវការពេលវេលាច្រើនសម្រាប់ធ្វើ ។ ទោះបីជាមានរយៈពេល១ថ្ងៃក្នុងការបណ្តុះបណ្តាលក៏ដោយ គួរតែរៀបចំលំហាត់អនុវត្ត ១ ឬ ២ ដើម្បីឱ្យអ្នកចូលរួមយកចិត្តទុកដាក់ចំពោះវគ្គបណ្តុះបណ្តាល។ អ្នកអាចពិចារណាយកការពិភាក្សាដែលមានភាពជាក់ស្តែងនៅក្នុងការរស់នៅដើម្បីឆ្លុះបញ្ចាំងពីតថភាពរបស់វគ្គបណ្តុះបណ្តាល។

វាមានសារៈសំខាន់ផងដែរ ដែលអ្នកគួរតែពិចារណា ថាតើនរណាជាអ្នកផ្តល់នូវសារដល់អ្នកចូលរួម។ អ្នកចូលរួមដែលជាអ្នកធ្វើសេចក្តីសម្រេចចិត្តប្រហែលជាចាប់អារម្មណ៍លើអ្នកផ្តល់សារ(អ្នកសម្របសម្រួល)នៅក្នុងវគ្គបណ្តុះបណ្តាលដោយអ្នកជំនាញការល្បីៗ ឬអ្នកមានបទពិសោធន៍ការងារច្រើន។ ឧទាហរណ៍ អ្នកចូលរួមប្រភេទនេះប្រហែលចង់បានអ្នកធ្វើបទបង្ហាញដែលជាអតីតនាយករដ្ឋមន្ត្រី ឬអ្នកទទួលបានពានរង្វាន់ណូបែល។

## ៨. ការតាក់តែងលំហាត់អនុវត្ត

ឯកសារនេះផ្តល់នូវលំហាត់អនុវត្តផ្សេងៗគ្នាជាច្រើន ដែលអ្នកប្រហែលជាចង់ប្រើប្រាស់នៅក្នុងវគ្គបណ្តុះបណ្តាលស្តីពី «យេនឌ័រ និងការប្រែប្រួលអាកាសធាតុ»។ ទោះបីជាយ៉ាងក៏ដោយ លំហាត់ទាំងនោះគ្រាន់តែជាគំនិតសម្រាប់អ្នកប៉ុណ្ណោះ។ អ្នកអាចផ្លាស់ប្តូរខ្លះដើម្បីឱ្យស្របទៅតាមតម្រូវការរបស់អ្នក ឬក៏បង្កើតថ្មីតែម្តង។

## ៩. រៀបចំ ឯកសារ និងសម្ភារៈសម្រាប់អាន

អ្នកអាចស្វែងរកឯកសារនៅក្នុងសៀវភៅមេរៀននេះ និងធ្វើការចែកចាយដល់អ្នកចូលរួម។ អ្នកប្រហែលជាចង់យកឯកសារផ្សេងទៀតដែលមានប្រយោជន៍ទាក់ទងនឹង «យេនឌ័រ និងការប្រែប្រួលអាកាសធាតុ» និងករណីសិក្សាពីប្រទេសផ្សេងទៀត ដែលអាចទទួលបានពីគេហទំព័រផ្សេងៗ។ នៅចុងបញ្ចប់នៃឯកសារមេរៀននេះ អ្នកនឹងអាចស្វែងរកឧបសម្ព័ន្ធដោយមានការពន្យល់ពីជីវប្រវត្តិឯកសារ ដែលជាឯកសារសម្រាប់អានបន្ថែម ព្រមទាំងគេហទំព័រដែលមានប្រយោជន៍ជាច្រើនទៀត។ ព័ត៌មានដែលទាក់ទងនឹងបរិបទដែលអ្នកចូលរួមអនុវត្តនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួនដែលអាចជាការអនុវត្តជាក់ស្តែងនៅក្នុងសហគមន៍ប្រទេស ឬតំបន់ដែលជួយដល់វគ្គបណ្តុះបណ្តាលរបស់អ្នក។

## ១០. ការវាយតម្លៃ

នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលនីមួយៗ អ្នកគួរស្នើឱ្យអ្នកចូលរួមវាយតម្លៃវគ្គបណ្តុះបណ្តាល។ វិធីសាស្ត្រនៃការវាយតម្លៃមានភាពខុសគ្នាអាស្រ័យលើរយៈពេលនៃវគ្គបណ្តុះបណ្តាល។ ប្រសិនបើអ្នកចង់ធ្វើរយៈពេលខ្លី (១ថ្ងៃ) អ្នកគួរតែស្នើឱ្យអ្នកចូលរួមយកក្រដាសពណ៌ចំនួន២សន្លឹកមកសរសេរ។ ក្រដាសពណ៌មួយសម្រាប់អ្វីដែលអ្នកចូលរួមបានរៀន និងមួយទៀតសម្រាប់អ្វីដែលអ្នកចូលរួមចង់ដឹងបន្ថែមទៀត ឬក៏មិនយល់។ បន្ទាប់ពីបណ្តុះបណ្តាលមួយរយៈអ្នកប្រហែលជាមានបទពិសោធន៍ក្នុងការចែកចាយនូវបញ្ជីសំនួរសម្រាប់អ្នកចូលរួមបំពេញ។

យើងគួរតែធ្វើបច្ចុប្បន្នកម្មឯកសារបង្រៀននេះ។ ហេតុដូច្នេះ យើងទទួលស្វាគមន៍មតិស្ថាបនា ប្រសិនបើអ្នកមានបំណងចង់ចែករំលែកបទពិសោធន៍ក្នុងការប្រើប្រាស់ឯកសារមេរៀននេះ ឬឯកសារព័ត៌មានផ្សេងទៀតដែលមានប្រយោជន៍ សូមអ៊ីម៉ែលមក info@gender-climate.org។

# ជំពូក ១

# យេនឌ័រ និងការបញ្ជ្រាបយេនឌ័រ

*វិសមភាពយេនឌ័រ ទូលំទូលាយជាងវិសមភាពដទៃផ្សេងទៀត។ វិសមភាពនេះ ជ្រួតជ្រាបក្នុងទម្រង់វិសមភាពផ្សេងទៀតដែលបង្ហាញនូវលក្ខណៈក្រុមមនុស្សរវាងអ្នកមាន អ្នកក្រ។ វិសមភាពយេនឌ័រ គឺពាក់ព័ន្ធទៅនឹងភាពខ្វះខាតខាងសេដ្ឋកិច្ច ដែលនាំឱ្យភាពក្រីក្រ កាន់តែមានខ្លាំងឡើងចំពោះស្ត្រីច្រើនជាងបុរស។ វិសមភាពយេនឌ័រ ជាផ្នែកមួយនៃដំណើរការបង្កើតភាពក្រីក្រដែលចាក់ឫសគល់នៅក្នុងសង្គម។ ដូច្នេះហើយបញ្ហានេះ ត្រូវតែក្លាយជាផ្នែកមួយនៃវិធានការលុបបំបាត់ភាពក្រីក្រ* ( Kabeer, 2003 ) ។

## សារសំខាន់ៗ

- “ភេទ” និង “យេនឌ័រ” មិនដូចគ្នាទេ៖ ការយល់ដឹងពីសារៈសំខាន់នៃភាពខុសគ្នា
- វិសមភាពយេនឌ័រនៃការពិតបង្ហាញព័ត៌មានការពិតជាក់ស្តែង
- ស្វែងយល់អំពីឧទាហរណ៍ការគ្រប់គ្រងទ្រព្យសម្បត្តិ
- ការបញ្ជ្រាបយេនឌ័រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ
- ការបញ្ចូលបញ្ហាយេនឌ័រក្នុងការធ្វើផែនការ និងការអនុវត្តគោលនយោបាយប្រែប្រួលអាកាសធាតុ
- យេនឌ័រក៏បានបង្ហាញលើវិសមភាពដទៃទៀត ឧទាហរណ៍ វណ្ណៈ ជាតិ សាសន៍។

### ១.១ តើអ្វីជាយេនឌ័រ ?

យេនឌ័រ គឺសំដៅយកតួនាទី ឥរិយាបថ និងគុណតម្លៃនានាដែលវប្បធម៌ និងសង្គមដាក់កំណត់ឱ្យស្ត្រី និងបុរសអនុវត្តដោយឡែកពីគ្នា។ តួនាទីឥរិយាបថ និងគុណតម្លៃទាំងនេះកំណត់នូវអាកប្បកិរិយា និងទំនាក់ទនងរវាងស្ត្រី និងបុរស។ តួនាទីឥរិយាបថ និងគុណតម្លៃទាំងនេះត្រូវបានបង្កើតឡើង និងថែរក្សាដោយស្ថាប័នសង្គមនានាដូចជាគ្រួសាររដ្ឋាភិបាល សហគមន៍ សាលារៀន វត្តអារាម និងសារព័ត៌មាន។ យេនឌ័របានកំណត់អំពីតួនាទី និងលក្ខណៈសំគាល់មួយចំនួនផ្សេងពីគ្នា និងតឹងរឹងសម្រាប់ស្ត្រី និងបុរស។ យេនឌ័រអាចកែប្រែបាន តែភេទមិនអាចកែប្រែបានទេ។

ឥឡូវនេះសព្វ យេនឌ័រត្រូវបានបំលែងន័យដំបូងរបស់វាដែលប្រើប្រាស់ក្នុងវេយ្យាករណ៍សម្រាប់បញ្ជាក់នាមថាជាបុំលិង្គ (ភេទប្រុស) ឥត្ថីលិង្គ (ភេទស្រី) នបុំសកលិង្គ(អភេទ) ឱ្យទៅជាន័យថ្មី។ សង្គមវិទូប្រើពាក្យនេះសំដៅយកតួនាទីរបស់ស្ត្រី និងបុរស ឥរិយាបថគុណតម្លៃដែលសង្គមបានកំណត់ ហើយដែលសហគមន៍ និងសង្គមអះអាងថាសមស្របសម្រាប់ភេទនីមួយៗ។ (ឯកសារនេះដកស្រង់ពីសទ្ទានុក្រមយេនឌ័រខែសីហា ឆ្នាំ២០០៦)។



## ប្រអប់១ ភាពខុសគ្នានៃយេនឌ័រ

យោងតាមទិន្នន័យដែលអាចជឿទុកចិត្តបានបង្ហាញថាប្រមាណ ៧០% នៃអ្នកដែលមានកម្រិតជីវភាពរស់នៅក្រោមមួយដុល្លារក្នុងមួយថ្ងៃ គឺជាស្ត្រី។

ស្ត្រីធ្វើការ ២/៣ នៃម៉ោងការងាររបស់ពិភពលោក ប៉ុន្តែទទួលបានត្រឹមតែ ១០% នៃចំណូលរបស់ពិភពលោកប៉ុណ្ណោះ។

ស្ត្រីគ្រប់គ្រងត្រឹមតែ ១% ប៉ុណ្ណោះនៃអចលនទ្រព្យពិភពលោក។

ស្ត្រីជាសមាជិកសភាពិភពលោកមានប្រមាណ ១៧% ប៉ុណ្ណោះនៃចំនួនអសនៈទាំងអស់។

ស្ត្រីមានតួនាទីជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាលនៃគណៈរដ្ឋភិបាលទូទាំងពិភពលោក។ ស្ត្រីមានតួនាទីជាន់ខ្ពស់ក្នុងជួររាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមាន១៣ភាគរយ (ស្ថិតិយេនឌ័រសំខាន់ៗក្នុងប្រទេសកម្ពុជាគិតត្រឹមខែមករា ឆ្នាំ២០១៤) ទូទាំងពិភពលោកមានត្រឹមតែ ៨% ប៉ុណ្ណោះ។

៧៥% នៃមនុស្សពេញវ័យចំនួន ៨៧៦លាននាក់នៅក្នុងពិភពលោកដែលមិនចេះអក្សរ គឺជាស្ត្រី។

ទូទាំងពិភពលោក ស្ត្រីទទួលបានត្រឹមតែ ៧៨% ប៉ុណ្ណោះនៃប្រាក់ឈ្នួលដែលបុរសទទួលបានចំពោះការងារដូចគ្នា។ បើទោះជានៅតំបន់មួយចំនួន ស្ត្រីមានការអប់រំខ្ពស់ជាងបុរសក៏ដោយ។ ផ្នែកខ្លះនៃពិភពលោក គម្លាតប្រាក់ឈ្នួលរវាងស្ត្រី និងបុរស គឺក្បែរនឹង ៤០%។

នៅក្នុងចំណោមកម្មករ ៥៥០លាននាក់ទូទាំងពិភពលោកដែលមានប្រាក់កម្រៃទាប ស្ត្រីមានចំនួនរហូតដល់ ៣៣០លាននាក់ ស្មើនឹង៦០%។

ករណីមួយបានរកឃើញថា នៅក្នុងប្រទេសចំនួន ១៤១ ក្នុងកំឡុងឆ្នាំ១៩៨១ ដល់ ២០០២ គ្រោះមហន្តរាយធម្មជាតិ (និងឥទ្ធិពលរបស់វា) ជាមធ្យមអត្រាមរណភាពស្ត្រីច្រើនជាងបុរស ឬក៏អត្រាមរណភាពស្ត្រីវ័យក្មេងច្រើនជាងបុរស។

*ប្រភព៖ Social Watch, 2007 and 2008; Oxfam, 2007; Neumayer and Plümper, 2007; and ILO, 2008.*

ការកាត់បន្ថយវិសមភាព និងការពង្រីកឱកាសពេញលេញ រួមទាំងការចូលរួមដោយប្រសិទ្ធភាពពីគ្រប់វិស័យ/រាល់អ្នកពាក់ព័ន្ធទាំងអស់ក្នុងសង្គមនៅក្នុងការតាក់តែងច្បាប់ និងការអនុវត្តគោលនយោបាយត្រូវបានចាត់ទុកថាមានក្នុងសារៈសំខាន់ ដើម្បីសម្រេចបានការអភិវឌ្ឍ និងសិទ្ធិមនុស្សពិតពលោក។ ដូច្នេះការដោះស្រាយដោយចីរភាព វិសមភាពយេនឌ័រ ការលើកកម្ពស់ និងការដាក់បញ្ចូលទស្សនទានវិសមភាពយេនឌ័រក្នុងច្បាប់ និងគោលនយោបាយអភិវឌ្ឍត្រូវបានមើលឃើញថា ជាមធ្យោបាយមួយដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងពិភពលោកនៅពេលណាដែលមានការលើកឡើងនូវវិសមភាពយេនឌ័រក្នុងច្បាប់ វប្បធម៌កាន់តែតឹងរឹងនោះ ការមិនទទួលយកនូវការផ្លាស់ប្តូរកាន់តែខ្លាំង។ វិសមភាពយេនឌ័រនៅក្នុងវប្បធម៌ និង/ឬក៏ប្រទេសជាតិ ឬក៏ច្បាប់ទម្លាប់ភាពមិនព្រមទទួលយកការផ្លាស់ប្តូរអាចនឹងខ្លាំងក្លា។ សម្រាប់បុរសដែលមានសេចក្តីព្រួយបារម្ភថា នៅពេលដែលស្ត្រីទទួលការកើនឡើងនៃភាពស្មើគ្នា បុរសអាចនឹងបាត់នូវអំណាចកិត្យានុភាព និងផលប្រយោជន៍ជាច្រើន។ ការសំខាន់ដែលត្រូវទទួលស្គាល់សេចក្តីភ័យខ្លាចទាំងឡាយនេះគួរត្រូវកំណត់កិច្ចពិភាក្សាប្រកបដោយប្រសិទ្ធភាព ដែលអនុញ្ញាតឱ្យបុរសយល់ថា ជោគជ័យក្នុងសមភាពយេនឌ័រផ្តល់ផលប្រយោជន៍មិនត្រឹមតែស្ត្រីនោះទេ តែបុរសផងដែរ។ ដើម្បីទទួលបាននូវសមភាពយេនឌ័រ ចាំបាច់ត្រូវដោះស្រាយវិសមភាពដែលទាក់ទងទៅនឹងការប្រើប្រាស់ធនធាននានា និងក្នុងការលើកកម្ពស់សមធម៌ យេនឌ័រ (សូមមើលប្រអប់២)។

**ប្រអប់២** សមភាពនិងសមធម៌យេនឌ័រ

**សមភាពយេនឌ័រ** ជាគោលគំនិតមួយដែលមនុស្សទាំងអស់ទាំងស្រីទាំងប្រុសមានសេរីភាពក្នុងការបង្កើនសមត្ថភាពផ្ទាល់ខ្លួន និងជ្រើសរើសអ្វីមួយដោយមិនមានព្រំដែនដែលកំណត់ដោយគំនិតសង្គម តួនាទីមិនអាចបត់បែនបានរបស់យេនឌ័រ ឬក៏ភាពរើសអើងទាំងឡាយ។ សមភាពយេនឌ័រមានន័យថា អាកប្បកិរិយាសេចក្តីប្រាថ្នានិងតម្រូវការដែលខុសគ្នារបស់ស្ត្រីនិងបុរស ត្រូវបានពិចារណាផ្តល់តម្លៃ និងគោរពស្មើគ្នា។ នេះមិនមែនមានន័យថា ស្ត្រី និងបុរសត្រូវតែដូចគ្នានោះឡើយ ប៉ុន្តែមានន័យថា សិទ្ធិទំនួលខុសត្រូវនិងឱកាសរបស់ពួកគេមិនអាស្រ័យលើកត្តាដែលពួកគេកើតមកជាប្រុស ឬស្រីនោះឡើយ។

**សមធម៌យេនឌ័រ** សំដៅដល់ការប្រព្រឹត្តស្មើគ្នារវាងស្ត្រី និងបុរសដោយផ្អែកលើតម្រូវការផ្សេងគ្នារបស់ពួកគេ។ អាចរួមបញ្ចូលការប្រព្រឹត្តស្មើគ្នា ឬក៏ការប្រព្រឹត្តដែលខុសគ្នា ប៉ុន្តែត្រូវបានចាត់ទុកថា សមមូលលើផ្នែកសិទ្ធិ ផលប្រយោជន៍ កាតព្វកិច្ច និងឱកាស។ នៅក្នុងបរិបទនៃការអភិវឌ្ឍ គោលបំណងនៃសមធម៌យេនឌ័រ ជាញឹកញាប់តម្រូវឱ្យមានវិធានការជាស្រេចដើម្បីទូទាត់ការខូចប្រយោជន៍ប្រវត្តិសាស្ត្រ និងសង្គមរបស់ស្ត្រី។

ហេតុដូចនេះហើយ ទាំងសមភាព និងសមធម៌យេនឌ័រចាំបាច់ត្រូវតែធ្វើឡើងក្នុងរូបភាពបំពេញបន្ថែមមួយដែលសមភាពយេនឌ័រជាគោលបំណងចម្បងបំផុត។ ឬយើងអាចនិយាយម្យ៉ាងទៀតថា ដើម្បីទទួលបាននូវសមភាពយេនឌ័រ ជានិច្ចជាកាលចាំបាច់ក្នុងការសម្រេចឱ្យបាននូវវិធានការលើសមធម៌យេនឌ័រ។ ជោគជ័យនៃសមភាពយេនឌ័រមិនមែនជាគោលដៅតែមួយដែលកើតឡើងតែម្តងហើយបញ្ចប់នោះទេ។ ដោយសារតែសេចក្តីចម្រើនអាចនឹងបាត់បង់ទៅវិញទាំងអស់ដោយងាយស្រួលសមធម៌យេនឌ័រត្រូវតែលើកកម្ពស់ជាដរាប និងទ្រទ្រង់យ៉ាងសកម្ម។

## ១.២ តើអ្វីជាការបញ្ជ្រាបយេនឌ័រ ?

“ការបញ្ជ្រាប” គឺជាដំណើរការដែលរួមបញ្ចូលការនាំយកនូវអ្វីដែលមិនបានគិតគូរឱ្យទៅជាចំណុចស្នូលក្នុងការងារ និងការសម្រេចចិត្តរបស់ស្ថាប័ន។

ការបញ្ជ្រាបយេនឌ័រជាដំណើរការប៉ាន់ប្រមាណ ផលប៉ះពាល់រវាងស្ត្រី និងបុរសនៅក្នុងផែនការសកម្មភាព គោលនយោបាយ ឬក៏កម្មវិធីណាមួយនៅគ្រប់ផ្នែក និងគ្រប់វិស័យទាំងថ្នាក់ជាតិ និងក្រោមជាតិ។ ការបញ្ជ្រាបយេនឌ័រជាយុទ្ធសាស្ត្រមួយសម្រាប់ធ្វើឱ្យកង្វល់ និងបទពិសោធន៍របស់ស្ត្រី និងបុរសក្លាយជាផ្នែកដ៏សំខាន់មួយក្នុងការបង្កើត អនុវត្តន៍ ត្រួតពិនិត្យ និងវាយតម្លៃនៃគោលនយោបាយ គំនិតផ្តួចផ្តើមថ្មី និងកម្មវិធីផ្សេងៗ។ ដូច្នេះ ការបញ្ជ្រាបយេនឌ័រធានាថា ស្ត្រី និងបុរសទទួលបាននូវផលប្រយោជន៍ស្មើគ្នាពីដំណើរការអភិវឌ្ឍយ៉ាងហោចណាស់ វិសមភាពត្រូវបានកាត់បន្ថយ (ECOSOC, 1997)។

ការបញ្ជ្រាបយេនឌ័រ មិនត្រឹមតែជាការយកចិត្តទុកដាក់លើយុត្តិធម៌សង្គម និងសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែជាការធានាឱ្យមានកិច្ចអភិវឌ្ឍដែលប្រកបដោយសមធម៌ និងចីរភាពនៃមនុស្សលោក តាមរយៈមធ្យោបាយដែលមានប្រសិទ្ធភាព និងគុណតម្លៃបំផុត។ យុទ្ធសាស្ត្រនៃការបញ្ជ្រាបយេនឌ័រ មិនមែនផ្តោតតែលើស្ត្រីនោះឡើយ ប៉ុន្តែជាការវាយតម្លៃលើស្ថានភាពរបស់ស្ត្រី និងបុរសដែលមានតួនាទីនៅក្នុងដំណើរការអភិវឌ្ឍ និងជាអ្នកទទួលផលពីដំណើរការនេះផងដែរ (ECOSOC, 1997)។

លើសពីការចូលរួមរបស់ស្ត្រីក្នុងកម្មវិធី និងយុទ្ធសាស្ត្រដែលមានស្រាប់ ការបញ្ជ្រាបយេនឌ័រមានគោលបំណងផ្លាស់ប្តូររចនាសម្ព័ន្ធ វិសមភាពសង្គម និងស្ថាប័នទាំងឡាយ

### ប្រអប់៣ ឧបសគ្គលើការបញ្ជ្រាបយេនឌ័រនៅក្នុងការបង្កើតគោលនយោបាយ

យេនឌ័រ មិនត្រូវបានគេចាត់ទុកថាជាធាតុសំខាន់ក្នុងស្ថាប័នបង្កើតគោលនយោបាយនោះឡើយ មិនថាតែនៅក្នុងសហគមន៍អភិវឌ្ឍអន្តរជាតិ ឬនៅថ្នាក់ជាតិ និងតំបន់នោះទេ។ ហេតុដូច្នេះ ទើបមានកង្វះខាតអ្នកជំនាញខាងយេនឌ័រនៅក្នុងស្ថាប័នទាំងអស់នោះ។ នៅពេលដែលមានជំនាញយេនឌ័រ បញ្ហាត្រូវបានរកឃើញថា (ក) ស្ថាប័នទាំងឡាយពាក់ព័ន្ធនឹងបញ្ហាស្ត្រី និងយេនឌ័រ ឬ (ខ) កម្មវិធីណាដែលដោះស្រាយបញ្ហាស្ត្រី ឬការតស៊ូសម្រាប់វិសមភាពយេនឌ័រ។

កិច្ចពិភាក្សាមានកម្រិតកើតឡើងតែជាមួយអ្នកពាក់ព័ន្ធសំខាន់ៗប៉ុណ្ណោះ។ ខណៈដែលអនុញ្ញាតឱ្យមានការចូលរួមដោយផ្ទាល់ពីសំណាក់ប្រជាជនក្រីក្រនៅក្នុងកិច្ចពិភាក្សាទាំងនេះ អាចនឹងចំណាយពេលច្រើនដើម្បីទទួលបានជោគជ័យ កិច្ចពិភាក្សានេះទៀតសោតក៏បានបរាជ័យក្នុងការបញ្ចូល ឬក៏បានបញ្ចូលត្រឹមតែនិមិត្តរូបនូវអង្គការដែលធ្វើការជាមួយអ្នកក្រីក្រ ក៏ដូចជាស្ថាប័នដទៃទៀតដែលធ្វើការសម្រាប់សមធម៌យេនឌ័រ។ ស្ថាប័នដែលត្រូវបានធ្វើការពិគ្រោះយោបល់ដូចជា មានតែស្ថាប័នណាដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាល និងម្ចាស់ជំនួយ។

ដើម្បីធ្វើឱ្យស្ថាប័នទាំងនេះអាចឆ្លើយតបទៅនឹងយេនឌ័របានកាន់តែខ្លាំង។ ដូច្នេះហើយ ការបញ្ជ្រាបយេនឌ័រខុសគ្នាពីយុទ្ធសាស្ត្រ "ស្ត្រីក្នុងការអភិវឌ្ឍ" ត្រង់ថាចំណុចផ្តើមរបស់ការបញ្ជ្រាបយេនឌ័រ គឺជាការវិភាគយ៉ាងលំអិត និងហ្មត់ចត់លើស្ថានភាពអភិវឌ្ឍជាជាងការសន្មតទុកមុនអំពីបញ្ហា និងតួនាទីរបស់ស្ត្រី។ បទពិសោធន៍បានបង្ហាញថា បញ្ហាយេនឌ័រខុសគ្នាទៅតាមប្រទេស តំបន់ និងបរិបទផ្សេងៗគ្នា។ ស្របពេលជាមួយគ្នានេះដែរ បទពិសោធន៍ក៏បានបង្ហាញថា ការវិភាគដែលផ្តោតលើយេនឌ័រ ជានិច្ចជាកាលតែងតែបង្ហាញនូវសេចក្តីត្រូវការ និងអាទិភាពខុសគ្នាជាច្រើនរវាងយេនឌ័រ ក៏ដូចជាវិសមភាពយេនឌ័រលើឱកាស និងលទ្ធផល។ ការបញ្ជ្រាបយេនឌ័រ ស្វែងរកដើម្បីកែតម្រូវបញ្ហាទាំងអស់នេះ (Aguilar et al., 2007)។

ការប្រើប្រាស់ទស្សនទានសមភាពយេនឌ័រតម្រូវឱ្យមានការវិភាគនិងយល់ដឹងពីភាពខុសគ្នាលើតួនាទី ទំនួលខុសត្រូវ តម្រូវការ និងចក្ខុវិស័យរបស់ស្ត្រី ក៏ដូចជាការចូលរួមនិងការជះឥទ្ធិពលលើការសម្រេចចិត្ត។ ក្នុងន័យនេះ គឺមិនត្រឹមតែទទួលស្គាល់លើភាពមិនដូចគ្នា ទំនាក់ទំនងសមធម៌រវាងស្ត្រីនិងបុរស។

គោលការណ៍ទាំងអស់នេះ បានជះឥទ្ធិពលដល់ដំណើរការរបស់អង្គការសហប្រជាជាតិ លើការបញ្ជ្រាបយេនឌ័រ។ នៅក្នុងឆ្នាំ២០០៥ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ (ECOSOC) បានទទួលយកកតិកាមួយក្នុងគោលដៅ ធានាឱ្យមានការបញ្ជ្រាបគោលគំនិតយេនឌ័រ ទៅក្នុងគ្រប់កម្មវិធីនិងគោលនយោបាយទាំងអស់នៃប្រព័ន្ធអង្គការសហប្រជាជាតិ។

កតិការបស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិអំពាវនាវដល់ "សហព័ន្ធនៃអង្គការសហប្រជាជាតិទាំងអស់ រួមមានទីភ្នាក់ងារ មូលនិធិ និងកម្មវិធីទាំងឡាយរបស់អង្គការសហប្រជាជាតិឱ្យរឹតបន្តឹងកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាដែលជាប់ពាក់ព័ន្ធនឹងសមាហរណកម្ម ទស្សនទានយេនឌ័រទៅក្នុងគោយនយោបាយ និងកម្មវិធីទាំងអស់។ សមាហរណកម្មទាំងនោះរួមមានដំណើរការមួយចំនួនដូចជា ការអភិវឌ្ឍផែនការសកម្មភាពសម្រាប់បញ្ជ្រាបយេនឌ័រ សមាហរណកម្មយេនឌ័រទៅក្នុងថវិកា កម្មវិធីបណ្តុះបណ្តាលបុគ្គលិកលើបញ្ហាយេនឌ័រ និងការវិភាគលើយេនឌ័រសម្រាប់ការងារកម្មវិធីនិងគោលនយោបាយ" (សូមមើលបញ្ជីទាំងមូលនៅក្នុងមេរៀនទី២)។

ឧបសគ្គចម្បងពីរលើការបញ្ជ្រាបយេនឌ័រ ត្រូវបានរកឃើញនៅក្នុងការសិក្សាដ៏សំខាន់ និងមានឥទ្ធិពលមួយលើយេនឌ័រ និងការកាត់បន្ថយភាពក្រីក្រ (Kabeer, 2003)។ ឧបសគ្គទាំងពីរនោះគឺ កង្វះខាតសមត្ថភាពស្នូលនៃស្ថាប័នបង្កើតគោលនយោបាយ និងកិច្ចពិភាក្សាមានកម្រិតជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ (សូមមើលប្រអប់៣)។

## ១.៣ លក្ខណៈពិសេសរបស់ស្ត្រី

ដើម្បីឱ្យទស្សនទានយេនឌ័រមានដំណើរការ ការចាប់អារម្មណ៍ត្រូវតែផ្តោតទៅលើអ្វីដែលត្រូវបានហៅថា "លក្ខណៈពិសេស" របស់ស្ត្រី ឧទាហរណ៍ កត្តា និងយុទ្ធសាស្ត្រវប្បធម៌ សេដ្ឋកិច្ច និងសង្គម ជាច្រើនដែលរារាំងស្ត្រីនៅក្នុងស្ថានភាពមួយដែលចាញ់ប្រៀប និងរណបគេ បើធៀបទៅនឹងបុរស (សូមមើលប្រអប់៤)។

**ប្រអប់៤ លក្ខណៈពិសេសរបស់ស្ត្រី**

លក្ខណៈពិសេសរបស់ស្ត្រីរួមមានកត្តា និងយុទ្ធសាស្ត្រវប្បធម៌ សេដ្ឋកិច្ច និងសង្គមជាច្រើនដែលរាំងស្ត្រីក្នុងស្ថានភាពមួយដែលចាញ់ប្រៀបនិងរណេបគេបើធៀបទៅនឹងបុរស។ ការរណែបរណបទាំងនេះ គឺបានស្តែងឡើងក្នុងអាកប្បកិរិយាខុសៗគ្នាទៅតាមបរិបទប្រពៃណី និងប្រវត្តិសាស្ត្រ។ ការដែលយកលក្ខណៈរបស់ស្ត្រីជាឧបករណ៍នៃគោលគំនិត និងប្រតិបត្តិការសម្រាប់ការវិភាគរួមមាន ការពិចារណាជាចាំបាច់ដល់ស្ថានភាពសម្ភារៈ ឬក៏កម្រិតដែលតម្រូវការជាក់ស្តែងរបស់ពួកគេត្រូវបានឆ្លើយតបដូចជាលទ្ធភាពក្នុងការទទួលបានសេវាប្រើប្រាស់ទឹក អគ្គិសនី ផ្ទះសំបែង ការថែទាំសុខភាព ការងារ និងការរកប្រាក់ចំណូល។ គំនិតនេះផ្សាភ្ជាប់សុខុមាលភាពសម្ភារៈរបស់ស្ត្រីទៅនឹងបរិបទជាក់លាក់ទាំងឡាយដែលពាក់ព័ន្ធបរិស្ថានសង្គម និងតួនាទី និងទំនួលខុសត្រូវរបស់គេ ដែលសង្គមផ្តល់ឱ្យទៅស្ត្រី។

សកម្មភាពរបស់រដ្ឋាភិបាល អាចនឹងតម្រូវឱ្យមានសម្រាប់សំណងលើវិសមភាពធម្មជាតិដែលកើតចេញពីលក្ខណៈពិសេសរបស់ស្ត្រី។ បើធៀបទៅនឹងការគ្រប់គ្រងការប្រែប្រួលអាកាសធាតុវិញ ករណីនេះអាចនឹងរួមបញ្ចូលនូវការបង្កើតវិធានការពិសេសមួយចំនួនដើម្បីជ្រោមជ្រែងការទទួលបានរបស់ស្ត្រី នូវព័ត៌មានបច្ចេកវិទ្យា និងការចូលរួមនៅក្នុងការកំណត់និតិវិធីយុទ្ធសាស្ត្រផ្តល់ហិរញ្ញវត្ថុ និងនៅក្នុងចំណោមរឿងដទៃទៀត។

លុបបំបាត់ទម្លាប់នៃការរើសអើងនិងបង្កើតឱកាសដែលមានអត្ថន័យសម្រាប់ការចូលរួមរបស់ស្ត្រីនៅគ្រប់លំដាប់ថ្នាក់ទាំងអស់លើការសម្រេចចិត្ត និងចំណាយពេលវេលានិងកិច្ចខិតខំប្រឹងប្រែងច្រើន នឹងចាំបាច់ឱ្យមានការប្តេជ្ញាចិត្តពីសំណាក់អ្នកសម្រេចចិត្តនិងស្ត្រីខ្លួនឯង។ ការធានានូវការប្តេជ្ញាចិត្តនេះនឹងតម្រូវឱ្យមានការទទួលយកនូវវិធានការផ្លូវច្បាប់ និងគោលនយោបាយ ដើម្បីធានាថាការចូលរួមរបស់ស្ត្រី និងកិច្ចពិភាក្សាជាមួយស្ត្រីផ្តល់ឱ្យពួកគេនូវឱកាសមានឥទ្ធិពលលើលទ្ធផលនៃដំណើរការសម្រេចចិត្តទាំងឡាយ។ ការបង្កើតដំណើរការទាំងអស់នេះនិងការធានានូវភាពស៊ីសង្វាក់គ្នា និងនិរន្តរភាពលើសមធម៌ និងសមភាពយេនឌ័រតម្រូវឱ្យមានការបញ្ជ្រាបយេនឌ័រនៅក្នុងការបង្កើតគោលនយោបាយគ្រប់លំដាប់ថ្នាក់ទាំងអស់។

## ឯកសារស្រាវជ្រាវ


Alfaro, C. (1999). Unveiling Gender: Basic Conceptual Elements for Understanding Equity. Toward Equity series. Costa Rica: IUCN-Arias Foundation.

Kabeer, N. (2003). Gender Mainstreaming in Poverty Eradication and the Millennium Development Goals: A handbook for policy-makers and other stakeholders. UK: Commonwealth Secretariat, International Development Research Centre, Canadian International Development Agency.

Kanji, N. (2003). Mind the Gap: Mainstreaming Gender and Participation Development. Institutionalising Participation series. UK: IIED and IDS.

Social Watch. (2008). Gender Equity Index 2008. Retrieved from the World Wide Web: http://www.socialwatch.org/en/avancesyRetrocesos/IEG_2008/images/img_full/exterior_eng_gde.gif

UNDP. (2000). Learning & Information Pack: Gender Mainstreaming. USA: Gender in Development Programme. UNESCO. (2003).

UNESCO Gender Mainstreaming Implementation Framework 2002-2007. Retrieved from the World Wide Web: http://portal.unesco.org/en/ev.php-URL_ID=11340&URL_DO=DO_TOPIC&URL_SECTION=201.html

Williams, S., Seed, J. and Mwau, A. (1994). The Oxfam Gender Training Manual. UK: Oxfam.



## កិច្ចការសម្រាប់ជំពូកនេះ

| សកម្មភាព | ដំណើរការ | រយៈពេល |
|---|---|---|
| បទបង្ហាញរបស់សិក្ខាកាម | ជ្រើសរើសនូវវិធីសាស្ត្រសម្រាប់ណែនាំមួយ | ១០ នាទី |
| ការណែនាំអំពីវាក្យស័ព្ទ និង គំនិតរបស់យេនឌ័រ | វិធីសាស្ត្រ “**ណែនាំគោលគំនិតទាក់ទងនឹងយេនឌ័រ**”<br>វិធីសាស្ត្រ “**បាយមួយចាន**” | ៣០ នាទី<br>២០ នាទី |
| យល់ដឹងពីភាពខុសគ្នា/គម្លាត នៃយេនឌ័រ | វិធីសាស្ត្រ “**វិភាគលើភាពខុសគ្នា/គម្លាត នៃយេនឌ័រ**”<br>និង/ឬ<br>វិធីសាស្ត្រ “**យល់ដឹងពីវិសមភាព**” | ១ ម៉ោង |

ក្នុងន័យនេះ កិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងការគ្រប់គ្រងបរិស្ថានបានរីកចម្រើននាចុងទសវត្សរ៍ក្រោយនេះ ជាមួយនឹងស្ថាប័នមួយចំនួនដូចជា អង្គការសហប្រជាជាតិសម្រាប់កម្មវិធីបរិស្ថាន សហគមន៍អន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងអនុសញ្ញាជីវចម្រុះ (CDB) ក្នុងការបង្កើតផែនការសកម្មភាព។ បទពិសោធន៍ដែលបង្កើតឱ្យមាននៅទីនេះ អាចជួយជាឯកសារយោងសម្រាប់ស្ថាប័ន ឬអង្គការដែលធ្វើការលើការប្រែប្រួលអាកាសធាតុ។

## កំណត់ត្រាសម្រាប់អ្នកសម្របសម្រួល

ដើម្បីដោះស្រាយបញ្ហាទាក់ទងទៅនឹងគោលគំនិតយេនឌ័រ ត្រូវពឹងផ្អែកទៅលើពេលវេលាដែលអ្នកត្រូវដំណើរការនៃវគ្គបណ្តុះបណ្តាល។ ទោះជាយ៉ាងណាក៏ដោយ ការយល់ដឹងរបស់សិក្ខាកាមអំពីទស្សនទានយេនឌ័រជាចំណុចសំខាន់មុននឹងស្វែងយល់មេរៀនបន្ទាប់។

ចំណុចសំខាន់ត្រូវស្វែងរកវិធីសាស្ត្រល្អបំផុតសម្រាប់យកមកប្រើប្រាស់ទៅតាមប្រភេទនៃសិក្ខាកាម។ វិធីសាស្ត្រនេះនឹងមានភាពប្លែកគ្នាទៅតាមប្រភេទនៃអ្នកចូលរួម។

# ករណីសិក្សា

## ករណីសិក្សាទី១៖
## ការធ្វើផែនការកសិកម្មប្រកបដោយចីរភាពរបស់ស្ត្រី

ចាប់តាំងពីឆ្នាំ២០០៣មកលេខាធិការដ្ឋាននៃសហគមន៍ប៉ាស៊ីហ្វិកបានអនុវត្តកម្មវិធីអភិវឌ្ឍចីរភាពកសិកម្មមួយទូទាំងតំបន់ប៉ាស៊ីហ្វិក។ ការអភិវឌ្ឍកសិកម្មដោយចីរភាពនៅតំបន់ប៉ាស៊ីហ្វិក (DSAP) របស់សហគមន៍នេះបានអនុវត្តនៅក្នុង ១៧ប្រទេស ក្នុងតំបន់ប៉ាស៊ីហ្វិក។

កម្មវិធី DSAP បានផ្តោតទៅលើការកំណត់បញ្ហា និងសាកល្បងបច្ចេកវិទ្យាជាមួយកសិករ ដើម្បីធ្វើឱ្យប្រព័ន្ធកសិកម្មបុរាណរបស់ពួកគាត់មានភាពល្អប្រសើរឡើងនៅតំបន់ កោះផ្កាថ្ម។ តាំងពីដើមមកប្រជាកសិករទាំងនេះបានប្រើប្រាស់ប្រព័ន្ធកសិកម្ម តាមបែបការដាំដុះដំណាំដែលចងរបងបន្តគ្នាជាថ្នាក់ៗជាច្រើន។ កម្មវិធីអភិវឌ្ឍចីរភាព កសិកម្ម DSAP បានធ្វើការដើម្បីរួមបញ្ចូលការចិញ្ចឹមសត្វទៅក្នុងប្រព័ន្ធទាំងនេះ។

តំបន់ដីទំនាបបានផ្តោតលើការប្តូរពីការស្រាវជ្រាវទៅរកការកំណត់និងផ្សព្វផ្សាយបច្ចេកវិទ្យាដែលមានអត្ថប្រយោជន៍ ដូចជា បច្ចេកវិទ្យាលើកកម្ពស់ដំណាំចម្រុះគ្រប់គ្រងសត្វល្អិតនិងជំងឺ ការគ្រប់គ្រងដី និងបច្ចេកវិទ្យារុក្ខាកសិកម្ម។

DSAP ក៏ប្រើប្រាស់សម្ភារៈទំនាក់ទំនងមួយចំនួនដើម្បីលើកកម្ពស់កិច្ចខិតខំប្រឹងប្រែងរបស់គម្រោងជាមួយប្រទេសជាសមាជិក ឧទាហរណ៍ ការប្រើប្រាស់វិទ្យុនិងការផលិតនិងប្រើប្រាស់ផ្ទាំងប្រកាស សៀវភៅ ខិតប័ណ្ណ និងវីដេអូនៅថ្នាក់ជាតិ។

គម្រោងនេះ ត្រូវបានបង្កីតឡើងតាមរយៈគំរូមួយដែលលើកទឹកចិត្តឱ្យមានការធ្វើផែនការអនុវត្ត និងសម្របសម្រួលតាមលក្ខណៈថ្នាក់ជាតិ។ ការនេះត្រូវបានទទួលជោគជ័យដោយមានការបង្កើតគណៈកម្មាធិការប្រតិបត្តិជាតិ (NSCs) ជាច្រើនដែលរួមបញ្ចូលអ្នកពាក់ព័ន្ធទាំងឡាយពីរដ្ឋាភិបាលដល់សង្គមស៊ីវិល។

អ្នកទទួលផលចម្បង គឺកសិករប្រុសស្រីនៅក្នុងប្រទេសតំបន់ប៉ាស៊ីហ្វិកនិងសហគមន៍ដទៃច្រើនទៀតដែលមានប្រជាជនរាប់សិបពាន់នាក់ក៏ទំនងជានឹងទទួលបានផលនេះផងដែរ។

ការផ្តោតទៅលើបរិស្ថានល្អប្រសើរ និងការគ្រប់គ្រងធនធានធម្មជាតិ កសិកម្ម និងប្រកបដោយចីរភាពការចិញ្ចឹមជីវិតបានផ្តល់ផលប្រយោជន៍ជាច្រើនដែលនឹកស្មានមិនដល់ទាំងទៅលើការកាត់បន្ថយគ្រោះមហន្តរាយ ជាពិសេសក្នុងការកាត់បន្ថយគ្រោះថ្នាក់ ដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជាសមធម៌និងសមភាពយេនឌ័រនៅក្នុងតំបន់។

ដោយយល់ឃើញថាប្រទេសកំពុងអភិវឌ្ឍនៅតាមកោះតូចៗ (SIDS) មានភាពងាយរងគ្រោះខ្ពស់ ចំពោះការប្រែប្រួលអាកាសធាតុ កម្មវិធីនេះបានបញ្ចូលវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុដូចជា ការលើកកម្ពស់ទៅលើគុណភាពដី ការប្រើប្រាស់គ្រាប់ពូជដែលធន់ទៅនឹងភាពរាំងស្ងួត ឬ ទឹកប្រៃ ភាពប្រសើរឡើងនៃប្រព័ន្ធធារាសាស្ត្រ ដំណាំនៅផ្ទៃរាបស្មើតាមជម្រាលភ្នំដើម្បីទប់ស្កាត់ការបាក់ដី និងហូរច្រោះ និងការគាំទ្រលើសួនបន្លែនៅក្នុងផ្ទះសម្រាប់ការទទួលបាននូវអាហារមានជីវជាតិ។

ការប្រើប្រាស់វិធីសាស្ត្រវាយតម្លៃលើតម្រូវការនៃដែលមានការចូលរួម ដើម្បីលើកកម្ពស់ចីរភាពផលិតផលកសិកម្មនិងសន្តិសុខស្បៀងអាហារ បានក្លាយជាគន្លឹះដល់ភាពជោគជ័យមួយលើការបញ្ជ្រាបយេនឌ័រ ខណៈពេលដែលដំណោះស្រាយបញ្ហាប្រឈមមុខលើគ្រោះមហន្តរាយ ដូចជា

គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ការកើនឡើងនូវកម្ពស់ទឹកសមុទ្រ និងគ្រោះមហន្តរាយដទៃផ្សេងទៀតដែលការប្រែប្រួលអាកាសធាតុត្រូវបានទស្សន៍ទាយថានឹងអាចធ្វើឱ្យតានតឹងជាងមុន។

កម្មវិធីអភិវឌ្ឍកសិកម្មប្រកបដោយចីរភាព DSAP បានប្រើប្រាស់គំរូការវាយតម្លៃដោយមានការចូលរួម (PRA) របស់ខ្លួនក្នុងការស្វែងយល់ស្ដីអំពីតម្រូវការរបស់ស្ត្រី បុរស និងយុវជនក្នុងសហគមន៍ទាំងមូល។ ឧទាហរណ៍ ស្ត្រីនិងបុរសដាំដំណាំនិងធ្វើការជាមួយដំណាំផ្សេងគ្នានៅកោះដោយឡែកពីគ្នា។ ដំណើរការនៃការពិភាក្សានេះ បានស្ដាប់នូវតម្រូវការរបស់សហគមន៍ដើម្បីស្វែងរកនូវឧបករណ៍ត្រឹមត្រូវ និងបច្ចេកវិទ្យាសមស្របទាំងឡាយជាការឆ្លើយតប។

គម្រោងនេះបានធ្វើការនៅថ្នាក់ជាតិនិងសហគមន៍ និងតម្រូវឱ្យមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការពិភាក្សា។ ទស្សនទានជាច្រើនស្ដីពីយេនឌ័រត្រូវបានបញ្ចូលទៅក្នុងដំណើរការនេះ។

ការបង្កើតនូវយន្តការថ្នាក់ជាតិដើម្បីធានាថា អ្នកពាក់ព័ន្ធទាំងអស់បានចូលរួមក្នុងគម្រោងកម្មវិធីនេះ និងការចូលរួមពិភាក្សាជាច្រើនពីថ្នាក់តំបន់ ជាតិ និងសហគមន៍។ ការងារនេះត្រូវបានបន្តដំណើរការដ៏លំបាកមួយក្នុងការបង្កើតនិន្នភាពទំនាក់ទំនងមួយចំនួនជាមួយសហគមន៍ជនបទក្នុងការបង្កើតសេចក្ដីទុកចិត្ត និងយល់ដឹងរបស់ពួកគេ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ សារៈប្រយោជន៍ទាំងឡាយនៃវិធីសាស្ត្រនេះ គឺកំពុងតែត្រូវបានជ្រួតជ្រាបនៅថ្នាក់ជាតិ និងសហគមន៍ដែលក្នុងន័យថា បច្ចេកវិទ្យាកសិកម្មដែលសមស្របទាំងអស់នេះត្រូវបានកត់សម្គាល់និងយកមកប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាដែលឈានដល់ភាពប្រសើរឡើងនៃផលិតផល។

នៅក្នុងឆ្នាំ២០០៧ កម្មវិធីអភិវឌ្ឍកសិកម្មប្រកបដោយចីរភាព DSAP ត្រូវបានទទួលរង្វាន់ជ័យលាភី យេនឌ័រ SPC សម្រាប់កិច្ចខិតខំប្រឹងប្រែងដ៏មានតម្លៃរបស់ខ្លួនដើម្បីធ្វើសមាហរណកម្មស្ត្រី ក៏ដូចជា យុវជននៅក្នុងសកម្មភាពរបស់គេ ទៅក្នុងវិធីខុសៗគ្នាជាច្រើន រួមមានដំណើរការជ្រើសរើសនិងសកម្មភាព កសាងសមត្ថភាពដោយប្រើប្រាស់ សូចនាករយេនឌ័រ ជាមធ្យោបាយនៃការវាស់ស្ទង់ការចូលរួមរបស់ស្ត្រី។

DSAP នេះ ក៏រួមបញ្ចូលវិធានការដទៃផ្សេងទៀត ដើម្បីធានាថា យេនឌ័រត្រូវបានដាក់បញ្ចូលទៅក្នុងការអនុវត្តរាល់សកម្មភាពគម្រោងទាំងឡាយដូចជា (១) ការតែងតាំងជនបង្គោលយេនឌ័រជាច្រើននិងក្រុមប្រឹក្សាមួយ (២) ការបង្កើតនិងអនុវត្ត ការបណ្ដុះបណ្ដាលស្ដីពីការយល់ដឹងអំពីយេនឌ័រដល់បុគ្គលិក និងសមាជិកទាំងឡាយដើម្បីដាក់បញ្ចូលវិធីសាស្ត្រផ្សេងៗលើការវិភាគយេនឌ័រ (៣) ការកសាងសមត្ថភាពទាំងបុរសនិងស្ត្រីដែលរស់ក្នុងសហគមន៍ និង (៤) ការផ្សព្វផ្សាយលើការបណ្ដុះបណ្ដាលផ្នែកបច្ចេកវិទ្យា និងការចូលរួមរបស់ស្ត្រីក្នុងចំណោមកម្មវិធីផ្សេងទៀត។

DSAP ត្រូវបានអនុវត្តនៅប្រទេសហ្វីជី កោះឃុក (Cook Islands) រដ្ឋសហព័ន្ធម៉ៃក្រូនេស៊ី (Federated States of Micronesia) ប៉ូលីណេស៊ីបារាំង (French Polynesia) គីរីបាទី (Kiribati) កោះម៉ាហ្សល (Marshall Islands) កោះណារូ (Nauru) នូវ (Niue) ប៉ាលូ (Palau) ប៉ាពួណូវហ្គីនី (Papua New Guinea) សាមូអា (Samoa) កោះសូឡូម៉ុន (Solomon Islands) តុងហ្គា (Tonga) ធូវ៉ាលូ (Tuvalu) វ៉ានូវ៉ាអាទូ (Vanuatu) និងវ៉ាលិស និងហ្វូទូនា (Wallis and Futuna)។

*ប្រភព៖*

*SDR. (2008). Gender perspectives: Integrating Disaster Risk Reduction into Climate Change Adaptation. Good Practices and Lessons Learned. Switzerland: ISDR.*

*Press release. (2007). "CRGA 37 – SPC Gender Award 2007 presented to LRD for its gender-inclusive approach". Retrieved on September 23, 2008 from: http://www.spc.int/corp/index.php?option=com_content&task=view&id=146&Itemid=27*

## ករណីសិក្សាទី២៖

# ផែនការសកម្មភាពយេនឌ័រ នៃកម្មវិធីបរិស្ថានសហប្រជាជាតិ

កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ (UNEP) មានកាតព្វកិច្ចនិងតួនាទីជាក់លាក់មួយ នៅក្នុងផ្នែកបរិស្ថាន និងការអភិវឌ្ឍ។ UNEP បានដើរតួនាទីជាអ្នកត្រួសត្រាយផ្លូវមុនគេបង្អស់ក្នុងការងារផ្សារភ្ជាប់ស្ត្រីទៅនឹងបរិស្ថាន ចាប់តាំងពីឆ្នាំ១៩៨៥មក នៅពេលដែលមានការប្រារព្ធពិធីពិសេសមួយស្តីពី “ស្ត្រីនិងបរិស្ថាន” នៅឯសន្និសីទពិភពលោកលើកទី៣ ក្នុងទីក្រុងណៃរ៉ូប៊ី។ បន្ថែមលើនេះផងដែរ អាណត្តិទី១៧ ១៨ និង ១៩ នៃក្រុមប្រឹក្សាដឹកនាំរបស់ UNEP ក៏បានផ្តោតលើតួនាទីស្ត្រីក្នុងបរិស្ថាននិងការងារអភិវឌ្ឍ។

បន្ទាប់ពីមានការតែងតាំងជនបង្គោល យេនឌ័រនៅក្នុងឆ្នាំ១៩៩៩ កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិបានដាក់ជូននូវរបាយការណ៍មួយដល់ក្រុមប្រឹក្សាដឹកនាំ នៅក្នុងអាណត្តិទី២០របស់ខ្លួនស្តីពី តួនាទីរបស់ស្ត្រីក្នុងបរិស្ថាននិងការងារអភិវឌ្ឍ (UNEP/GC.20/10)។ កម្មវិធីការងាររបស់ UNEP សម្រាប់ឆ្នាំ២០០៤-២០០៥ មានការប្តេជ្ញាចិត្តធ្វើឱ្យយេនឌ័រក្លាយជាសកម្មភាពអាទិភាព រាល់គ្រប់កម្មវិធីរបស់ខ្លួនទាំងអស់។ នៅក្នុងវិស័យអភិបាលកិច្ចបរិស្ថានអន្តរជាតិ ផែនការយុទ្ធសាស្ត្របាលីសម្រាប់ការគាំទ្រផ្នែកបច្ចេកវិទ្យា និងកសាងសមត្ថភាព ក្នុងឆ្នាំ២០០៤ សំណូមពរឱ្យកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ “ធ្វើសមាហរណកម្មយុទ្ធសាស្ត្របញ្ជ្រាប យេនឌ័រ ជាក់លាក់មួយចំនួន ក៏ដូចជាការអប់រំនិងបណ្តុះបណ្តាលសម្រាប់ស្ត្រី ក្នុងការបង្កើតគោលនយោបាយទាក់ទងទាំងឡាយ និងដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចស្តីពីបរិស្ថាន”។

នៅឆ្នាំ២០០៤ អនុលោមទៅតាមសភាសកលរបស់ស្ត្រីលើបរិស្ថាន “ស្ត្រីជាសម្លេងរបស់បរិស្ថាន” សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដឹកនាំ ២៣/១១ លើសមភាពយេនឌ័រនៅក្នុងវិស័យបរិស្ថាន បានគូសបញ្ជាក់នូវតម្រូវការដើម្បីលើកកម្ពស់សមត្ថភាពផ្ទៃក្នុងរបស់ UNEP ចំពោះផ្នែកទាំងអស់នេះ។ ទោះបីជាមានការខិតខំប្រឹងប្រែង ដាច់ដោយឡែកពីគ្នាឆ្ពោះទៅរកសមធម៌ និងសមភាពយេនឌ័រ អស់រយៈពេលជាច្រើនឆ្នាំមកនេះ រដ្ឋាភិបាល និងសង្គមស៊ីវិលមួយចំនួនបានខិតខំប្រឹងប្រែង និងសមភាពយេនឌ័រស្នើសុំឱ្យ UNEP បង្កើតនូវយុទ្ធសាស្ត្រស្តីពីយេនឌ័រ។

ផែនការសកម្មភាពស្តីពីយេនឌ័រឆ្នាំ២០០៦ របស់ UNEP ដែលចង្អុលបង្ហាញជាទូទៅលើគម្រោងសម្រាប់សមាហរណកម្មបញ្ជ្រាបយេនឌ័រ ទៅក្នុងគ្រប់ផ្នែក សាខាក្រុម និងសកម្មភាពទាំងអស់របស់ UNEP ក្នុងអំឡុងឆ្នាំ ២០០៦-២០១០ គឺជាលទ្ធផលមួយនៃការងារដែលកើតឡើងជាបន្តបន្ទាប់៖ ការវិភាគលើការប្រតិបត្តិបច្ចុប្បន្នភាពរបស់ UNEP លើការងារយេនឌ័រនិងបរិស្ថាន រួមទាំងបទសម្ភាសជាមួយបុគ្គលិកជាន់ខ្ពស់របស់ UNEP និងការវិភាគលើឯកសារផ្ទៃក្នុងជាង ៤០ ច្បាប់។ ការងារនេះក៏ផ្អែកលើការត្រួតពិនិត្យឡើងវិញ ការអនុវត្តផែនការសកម្មភាពរបស់ស្ថាប័នដែលស្រដៀងគ្នានឹងដៃគូអន្តរជាតិមួយចំនួន។

ផែនការនេះ ត្រូវបានបរិយាយលំអិត ដោយមានការគាំទ្រពីសហគមន៍អន្តរជាតិ សម្រាប់ការអភិរក្សធម្មជាតិ (IUCN) និងអង្គការអភិវឌ្ឍនិងបរិស្ថានរបស់ស្ត្រី (WEDO)។ ផែនការនេះទៀតសោត គឺចាត់ទុកជាផ្នែកមួយនៃកិច្ចការឆ្លើយតបឥតឈប់ឈររបស់ UNEP លើធន្ទះសកលនាទសវត្សរ៍ចុងក្រោយនេះ ក៏ដូចជាកិច្ចប្រតិបត្តិតាមអនុសាសន៍របស់កិច្ចពិភាក្សាអន្តរជាតិ និងច្បាប់សំខាន់ៗមួយចំនួននៅក្នុងប្រព័ន្ធការងារអង្គការសហប្រជាជាតិ។ ផែនការសកម្មភាពស្តីពីយេនឌ័រ ត្រូវបានយកមកពិនិត្យឡើងវិញនៅក្នុងសិក្ខាសាលាថ្នាក់ដឹកនាំជាន់ខ្ពស់មួយនាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦ និងជាបន្ទាប់ត្រូវបានដាក់ជូនបុគ្គលិក UNEP នៅក្នុងកិច្ចប្រជុំមួយនាថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦។ នៅក្នុងសិក្ខាសាលានោះនាយកប្រតិបត្តិរបស់ UNEP លោកអាឈឹមស្ទេន័រ (Achim Steiner) បានបង្ហាញពីការប្តេជ្ញាចិត្តទាំងស្រុងរបស់គាត់ លើការអនុវត្តផែនការសកម្មភាពនោះ។

លោក Steiner បានបញ្ជាក់ថា ការបញ្ជ្រាបយេនឌ័រនៅកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ UNEP ត្រូវបានតម្រូវឱ្យមាន តាមរយៈច្បាប់ទម្លាប់ជាច្រើន និងថាការងារនេះជារឿងចាំបាច់ត្រូវធ្វើ។

ខ្លឹមសារនៃឯកសារផែនការនេះ ក៏ជាការឆ្លុះបញ្ចាំងពីការកើនឡើងនៃការយល់ដឹងផងដែរ ដែលសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី គឺជាសេចក្តីត្រូវការសំខាន់ដំបូងគេសម្រាប់ការគាំពារបរិស្ថាន និងការអភិវឌ្ឍដែលមានចីរភាព។ ផែនការសកម្មភាពស្តីពីយេនឌ័ររបស់ UNEP មានខ្លឹមសារដូចតទៅ "ការបញ្ជ្រាបយេនឌ័របានក្លាយជាវិធីសាស្ត្រចម្បងសម្រាប់សមាហរណកម្ម យុទ្ធសាស្ត្រយេនឌ័រ ទៅក្នុងកិច្ចខិតខំប្រឹងប្រែងខាងផ្នែកអភិវឌ្ឍ ឬ បរិស្ថាន។ ជាជាងបន្ថែមការចូលរួមរបស់ស្ត្រី ទៅក្នុងកម្មវិធី និងយុទ្ធសាស្ត្រដែលមានស្រាប់ ការបញ្ជ្រាបយេនឌ័រមានគោលបំណងផ្លាស់ប្តូរប្រព័ន្ធមិនស្មើភាពគ្នារបស់សង្គម និងស្ថាប័នទាំងឡាយដើម្បីធ្វើឱ្យស្ថាប័នទាំងនេះ អាចឆ្លើយតបទៅនឹងយេនឌ័របានកាន់តែខ្លាំង។ ភាពជោគជ័យនៃសមធម៌និងសមភាពយេនឌ័រ គឺទាក់ទងនឹងរឿងដែលត្រូវផ្លាស់ប្តូរទំនាក់ទំនងអំណាចដែលមានស្រាប់ ដើម្បីឱ្យបានប្រយោជន៍ដល់ជនទាំងឡាយណាដែលមានអំណាចតិចតួច"។

ផែនការសកម្មភាពនេះកំណត់នូវតួនាទីដែលកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ UNEP នឹងដើរតួនាទីក្នុងការជំរុញនិងសម្របសម្រួល កិច្ចខិតខំប្រឹងប្រែងទាំងឡាយទាំងនៅក្នុងស្ថាប័ន និងជាមួយដៃគូនៅថ្នាក់ជាតិ តំបន់ និងសកលដើម្បីដោះស្រាយឧបសគ្គទាំងពួង និងទាញយកផលចំណេញលើឱកាស ដើម្បីលើកកម្ពស់សមធម៌ និងសមភាពយេនឌ័រក្នុងផ្នែកបរិស្ថាន។ ផែនការនេះ ត្រូវបានកំណត់ថាជាឯកសារអាចកែប្រែបានដែលនឹងបន្តវិវឌ្ឍ អាស្រ័យទៅលើស្ថានភាពជាក់ស្តែងរបស់ស្ថាប័ននយោបាយ តំបន់ និងពិភពលោកទាំងមូល។

**ផែនការមានគោលដៅយុទ្ធសាស្ត្របីគឺ៖**

១) ដើម្បីធានាថា សមធម៌ និងសមភាពយេនឌ័រ និងសិទ្ធិរបស់ស្ត្រីត្រូវបានគោរពគ្រប់ជ្រុងជ្រោយ តួនាទីរបស់ស្ត្រីត្រូវបានលើកកម្ពស់និងការចូលរួមសស្រាក់សស្រាំរបស់ស្ត្រីត្រូវបានធានានៅគ្រប់កិច្ចការងារនិងគោលនយោបាយរបស់កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ UNEP។

២) ដើម្បីលើកកម្ពស់សមភាពនៃឱកាស និងការប្រព្រឹត្តិរវាងស្ត្រី និងបុរសនៅក្នុងផ្នែកបរិស្ថាននៅថ្នាក់ជាតិ តំបន់ និងពិភពលោក។

៣) និងដើម្បីឱ្យមានកំណើននៃគុណភាព និងសមត្ថភាពការងារអភិរក្សបរិស្ថាន និងលើកកម្ពស់ចីរភាពនៃការងារអភិវឌ្ឍរបស់កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ UNEP។

ការអនុវត្តផែនការនេះ បានចាប់ផ្តើមឡើងរួចហើយ ហើយវិធានការរៀបចំជាច្រើនដែលបានណែនាំក៏ត្រូវសម្រេចបានហើយដែរ៖ ជំហានជាបឋមជាមួយនឹងការតែងតាំងអ្នកប្រឹក្សាជាន់ខ្ពស់ផ្នែកយេនឌ័រ ជំហានទីពីរ ជាមួយនឹងការបង្កើតជនបង្គោលផ្នែកយេនឌ័រចំនួន១៥រូប នៅក្នុងការិយាល័យនិងផ្នែករបស់ UNEP និងជំហានទីបីជាមួយនឹងការដែលឱ្យការិយាល័យ ថ្នាក់តំបន់នីមួយៗបង្កើត និងអនុវត្តផែនការសកម្មភាពយេនឌ័ររបស់ខ្លួនរៀងៗខ្លួន។

កិច្ចខិតខំប្រឹងប្រែងថ្មីទាំងអស់នេះ មិនត្រឹមតែនឹងផ្តល់ផលប្រយោជន៍ដល់ស្ត្រី និងបុរសរាប់សិបពាន់នាក់នៅជុំវិញពិភពលោកនោះទេ ក៏ប៉ុន្តែវាក៏នឹងលើកកម្ពស់ កិច្ចប្រតិបត្តិការបេសកកម្មរបស់ UNEP ផងដែរ ពីព្រោះផែនការនេះបង្កើតឡើងនូវយុទ្ធសាស្ត្រជាច្រើន ជាមួយនឹងគោលដៅដែលអាចធ្វើទៅបាន និងពីព្រោះវាជាក់ស្នើឱ្យមានសម្ភារៈទាំងឡាយដើម្បីដោះស្រាយបញ្ហាទាក់ទិននឹងយេនឌ័រ នៅក្នុងផ្នែកបច្ចេកទេសរបស់កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ UNEP។ អត្ថបទទាំងស្រុងអំពីផែនការសកម្មភាពស្តីពីយេនឌ័ររបស់ UNEP អាចទាញយកបានពីគេហទំព័រនេះ៖ www.unep.org/civil_society/PDF_docs/Unep-Gender-Action-Plan-5Feb07.pdf

## ករណីសិក្សាទី៣៖

# ផែនការសកម្មភាពយេនឌ័រនៃអនុសញ្ញាស្តីពីជីវចម្រុះ

អនុសញ្ញាស្តីពីជីវចម្រុះ (CDB) គឺជាអនុសញ្ញាអន្តរជាតិស្តីពីបរិស្ថានមួយ ដែលត្រូវបានគេចុះហត្ថលេខាចូលជាសមាជិកយ៉ាងទូលំទូលាយនៅលើពិភពលោកជាមួយនឹងសមាជិក១៩០ប្រទេស។ ការចូលជាសមាជិក ត្រូវបានបើកឱ្យចុះហត្ថលេខានៅឯជំនួបប្រជុំកំពូលស្តីពីផែនដី នៅទីក្រុងរីអូឌេជិន៉េរ៉ូ (Rio de Janeiro) កាលពីឆ្នាំ១៩៩២ ហើយអនុសញ្ញាស្តីពីជីវចម្រុះ គឺជាគោលការណ៍អន្តរជាតិមួយសម្រាប់កិច្ចការពារ និងនិរន្តរភាពនៃការប្រើប្រាស់ជីវចម្រុះ និងសមធម៌នៃការចែករំលែកផលប្រយោជន៍។

អគ្គលេខាធិការរបស់អនុសញ្ញាស្តីពីជីវចម្រុះបានផ្តល់ភាពសំខាន់ជាអនេកលើភាពជាក់ស្តែងដែលថា សមភាពយេនឌ័រ គឺជាកិច្ចការចម្បង សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងចីរភាពនៃការងារអភិវឌ្ឍ។ ជីវភាពរបស់អ្នកជនបទ និងជនជាតិភាគតិច និងអ្នកសហគមន៍ដែលរស់នៅក្នុងភាពក្រីក្រ ជានិច្ចជាកាល គឺមានភាពជិតស្និទ្ធទៅនឹងការប្រើប្រាស់ និងអភិរក្សជីវចម្រុះ។ នៅក្នុងសហគមន៍ទាំងអស់ ស្ត្រីមានតួនាទីចម្បងមួយក្នុងការថែរក្សាគ្រួសារនិងសហគមន៍របស់ខ្លួន ក្នុងការចែករំលែកនូវចំណេះដឹង ធនធានសង្គម និងក្នុងការគាំពារនិងគ្រប់គ្រងធនធានជីវចម្រុះទាំងឡាយ។ នៅក្នុងសង្គមជាច្រើន ស្ត្រីក៏ដូចជាបុរសផងដែរ គឺជាភ្នាក់ងារនៃការផ្លាស់ប្តូរ ប៉ុន្តែការចូលរួមរបស់ពួកគាត់ទៅក្នុងកិច្ចការនេះពុំទទួលបាននូវការទទួលស្គាល់ស្មើគ្នានោះឡើយ។ សមភាពយេនឌ័ររវាងបុរសនិងស្ត្រី មានអនុភាពបន្ថែមលើភាពចម្រើននៃការថែរក្សា និងគ្រប់គ្រងជីវចម្រុះ និងការកាត់បន្ថយភាពក្រីក្ររបស់សហគមន៍ទាំងឡាយ។

សេចក្តីប្តេជ្ញាចិត្តរបស់អនុសញ្ញាស្តីពីជីវចម្រុះ ដើម្បីដាក់បញ្ចូលគោលការណ៍ យេនឌ័រ ទៅក្នុងគ្រប់វិស័យការងាររបស់ខ្លួន គឺចាប់ផ្តើមឡើង កាលពីខែមីនា ឆ្នាំ២០០៧ នៅពេលដែលអគ្គលេខាធិការរបស់ CDB បានតែងតាំងជនបង្គោលយេនឌ័រមួយរូបជាមួយនឹងកិច្ចការផ្ទៃក្នុង។ បន្ទាប់ពីនោះមកអគ្គលេខាធិការនៃអនុសញ្ញានេះ និងអ្នកផ្តល់ប្រឹក្សាយេនឌ័រជាន់ខ្ពស់របស់សហគមន៍អន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិបានធ្វើសិក្ខាសាលាមួយ ឡើងដើម្បីបញ្ជាក់ពីផែនការសកម្មភាពយេនឌ័ររបស់អនុសញ្ញាស្តីពីជីវចម្រុះ។

ផែនការសកម្មភាពយេនឌ័រ របស់អនុសញ្ញាស្តីពីជីវចម្រុះត្រូវបានព្រាងឡើងដោយផ្អែកលើមូលដ្ឋាននៃ៖ ការវិភាគលើការងារ បច្ចុប្បន្នភាពរបស់ CDB លើផ្នែកយេនឌ័រ និងជីវចម្រុះ ការស្ទាបស្ទង់មួយដែលបានធ្វើឡើងក្នុងចំណោមបុគ្គលិករបស់ CDB ទាំងអស់ និងសិក្ខាសាលាមួយជាមួយនឹងបុគ្គលិកមកពីផ្នែកផ្សេងៗ នៅក្នុងអគ្គលេខាធិការដ្ឋាន។ អនុសញ្ញាស្តីពីជីវចម្រុះនិងជាមួយសិក្ខាកាមដែលជាអ្នកមានបច្ចេកទេសមកពីកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ UNEP អង្គការអភិវឌ្ឍនិងបរិស្ថានរបស់ស្ត្រី WEDO កម្មវិធីហិរញ្ញវត្ថុខ្នាតតូចនៃកម្មវិធីជំនួយខ្នាតតូចនៃមូលនិធិបរិស្ថានពិភពលោក (GEF-SGP) និងកម្មវិធីអភិវឌ្ឍសហប្រជាជាតិ។ ផែនការសកម្មភាពនេះ ក៏យោងទៅលើការពិនិត្យឡើងវិញនៃការអនុវត្តផែនការសកម្មភាពដទៃផ្សេងទៀតរបស់ស្ថាប័នដូចគ្នានេះ និងដៃគូអន្តរជាតិផ្សេងៗ រួមទាំងសហគមន៍អន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ និងកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ។

ផែនការសកម្មភាពនេះ កំណត់នូវតួនាទីដែលអគ្គលេខាធិការដ្ឋានអនុសញ្ញាស្តីពីជីវចម្រុះ នឹងដើរតួក្នុងការជំរុញនិងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងទាំងឡាយ ទាំងនៅក្នុងស្ថាប័ននិងជាមួយដៃគូនៅថ្នាក់ជាតិ តំបន់ និងសកលដើម្បីដោះស្រាយឧបសគ្គទាំងពួង និងទាញយកនូវផលចំណេញ លើឱកាសដើម្បីលើកកម្ពស់សមភាពយេនឌ័រ។ ផែនការនេះ ក៏ជាការឆ្លុះបញ្ចាំងពីការកើនឡើងនៃការយល់ដឹងផងដែរ ដែលសមភាពយេនឌ័រ និងការផ្តល់អំណាចដល់

ស្ត្រី គឺជាសេចក្តីត្រូវការសំខាន់ដំបូងគេសម្រាប់ការគាំពារបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព។

ផែនការសកម្មភាពនេះ ត្រូវបានបង្ហាញជូនដល់គណៈប្រតិភូនាកិច្ចប្រជុំលើកទី៦ ក្រុមការងារស្តីពីការទទួលបាន និងចែករំលែកអត្ថប្រយោជន៍ (WGABS6) និងបន្ទាប់មកសេចក្តីយល់ព្រមលើផែនការសកម្មភាពយេនឌ័រ ត្រូវបានបង្កើតឡើងសម្រាប់ជាគោលការណ៍សម្រេចចិត្តនៃសន្និសីទភាគីលើកទី៩ (COP 9) អនុសញ្ញាស្តីពីជីវចម្រុះដែលបានប្រារព្ធធ្វើឡើងនៅទីក្រុងប៊ន នាថ្ងៃទី១៩ ទៅ៣០ ខែមេសា ឆ្នាំ២០០៨។ សេចក្តីសម្រេចចិត្តរបស់សន្និសីទភាគី លើកទី៩ មានន័យដូចតទៅ៖ "សន្និសីទលើកទី៩ របស់គូភាគីនេះ សូមស្វាគមន៍ដល់ការងារអភិវឌ្ឍដោយលេខាធិការដ្ឋាន ប្រតិបត្តិនៃផែនការសកម្មភាពយេនឌ័ររបស់អនុសញ្ញាស្តីពីជីវចម្រុះ (UNEP/CBD/COP/9/INF/Rev.1) និងសូមអញ្ជើញគូភាគីទាំងអស់ឱ្យជួយគាំទ្រដល់ការអនុវត្តផែនការសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន"។

ផែនការសកម្មភាពនេះមានទិសដៅសម្រេចនូវយុទ្ធសាស្ត្របួនគឺ ៖

- ដើម្បីបញ្ជ្រាបកិច្ចការងារយេនឌ័រ ទៅក្នុងការអនុវត្តអនុសញ្ញានេះ និងការងារទាក់ទិននឹងអគ្គលេខាធិការដ្ឋានអនុសញ្ញាស្តីពីជីវចម្រុះ។
- ដើម្បីលើកកម្ពស់សមភាពយេនឌ័រ ដើម្បីសម្រេចបាននូវទិសដៅទាំងបីរបស់ CBD និងគោលដៅជីវចម្រុះឆ្នាំ២០១០។
- ដើម្បីបង្ហាញពីផលប្រយោជន៍នៃការបញ្ជ្រាបយេនឌ័រទៅក្នុងកិច្ចការអភិរក្សជីវចម្រុះបម្រើបម្រាស់ដែលមានចីរភាព និងការចែករំលែកផលប្រយោជន៍ដែលបានមកពីការប្រើប្រាស់ពន្ធុធនធាន។
- និងដើម្បីឱ្យមានកំណើននៃប្រសិទ្ធភាពការងាររបស់អគ្គលេខាធិការដ្ឋានអនុសញ្ញាស្តីពីជីវចម្រុះ។

រយៈពេលអនុវត្តសកម្មភាព ដែលបានដាក់ឡើងទាំងអស់នេះ គឺចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១២។ អគ្គលេខាធិការដ្ឋានអនុសញ្ញាស្តីពីជីវចម្រុះបានធ្វើឱ្យមានដំណើរការនៃការអនុវត្តដោយ៖ ជាជំហានដំបូងគឺប្រមូលនិងចែកចាយទិន្នន័យទាក់ទងនឹងយេនឌ័រ និងជីវចម្រុះ។ ដំណាក់កាលទីពីរ គឺកំណត់និងបង្កើតវិធីសាស្ត្រ និងឧបករណ៍ជីវចម្រុះយេនឌ័រផ្សេងៗ។ ដំណាក់កាលទី៣ គឺកសាងសមត្ថភាពស្ត្រីជាពិសេសស្ត្រីជនជាតិភាគតិច ដើម្បីឱ្យពួកគេអាចចូលរួមក្នុងការសម្រេចចិត្ត និងដំណើរការរបស់ CBD និងនៅដំណាក់កាលទី៤ គឺបង្កើតឱ្យមានមូលដ្ឋានសម្រាប់គូភាគីរបស់ CBD អាចបញ្ជ្រាបយេនឌ័រក្នុងដំណើរការធ្វើផែនការជាតិស្តីពីជីវចម្រុះរបស់គេ។

សមិទ្ធផលមួយក្នុងចំណោមសមិទ្ធផលជាច្រើននោះ គឺជាការបង្កើតគេហទំព័រយេនឌ័រ និងជីវចម្រុះមួយនិងការបង្កើត និងចែកចាយសេចក្តីណែនាំពីការរួមបញ្ចូលគោលយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវចម្រុះជាតិ (NBSAPs)។

អត្ថបទទាំងស្រុង ស្តីពីផែនការសកម្មភាពយេនឌ័ររបស់ CBD អាចទាញយកបានពីគេហទំព័រ៖ www.cbd.int/doc/meetings/cop/cop-09/information/cop-09-inf-12-rev1-en.pdf

# ខ្ញុំមានអារម្មណ៍ថា...



**គោលបំណង ៖** សិក្ខាកាមទាំងអស់ណែនាំអំពីខ្លួនឯង

**សម្ភារៈ ៖** គ្មាន

**ដំណើរការ ៖**

១) ឱ្យសិក្ខាកាមគិតពីសត្វណាមួយដែលពួកគាត់គិតថាស្រដៀងគាត់បំផុត។

២) បន្ទាប់មក សួរពួកគាត់ម្នាក់ម្តងៗឱ្យរៀបរាប់អំពីសត្វនោះ និងបញ្ជាក់ថាហេតុអ្វីបានជាគាត់គិតថាសត្វនោះស្រដៀងគាត់បំផុត។ ពួកគាត់គួរតែត្រូវរៀបរាប់ពីឈ្មោះ និងបុគ្គលិកលក្ខណៈណាមួយរបស់សត្វនោះដែលពួកគាត់ចង់ចែករំលែកនៅក្នុងក្រុម។

៣) លំហាត់នេះ ជួយឱ្យសិក្ខាកាមបានចំណាំគ្នានិងស្វែងយល់បន្ថែមបន្តិចបន្តួចទៀតអំពីអត្តចរិត និងគុណភាពនៃមនុស្សក្នុងក្រុម។

# ឈ្មោះរបស់ខ្ញុំផ្តើមដោយ...



**គោលបំណង ៖** សិក្ខាកាមទាំងអស់ណែនាំអំពីខ្លួនឯង

**សម្ភារៈ ៖** គ្មាន

**ដំណើរការ ៖**

១) សួរសិក្ខាកាមឱ្យគិតពីបុគ្គលិកលក្ខណៈណាមួយដែលពួកគាត់មានដែលផ្តើមឡើងដោយតួអក្សរទីមួយនៃឈ្មោះរបស់គាត់ (ឧទាហរណ៍ ខ្ញុំឈ្មោះសុភាព ហើយខ្ញុំជាមនុស្សសុភាព)។

២) សួរពួកគាត់ម្នាក់ម្តងៗឱ្យរៀបរាប់អំពីឈ្មោះនេះទៅកាន់សមាជិកក្រុម។

៣) លំហាត់នេះជួយឱ្យសិក្ខាកាមបានចំណាំគ្នា និងស្វែងយល់បន្ថែមបន្តិចបន្តួចទៀតអំពីអត្តចរិត និងគុណភាពនៃមនុស្សក្នុងក្រុម។

## ចង់បាន

**គោលបំណង ៖** ជួយឱ្យសិក្ខាកាមស្គាល់គ្នាទៅវិញទៅមក និងណែនាំប្រធានបទយេនឌ័រ

**សម្ភារៈ ៖** ផ្ទាំងប្រកាស "ចង់បាន" សម្រាប់សិក្ខាកាមម្នាក់ៗ

**ដំណើរការ ៖**

១) ឱ្យសិក្ខាកាមបំពេញផ្ទាំងប្រកាស "ចង់បាន" ដោយយកគំរូតាមទម្រង់ដែលមាននៅទំព័របន្ទាប់។

២) សិក្ខាកាមត្រូវគូររូបរបស់ខ្លួន នៅក្នុងប្រអប់មួយដែលនៅខាងលើទំព័រ។ សិក្ខាកាមមិនត្រូវសរសេរឈ្មោះខ្លួនឯងលើផ្ទាំងប្រកាសទេ។

៣) ប្រមូលផ្ទាំងប្រកាសដែលបំពេញរួចហើយចែកផ្ទាំងទាំងនោះវិញ ដោយធ្វើឱ្យប្រាកដថាគ្មាននរណាម្នាក់ទទួលបានផ្ទាំងប្រកាសរបស់ខ្លួនឯងវិញឡើយ។

៤) សិក្ខាកាមត្រូវអានផ្ទាំងប្រកាសដែលគេទទួលបាន ហើយព្យាយាមសំគាល់រកថាតើអ្នកណាជាអ្នកសរសេរ?

៥) នៅពេលត្រូវបានរកឃើញហើយ អ្នកដែលបានបំពេញផ្ទាំងប្រកាសនោះត្រូវសរសេរឈ្មោះរបស់ខ្លួនលើផ្ទាំងនោះ ហើយបន្ទាប់មកឱ្យរង្វាន់អ្នករកឃើញ។

៦) បន្ទាប់មក ផ្ទាំងប្រកាសទាំងអស់គួរតែត្រូវបានយកទៅបិទលើជញ្ជាំងសម្រាប់មើល។

**សំគាល់៖** មានវិធីសាស្ត្រមានប្រយោជន៍ជាច្រើន ដើម្បីជំរុញឱ្យសិក្ខាកាមបានស្គាល់គ្នា។ វិធីសាស្ត្រមួយអាចជាការឱ្យពួកគាត់ធ្វើការជាគូ ហើយឱ្យគាត់ណែនាំខ្លួនឯង។ ប្រសិនក្នុងករណីដែលសិក្ខាកាមហាក់ដូចជាគ្របដណ្តប់សិក្ខាសាលា ឬចំណាយពេលយូរពេកក្នុងការណែនាំខ្លួន អ្នកសម្របសម្រួលអាចប្រើប្រាស់ "វិធីសាស្ត្រអុចឈើគូស" ដែលអ្នកបង្ហាញត្រូវអុចឈើគូសនៅពេលដែលគាត់កំពុងធ្វើបទបង្ហាញ។ ធ្វើបែបនេះ គឺអាចឱ្យសិក្ខាកាមទាំងអស់មានពេលវេលាស្មើគ្នា ហើយប្រហែលជាអាចមានប្រយោជន៍ជាពិសេសនៅពេលដែលដោះស្រាយជាមួយមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល។

# ចង់បាន

ចូរសរសេរពីអ្វីដែលអ្នកចូលចិត្តធ្វើដែលជាតំណាងយេនឌ័ររបស់អ្នក។

ចូរសរសេរពីអ្វីដែលអ្នកមិនចូលចិត្តធ្វើដែលជាតំណាងយេនឌ័ររបស់អ្នក។

ចូរសរសេរពីអ្វីដែលអ្នកចូលចិត្តធ្វើដែលមិនមែនជាតំណាងយេនឌ័ររបស់អ្នក។

ចូរសរសេរពីអ្វីដែលអ្នកមិនចូលចិត្តធ្វើដែលមិនមែនជាតំណាងយេនឌ័ររបស់អ្នក។

# រង្វាន់

(សូមសរសេរប្រភេទរង្វាន់សម្រាប់អ្នកដែលរកអ្នកឃើញ។)

# ណែនាំអំពីពាក្យទាំងឡាយទាក់ទងនឹងយេនឌ័រ




**គោលបំណង ៖** ណែនាំអំពីគំនិត ឬទស្សនទានទាក់ទងនឹងយេនឌ័រ

**សម្ភារៈ ៖** ពាក្យនិងនិយមន័យប្រអប់មួយ និងស្កុតមុខពីរមួយដុំ

**ដំណើរការ ៖**

១) មុនពេលចាប់ផ្តើមចូរសរសេរពាក្យ និងនិយមន័យទាំងពួងរបស់យេនឌ័រនៅលើក្រដាសផ្សេងៗគ្នា (សូមមើលប្រអប់ខាងក្រោម)។

២) ដាក់ក្រដាសទាំងអស់នៅក្នុងប្រអប់មួយ។

៣) ចូរពន្យល់ប្រាប់សិក្ខាកាមថា កិច្ចការនេះគឺធ្វើឡើងដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់ពួកគាត់ទៅលើពាក្យទាក់ទងនឹងយេនឌ័រមួយចំនួន។

៤) អញ្ជើញសិក្ខាកាមទាំងអស់ឱ្យជ្រើសរើសសន្លឹកក្រដាសមួយពីក្នុងប្រអប់។ បន្ទាប់មកពួកគាត់ត្រូវដើរជុំវិញបន្ទប់ដើម្បីស្វែងរកពាក្យ ឬក៏និយមន័យណាដែលស៊ីគ្នានឹងអ្វីដែលបានសរសេរក្នុងក្រដាសរបស់ពួកគាត់។

៥) ក្នុងនាមជាអ្នកសម្របសម្រួល ចូរផ្តល់នូវជំនួយប្រសិនបើមានសំនួរ។

៦) នៅពេលដែលសិក្ខាកាមទាំងអស់បានសម្រេចលើការជ្រើសរើសរបស់ពួកគាត់ ហើយចូរឱ្យគាត់បិទគូដែលរើសបាននៅទីតាំងណាមួយដែលអ្នករាល់គ្នាអាចមើលឃើញ។

៧) ចូរមើលនិយមន័យនិងពាក្យនីមួយៗដោយកែកំហុស និងឆ្លើយនូវសំនួរទាំងឡាយណាដែលមាន។

៨) នៅចុងក្រោយ ចូរសួរសិក្ខាកាមទាំងអស់ ថាតើពួកគាត់មានគំនិតដទៃណាផ្សេងទៀតដែលគាត់ចង់ឱ្យមានការបកស្រាយ និងថាតើគាត់បានយល់ដឹងអ្វីខ្លះពីកិច្ចការនេះ?

## និយមន័យ និងពាក្យទាក់ទងនឹងយេនឌ័រ

**យេនឌ័រ** សំដៅដល់តួនាទី ការទទួលខុសត្រូវ សិទ្ធិ ទំនាក់ទំនង និងអត្តសញ្ញាណរបស់ស្ត្រី និងបុរសដែលបានបែងចែក ឬផ្តល់ឱ្យដោយសង្គម និងបរិបទ - និងថាតើតួនាទី ការទទួលខុសត្រូវ សិទ្ធិ ទំនាក់ទំនង និងអត្តសញ្ញាណរបស់ស្ត្រី និងបុរសទាំងអស់នេះមានអំណាច និងឥទ្ធិពលលើគ្នាទៅវិញទៅមកយ៉ាងដូចម្តេច? តួនាទីទាំងអស់នេះ អាចផ្លាស់ប្តូរបានទៅតាមពេលវេលាទាំងក្នុង និងក្រៅផ្ទះ?

**ការបែងចែកពលកម្មទៅតាមភេទ** ទាក់ទិនទៅនឹងការបែងចែកការងារ និងទំនួលខុសត្រូវរបស់ស្ត្រី និងបុរសនៅផ្ទះ កន្លែងការងារ និងក្នុងសង្គមដោយយោងទៅលើប្រភេទនៃការងារដែលត្រូវបានយល់ថាអាចទទួលយកបានតាមពេលវេលា និងកន្លែងជាក់លាក់ណាមួយ។

**សមភាពយេនឌ័រ** គឺជាភាពស្មើគ្នានៃសិទ្ធិ យោបល់ ទំនួលខុសត្រូវនិងឱកាសសម្រាប់បុរស និងស្ត្រីទាំងនៅក្នុងសង្គម កន្លែងការងារ និងក្នុងផ្ទះ។

**សមធម៌យេនឌ័រ** សំដៅដល់ភាពមានយុត្តិធម៌ រវាងស្ត្រី និងបុរសក្នុងការទទួលបានធនធាន រង្វាន់ និងឱកាសរបស់សង្គម រួមទាំងទំនិញមានតម្លៃរបស់សង្គម។

**គម្លាតយេនឌ័រ** សំដៅដល់ភាពខុសគ្នាផ្នែកសង្គមទាំងឡាយរវាងស្ត្រី និងបុរសដែលត្រូវបានយល់ថាមិនគប្បី។

**ការបញ្ជ្រាបយេនឌ័រ** សំដៅដល់ការពិចារណាបញ្ហាដែលទាក់ទងនឹងសមភាពយេនឌ័រនៅក្នុងសកម្មភាពហិរញ្ញវត្ថុ រដ្ឋបាល កម្មវិធី និងគោលនយោបាយទាំងឡាយ និងនៅក្នុងគ្រប់ដំណើរការរៀបចំទាំងអស់ដែលនៅចុងក្រោយអាចឈានទៅដល់ការចូលរួមផ្លាស់ប្តូរនៃកិច្ចការរៀបចំស្ថាប័ន។

**តួនាទីយេនឌ័រ** សំដៅថាតើស្ត្រី និងបុរសគួរតែគិត និងមានអារម្មណ៍បែបណា យោងទៅតាមបទដ្ឋាន និងប្រពៃណីនៅក្នុងកន្លែង និងពេលវេលាជាក់លាក់ណាមួយ?

**តម្លៃយេនឌ័រក្នុងការងារ** សំដៅដល់តម្លៃរបស់សេដ្ឋកិច្ច និងសង្គមទាំងឡាយណាដែលផ្សាភ្ជាប់ទៅនឹងការងារ និងទំនួលខុសត្រូវខុសគ្នារបស់ស្ត្រី និងបុរស។

**ការទទួលបានរបស់យេនឌ័រ** លើធនធានសម្ភារៈ សេវាកម្ម ប្រាក់កាក់ ផលប្រយោជន៍ និងការសម្រេចចិត្តសំដៅដល់ភាពខុសគ្នារវាងឱកាស និងសិទ្ធិរបស់ស្ត្រី និងបុរសក្នុងការប្រើប្រាស់ធនធានទាំងឡាយនេះ និងការចូលរួមក្នុងដំណើរការនៃការសម្រេចចិត្តអាស្រ័យទៅលើបទដ្ឋាន និងតម្លៃដែលមាននៅក្នុងកន្លែង និងពេលវេលាជាក់លាក់ណាមួយ។

**ការគ្រប់គ្រងរបស់យេនឌ័រ** លើធនធាន និងដំណើរការនៃការសម្រេចចិត្តសំដៅដល់ភាពខុសគ្នារវាងអំណាច និងសិទ្ធិរបស់ស្ត្រី និងបុរសក្នុងការសម្រេចចិត្តប្រើប្រាស់ធនធានទទួលបានផលប្រយោជន៍ និងចូលរួមក្នុងដំណើរការនៃការសម្រេចចិត្តទាំងឡាយអាស្រ័យទៅលើបទដ្ឋាននិងតម្លៃដែលមាននៅក្នុងសង្គមមួយ។

**ទស្សនទានយេនឌ័រ** មានន័យថា៖

- ភាពផ្សេងគ្នានៃតម្រូវការ និងអាទិភាពរបស់ស្ត្រី និងបុរសត្រូវបានធ្វើឡើង។
- គំនិត និងការយល់ឃើញរបស់ស្ត្រី និងបុរសត្រូវបានយកចិត្តទុកដាក់យ៉ាងមធ្យ័ត។
- សេចក្ដីសន្និដ្ឋាននៃការសម្រេចចិត្តលើស្ថានភាពរបស់ស្ត្រីបើធៀបទៅនឹងបុរសត្រូវបានពិចារណា៖ ថាតើអ្នកណាចាញ់ ហើយអ្នកណាឈ្នះ?
- ការចាត់ការត្រូវបានធ្វើឡើងដើម្បីដោះស្រាយបញ្ហាវិសមភាព ឬភាពមិនស្មើគ្នារវាងស្ត្រី និងបុរស។

**ភេទ** សំដៅដល់ជីវសាស្ត្រធម្មជាតិនៃភាពជាមនុស្សប្រុស ឬស្រី។ លក្ខណៈធម្មជាតិនៃភាពជាមនុស្សប្រុស និងស្រីទាំងនេះគឺទូទៅនឹងប្រាកដ។

**តួនាទីភេទ** គឺជាអ្វីដែលនៅជាប់ទាក់ទងនឹងភេទជាក់លាក់ណាមួយអាស្រ័យទៅលើកត្តាជីវសាស្ត្រទាំងឡាយ ឧទាហរណ៍ ការផ្ដល់កំណើត។

**ការផ្ដល់អំណាចស្ត្រី** សំដៅដល់ដំណើរការមួយដែលស្ត្រីធ្វើការឆ្លុះបញ្ចាំងលើភាពជាក់ស្ដែងរបស់ខ្លួន និងចោទសួរហេតុផលនៃស្ថានភាពរបស់ខ្លួននៅក្នុងសង្គម។ វារួមបញ្ចូលនូវការបង្កើតមធ្យោបាយជាច្រើនផ្សេងគ្នា និងចាប់យកឱកាសដើម្បី ដោះស្រាយបញ្ហាវិសមភាពដែលកំពុងកើតមាន។ ការផ្ដល់អំណាចដល់ស្ត្រីក៏អាចឱ្យពួកគាត់រស់នៅដោយមានសមត្ថភាព និងជម្រើសពេញលេញដោយខ្លួនឯងស្របទៅតាមសិទ្ធិមនុស្ស។ នៅក្នុងសេចក្ដីថ្លែងការណ៍ទីក្រុងប៉េជីងត្រូវបានគេយល់ស្របថា "ការផ្ដល់អំណាចដល់ស្ត្រី និងការចូលរួមពេញលេញរបស់គាត់ដោយផ្អែកលើស្មារតីសមភាពនៅគ្រប់វិស័យរបស់សង្គម រួមមានការចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត និងការទទួលបាននូវអំណាច គឺមានភាពចាំបាច់ណាស់សម្រាប់ភាពជោគជ័យនៃសមភាព ការអភិវឌ្ឍ និងសន្តិសុខ"៕[១]

*ប្រភព៖ UNDP. (2007). Gender Mainstreaming: a Key Driver of Development in Environment and Energy. USA: UNDP.*

## បាយមួយចាន[១]



**គោលបំណង ៖** បង្ហាញពីគំនិតនៃសមធម៌

**សម្ភារៈ ៖** បាយមួយចាន (ឬក៏រូបភាព ឬផ្ទាំងគំនូរបាយមួយចាន)

**ដំណើរការ ៖**

១) ចូររើសមនុស្សពីរនាក់ (បុរសម្នាក់ និងស្ត្រីម្នាក់ប្រសិនបើអាច) ហើយប្រាប់គាត់នូវឧទាហរណ៍ខាងក្រោម៖

"មានបុរសម្នាក់ខិតខំធ្វើការងារខ្លាំងសម្បើមណាស់ ហើយគាត់មានកិច្ចការច្រើន។ គាត់ត្រូវក្រោកពីព្រឹកដើម្បីទៅធ្វើការដោយព្យាយាមធ្វើការងារឱ្យខ្លាំងតាមដែលអាចធ្វើទៅបាន។ គ្មាននរណាម្នាក់អាចជួយគាត់បានទេ។ គាត់សម្រាកមិនគ្រប់ គ្មានពេលវេលាដើម្បីលេងកីឡាឡើយ ហើយគាត់ពិសាអ្វីក៏មិនឆ្ងាញ់ផង។

១. វិធិសាស្ត្រនេះត្រូវបានបង្កើតឡើងដោយ ប្រីជីត ឡេដ៉ុក (Brigitte Leduc) នៃមជ្ឈមណ្ឌលអន្តរជាតិសម្រាប់សមាហរណកម្មការងារ អភិវឌ្ឍភ្នំ (ICIMOD)។

ដែរ។ នៅព្រឹកនេះ គាត់ឋិតក្នុងសភាពប្រញ៉ាប់ប្រញាល់ខ្លាំងរហូតគ្មានពេលដើម្បីទទួលទានអាហារពេលព្រឹក។ យ៉ាងណាក៏ដោយមានតែបាយទេដែលនៅសល់តែគាត់ត្រូវការគុយទាវ។ អាចនិយាយបានថាបុរសនេះគឺអស់កម្លាំងហើយ។”

“នារីម្នាក់នេះ មានរូបរាងស្អាតសមម្យេនិងរឹងមាំណាស់! នាងធ្វើលំហាត់ប្រាណជារៀងរាល់ព្រឹកហូបបាននិងសំរាកក៏បាន។ នាងក៏ធ្វើការដែរ ប៉ុន្តែមិនច្រើនពេកនោះទេដោយសារមានអ្នកផ្សេងទៀតជួយ។ ព្រឹកនេះនាងបានពិសាអាហារយ៉ាងឆ្ងាញ់ គឺបាយ! នេះជាអាហារដែលនាងចូលចិត្ត!”

“ឥឡូវនេះ ខ្ញុំនឹងទៅប្រហែលជា៥០០ ម៉ែត្រពីបុរសនិងនារីម្នាក់នេះ ហើយខ្ញុំនឹងដាក់ចានបាយមួយចានធំនៅចន្លោះពួកគាត់ទាំងពីរ។ បាយនេះ គឺសម្រាប់គាត់ទាំងពីរនោះឯង មិនមានការរើសអើងនោះឡើយ។”

**សំគាល់៖** ដើម្បីឱ្យសិក្ខាកាមចាប់អារម្មណ៍គួរលើកយកឧទាហរណ៍ស្ត្រីជាបុគ្គលដែលមានឥទ្ធិពល និងបុរសជាបុគ្គលទន់ខ្សោយ។ មនុស្សទាំងពួងនឹងអាចវាយតម្លៃស្ថានភាពនេះដោយងាយដោយមិនមានបុរេវិនិច្ឆ័យឡើយ។ ប្រសិនបើអ្នកយកបុរសទៅដាក់ក្នុងស្ថានភាពមានអំណាចវិញ ពួកគាត់នឹងព្យាយាមបកស្រាយកែប្រែស្ថានភាពរបស់បុរសនេះជាជាងវាយតម្លៃស្ថានការណ៍ នេះដោយមិនលំអៀង។

២) ចូរសួរសិក្ខាកាមនូវសំណួរដូចខាងក្រោម៖

- “តើអ្នកគិតថានឹងមានរឿងអ្វីកើតឡើង?”

**ចម្លើយដែលអាចទៅរួច៖**

- “នារីនោះនឹងទៅដល់មុន៖ នាងអាចរត់លឿនជាងបុរសខណៈពេលដែលបុរសនោះ ល្វិតល្វៃ និងមិនរឹងមាំ។”
- “នារីនោះនឹងទៅដល់មុន និងប្រហែលជាអាចហូបបាយនោះជិតអស់ប្រសិនបើគាត់ហូបមិនអស់។ នារីនេះគាត់ចូលចិត្តបាយខ្លាំងណាស់នៅពេលដែលបុរសនោះចូលចិត្តគុយទាវ។ ក្នុងករណីដែលនាងមិនបានដឹងអំពីស្ថានភាពចាញ់ប្រៀបគេ នាងប្រហែលជានឹងមិនបន្សល់ទុកបាយនោះឡើយ។”

**សំណួរសំខាន់ៗ៖**

- “តើស្ថានភាពនេះយុត្តិធម៌ដែរឬទេ?”
- “ហេតុអ្វីបានជាវាមិនយុត្តិធម៌?”

(ចូររំលឹកសិក្ខាកាមទាំងអស់ថា វាមិនមានការលំអៀងឡើយ - ចានបាយនោះ គឺត្រូវបានដាក់នៅទីតាំងមួយដែលអ្នកទាំងពីរអាចមកយកបាន)។

**សំណួរសំខាន់៖**

- “បើដូច្នេះ តើយើងអាចធ្វើអ្វីបានដើម្បីឱ្យស្ថានការណ៍នេះមានយុត្តិធម៌?”

**ចម្លើយដែលអាចទៅរួចៈ**

- “ធ្វើឱ្យបុរសនោះមកដល់ចានបាយមុន ឬដាក់ចានឱ្យនៅកៀកគាត់បន្តិច។”
- “រំលែកបាយនៅក្នុងចានជាពីរចំណែកស្មើគ្នាដែលមួយចំណែកសម្រាប់បុរស និងមួយទៀតសម្រាប់នារី។”
- “ឱ្យនារីនោះបានដឹងថា បុរសម្នាក់នេះមិនបានទទួលទានអាហារពេលព្រឹកឡើយ ដូច្នេះនារីនោះគាត់ត្រូវតែចែករំលែកបាយជាមួយគាត់ ហើយប្រហែលជានឹងអាចទុកបាយច្រើនឱ្យបុរស។”
- “ព្យាយាមរកមធ្យោបាយមួយដើម្បីសម្រាលការងាររបស់បុរសនោះ”។
- “ឱ្យបុរសនោះមានពេលទំនេរខ្លះដើម្បីឱ្យគាត់អាចធ្វើលំហាត់ប្រាណបាន ដូច្នេះគាត់នឹងអាចមានរូបរាងមាំទាំជាងមុន និងអាចប្រកួតប្រជែងជាមួយនារីនោះបាន”។
- “ស្នើឱ្យមានទាំងគុយទាវ និងបាយដើម្បីឆ្លើយតបទៅនឹងការចង់បានរបស់អ្នកទាំងពីរ។ ប្រសិនបើសំណើនេះមិនអាចទៅរួច ប្រហែលជាយើងគួរមានត្រឹមតែគុយទាវវិញ ពីព្រោះបុរសនេះហាក់ដូចជាមានតម្រូវការហូបគុយទាវខ្លាំងជាងនារីនោះ។

**សំគាល់៖** សូមបញ្ជាក់ថា ដំណោះស្រាយដែលអាចទៅរួចទាំងអស់នេះ គឺជាអ្វីដែលយើងហៅថា “សកម្មភាពវិជ្ជមាន” ដែលមានគោលបំណងធ្វើឱ្យស្ថានការណ៍នេះមានភាពយុត្តិធម៌ និងសមធម៌ជាង។ ដំណោះស្រាយទាំងអស់នេះ យកចិត្តទុកដាក់ទៅលើការជាក់ស្តែងដែលមានមនុស្សខ្លះមិនមានឱកាសដើម្បីទទួលបាននូវធនធានទាំងឡាយ។ សមភាពអាចនឹងមិនមាន នៅខណៈដែលមនុស្សរាល់គ្នាមិនមានឱកាសដូចគ្នា។

# វិភាគគម្លាត/ភាពខុសគ្នានៃយេនឌ័រ



**គោលបំណង ៖** បង្ហាញពីគម្លាត/ភាពខុសគ្នានៃយេនឌ័រ និងយល់ដឹងពីមូលហេតុនិងដំណោះស្រាយមួយចំនួន

**សម្ភារៈ ៖** សន្លឹកកិច្ចការទី១ ៖ វិភាគគម្លាត/ភាពខុសគ្នានៃយេនឌ័រ ប៊ិច ហ្វឺត និងផ្ទាំងគំនូររូបភាព

**ដំណើរការ ៖**

១) ចូរចែកសិក្ខាកាមទាំងអស់ជាក្រុមផ្សេងគ្នា ហើយតែងតាំងប្រធានក្រុមនីមួយៗ។

២) អញ្ជើញប្រធានក្រុមនីមួយៗអានខ្លឹមសារទាំងអស់។

៣) ប្រសិនបើសិក្ខាកាមដឹងពីគម្លាតយេនឌ័រដទៃទៀត ពួកគាត់អាចបញ្ចូលចំណុចទាំងនេះទៅក្នុងបញ្ជី។

៤) ចូរសួរក្រុមទាំងអស់ឱ្យរកនូវមូលហេតុនៃគម្លាតយេនឌ័រ និងវិធានការដែលអាចទៅរួចដើម្បីដោះស្រាយបញ្ហានេះ។ សិក្ខាកាមគួរតែសរសេរនូវចម្លើយទាំងអស់របស់ខ្លួន នៅលើផ្ទាំងគំនូររូបភាពដែលបានចែកជូន។

៥) ចូរអញ្ជើញក្រុមទាំងអស់ឱ្យបង្ហាញសមិទ្ធផលរបស់ខ្លួន។ ប្រសិនជាអាចទៅរួច ចូរផ្តល់នូវព័ត៌មានបន្ថែមលើមូលហេតុ និងវិធីសាស្ត្រទាំងឡាយដែលមានដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហានេះ។

៦) ជាចុងក្រោយ ចូរសួរសិក្ខាកាមទាំងអស់ថា តើគាត់បានយល់ដឹងអ្វីខ្លះពីកិច្ចការនេះ?។

**សំគាល់៖** ប្រសិនបើពេលវេលាមានកំណត់ អ្នកសម្របសម្រួលអាចរៀបចំលំហាត់មួយនៅក្នុងបទបង្ហាញ ដើម្បីបង្ហាញក្រុមទាំងអស់ ហើយបង្កើតឱ្យមានការពិភាក្សា។ ឧទាហរណ៍នៃលំហាត់ស្តីពីយេនឌ័រនេះ គឺជាលំហាត់លើយេនឌ័រនៃគោលដៅអភិវឌ្ឍសហស្សវត្សរ៍របស់អង្គការអ៊ុកហ្វាម ឆ្នាំ២០០៧ ដែលអាចទាញយកបានពីគេហទំព័រ៖

http://www.oxfam.org.uk:80/generationwhy/do_something/campaigns/healthandeducation/quiz/index.htm

វាជាការសំខាន់ដែលអ្នកសម្របសម្រួល ដាក់បញ្ចូលព័ត៌មានជាតិនិងតំបន់ស្តីពីយេនឌ័រទៅក្នុងការវាយតម្លៃគម្លាត/ភាពខុសគ្នានៃយេនឌ័រដើម្បីជំរុញការពិភាក្សា និងធ្វើឱ្យស្របនឹងបរិបទ។ សូមចងចាំស្រង់ឯកសារយោង សម្រាប់ព័ត៌មានដែលបានបង្ហាញ (ព័ត៌មានជាក់លាក់សម្រាប់តំបន់និងប្រទេស មានទុកក្នុងរបាយការណ៍ពិភពលោកស្តីពីគម្លាតយេនឌ័រ៖ www.weforum.org/en/initiatives/gcp/Gender Gap/index.htm)

## ប្រអប់១ គម្លាត/ភាពខុសគ្នានៃយេនឌ័រ

យោងតាមទិន្នន័យដែលអាចជឿទុកចិត្ត បានបង្ហាញថាប្រមាណ ៧០% នៃអ្នកដែលមានកម្រិតជីវភាពរស់នៅក្រោមមួយដុល្លារក្នុងមួយថ្ងៃ គឺជាស្ត្រី។

ស្ត្រីធ្វើការ ២/៣ នៃម៉ោងការងាររបស់ពិភពលោក ប៉ុន្តែទទួលបានត្រឹមតែ ១០% នៃចំណូលរបស់ពិភពលោកប៉ុណ្ណោះ។

ក្នុងពិភពលោកស្ត្រីគ្រប់គ្រងអចលនទ្រព្យមានត្រឹមតែ ១% ប៉ុណ្ណោះ ។

ស្ត្រីជាសមាជិកសភាជុំវិញពិភពលោកមានប្រមាណជា ១៧% ប៉ុណ្ណោះនៃចំនួនកៅអីទាំងអស់។

ស្ត្រីជារដ្ឋមន្ត្រីនៃគណៈរដ្ឋមន្ត្រីទូទាំងពិភពលោក មានត្រឹមតែ ៨% ប៉ុណ្ណោះ។

៧៥%ភាគរយ នៃមនុស្សពេញវ័យចំនួន ៨៧៦លាននាក់នៅក្នុងពិភពលោកដែលមិនចេះអក្សរ គឺជាស្ត្រី។

ទូទាំងពិភពលោក ស្ត្រីបានទទួលត្រឹមតែ ៧៨% ប៉ុណ្ណោះនៃប្រាក់ឈ្នួលដែលបុរសទទួលបានចំពោះការងារដូចគ្នា បើទោះជានៅតំបន់មួយចំនួនស្ត្រីមានការអប់រំខ្ពស់ជាងបុរសក៏ដោយ។ ផ្នែកខ្លះនៃពិភពលោក គម្លាតប្រាក់ឈ្នួលរវាងស្ត្រីនិងបុរស គឺក្បែរនឹង៤០%។

នៅក្នុងចំណោមកម្មករ ៥៥០ លាននាក់ទូទាំងពិភពលោកដែលមានប្រាក់កម្រៃទាប ស្ត្រីមានចំនួនរហូតដល់ ៣៣០ លាននាក់ ឬ ៦០%។

មានករណីមួយបានរកឃើញថា នៅក្នុងប្រទេសចំនួន ១៤១ ក្នុងកំឡុងឆ្នាំ ១៩៨១ ដល់ ២០០២ គ្រោះមហន្តរាយធម្មជាតិ (និងឥទ្ធិពលរបស់វា) ជាមធ្យមសម្លាប់ស្ត្រីច្រើនជាងបុរស ឬក៏សម្លាប់ស្ត្រីវ័យក្មេងជាងបុរស។

*ប្រភព៖ Social Watch, 2007 and2008; Oxfam, 2007; Neumayer and Plümper, 2007; and ILO, 2008.*

# យល់ដឹងអំពីវិសមភាព






**គោលបំណង ៖** បង្ហាញពីគម្លាតខុសគ្នាដែលមនុស្សមានអាស្រ័យទៅតាមឋានៈ តួនាទីក្នុងសង្គម និងយេនឌ័ររបស់គេ។

**សម្ភារៈ ៖** រៀបចំកាតមួយចំនួនដែលពិពណ៌នាអំពីតួនាទីផ្សេងៗគ្នា ដែលមនុស្សរាល់គ្នាដើរតួនៅក្នុងសហគមន៍/សង្គម/រដ្ឋាភិបាល៖ ឧទាហរណ៍ "ប្រធានភូមិស្ត្រីមេម៉ាយ កសិករ-កម្មករ ប្រពន្ធកសិករ-កម្មករ" ។ល។ ធ្វើឱ្យតួនាទីទាំងអស់នេះ ស្របទៅនឹងបរិបទ តំបន់/ប្រទេសដែលសំដែង។ ហើយតួនាទីទាំងអស់នេះគួរតែគិតគូរដល់ភាពខុសគ្នានៃឋានៈផងដែរ។

**ដំណើរការ ៖**

១) អញ្ជើញសិក្ខាកាមឱ្យរើសកាតមួយពីក្នុងប្រអប់។ ជាមួយនឹងកាតទាំងអស់នេះចូរឱ្យពួកគាត់តម្រង់ជាជួរនៅកណ្តាលបន្ទប់ត្រង់ដែលអ្នកផ្សេងទៀតអាចមើលឃើញ។

២) ឱ្យសិក្ខាកាមឈានមួយជំហានមកមុខសម្រាប់ចម្លើយស្រប និងមួយជំហានថយក្រោយសម្រាប់ចម្លើយអវិជ្ជមាន។

៣) សំនួរគួរតែផ្តោតលើលក្ខណៈខុសគ្នាដែលម្ចាស់កាតមាននៅក្នុងតួនាទីតំណាងរបស់គាត់៖ ឧទាហរណ៍ ជាការឆ្លើយទៅនឹងសំណួរ "តើអ្នកមានអំណាចគ្រប់គ្រងលើអចលនទ្រព្យរបស់អ្នកទេ?" ឬ "តើអ្នកជាមនុស្សមានការអប់រំឬទេ? "ម្ចាស់កាតដែលមាននាទីជា "ប្រពន្ធកសិករ" ប្រហែលជានឹងត្រូវដើរថយក្រោយមួយជំហាន ខណៈពេលដែលម្ចាស់កាត "ប្រធានភូមិ" ត្រូវដើរទៅមុខមួយជំហាន។

៤) រៀបចំសំណួរឱ្យបានហ្មត់ចត់ យោងទៅលើតម្រូវការរបស់តំបន់/ប្រទេស។ អ្នកសម្របសម្រួលអាចពិចារណាប្រើប្រាស់វិធីសាស្ត្រនេះនៅពេលដែលសិក្ខាកាមជឿថា ទម្រង់នៃវិសមភាពគឺមិនមាននោះឡើយ។

**សំគាល់៖** អ្នកសម្របសម្រួល គួរតែរំលឹកសិក្ខាកាមទាំងអស់ម្តងទៀតថា ការយល់ដឹងអំពីឥទ្ធិពលផ្សេងៗគ្នារបស់យេនឌ័រ អាចឱ្យពួកគាត់ប្រឈមនឹងបញ្ហាប្រែប្រួលអាកាសធាតុ។

# ជំពូក ២

# លិខិតតូបករណ៍ច្បាប់អន្តរជាតិនានា ជាយន្តការសម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងការប្រែប្រួលអាកាសធាតុ[២]



*ក្នុងរយៈកាលបីទសវត្សរ៍កន្លងមកនេះ មានលិខិតតូបករណ៍ច្បាប់អន្តរជាតិជាច្រើនបានត្រូវបង្កើតឡើងដើម្បីធានាឱ្យមានសមភាពយេនឌ័រ និងភាពមិនរើសអើងប្រឆាំងនារីភេទ និងដើម្បីជ្រើសយកនូវវិធានការដែលទាក់ទងនឹងការអភិវឌ្ឍប្រកបដោយចីរភាព។ វិធានការ និងលិខិតតូបករណ៍ទាំងនោះរួមបញ្ចូលសេចក្តីថ្លែងការណ៍សន្និសីទអនុសញ្ញា ផែនការ សកម្មភាព ដំណោះស្រាយ និងកិច្ចព្រមព្រៀង។*

## *សារសំខាន់ៗ*

- អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ជាសន្ធិសញ្ញាអន្តរជាតិតែមួយគត់ក្នុងចំណោមអនុសញ្ញាទីក្រុងរីយ៉ូទាំងបីដែលមិនបានបញ្ចូលយេនឌ័រ
- សារៈសំខាន់នៃសិទ្ធិស្ត្រីតែងបានគាំពារដោយលិខិតតូបករណ៍អន្តរជាតិនានា (អនុសញ្ញាស៊ីដ ECOSOC Resolution 2005/31 សន្និសីទទីក្រុងប៉េកាំងដើម្បីសកម្មភាព)
- ការបញ្ជ្រាបយេនឌ័រទៅក្នុងការប្រែប្រួលអាកាសធាតុនិងគោលនយោបាយ - ជាពិសេស UNFCCC និងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) - មិនគ្រាន់តែជាបញ្ហានៃការស្ម័គ្រចិត្តទេ ប៉ុន្តែជាកាតព្វកិច្ចផ្លូវច្បាប់។

ការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់ទៅលើបរិស្ថាន សិទ្ធិមនុស្ស ការអភិវឌ្ឍប្រកបដោយចីរភាព សុខភាព និងគ្រប់វិស័យនៅក្នុងសង្គម។ សកម្មភាពជាវិជ្ជមាន ប្រសិនបើបានអនុវត្ត អាចកាត់បន្ថយនូវសម្ពាធពីការប្រែប្រួលអាកាសធាតុ។ ទោះបីជា UNFCCC និងពិធីសារ KYOTO មិនបានបញ្ជាក់ឱ្យបានច្បាស់លើបញ្ហាដែលទាក់ទងនឹងយេនឌ័រ ប៉ុន្តែក៏មានលិខិតតូបករណ៍ផ្លូវច្បាប់អន្តរជាតិជាច្រើនបានភ្ជាប់ទស្សនទានយេនឌ័រដែលរាប់បញ្ចូលនូវក្របខ័ណ្ឌការប្រែប្រួលអាកាសធាតុ ដែលមានស្រាប់ផងដែរ។

សារៈសំខាន់នៃការបញ្ជ្រាបយេនឌ័រ គឺដើម្បីយល់ដឹងពីសិទ្ធិមនុស្ស ការអភិវឌ្ឍប្រកបដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ និងការកាត់បន្ថយគ្រោះមហន្តរាយ ត្រូវបានទទួលស្គាល់នៅក្នុងលិខិតតូបករណ៍អន្តរជាតិជាច្រើន និងបន្តបន្ទាប់។

---

២. The discussion on legal instruments draws heavily upon: Tobin, B. and Aguilar, L. (2007). Mainstreaming Gender Equality and Equity in ABS Governance; and Aguilar, L. [In press]. Putting Words into Action…Analysis of the Status of Gender Mainstreaming in the Main Multilateral Environmental Agreements.

លិខិតតូបករណ៍ទាំងនោះរួមមាន របៀបវារៈ ២១ (សន្និសីទអង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍ ឆ្នាំ ១៩៩២) សន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្ស (ឆ្នាំ១៩៩៣) សន្និសីទទីក្រុងប៉េកាំង ដើម្បីសកម្មភាព (សន្និសីទពិភពលោកស្តីពីស្ត្រីលើកទី៤ ឆ្នាំ១៩៩៥) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ឆ្នាំ១៩៩៧ គោលដៅសហស្សវត្សរ៍ (ឆ្នាំ២០០០) ផែនការនៃការអនុវត្ត Johannesburg (ជំនួបកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព (WSSD) ឆ្នាំ ២០០២ អនុសញ្ញាស្តីពីជីវចម្រុះ អនុសញ្ញាអង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងវហោស្ថានកម្ម (UNCCD) ក្របខ័ណ្ឌសកម្មភាពយូហ្គោ (សន្និសីទពិភពលោកស្តីពីការកាត់បន្ថយគ្រោះមហន្តរាយឆ្នាំ២០០៥)។

អាណត្តិផ្ទៃក្នុងអង្គការសហប្រជាជាតិ ក៏បានអំពាវនាវឱ្យមានការបញ្ជ្រាបយេនឌ័រ ក្នុងនោះរួមមានដំណោះស្រាយនានាមកពីក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ និងគណៈកម្មការស្តីពីស្ថានភាពស្ត្រី (CSW) ជាដើម។

លិខិតតូបករណ៍សិទ្ធិមនុស្ស ច្បាប់ និងគោលនយោបាយបរិស្ថាននៃអង្គការក្នុងតំបន់ដូចជា អង្គការសហរដ្ឋអាមេរិក ក្រុមប្រឹក្សាអឺរ៉ុប អង្គការរួបរួមអាហ្វ្រិក និងច្បាប់ជាតិនៃបណ្តារដ្ឋនានាក៏អាចដើរតួជា "មធ្យោបាយដើម្បីទាមទារឱ្យរដ្ឋាភិបាលបំពេញកាតព្វកិច្ចរបស់ខ្លួន លើបញ្ហាសមធម៌យេនឌ័រដែរ" (Garcia ឆ្នាំ១៩៩៩)។

### ប្រអប់១៖ តើសេចក្តីថ្លែងការណ៍អនុសញ្ញាកតិកាសញ្ញា ខុសគ្នាដូចម្តេច?

**សេចក្តីថ្លែងការណ៍** ជាបទដ្ឋាននិងគោលការណ៍ជាបន្តបន្ទាប់ដែលព្រាងដោយរដ្ឋ និងសន្យាថានឹងគោរពអនុវត្តតាម។ ទោះបីជាយ៉ាងណា មិនមានជាតុជំរុញណាមួយទៅលើសេចក្តីថ្លែងការណ៍ឡើយ រដ្ឋដែលមិនតាមដានពិនិត្យលើបទដ្ឋាននិងគោលការណ៍ទាំងនោះ អាចប្រឈមនឹងការដាក់ទណ្ឌកម្ម ដោយសហគមន៍អន្តរជាតិ (ឧ. គោលដៅអភិវឌ្ឍសហស្សវត្សរ៍)។

**អនុសញ្ញា** រាប់បញ្ចូលនូវកិច្ចព្រមព្រៀងរវាងរដ្ឋភាគី ដែលរួមមានបទដ្ឋាន និងគោលការណ៍តម្រូវឱ្យរដ្ឋអនុវត្តតាម (ឧ. អនុសញ្ញាសហរដ្ឋអាមេរិកស្តីពីសិទ្ធិមនុស្ស)។

**កតិកាសញ្ញា** ដាក់បញ្ចូលនូវបទដ្ឋាននិងគោលការណ៍ថ្មីបន្ថែមលើអនុសញ្ញាដែលមានពីមុន។

(ឧ. ពិធីសារបន្ថែមនៃអនុសញ្ញាសហរដ្ឋអាមេរិកស្តីពីសិទ្ធិមនុស្ស ក្នុងផ្នែកសិទ្ធិ សេដ្ឋកិច្ច សង្គមនិងវប្បធម៌ "ពិធីសារ San Salvador"។

ដោយហេតុថា កាតព្វកិច្ចដែលមានមកលើរដ្ឋ អនុសញ្ញានិងកតិកាសញ្ញាចូលជាធរមាន លុះត្រាតែមានការផ្តល់សច្ចាប័នពីរដ្ឋាភិបាលនៃរដ្ឋទាំងនោះ។ ការចុះហត្ថលេខាលើលិខិតតូបករណ៍ទាំងនេះមិនគ្រប់គ្រាន់ទេ។

*ប្រភព៖ http://www.unfpa.org/derechos/preguntas_eng.htm#faq6*

## ២.១ សិទ្ធិមនុស្សជាចំណុចចាប់ផ្តើម

សិទ្ធិមនុស្សអន្តរជាតិដើរតួយ៉ាងសំខាន់ក្នុងការលើកកម្ពស់សមភាពនិងសមធម៌យេនឌ័រ។ ទាំងនេះរួមបញ្ចូលទាំងច្បាប់នានាមានទម្រង់ជាអនុសញ្ញា សេចក្តីថ្លែងការណ៍សហប្រជាជាតិ ផែនការសកម្មភាព សេចក្តីថ្លែងការណ៍ និងគោលនយោបាយផ្សេងៗជាច្រើនទៀត។ បញ្ហាយេនឌ័រត្រូវបានដោះស្រាយក្នុងលក្ខណៈទូលំទូលាយក្នុងអនុសញ្ញា ស៊ី-ដ សេចក្តីថ្លែងការណ៍សហប្រជាជាតិស្តីពីជនជាតិដើមភាគតិច សេចក្តីថ្លែងការណ៍សហប្រជាជាតិស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាសហប្រជាជាតិចំនួន២ ស្តីពីសិទ្ធិនយោបាយនិងស៊ីវិល និងសិទ្ធិសេដ្ឋកិច្ច សង្គមនិងវប្បធម៌។ គោលការណ៍នៃសមភាព និងការការពារប្រឆាំងនឹងការរើសអើងត្រូវបានចារឹកទុកក្នុងលិខិតតូបករណ៍ស្តីពីសិទ្ធិមនុស្សចម្បងៗដែលរួមមាន៖

- សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សដែលដាក់បញ្ចូលនូវការការពារសិទ្ធិរបស់ស្ត្រី ហាមឃាត់ការរើសអើង និងសមភាពនៅចំពោះមុខច្បាប់។[៣]
- កតិកាសញ្ញាអន្តរជាតិសិទ្ធិនយោបាយនិងស៊ីវិលដែលហាមឃាត់ការរើសអើង[៤] លើកកម្ពស់សមភាពសិទ្ធិស្ត្រី និងបុរស[៥] និងសមភាពនៅចំពោះមុខច្បាប់។[៦]
- កតិកាសញ្ញាអន្តរជាតិសិទ្ធិសេដ្ឋកិច្ច សង្គមនិងវប្បធម៌ដែលហាមឃាត់ការរើសអើង[៧] អំពាវនាវសមភាពស្ត្រីនិងបុរស ទាក់ទងនឹងសិទ្ធិដែលទទួលស្គាល់ដោយកតិកាសញ្ញា។

លិខិតតូបករណ៍ទាំងនេះ ទោះមិនភ្ជាប់លក្ខណៈផ្លូវច្បាប់ មានឥទ្ធិពលយ៉ាងខ្លាំងជាមួយនឹងអនុសញ្ញាស៊ី-ដ បានបង្កើតឡើងនូវការហាមឃាត់យ៉ាងច្បាស់លើការរើសអើង។ ភាពទាក់ទងគ្នាជាមួយនឹងការប្រែប្រួលអាកាសធាតុគឺ កំណត់កាន់តែច្បាស់នូវកាតព្វកិច្ចនៃរដ្ឋដើម្បីធានាថា រាល់ច្បាប់និងគោលនយោបាយដែលរៀបចំឡើង មានការគោរពយ៉ាងពេញលេញនូវសិទ្ធិស្ត្រីស្មើគ្នានៅចំពោះមុខច្បាប់ ដើម្បីពង្រឹងការអនុវត្តនូវកាតព្វកិច្ចនានាលើរដ្ឋភាគី ដើម្បីធានាការបែងចែកសមរម្យនិងប្រកបដោយសមភាពនូវអត្ថប្រយោជន៍ (មូលនិធិ បច្ចេកវិទ្យា ព័ត៌មាន) និងដើម្បីធានាការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងគំនិតផ្តួចផ្តើមលើការបន្សាំនិងការកាត់បន្ថយគោលនយោបាយ និងយន្តការ។

### ២.១.១ អនុសញ្ញាស្តីពីការទប់ស្កាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ CEDAW)

អនុសញ្ញា ស៊ី-ដ គឺជាលិខិតតូបករណ៍ដ៏ចម្បងមួយក្នុងការការពារសិទ្ធិស្ត្រី ដែលបានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ។[៨] ពិធីសារតាមជម្រើសនៃអនុសញ្ញា ស៊ី-ដ ត្រូវបានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ ក្នុងខែធ្នូ ឆ្នាំ១៩៩៩ ហើយចូលជាធរមាន នៅខែធ្នូ ឆ្នាំ២០០០។[៩] ពិធីសារតាមជម្រើសបង្កើតនូវនីតិវិធី ដែលស្ត្រីអាចដាក់ពាក្យបណ្តឹងអំពាវនាវឱ្យមានការស៊ើបអង្កេតលើការរំលោភសិទ្ធិ។

---

៣. មាត្រា ៧

៤. មាត្រា ២.១

៥. មាត្រា ៣

៦. មាត្រា ២៦

៧. មាត្រា 2.2.

៨. As of September 2007 CEDAW had been ratified by 185 countries (ratifications, accessions and successions): http://www.ohchr.org/english/law/cedaw.htm

៩. As of September 2007, 90 countries had ratified the Optional Protocol to CEDAW.

អនុសញ្ញា ស៊ី-ដ ត្រូវបានស្គាល់ជាទូទៅថាជាសិទ្ធិសម្រាប់ស្ត្រីស្វែងរកនូវការលើកកម្ពស់ ការទទួលយកវិធីសាស្ត្រដើម្បីធានាការលុបបំបាត់រាល់ទម្រង់ផ្សេងៗ( និងគ្រប់កម្រិត )នៃការរើសអើងប្រឆាំងនារីភេទ។ អនុសញ្ញា ស៊ី-ដ បានឱ្យនិយមន័យការរើសអើងប្រឆាំងនារីភេទថា៖ “រាល់ការបែងចែក ការដកចេញ ការកំណត់ដាក់លក្ខខណ្ឌ ដោយផ្អែកលើភេទដែលមានចេតនា ឬផលប៉ះពាល់ នាំឱ្យអន់ថយ ឬបាត់បង់ ការទទួលស្គាល់ភាពសប្បាយរីករាយ ឬការប្រើប្រាស់ដោយស្ត្រីការមិនគោរពដល់ស្ថានភាពគ្រួសាររបស់ពួកគេលើមូលដ្ឋាននៃសមភាពរវាងស្ត្រី និងបុរសនៃសិទ្ធិមនុស្ស និងសេរីភាពគ្រឹះក្នុងនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ ស៊ីវិល ឬផ្នែកផ្សេងទៀត”។[១០] ទោះបីជាសកម្មភាព ច្បាប់ ឬគោលនយោបាយមិនមានគោលបំណងរើសអើងក្តី ប៉ុន្តែអាចនឹងមានឥទ្ធិពលបង្កឱ្យមានការរើសអើង ( Facio ឆ្នាំ១៩៩៦ )។

នៅក្នុងបុព្វកថា អនុសញ្ញា ស៊ី-ដ បានបញ្ជាក់ថា រដ្ឋភាគី មានកាតព្វកិច្ចធានា ស្ត្រីនិងបុរស មានឱកាសស្មើគ្នាលើសិទ្ធិសេដ្ឋកិច្ច សង្គម វប្បធម៌ស៊ីវិល និងនយោបាយ។ រដ្ឋភាគី យល់ព្រមដាក់បញ្ចូលគោលការណ៍សមភាពស្ត្រីនិងបុរសក្នុងរដ្ឋធម្មនុញ្ញច្បាប់សមស្របនានា ជានាតាមរយៈច្បាប់និងមធ្យោបាយសមស្របផ្សេងទៀត។[១១]

ការរៀបចំបទបញ្ញត្តិទាក់ទងលើបញ្ហាប្រែប្រួលអាកាសធាតុ អនុសញ្ញាកំណត់កាតព្វកិច្ចឱ្យរដ្ឋភាគី "ប្រើប្រាស់គ្រប់មធ្យោបាយសមស្របនានា ដើម្បីលុបបំបាត់ ការរើសអើងប្រឆាំងនារីភេទក្នុងតំបន់ជនបទដើម្បីធានាថា ពួកគេចូលរួម និងទទួលអត្ថប្រយោជន៍ពីការអភិវឌ្ឍជនបទ"និង“ចូលរួមក្នុងការអនុវត្តផែនការអភិវឌ្ឍនៅគ្រប់កម្រិត”និងនៅក្នុងគ្រប់សកម្មភាពសហគមន៍ដោយផ្អែកលើមូលដ្ឋានសមភាពស្ត្រីនិងបុរស។[១២]

អនុសញ្ញាក៏ទទួលស្គាល់ថា ស្ត្រីគួរមានភាពស្មើគ្នាដើម្បី “ទទួលបានគ្រប់ការបណ្តុះបណ្តាល និងការអប់រំក្នុង និងក្រៅប្រព័ន្ធរួមបញ្ចូល... អត្ថប្រយោជន៍គ្រប់សេវាកម្មសហគមន៍ និងសេវាបន្ថែមទាំងអស់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពបច្ចេកទេសរបស់ពួកគេ”។[១៣]

អនុសញ្ញាតម្រូវឱ្យរដ្ឋភាគី “ប្រើប្រាស់គ្រប់មធ្យោបាយសមស្របនានា ដើម្បីលុបបំបាត់រាល់ការរើសអើងប្រឆាំងនារីភេទក្នុងផ្នែកផ្សេងទៀតដូចជា សេដ្ឋកិច្ច និងជីវភាពសង្គមដើម្បីធានាសិទ្ធិដូចគ្នាដោយផ្អែកលើមូលដ្ឋានសមភាពស្ត្រីនិងបុរស។”[១៤] ជាពិសេសពេលដែលមានយន្តការហិរញ្ញវត្ថុតម្រូវឱ្យមានការធានាថាស្ត្រី "អាចទទួលបានកម្ចី និងឥណទានពីធនាគារបរិក្ខារទីផ្សារ និងបច្ចេកវិទ្យាសមស្រប"[១៥]។

---

១០. មាត្រា ១

១១. មាត្រា ២(a).

១២. មាត្រា១៤.២

១៣. មាត្រា ១៤.២ (d)

១៤. មាត្រា ១៣

១៥. មាត្រា ១៤.២(g)

អនុសញ្ញា ស៊ី-ដ បានបញ្ជាក់ថា រដ្ឋភាគី "គួរប្រើប្រាស់គ្រប់មធ្យោបាយសមស្របនានាដើម្បីធានាថាស្ត្រីទទួលបានឱកាសធ្វើជាតំណាងរដ្ឋាភិបាលនៅលើឆាកអន្តរជាតិ និងចូលរួមការងារជាមួយអង្គការអន្តរជាតិនានា ដោយផ្អែកលើគោលការណ៍សមភាពស្ត្រី និងបុរសដោយគ្មានការរើសអើង"។[១៦]

វិធានការទាំងនេះគឺជាកាតព្វកិច្ចរបស់រដ្ឋភាគី ធានាថាស្ត្រីត្រូវបានផ្តល់ឱកាស និងលក្ខខណ្ឌចាំបាច់ដើម្បីឱ្យស្ត្រីអាចចូលរួមក្នុងការធ្វើសេចក្តីសម្រេច ការចរចាក្នុងកិច្ចព្រមព្រៀងលើបញ្ហាប្រែប្រួលអាកាសធាតុ និងចូលរួមប្រកបដោយសមធម៌ ក្នុងការទទួលបានបច្ចេកវិទ្យានិងយន្តការហិរញ្ញវត្ថុ។ ម្យ៉ាងទៀត តម្រូវឱ្យរដ្ឋភាគីធានាការចូលរួមពេញលេញរបស់ស្ត្រីក្នុងការតាក់តែងច្បាប់និងគោលនយោបាយនៅកម្រិតអន្តរជាតិដែលច្បាប់និងគោលនយោបាយទាំងនេះ ចាំបាច់ឱ្យមានការទប់ស្កាត់ការរើសអើង។

ការអនុវត្តអនុសញ្ញា ស៊ី-ដ នៅថ្នាក់ជាតិរួមទាំងការបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញមាននៅគ្រប់កម្រិត។ ឧទាហរណ៍ រដ្ឋធម្មនុញ្ញប្រទេសអាហ្វ្រិកខាងជើង និងអ៊ូហ្គាន់ដា មានមាត្រាជាច្រើនបានឈរលើគោលការណ៍អនុសញ្ញាដែលធានានូវសមភាពយេនឌ័រ។[១៧] តុលាការបានចាប់ផ្តើមរៀបចំយុត្តិសាស្ត្រស្ត្រីពីសមភាពយេនឌ័រ ដោយយោងទៅលើអ្វីដែលមានចែងក្នុងអនុសញ្ញា។ បទបង្ហាញដោយទីប្រឹក្សាពិសេសស្តីពីបញ្ហាយេនឌ័រនិងការជឿនលឿនរបស់ស្ត្រី នៅខួបទី២៥ នៃការអនុម័តអនុសញ្ញា ស៊ី-ដ បានទាក់ទាញចំណាប់អារម្មណ៍ក្នុងករណីជាច្រើនដែលតុលាការបានពឹងផ្អែកលើអនុសញ្ញា។ ករណីនេះរួមបញ្ចូលសេចក្តីសម្រេចដោយតុលាការកំពូលប្រទេសនេប៉ាល់ ដែលបញ្ជាឱ្យរាជរដ្ឋាភិបាលបញ្ជូនច្បាប់ទៅរដ្ឋសភាដើម្បីដោះស្រាយច្បាប់ការរើសអើង តុលាការធម្មនុញ្ញប្រទេសហ្គាតេម៉ាឡាកំពុងបានដាក់បញ្ហាប្រឈមនៃក្រមព្រហ្មទណ្ឌដែលចែងពីការប្រព្រឹត្តលើស្ត្រីនិងបុរសផ្សេងគ្នា និងការសម្រេចរបស់តុលាការជាន់ខ្ពស់ប្រទេសតង់ហ្សានីបានបំបាត់នូវសមាសធាតុនៃច្បាប់ជាទម្លាប់ ដែលបដិសេធស្ត្រីនូវសិទ្ធិទទួលបានមរតក និងលក់ដីធ្លី។[១៨] ករណីទាំងនេះ តុលាការត្រូវត្រៀមនីតិវិធីដោយផ្អែកលើអនុសញ្ញាដើម្បីដោះស្រាយបញ្ហាខាងលើឱ្យបានទូលំទូលាយ។ ករណីដែលទាក់ទងនឹងបញ្ហាការប្រែប្រួលអាកាសធាតុអាចកើតមាននៅតុលាការតាមការរើសអើងប្រឆាំងនារីភេទ ឧទាហរណ៍ បញ្ហាទាក់ទងនឹងការទទួល

---

១៦. មាត្រា ៨

១៧. Statement by Ms Rachel Mayanja, Assistant Secretary-General, Special Adviser on Gender Issues and Advancement of Women, on the occasion of the 25th anniversary of the work of the Committee on the Elimination of Discrimination against Women, New York, 23 July 2007.

១៨. Ibid

បានយន្តការហិរញ្ញវត្ថុនិងបច្ចេកវិទ្យា ឬសិទ្ធិក្នុងការចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេច។

គួរកត់សម្គាល់ផងដែរថា រដ្ឋភាគីនិងរដ្ឋសង្កេតការរបស់ UNFCCC ទាំង១៩៥ ប្រទេស មានតែប្រទេសចំនួន៨ប៉ុណ្ណោះ ដែលមិនបានចុះហត្ថលេខាលើអនុសញ្ញា ស៊ី-ដ។[១៩] ភាគច្រើនលើសលប់នៃរដ្ឋភាគី UNFCCC បានប្តេជ្ញាចំពោះសមភាពយេនឌ័រ និងច្បាប់អន្តរជាតិនានា។

## ២.១.២ យេនឌ័រ និងសេចក្តីថ្លែងការណ៍សហប្រជាជាតិ ស្តីពីជនជាតិដើមភាគតិច

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៧ បន្ទាប់ពីមានការចរចាគ្នាអស់រយៈពេលជាង២០ឆ្នាំ សេចក្តីប្រកាសសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (DECRIPS) ត្រូវបានអនុម័តដោយទទួលបានសំឡេងគាំទ្រចំនួន ១៤៣ សំឡេង មិនគាំទ្រ ចំនួន ៤ (អូស្ត្រាលី កាណាដា នូវែលសេឡង់ និងអាមេរិក) និងសំឡេងអនុបវាទចំនួន ១១ (អាស៊ែបៃហ្សង់ បង់ក្លាដេស ប៊ូតាន ប៊ូរ៉ុនឌី កូឡុំប៊ី ហ្សកហ្ស៊ី កេនយ៉ា នីហ្សេរីយ៉ា រុស្ស៊ី សាម័រ និងអ៊ុយក្រែន)។ ទោះបីជាសេចក្តីថ្លែងការណ៍សហប្រជាជាតិមិនមែនជាលិខិតតូបករណ៍គតិយុត្តិផ្លូវច្បាប់ ប៉ុន្តែមានឥទ្ធិពលក្នុងកិច្ចពិភាក្សា និងការតាក់តែងបទបញ្ញត្តិគ្រប់កិច្ចព្រមព្រៀងទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។

ប្រកាសសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (DECRIPS) បានហាមឃាត់ ជាពិសេសលើការរើសអើងប្រឆាំងនារីភេទ[២០] ដោយបានចែងថា រាល់សិទ្ធិនិងសេរីភាពដែលបានទទួលស្គាល់ក្នុងសេចក្តីថ្លែងការណ៍ត្រូវធានានូវភាពស្មើគ្នាសម្រាប់ស្ត្រី និងបុរសដែលជាជនជាតិដើមភាគតិច។[២១] សេចក្តីប្រកាសនេះបានកំណត់បទដ្ឋានមួយសម្រាប់ការអនុវត្ត។

នៅក្នុងបុព្វកថានៃសេចក្តីប្រកាស DECRIPS ទទួលស្គាល់នូវភាពចាំបាច់នៃចំណេះដឹង វប្បធម៌ និងប្រពៃណីសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព សមធម៌ និងការគ្រប់គ្រងបរិស្ថានសមស្របនៃជនជាតិដើមភាគតិច។[២២] DECRIPS ទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិច លើដីធ្លី ទឹកដី និងធនធានដែលពួកគេបានកាន់កាប់ តាំងទីលំនៅប្រើប្រាស់ ឬទទួលបានជាលក្ខណៈប្រពៃណី។[២៣]

សេចក្តីប្រកាស DECRIPS ទទួលស្គាល់ផងដែរថា "ជនជាតិដើមភាគតិចមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេចរាល់បញ្ហាដែលមានផលប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ"។[២៤]

តាមអ្វីដែលបានចែងទាំងនេះ ដើម្បីឱ្យសេចក្តីប្រកាស DECRIPS ត្រូវបានអនុវត្តពេញលេញ តម្រូវឱ្យមានការទទួល

---

១៩. They are Iran, Nauru, Palau, Tonga, Sudan, Somalia and Qatar. The USA has signed but not ratified CEDAW.

២០. មាត្រា ២២.២

២១. មាត្រា ៤៤

២២. កថាខ័ណ្ឌ ១១

២៣. មាត្រា ២៦.១

២៤. មាត្រា ១៨

ស្គាល់តួនាទីរបស់ស្ត្រីក្នុងគំនិតផ្តួចផ្តើម និងគោលនយោបាយស្តីពីការបន្សុំា និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ ដោយស្ត្រីបានរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដូច្នេះតម្រូវការ និងផលប្រយោជន៍របស់ពួកគេត្រូវតែឆ្លុះបញ្ចាំង នៅថ្នាក់សហគមន៍ ថ្នាក់ជាតិ និងអន្តរជាតិ។ ស្ត្រីគួរមានសិទ្ធិចូលរួមដោយស្មើភាពក្នុងការធ្វើសេចក្តីសម្រេចដែលទាក់ទង នឹងការប្រែប្រួលអាកាសធាតុ។

ការលំបាកអាចកើតឡើងនៅពេលមានភាពស៊ីសង្វាក់គ្នានៃបញ្ញតិនានា ក្នុងការទប់ស្កាត់ការរើសអើង និងបញ្ហាដែល ទាក់ទងកិច្ចការពារផ្ទាល់ខ្លួនក្នុងសេចក្តីប្រកាស DECRIPS ។ ក្នុងចំណោមសិទ្ធិដែលអាចទំនាស់ជាមួយវិធីសាស្ត្រសមភាព យេនឌ័រក្នុងការអនុវត្តសេចក្តីប្រកាសនេះ គឺសិទ្ធិកំណត់ការទទួលខុសត្រូវរបស់បុគ្គលនៅក្នុងសហគមន៍ដើម្បីអនុវត្តច្បាប់ ប្រពៃណីក្នុងការចាត់ចែងកិច្ចការសហគមន៍ និងជ្រើសរើសតំណាងចូលរួមក្នុងការធ្វើសេចក្តីសម្រេច។[២៥] ការធ្វើឱ្យមានតុល្យភាព រវាងសិទ្ធិបុគ្គល និងសិទ្ធិសមូហភាព ដែលជានាសិទ្ធិស្ត្រី គឺជាបញ្ហាប្រឈមមួយដែលទាមទារឱ្យមានការបើកចិត្តគំនិត ឆន្ទៈ សម្រុះសម្រួល ការផ្លាស់ប្តូរ និងការប្តេជ្ញាចិត្តពីគ្រប់ភាគី។

## ២.២ សមភាពយេនឌ័រ

នៅក្នុងអង្គការសហប្រជាជាតិ មានយន្តការជាច្រើនដែលត្រូវជានា និងគាំទ្រគោលការណ៍បញ្ជ្រាបយេនឌ័រ។

នៅខែកក្កដា ឆ្នាំ២០០៥ ក្នុងកិច្ចប្រជុំពេញអង្គលើកទី ៣៩ របស់ ECOSOC បានអនុម័តលើដំណោះស្រាយ “បញ្ជ្រាប គោលគំនិតយេនឌ័រទៅគ្រប់គោលនយោបាយ និងកម្មវិធីនៅក្នុងប្រព័ន្ធនៃអង្គការសហប្រជាជាតិ”។ ដំណោះស្រាយនេះ អំពាវនាវឱ្យគ្រប់យន្តការរបស់អង្គការសហប្រជាជាតិរួមបញ្ចូលភ្នាក់ងារ មូលនិធិ និងកម្មវិធីបង្កើនកិច្ចខិតខំបន្ថែមដើម្បី បញ្ចូលគោលគំនិតយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធី រួមមាន៖

- ការរៀបចំផែនការសកម្មភាពដែលមានការណែនាំច្បាស់លាស់លើការអនុវត្តជាក់ស្តែងលើការបញ្ជ្រាបយេនឌ័រ
- ដាក់បញ្ចូលនូវគោលគំនិតយេនឌ័រទៅក្នុងកម្មវិធីថវិកា
- ធានាបង្កើនការយល់ដឹង និងការបណ្តុះបណ្តាលលើបញ្ហាយេនឌ័រសម្រាប់បុគ្គលិកគ្រប់រូប
- តម្រូវឱ្យមានការវិភាគយេនឌ័រ ទាំងការរៀបចំគោលនយោបាយ និងកម្មវិធីការងារ
- ធានានូវការប្តេជ្ញាចិត្តពីថ្នាក់គ្រប់គ្រងជាន់ខ្ពស់លើការបញ្ជ្រាបយេនឌ័រ
- ពង្រឹងប្រព័ន្ធគណនេយ្យភាពសម្រាប់ការបញ្ជ្រាបយេនឌ័រ
- បន្តការគាំទ្រដល់រដ្ឋាភិបាល និងធ្វើការជាមួយសង្គមស៊ីវិលក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ លើការអនុវត្ត សន្និសីទទីក្រុងប៉េកាំង

២៥. Tobin, 2007.

- អភិវឌ្ឍ និងដាក់បញ្ចូលឧបករណ៍តាមដាន វាយតម្លៃ និងវិធីសាស្ត្រវិភាគផលប៉ះពាល់យេនឌ័រ លើកកម្ពស់ការប្រមូល ការចងក្រង និងការវិភាគទិន្នន័យបែងចែកតាមភេទទៅក្នុងស្ថាប័ន
- លើកកម្ពស់ការបញ្ជ្រាបគោលគំនិតយេនឌ័រទៅក្នុងគោលនយោបាយអភិវឌ្ឍសង្គម ម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ និងកម្មវិធីអភិវឌ្ឍជាតិ។ "លើសពីនេះ កិច្ចប្រជុំទី៥២នៃគណកម្មការស្ថានភាពស្ត្រី (ឆ្នាំ២០០៨) បានកំណត់បញ្ហាយេនឌ័រ និងការប្រែប្រួលអាកាសធាតុជាបញ្ហាបន្ទាន់។ ការចែងដាក់លាក់ ស្ដីពីការធ្វើហិរញ្ញប្បទានសម្រាប់សមភាពយេនឌ័រនិងការបង្កើនភាពអង់អាចដល់ស្ត្រីអំពាវនាវឱ្យរដ្ឋាភិបាល" បញ្ចូលគោលគំនិតយេនឌ័រទៅក្នុងការរៀបចំ អនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ និងធ្វើរបាយការណ៍នៃគោលនយោបាយបរិស្ថាន ពង្រឹងយន្តការ និងផ្ដល់ធនធានសមរម្យដើម្បីធានានូវការចូលរួមពេញលេញ និងស្មើភាពរបស់ស្ត្រីក្នុងការធ្វើសេចក្ដីសម្រេចគ្រប់លំដាប់ថ្នាក់លើបញ្ហាបរិស្ថាន ជាពិសេសលើយុទ្ធសាស្ត្រទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងជីវិតរបស់ស្ត្រីនិងក្មេងស្រី។"[២៦]

## ២.៣ ការកាត់បន្ថយគ្រោះមហន្តរាយ

ក្របខ័ណ្ឌសកម្មភាពយូហ្គោ (HFA) ដែលជាលទ្ធផលចេញពីសន្និសីទពិភពលោក ស្ដីពីការកាត់បន្ថយមហន្តរាយក្នុងទីក្រុងកូបេ ប្រទេសជប៉ុន (ឆ្នាំ២០០៥) ដោយរួមបញ្ចូលនូវតួនាទីសំខាន់ៗដែលទាក់ទងនឹងសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីក្នុងបរិបទនៃការកាត់បន្ថយគ្រោះមហន្តរាយ។ ក្របខ័ណ្ឌសម្រាប់សកម្មភាពនេះ ត្រូវបានអនុម័តដោយរដ្ឋចំនួន ១៦៨ បានកំណត់នូវលទ្ធផលរំពឹងទុកច្បាស់លាស់មួយ - ការកាត់បន្ថយនូវការបាត់បង់មកពីគ្រោះមហន្តរាយដល់អាយុជីវិត ក៏ដូចជាធនធានសង្គម សេដ្ឋកិច្ច បរិស្ថានរបស់សហគមន៍ និងប្រទេសដោយបានរៀបចំជាកញ្ចប់អាទិភាពដើម្បីសម្រេចបាននៅឆ្នាំ២០១៥។ ចំណុចសំខាន់នៃ HFA គឺទម្រង់ដែលមិនមានចងភ្ជាប់ជាច្បាប់ដែលអនុញ្ញាតឱ្យ HFA ដាក់ចេញនូវតម្រូវការបច្ចេកទេស និងស្ថាប័នសម្រាប់កាត់បន្ថយគ្រោះមហន្តរាយ និងទុកលទ្ធភាពឱ្យរដ្ឋាភិបាលនិងអង្គភាពពាក់ព័ន្ធធ្វើការសម្រេចចិត្តដោយផ្អែកលើតម្រូវការ និងសមត្ថភាពរបស់ពួកគេ។ HFA បានសង្កត់ធ្ងន់ថាការកាត់បន្ថយគ្រោះមហន្តរាយគឺជាបញ្ហាស្នូលសម្រាប់អភិវឌ្ឍគោលនយោបាយ។

ក្របខ័ណ្ឌនេះបានបញ្ជាក់ថា "គោលគំនិតយេនឌ័រគួរត្រូវបានបញ្ចូលនៅគ្រប់គោលនយោបាយ ផែនការគ្រប់គ្រងនិងដំណើរការនៃការធ្វើសេចក្ដីសម្រេចលើការគ្រប់គ្រងគ្រោះមហន្តរាយរួមមាន៖ ការវាយតម្លៃហានិភ័យ ការប្រកាសអាសន្នជាមុន ការគ្រប់គ្រងព័ត៌មាន ការអប់រំ និងការបណ្ដុះបណ្ដាល។"[២៧] ក្របខ័ណ្ឌនេះទទួលស្គាល់ថា យេនឌ័រត្រូវតែរួមបញ្ចូលក្នុងគ្រប់ផ្នែកនៃការគ្រប់គ្រងហានិភ័យតាមរយៈដំណាក់កាលនៃវដ្តមហន្តរាយ រួមបញ្ចូលទាំងការឆ្លើយតប ការស្ដារឡើងវិញ ការត្រៀមបង្ការ និងកាត់បន្ថយមុខសញ្ញាគ្រោះមហន្តរាយ។

---

២៦. Resolution 21(jj) (E/CN.6/2008/L.8).

២៧. General considerations 13(d).

ក្នុងសកម្មភាពអាទិភាពសម្រាប់ឆ្នាំ២០០៥-២០១៥ ក្របខ័ណ្ឌនេះបានបញ្ចូល តម្រូវការរៀបចំ “ប្រព័ន្ធផ្តល់ព័ត៌មានជាមុនដែលផ្តោតការសំខាន់លើមនុស្ស ជាពិសេសប្រព័ន្ធដែលផ្តល់ព័ត៌មានទាន់ពេលវេលា និងអាចយល់បានដោយអ្នកងាយរងគ្រោះ។ ព័ត៌មាននេះត្រូវគិតគូរពីកត្តាភូមិសាស្ត្រ យេនឌ័រ វប្បធម៌ ជីវភាពរស់នៅរបស់ក្រុមគោលដៅដោយរួមបញ្ចូលការណែនាំ និងការគាំទ្រប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរបស់អ្នកគ្រប់គ្រងគ្រោះមហន្តរាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត។”[២៨]

ទាក់ទងនឹងការអប់រំ និងបណ្តុះបណ្តាលក្របខ័ណ្ឌបានអំពាវនាវឱ្យរដ្ឋភាគី “ធានាការទទួលបានឱកាសអប់រំ និងបណ្តុះបណ្តាលស្មើគ្នាសម្រាប់ស្ត្រី និងជនងាយរងគ្រោះ លើកកម្ពស់ការបណ្តុះបណ្តាលអំពីភាពរសើបយេនឌ័រ និងវប្បធម៌ដែលជាផ្នែកមួយនៃការអប់រំ និងបណ្តុះបណ្តាលសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ។”[២៩]

ឯកសារ “ពាក្យទៅជាសកម្មភាព” (ឆ្នាំ២០០៧) ប្រើជាគោលការណ៍ណែនាំសម្រាប់ការអនុវត្ត HFA និងការគាំពារមតិនៅក្នុងគ្រប់ជំហាននៃវដ្តមហន្តរាយក្នុងយុទ្ធសាស្ត្រសកម្មភាពជាតិ។ ក្នុងគោលការណ៍នេះ ឯកសារបានបញ្ជាក់៖ “យេនឌ័រគឺជាកត្តាស្នូល ក្នុងការគ្រប់គ្រង និងការអនុវត្តការកាត់បន្ថយគ្រោះមហន្តរាយ” យេនឌ័រគឺជាគោលការណ៍ចាត់ចែងសំខាន់មួយនៅក្នុងគ្រប់សង្គម ដោយសារស្ត្រី និងបុរសទទួលរងគ្រោះខុសៗគ្នាពីហានិភ័យនៃគ្រោះមហន្តរាយ។ យេនឌ័របានតម្រង់សមត្ថភាព និងធនធានរបស់បុគ្គលម្នាក់ៗក្នុងការកាត់បន្ថយ បន្សាំ និងឆ្លើយតបគ្រោះមហន្តរាយនៅគ្រប់ស្ថានភាព - នៅផ្ទះ នៅកន្លែងធ្វើការ ឬនៅទីជិតខាង ។ មានភស្តុតាងពីអតីតកាលបង្ហាញថា ស្ត្រីដែលមានប្រាក់ចំណូលទាប និងជនបាត់បង់ឱកាសដោយសារស្ថានភាពគ្រួសារ លទ្ធភាពពលកម្ម អាយុ វណ្ណៈ និងមានកេរ្តិ៍ឈ្មោះមិនល្អក្នុងសង្គម គឺជាអ្នកដែលងាយរងគ្រោះ។ ម៉្យាងវិញទៀតនៅថ្នាក់មូលដ្ឋាន ស្ត្រីតែងតែដើរតួក្នុងការគ្រប់គ្រងហានិភ័យដោយសារពួកគេមានតួនាទីជាអ្នកប្រើប្រាស់ និងគ្រប់គ្រងធនធានបរិស្ថាន ជាអ្នកផ្តល់សេវាសេដ្ឋកិច្ច ជាអ្នកផ្តល់ការថែទាំ និងជាអ្នកធ្វើការក្នុងសហគមន៍។ ហេតុនេះ ជាការចាំបាច់ក្នុងការកំណត់និងប្រើប្រាស់ព័ត៌មានយេនឌ័រដែលញែកដាច់ពីគ្នា ដើម្បីធានាថា យុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ ត្រូវបានកំណត់ឱ្យចំគោលដៅដែលត្រឹមត្រូវចំពោះក្រុមងាយរងគ្រោះបំផុត និងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពតាមរយៈតួនាទីរបស់ស្ត្រី និងបុរស”( UNISDR 2007, 5 ) ។

ដើម្បីគាំទ្ររដ្ឋាភិបាលជាតិក្នុងការសម្រេចបានគោលដៅលើការកាត់បន្ថយហានិភ័យ លេខាធិការដ្ឋាននៃយុទ្ធសាស្ត្រអន្តរជាតិសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយនៃអង្គការសហប្រជាជាតិ (ISDR) បានរៀបចំវេទិកាសកលលោក (ខែមិថុនា ឆ្នាំ២០០៧ និងខែមិថុនា ឆ្នាំ២០០៩) ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងពិភាក្សាលើការគំរាមកំហែងដែលបានកើតឡើងដូចជាការប្រែប្រួលអាកាសធាតុជាដើម។

---

២៨. សកម្មភាពអាទិភាព 2: 17 ii-(d).

២៩. សកម្មភាពអាទិភាព 3: 18 ii-(m).

## ២.៤ យេនឌ័រ និងការអភិវឌ្ឍប្រកបដោយចីរភាព

នៅក្នុងថ្នាក់អន្តរជាតិបញ្ហាយេនឌ័រត្រូវបានលើកឡើងក្នុងកិច្ចប្រជុំកំពូលនិងសន្និសីទនានា[៣០] និងមានឯកសារយោងច្បាស់លាស់អំពីសិទ្ធិស្ត្រីនៅក្នុងលិខិតតូបករណ៍អន្តរជាតិជាច្រើន ។[៣១]ក្នុងនោះមានកិច្ចព្រមព្រៀងស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ដូចជារបៀបវារៈ២១ ផែនការនៃការអនុវត្ត WSSD អនុសញ្ញាស្តីពីជីវៈចម្រុះ និងអនុសញ្ញាសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម (UNCCD) ដែលបានធ្វើការប្តេជ្ញាចិត្តលើបញ្ហាស្ត្រី និងយេនឌ័រ។ ទំនាក់ទំនងរវាងស្ត្រីនិងបរិស្ថានក៏បានកើតឡើងទាក់ទងទៅនឹងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីស្ត្រីនិងសមភាពយេនឌ័រដូចជា សន្និសីទទីក្រុងប៉េកាំងនិងការពិនិត្យឡើងវិញសម្រាប់រយៈពេល១០ឆ្នាំ និងសេចក្តីថ្លែងការណ៍សហស្សវត្សរ៍។

### ២.៤.១ របៀបវារៈ២១

របៀបវារៈ២១ ដែលបង្កើតសំណៅដើមមួយសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពត្រូវបានអនុម័តនៅឯសន្និសីទសហប្រជាជាតិស្តីពីបរិស្ថាននិងការអភិវឌ្ឍនៅទីក្រុងរីយ៉ូដឺជេនីរ៉ូ ក្នុងឆ្នាំ១៩៩២។ របៀបវារៈនេះបានបញ្ចូលជំពូកពេញលេញមួយ(២៤) ស្តីពី "សកម្មភាពពិភពលោកសម្រាប់ស្ត្រីឆ្ពោះទៅការអភិវឌ្ឍប្រកបដោយចីរភាព" ដែលអំពាវនាវឱ្យរដ្ឋាភិបាលធ្វើការកែសម្រួលរដ្ឋធម្មនុញ្ញ ច្បាប់ នីតិវិធីរដ្ឋបាល វប្បធម៌ សង្គម និងសេដ្ឋកិច្ចក្នុងការលុបបំបាត់រាល់ឧបសគ្គក្នុងការចូលរួមពេញលេញរបស់ស្ត្រីលើការអភិវឌ្ឍប្រកបដោយចីរភាពនិងក្នុងជីវិតសាធារណៈ។

របៀបវារៈ២១ អំពាវនាវឱ្យមានការអនុម័តនូវវិធានការក្នុងការបកស្រាយគោលបំណង ឱ្យក្លាយទៅជាយុទ្ធសាស្ត្រច្បាស់លាស់ ។[៣២] យុទ្ធសាស្ត្រនេះ អាចសម្រេចបានតាមរយៈគោលនយោបាយរបស់រាជរដ្ឋាភិបាល សេចក្តីណែនាំថ្នាក់ជាតិនិងផែនការ ដើម្បីធានាសមធម៌នៅគ្រប់ទិដ្ឋភាពក្នុងសង្គម ដោយរួមបញ្ចូល "គន្លឹះនៃការចូលរួម" របស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច និងការគ្រប់គ្រងបរិស្ថាន។

---

៣០. These include: Children's World Summit (New York, 1990); United Nations Conference on Environment and Development, (Río de Janeiro, 1992); World Conference on Human Rights (Vienna, 1993); International Conference on Population and Development (Cairo, 1994); World Summit on Social Development (Copenhagen, 1995); Fourth World Conference on Women (Beijing, 1995); Second United Nations Conference on Human Settlements (Istanbul, 1996); World Summit on Food (Rome, 1996); and United Nations Conference of Plenipotentiaries on the Establishment of an International Criminal Court (Rome, 1998).

៣១. These include the Cairo Action Programme, Agenda 21, Copenhagen Declaration on Social Development, Copenhagen Action Plan, Istanbul Declaration on Human Settlements, the UN Human Settlements Programme (UN-HABITAT), the Rome Declaration on World Food Security, Rome Action Plan on World Food Security, and the Vienna Declaration and Programme of Action which contains a whole section entitled: "The equal status and human rights of women".

៣២. Section 24(f).

## ២.៤.២ ការអនុវត្តផែនការនៃសន្និសីទកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព

កិច្ចប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ផែនការនៃការអនុវត្ត (ឆ្នាំ២០០២) បានអនុម័តនៅទីក្រុងចូហានបឺក លើកកម្ពស់ការទទួលបានភាពស្មើគ្នារបស់ស្ត្រី និងបុរសក្នុងការចូលរួមការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត។ កិច្ចប្រជុំនេះអំពាវនាវឱ្យមានការបញ្ជ្រាបគោលគំនិតយេនឌ័រទៅក្នុងគ្រប់គោលនយោបាយ និងយុទ្ធសាស្ត្រ ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ និងការធ្វើឱ្យប្រសើរឡើងពីស្ថានភាពសេដ្ឋកិច្ច សុខភាពរបស់ស្ត្រី និងក្មេងស្រីតាមរយៈការទទួលបានពេញលេញ និងស្មើភាពនៅលើកាលានុវត្តភាពសេដ្ឋកិច្ច ដីធ្លី ឥណទាន ការអប់រំ និងសេវាថែទាំសុខភាព។

## ២.៤.៣ សេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំងនិងវេទិកាសកម្មភាព និងទីក្រុងប៉េកាំង+១០

ឯកសារចំនួនពីរកើតចេញពីសន្និសីទពិភពលោកស្តីពីស្ត្រីលើកទី៤៖ សេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំងនិងសន្និសីទដើម្បីសកម្មភាព។ ឯកសារទាំងនេះបង្កើតបានជាយុទ្ធសាស្ត្រ និងទំនួលខុសត្រូវ សម្រាប់រដ្ឋភាគី។ សន្និសីទដើម្បីសកម្មភាពបានព្រមានថា៖ "សិទ្ធិស្ត្រីដែលបានចែងក្នុងលិខិតតូបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស នឹងមានសុពលភាពលុះត្រាតែសិទ្ធិនេះត្រូវបានទទួលស្គាល់ ការការពារ ការទទួលយក និងការអនុវត្តដោយប្រសិទ្ធភាពពេញលេញនៅក្របខ័ណ្ឌច្បាប់ និងការអនុវត្តថ្នាក់ជាតិ ក្នុងគ្រួសារ ក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ច្បាប់ការងារ និងច្បាប់ពាណិជ្ជកម្ម ក៏ដូចជាក្នុងបញ្ញត្តិនីតិវិធីរដ្ឋបាលនានា" (កថាខណ្ឌ២១៨)។

គោលបំណងយុទ្ធសាស្ត្រចំណុច K នៃសន្និសីទទីក្រុងប៉េកាំង ប្តេជ្ញាជានាការចូលរួមយ៉ាងសកម្មរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចទាក់ទងបរិស្ថាន ដើម្បីបញ្ចូលគោលគំនិត និងកង្វល់យេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងពង្រឹង ឬបង្កើតយន្តការនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ដើម្បីប៉ាន់ប្រម៉ាណផលប៉ះពាល់នៃគោលនយោបាយអភិវឌ្ឍនិងបរិស្ថានដែលផ្តោតលើស្ត្រី។

ក្នុងខែមីនា ឆ្នាំ២០០៥ កិច្ចប្រជុំទី៤៩ នៃ CSW នៅទីស្នាក់ការអង្គការសហប្រជាជាតិដែលត្រូវបានស្គាល់ថាជា "សន្និសីទទីក្រុងប៉េកាំង+១០" បានប៉ាន់ប្រមាណវឌ្ឍនភាព ចាប់តាំងពីមានការអនុម័តសន្និសីទទីក្រុងប៉េកាំង។ សន្និសីទនេះបានទាមទារឱ្យធ្វើសកម្មភាពប្រឆាំងនឹងច្បាប់ដែលរើសអើងលើសិទ្ធិស្ត្រី និងអំពើហិង្សាផ្សេងៗ។ សន្និសីទនេះបានអំពាវនាវ ជាពិសេសទៅកាន់រដ្ឋភាគីដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពរកប្រាក់ចំណូលរបស់ស្ត្រីនៅជនបទ ដោយបញ្ជាក់ពីសារៈសំខាន់នៃវិស័យកសិកម្ម សុវត្ថិភាពនៃកម្មសិទ្ធដីធ្លី និងទ្រព្យសម្បត្តិសម្រាប់ការកៀងគរធនធាន និងការគ្រប់គ្រងបរិស្ថាន ជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍ។

## ២.៤.៤ សេចក្តីថ្លែងការណ៍សហស្សវត្សរ៍និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍

នៅក្នុងកិច្ចពិភាក្សាពេញអង្គទី៨ នៃមហាសន្និបាតអង្គការសហប្រជាជាតិនៅខែកញ្ញា ឆ្នាំ២០០០ ប្រទេសជាច្រើនបានអនុម័តសេចក្តីថ្លែងការណ៍សហស្សវត្សរ៍ បានប្តេជ្ញាគោរពសិទ្ធស្មើគ្នាដោយមិនបែងចែកពូជសាសន៍ ភេទ ភាសា ឬសាសនា។[៣៣] អង្គការសហប្រជាជាតិ បានអនុម័តគោលដៅអភិវឌ្ឍសហស្សវត្សរ៍ (MDGs) ដែលជាសំណៅដើមសម្រាប់ការធ្វើឱ្យសម្រេចបានសេចក្តីថ្លែងការណ៍សហស្សវត្សរ៍។ MDGs លើកកម្ពស់ ការកាត់បន្ថយភាពក្រីក្រ ការអប់រំ សុខភាពមាតា សមភាពយេនឌ័រ និងមានគោលបំណងកាត់បន្ថយមរណភាពកុមារ មេរោគអេដស៍ និងជម្ងឺផ្សេងទៀត។ គោលដៅ MDGs ឆ្នាំ២០១៥ គឺជាបណ្តុំនៃការព្រមព្រៀង ដែលអាចសម្រេចទៅបានលុះត្រាតែមានការប្តេជ្ញាចិត្តពេញលេញនិងកិច្ចសហការពីគ្រប់ស្ថាប័នពាក់ព័ន្ធ។[៣៤] ប្រទេសកំពុងអភិវឌ្ឍសន្យានឹងធ្វើការគ្រប់គ្រងនិងវិនិយោគកាន់តែប្រសើរលើប្រជាពលរដ្ឋរបស់ពួកគេ តាមរយៈការអប់រំនិងថែទាំសុខភាព។ ប្រទេសអភិវឌ្ឍសន្យាគាំទ្រប្រទេសក្រីក្រ តាមរយៈជំនួយការដោះបំណុល និងពាណិជ្ជកម្មប្រកបដោយយុត្តិធម៌។[៣៥]

សេចក្តីថ្លែងការណ៍ កំណត់តម្លៃមូលដ្ឋានគ្រឹះជាក់លាក់ និងចាំបាច់សម្រាប់ទំនាក់ទំនងអន្តរជាតិ នៅសតវត្សរ៍ទី ២១។ ក្នុងនោះប្រទេសហត្ថលេខីប្តេជ្ញា៖ ធានាសិទ្ធិនិងឱកាសស្មើគ្នាសម្រាប់ស្ត្រីនិងបុរស[៣៦] លើកកម្ពស់ភាពអង់អាចរបស់ស្ត្រីដែលជាមធ្យោបាយមានប្រសិទ្ធភាព ក្នុងការកាត់បន្ថយភាពក្រីក្រ ប្រយុទ្ធប្រឆាំងនិងភាពអត់ឃ្លាន ជម្ងឺ និងការសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាពពិតប្រាកដ និងធានាថាអត្ថប្រយោជន៍នៃបច្ចេកវិទ្យាថ្មីៗ ជាពិសេសបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងត្រូវទទួលបានគ្រប់គ្នា។

សេចក្តីថ្លែងការណ៍ មានអត្ថប្រយោជន៍ជាពិសេស ដោយសារការផ្សារភ្ជាប់រវាងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិផ្សេងៗទៀតដែលមានក្នុង UNFCCC។ សរុបជារួម សេចក្តីថ្លែងការណ៍បង្កើតបានទម្រង់ជាមូលដ្ឋានអន្តរតម្លៃដែលមានទំនាក់ទំនងគ្នារវាងយេនឌ័រ បរិស្ថាន និងសិទ្ធិមនុស្ស។

យោងទៅលើរបាយការណ៍អភិវឌ្ឍមនុស្សរបស់កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិនៅឆ្នាំ២០០៥ យេនឌ័រ នៅតែជា "ចំណុចកត់សំគាល់ដ៏សំខាន់មួយនៃពិភពលោក"។ ដូច្នេះការកាត់បន្ថយវិសមភាពមានសារៈសំខាន់ក្នុងការធ្វើឱ្យសម្រេចបាន MDGs។

---

៣៣. មាត្រា៤

៣៤. For a review of progress on the MDGs see www.paris21.org/betterworld.

៣៥. Retrieved on July 21, 2006, from: http://www.undp.org/mdg/.

៣៦. មាត្រា៦

## ២.៤.៥ អនុសញ្ញាទីក្រុងរីយ៉ូ

លទ្ធផលនៃសន្និសីទអង្គការសហប្រជាជាតិស្តីពីបរិស្ថាននិងការអភិវឌ្ឍក្នុងឆ្នាំ១៩៩២ ក្នុងទីក្រុង Rio de Janeiro ប្រទេសប្រេស៊ីល ត្រូវបានស្គាល់ថាជាសន្និសីទផែនដីកំពូលទីក្រុងរីយ៉ូ ដែលក្នុងនោះមានសន្ធិសញ្ញាអន្តរជាតិចំនួន៣៖ UNFCCC, CBD និង UNCCD។

អនុសញ្ញាទីក្រុងរីយ៉ូទាំងបីនេះមានទំនាក់ទំនងជាមួយគ្នាដោយសារការប្រែប្រួលអាកាសធាតុ ផ្តល់ផលប៉ះពាល់ទៅលើជីវៈចម្រុះ និងរហោស្ថានកម្ម។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុកាន់តែរីករាលដាលបណ្តាលឱ្យការបាត់បង់ដំណាំ រុក្ខជាតិ សត្វ ដីខ្សោះជីជាតិកាន់តែមានទំហំកើនឡើងនៅជុំវិញពិភពលោក។

អាស្រ័យលើតថភាពនេះ ក្រុមទំនាក់ទំនងរួមគ្នា (JLG) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០១ ដើម្បីបង្កើនកិច្ចសហការរវាងលេខាធិការដ្ឋាននៃអនុសញ្ញាទាំងបី។ តាមរយៈ JLG ព័ត៌មានត្រូវបានចែករំលែក ការសម្របសម្រួល សកម្មភាព និងវិធានការត្រូវបានកំណត់ដើម្បីដោះស្រាយជាបន្តបន្ទាប់ចំពោះបញ្ហាទាំងបី។

ដូចបានបង្ហាញមុននេះ UNFCCC និងពិធីសារក្យូតូ មិនបានដាក់បញ្ចូលទាល់តែសោះ ទាក់ទងនឹងបញ្ហាយេនឌ័រ។ កត្តាទាំងនេះ បណ្តាលមកពីការផ្តោតការយកចិត្តទុកដាក់ជាចម្បងទៅលើផ្នែកវិទ្យាសាស្ត្រ អំពីការកើនកំដៅជាសកលក៏ដូចជាការមានចលនាយេនឌ័រតិចតួច។ ផ្អែកលើការចុះហត្ថលេខានៃ UNFCCC ២ឆ្នាំក្រោយអនុសញ្ញាពីរផ្សេងទៀតត្រូវបានចុះហត្ថលេខាទទួលស្គាល់ក្នុងឆ្នាំ១៩៩២។ ដោយមិនគិតពីបញ្ហានេះ អ្វីដែលបានលើកឡើងទាក់ទងនឹងសិទ្ធិមនុស្ស ការកាត់បន្ថយគ្រោះមហន្តរាយនិងលិខិតតូបករណ៍យេនឌ័រសុទ្ធតែមានទំនាក់ទំនងជាមួយនឹងការងាររបស់ UNFCCC។

នៅក្នុងបរិបទនេះ ការគិតគូរពីបទពិសោធន៍និងជោគជ័យនៃសន្និសីទផែនដីកំពូលទីក្រុងរីយ៉ូ ពីរផ្សេងទៀត CBD និង UNCCD ដែលមានការលូតលាស់លើការបញ្ជ្រាបសមភាពយេនឌ័រនិងការគិតគូរពីសមធម៌។

## អនុសញ្ញាស្តីពីជីវៈចម្រុះ (CBD)

អនុសញ្ញាស្តីពីជីវៈចម្រុះ ជាក្របខ័ណ្ឌអន្តរជាតិមួយសម្រាប់អភិរក្ស និងប្រើប្រាស់ប្រកបដោយចីរភាពនៃជីវៈចម្រុះ និងការបែងចែកដោយយុត្តិធម៌និងសមធម៌នូវផលប្រយោជន៍ដែលកើតចេញពីការប្រើប្រាស់ធនធានដើម។បច្ចុប្បន្នអនុសញ្ញានេះត្រូវបានអនុម័តដោយរដ្ឋចំនួន១៩០។

គួរកត់សម្គាល់ផងដែរថា CBD ជាកិច្ចព្រមព្រៀងបរិស្ថានតែមួយគត់ដែលបានបញ្ជាក់ពីសន្និសីទទីក្រុងប៉េកាំងដើម្បីសកម្មភាពនៅក្នុងចំណុច K៖ *“លើកទឹកចិត្ត ដោយផ្តោតលើច្បាប់ជាតិ និងដាក់លាក់ជាមួយនឹងអនុសញ្ញាស្តីពីជីវៈចម្រុះ ការការពារ ប្រកបដោយប្រសិទ្ធភាពនិងការប្រើប្រាស់ចំណេះដឹង ការរកឃើញ និងការអនុវត្តរបស់ស្ត្រីជាជនជាតិដើមភាគតិច*

*និងនៅក្នុងសហគមន៍ មូលដ្ឋាន រួមបញ្ចូលការអនុវត្តទាក់ទងនឹងការប្រើប្រាស់ថ្នាំបុរាណ ជីវៈចម្រុះ និងបច្ចេកវិទ្យាពីដើម និងការខិតខំប្រឹងប្រែងដើម្បីធានាថា កត្តាទាំងនេះត្រូវបានគោរព ថែទាំ លើកកម្ពស់ និងថែរក្សាក្នុងលក្ខខណ្ឌចីរភាពអេកូឡូស៊ី លើកកម្ពស់លទ្ធភាពទទួលបានកាន់តែប្រសើរជាមួយនឹងការយល់ព្រមនិងចូលរួមអ្នកដែលជាម្ចាស់ចំណេះដឹង ។ បន្ថែមលើសពីនេះការពារកម្មសិទ្ធិបញ្ញាដែលមានស្រាប់នៃស្ត្រីទាំងនេះ ដូចដែលបានការពារនៅក្រោមច្បាប់ជាតិនិងអន្តរជាតិៈ ធ្វើការយ៉ាងសកម្ម ទីដែលចាំបាច់ដើម្បីកែមធ្យោបាយនិងវិធីសាស្ត្របន្ថែមសម្រាប់ការការពារនិងប្រើប្រាស់នូវចំណេះដឹង ការរកឃើញ និងការអនុវត្តផ្តោតលើច្បាប់ជាតិ និងដាក់លាក់ជាមួយនឹងអនុសញ្ញាស្តីពីជីវៈចម្រុះនិងច្បាប់អន្តរជាតិពាក់ព័ន្ធ និងលើកទឹកចិត្តការចែករំលែកសមរម្យនិងស្មើភាពនូវអត្ថប្រយោជន៍ដែលកើតចេញពីការប្រើប្រាស់ចំណេះដឹង ការរកឃើញ និងការអនុវត្តទាំងនេះ” ។*[៣៧]

ដោយគោរពលើតម្លៃស្ត្រីនិងយេនឌ័រ កថាខណ្ឌ១៣ក្នុងបុព្វកថានៃ CBD បញ្ជាក់៖ “ទទួលស្គាល់នូវតួនាទីដ៏សំខាន់របស់ស្ត្រីក្នុងការប្រើប្រាស់ប្រកបដោយចីរភាពនិងអភិរក្សនូវជីវចម្រុះ និងបញ្ជាក់ពីតម្រូវការពីការចូលរួមពេញលេញរបស់ស្ត្រីគ្រប់កម្រិតក្នុងតួនាទីធ្វើសេចក្តីសម្រេចនិងការអនុវត្តការអភិរក្សជីវៈចម្រុះ... ។” មិនមានសេចក្តីយោងណាមួយផ្សេងទៀតទេដែលត្រូវបានធ្វើឡើងនៅក្នុងអត្ថបទនៃអនុសញ្ញាឡើយ ។

ការចែងផ្សេងទៀតដែលកើតចេញពីសន្និសីទនៃភាគីដែលពាក់ព័ន្ធ (COP) និងក្រុមការងារ ។ ភាគច្រើនអ្វីដែលកើតមានឡើង តាមរយៈសេចក្តីស្នើនៃក្រុមជនជាតិដើមភាគតិចនិងក្រុមសហគមន៍ នៅមាត្រា៨ (j) ៖

- **សេចក្តីសម្រេច V/១៦៖ មាត្រា ៨(j) និងការចែងផ្សេងទៀត៖** “ទទួលស្គាល់តួនាទីដ៏សំខាន់របស់ស្ត្រីក្នុងការប្រើប្រាស់ជីវៈចម្រុះប្រកបដោយចីរភាពនិងអភិរក្ស ការសង្កត់ធ្ងន់ដែលចំណាប់អារម្មណ៍កាន់តែខ្លាំងឡើងគួរតែផ្តល់លើការពង្រឹងតួនាទីនេះនិងការចូលរួមរបស់ស្ត្រីជាជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋានក្នុងកម្មវិធីការងារ ។”
- **កម្មវិធីការងារលើការអនុវត្ត មាត្រា៨ (j) និងការចែងពាក់ព័ន្ធនានាក្នុង CBD៖ ១. គោលការណ៍ទូទៅ៖** “ការចូលរួមប្រកបដោយប្រសិទ្ធភាព និងពេញលេញរបស់ស្ត្រីជាជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាននៅគ្រប់សកម្មភាព កម្មវិធីការងារ ។”
- តារាងទី៤នៃកម្មវិធីការងារស្នើឱ្យ “រដ្ឋភាគីរៀបចំតាមការសមរម្យនូវយន្តការដើម្បីលើកកម្ពស់ការចូលរួមប្រកបដោយប្រសិទ្ធភាពនិងពេញលេញរបស់ស្ត្រីក្នុងគ្រប់ជាតុទាំងអស់នៃកម្មវិធីការងារដោយគិតលើ៖

៣៧. Strategic Objective K.1, 253c.

a. កសាងលើមូលដ្ឋាននៃចំណេះដឹងរបស់ពួកគេ

b. ពង្រឹងការទទួលបាននូវជីវៈចម្រុះ

c. ពង្រឹងសមត្ថភាពរបស់ពួកគេលើបញ្ហាដែលជាប់ពាក់ព័ន្ធនឹងការអភិរក្ស ថែរក្សា និងការការពារជីវៈចម្រុះ

d. ការលើកកម្ពស់ការផ្លាស់ប្តូរបទពិសោធន៍និងចំណេះដឹង និង

e. ការលើកកម្ពស់ការយល់ដឹងពីយេនឌ័រឱ្យបានជាក់លាក់និងសមស្របតាមវប្បធម៌ ដែលចងក្រង និងថែរក្សាចំណេះដឹងរបស់ស្ត្រីស្តីពីជីវៈចម្រុះ។"



រាល់សេចក្តីដែលមានចែងទាំងអស់ដែលយោងជាក់លាក់លើការចូលរួមរបស់ស្ត្រី ក្នុងសកម្មភាព CBD និងមិនពាក់ព័ន្ធដោយផ្ទាល់លើការលើកកម្ពស់សមភាពយេនឌ័រ។ ទោះបីជាយ៉ាងណា ជាពិសេស ចាប់តាំងពីឆ្នាំ២០០៧ CBD បានចាប់ផ្តួចផ្តើមនូវដំណើរការដែលផ្តោតការយកចិត្តទុកដាក់ក្នុងការលើកកម្ពស់ការបញ្ជ្រាបយេនឌ័រ ក្នុងការងារធម្មតារបស់វា។

ឧទាហរណ៍៖ ក្នុងសេចក្តីសម្រេចដែលធ្វើឡើងក្នុងកិច្ចប្រជុំលើកទី២របស់ខ្លួន ក្រុមការងារបណ្តោះអាសន្នសម្រាប់ពិនិត្យតាមដានការអនុវត្តអនុសញ្ញាស្តីពីជីវៈចម្រុះ ស្តីពីការវាយតម្លៃលើការអនុវត្តអនុសញ្ញា (WG RI-2) ទទូចឱ្យភាគីពាក់ព័ន្ធ៖ "ធ្វើការរៀបចំ អនុវត្ត និងកែសម្រួលឱ្យបានសមស្របទៅតាមផែនការនិងយុទ្ធសាស្ត្រជីវៈចម្រុះនៅថ្នាក់ជាតិនិងតំបន់... ក្នុងន័យលើកកម្ពស់ការបញ្ជ្រាបយេនឌ័រ"។[៣៨]

ទាក់ទងនឹងយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ (NBSAPs) មាត្រា៦ នៃ CBD បញ្ជាក់ថាភាគីនីមួយៗ គួររៀបចំផែនការសកម្មភាព NBSAP របស់ខ្លួន ឬឧបករណ៍ស្រដៀងគ្នាដើម្បីឆ្លុះបញ្ចាំងគោលបំណងផែនការបច្ចុប្បន្ន កម្មវិធី និងគោលនយោបាយនៅតាមវិស័យនិងពហុវិស័យរបស់ CBD និងប្រទេសជាហត្ថលេខី។

៣៨. UNEP/CBD/COP/9/4, Annex, Recommendation 2/1, Annex, Paragraph 8(d).

**ប្រអប់២៖** ឧទាហរណ៍ នៃការដោះស្រាយបញ្ហាស្ត្រីនិងយេនឌ័រ ក្នុង NBSAPs

- ប្រទេសនេប៉ាល់ ស្វាស៊ីឡង់ និងអូហ្គាដា ទទួលស្គាល់ស្ត្រីនៅជនបទ ពឹងផ្អែកយ៉ាងខ្លាំងទៅតាមភាពខុសគ្នានៃធនធានធម្មជាតិ។ ជាងនេះប្រទេសស្វាស៊ីឡង់ បានបញ្ជាក់ថាទោះបីជាមានការពឹងផ្អែកលើធនធានធម្មជាតិក៏ដោយ ស្ត្រីមិនត្រូវបានគេបញ្ចូលទៅក្នុងការគ្រប់គ្រងធនធានទាំងនេះ។ ប្រទេសនេប៉ាល់ទទួលស្គាល់ថាពួកគេមាននូវការចូលរួមចំណែកដ៏សំខាន់ និងសំណូមពរឱ្យទទួលស្គាល់ពីតួនាទីរបស់ស្ត្រីដែលមានចំណេះដឹងពីគំរូនិងការប្រើប្រាស់ជីវៈចម្រុះជាមូលដ្ឋាន។ គ្រប់ឯកសារនៃប្រទេសទាំងនេះបានកត់សំគាល់ថាស្ត្រី ចូលរួមរាល់ដំណើរការនៃការធ្វើសេចក្តីសម្រេចដែលទាក់ទងនឹងជីវៈចម្រុះ។
- ស្ត្រីក្នុងប្រទេសជាច្រើនប្រើប្រាស់ធនធាន និងចំណេះដឹងដែលជាក់លាក់។ ឧទាហរណ៍៖ ការទទួលស្គាល់ទាំងនេះបានរកឃើញនៅក្នុង NBSAPs ពីប្រទេសម៉ាលី ប៊ូតង់ និងប្រទេសអែលសាល់វ៉ាឌ័រក្នុងចំណោមប្រទេសផ្សេងទៀត។ ឧ. ក្នុងប្រទេសម៉ាលី ស្ត្រីជាអ្នកប្រើប្រាស់ប្រភេទដើមឈើ Shea ផ្លែអម្ពិល និង fonio។ បន្ថែមពីនេះទៀត ប្រភេទបន្លែម្យ៉ាងត្រូវបានគេឱ្យតម្លៃដោយសារស្ត្រីប្រើប្រាស់វាដើម្បីធ្វើជាកន្ត្រក ត្បាញ និងស្នួន។ ស្ត្រីជនជាតិប៊ូតង់ជាអ្នកគ្រប់គ្រងឬប្រមូលផលប្រភេទពូជមិនត្រូវបានប្រើប្រាស់ពេញលេញដែលបានជួយដល់សន្តិសុខស្បៀង ការបែងចែកប្រភេទកសិកម្មចម្រុះ និងការបង្កើនប្រាក់ចំណូល។ នៅក្នុងសហគមន៍ជាច្រើនក្នុងប្រទេសអែលសាល់វ៉ាឌ័រ ស្ត្រីមានចំណេះដឹងទូលំទូលាយលើភាពចម្រុះនៃរុក្ខជាតិ និងសត្វសម្រាប់ប្រើប្រាស់ជាលក្ខណៈថ្នាំ សង្កូវ ដោយសារតែពួកគេមានតួនាទីជាអ្នកព្យាបាល និងមើលថែរក្សាតាមលក្ខណៈប្រពៃណី។
- ស្ត្រីបានដើរតួយ៉ាងសំខាន់ក្នុងការអភិរក្សជីវៈចម្រុះ និងជាពិសេសការអភិរក្សជីវៈចម្រុះកសិកម្ម។ ឧទាហរណ៍៖ នៅក្នុងប្រទេស យេម៉េន ស្ត្រីធ្វើការជ្រើសរើសពូជទៅតាមលក្ខណៈនិងទទួលខុសត្រូវលើការដាំដុះ "ដំណាំរបស់ស្ត្រី" ដូចជាសណ្តែកដី ល្ពៅ និងបន្លែស្លឹក។ ដំណាំទាំងនេះមានឥទ្ធិពលលើការកើនឡើងនៃជីវៈចម្រុះនិងសន្តិសុខស្បៀងក្នុងកសិដ្ឋានរបស់គេ។ បន្ថែមពីនេះ ក្នុងប្រទេស ម៉ាលី គេបានទទួលស្គាល់ថា ការថែទាំ និងការវិវឌ្ឍនៃប្រភេទដើមឃ្លោក (Calabash) ដោយសារមានការប្រើប្រាស់ពីស្ត្រី។
- សុវត្ថិភាពនិងសេរីភាពសេដ្ឋកិច្ចស្ត្រី ពឹងផ្អែកមួយផ្នែកធំលើសកម្មភាពកសិកម្ម និងការប្រើប្រាស់ធនធានធម្មជាតិ។ ប្រទេសប៊ូតង់ទទួលស្គាល់ថាស្ត្រីអាចនឹងទទួលបានផលប្រយោជន៍យ៉ាងច្រើន ប្រសិនបើសកម្មភាពដែលជីវភាពរបស់ពួកគេត្រូវបានលើកកម្ពស់ការគាំទ្រ និងការប្រើប្រាស់ធនធានប្រកបដោយចីរភាព។ ឧទាហរណ៍នៅក្នុងប្រទេសបេណាំងបង្ហាញថាផ្សិតជាអាហារដ៏សំខាន់សម្រាប់ប្រជាជននៅជនបទ។ សកម្មភាពដែលបានអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលបានបង្កើតនូវឱកាសសម្រាប់រកទីផ្សារផ្សិត ដែលជាលទ្ធផលបង្កើនប្រាក់ចំណូលដល់ស្ត្រី។
- NBSAPs ពីប្រទេស ហ្គីណេ ម៉ូរីស និងម៉ាលីទទួលស្គាល់ថាធនធានមួយចំនួនដែលប្រើប្រាស់ដោយស្ត្រីត្រូវបានប្រមូលឡើងដែលធ្វើឱ្យបាត់បង់នូវការអភិវឌ្ឍ និងការដាំឡើងវិញ។ យុទ្ធសាស្ត្រអភិរក្សនឹងមានប្រសិទ្ធភាពប្រសិនបើស្ត្រីត្រូវបានដាក់បញ្ចូលក្នុងដំណើរការ ។ ឧ. ក្នុងប្រទេសហ្គីណេ ដីខ្សោះជីជាតិត្រូវបានផ្សារភ្ជាប់ជាមួយនឹងបច្ចេកទេសតាមបែបប្រពៃណី ការធ្វើត្រីដែលធ្វើឡើងដោយស្ត្រី បានប្រើប្រាស់ចំនួនដ៏ច្រើននៃព្រៃកោងកាង (Rizophora sp.)។ អ្នកនេសាទភាគច្រើនជាស្ត្រីក្នុងប្រទេសម៉ូរីសពឹងផ្អែកលើការនេសាទមឹក ទោះបីជា

ទិន្នផលបានកម្រិតអតិបរមា ដោយសារពួកគេប្រមូលមឹកញីមុននឹងវាពេញវ័យ។

- ប្រទេសនេប៉ាល់ទទួលស្គាល់ថា ក្នុងចំណោមចំណុចខ្សោយនៃសហគមន៍ព្រៃឈើជាអ្នកដែលប្រើប្រាស់ព្រៃទាំងអស់ មិនមានតំណាងស្មើភាពក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ។ ពួកគេស្នើថាគួរតែមានការយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងការកំណត់អ្នកប្រើប្រាស់ទាំងអស់ដើម្បីប្រាប់ពួកគេដឹងពីសិទ្ធិនិងការទទួលខុសត្រូវរបស់ពួកគេ និងដើម្បីឱ្យមានការចូលរួមពីស្ត្រីនិងក្រុមដែលជួបការលំបាកក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ។
- ចំណុចផ្សាភ្ជាប់រវាងការអប់រំស្ត្រី ការបង្ការ និងការអភិរក្សធនធានធម្មជាតិ។ ក្នុងប្រទេសតូហ្គោ ស្ត្រីទទួលខុសត្រូវលើការគ្រប់គ្រងធម្មជាតិ ប៉ុន្តែពួកគេទទួលបានការអប់រំតិចជាងបុរស ឧ. ទំហំនៃបុរសដែលត្រូវបានបង្រៀនពីការអាន និងសរសេរមានអត្រាខ្ពស់ (៦៩%) ជាងស្ត្រីដែលមានត្រឹមតែ (៣៨%)។ ការយល់ដឹងរបស់ស្ត្រីពីការវិចរិលធនធានធម្មជាតិនៅមានកម្រិត បណ្តាលមកពីកង្វះខាតការអប់រំ ការរារាំង ការយល់ដឹងរបស់ស្ត្រីលើការអនុវត្តប្រកបដោយចីរភាព។
- ក្នុងប្រទេសកេនយ៉ា លីបង់ និងស៊ីមបាវេ បានលើកឡើងពីសមភាពយេនឌ័រ ការប្រើប្រាស់និងជាម្ចាស់កម្មសិទ្ធិដីធ្លី។ ប្រទេសកេនយ៉ា បានកំណត់យកដីជាធនធានធម្មជាតិដ៏សំខាន់បំផុតរបស់ប្រទេស និងទទួលស្គាល់ថាទោះបីជាច្បាប់លក្ខន្តិកៈ មិនបានហាមឃាត់ស្ត្រីមិនឱ្យកាន់កាប់ដីធ្លីក៏ដោយ ស្ត្រីនៅតែប្រឈមនឹងផលលំបាកជាច្រើនដែលទាក់ទងនឹងកម្មសិទ្ធិដីធ្លី។
- NBSAP របស់ប្រទេសម៉ាឡាវី បង្ហាញថា ទាំងជម្ងឺ - មេរោគអេដស៍ និងយេនឌ័រ ជាបញ្ហាគន្លឹះ ដែលមានផលប៉ះពាល់ទៅលើជីវៈចម្រុះ។ បញ្ហាទាំងនេះនឹងត្រូវដាក់បញ្ចូលទៅក្នុងកម្មវិធីជីវៈចម្រុះរបស់ប្រទេស។
- ភាគីមួយចំនួន ដូចជាប្រទេសបេលី បេណាំង ម៉ាល់ឌីវ និងកោះម៉ាស្សល បានដាក់បញ្ចូលក្រុមស្ត្រីក្នុងដំណើរការពិគ្រោះយោបល់ដើម្បីបង្កើត NBSAP។ លើសពីនេះ NBSAP របស់ប្រទេសនេប៉ាល់ បានស្នើឱ្យមានការបង្កើតក្រុមស្ត្រី និងបុរសដាច់ដោយឡែកពីគ្នាដើម្បីធានាការចូលរួមយ៉ាងសកម្មរបស់ស្ត្រី។ ការដាក់បញ្ចូលស្ត្រីនិងបញ្ហារបស់ពួកគេប្រកបដោយប្រសិទ្ធភាពទៅក្នុងដំណើរការនៅថ្នាក់មូលដ្ឋាននិងថ្នាក់អន្តរជាតិមិនបានពេញលេញ ដោយសារក្នុងប្រទេសមួយចំនួនបុរសនៅតែជាអ្នកគ្រប់គ្រងលើផ្នែកសាធារណៈ និងនៅក្នុងក្រុមការងារជាច្រើនដែលមានការយល់ខុសថាបុរសជាអ្នកជានាទស្សនទាន "សហគមន៍"។



លក្ខណៈមូលដ្ឋាននៃ NBSAP គឺថាក្រុមសង្គមទាំងអស់ចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការនិងយុទ្ធសាស្ត្រនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ភាពជាតំណាងពិតប្រាកដ ានទាមទារឱ្យមានការទទួលស្គាល់លក្ខណៈខុសគ្នានៃភាគីពាក់ព័ន្ធទាំងអស់ទៅលើភេទ អាយុ ក្រុមជនជាតិដើមភាគតិច ប្រាក់ចំណូល មុខរបរ និងស្ថានភាពគ្រួសារ ក្នុងចំណោមកត្តាផ្សេងៗទៀត។

ជាការពិត មិនមានគោលការណ៍ណែនាំ ឬអាណត្តិច្បាស់លាស់លើការដាក់បញ្ចូលយេនឌ័រ ក្នុង NBSAPs (រហូតដល់កិច្ចប្រជុំឆ្នាំ២០០៧ នៃ WG RI–2 ក្នុងទីក្រុងប៉ារីស) ប្រទេសមួយចំនួនដែលបានចាប់ផ្តើមដាក់បញ្ចូលនូវប្រធានបទ

ទោះបីជាក្នុងការបង្ហាញពីយុទ្ធសាស្ត្រយេនឌ័រច្បាស់លាស់ ឬក៏តាមរយៈការដាក់បញ្ចូលការគិតគូរពីយេនឌ័រក្នុងផ្នែកមួយចំនួននៃ NBSAP ។

ការវិភាគលើ NBSAPs ត្រូវបានធ្វើឡើងនៅដើមឆ្នាំ២០០៨។ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៨ បានកំណត់ថារដ្ឋភាគី១៦០ ក្នុងចំណោម ១៩០ រដ្ឋភាគីសរុប នៃ CBD បានបង្ហាញ NBSAP ជាមួយនឹងរដ្ឋចំនួន១៤១ ដែលបានពិនិត្យ មាន៧៧រដ្ឋភាគីបានបញ្ជាក់ពីយេនឌ័រនិងទិដ្ឋភាពនានាដែលទាក់ទងនឹងស្ត្រីដោយផ្អែកលើការវិភាគរបស់ Quesada-Aguilar និង Mata (ឆ្នាំ២០០៨) ឧទាហរណ៍មួយចំនួនដែលមានប្រទេសនានា ដោះស្រាយបញ្ហាយេនឌ័របានបង្ហាញក្នុងប្រអប់២ខាងលើ។

ក្នុងឆ្នាំ២០០៧ ដូចដែលបានបញ្ជាក់ខាងលើ លេខាធិការប្រតិបត្តិ CBD បង្កើតឱ្យមាននូវដំណើរការក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងអនុសញ្ញា។ ជាផ្នែកមួយលើការអបអរសាទរ ទិវាអន្តរនារី (៨ មីនា ២០០៧) លេខាធិការប្រតិបត្តិបានតែងតាំងជនបង្គោលយេនឌ័រ នៅក្នុងលេខាធិការដ្ឋាន។

ជាមួយនឹងទិសដៅបច្ចេកទេស និងការគាំទ្រពី IUCN នៅបំណាច់ឆ្នាំ២០០៧និងដើមឆ្នាំ២០០៨ លេខាធិការដ្ឋាន CBD បានអនុវត្តដំណើរការផ្ទៃក្នុង ក្នុងគោលបំណងរៀបចំយុទ្ធសាស្ត្រយេនឌ័រដំបូងនៅក្នុងអនុសញ្ញា។ ផែនការនេះត្រូវបានយល់ព្រមដោយការិយាល័យ CBD នៅខែកុម្ភៈ ឆ្នាំ២០០៨ និងដោយ COP9 នៅខែមិថុនាឆ្នាំដដែល៖ “COP ស្វាគមន៍ការរៀបចំផែនការសកម្មភាពយេនឌ័រនៅក្រោម CBD ដូចដែលមានចែងក្នុងឯកសារ UNEP/CBD/COP/9/L.4 និងស្នើឱ្យរដ្ឋភាគីគាំទ្រលេខាធិការដ្ឋានក្នុងការអនុវត្តរបស់វា” នៅក្នុងន័យនេះ CBD បង្កើតនូវគោលការណ៍ជាប្រវត្តិសាស្ត្រដោយក្លាយជាកិច្ចព្រមព្រៀងបរិស្ថានពហុភាគី (MEA) ដំបូងបំផុត ជាមួយនឹងយុទ្ធសាស្ត្រក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងចំណោមស្ត្រីនិងបុរស។

### អនុសញ្ញាសហប្រជាជាតិ ប្រយុទ្ធប្រឆាំងនឹងវហោស្ថានកម្ម (UNCCD)

នៅដើមទសវត្សរ៍ទី៩០ គណៈកម្មាធិការចរចាអន្តររដ្ឋាភិបាលស្តីពី (INCD) បានរៀបចំ UNCCD និយាយអំពីការប្រឆាំងនឹងវហោស្ថានកម្មដោយមានការចូលរួមទាំងស្ត្រី និងបុរស ក្នុងការរៀបចំសកម្មភាពអភិវឌ្ឍដីវហោស្ថានឱ្យបានប្រសិទ្ធភាព។ INCD បានទទួលស្គាល់ គ្រាន់តែការចូលរួមមួយមុខគឺមិនធ្វើឱ្យសម្រេចបានទេ តែត្រូវទាមទារឱ្យមានសកម្មភាពគាំទ្រ ពិសេសក្នុងការផ្តល់ឱកាសចូលរួមសម្រាប់ស្ត្រី ដូចជាការធ្វើយុទ្ធនាការការបណ្តុះបណ្តាល កសាងសមត្ថភាព និងការអប់រំ។

អនុសញ្ញានេះជាលិខិតតូបករណ៍មួយ មានទំនាក់ទំនងរវាង បរិបទបរិស្ថាន សមភាពយេនឌ័រ និងការចូលរួមក្នុងសង្គម។ កត្តាដោយសារ UNCCD តែងតែផ្សាភ្ជាប់ការអភិវឌ្ឍនិងការលុបបំបាត់ភាពក្រីក្រ (ដោយប្រៀបធៀបជាមួយនឹង MEA ផ្សេងៗទៀត) ដោយមូលហេតុថាប្រទេសមកពីតំបន់ខាងត្បូងដឹកនាំកិច្ចសហការនេះ។

ក្នុងឆ្នាំដំបូងៗនៃការអនុវត្ត ការប្តេជ្ញាចិត្តដើម្បីជម្រុញឱ្យមានសមភាពរវាងស្ត្រីនិងបុរស មានជាធាតុដ៏សំខាន់ក្នុងសកម្មភាពទាក់ទងជាច្រើនដែលធ្វើឡើងដោយ UNCCD ក្នុងកម្រិតមូលដ្ឋាន ជាតិ អន្តរជាតិ តំបន់ និងពិភពលោក។ ក្នុងការ

អនុវត្តអនុសញ្ញា រដ្ឋាភិបាល ក៏ដូចជា អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ បានផ្តល់ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់កម្មវិធី ដែលផ្តោតការយកចិត្តទុកដាក់ខ្លាំងទៅលើស្ត្រី។ បន្ថែមពីនេះ UNCCD ត្រូវបានកត់សម្គាល់លើកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីពង្រឹងតួនាទីស្ត្រីលើគ្រប់ផ្នែកទាំងអស់នៃការអនុវត្ត។

អនុសញ្ញាមានការរីកចម្រើនយ៉ាងខ្លាំង ក្នុងការដាក់បញ្ចូលសមភាពរវាងស្ត្រីនិងបុរស ក្នុងអភិបាលកិច្ចរបស់ UNCCD និងពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើងនៃចំនួនការចូលរួមរបស់ស្ត្រីជាថ្នាក់ដឹកនាំក្នុងអង្គភាព។ ទោះបីជាយ៉ាងណាក៏ដោយ នៅមានដំណើរផ្លូវដ៏វែងឆ្ងាយទៀត សមភាពរវាងស្ត្រី និងបុរស មានតំណាងស្មើគ្នា និងមានប្រតិភូចូលរួមក្នុងសន្និសីទភាគីពាក់ព័ន្ធ (COP) បន្តអំពាវនាវឱ្យមានការកែតម្រូវទៅលើវិសមភាពយេនឌ័រ ជាពិសេសការគោរពទៅលើការចូលរួមតិចតួចរបស់ស្ត្រីនៅក្នុងក្រុមអ្នកជំនាញ (Rooster of Experts) ក្រុមការងារបណ្ដោះអាសន្នសម្រាប់ពិនិត្យការតាមដានការអនុវត្តអនុសញ្ញាស្តីពីជីវៈចម្រុះ និងនៅក្នុងដំណើរការ ការរៀបចំកម្មវិធីសកម្មភាពជាតិ។

ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសន្និសីទ COP រហូតមកដល់បច្ចុប្បន្ន សេចក្តីសម្រេចលើ តួនាទីរបស់ស្ត្រីនិងការបញ្ជ្រាបយេនឌ័រមិនទាន់បានដើរតួសំខាន់ក្នុងកិច្ចពិភាក្សាសន្និសីទ COP ឬនៅក្នុងគណៈកម្មាធិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៅឡើយទេ។ ការពិនិត្យទៅលើសេចក្តីសម្រេចក្នុងកិច្ចពិភាក្សាផ្សេងៗបង្ហាញថា បញ្ហាដែលទាក់ទងនឹងតួនាទីស្ត្រី និងយេនឌ័រ ត្រូវបានលើកយកមកពិភាក្សាមិនបានទូលំទូលាយ ដោយសេចក្តីសន្និដ្ឋាននិងអនុសាសន៍ទូទៅ តម្រូវឱ្យមានការងារជាច្រើនទៀត មុននឹងក្លាយជាសកម្មភាពដែលអនុវត្តបាន។

អ្នកដែលត្រូវបានសម្ភាសន៍ដោយ Knabe និង Poulsen (ឆ្នាំ២០០៤) បានបញ្ជាក់ថា យេនឌ័រ និងតួនាទីរបស់ស្ត្រីជារឿយៗត្រូវបានគេមើលឃើញថា គ្រាន់តែជាការនិយាយ និងហាក់បីដូចជាមិនមានសកម្មភាពជាក់លាក់។ បញ្ហានេះ អាចមកពីសមត្ថភាពនៅមានកម្រិត និងគួរតែត្រូវបានវិភាគនិងដោះស្រាយក្នុងគំនិតផ្តួចផ្តើមនានារបស់ UNCCD នៅពេលអនាគត។

## ២.៥ ការជាប់ទាក់ទងគ្នានៃគោលនយោបាយ

ការភ្ជាប់នឹងគោលនយោបាយ ជាកត្តាសំខាន់ផ្សាភ្ជាប់ទៅលើប្រសិទ្ធភាពនិងចីរភាព ដែលធានាថារាល់គោលនយោបាយផ្សេងទៀត នឹងមិនធ្វើឱ្យអន្តរាយដល់កិច្ចខិតខំដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ដូចដែលបានកំណត់ដោយ Lambrou និង Laub (ឆ្នាំ២០០៤) ការកើនឡើងនៃលិខិតតូបករណ៍អន្តរជាតិ ដែលមានប្រភពពីច្បាប់រឹង (ដូចជាអនុសញ្ញាទីក្រុងរីយ៉ូ អនុសញ្ញា ស៊ី-ដ...) និងច្បាប់ទន់ (ដូចជា របៀបវារៈ២១ផែនការអនុវត្តទីក្រុង ចូហែនបឺក គោលដៅអភិវឌ្ឍសហស្សវត្សរ៍ សន្និសីទទីក្រុងប៉េកាំងដើម្បីសកម្មភាព...) បង្កើតឱ្យមានជាដំណើរការត្រួតពិនិត្យកាន់តែមានការលំបាក។ សុខដុមនីយកម្មនៃនីតិវិធីនិងវិធីសាស្ត្ររវាងលិខិតតូបករណ៍អន្តរជាតិ អាចសម្របសម្រួលការត្រួតពិនិត្យ លិខិតតូបករណ៍ទាំងនេះចេញពីគោលគំនិតអន្តរវិស័យដូចជា យេនឌ័រ ការអភិវឌ្ឍប្រកបដោយចីរភាព ប្រឆាំងនឹងភាពក្រីក្រ និងការប្រែប្រួលអាកាសធាតុ។

ក្នុងន័យលិខិតតូបករណ៍ច្បាប់ ការភ្ជាប់នឹងគោលនយោបាយគួរត្រូវបានជានាជាផ្នែក៣ផ្សេងៗគ្នា ទាក់ទងនឹងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ៖

- **ភាពភ្ជាប់រវាង "អនុសញ្ញាទីក្រុងរីយ៉ូ"។** ទាំងការប្រែប្រួលអាកាសធាតុ និងយេនឌ័រមានឥទ្ធិពលលើគ្រប់អនុសញ្ញាទីក្រុងរីយ៉ូ។ អនុសញ្ញានេះមានអត្ថប្រយោជន៍ក្នុងការប្រើប្រាស់វិធីសាស្ត្រប្រហាក់ប្រហែលគ្នា លើការបញ្ជ្រាបយេនឌ័រ និងការលើកកម្ពស់ការទទួលផលនៃបទពិសោធន៍ជាអន្តរវិស័យ។ ដោយសារ CBD ស្ថិតនៅជំណាក់ការការអភិវឌ្ឍក្នុងការបញ្ជ្រាបយេនឌ័រ វិធីសាស្ត្រដែលដាក់ឡើងដោយលេខាធិការដ្ឋាន CBD អាចត្រូវប្រើជាប្រភពលើការគិតគូរសម្រាប់អនុសញ្ញាពីរផ្សេងទៀតពីការប្រែប្រួលអាកាសធាតុនិងវហោស្ថាន។
- **វិធីសាស្ត្រដែលបានចែករំលែកនៅថ្នាក់ជាតិក្នុងចំណោម NFSAPs NAPAs និងNAPs។** ដោយសារតែគ្រប់អនុសញ្ញាទីក្រុងរីយ៉ូទាំងអស់ស្ថិតក្នុងពេលជាមួយគ្នានឹងបញ្ហាការប្រែប្រួលអាកាសធាតុ ការអនុវត្តប្រកបដោយសុខដុមនីយកម្ម គួរត្រូវបានធ្វើឡើងនៅថ្នាក់ជាតិទាក់ទងនឹងវិធីសាស្ត្ររបស់ពួកគេស្តីពីការប្រែប្រួលអាកាសធាតុ និងយេនឌ័រ (NBSAPs, NAPAs និង NAPs) ដែលផ្តល់ជាវិធីសាស្ត្រជាប្រព័ន្ធក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងផ្នែក បរិស្ថាន។ ដោយសារ NBSAPs បានធ្វើឡើងរួចជាស្រេចនូវជំហានសំខាន់ៗដើម្បីលើកកម្ពស់សមភាពយេនឌ័រ NAPA ក៏បានរៀបចំដកស្រង់យកជាបទពិសោធន៍។ NAPA ក៏បានដោះស្រាយនូវបញ្ហាយេនឌ័រ (Pearl, ការទំនាក់ទំនងផ្ទាល់ខ្លួន) មួយចំនួនរួចមកហើយ។ ឧទាហរណ៍៖
  - ប្រទេសអ៊ូហ្គង់ដា បានដាក់បញ្ចូលនូវបញ្ហាសមធម៌និងយេនឌ័រក្នុងលក្ខណៈវិនិច្ឆ័យដោយធ្វើការគិតគូរក្រុមដែលងាយចាញ់ប្រៀប។ **NAPA** ក៏បានបង្ហាញពីតម្រូវការក្នុងការរៀបចំការណែនាំសម្រាប់ការបញ្ជ្រាបបញ្ហាយេនឌ័រ។
  - ផែនការបន្សាំរបស់ប្រទេសប៊ូរុនឌី បញ្ជាក់ជាចំណុចមួយនៃគោលបំណងការបង្កើនភាពអង់អាចរបស់ស្ត្រី។
  - សាធារណរដ្ឋប្រជាធិបតេយ្យ កុងហ្គោ និងហ្គីណេ ធ្វើការចងក្រងដោយទទួលស្គាល់ពីតួនាទីរបស់ស្ត្រីក្នុងវិស័យធនធានទឹក កសិកម្ម ការអភិវឌ្ឍសហគមន៍ និងភាពងាយរងគ្រោះរបស់ពួកគេ។
  - ប្រទេសប៊ូតង់ និងម៉ាឡាវី បញ្ចូលនូវចំណុចយោងទៅនឹងយេនឌ័រដែលទាក់ទងនឹងការសម្រេចឱ្យបានគោលដៅអភិវឌ្ឍសហស្សវត្សរ៍ និងការចូលរួមរបស់ស្ត្រី។
- **ភាពភ្ជាប់រវាង NAPA និងឧបករណ៍ច្បាប់ជាតិផ្សេងៗទៀតដែលទាក់ទងនឹងសមភាពយេនឌ័រ។** នៅក្នុងប្រទេសប្រជាធិបតេយ្យ សមភាពយេនឌ័រ ជាចំណុចសំខាន់មួយនៃគោលការណ៍ច្បាប់សំខាន់ៗនៃប្រព័ន្ធច្បាប់ជាតិ។ ក្នុងករណីមួយចំនួន ការប្តេជ្ញាចិត្តនៃប្រទេសនានាលើសមភាពយេនឌ័រត្រូវបានបង្ហាញនិងធានា ដោយលិខិតតូបករណ៍នានាដូចជា៖ រដ្ឋធម្មនុញ្ញ កិច្ចព្រមព្រៀងអន្តរជាតិនានាដែលប្រទេសទាំងនោះជារដ្ឋភាគី"ច្បាប់ការប្រព្រឹត្តដោយស្មើគ្នា"និងបញ្ញត្តិជាតិផ្សេងៗនានា។ ដូច្នេះ ការបញ្ជ្រាបយេនឌ័រនៅក្នុង NAPA ផ្សាភ្ជាប់ប្រព័ន្ធច្បាប់ជាតិ និងធានាថា កម្មវិធីបន្សាំជាតិមិនមានការរើសអើង ដោយបំពានលើឧបករណ៍ច្បាប់ជាតិ និងអន្តរជាតិទាក់ទងនឹងសមភាពយេនឌ័រ។

ជាកំណត់សម្គាល់ចុងក្រោយ ជាការសំខាន់ដើម្បីបញ្ជាក់ថា UNFCCC ត្រូវបានធ្វើឡើងក្នុងក្របខណ្ឌ អង្គការ

សហប្រជាជាតិ រាល់សេចក្តីសម្រេចនៃមហាសន្និបាត និងអនុសញ្ញា ឬសន្ធិសញ្ញាដែលទាក់ទងនឹងបញ្ហាយេនឌ័រស្ថិតជាផ្នែកមួយនៃអាណត្តិ។

## ឯកសារស្រាវជ្រាវ


Aguilar, L. et al. (2008). CBD Gender Plan of Action. UNEP/CBD/COP/9/INF/12/R. May 23, 2008.

Quesada-Aguilar, A. and Mata, G. (2008). Gender and National Biodiversity Strategies and Action Plans (NBSAPs). Fact sheet. IUCN-CBD.

Knabe, F. and Poulsen, L. (2004). How the UN Convention to Combat Desertification and Drought Has Promoted the Role of Women in Decision- Making. Switzerland: IUCN.

Lambrou, Y. and Laub, R. (2004). Gender Perspective on the Conventions on Biodiversity, Climate Change and Desertification. Italy: Natural Resource Management and Environment Department, FAO.

# កំណត់ត្រាសម្រាប់អ្នកសម្របសម្រួល

ជាការសំខាន់ណាស់ ដែលអ្នកសម្របសម្រួលត្រូវយល់ដឹងពីគ្រប់លិខិតតូបករណ៍ផ្លូវច្បាប់ទាំងអស់ដែលមាននៅក្នុងជំពូកនេះមុននឹងចាប់ផ្តើមវគ្គបណ្តុះបណ្តាល។ នេះអាចជាជំនួយឱ្យអ្នកសម្របសម្រួលយល់ដឹងបន្ថែមពីច្បាប់ និងកិច្ចព្រមព្រៀងជាតិ និងអន្តរជាតិដែលអនុវត្តនៅក្នុងតំណាងប្រទេសអ្នកចូលរួមផងដែរ នៅពេលដែលអ្នកយល់ដឹងបន្ថែមលើកិច្ចព្រមព្រៀងជាតិនិងអន្តរជាតិ និងច្បាប់ដែលពាក់ព័ន្ធនឹងប្រទេសតំណាងរបស់អ្នកចូលរួម។



បន្ថែមទៅលើទស្សនទានផ្លូវច្បាប់នៅមានជាតុផ្សេងៗទៀតដែលអាចប្រើប្រាស់សម្រាប់ "ជដែកអំពីករណីរបស់អ្នក" ទាក់ទងនឹងសារៈសំខាន់នៃគំនិតផ្តួចផ្តើម យេនឌ័រ និងការប្រែប្រួលអាកាសធាតុក្នុងកម្មវិធី និងគោលនយោបាយ។

តម្លៃបន្ថែមនៃការបញ្ជ្រាបយេនឌ័រមាន៣ផ្នែក៖ សមភាពនិងយុត្តិធម៌ គណនេយ្យភាព និងការទទួលខុសត្រូវ និងប្រសិទ្ធភាពនិងចីរភាព។ ផ្នែកទាំងនេះផ្តល់នូវលទ្ធភាពនៃការបញ្ជ្រាបយេនឌ័រនៅក្នុងបរិបទអភិវឌ្ឍ និងផ្តល់នូវការជដែកវែកញែកសម្រាប់ស្វែងរកសមភាពយេនឌ័រ។

### សមភាព និងយុត្តិធម៌

- បើយើងចង់បន្តគោលការណ៍ប្រជាធិបតេយ្យ និងសិទ្ធិមនុស្សជាមូលដ្ឋានដែលជាតម្លៃក្នុងការទាមទារសមភាពយេនឌ័រនោះ យើងក៏ត្រូវបន្តការបញ្ជ្រាបយេនឌ័រផងដែរ។
- ភាពជាតំណាងនិងការចូលរួមស្មើគ្នារវាងបុរស និងស្ត្រីជាបញ្ហាយុត្តិធម៌។
- ភាគច្រើនលើសលប់រដ្ឋភាគីនៃ UNFCCC ជាហត្ថលេខីនៃកិច្ចព្រមព្រៀងផ្សេងៗទៀតដែលអំពាវនាវឱ្យមានសមភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ។

### គណនេយ្យភាពនិងការទទួលខុសត្រូវ

- ជាទូទៅ ការបញ្ជ្រាបយេនឌ័រជាលក្ខខណ្ឌដំបូងដើម្បីបង្កើតឱ្យមានសម្ព័ន្ធភាព ឬភាពជាដៃគូផ្លូវការជាមួយនឹងម្ចាស់ជំនួយ និងស្ថាប័នផ្សេងៗទៀត។
- ដោយសារស្ត្រី និងបុរសជាចំណែកនៃប្រជាជនពិភពលោកសរុបរាល់គំនិតផ្តួចផ្តើមដែលមិនបានទទួលស្គាល់ និងមិនបានដោះស្រាយយេនឌ័រស្មើគ្នាជាកង្វះខាតមួយដ៏ធំធេង។
- គណនេយ្យភាពទៅលើដំណោះស្រាយយេនឌ័រនៅក្នុងយន្តការអង្គការសហប្រជាជាតិ។
- ទំនួលខុសត្រូវសង្គមដើម្បីបន្តនូវគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សង្គម ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយចីរភាព។

**ប្រសិទ្ធភាពនិងចីរភាព**

- មានការសិក្សាជាច្រើនបានបង្ហាញនូវការពិតដែលមិនអាចប្រកែកបានថា ការគិតគូរពីបញ្ហាស្ត្រីនិងបុរស ដោយស្មើភាពគ្នានៅក្នុងគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍប្រកបដោយចីរភាព នឹងទទួលបានលទ្ធផល ប្រកបដោយប្រសិទ្ធភាព។
- ការដាក់បញ្ចូលវិធីសាស្ត្រលើកកម្ពស់កម្មវិធីបញ្ជ្រាបយេនឌ័រ និងប្រសិទ្ធភាពស្ថាប័ន តាមរយៈការកំណត់គោលដៅ ការយល់ដឹង និងការចូលរួមរបស់ប្រជាជនកាន់តែច្រើនឡើង។
- ការសិក្សាបានរកឃើញថាវិសមភាពយេនឌ័រធ្វើឱ្យប៉ះពាល់កំណើនសេដ្ឋកិច្ចរយៈពេលវែង (ធនាគារពិភពលោក) និងវាមានទំនាក់ទំនងដ៏ច្បាស់រវាង យេនឌ័រ និងផលិតផលក្នុងស្រុកសរុបសម្រាប់បុគ្គលម្នាក់ (វេទិកាសេដ្ឋកិច្ចពិភពលោក)។



## កិច្ចការសម្រាប់ជំពូកនេះ

| សកម្មភាព | នីតិវិធី | ពេលវេលា |
|---|---|---|
| យល់ដឹងពីក្របខណ្ឌផ្លូវច្បាប់ទាក់ទងនឹងយេនឌ័រ និងការប្រែប្រួលអាកាសធាតុផ្លាស់ប្តូរសំខាន់ៗ | រៀបចំបទបង្ហាញ ជាមួយនឹងក្នុងប្រធានបទទាក់ទងនឹងសិទ្ធិមនុស្ស ការអភិវឌ្ឍប្រកបដោយចីរភាព សមភាពយេនឌ័រ និងគ្រោះមហន្តរាយ។ ប្រើប្រាស់តារាង ១ ដែលមានបញ្ចូលនៅក្នុងជំពូកនេះ។ ក្រោយពីបទបង្ហាញនេះបានបញ្ចប់ អនុញ្ញាតឱ្យមានពេលវេលាសម្រាប់អ្នកចូលរួមពិភាក្សាលើការជាប់ពាក់ព័ន្ធនៃក្របខណ្ឌច្បាប់ | ៣០នាទី<br><br>១០នាទី |
| ការវិភាគស៊ីជម្រៅ តាមនីតិវិធី និងការអនុវត្តច្បាប់មួយចំនួនសម្រាប់គោលនយោបាយជាតិ និងអន្តរជាតិ និងដំណើរការនៃធ្វើសេចក្តីសម្រេចដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | វិធីសាស្ត្រ **"តើធ្វើដូចម្តេចដើម្បីចងភ្ជាប់លិខិតតូបករណ៍ ? ចុះតើលិខិតតូបករណ៍ទាំងនោះមានទំនាក់ទំនងយ៉ាងដូចម្តេចដែរជាមួយនឹង UNF-CC ?"** | ១ម៉ោង ១៥នាទី |

**តារាង ១.** សង្ខេបលិខិតតូបករណ៍ផ្លូវច្បាប់សំខាន់ៗ

## សិទ្ធិមនុស្ស

| | |
|---|---|
| **ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ** | |
| ជាតុចូលចម្បង | នៅខែមីនា ឆ្នាំ២០០៨ នៅកិច្ចពិភាក្សាទី៧ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានអនុម័តព្រមព្រៀងលើដំណោះស្រាយស្តីពីសិទ្ធិមនុស្ស និងការប្រែប្រួលអាកាសធាតុ ការព្រួយបារម្ភ បានបង្ហាញថាការប្រែប្រួលអាកាសធាតុជាការគំរាមកំហែងបន្ទាន់និងមានលក្ខណៈយូរអង្វែងដល់មនុស្ស និងសហគមន៍ជុំវិញពិភពលោក និងមានទំនាក់ទំនងសិទ្ធិមនុស្ស។ ការិយាល័យអ្នកទទួលបន្ទុកសិទ្ធិមនុស្សជាន់ខ្ពស់បានលើកទឹកចិត្តក្នុងការសិក្សាវិភាគពីទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុនិងសិទ្ធិមនុស្ស។ |
| **សេចក្តីថ្លែងការណ៍សហប្រជាជាតិ ស្តីពីជនជាតិដើមភាគតិច** | |
| ជាតុចូលចម្បង | នៅខែកញ្ញា ឆ្នាំ២០០៧ បន្ទាប់ពីមានការចរចាគ្នាជាង២០ឆ្នាំ សេចក្តីថ្លែងការណ៍សហប្រជាជាតិស្តីពីជនជាតិដើមភាគតិច ( DECRIPS ) ត្រូវបានអនុម័ត។ |
| អត្ថបទជាក់លាក់ | DECRIPS បានហាមឃាត់ជាពិសេសលើការរើសអើងប្រឆាំងនារីភេទ ដោយបានចែងថា រាល់សិទ្ធិ និងសេរីភាពដែលបានទទួលស្គាល់ក្នុងសេចក្តីថ្លែងការណ៍ត្រូវជានាស្មើភាពគ្នាសម្រាប់ស្ត្រីនិងបុរសដែលជាជនជាតិដើមភាគតិច។ កត្តានេះបានកំណត់ជាបទដ្ឋានសម្រាប់ការអនុវត្តសេចក្តីថ្លែងការណ៍។<br>**មាត្រា១៨** បានបញ្ជាក់ថា "ជនជាតិដើមភាគតិច មានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេចក្នុងបញ្ហាដែលមានផលប៉ះពាល់ដល់សិទ្ធិរបស់ពួកគេតាមរយៈតំណាងដែលជ្រើសតាំងដោយពួកគេផ្ទាល់ស្របតាមនីតិវិធីរបស់ពួកគេផ្ទាល់..."<br>**មាត្រា៣១** បានបញ្ជាក់ជាថ្មីថា "ជនជាតិដើមភាគតិចមានសិទ្ធិក្នុងការកំណត់និងរៀបចំអាទិភាព និងយុទ្ធសាស្ត្រសម្រាប់កិច្ចអភិវឌ្ឍ ឬការប្រើប្រាស់ដីធ្លី ខណ្ឌប្រទល់ និងធនធានផ្សេងៗទៀត" |
| **សន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្ស** | |
| ជាតុចូលចម្បង | នៅឆ្នាំ១៩៩៣ សន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្សក្នុងទីក្រុង Vienna រដ្ឋភាគី១៧១ អនុម័តលើសេចក្តីថ្លែងការណ៍ទីក្រុង Vienna និងកម្មវិធីសកម្មភាព។ |
| អត្ថបទជាក់លាក់ | **មាត្រា១១** នៃសេចក្តីថ្លែងការណ៍ បានលើកឡើងថា "សិទ្ធិក្នុងការអភិវឌ្ឍគួរត្រូវបានអនុវត្ត ដើម្បីបំពេញតម្រូវការបរិស្ថាន និងការអភិវឌ្ឍប្រកបដោយភាពស្មើភាពរបស់មនុស្សបច្ចុប្បន្ន និងនាពេលអនាគត"។ ជាលទ្ធផលឯកសារនេះទាមទារអង្គភាពត្រួតពិនិត្យសន្ធិសញ្ញា ដើម្បីដាក់បញ្ចូលស្ថានភាពស្ត្រី និងសិទ្ធិមនុស្សរបស់ស្ត្រីនៅក្នុងសេចក្តីសម្រេចនិងរបកគំហើញ ការប្រើប្រាស់ទិន្នន័យយេនឌ័រជាក់លាក់។ ឯកសារនេះក៏បានជំរុញរដ្ឋាភិបាល និងអង្គការថ្នាក់តំបន់និងអន្តរជាតិ ដើម្បីសម្របសម្រួលឱ្យស្ត្រីស្ថិតក្នុងដំណើរធ្វើការសេចក្តីសម្រេច។" |
| **អនុសញ្ញាស្តីពីការទប់ស្កាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ( CEDAW )** | |

| | |
|---|---|
| ធាតុចូលចម្បង | អនុសញ្ញាស្តីពីការទប់ស្កាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ត្រូវបានអនុម័តក្នុងឆ្នាំ១៩៧៩ ដោយមហាសន្និបាតអង្គការសហប្រជាជាតិ។[៣៩] ពិធីសារតាមជម្រើសនៃអនុសញ្ញា ស៊ី-ដ ត្រូវបានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ ក្នុងខែធ្នូ ឆ្នាំ១៩៩៩ ហើយចូលជាធរមាននៅខែធ្នូ ឆ្នាំ២០០០។[៤០] ពិធីសារតាមជម្រើសបង្កើតនូវនីតិវិធីដែលស្ត្រីអាចដាក់ពាក្យបណ្តឹងអំពាវនាវឱ្យមានការស៊ើបអង្កេតលើការរំលោភសិទ្ធិ។ អនុសញ្ញាស៊ី-ដ ត្រូវបានស្គាល់ជាទូទៅថាជាសិទ្ធិសម្រាប់ស្ត្រីស្វែងរកនូវការលើកកម្ពស់ការទទួលយកវិធីសាស្ត្រដើម្បីធានាការលុបបំបាត់រាល់ទម្រង់ផ្សេងៗ (និងគ្រប់កម្រិត) នៃការរើសអើងប្រឆាំងនារីភេទ។ |
| អត្ថបទដាក់លាក់ | អនុសញ្ញា ស៊ី-ដ បានឱ្យនិយមន័យការរើសអើងប្រឆាំងនរីភេទថា៖ "រាល់ការបែងចែក ការដកចេញ ការកំណត់ដាក់លក្ខខណ្ឌ ដោយផ្អែកលើភេទដែលមានចេតនា ឬផលប៉ះពាល់នាំឱ្យអន់ថយ ឬបាត់បង់ការទទួលស្គាល់ ភាពសប្បាយរីករាយ ឬការប្រើប្រាស់ដោយស្ត្រី ការមិនគោរពដល់ស្ថានភាពគ្រួសារពួកគេលើមូលដ្ឋាននៃសមភាពរវាងស្ត្រីនិងបុរសនៃសិទ្ធិមនុស្សនិងសេរីភាពគ្រឹះក្នុងនយោបាយ សេដ្ឋកិច្ចសង្គម វប្បធម៌ ស៊ីវិល ឬផ្នែកផ្សេងទៀត" (មាត្រា១)។<br>**មាត្រា៨**<br>រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ដើម្បីធានាឱ្យស្ត្រីមានឱកាសធ្វើជាតំណាងរដ្ឋាភិបាលនៅថ្នាក់អន្តរជាតិ និងចូលរួមក្នុងកិច្ចការរបស់អង្គការអន្តរជាតិ ដោយផ្អែកលើលក្ខខណ្ឌស្មើភាពជាមួយបុរស និងដោយគ្មានការរើសអើង។<br>**មាត្រា១៣**<br>រដ្ឋភាគី ត្រូវចាត់វិធានការសមស្របនានា ដើម្បីបំបាត់ការរើសអើងប្រឆាំងនារីភេទ ក្នុងវិស័យជីវភាពសេដ្ឋកិច្ច និងសង្គមកិច្ចផ្សេងទៀត ដើម្បីធានា ដោយផ្អែកលើមូលដ្ឋានសមភាពរវាងស្ត្រីនិងបុរសនូវសិទ្ធិដូចគ្នា ជាពិសេស៖<br>(b) សិទ្ធិខ្ចីប្រាក់ពីធនាគារ និងទម្រង់ផ្សេងៗទៀតនៃឥណទានហិរញ្ញវត្ថុ។<br>**មាត្រា១៤**<br>១. រដ្ឋភាគីត្រូវគិតគូរដល់បញ្ហាពិសេសដែលស្ត្រីនៅជនបទប្រឈមមុខ និងតួនាទីសំខាន់របស់ស្ត្រីជនបទក្នុងការរក្សាភាពគង់វង្សសេដ្ឋកិច្ចគ្រួសាររបស់ខ្លួន រួមមានការងាររបស់ពួកគេក្នុងផ្នែកគ្មានចំណូលសេដ្ឋកិច្ចផង។ រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីធានាការអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះសម្រាប់ស្ត្រីនៅជនបទ។<br>២. រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនារីភេទនៅជនបទដើម្បីធានា ដោយផ្អែកលើមូលដ្ឋានសមភាពរវាងស្ត្រីនិងបុរស នូវការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍជនបទ និងទទួលអត្ថប្រយោជន៍ពីការអភិវឌ្ឍជនបទ និងជាពិសេស ត្រូវធានាឱ្យស្ត្រីជនបទទាំងនោះនូវសិទ្ធិ៖<br>(a) ចូលរួមពេញលេញក្នុងការតាក់តែង និងអនុវត្តផែនការអភិវឌ្ឍ នៅគ្រប់លំដាប់ថ្នាក់។<br>(d) ទទួលបានការបណ្តុះបណ្តាលនិងការអប់រំក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធគ្រប់ប្រភេទ រួមមានការអប់រំអក្ខរកម្មមុខរបរផងព្រមទាំង ជាពិសេសអត្ថប្រយោជន៍ខាងសេវាសហគមន៍ និងការពន្យល់ ផ្សព្វផ្សាយរបស់ថ្មី ដើម្បីបង្កើនសមត្ថភាពបច្ចេកទេសរបស់ស្ត្រី។<br>(e) ចូលរួមក្នុងគ្រប់សកម្មភាពរបស់សហគមន៍<br>(f) មានសិទ្ធិទទួលបានឥណទាននិងប្រាក់កម្ចីខាងកសិកម្ម សេវារកទីផ្សារ បច្ចេកវិទ្យាសមស្របនិងការគិតគូរស្មើគ្នាក្នុងការកែទម្រង់ដីធ្លីនិងកសិកម្ម ព្រមទាំងក្នុងគម្រោងបែងចែកដីធ្លី។ |

៣៩. As of September 2007 CEDAW had been ratified by 185 countries (ratifications, accessions and successions): http://www.ohchr.org/english/law/cedaw.htm.

៤០. As of September 2007, 90 countries had ratified the Optional Protocol to CEDAW.

## សមភាពយេនឌ័រ

| | |
|---|---|
| **កិច្ចពិភាក្សាទី៥២ នៃគណៈកម្មការស្តីពីស្ថានភាពស្ត្រី** | |
| ជាតុចូលចម្បង | កិច្ចពិភាក្សាទី៥២នៃគណៈកម្មការស្តីពីស្ថានភាពស្ត្រី (ឆ្នាំ២០០៨) បានកំណត់គោលគោលគំនិតយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុថាជាបញ្ហាសំខាន់ដែលកំពុងលេចឡើង។ |
| អត្ថបទជាក់លាក់ | ដំណោះស្រាយ ២១(jj) ស្តីពីការធ្វើហិរញ្ញប្បទានសម្រាប់សមភាពយេនឌ័រនិងការបង្កើនភាពអង់អាចដល់ស្ត្រី (E/CN.6/2008/l.8)៖<br>រដ្ឋាភិបាលត្រូវបានទទូចឱ្យដាក់បញ្ចូល៖ “គោលគំនិតយេនឌ័រទៅក្នុងការរៀបចំ អនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ និងការធ្វើរបាយការណ៍នៃគោលនយោបាយការពង្រឹងយន្តការ និងផ្តល់ធនធានសមស្របដើម្បីធានាបាននូវការចូលរួមពេញលេញ និងស្មើភាពរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិតស្តីពីបញ្ហាបរិស្ថាន ជាពិសេសលើយុទ្ធសាស្ត្រទាក់ទងនឹងការប្រែប្រួលអាកាសធាតុនិងជីវិតរស់នៅរបស់ស្ត្រីនិងក្មេងស្រី។” |
| **ក្រុមប្រឹក្សាសង្គមនិងសេដ្ឋកិច្ច (ECOSOC) ដំណោះស្រាយ ២០០៥/៣១** | |
| ជាតុចូលចម្បង | នៅខែកក្កដា ឆ្នាំ២០០៥ ក្នុងកិច្ចប្រជុំពិភាក្សាលើកទី៣៩របស់ខ្លួន ក្រុមប្រឹក្សាសង្គមនិងសេដ្ឋកិច្ចបានអនុម័តលើដំណោះស្រាយ “បញ្ជ្រាបគោលគំនិតយេនឌ័រទៅក្នុងគ្រប់គោលនយោបាយ និងកម្មវិធីនៅក្នុងប្រព័ន្ធនៃអង្គការសហប្រជាជាតិ”។ |
| អត្ថបទជាក់លាក់ | ដំណោះស្រាយ ECOSOC នេះ អំពាវនាវឱ្យ “គ្រប់អង្គភាពនៃប្រព័ន្ធរបស់អង្គការសហប្រជាជាតិរួមបញ្ចូលភ្នាក់ងារអង្គការសហប្រជាជាតិ មូលនិធិនិងកម្មវិធីបង្កើនកិច្ចខិតខំបន្ថែមដើម្បីដោះស្រាយបញ្ហាប្រឈមនានា ការបញ្ចូលគោលគំនិតយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីដូចជា៖<br>• ការរៀបចំផែនការសកម្មភាពដោយមានការណែនាំច្បាស់លាស់លើការអនុវត្តជាក់ស្តែងលើការបញ្ជ្រាបយេនឌ័រ<br>• ដាក់បញ្ចូលយ៉ាងពេញលេញនូវគោលគំនិតយេនឌ័រទៅក្នុងការធ្វើផែនការថវិកា<br>• ធានាផ្តល់ការយល់ដឹង និងការបណ្តុះបណ្តាលជាបន្តបន្ទាប់អំពីបញ្ហាយេនឌ័រដល់បុគ្គលិកទាំងអស់<br>• តម្រូវឱ្យមានការវិភាគយេនឌ័រ ទាំងការរៀបចំគោលនយោបាយនិងការងារកម្មវិធី<br>• ធានានូវការប្តេជ្ញាចិត្តពីសំណាក់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់លើការបញ្ជ្រាបយេនឌ័រ<br>• ពង្រឹងប្រព័ន្ធគណនេយ្យភាពសម្រាប់ការបញ្ជ្រាបយេនឌ័រ<br>• ដាក់បញ្ចូលគោលគំនិតយេនឌ័រទៅក្នុងយន្តការប្រតិបត្តិដូចជា យន្តការដែលទាក់ទងនឹងការអនុវត្តគោលដៅអភិវឌ្ឍសហស្សវត្សរ៍<br>• បន្តការគាំទ្រដល់រដ្ឋាភិបាល និងធ្វើការជាមួយសង្គមស៊ីវិលក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេលើការអនុវត្តសន្និសីទទីក្រុងប៉េកាំងដើម្បីសកម្មភាព<br>• បង្កើត និងដាក់បញ្ចូលឧបករណ៍តាមដាននិងវាយតម្លៃ និងវិធីសាស្ត្រវិភាគឥទ្ធិពលយេនឌ័រក្នុងស្ថាប័នការត្រួតពិនិត្យ និងឧបករណ៍វាយតម្លៃនិងវិធីសាស្ត្រវិភាគផលប៉ះពាល់យេនឌ័រ លើកកម្ពស់ការប្រមូលចងក្រង វិភាគទិន្នន័យបែងចែកតាមភេទ និង<br>• លើកកម្ពស់ការបញ្ជ្រាបគោលគំនិតយេនឌ័រទៅក្នុងគោលនយោបាយអភិវឌ្ឍសង្គម និងម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ និងកម្មវិធីអភិវឌ្ឍជាតិ។” |

| សេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំងនិងសន្និសីទដើម្បីសកម្មភាព | |
|---|---|
| ជាតុចូលចម្បង | ឯកសារចំនួន២កើតចេញពីសន្និសីទពិភពលោកស្តីពីស្ត្រីលើកទី៤៖ សេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំង និងសន្និសីទដើម្បីសកម្មភាព។ ឯកសារទាំងនេះបង្កើតបានជាយុទ្ធសាស្ត្រនិងទំនួលខុសត្រូវសម្រាប់ រដ្ឋភាគី។ សន្និសីទដើម្បីសកម្មភាពបានរំលឹកថា៖ "សិទ្ធិមនុស្សសម្រាប់នារីដូចដែលបានកំណត់ក្នុង លិខិតតូបករណ៍សិទ្ធិមនុស្សអន្តរជាតិនឹងក្លាយទៅជាពាក្យលែងប្រើ លុះត្រាតែវាត្រូវបានទទួលស្គាល់ ការពារទទួលយក និងអនុវត្តដោយប្រសិទ្ធភាពពេញលេញនៅក្របខណ្ឌច្បាប់និងការអនុវត្តថ្នាក់ ជាតិ..." (កថាខណ្ឌ២១៨)។ |
| អត្ថបទជាក់លាក់ | **គោលបំណងយុទ្ធសាស្ត្រ K.1**<br>ឱ្យមានការចូលរួមយ៉ាងសកម្មពីស្ត្រីក្នុងការធ្វើសេចក្តីសម្រេចទាក់ទងបរិស្ថាននៅគ្រប់កម្រិត។<br>**គោលបំណងយុទ្ធសាស្ត្រ K.2**<br>ដាក់បញ្ចូលកង្វល់និងគោលគំនិតយេនឌ័រនៅក្នុងគោលនយោបាយនិងកម្មវិធីសម្រាប់ការអភិវឌ្ឍប្រកប ដោយចីរភាព។<br>**គោលបំណងយុទ្ធសាស្ត្រ K.3**<br>ពង្រឹង ឬបង្កើតយន្តការ នៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិដើម្បីវាយតម្លៃផលប៉ះពាល់នៃគោលនយោបាយ បរិស្ថាន និងអភិវឌ្ឍលើស្ត្រី។ |

## ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិស្ថាន

| របៀបវារៈ២១ | |
|---|---|
| ជាតុចូលចម្បង | របៀបវារៈ២១ដែលបង្កើតឱ្យមាននូវប្លង់មួយសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពត្រូវបានអនុម័តនៅ ឯសន្និសីទសហប្រជាជាតិស្តីពីបរិស្ថាននិងការអភិវឌ្ឍ Rio de Janeiro ក្នុងឆ្នាំ១៩៩២។ វានឹងសម្រេចបាន តាមរយៈគោលនយោបាយរបស់រដ្ឋាភិបាល សេចក្តីណែនាំថ្នាក់ជាតិ និងផែនការដើម្បីធានាសមធម៌នៅ គ្រប់ទិដ្ឋភាពក្នុងសង្គមដោយរួមបញ្ចូល "ការចូលរួមគន្លឹះ" របស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចនិងការ គ្រប់គ្រងបរិស្ថាន។ |
| អត្ថបទជាក់លាក់ | ជំពូក២៤ ដែលមានចំណងជើងថា "សកម្មភាពពិភពលោកសម្រាប់ស្ត្រី ឆ្ពោះទៅការអភិវឌ្ឍប្រកបដោយ ចីរភាព" ដែលអំពាវនាវឱ្យរដ្ឋាភិបាលធ្វើការផ្លាស់ប្តូរ រដ្ឋធម្មនុញ្ញ ច្បាប់ រដ្ឋបាល វប្បធម៌ សង្គម និង សេដ្ឋកិច្ច ក្នុងការជំនះរាល់ឧបសគ្គ ដើម្បីឱ្យមានការចូលរួមពេញលេញរបស់ស្ត្រីលើការអភិវឌ្ឍប្រកប ដោយចីរភាព និងក្នុងជីវិតសាធារណៈ។<br>របៀបវារៈ២១ ទទួលស្គាល់នូវសារៈសំខាន់ចំណេះដឹងនិងការអនុវត្តជាប្រពៃណីរបស់ស្ត្រី និងសង្កត់ធ្ងន់ លើការរួមចំណែករបស់ស្ត្រីដែលបានធ្វើឡើងទាក់ទងនឹងការអភិរក្សជីវៈចម្រុះ (Section 24.2 (c)) របៀបវារៈ២១ អំពាវនាវឱ្យមានការអនុម័តនូវវិធានការ ការបកស្រាយគោលបំណងរបស់វាទៅជា យុទ្ធសាស្ត្រច្បាស់លាស់(Section 24 (f))។<br>នៅផ្នែកផ្សេងទៀតនៃអត្ថបទស្ត្រីត្រូវបានលើកឡើងក្នុងករណីចំនួន១៥៩។ |

| WSSD ផែនការនៃការអនុវត្ត |
|---|

| | |
|---|---|
| ជាតុចូលចម្បង | កិច្ចប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព (WSSD) ផែនការនៃការអនុវត្ត (ឆ្នាំ២០០២) បានអនុម័តនៅទីក្រុង Johannesburg លើកកម្ពស់ការទទួលបានស្មើភាពរបស់ស្ត្រី និងការចូលរួមពេញលេញក្នុងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិតឈរលើមូលដ្ឋានសមភាពនឹងបុរស។ |
| អត្ថបទជាក់លាក់ | អំពាវនាវការបញ្ជ្រាបគោលគំនិតយេនឌ័រ ទៅក្នុងគ្រប់គោលនយោបាយនិងយុទ្ធសាស្រ្តការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងការធ្វើឱ្យប្រសើរឡើងស្ថានភាព សេដ្ឋកិច្ច សុខភាពរបស់ស្ត្រី និងក្មេងស្រីតាមរយៈការទទួលបានពេញលេញ និងស្មើភាពលើកាលានុវត្តភាពសេដ្ឋកិច្ច ដីធ្លី ឥណទាន ការអប់រំ និងសេវាថែទាំសុខភាព។ |

**សេចក្តីថ្លែងការណ៍សហស្សវត្សរ៍និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍**

| | |
|---|---|
| ជាតុចូលចម្បង | នៅក្នុងកិច្ចពិភាក្សាទី៨ នៃមហាសន្និបាតអង្គការសហប្រជាជាតិ នៅខែកញ្ញា ឆ្នាំ២០០០ ប្រទេសដែលបានអនុម័តសេចក្តីថ្លែងការណ៍សហស្សវត្សរ៍ បានប្តេជ្ញាគោរពសិទ្ធិស្មើគ្នាដោយមិនមានការបែងចែកលើពូជសាសន៍ ភេទ ភាសា ឬសាសនា។ អង្គការសហប្រជាជាតិក៏បានអនុម័តគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ដែលត្រូវបានចាត់ទុកថាជាប្លង់មេក្នុងការពិនិត្យលើសេចក្តីថ្លែងការណ៍សហស្សវត្សរ៍។ |
| អត្ថបទជាក់លាក់ | សេចក្តីថ្លែងការណ៍ កំណត់តម្លៃមូលដ្ឋានគ្រឹះជាក់លាក់ដែលជាការចាំបាច់ក្នុងទំនាក់ទំនងអន្តរជាតិនៅសតវត្សរ៍ទី២១។ ប្រទេសហត្ថលេខីប្តេជ្ញា៖<br>• ធានាសិទ្ធិ និងឱកាសស្មើគ្នាសម្រាប់ស្ត្រី និងបុរស លើកកម្ពស់ភាពអង់អាចរបស់ស្ត្រីជាមធ្យោបាយដែលមានប្រសិទ្ធភាពក្នុងការប្រឆាំងនឹងភាពក្រីក្រភាពអត់ឃ្លាននិងជម្ងឺនិងការសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាពពិតប្រាកដ(មាត្រ២០)។<br>• ធានាថាអត្ថប្រយោជន៍នៃបច្ចេកវិទ្យាថ្មីៗ ជាពិសេសបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មានសម្រាប់ទាំងអស់គ្នា(មាត្រា២០)។ |

**អនុសញ្ញាសហប្រជាជាតិ ប្រើតាមខ្លឹមសារដែលបានឯកភាព**

| | |
|---|---|
| ជាតុចូលចម្បង | នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៤ អនុសញ្ញានេះបើកទូលាយឱ្យរដ្ឋាភិបាលជាតិចុះហត្ថលេខា និងបានចាប់ផ្តើមអនុវត្តនៅឆ្នាំ១៩៩៦។<br>មួយក្នុងចំណោមអនុសញ្ញាដែលត្រូវបានគេស្គាល់ថា អនុសញ្ញា ទីក្រុងរីយ៉ូ អនុសញ្ញាសហប្រជាជាតិដើម្បីប្រឆាំងនឹងការបោះបង់ដី (UNCCD ឆ្នាំ១៩៩៤) បានទទួលស្គាល់យ៉ាងច្បាស់នូវតួនាទីរបស់ស្ត្រីក្នុងជីវភាពជនបទ និងលើកទឹកចិត្តការចូលរួមពេញលេញរបស់ស្ត្រីនិងបុរស ក្នុងការអនុវត្តអនុសញ្ញានេះ។ UNCCD សង្កត់ធ្ងន់ពីតួនាទីសំខាន់របស់ស្ត្រីនៅក្នុងតំបន់ដែលរងការប៉ះពាល់ដោយការបោះបង់ដី និង/ឬតាមរយៈភាពរាំងស្ងួត ជាពិសេសនៅតំបន់ជនបទ និងណែនាំដល់កម្មវិធីសកម្មភាពជាតិផ្តល់ការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ស្ត្រីនិងបុរស ជាពិសេសអ្នកដែលប្រើប្រាស់ធនធានដោយរួមបញ្ចូលទាំងកសិករ អ្នកចិញ្ចឹមសត្វ និងសហគមន៍របស់ពួកគេ។ |

អត្ថបទដាក់លាក់

**បុព្វកថា៖** សង្កត់ធ្ងន់ពីតួនាទីដ៏សំខាន់របស់ស្ត្រីនៅក្នុងតំបន់ដែលរងការប៉ះពាល់ដោយការបោះបង់ដី ឬដោយភាពរាំងស្ងួត ជាពិសេសនៅតំបន់ជនបទនៃប្រទេសកំពុងអភិវឌ្ឍ និងភាពចាំបាច់ក្នុងការធានាការចូលរួមពេញលេញរបស់ស្ត្រីនិងបុរស នៅគ្រប់កម្រិតក្នុងកម្មវិធីនានាលើការប្រឆាំងនឹងការបោះបង់ដី និងការកាត់បន្ថយផលប៉ះពាល់នៃភាពរាំងស្ងួត។

**ជំពូកទី២៖ បញ្ញត្តិទូទៅ**

**មាត្រា៦៖** កាតព្វកិច្ចនៃប្រទេសភាគីដែលរងផលប៉ះពាល់

(d) លើកកម្ពស់យុទ្ធនាការ និងសម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន ជាពិសេសស្ត្រី និងយុវវ័យជាមួយនឹងការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ក្នុងកិច្ចខិតខំប្រឹងប្រែងប្រឆាំងនឹងការបោះបង់ដី និងការកាត់បន្ថយផលប៉ះពាល់នៃភាពរាំងស្ងួត។

**ជំពូកទី៣៖ ផែនការសកម្មភាព កិច្ចសហការបច្ចេកទេសនិងវិទ្យាសាស្ត្រ និងវិធានការគាំទ្រ**

**ផ្នែកទី១៖ កម្មវិធីសកម្មភាព**

**មាត្រា១០៖** កម្មវិធីសកម្មភាពជាតិ

២. កម្មវិធីសកម្មភាពជាតិត្រូវគូសបញ្ជាក់ពីតួនាទីនីមួយៗនៃរដ្ឋាភិបាល សហគមន៍មូលដ្ឋាន និងអ្នកប្រើប្រាស់ដី និងធនធានដែលត្រូវការ។ កម្មវិធីទាំងនេះត្រូវតែផ្តល់ដល់អង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋមូលដ្ឋាន ទាំងស្ត្រីនិងបុរស ជាពិសេសសម្រាប់ការចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងការធ្វើផែនការថ្នាក់មូលដ្ឋាន ជាតិ និងតំបន់របស់អង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋមូលដ្ឋានទាំងស្ត្រីនិងបុរស ជាពិសេសអ្នកដែលប្រើប្រាស់ធនធានដោយរួមបញ្ចូលកសិករ អ្នកស្រែចំការ និងសហគមន៍របស់ពួកគេក្នុងការធ្វើផែនការគោលនយោបាយ សេចក្តីសម្រេចចិត្ត និងការអនុវត្ត និងការពិនិត្យឡើងវិញកម្មវិធីសកម្មភាពជាតិ។

**ផ្នែកទី៣៖ វិធានការគាំទ្រ**

**មាត្រា១៩៖** ការកសាងសមត្ថភាព ការអប់រំ និងការបង្កើនការយល់ដឹង

១. រដ្ឋភាគី ទទួលស្គាល់នូវសារៈសំខាន់នៃការកសាងសមត្ថភាព - ការកសាងសមត្ថភាពស្ថាប័ន បណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពនៅមូលដ្ឋាននិងជាតិ - ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីប្រឆាំងនឹងការបោះបង់ដី និងការកាត់បន្ថយផលប៉ះពាល់នៃភាពរាំងស្ងួត។រដ្ឋភាគីត្រូវតែលើកកម្ពស់ការកសាងសមត្ថភាពតាមភាពសមស្រប៖

(a) តាមរយៈការចូលរួមពេញលេញនៅគ្រប់កម្រិតរបស់ប្រជាពលរដ្ឋមូលដ្ឋាន ជាពិសេសស្ត្រី និងយុវវ័យជាមួយនឹងកិច្ចសហការរវាងអង្គការក្រៅរដ្ឋាភិបាល និងអង្គការនៅមូលដ្ឋាន។

៣. រដ្ឋភាគីគួរសហការ និងតាមរយៈអង្គការអន្តររដ្ឋាភិបាលដែលមានសមត្ថកិច្ច ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលក្នុងការរៀបចំនិងគាំទ្រយុទ្ធនាការសាធារណៈ និងកម្មវិធីអប់រំទាំងនៅប្រទេសដែលមិនរងផលប៉ះពាល់សម្រាប់ទីកន្លែងដែលពាក់ព័ន្ធ និងប្រទេសដែលរងផលប៉ះពាល់នៃរដ្ឋភាគីដើម្បីលើកកម្ពស់ការយល់ដឹងពីមូលហេតុ និងផលប៉ះពាល់ការបោះបងដី និងភាពរាំងស្ងួត និងយល់ដឹងពីសារៈសំខាន់ក្នុងការសម្រេចបាននូវគោលបំណងនៃអនុសញ្ញានេះ។ដើម្បីសម្រេចបានគោលបំណងនេះ ពួកគេគួរតែ៖ (ង) ប៉ាន់ប្រមាណពីតម្រូវការអប់រំ នៅតំបន់ដែលរងផលប៉ះពាល់រៀបចំនូវកម្មវិធីសិក្សា របស់សាលាសមស្រប និងពង្រីកតាមការដាក់ស្តែងនូវកម្មវិធីអប់រំមនុស្សពេញវ័យ និងឱកាសសម្រាប់ទាំងអស់ ជាពិសេសក្មេងស្រីនិងស្ត្រី ក្នុងការកំណត់ ការអភិរក្ស និងការប្រើប្រាស់ និងគ្រប់គ្រងប្រកបដោយចីរភាពនូវធនធានធម្មជាតិក្នុងតំបន់ដែលរងផលប៉ះពាល់។

**ឧបសម្ព័ន្ធ១៖ ការអនុវត្តថ្នាក់តំបន់សម្រាប់ ទ្វីបអាហ្វ្រិក**

**មាត្រា១៖** មាតិកានៃកម្មវិធីសកម្មភាពថ្នាក់ជាតិ

២. កម្មវិធីសកម្មភាពជាតិគួរតែតាមភាពសមស្របបញ្ចូលនូវលក្ខណៈទូទៅដូចតទៅ៖ (គ) ការបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋនិងសហគមន៍មូលដ្ឋានដោយរួមបញ្ចូលស្ត្រី កសិករ និងអ្នកស្រែចំការ និងផ្តល់ភាពតំណាងដល់ពួកគេនូវការទទួលខុសត្រូវកាន់តែច្រើនសម្រាប់ការគ្រប់គ្រង។

| អនុសញ្ញាស្តីពីជីវៈចម្រុះ ( CBD ) | |
|---|---|
| ជាតុចូលចម្បង | អនុសញ្ញាស្តីពីជីវៈចម្រុះនៅឆ្នាំ១៩៩២ ទទួលស្គាល់តួនាទីសំខាន់របស់ស្រ្តីក្នុងការអភិរក្ស និងប្រើប្រាស់ជីវៈចម្រុះប្រកបដោយចីរភាព ហើយបានបញ្ជាក់អំពីភាពចាំបាច់នៃការចូលរួមពេញលេញរបស់ស្រ្តី។ តែទោះជាយ៉ាងណាក៏ដោយ ការបញ្ជ្រាបយេនឌ័រក្នុងការអនុវត្តអនុសញ្ញាទើបតែបានប្រព្រឹត្តិឡើងក្នុងពេលខ្លីៗនេះ។<br>ចាប់តាំងពីឆ្នាំ២០០៧ វិធីសាស្រ្ត លេខាធិការដ្ឋាន CBD បានផ្តោតការយកចិត្តទុកដាក់លើការបញ្ជ្រាបយេនឌ័រដោយបានតែងតាំងជនបង្គោលនិងរៀបចំផែនការសកម្មភាពយេនឌ័រថ្មី ដោយផ្តោតការយកចិត្តទុកដាក់សម្រាប់ការបញ្ជ្រាបយេនឌ័រជាច្រើន។ |
| អត្ថបទជាក់លាក់ | អង្គភាពផ្តល់យោបល់លើផ្នែកវិទ្យាសាស្រ្ត បច្ចេកទេស និងបច្ចេកវិទ្យារបស់ CBD ក៏ដូចសេចក្តីសម្រេចមួយចំនួនក្នុងសន្និសីទភាគីពាក់ព័ន្ធបានលើកពី (SBSTTA) បានលើកឡើងពីការអនុវត្តរបស់ស្រ្តី ចំណេះដឹង និងតួនាទីយេនឌ័រក្នុងការផលិតចំណីអាហារដូចជា៖<br>(a) **SBSTTA** អនុសាសន៍ **II/7** នៃ **SBSTTA** តួនាទីរបស់ស្រ្តីក្នុងការអនុវត្តជីវចម្រុះក្នុងវិស័យកសិកម្ម និងការគ្រប់គ្រងចំណេះដឹង<br>(b) **COP** សេចក្តីសម្រេច **III/11,** កថាខ័ណ្ឌ**17** ស្តីពីការលើកកម្ពស់ការអនុវត្ត និងចំណេះដឹងរបស់ស្រ្តីក្នុងការអភិរក្ស និងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះក្នុងវិស័យកសិកម្ម<br>(c) ឧបសម្ព័ន្ធនៃសេចក្តីសម្រេច **III**/14 របស់ **COP** លើមាត្រា 8 (**j**)៖ តុល្យភាពយេនឌ័រនៅក្នុងសិក្ខាសាលា<br>(d) ឧបសម្ព័ន្ធនៃអនុសាសន៍IV/7 របស់ SBSTTA ស្តីពីផលប៉ះពាល់នៃវិស័យទេសចរណ៍ដែលអាចជះឥទ្ធិពលលើវប្បធម៌រួមទាំងយេនឌ័រ<br>(e) កថាខ័ណ្ឌ 2(i) នៃអនុសាសន៍ V/14 របស់ SBSTTA និងឧបសម្ព័ន្ធ III នៃសេចក្តីសម្រេច VIII/10 របស់ COP. ស្តីពីតុល្យភាពយេនឌ័រក្នុងសមាសភាគក្រុមការងារបណ្តោះអាសន្នសម្រាប់ការពិនិត្យតាមដានការអនុវត្តអនុសញ្ញាស្តីពីជីវៈចម្រុះ SBSTTA និងក្នុងចំណោមអ្នកជំនាញការដទៃទៀត<br>(f) សេចក្តីសម្រេច V/16 នៃ COP – ជាតុ 1 នៃកម្មវិធីការងារនៃមាត្រា៨(j) ស្តីពីការលើកកម្ពស់មធ្យោបាយយេនឌ័រជាក់លាក់ដែលចងក្រងនិងថែរក្សាចំណេះដឹងស្រ្តីស្តីពីជីវៈចម្រុះ<br>(g) សេចក្តីសម្រេច V/20 នៃ COP ស្តីពីតុល្យភាពយេនឌ័រនៅក្នុងបញ្ជីអ្នកជំនាញការ<br>(h) **COP decision V/25** ស្តីពីផលប៉ះពាល់សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទេសចរណ៍អាចប៉ះពាល់ទំនាក់ទំនងយេនឌ័រ (ឧទាហរណ៍៖ តាមរយៈឱកាសការងារ) និង<br>(e) **Annexes I and II to COP decision VI/10**, annex to COP decision VII/1: យេនឌ័រជាកត្តាសង្គមដែលអាចប៉ះពាល់ដល់ចំណេះដឹងជាប្រពៃណី។<br>**សេចក្តីសម្រេច V/16៖ មាត្រា ៨(j) និងការថែងផ្សេងទៀត៖** "ទទួលស្គាល់តួនាទីសំខាន់របស់ស្រ្តី ក្នុងការអភិរក្សនិងប្រើប្រាស់ជីវចម្រុះប្រកបដោយចីរភាព និងព្រមទាំងសារៈសំខាន់លើការពង្រឹងតួនាទី និងការចូលរួមរបស់ស្រ្តីជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានក្នុងកម្មវិធីការងារ។" |

| | |
|---|---|
| | **នៅក្នុង“គោលការណ៍ទូទៅ” កម្មវិធីការងារលើការអនុវត្ត មាត្រា ៨(j) និងការចែងផ្សេងទៀតនៃ CBD អំពាវនាវ៖** “ការចូលរួមប្រកបដោយប្រសិទ្ធភាពនិងពេញលេញរបស់ស្ត្រីអន្តោគ្រាមនិងសហគមន៍មូលដ្ឋាននៅគ្រប់សកម្មភាពកម្មវិធីការងារ។ ”ការងារទី៤នៃកម្មវិធីការងារស្នើឱ្យរដ្ឋភាគីរៀបចំតាមការសមរម្យនូវយន្តការដើម្បីលើកកម្ពស់ការចូលរួមប្រកបដោយប្រសិទ្ធភាព និងពេញលេញរបស់ស្ត្រីក្នុងគ្រប់នៃកម្មវិធីការងារដោយគិតលើ៖ (a) កសាងលើមូលដ្ឋាននៃចំណេះដឹងរបស់ពួកគេ (b) ពង្រឹងការទទួលបាននូវជីវៈចម្រុះ (c) ពង្រឹងសមត្ថភាពរបស់ពួកគេលើបញ្ហាដែលជាប់ពាក់ព័ន្ធនឹងការថែរក្សា និងការការពារជីវៈចម្រុះ (d) ការលើកកម្ពស់ការផ្លាស់ប្តូរបទពិសោធន៍និងចំណេះដឹង និង (e) ការលើកកម្ពស់មធ្យោបាយយេនឌ័រជាក់លាក់ និងសមស្របតាមវប្បធម៌ដែលនិងចងក្រង និងថែរក្សាចំណេះដឹងរបស់ស្ត្រីស្តីពីជីវៈចម្រុះ។<br>**ក្នុងកិច្ចប្រជុំទី២ ធ្វើនៅខែកក្កដា ឆ្នាំ២០០៧ ក្រុមការងារបណ្តោះអាសន្នសម្រាប់ការពិនិត្យតាមដានការអនុវត្តអនុសញ្ញាស្តីពីជីវចម្រុះ**<br>**អនុសញ្ញា** ផ្តល់ជាអនុសាសន៍ឱ្យសន្និសីទភាគីពាក់ព័ន្ធនៅក្នុងកិច្ចប្រជុំលើកទី៩ គួរឱ្យរដ្ឋភាគី រៀបចំអនុវត្ត និងកែសម្រួលផែនការសកម្មភាព និងយុទ្ធសាស្ត្រជីវៈចម្រុះថ្នាក់ជាតិដើម្បីបញ្ជ្រាបការគិតគូរពីយេនឌ័រ ( UNEP/CBD/COP/9/4, annex, recommendation 2/1, annex, paragraph 8 (d) ) ។<br>**COP 9**: ស្វាគមន៍ការរៀបចំ “ផែនការសកម្មភាពយេនឌ័រ” ដោយលេខាប្រតិបត្តិនៅក្រោម អនុសញ្ញាស្តីពីជីវៈចម្រុះដូចដែលមានចែងក្នុងឯកសារ UNEP/CBD/COP/9/INF/12 និងស្នើឱ្យរដ្ឋភាគីគាំទ្រលេខាធិការដ្ឋានក្នុងការអនុវត្តអនុសញ្ញា។” |
| **អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ** | |
| ជាតុចូលចម្បង | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) មិនបានបញ្ចូលគំនិតយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុ និងមិនបានគិតគូរអំពីសមភាពយេនឌ័រ និងការចូលរួមរបស់ស្ត្រី។ ជាមួយគ្នានេះ ពិធីសារក្យូតូដែលគូសបង្ហាញពីការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់រហូតដល់ឆ្នាំ២០១២ ក៏មិនបានដាក់បញ្ចូលគោលគំនិតយេនឌ័រនៅក្នុងយន្តការនិងប្រតិបត្តិការរបស់ខ្លួន ដូចជាយន្តការអភិវឌ្ឍស្អាតជាដើម។<br>កិច្ចប្រជុំរបស់ស្ត្រីចាប់តាំងពី COP-11 ក្នុងឆ្នាំ២០០៥ បានខិតខំស្វែងរកការគាំទ្រមតិទៅលើវិធីសាស្ត្រយេនឌ័រក្នុងផ្នែកសំខាន់ៗនៃច្បាប់អន្តរជាតិនានា។ បន្ទាប់ពីកិច្ចប្រជុំ COP-13 នៅទីក្រុងបាលី ស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ "ស្ត្រីដើម្បីសមធម៌អាកាសធាតុសម្រាប់បណ្តាញបុគ្គល និងអង្គការស្ត្រី"។ ក៏ដូចជាសម្ព័ន្ធអាកាសធាតុ និងយេនឌ័រពិភពលោកនៃអង្គការសហប្រជាជាតិ IUCN និង WEDO ជាមួយអង្គការអន្តរជាតិផ្សេងទៀត។<br>IUCN បានចាប់ផ្តើមការងារជាមួយលេខាធិការដ្ឋាន UNFCCC ដោយមានជនបង្គោលយេនឌ័រថ្មីមួយរូប និងជំហានជាបន្តបន្ទាប់ (ឧទាហរណ៍៖ គិតគូរអំពីការយល់ដឹងរបស់បុគ្គលិក កិច្ចខិតខំលើការបន្សាំ និងយេនឌ័រជាដើម) នឹងត្រូវធ្វើឡើង។ |

| | |
|---|---|
| អត្ថបទជាក់លាក់ | សមភាពយេនឌ័រ ជាគោលការណ៍ណែនាំមួយក្នុងការរៀបចំកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPAs) និងត្រូវបានផ្តល់អនុសាសន៍ធ្វើការដាក់បញ្ចូលអ្នកជំនាញយេនឌ័រក្នុងក្រុម NAPA ។ របាយការណ៍ជាតិមួយចំនួនធំរបស់រដ្ឋជាហត្ថលេខីដែលបានផ្ញើជូនលេខាធិការដ្ឋាន UNFCC នៃលេខាធិការដ្ឋាន UNFCCC បានផ្តោតលើភាពងាយរងគ្រោះរបស់ស្ត្រី និងសង្កត់ធ្ងន់ពីសារៈសំខាន់សមភាពយេនឌ័រក្នុងន័យទូលំទូលាយ។<br>ប្រទេសភាគច្រើនដាក់បញ្ចូលនូវឯកសារយោងមួយចំនួនទាក់ទងនឹង MDGs ឬការប្តេជ្ញាចិត្តថ្នាក់ជាតិក្នុងការបង្កើនភាពអង់អាចដល់ស្ត្រី។ តែឯកសារទាំងឡាយនោះ មិនបានលំអិតអំពីភាពងាយរងគ្រោះរបស់ស្ត្រី ហើយក៏មិនបានលើកអំពីតួនាទីស្ត្រីជាតួអង្គសំខាន់ និងជាភ្នាក់ងារសម្រាប់ការផ្លាស់ប្តូរ។ |

## ការកាត់បន្ថយហានិភ័យ

### ក្របខ័ណ្ឌសកម្មភាពយូហ្គោ

| | |
|---|---|
| ធាតុចូលចម្បង | ក្របខ័ណ្ឌនេះបានដាក់បញ្ចូលនូវអាណត្តិដ៏សំខាន់ ទាក់ទងនឹងសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងបរិបទនៃការកាត់បន្ថយគ្រោះមហន្តរាយ និងជាលទ្ធផលចេញពីសន្និសីទពិភពលោកស្តីពីការកាត់បន្ថយមហន្តរាយក្នុងទីក្រុងកូបេ ប្រទេសជប៉ុន (ឆ្នាំ២០០៥)។ |
| អត្ថបទជាក់លាក់ | **ការគិតគូរទូទៅ**<br>(d) គោលគំនិតយេនឌ័រគួរត្រូវបានបញ្ចូលនៅគ្រប់ផែនការគោលនយោបាយគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងដំណើរការនៃការធ្វើសេចក្តីសម្រេច ដោយរួមបញ្ចូលកត្តាទាក់ទងការវាយតម្លៃហានិភ័យ ការប្រកាសអាសន្នមុនការគ្រប់គ្រងព័ត៌មាន និងការអប់រំនិងបណ្តុះបណ្តាល។<br>**ii) ការប្រកាសអាសន្នមុន**<br>(d) រៀបចំប្រព័ន្ធប្រកាសអាសន្នមុនដែលផ្តោតសារៈសំខាន់លើមនុស្ស ជាពិសេសប្រព័ន្ធដែលការប្រកាសអាសន្នទៀងពេលវេលា និងអាចយល់បានសម្រាប់អ្នកដែលប្រឈមនឹងមហន្តរាយដែលគិតពីកត្តាភូមិសាស្ត្រ យេនឌ័រ វប្បធម៌ លក្ខណៈជីវភាពនៃគោលដៅដោយរួមបញ្ចូលការណែនាំលើសកម្មភាពដែលត្រូវធ្វើនៅពេលមានការប្រកាសអាសន្ន និងដែលគាំទ្រប្រតិបត្តិការដែលមានប្រសិទ្ធភាពដោយអ្នកគ្រប់គ្រងគ្រោះមហន្តរាយ និងអ្នកធ្វើសេចក្តីសម្រេចផ្សេងទៀត។<br>**ii) ការអប់រំនិងបណ្តុះបណ្តាល**<br>(m) ធានាការទទួលបានឱកាសអប់រំនិងបណ្តុះបណ្តាលសមរម្យសម្រាប់ស្ត្រីនិងជនងាយរងគ្រោះលើកកម្ពស់យេនឌ័រ ការបណ្តុះបណ្តាលយល់ដឹងពីវប្បធម៌ ជាផ្នែករួមនៃការអប់រំនិងបណ្តុះបណ្តាលសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ។ |

# ការផ្សាភ្ជាប់ជាមួយលិខិតតូបករណ៍ផ្លូវច្បាប់ មានត្រឹមកម្រិតណានិងទំនាក់ទំនងទៅនឹង UNFCCC




**គោលបំណង ៖** ណែនាំលិខិតតូបករណ៍ផ្លូវច្បាប់សំខាន់ៗបំផុតមួយចំនួន និងបង្ហាញពីសារៈសំខាន់នៃលិខិតតូបករណ៍ទាំងនោះ សម្រាប់គំនិតផ្តួចផ្តើមនិងគោលនយោបាយការប្រែប្រួលអាកាសធាតុ នៅថ្នាក់ជាតិនិងអន្តរជាតិ។

**សម្ភារៈ ៖** ចម្លងឯកសារស្តីពីអនុសញ្ញាស៊ី-ដ Resolution 2005/31 របស់ក្រុមប្រឹក្សាសង្គមនិងសេដ្ឋកិច្ចក្របខ័ណ្ឌសកម្មភាពយូហ្គោ និងសន្និសីទទីក្រុងប៉េកាំងដើម្បីសកម្មភាព (ចំណុច K)។ នៅក្នុងក្រុមដែលមានសមាជិកច្រើន អ្នកសម្របសម្រួលអាចថតតចម្លងច្បាប់ដទៃទៀតដើម្បីវិភាគ ហ្វីត និងក្រដាសផ្ទាំងធំ។

**ដំណើរការ ៖**

១) បែងចែកអ្នកចូលរួមជាបួនក្រុម និងចាត់តាំងប្រធានតាមក្រុមនីមួយៗ។

២) ចែកឯកសារច្បាប់ដែលបានចម្លងទុកមួយក្រុមមួយច្បាប់។ ផ្តល់ពេលវេលាសម្រាប់ពួកគេអាន។

៣) ស្នើឱ្យក្រុមនីមួយៗ រកទំនាក់ទំនងនៃលិខិតតូបករណ៍ផ្លូវច្បាប់ជាមួយនឹងគំនិតផ្តួចផ្តើម និងគោលនយោបាយ ការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងអន្តរជាតិ។

៤) ស្នើឱ្យក្រុមនីមួយៗបង្ហាញពីសកម្មភាពជាក់លាក់ដែលគួរអនុវត្ត។

៥) ស្នើឱ្យក្រុមនីមួយៗបង្ហាញសេចក្តីសន្និដ្ឋានរបស់ខ្លួន។ ប្រសិនបើអាចផ្តល់នូវគំនិតបន្ថែមសម្រាប់អនុវត្តសកម្មភាព។

៦) ជាចុងបញ្ចប់ ស្នើអ្នកចូលរួមបង្ហាញពីអ្វីដែលគេបានសិក្សាពីនេះ។



## បញ្ជាក់៖

អត្ថបទនៃលិខិតតូបករណ៍ផ្លូវច្បាប់ទាំងនេះអាចរកបាននៅ៖

**អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ)**

http://www.un.org/womenwatch/daw/cedaw/cedaw.htm

**Resolution 2005/31 របស់ក្រុមប្រឹក្សាសង្គមនិងសេដ្ឋកិច្ច**

http://www.unhcr.org/refworld/docid/463b3d652.html

**ក្របខ័ណ្ឌសកម្មភាពយូហ្គោ**

http://www.unisdr.org/wcdr/intergover/official-doc/L-docs/Hyogoframework-for-action-english.pdf

**សន្និសីទទីក្រុងប៉េកាំងដើម្បីសកម្មភាព (ចំណុច K)**

http://www.un.org/womenwatch/daw/beijing/platform/plat1.htm

យុទ្ធសាស្ត្រអន្តរជាតិសហប្រជាជាតិដើម្បីកាត់បន្ថយហានិភ័យ។ ឆ្នាំ២០០៧។ **សម្តីជាសកម្មភាព៖ សេចក្តីណែនាំដើម្បីអនុវត្តក្របខ័ណ្ឌសកម្មភាពយូហ្គោ។** ក្រុងហ្សឺណែវ ប្រទេសស្វីស៖ លេខាធិការដ្ឋានអង្គការសហប្រជាជាតិ យុទ្ធសាស្ត្រអន្តរជាតិដើម្បីកាត់បន្ថយហានិភ័យ។ Available on-line: ttp://www.preventionweb.net/globalplatform/first-session/docs/Background_docs/Words_into_Action.pdf (Accessed on 8 July 2007).

# ជំពូក ៣

## ទិដ្ឋភាពទូទៅនៃបញ្ហាយេនឌ័រ និងការប្រែប្រួលអាកាសធាតុ

*វិសមភាពយេនឌ័រមានភាពពាក់ព័ន្ធទៅនឹងហានិភ័យនៃការប្រែប្រួលអាកាសធាតុនិងភាពងាយរងគ្រោះ។ ភាពមិនជឿនលឿនជាប្រវត្តិសាស្ត្ររបស់ស្ត្រី៖ ការទទួលបានធនធានមានកម្រិត ការកម្រិតនូវសិទ្ធិ និងការមិនមានសម្លេងនៅក្នុងការធ្វើសេចក្តីសម្រេច កត្តាទាំងនេះបានធ្វើឱ្យពួកគេមានភាពរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ។ កត្តាងាយរងគ្រោះមានភាពខុសគ្នា ដែលយើងមិនអាចកំណត់ជាទូទៅបាន។ ក៏ប៉ុន្តែការប្រែប្រួលអាកាសធាតុទំនងជាធ្វើឱ្យមានផលវិបាកផ្នែកយេនឌ័រ កាន់តែខ្លាំងក្លាឡើង (របាយការណ៍ អភិវឌ្ឍមនុស្សរបស់ UNDP, 2007)។*



### *សារសំខាន់ៗ*

- មានទំនាក់ទំនងជាធម្មតារវាងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ៖

  ១. ការប្រែប្រួលអាកាសធាតុមានទំនោរធ្វើឱ្យមានវិសមភាពយេនឌ័រកាន់តែខ្លាំង។

  ២. វិសមភាពយេនឌ័រកាន់តែធ្វើឱ្យស្ត្រីប្រឈមមុខនឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។
- ស្ត្រីមិនគ្រាន់តែជាជនរងគ្រោះទេ ប៉ុន្តែក៏ជាភ្នាក់ងារធ្វើឱ្យមានការផ្លាស់ប្តូរបង្កើននូវចំណេះដឹង និងជំនាញ។
- ការយល់ដឹងពីភាពរងគ្រោះ និងផលប៉ះពាល់ចំពោះការប្រែប្រួលអាកាសធាតុ មកលើបុរសស្ត្រី គឺជាគន្លឹះធ្វើឱ្យមានភាពជោគជ័យនៃការអភិវឌ្ឍប្រកបដោយស្ថិរភាព និងការសម្រេចបាននូវគោលដៅអភិវឌ្ឍសហស្សវត្សរ៍។

ការប្រែប្រួលអាកាសធាតុធ្វើឱ្យមានផលប៉ះពាល់ដល់ប្រទេសទាំងអស់នៅក្នុងសកលលោក។ ប៉ុន្តែផលប៉ះពាល់ទាំងនោះមានភាពខុសគ្នាពីទៅតាមតំបន់ ជំនាន់ អាយុ ប្រាក់ចំណូល មុខរបរ និងភេទ(IPCC, 2001)។ អ្នកក្រីក្រភាគច្រើនជាស្ត្រីដែលកំពុងរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍនឹងទទួលផលប៉ះពាល់ក្នុងកម្រិតខុសៗគ្នា។ ការជជែកពិភាក្សាស្តីពីអាកាសធាតុភាគច្រើនមិនបានគិតគូរពីបញ្ហាយេនឌ័រទេ។

ដោយសារការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់ទៅលើស្ត្រី និងបុរសខុសគ្នា ការគិតគូរពីសមភាពយេនឌ័រ គឺសំខាន់ណាស់នៅពេលពិភាក្សាពីការធ្វើគោលនយោបាយក្នុងការធ្វើការធ្វើសម្រេច និងយុទ្ធសាស្ត្រសម្រាប់ធ្វើទេសន្តប្រវេសន៍ និងការបន្សាំ។ ស្ត្រីមិនគ្រាន់តែជាជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែពួកគេគឺជាភ្នាក់ងារដ៏សំខាន់សម្រាប់ការផ្លាស់ប្តូរ និងភាពជាអ្នកដឹកនាំផងដែរ។ ស្ត្រីអាចជួយ ឬក៏ជំរុញយុទ្ធសាស្ត្រដែលពាក់ព័ន្ធនឹងការប្រើប្រាស់ថាមពល ការកាប់បំផ្លាញព្រៃឈើ កំណើនប្រជាជន ការលូតលាស់ផ្នែកសេដ្ឋកិច្ចវិទ្យាសាស្ត្រនិងបច្ចេកទេស ការបង្កើតគោលនយោបាយព្រមទាំងបញ្ហាផ្សេងៗ។

ការប្រែប្រួលអាកាសធាតុ និងវិសមភាពយេនឌ័រមានពាក់ព័ន្ធគ្នាយ៉ាងខ្លាំង។ ដោយសារ មានវិសមភាពនៅគ្រប់ផ្នែកទាំងអស់ ការប្រែប្រួលអាកាសធ្វើឱ្យយឺតយ៉ាវ ឆ្ពោះទៅរកសមភាពយេនឌ័រហើយធ្វើឱ្យរាំងស្ទះ ដល់កិច្ចខិតខំប្រឹងប្រែងធ្វើឱ្យសម្រេច បានគោលដៅទូលំទូលាយដូចការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយស្ថិរភាព។ វិសមភាពយេនឌ័រកាន់តែធ្វើឱ្យផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ មានភាពកាន់តែធ្ងន់ធ្ងរឡើង(មើលប្រអប់ទី១)។ ទោះជាយ៉ាងណាក៏ដោយ ការយកចិត្តទុកដាក់កាត់បន្ថយគម្លាតយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រីអាចជួយកាត់បន្ថយនូវផលប៉ះពាល់ទាំងនេះ។

**ប្រអប់ទី១៖ វិសមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ**

សហគមន៍ខ្លះនៅក្នុងប្រទេសបង់ក្លាដេស ស្ត្រីគ្មានសមត្ថភាពក្នុងការប្រឈមទៅនឹងគ្រោះមហន្តរាយដោយពួកគាត់ពឹងផ្អែកលើការទទួលព័ត៌មានពីពិភពខាងក្រៅ ហើយបដិសេធការទទួលសិទ្ធិក្នុងការជ្រើសរើសចេតនាសម្រេចការងារធំៗ។ ហេតុដូច្នោះហើយ Purdah ដែលជាវិទ្យាស្ថានមួយការពារស្ត្រី មិនឱ្យចូលរួមក្នុងតួនាទីសេដ្ឋកិច្ចសង្គមក្រៅពីការងារផ្ទះបានធ្វើឱ្យស្ត្រីទាំងនោះ មានភាពរងគ្រោះទៅនឹងគ្រោះមហន្តរាយ។

( Ikeda, 1995 )

## ៣.១ មូលហេតុនៃភាពងាយរងគ្រោះ ឬ ស្ថានភាពជាក់លាក់ដែលធ្វើឱ្យស្ត្រី ជាពិសេសស្ត្រីក្រីក្រ ងាយរងគ្រោះទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

ភាពងាយរងគ្រោះគឺជាការឆ្លុះបញ្ចាំងមួយពីសភាពនៃមនុស្សម្នាក់ ឬជាក្រុមដោយផ្តោតទៅលើស្ថានភាពសង្គម សេដ្ឋកិច្ច និងស្ថានភាពបរិស្ថានរបស់គេ។ សភាពនៃមនុស្សម្នាក់ឬជាក្រុមនេះបានជះឥទ្ធិពល មកពីមូលហេតុជាច្រើនក្នុងនោះ យេនឌ័រដើរតួយ៉ាងសំខាន់ផងដែរ។ ភាពងាយរងគ្រោះដោយផ្តោតលើយេនឌ័រ មិនមែនមកពីកត្តាតែមួយទេ ប៉ុន្តែបានរួមផ្សំនឹងកត្តាវប្បធម៌ ប្រវត្តិសាស្ត្រ និងជីវិតផ្ទាល់ខ្លួនផងដែរ (Enarson, 1998)។ ទំនាក់ទំនងយេនឌ័រនឹងឆ្លើយតបទៅនឹងស្ថានភាពទាំង៤នៃភាពងាយរងគ្រោះ។ ទំនាក់ទំនងទៅនឹងកត្តាទាំងនោះគឺ ការបែងចែកវណ្ណៈ ជាតិសាសន៍ ការរើសអើង និងវិសមភាពផ្សេងៗដែលបង្កើតស្ថានភាពសង្គមប្រកបដោយគ្រោះថ្នាក់ដល់ស្ត្រី (Enarson, 1998)។

ទោះបីជាយ៉ាងណាក៏ដោយ មានតម្រូវការមួយដើម្បីជៀសវាងការចាត់ទុកស្ត្រីជាជនងាយរងគ្រោះដោយសារតែលក្ខណៈជាស្ត្រី (ដោយសារភេទរបស់គាត់)។ ស្ត្រីមិនមែនក្លាយជាជនរងគ្រោះដោយសារតែគេមានលក្ខណៈមិនអំណោយផលពីធម្មជាតិ។ ស្ត្រី និងបុរសមានលក្ខណៈខុសគ្នាក្នុងការប្រឈមទៅនឹងភាពងាយរងគ្រោះដោយសារតែតួនាទីក្នុងសង្គមរបស់ពួកគេមានភាពខុសគ្នា។ ឧទាហរណ៍ ស្ត្រីជាច្រើនរស់នៅក្នុងស្ថានភាពមួយដែលសង្គមមានការរើសអើង។ កត្តាខ្លះបានបង្ហាញការពិតដូចជា សមត្ថភាពក្នុងការរត់ ឬហែលទឹក ឬក៏ឧបសគ្គក្នុងការបន្លាស់ទី ឬការបន្ទឹងផ្អែកឥរិយាបថដែលកត្តាទាំងនេះហើយធ្វើឱ្យពួកគេអាចផ្លាស់ទីដោយពឹងផ្អែកលើប្តី ឪពុក បងប្អូនប្រុសជាដើម។

មានការរកឃើញផងដែរថា ភាពងាយរងគ្រោះ និងសមត្ថភាពរបស់ក្រុមនៅក្នុងសង្គមមួយក្នុងការបន្សាំ ឬផ្លាស់ប្តូរ ពឹងផ្អែកលើទ្រព្យសម្បត្តិរបស់ពួកគេ។ ក្រៅពីផ្នែករាងកាយ ទ្រព្យសម្បត្តិរបស់ស្ត្រី ដូចជា ធនធាន ដីធ្លី ចំណេះដឹងបច្ចេកទេស ភាពអង់អាច ការធ្វើសេចក្តីសម្រេច ការអប់រំ ការថែទាំសុខភាព និងចំណីអាហារត្រូវបានកំណត់ថាជាកត្តាងាយរងគ្រោះ និងសមត្ថភាពបន្សាំ។ លោក Moser & Satterwaite, (2008) លើកឡើងថា នៅពេលប្រជាពលរដ្ឋមានទ្រព្យធនកាន់តែច្រើន កម្រិតភាពរងគ្រោះកាន់តែតិច ហើយនៅពេលមានការបាត់បង់ទ្រព្យសម្បត្តិរបស់មនុស្សច្រើន មនុស្សមិនមានសុវត្ថិភាពកាន់តែខ្លាំង។ តាមទិន្នន័យនានាក្នុងពិភពលោកបង្ហាញថា ស្ត្រីទំនងជាមាន ឬទទួលបានទ្រព្យសម្បត្តិតិច (ផ្នែករាងកាយ ហិរញ្ញវត្ថុ មនុស្ស ធនធានសង្គម និងធម្មជាតិ)។



**ប្រអប់ទី២៖ យេនឌ័រ និងទ្រព្យសម្បត្តិ ( Assets )**

វិសមភាពយេនឌ័រកើតមាននៅក្នុងការទទួលបានធនធានដ៏មានតម្លៃ ដូចជា ដីធ្លី ឥណទាន ឧបករណ៍កសិកម្ម បច្ចេកទេសកសិកម្ម និងសេវាបណ្តុះបណ្តាលផ្សេងៗដែលអាចពង្រឹងសមត្ថភាពរបស់ពួកគាត់ក្នុងការបន្សាំ។ នៅក្នុងប្រទេស លីប៊ីស្ត្រីផលិតបាន ៦០%នៃដំណាំផ្សេងៗ ទោះបីជាពួកគេខ្វះខាតនូវដីកសិកម្មមានចំណេះដឹងតិចតួចទាក់ទងនឹងបច្ចេកទេស និងកង្វះខាតនូវហិរញ្ញវត្ថុក៏ដោយ ( Liberia NBSAP, 2004 ) ។ ការវិភាគកម្មវិធីឥណទាននៅក្នុងប្រទេសអាហ្វ្រិកចំនួន៥បង្ហាញថា ស្ត្រីទទួលបានឥណទានតិចជាង១០% បើប្រៀបធៀបនឹងបុរស ( FAO, 2008 )។ ស្ត្រីទទួលបានដីធ្លី១០% តិចជាងបុរសនៅក្នុងប្រទេសឥណ្ឌា នេប៉ាល់ និងប្រទេសថៃ។ នៅប្រទេសកេនយ៉ា ទោះបីជាច្បាប់ដីធ្លីមិនបានហាមស្ត្រីជាម្ចាស់ដីធ្លី ប៉ុន្តែស្ត្រីនៅតែមានការលំបាកក្នុងការកាន់កាប់ដីធ្លី ( Kenya NBSAP, 2000 )។

ទ្រព្យសម្បត្តិស្ត្រីជាអ្នកកំណត់ថា តើពួកគេអាចឆ្លើយតបទៅនឹងផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុឬអត់? ដូច្នេះ សកម្មភាពនានាគួរតែត្រូវធ្វើឡើងដើម្បីកសាងមូលដ្ឋានទ្រព្យសម្បត្តិរបស់ស្ត្រីឱ្យទៅជាគោលការណ៍គ្រឹះនៅក្នុងយុទ្ធសាស្ត្របន្សាំ។

## ៣.២ ការបន្ថែមនូវគ្រោះថ្នាក់ដល់សុខុមាលភាព

ការប្រែប្រួលអាកាសធាតុបានធ្វើឱ្យប៉ះពាល់ដល់សុខុមាលភាពស្ត្រីជាងបុរស។ តាមរយៈផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល វាអាចធ្វើឱ្យមានផលប៉ះពាល់ជីវភាពរស់នៅប្រចាំថ្ងៃ និងអាយុកាលមធ្យមរស់របស់ពួកគេ (សូមមើលតារាង ទី១)។ បន្ថែមពីលើគ្រោះមហន្តរាយដែលមានស្រាប់ការប្រែប្រួលអាកាសធាតុជាគ្រោះថ្នាក់ថ្មីដែលត្រូវបានគេមើលមិនឃើញ។

**តារាងទី១៖** គ្រោះថ្នាក់ដោយផ្ទាល់ និងដោយប្រយោលនៃការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ដោយផ្ទាល់លើស្ត្រី

| មុខសញ្ញាគ្រោះថ្នាក់ | ឧទាហរណ៍ | ផលប៉ះពាល់ចំពោះស្ត្រី |
|---|---|---|
| **ផលប៉ះពាល់ដោយផ្ទាល់** | | |
| ការកើនឡើងនូវសីតុណ្ហភាពទឹកសមុទ្រ | ការកើនឡើងនូវគ្រោះថ្នាក់ដល់សត្វល្អិតតូចៗ ក្នុងសមុទ្រ ដោយសារតែការឡើងកំដៅ | ការបាត់បង់នូវផ្កាថ្ម អាចប៉ះពាល់ដល់ឧស្សាហកម្ម ទេសចរណ៍ ដែលជាវិស័យមួយមានស្ត្រីចំនួន ៤៦%នៃកម្លាំងពលកម្ម។ |
| កង្វះខាតទឹកនិងការកើនឡើងនូវភាពរាំងស្ងួត | - ប្រទេស ម៉ូរ៉ុកកូ មានបទពិសោធន៍ភាពរាំងស្ងួត ចំនួន១០ឆ្នាំ (១៩៨៤-២០០០)<br>- ភាគខាងជើងប្រទេស ខេនយ៉ា មានរាំងស្ងួត ៤ដង(១៩៨៣-២០០១) | ស្ត្រី និងក្មេងស្រីនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ទទួលខុសត្រូវចម្បងក្នុងការប្រមូលប្រើប្រាស់ និងចាត់ចែងទឹក។ ការថយចុះនូវបរិមាណទឹក និងធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ និងបង្កើននូវការងារបន្ថែមសម្រាប់ពួកគេ ព្រមទាំងប៉ះពាល់ដល់ការសិក្សា ឬប៉ះពាល់ដល់ឱកាស ការរកប្រាក់ចំណូលរបស់ស្ត្រី។ |
| ការកើនឡើងនូវបាតុភូតអាកាសធាតុ | ការកើតឡើងញឹកញាប់នូវព្យុះ (ស៊ីក្លូន ហារីខេន) ទឹកជំនន់ និងកំដៅ | តាមទិន្នន័យពីប្រទេស ១៤១ ក្នុងរយៈពេលពី ១៩៨១-២០០២ បានបង្ហាញថា គ្រោះធម្មជាតិគិត ជាមធ្យមសម្លាប់ស្ត្រីច្រើនជាងបុរស ឬសម្លាប់ស្ត្រី នៅអាយុតិចជាងបុរស។ |
| **ផលប៉ះពាល់ដោយប្រយោល** | | |
| ការកើនឡើងនូវជំងឺឆ្លង | ការប្រែប្រួលនៃអាកាសធាតុបានដើរតួយ៉ាងសំខាន់ក្នុងការចម្លងជំងឺគ្រុនចាញ់ នៅតំបន់ភ្នំ អាហ្វ្រិកខាងកើត នៅបង់ក្លាដេស មានការចម្លងជំងឺអាសន្នរោគមាន៧០% នៃជំងឺសរុប។ | ស្ត្រីទទួលបាននូវសេវាសុខភាពមានកំណត់បើប្រៀបធៀបនឹងបុរស ហើយស្ត្រីមានបន្ទុកការងារ កាន់តែច្រើន នៅពេលគេត្រូវចំណាយពេលច្រើនទៀតសម្រាប់មើលថែទាំអ្នកជំងឺ។ គ្រួសារក្រីក្រដែលឆ្លងមេរោគហ៊ីវ/ជំងឺអេដស៍កាន់តែមានធនធានតិចតួចក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ការទទួលនូវវិធីសាស្ត្រថ្មី សម្រាប់ផលិតកម្មដំណាំ ឬការចិញ្ចឹមសត្វ កាន់តែមានការលំបាក សម្រាប់ស្ត្រីជាមេគ្រួសារនិងគ្រួសារដែលមានអ្នកឆ្លងជំងឺ។ |
| ការបាត់បង់នូវពូជសត្វ | នៅឆ្នាំ ២០៥០ ការប្រែប្រួលអាកាសធាតុនឹងធ្វើឱ្យមានការផុតពូជនូវប្រភេទសត្វពី ១៨% ទៅ ៣៥% | ស្ត្រីជារឿយពឹងពាក់លើការដាំដំណាំផ្សេងៗដើម្បីឆ្លើយតបនឹងការផ្លាស់ប្តូរអាកាសធាតុ ប៉ុន្តែការផ្លាស់ប្តូរសីតុណ្ហភាពជានិរន្តរ៍នឹងកាត់បន្ថយនូវជីវចម្រុះកសិកម្ម និងថ្នាំបុរាណ ដែលធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងក្លាដល់សន្តិសុខស្បៀង និងសុខុមាលភាព។ |
| ការថយចុះនូវផលិតកម្មដំណាំ | នៅទ្វីបអាហ្វ្រិក ផលិតកម្ម ដំណាំ ត្រូវបានគេរំពឹងទុក នឹងថយចុះពី ២០-៥០% ដោយសារតែស្ថានភាពអាកាសធាតុ | ជាពិសេសស្ត្រីជនបទបានទទួលខុសត្រូវពាក់កណ្តាលនៃផលិតកម្មស្បៀងពិភពលោក ហើយផលិតស្បៀងពី ៦០-៨០% នៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ នៅទ្វីបអាហ្វ្រិក ផលប៉ះពាល់នៃអាកាសធាតុធ្វើឱ្យដំណាំខូចខាត ៤៨% នៅប្រទេសប៊ូគីណា និង ៧៣% នៅប្រទេស កុងហ្គោ។ |

ឧទាហរណ៍ ការកើតឡើងនូវជំងឺដែលពាក់ព័ន្ធនឹងអាកាសធាតុ នឹងបណ្ដាលឱ្យមានផលប៉ះពាល់ផ្សេងគ្នារវាងស្ត្រី និងបុរស។ ជារៀងរាល់ឆ្នាំ ស្ត្រីប្រហែល៥០លាននាក់ ដែលមានផ្ទៃពោះ បានឆ្លងជំងឺគ្រុនចាញ់ ក្នុងចំណោមនោះពាក់កណ្ដាល រស់នៅក្នុងទ្វីបអាហ្វ្រិក តំបន់ត្រូពិក បានឆ្លងមេរោគ Plasmodium Falciparum។ គេបានប៉ាន់ប្រមាណថា មានស្ត្រី ១០.០០០នាក់ និងកុមារ ២០០.០០០ បានស្លាប់ដោយសារការឆ្លងជំងឺគ្រុនចាញ់ ហើយការស្លាប់ដោយជំងឺគ្រុនចាញ់មាន ពាក់កណ្ដាលនៃការស្លាប់សរុប។

ការសិក្សាដោយសាលាសេដ្ឋកិច្ចនៃទីក្រុងឡុង និងវិទ្យាស្ថានសេដ្ឋកិច្ច ម៉ាក ភ្លេន កាលពីឆ្នាំ ២០០៧ បានវិភាគថា គ្រោះមហន្តរាយនៅក្នុងប្រទេស១៤១ បានបង្ហាញថា នៅពេលដែលសិទ្ធិនៅក្នុងសង្គមនិងសេដ្ឋកិច្ចរបស់ស្ត្រីមិនត្រូវបានគេ ការពារនោះមានស្ត្រីច្រើនជាងបុរសបានស្លាប់ដោយសារគ្រោះមហន្តរាយ។ យ៉ាងណាមិញ នៅក្នុងសង្គមដែលស្ត្រី និង បុរសមានសិទ្ធិស្មើគ្នា ការស្លាប់ដោយសារគ្រោះមហន្តរាយមានចំនួនស្មើគ្នា (Neumayer and Plumper, 2007)។

ដូច្នេះហើយ អន្តរាគមន៍ដែលទាក់ទងនឹងកាត់បន្ថយហានិភ័យ និងគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ គួរតែយក ចិត្តទុកដាក់ ជាពិសេសដោយផ្ដោតទៅលើការពង្រឹងសមត្ថភាពស្ត្រី ដើម្បីគ្រប់គ្រងគ្រោះមហន្តរាយបណ្ដាលមកពីការ ប្រែប្រួលអាកាសធាតុដើម្បីកាត់បន្ថយនូវភាពងាយរងគ្រោះ និងកសាងនូវឱកាសសម្រាប់អភិវឌ្ឍ។ សកម្មភាពមួយចំនួនគួរ តែត្រូវគេអនុវត្ត៖

- ពង្រឹងនូវការទទួលបានជំនាញផ្សេងៗ ការអប់រំ និងចំណេះដឹង
- ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងគ្រោះមហន្តរាយ និងការរៀបចំទុកជាមុន
- គាំទ្រស្ត្រីក្នុងការបង្កើតសម្លេង និងដើមទុននយោបាយដើម្បីទទួលបានឧបករណ៍ គ្រប់គ្រងហានិភ័យ និង
- បង្កើតគោលនយោបាយដើម្បីជួយស្ត្រីមេផ្ទះក្នុងការចំណាយទិញជូរមានស្ថិរភាព

## ៣.៣ សមភាពយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍៖ តើមានការពាក់ព័ន្ធគ្នាយ៉ាងដូចម្ដេច?

សមភាពយេនឌ័រ មានផ្ដោតនៅក្នុងគោលដៅអភិវឌ្ឍសហស្សវត្សរ៍ទី៣ និងតម្រូវឱ្យឈានទៅសម្រេចបានគ្រប់គោល ដៅនៃគោលដៅសហស្សវត្សរ៍ (Kabeer, 2003)។ ការមានវិសមភាពយេនឌ័រនៅក្នុងការប្រែប្រួលអាកាសធាតុកាន់តែរារាំង ដល់ការសម្រេចនូវគោលដៅសហស្សវត្សរ៍។ ប្រទេសកំពុងអភិវឌ្ឍកំពុងដោះស្រាយការប្រែប្រួលបរិស្ថាន ដែលរារាំងដល់ការរីក ចម្រើននៃការកាត់បន្ថយភាពក្រីក្រនិងគោលដៅការអភិវឌ្ឍប្រកបដោយស្ថិរភាព ហើយវិសមភាពយេនឌ័របានទប់ប្រទេសទាំង នោះ ឱ្យស្ថិតនៅក្នុងភាពក្រីក្រ និងគ្មានការអភិវឌ្ឍ។ នៅក្នុងករណីប្រហាក់ប្រហែលគ្នានេះ គោលដៅនៃគោលដៅសហស្សវត្សរ៍ នីមួយៗ មានតភ្ជាប់គ្នានិងពង្រឹងគ្នាទៅវិញទៅមក (សូមមើលតារាងទី២)។

ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាសិទ្ធិមនុស្ស និងសន្តិសុខពិភពលោក។ ការប្រែប្រួលអាកាសធាតុនេះ គឺជាបញ្ហា ប្រឈមដ៏ខ្លាំងដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព យុត្តិធម៌ សង្គម សមធម៌ និងការគោរពសិទ្ធិមនុស្ស ហើយជះឥទ្ធិពល ដល់មនុស្សជំនាន់ក្រោយផងដែរ។ យេនឌ័រគឺជាចំណុចស្នូលនៅក្នុងការដោះស្រាយបញ្ហាទាំងអស់នេះ។

**តារាងទី២៖** ទំនាក់ទំនងរវាង MDGs ការប្រែប្រួលអាកាសធាតុ និងយេនឌ័រ

| គោលដៅអភិវឌ្ឍសហស្សវត្សរ៍ (MDGs) | ការគំរាមកំហែងដោយការប្រែប្រួលអាកាសធាតុ | ការពាក់ព័ន្ធនឹងយេនឌ័រ |
|---|---|---|
| MDG ១៖ ការកាត់បន្ថយភាពក្រីក្រ និងការអត់ឃ្លាន | • ការកាត់បន្ថយ នូវផលិតកម្មកសិកម្ម សម្រាប់ការរស់នៅ និងពាណិជ្ជកម្ម<br>• ហានិភ័យចំពោះសន្តិសុខស្បៀង | • ស្ត្រីនៅក្នុងពិភពលោកភាគច្រើនស្ថិតនៅក្នុងភាពក្រីក្រ ក្នុងចំណោម ១,៣កោដ្ឋនៃអ្នកក្រីក្រក្នុងពិភពលោកមានស្ត្រី ចំនួន៧០%។<br>• មានការថយចុះឬបាត់បង់ប្រភេទរុក្ខជាតិ និងសត្វ ប្រើប្រាស់ដោយស្ត្រីដែលធានាដល់សន្តិសុខស្បៀងសម្រាប់គ្រួសារ។ ពពកប្រផេះក្នុងបរិយាកាស និងការបញ្ចេញនូវឧស្ម័នផ្ទះកញ្ចក់បានកាត់បន្ថយការច្រូតកាត់ស្រូវ (Cramer, 2006)។ អង្ករគឺប្រភពថាមពលចម្បងសម្រាប់ប្រជាជននៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ ស្ត្រីមានបញ្ហាអាហារូបត្ថម្ភ (Ex. 50% នៃស្ត្រី និងកុមារ នៅក្នុងប្រទេសកំពុងអភិវឌ្ឍមានបញ្ហាកង្វះអាហារូបត្ថម្ភ) ដោយសារតែកត្តាជីវសាស្ត្រ សង្គម សេដ្ឋកិច្ច យេនឌ័រ និងបញ្ហាវប្បធម៌ (ការមានផ្ទៃពោះ ការរំលូតកូន ការបែងចែកអាហារមិនស្មើភាពនៅក្នុងគ្រួសារ)។<br>• មានការថយចុះ និងផុតពូជនៃប្រភេទសត្វសមុទ្រដែលប្រើប្រាស់ដោយស្ត្រីសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ ឬសម្រាប់ផលិតកម្មផ្សេងៗ។<br>• នៅក្នុងករណីខ្លះ ការដោះដូររវាងការប្រើប្រាស់ និងការរស់រាន ជំរុញឱ្យមានភាពលំអៀងផ្នែកយេនឌ័រនៅក្នុងអាហារូបត្ថម្ភ។ ការសិក្សានៅប្រទេសឥណ្ឌាបានបង្ហាញថា អាហារូបត្ថម្ភរបស់ក្មេងស្រី មានការខ្វះខាតនៅពេលការប្រមូលផលបានតិច និងតម្លៃអាហារឡើងថ្លៃ ហើយពេលដែលមានភ្លៀងធ្លាក់តិចតួចដែលធ្វើឱ្យមានក្មេងស្រីច្រើនស្លាប់ បើប្រៀបធៀបនឹងក្មេងប្រុស (UNDP, 2007) |

| | | |
|---|---|---|
| MDG ២ ៖ ការសម្រេចនូវការអប់រំបឋមជាសកល | • បង្កើនបន្ទុកការងារចាំបាច់សម្រាប់ផលិតកម្មកសិកម្ម និងសកម្មភាពការងារឥតកម្រៃ<br>• ការប្រែប្រួលបរិស្ថានទំនងជាជំរុញឱ្យមានទេសន្តប្រវេសន៍<br>• ការទទួលបានទឹកស្អាតមានតិចតួច | • ជាទូទៅស្ត្រី និងក្មេងស្រីជាអ្នកទទួលខុសត្រូវលើ ការរកអុសនិងទឹក។ នៅក្នុងតំបន់ក្រីក្របំផុតនៃពិភពលោក ជាពិសេសនៅអនុតំបន់សាហារ៉ាអាហ្វ្រិក ស្ត្រី និងក្មេងស្រីចំណាយពេលពី ៣-៤ ម៉ោងក្នុង១ថ្ងៃដើម្បីរកអុស និងទឹក។ ទឹកជំនន់ រាំងស្ងួត និងតំបន់វាលខ្សាច់កាន់តែធ្វើឱ្យស្ថានភាពនេះលំបាកឡើង ដែលជំរុញឱ្យក្មេងស្រីនៅក្នុងសហគមន៍បោះបង់ការសិក្សា។ ក្នុងចំណោមក្មេង ១១៥ លាននាក់ ដែលមិនបានទៅសាលានៅក្នុងពិភពលោក មាន៣/៥ ជាក្មេងស្រី ហើយស្ត្រីមានចំនួន ៧៥% ក្នុងចំណោមអ្នកមិនចេះអក្សរសរុប ( Oxfam, 2007 )។<br>• យោងទៅតាមអង្គការ UNHCR ៨០% នៃជនភៀសខ្លួននៅក្នុងពិភពលោកជាស្ត្រីនិងកុមារ។ ការធ្វើទេសន្តប្រវេសន៍នៃប្រជាជនបានធ្វើឱ្យមានការប្រែប្រួល និងគ្រោះមហន្តរាយដែលអាចបញ្ឈប់ និងកម្រិតដល់ឱកាសទទួលបាននូវការអប់រំ។<br>• បុរសទំនងជាធ្វើទេសន្តប្រវេសន៍ទៅតាមរដូវកាល ឬប្រចាំឆ្នាំ។ ស្ត្រីជាមេគ្រួសារដែលនៅចាំផ្ទះជារឿយក្លាយជាអ្នកក្រីក្រជាងគេ។ ការងារដ៏ធ្ងន់ធ្ងររបស់ស្ត្រីទាំងនោះ ក្មេងៗ និងចាស់ជរាមានការកើនឡើងជាអតិបរមាដែលជាលទ្ធផលនៃការធ្វើទេសន្តប្រវេសន៍របស់បុរស។ |

| | | |
|---|---|---|
| MDG ៣៖ លើកកម្ពស់ សមភាពយេនឌ័រ និងផ្ដល់ភាពអង់អាចដល់ស្ត្រី | • ការស្លាប់ និងការរងរបួសបានកើនឡើងនៅពេលដែលមានវិសមភាព<br>• ស្ថានភាពលំបាកកើតឡើងនៅពេលដែលមានវិសមភាពយេនឌ័រ<br>• ធ្វើឱ្យមានគោលនយោបាយ ទីជម្រក និងការផ្ដល់ភាពអង់អាចផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច | • ការសិក្សានៅឆ្នាំ ២០០៧ លើគ្រោះមហន្តរាយធម្មជាតិចំនួន១៤១ ដោយសាលាសេដ្ឋកិច្ចនៃទីក្រុងឡុងដ៍ បង្ហាញថា នៅពេលដែលសេដ្ឋកិច្ចសង្គមត្រូវបានបំពេញសម្រាប់ស្ត្រី និងបុរស ផលប៉ះពាល់ដល់ស្លាប់នៃគ្រោះមហន្តរាយមានចំនួនស្មើគ្នា។ ផ្ទុយមកវិញ នៅពេលដែលស្ត្រីមិនបានទទួលផលពីសេដ្ឋកិច្ចសង្គមដូចបុរស នោះមានស្ត្រីច្រើនជាងបុរសស្លាប់ដោយសារគ្រោះមហន្តរាយ។ វិសមភាពយេនឌ័រនេះត្រូវបានបង្ហាញនៅក្នុងគ្រោះមហន្តរាយធំៗដូចជា ហ៊ីរីខេន-មិច ហ៊ីរីខេនកាតទ្រីណា ព្យុះផ្សេងៗនៅទ្វីបអាមេរិក ការឡើងកំដៅនៅអឺរ៉ុប និងព្យុះស៊ីក្លូននៅអាស៊ីខាងត្បូង<br>• ប្រទេសនៅអាមេរិកឡាទីនខ្លះ ដោយសារតែកត្តាសង្គមដែលកំណត់ថា បុរសជាអ្នកដោះស្រាយនៅពេលមានមហន្តរាយកើតឡើង ដូចនេះបុរសទទួលគ្រោះថ្នាក់ខ្លាំងនៅពេលមានគ្រោះមហន្តរាយកើតឡើង ដោយសារតែភាពអង់អាចក្លាហានរបស់គេ (Superman Syndrome) ហេតុនេះបណ្ដាលឱ្យមានការស្លាប់ដែលមិនចាំបាច់ ដូចជាហែលឆ្លងទន្លេនៅពេលមានព្យុះ។<br>• ពេលការប្រែប្រួលបរិស្ថានកើតឡើងភ្លាមៗ វិសមភាពកើតឡើងយ៉ាងរហ័សផងដែរ ជាពិសេសពាក់ព័ន្ធនឹងការប្រើប្រាស់ធនធាន។ កង់ប្រវត្តិសាស្ត្របានបង្ហាញពីគុណវិបត្តិ រួមបញ្ចូលទាំងការបែងចែកដីធ្លី ធនធានព័ត៌មាន និងការធ្វើសេចក្ដីសម្រេច។ លទ្ធផលបង្ហាញថាស្ត្រីមានបន្ទុកយ៉ាងធ្ងន់ធ្ងរបន្ទាប់ពីគ្រោះធម្មជាតិ។<br>• ស្ត្រីនៅក្នុងប្រទេសកំពុងអភិវឌ្ឍភាគច្រើនទទួលខុសត្រូវក្នុងសន្តិសុខស្បៀង ការប្រើប្រាស់ទឹក និងថាមពលសម្រាប់ចំអិនអាហារ។ ប្រសិនបើគ្រោះធម្មជាតិកើតឡើងស្ត្រីនឹងទទួលរងផលប៉ះពាល់យ៉ាងខ្លាំងក្លាជាពិសេសពួកគាត់មិនអាចប្រើប្រាស់ធនធានបានដូចជារកប្រាក់ចំណូល ការទទួលបានការអប់រំ ឬការថែទាំសម្រាប់ក្រុមគ្រួសាររបស់ពួកគេ។<br>• ស្ត្រីមានការចូលរួមតិចតួច និងខ្វះអ្នកតំណាងរបស់ខ្លួននៅក្នុងការធ្វើសេចក្ដីសម្រេចនៅគ្រប់កម្រិតដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ លទ្ធផលបង្ហាញថា មិនមានកម្មវិធី និងគោលនយោបាយដែលឆ្លើយតបនឹងតម្រូវការស្ត្រីទេ។ |
| MDG ៤៖ កាត់បន្ថយ ការស្លាប់របស់កុមារ | ផលប៉ះពាល់នៃបរិស្ថានបណ្ដាលឱ្យគ្រោះថ្នាក់កាន់អាក្រក់ឡើងជាពិសេសការមានជំងឺ | ការកើនឡើងនូវការងាររបស់ស្ត្រី ដោយសារតែតួនាទីថែទាំនៅក្នុងគ្រួសារ ឧទាហរណ៍៖ ការចំណាយពេលលើការថែទាំកូននិងអ្នកជំងឺ។ ការបាត់បង់នូវរុក្ខជាតិដែលប្រើប្រាស់ដោយស្ត្រី។ |

| | | |
|---|---|---|
| MDG 5៖ ការធ្វើឱ្យប្រសើរឡើងនូវសុខភាពមាតា | បង្កើននូវប្រេវ៉ាឡង់នៃប្រភពជំងឺឆ្លងខ្លះៗ | • ស្ត្រី និងកុមារមាន១៤ដងច្រើនជាងបុរសស្លាប់ដោយសារគ្រោះមហន្តរាយ ( Peterson, 2007 )<br>• អត្រាស្លាប់ខ្ពស់របស់ម្តាយ/ស្ត្រី/ប្រពន្ធ ក្នុងអំឡុងពេលគ្រោះមហន្តរាយមានការកើនឡើងដូចជាចំនួនកុមារកំព្រា និងអត្រាស្លាប់ ការផាប់រៀបការរបស់ក្មេងស្រីបណ្តាលឱ្យពួកគេបោះបង់ការសិក្សាទទួលរងការជួញដូរ និង ពេស្យាចារដែលជាកត្តាជំរុញឱ្យមានការកើនឡើងនូវជំងឺអេដស៍ ( Oxfam, 2005 )។ |
| MGD 6៖ ការបំបាត់នូវជំងឺអេដស៍ ជំងឺគ្រុនចាញ់និងជំងឺឆ្លងផ្សេងៗ | ការកើនឡើងនូវកំដៅ ( រលកកំដៅ ) | ទេសន្តប្រវេសន៍ធ្វើឱ្យមានហានិភ័យនៃជំងឺអេដស៍ ដែលបណ្តាលឱ្យគ្រួសារបែកបាក់ និងជំរុញឱ្យពួកគេរស់នៅតំបន់ដែលមានប្រជាជនច្រើនហួស។ |
| MDG 7៖ ជានានិរន្តរភាពផ្នែកបរិស្ថាន | • ការផុតពូជនូវប្រភេទសត្វ និងរុក្ខជាតិ<br>• ការប្រែប្រួលផ្នែកបរិមាណ និងគុណភាពនៃធនធានធម្មជាតិ អាចបណ្តាលឱ្យមានការកាត់បន្ថយផលិតកម្មប្រព័ន្ធអេកូឡូស៊ី<br>• ទឹកជំនន់ គ្រោះរាំងស្ងួតការឡើងនូវនីវ៉ូទឹកសមុទ្រ និងការរលាយផ្ទាំងទឹកកកតំបន់ប៉ូល | • ដោយគ្មានការថែរក្សា និងត្រួតពិនិត្យនូវធនធានធម្មជាតិ ( ទឹកដីដើមឈើ និងការចិញ្ចឹមសត្វ ) ស្ត្រីមានបញ្ហាប្រឈមខ្លាំងក្នុងការឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។<br>• ការរាំងរាលការបន្សាំដែលពាក់ព័ន្ធនឹងការក្លាយជាតំបន់វាលខ្សាច់ជារឿយៗទាក់ទងទៅនឹងកម្លាំងពលកម្ម ហើយស្ត្រីជារឿយៗប្រឈមនឹងការកើនឡើងនូវការរំពឹងទុកក្នុងការធ្វើការងារផ្ទះដែលគ្មានប្រាក់កម្រៃ និងការងារ សហគមន៍ដែលពាក់ព័ន្ធនឹងការរៀបចំដីធ្លី និងការរកទឹក។<br>• ការថយចុះនូវធនធានព្រៃឈើដែលប្រើប្រាស់ដោយស្ត្រី ជាពិសេសស្ត្រីជនបទក្នុងប្រទេសកំពុងអភិវឌ្ឍដែលពួកគាត់ប្រមូលអនុផលព្រៃឈើដូចជាអុស ថ្នាំ សង្កូវ ឬចំណីសត្វ។ ការថយចុះនិងការបាត់បង់នូវអនុផលទាំងនេះបណ្តាលឱ្យមានផលប៉ះពាល់ដូចជា សុខុមាលភាពរបស់ពួកគាត់ និងក្រុមគ្រួសារ។ ស្ត្រីជារឿយៗពឹងផ្អែកលើដំណាំផ្សេងៗ ( ជីវចម្រុះ-កសិកម្ម ) ដើម្បីប្រឈមនឹងភាពប្រែប្រួលនៃអាកាសធាតុ ក៏ប៉ុន្តែការប្រែប្រួលសីតុណ្ហភាពនឹងកាត់បន្ថយនូវជីវចម្រុះ-កសិកម្មនិងថ្នាំសង្កូវបុរាណ។ |

| | | |
|---|---|---|
| MDG 8៖ បង្កើតភាពជាដៃគូសម្រាប់ការអភិវឌ្ឍ | • ការប្រែប្រួលអាកាសធាតុបន្ថែមនូវការលំបាកក្នុងការធ្វើឱ្យសម្រេចនូវគោលដៅអភិវឌ្ឍសហស្សវត្សរ៍<br>• បង្កើនថវិកាសម្រាប់ការបន្សាំ និងការការពារ | • សហការដោយមានការឆ្លើយតបនឹងយេនឌ័រ នៅក្នុងការផ្ទេរនូវបច្ចេកទេស កម្មវិធី និងគម្រោងនានា ដើម្បីបង្កើនសមត្ថភាពសម្រាប់ការបន្សាំ និងទេសន្តប្រវេសន៍<br>• ជំរុញ សម្របសម្រួល អភិវឌ្ឍន៍ ដល់កម្មវិធីបណ្តុះបណ្តាល និងអប់រំ អំពីការប្រែប្រួលអាកាសធាតុ និងផ្តោតលើស្ត្រី។<br>• សម្របសម្រួលការទទួលបានជាសាធារណៈនូវទិន្នន័យ និងព័ត៌មាន ដោយផ្តល់នូវព័ត៌មាន អំពីអាកាសធាតុ គោលនយោបាយផ្សេងៗ និងសកម្មភាពមួយចំនួនដែលស្ត្រីត្រូវយល់ដឹង ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយផ្តោតលើ៖ គុណភាពនៃការទទួលបានអ៊ីនធឺណេត បញ្ហាអក្ខរកម្ម និងបញ្ហាភាសា។<br>• ជំរុញការចូលរួមរបស់ស្ត្រីក្នុងប្រែប្រួលអាកាសធាតុ ការប៉ះពាល់របស់វា និងការបង្កើតចម្លើយដោយសម្របសម្រួលយោបល់ត្រឡប់ ការជជែកពិភាក្សា និងភាពដៃគូ ក្នុងសកម្មភាពប្រែប្រួលអាកាសធាតុ។<br>• ការបែងចែកថវិកាត្រូវឆ្លើយតបនឹងយេនឌ័រ ជាពិសេសក្នុងការបន្សាំនឹងភាពធន់ទ្រាំ។ |



## ឯកសារស្រាវជ្រាវ


Enarson, E. (1998). “Through Women’s Eyes: A Gendered Research Agenda for Disaster Social Science”. Disasters 22(2): 157–173.

Lambrou, Y. and Piana, G. (2006). Gender: The missing component of the response to climate change. Italy: FAO.

Masika, R. (Ed.) (2002). Gender, Development and Climate Change. UK: Oxfam. Nelson, V., Meadows, K., Cannon, T., Morton, J. and Martin, A. (2002). “Uncertain Predictions, Invisible Impacts, and the Need to Mainstream Gender in Climate Change Adaptations”. Gender & Development 10(2).

Neumayer, E. and Plümper, T. (2007). “The Gendered Nature of Natural Disasters: The Impact of Catastrophic Events on the Gender Gap in Life Expectancy, 1981–2002”. Annals of the Association of American Geographers 97(3): 551-566.

WEDO, ABANTU, ActionAid and ENDA. (2008). Gender, Climate Change and Human Security Lessons from Bangladesh, Ghana and Senegal. Report for the Hellenic Foundation for European and Foreign Policy (ELIAMEP).

## កិច្ចការសម្រាប់ជំពូកនេះ៖

| សកម្មភាព | ដំណើរការ | រយៈពេល |
|---|---|---|
| ការយល់ដឹងពីទំនាក់ទំនងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ | ជាមួយព័ត៌មានដែលផ្តល់នៅក្នុងជំពូកនេះ ធ្វើបទបង្ហាញ ដោយលើកយកបញ្ហានៃភាពងាយរងគ្រោះ និងទ្រព្យសម្បត្តិ ( assets ) និងស្ត្រីជាភ្នាក់ងារនៃការផ្លាស់ប្តូរ ការបង្ហាញវីដេអូរបស់ Oxfam http://www.youtube.com/watch?v=iSMB8m4_4BM&eurl= http://www.newscientist.com/blog/environment/2008/06/is-climate-changefeminist-issue.html?DCMP=ILCrhts&nsref=ts12_he | ១០ នាទី |
| | បន្ទាប់មក សួរអ្នកចូលរួមឱ្យរកគំនិតសំខាន់នៃវីដេអូខ្លីប និងរកដំណោះស្រាយមួយចំនួន | ១៥ នាទី |
| | បែងចែកក្រុមពិភាក្សា ជា២ក្រុម ដោយអនុវត្ត វិធីសាស្ត្រ តើការប្រែប្រួលអាកាសធាតុ មានផលប៉ះពាល់ខុសគ្នារវាងបុរស ស្ត្រីយ៉ាងដូចម្តេច ? | ៥០ នាទី |

# ករណីសិក្សា

## ករណីសិក្សាទី១៖ ក្រុម ម៉ាម៉ា វ៉ាតូ



ម៉ាម៉ាវ៉ាតូ បានអនុវត្តគម្រោងដាំព្រៃឈើឡើងវិញតាំងពីឆ្នាំ១៩៩៤ ដែលផ្តល់អត្ថប្រយោជន៍ដល់ការអភិរក្សជីវចម្រុះនៅក្នុងសហគមន៍ ការពារការសឹករិចរិលនៃដី និងធ្វើឱ្យប្រសើរនូវគុណភាពដី។ គោលបំណងធំនៃគម្រោងគឺដើម្បីដោះស្រាយនូវកង្វះខាតអុស និងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជននៅក្នុងសហគមន៍។ ទោះជាយ៉ាងណាក៏ដោយ នៅពេលគម្រោងមានការវិវត្ត ជាពិសេសការផ្តល់ភាពអង់អាចលើការអប់រំពីបរិស្ថាន និងការផ្តល់នូវជំនាញសម្រាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃដោយពឹងផ្អែកលើបរិស្ថានជុំវិញធ្វើឱ្យមានភាពជោគជ័យដោយមានការផ្លាស់ប្តូរ។ ប្រភពប្រាក់ចំណូលផ្សេងៗ និងការដាំព្រៃឈើឡើងវិញនៅក្នុងសហគមន៍នឹងកាត់បន្ថយនូវការគំរាមកំហែងនៃការប្រែប្រួលអាកាសធាតុ នូវគ្រោះថ្នាក់ធម្មជាតិមួយចំនួនដូចជា ទឹកជំនន់ ការហូរដី និងគ្រោះរាំងស្ងួត។ ការផ្តួចផ្តើមនេះ នឹងជួយដល់ការកាត់បន្ថយនូវការប្រែប្រួលអាកាសធាតុ តាមរយៈការដាំដើមឈើឡើងវិញ។

ក្រុមស្ត្រី ម៉ាម៉ា វ៉ាតូនៅក្នុងប្រទេសខេនយ៉ា ត្រូវគេបង្កើតឡើងនៅឆ្នាំ ១៩៩០ ដើម្បីដោះស្រាយការខ្វះខាតអុស និងភាពក្រីក្ររបស់ស្ត្រីនៅជនបទ។ ក្រុមនេះមានស្ត្រីចំនួន ២៨នាក់ និងសមាជិកនៅក្នុងគ្រួសាររបស់គេ ( សរុប ១៥០នាក់ ) ដែលស្ថិតនៅតំបន់ កាកាមេកា ភាគខាងលិចនៃប្រទេសខេនយ៉ា។ កាកាមេកា មានចម្ងាយ៣០ គីឡូម៉ែត្រពីអេក្វាទ័រ ដោយតំបន់នេះមានរបបទឹកភ្លៀងខ្ពស់។

អុសគឺជាប្រភពថាមពលប្រើប្រាស់សំខាន់របស់សហគមន៍។ នៅពេលដែលកាន់តែលំបាករក ស្ត្រីត្រូវបង្ខំរកអុសដោយខុសច្បាប់ពីតំបន់អភិរក្សតាមព្រំដែនរបស់សហគមន៍ ជាពិសេសពីតំបន់អភិរក្សព្រៃឈើជាតិ តំបន់កាកាមេហ្គា (Kakamega) នៃប្រទេសកេនយ៉ាភាគខាងលិច ដែលពួកគេត្រូវគេពិន័យ និងចាប់ដាក់គុក។ ចាប់តាំងពីមានការបង្កើតក្រុម ក្រុមបានដាំដើមឈើហូតដល់ធំសម្រាប់ធ្វើអុស និងក្តារបន្ទះ ( ព្រៃបង្កើតដោយស្ត្រី ) ដែលជាផ្នែកមួយរបស់គ្រួសារ និងកសិដ្ឋានរបស់ពួកគេ។ កម្មវិធីចំការព្រៃដាំបានធ្វើឱ្យប្រសើរឡើងនូវគុណភាពដី កាត់បន្ថយនូវការកាប់ឈើខុសច្បាប់ និងការដាំបន្លែនៅតំបន់កាមបេរី ដូចនេះវាអាចបង្កើននូវការស្រូបកាបូន ( FAO, 1994 )។

សមាជិកក្រុមបានធ្វើឱ្យប្រាកដប្រជាថា គ្រួសារដែលពីមុនបានកាប់បំផ្លាញព្រៃឈើ បានប្រើប្រាស់នូវចំការព្រៃដាំជំនួសវិញ។ សមាជិកក្រុមបានពង្រីកនូវការប្រមូលអនុផលព្រៃឈើកែច្នៃ និងការវេចខ្ចប់ទឹកឃ្មុំដែលធ្វើឱ្យប្រសើរឡើងនូវប្រាក់ចំណូល។ ការដាំដុះនូវសណ្តែកសៀងបានធ្វើឱ្យប្រសើរឡើងនូវប្រាក់ចំណូលប្រចាំគ្រួសារ ដោយមានការបង្កើត ឃ្លាំងសម្រាប់រក្សាទុកជារួមរបស់ក្រុម។ បន្ថែមពីនេះ ក្រុមណែនាំធ្វើកសិដ្ឋានចិញ្ចឹមត្រី ការប្រមូលនូវស្មៅផ្សេងៗ និងរុក្ខជាតិឱសថ។ ការបំផ្លាញនូវធនធានព្រៃឈើ មានកាត់បន្ថយយ៉ាងឆាប់រហ័សចាប់តាំងពីសហគមន៍បានធ្វើនូវកសិកម្មចម្រុះ។

សមាជិកក្រុម បានធ្វើការក្នុងការកាត់បន្ថយនូវការគំរាមកំហែងនូវជីវៈចម្រុះតាមរយៈការអប់រំ។សមាជិកក្រុមបានយកចិត្តទុកដាក់ដល់ក្មេងកំព្រា និងជនផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍។

គ្រប់សកម្មភាពរបស់សមាជិកធ្វើជាលក្ខណៈក្រុម និងរចនាសម្ព័ន្ធរបស់ក្រុម បង្កើតឡើងនូវការចូលរួមរបស់សមាជិកគ្រប់រូបដែលជួយថែរក្សានូវស្ថិរភាពរបស់គម្រោង។ សមាជិកក្រុមបានធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងរដ្ឋាភិបាល និងវិទ្យាស្ថានស្រាវជ្រាវ។ ដៃគូសហការមានក្រុមជួយខ្លួនឯងសានជីវ៉ាមា ( ក្រុមកុមារកំព្រា ) ក្រុមជួយតំបន់អ៊ីវ៉ាកាលី និងក្រុមស្ត្រីម៉ូស៊ីមប៊ីលី និងក្រុមផ្សេងៗទៀតដូចជា Lugusi Post Test Group (ការថែទាំជម្ងឺអេដស៍នៅតាមផ្ទះ), Kenya Wildlife Service-Buyangu Camp (ការការពារធនធានព្រៃឈើ); GROOTS Kenya (ការរៀនសូត្រ និងផ្លាស់ប្តូរបទពិសោធន៍គ្នា); Jamii Network Group, Ivakale Bidi Self-Help Group, Ileho Youth Association, I.I.R.R (គ្រាប់សណ្តែកសៀង), and Vihiga District Rotarians (ម៉ាស៊ីនបូមទឹក)។

## ករណីសិក្សាទី២៖ ប្រជាធិបតេយ្យូបនីយកម្ម ចំណេះដឹងដល់ថ្នាក់មូលដ្ឋាន

បូលីវៀន ឬខ្ពង់រាបខ្ពស់ពីនីវ៉ូទឹកសមុទ្រ ដែលជាតំបន់មិនមានអាកាសធាតុល្អ ត្រជាក់និងមិនសូវមានភ្លៀងសម្រាប់ធ្វើកសិកម្មដែលត្រូវការច្នៃប្រឌិតខ្ពស់ក្នុងការរស់នៅ។

គំនិតផ្តួចផ្តើមនូវការបង្កើតសហប្រតិបត្តិការ បូលិវៀន មានគោលបំណងដើម្បីជួយគាំទ្រ និងការប្រើប្រាស់ចំណេះដឹង ជាលក្ខណៈប្រពៃណីអំពីការទស្សន៍ទាយអាកាសធាតុសម្រាប់ការធ្វើសេចក្តីសម្រេចក្នុងការធ្វើកសិកម្ម និងការគ្រប់គ្រងគ្រោះមហន្តរាយ។ ហេតុដូច្នេះហើយ សកម្មភាពនេះគាំទ្រលើការពង្រឹងសមត្ថភាពស្ត្រីនិងបុរសនៅក្នុងសហគមន៍ជនបទ។ ជាលទ្ធផល ក្រុមសម្រាប់ផ្គត់ផ្គង់បច្ចេកទេសត្រូវបានបង្កើតឡើង ដោយឱ្យឈ្មោះថា យ៉ាពូធីរី ដែលលក់នូវសេវាកម្មសម្រាប់ផ្គត់ផ្គង់ឱ្យកសិករផ្សេងៗ។

នៅក្នុងភាសាអាយម៉ារ៉ានៅសហគមន៍ដែលហ៊ុំព័ទ្ធដោយបឹងទីទីកាកា នៅក្នុងតំបន់ បូលីវៀ ដែលគេហៅថា«យ៉ាពូធីរី» មានន័យថា«សាបព្រួស» ហើយដែលសំដៅលើកសិករដែលមានជំនាញច្បាស់លាស់ក្នុងការរៀនជំនាញកសិកម្ម។ កសិករជំនាញទាំងនេះ បានផ្ទេរចំណេះដឹងដល់សហគមន៍ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ កសិកម្មបែបប្រពៃណី និងចំណេះដឹងពីអាកាសធាតុដោយរួបបញ្ចូលតែមួយ និងផ្សព្វផ្សាយចំណេះដឹងពីជនជាតិភ្នំ។ ការប្រមូលផ្តុំការច្នៃប្រឌិតនៃប្រព័ន្ធយ៉ាពូធីរី មានការកើនឡើងនូវតម្រូវការជំនួយបច្ចេកទេសដល់កសិករ។ ការគាំទ្រនូវកិច្ចសហប្រតិបត្តិការដល់ យ៉ាពូធីរី នៅក្នុងការលក់បច្ចេកទេស និងសេវាកម្មហិរញ្ញវត្ថុដល់កសិករក្នុងសហគមន៍។

ប្រូស៊ូកូគឺជាសហគមន៍កសិករ ដែលបង្កើតឡើងពីគម្រោងប្រូស៊ូកូដែលគិតពីផលប្រយោជន៍កសិករ (UNAPA) ដែលបានប្រមូលផ្តុំនូវសហគមន៍ចំនួន៣២។ UNAPA មានសមាជិកចំនួន២៨៩គ្រួសារ និងបានផ្តល់នូវសេវាកម្មដល់ ២៥០០ គ្រួសារ នៅក្នុងខេត្តចំនួនប្រាំ នៅក្នុងប្រទេសបូលីវៀ។ UNAPA ផ្តល់នូវហិរញ្ញវត្ថុ និងសេវាកម្មមិនមែនហិរញ្ញវត្ថុទៅសមាជិករបស់ខ្លួន។ សេវាកម្មហិរញ្ញវត្ថុគឺជាសេវាកម្មឥណទាន តាមរយៈប្រព័ន្ធមីក្រូហិរញ្ញវត្ថុបូលីវៀ និងសេវាកម្មធានារ៉ាប់រងដំណាំក្នុងការប្រយុទ្ធនឹងហានិភ័យអាកាសធាតុ។ សេវាកម្មទាំងនោះត្រូវបានអភិវឌ្ឍដោយមានការជួយពីដៃគូជំនាញៗ ដូចជាមូលនិធិប្រូហីន ដែលជាកម្មវិធីគាំទ្រដល់សេវាកម្មហិរញ្ញវត្ថុរបស់ប្រទេសបូលីវៀ។

UNAPA ដែលជាសេវាកម្មមិនមែនហិរញ្ញវត្ថុត្រូវបានផ្តល់ដោយយ៉ាពូធីរី ដែលជាក្រុមធ្វើសិប្បកម្មកសិកម្ម។ ប្រូស៊ូកូបានធ្វើការជាមួយយ៉ាពូធីរី ក្នុងការពង្រឹងនូវសមត្ថភាពកសិករ ក្នុងគោលបំណងឱ្យពួកគេធ្វើការសម្រាប់ UNAPA ជាអ្នកផ្តល់នូវការស្រាវជ្រាវផ្នែកកសិកម្ម និងសេវាកម្មផ្សេងៗ។ ដោយមានកាសម្របសម្រួលពី ប្រូស៊ូកូ ពួកគេបានកំណត់ឱ្យ UNAPA ជាអ្នកគ្រប់គ្រងគ្រោះមហន្តរាយផ្នែកកសិកម្ម ហើយនិងជាអ្នកអភិវឌ្ឍ និងសាកល្បងបច្ចេកទេសក្នុងការប្រយុទ្ធនឹងហានិភ័យផ្សេងៗ។

បច្ចុប្បន្ននេះ UNAPA មានយ៉ាពូធីរី ចំនួន ៦០ ដែលក្នុងនោះមានស្ត្រី១០នាក់។ សមាសធាតុយេនឌ័រនៃប្រព័ន្ធមានការកើនឡើងពីតម្រូវការដល់ចំណុចដែលចង់បាន និងធ្វើឱ្យប្រសើរឡើងផលិតកម្មកសិកម្មដល់ស្ត្រី។ ឧទាហរណ៍តាមទម្លាប់ ស្ត្រីជាអ្នកទទួលខុសត្រូវក្នុងការរក្សាគ្រាប់ពូជ និងសម្ភារៈសម្រាប់សាបព្រួស ប៉ុន្តែមានស្ត្រីតិចតួចនៅក្នុងសហគមន៍ធ្វើការងារនេះបានលទ្ធផលខ្ពស់។ ស្ត្រីជនជាតិយ៉ាពូធីរី ជាអ្នករក្សាទុកនូវពូជដំឡូងផ្សេងៗ គ្រាប់ពូជ និងប្រភេទដំណាំផ្សេងៗទៀត រួមបញ្ចូលទាំងប្រភេទរុក្ខជាតិជាឱសថផ្សេងៗ។ បន្ថែមពីនេះ ពួកគេបានស្រាវជ្រាវ និងដឹងពីស្ថានភាពនិងទីកន្លែងក្នុងការសាបពូជដំណាំផ្សេងៗ។ ពួកគេមានចំណេះដឹង ក្នុងការកំណត់នូវយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងហានិភ័យ និងជួយស្ត្រីដែលជាកសិករផ្សេងៗទៀតឱ្យធ្វើដូចពួកគេដែរ។ ករណីភាគច្រើន ស្ត្រីជនជាតិយ៉ាពូធីរី មិនត្រឹមតែផ្ទេរនូវចំណេះដឹង ប៉ុន្តែជួយក្នុងការកសាងនូវសមត្ថភាពវិភាគដល់ស្ត្រីដែលជាកសិករផ្សេងទៀត។

បន្ថែមពីនេះ ស្ត្រីជនជាតិយ៉ាពូធីរីមានតួនាទីជាក់លាក់នៅក្នុងការចរចារកទីផ្សារលក់ ផលិតផលសហគមន៍។ ដោយសារតែការទទួលបាននូវទីផ្សារលក់ផលិតផល គឺជាសេវាកម្មមួយទៀតរបស់ UNAPA ដូច្នេះ ស្ត្រីជនជាតិយ៉ាពូធីរី ចរចាដើម្បីបានកិច្ចសន្យាលក់ដំឡូង និងអភិវឌ្ឍទីផ្សារសម្រាប់ផលិតផលថ្មីដូចជា ដំឡូងកែច្នៃដំឡូងស្ងួត និងកក ព្រមទាំងគ្រាប់ធនធានជាតិផ្សេងៗ។ ពួកគេក៏បានធ្វើ

ការពាក់ព័ន្ធនឹងការបន្សាំនឹងការគ្រប់គ្រងហានិភ័យ ត្រួតពិនិត្យសូចនាករជីវៈនៃអាកាសធាតុ និងមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗពាក់ព័ន្ធនឹងអាកាសធាតុ។

សកម្មភាពនេះចាប់ផ្តើមនៅខែតុលា ឆ្នាំ២០០៦ ហើយបញ្ចប់នៅខែកក្កដា ឆ្នាំ២០០៨ ដែលបានធ្វើការងារកសិកម្មបាន២ជុំ។ នៅក្នុងរយៈពេល២ឆ្នាំនេះ ជនជាតិ យ៉ាពូធីរី មានលទ្ធភាពក្នុងការប្រយុទ្ធនឹងភាពគ្រាំដាក់ ដែលបំផ្លាញនូវដំណាំដំឡូងនៅក្នុងសហគមន៍ ខណៈពេលដែលការស្រាវជ្រាវវិទ្យាសាស្ត្ររយៈពេល១០ឆ្នាំបានបង្ហាញថា គ្មានការប៉ះពាល់នៅក្នុងសហគមន៍ផងដែរ។ ដំណាក់កាលដំបូលនៃគម្រោងសង្កត់ធ្ងន់លើការទស្សន៍ទាយផ្នែកអាកាសធាតុ តាមរយៈការអង្កេតលើរុក្ខជាតិ និងសត្វ ហើយគម្រោងអនុញ្ញាតឱ្យផែនការដាំដំណាំអាចឆ្លើយតបនឹងហានិភ័យ។ ទិន្នផលដែលខូចបានកាត់បន្ថយពី៣០-៤០%នៅក្នុងដំណាក់កាលដំបូងនេះ។ ដំណាក់កាលទីពីរនៃគម្រោងបានផ្តោតលើការផ្តល់ភាពអង់អាចដល់ស្ត្រីក្នុងការទទួលបានទីផ្សារលក់ផលិតផល។ នៅឆ្នាំនោះ ទិន្នផលដែលខូចពីភាពគ្រាំដាក់ ទឹកជំនន់ រាំងស្ងួត និងការធ្លាក់ព្រិលបានកាត់បន្ថយពី ៨០-៩០%។

ទាំងនេះ បានកាត់បន្ថយនូវភាពងាយរងគ្រោះពីស្ថានភាពអាក្រក់ផ្នែកអាកាសធាតុ ជាពិសេសការធ្លាក់ព្រិល ភ្លៀងលាយដុំព្រិល និងជាពិសេសកំដៅ និងភាពរាំងស្ងួត ដែលត្រូវបានគេទាយថាមកពីការប្រែប្រួលអាកាសធាតុ។

មានការសន្និដ្ឋានថា ទាំងនេះធ្វើឱ្យមានស្ថិរភាពទីផ្សារនៃដំណាំក្នុងសហគមន៍។ ជនជាតិយ៉ាពូធីរី បានបង្កើននូវភាពជោគជ័យរបស់ខ្លួននៅក្នុងសហគមន៍ ក្នុងការប្រយុទ្ធនឹងភាពមិនទៀងទាត់នៃអាកាសធាតុ ដែលជាភស្តុតាងបញ្ជាក់ពីការកើនឡើងរបស់សហគមន៍ក្នុងការកសាងភាពធន់ទ្រាំ។ ការបញ្ចូលស្ត្រីដែលមានជំនាញនៅក្នុងប្រព័ន្ធរបស់ជនជាតិយ៉ាពូធីរី មានសារៈសំខាន់សម្រាប់ការផ្ទេរនូវបច្ចេកទេសកសិកម្ម ដើម្បីឱ្យមានភាពជោគជ័យនិងធ្វើឱ្យមានស្ថិរភាពនៃជីវភាពរស់នៅតាមរយៈជំនាញតាមទម្លាប់របស់ស្ត្រី និងតួនាទីក្នុងការថែរក្សាពូជ និងការទទួលបានទីផ្សារ។

បទពិសោធន៍បានពង្រីកទៅសហគមន៍ជនបទ អាយម៉ារ៉ា ដែលស្ថិតនៅជុំវិញបឹង ទីទីកូកូ។ នៅក្នុងខេត្តឡូសអេនដេស អ៊ីហ្គាវី អូមាស៊ូយូស មានសហគមន៍ ភីលាភី ឆូកូកូផា និងកូរ៉ូមាតា។ នៅក្នុងសហគមន៍ទាំងនេះ ឆូកូកូផាជំនាញក្នុងការផលិតពូជដំឡូង ព្រមទាំងផ្គត់ផ្គង់ទៅសហគមន៍ផ្សេងទៀតដែលបានទទួលនូវចំណែកទីផ្សារជាមួយភោជនីយដ្ឋានបូលីវៀន។

**បទពិសោធន៍ទទួលបាន៖**

- ការគ្រប់គ្រងហានិភ័យកសិកម្មគឺជាការងារសម្រាប់ស្ត្រី និងបុរសនៅតំបន់ជនបទ។ នៅបរិស្ថានរស់នៅដែលមានស្ថានភាពអាក្រក់ដូចជាតំបន់ បូលីវៀន អាទីផ្លាណូ ដំណោះស្រាយរបស់ពួកគេត្រូវតែជាក់លាក់ ដែលស្ថិតនៅក្រោមលក្ខខណ្ឌការងារគ្រប់គ្រងហានិភ័យ វាមិនមែនសាមញ្ញដូចប្រព័ន្ធផលិតកម្ម ឬក៏ការគ្រប់គ្រងគ្រោះធម្មជាតិនោះឡើយ។
- ការផ្តល់ភាពអង់អាចដល់ស្ត្រីអាចសម្រេចបានតែមួយគត់លុះត្រាណា ស្ត្រីត្រូវបានគេទទួលស្គាល់ជាអ្នកគ្រប់គ្រងមានចំណេះដឹង នៅក្នុងទិដ្ឋភាពខ្លះនៃដំណើរការផលិតកម្មកសិកម្ម និងជាអ្នកមានវចំណេះដឹងតែម្នាក់គត់។
- ការគ្រប់គ្រងចំណេះដឹងតាមខ្សែបណ្តោយគឺជាឧបករណ៍សម្រាប់ការគ្រប់គ្រងហានិភ័យ និងការពារគ្រោះមហន្តរាយ។ នៅពេលដែលការសិក្សាស្រាវជ្រាវ និងរបៀបវារៈនៃការគ្រប់គ្រងត្រូវបានកំណត់ដោយសហគមន៍ក្នុងតំបន់ (ដោយមានស្ត្រី និងបុរសជាអ្នកចូលរួម) អ្នកវិទ្យាសាស្ត្រ និងអង្គការអភិវឌ្ឍ អាចមានលទ្ធភាពបន្ថែមកិច្ចខិតខំប្រឹងប្រែងលើផែនការអភិវឌ្ឍ និងការគាំទ្រយ៉ាងពេញទំហឹងដោយប្រជាជន។
- ការគ្រប់គ្រងហានិភ័យកសិកម្មជាវិធីសាស្ត្រដ៏សាមញ្ញ ពីព្រោះបានផ្អែកលើសមត្ថភាពរបស់កសិករ និងការអនុវត្តរបស់ពួកគេផ្ទាល់។ ការច្នៃប្រឌិតនៅក្នុងសហគមន៍អាចត្រូវបានគេអភិវឌ្ឍបន្ថែម និងពង្រីកតាមរយៈការប្រើវិធីសាស្ត្រចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេច និងកិច្ចសហការក្នុងការផ្តល់ព័ត៌មានជាមុន នៅក្នុងការសិក្សាស្រាវជ្រាវ (ធម្មតាកសិករមានព័ត៌មានជាច្រើនទុកជាមុន)។ បច្ចុប្បន្ននេះ សេវាកម្មនៃព្យាករណ៍អាកាសធាតុផ្នែកកសិកម្មពិភពលោកកំពុងត្រូវបានគេអនុវត្ត។

*ប្រភព៖ ISDR (2008) Gender perspectives: Integrating Disaster Risk Reduction into Climate Change Adaptation. Good Practices and Lessons Learned. Switzerland: UN/ISD*

## ករណីសិក្សាទី៣
## ការរំលេចនូវយុទ្ធសាស្ត្រតម្រូវទៅនឹងគ្រោះរាំងស្ងួត ឧបករណ៍ត្រីស្តាលៈ ឧបករណ៍នៃការជ្រើសរើសហានិភ័យដោយផ្អែកលើសហគមន៍ ជីវភាពរស់នៅ និងការបន្សាំ

ឧបករណ៍នៃការជ្រើសរើសហានិភ័យ ដោយផ្អែកលើសហគមន៍ ជីវភាពរស់នៅ និងការបន្សាំ (CRiSTAL) គឺជាឧបករណ៍ក្នុងការគាំទ្រការធ្វើសេចក្តីសម្រេច។ ការគូរវាសអំពីការវាយតម្លៃគំរូនៃផលប៉ះពាល់បរិស្ថាន និងក្របខ័ណ្ឌនៃការធ្វើឱ្យមានស្ថិរភាពនៃការរស់នៅ។ CRiSTAL មានគោលបំណងជាក់លាក់ ងាយស្រួលដល់អ្នកប្រើប្រាស់ និងងាយយល់ដឹងពីទំនាក់ទំនងរវាងហានិភ័យ ពាក់ព័ន្ធនឹងអាកាសធាតុ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសកម្មគម្រោង។

នៅកំឡុងឆ្នាំ២០០៤ ដល់២០០៦ ក្រុមអន្តរសកម្មភាពបានធ្វើការសាកល្បង នៅកសិដ្ឋាននៃគម្រោងគ្រប់គ្រងធនធានធម្មជាតិនៅប្រទេស បង់ក្លាដេស ម៉ាលី នីការ៉ាហ្គូតង់ហ្សានៀ និងស្រីលង្កា។

នៅក្នុងតំបន់ម៉ាលីន សាហែល CRiSTAL បានបង្ហាញលទ្ធផលថា សហគមន៍នៅជនបទបានអភិវឌ្ឍយុទ្ធសាស្ត្រប្រយុទ្ធនឹងព្រឹត្តការណ៍អាកាសធាតុអាក្រក់ ដូចជាភាពរាំងស្ងួត។ ការនេះត្រូវបានគេកំណត់ថា ការកើនឡើងនូវគ្រោះមហន្តរាយនៃភ្លៀងធ្លាក់ខ្លាំង ដែលត្រូវនឹងការទស្សន៍ទាយនៃការប្រែប្រួលអាកាសធាតុនោះ មិនមានយុទ្ធសាស្ត្រតម្រូវទៅតាមប្រពៃណីត្រូវបានបង្កើតទេ។CRiSTAL ត្រូវបានគេអភិវឌ្ឍដោយមានកិច្ចសហការជាច្រើន (មូលនិធិស្វីសសម្រាប់ការអភិវឌ្ឍអន្តរជាតិនិងសហប្រតិបត្តិការ) ដូចជា វិទ្យាស្ថានអន្តរជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយ ស្ថិរភាព សហភាពអន្តរជាតិសម្រាប់ថែរក្សាធម្មជាតិ និងវិទ្យាស្ថានបរិស្ថានស្តុកខុមន៍ (Stockholm Environment Institute) ដោយមានការផ្តល់មូលនិធិពីទីភ្នាក់ងារស្វីសសម្រាប់ប្រតិបត្តិការអភិវឌ្ឍ (Swiss Foundation for International Development and Cooperation. (SDC))។

វិធីសាស្ត្រ CRiSTAL ផ្តល់នូវការវិភាគភាពងាយរងគ្រោះផ្អែកលើយេនឌ័រយ៉ាងជាក់លាក់សម្រាប់ប្រជាជនផ្អែកផ្សេងៗគ្នា ដោយរំលេចនូវគោលសំខាន់ៗនៃយុទ្ធសាស្ត្រឆ្លើយតបជាក់លាក់សម្រាប់ស្ត្រី និងបង្ហាញចំនុចនីមួយៗសម្រាប់វាស់វែងយេនឌ័រជាក់លាក់ដែលត្រូវចាំបាច់ត្រូវបញ្ចូលទៅក្នុងគម្រោង។

**គំនិតនៃការផ្តួចផ្តើម**

ការវិភាគនៃ CRiSTAL នៅក្នុងប្រទេសម៉ាលី គម្រោងនៃការធ្វើផែនការ និងការគ្រប់គ្រងគឺជាផ្នែកមួយនៃវិធីសាស្ត្រដោយមានកិច្ចសហការរួម ដើម្បីពង្រឹងសមត្ថភាព សហគមន៍ចំពោះការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ។ ឧបករណ៍នេះបានបង្កើតចម្លើយអំពីហានិភ័យនៃអាកាសធាតុបច្ចុប្បន្ន ផលប៉ះពាល់នៅកម្រិតសហគមន៍ និងយុទ្ធសាស្ត្រឆ្លើយតបរបស់សហគមន៍។ ដោយរ៉ាយរ៉ាប់នូវកម្រិតមុខសញ្ញាគ្រោះថ្នាក់ខុសគ្នានៅក្នុងតំបន់ និងផលប៉ះពាល់ដល់ជីវភាពរស់នៅ ដែលក្នុងនោះអ្នកចូលរួមបានសិក្សាអំពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយ ដែលពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។ វិធីសាស្ត្រនេះ បានផ្តល់នូវកន្លែងក្នុងការវិភាគយេនឌ័រជាក់លាក់នៃភាពងាយរងគ្រោះខុសៗគ្នានៃប្រជាជននៅជនបទ។

ការវិភាគត្រូវបានបង្កើតឡើងជាមួយនឹងកម្មវិធី នៅក្នុងប្រទេសម៉ាលី។ កម្មវិធីនេះត្រូវបានផ្តល់មូលនិធិដោយ SDC និងអនុវត្តដោយមានកិច្ចសហការជាច្រើនដោយមានគោលបំណងជួយការអភិវឌ្ឍឱ្យមានស្ថិរភាព និងធនធានធម្មជាតិនៃជីវចម្រុះនៅក្នុងតំបន់សេគូ និងស៊ីកាស៊ូ និងសកម្មភាពបំពេញខ្វះៗនៃការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសហគមន៍ ត្រូវបានបដិភាគដោយសេវាកម្មអភិវឌ្ឍឡិចថេនស្វេន និង Canton of Vaud។

**លក្ខខណ្ឌក្នុងការជ្រើសរើសតំបន់មានដូចជាៈ**

- សេដ្ឋកិច្ចគ្រួសារដែលគាំទ្រដោយប្រាក់ចំណូលរបស់ស្ត្រីតាមរយៈការប្រើប្រាស់ អនុផលដែលមិនមែនជាឈើ។
- ជម្លោះក្នុងសង្គមក្នុងការទទួលបាន និងការប្រើប្រាស់នៃធនធានធម្មជាតិក្នុងចំណោម បុព្វជិត កសិករ និងអ្នកយាមល្បាតព្រៃ។
- ការសឹករិចរិលនៃដី និងការក្លាយជាវាលខ្សាច់ដោយមាន

ការដាក់សម្ពាធលើដីដែលមានជីជាតិ។ នៅក្នុងប្រទេសម៉ាលី ការវិភាគត្រូវបានគេធ្វើឡើងនៅរវាងខែតុលា និងធ្នូ ឆ្នាំ២០០៧ ដែលជាសកម្មភាពសាកល្បងនៅក្នុងតំបន់ជាមួយនឹងសកម្មភាពនាអនាគត ដែលត្រូវបានគេគ្រោងទុក។

CRiSTAL ត្រូវបានគេអនុវត្ត៣ដងនៅក្នុងតំបន់ សេគូសាន និងភាគខាងកើតនៃប្រទេសម៉ាលី ដូចជាតំបន់ស៊ីកាស៊ូ។

ឧបករណ៍ត្រូវបានគេអនុវត្ត ដូចនេះអ្នកធ្វើគម្រោងអាចយល់ដឹងពីភាពងាយរងគ្រោះ ដល់ជីវភាពរស់នៅរបស់សហគមន៍ទៅនឹងមុខសញ្ញាគ្រោះថ្នាក់ពីអាកាសធាតុ ជាពិសេសឧតុនិយមអំពីភ្លៀង។ ទាំងនេះនាំមកនូវភាពងាយស្រួលដល់អ្នកធ្វើយុទ្ធសាស្ត្រក្នុងការប្រើប្រាស់ដើម្បីប្រយុទ្ធនឹងភាពតប់ប្រមល់។ ជាពិសេសទៅទៀត ត្រូវបានគេប្រើប្រាស់សម្រាប់ឱ្យប្រជាពលរដ្ឋក្នុងសហគមន៍មានការយល់ដឹងកាន់តែខ្លាំងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ជាពិសេស ថាតើវាមានផលប៉ះពាល់កម្រិតណាដល់សកម្មភាពរស់នៅប្រចាំថ្ងៃ និងផលិតកម្មកសិកម្ម។

CRiSTAL បានផ្តល់នូវកន្លែងសម្រាប់អ្នកពាក់ព័ន្ធនៅសហគមន៍បានដឹង។ បន្ថែមពីនេះ បានធ្វើនូវភាពសាមញ្ញប៉ុន្តែជាប្រព័ន្ធអាកាសធាតុ និងការវិភាគនៃជីវភាពរស់នៅដូច្នេះ អ្នកចូលរួមអាចទទួលបានគំនិតជាក់លាក់ពីស្ថានភាពនៃការប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន និងភាពគំរាមកំហែងចំពោះជីវភាពរស់នៅប្រចាំថ្ងៃ។ ហេតុដូច្នេះ ហើយ ការវិភាគអាចឱ្យអ្នកពាក់ព័ន្ធនៅកម្រិតជាតិ តំបន់ និងកម្រិតសហគមន៍យល់ដឹងពីបញ្ហានៃការប្រែប្រួលអាកាសធាតុ។

ស្ត្រីមិនបានធ្វើសិក្ខាសាលាផ្ទាល់ខ្លួន ក្នុងអំឡុងពេលដំណើរការ CRiSTAL ប៉ុន្តែមានការយកចិត្តទុកដាក់ឱ្យមានការចូលរួមពីស្ត្រី និងមន្ត្រីកម្មវិធីជាស្ត្រីដែលទទួលបន្ទុកការងារតំបន់ត្រូវបានពង្រឹងសមត្ថភាព ដើម្បីឆ្លើយតបនឹងបញ្ហារសើបផ្សេងៗ។

CRiSTAL វិភាគដោយលើកយកមកគោលសំខាន់ៗនៃសកម្មភាពរស់នៅប្រចាំថ្ងៃជាមួយនឹងស្ត្រី មានតួនាទីសំខាន់ជាក់លាក់នៅក្នុងសកម្មភាពកសិកម្ម ដូចជាដាំស្ល ការប្រមូលអុសស្ងួត និងរុក្ខជាតិគ្រាប់ជាតិខ្លាញ់ (Shea nuts) និងការចម្រាញ់យកប្រេងពីប័រ ( Shea Butter)។ ទោះបីជាយ៉ាងណាក៏ដោយ ការគ្រប់គ្រងដីកសិកម្មក៏ដូចជាសកម្មភាពផ្សេងៗពាក់ព័ន្ធនឹងកសិរុក្ខកម្ម ត្រូវបានគ្រប់គ្រងដោយអ្នកដឹកនាំជាបុរស។ ទោះបីជាយ៉ាងណា តាមទស្សនៈផ្លូវច្បាប់ គ្រប់គ្រងធនធានធម្មជាតិទាំងអស់ជាកម្មសិទ្ធិរបស់រដ្ឋ តាមទស្សនៈប្រពៃណីរបស់សហគមន៍ ម្ចាស់កម្មសិទ្ធិត្រូវបានកំណត់យ៉ាងជាក់លាក់នៅក្នុងសហគមន៍ និងត្រូវបានគ្រប់គ្រងដោយបុរស។ ស្ត្រីនៅក្នុងសហគមន៍មិនមានកម្ម សិទ្ធិដីធ្លី និងមានសិទ្ធិតិចតួច ពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ ទោះបីជាពួកគេធ្វើការនៅកសិដ្ឋាន ឬស្រែ។ អំណាចរបស់បុរសក្នុងការគ្រប់គ្រងកម្មសិទ្ធិដីធ្លី ចំពោះធនធានធម្មជាតិមានន័យថា មានអ្នកក្រីក្របំផុតហើយនៅក្នុងក្រុមនោះ ជាពិសេសគឺស្ត្រីតែម្តង ដែលត្រូវបានគេដកចេញពីកម្មសិទ្ធិដី និងធនធានធម្មជាតិធ្វើឱ្យពួកគេក្លាយជាអ្នករងគ្រោះជាងគេ។

សហគមន៍តែងតែតស៊ូនឹងតំបន់ដែលមានស្ថានភាពពាក់កណ្តាលរាំងស្ងួត។ មុខសញ្ញាគ្រោះថ្នាក់អាកាសធាតុមានដូចជាការរាំងស្ងួត កង្វះខាតភ្លៀងធ្លាក់នៅរដូវភ្លៀង និងភ្លៀងធ្លាក់មិនទៀងទាត់ដែលជាផ្នែកមួយនៃជីវភាពប្រចាំថ្ងៃ។ បើយោងទៅតាមអ្នកចូលរួម ដោយសារតែមានគ្រោះរាំងស្ងួតខ្លាំងនៅទសវត្សរ៍ឆ្នាំ១៩៧០ រដ្ឋាភិបាលម៉ាលីបានចាត់ទុកថា ព្រឹត្តការណ៍នេះមិនគួរត្រូវបានគេចាត់បញ្ចូលក្នុងការគំរាមកំហែងផ្នែកខាងក្រៅទេ តែគួរចាត់បញ្ចូលទៅក្នុងជីវភាពប្រចាំថ្ងៃ និងយុទ្ធសាស្ត្រផលិតកម្ម។

CRiSTAL អាចលើកយកចំណុចគោលសំខាន់ៗនៃយុទ្ធសាស្ត្ររបស់ស្ត្រីប្រយុទ្ធនឹងការប្រែប្រួលអាកាសធាតុ៖

- ដោយសារតែអសន្តិសុខស្បៀងនៅក្នុងតំបន់ ជាទូទៅបណ្តាលមកពីភាពរាំងស្ងួត ស្ត្រីនៅក្នុងប្រទេសម៉ាលីតែងរក្សានូវដំណាំដែលប្រមូលផលបានដាច់ដោយឡែក ពីការទុកសម្រាប់គ្រួសារ។ ទោះបីជាយ៉ាងណាក៏ដោយស្ត្រីភាគច្រើនមិនមានកម្មសិទ្ធិ ដីធ្លីឬដើមឈើ ផលិតផលជាក់លាក់ត្រូវបានប្រមូលផលដោយស្ត្រី។ ឧទាហរណ៍ ការប្រមូលរុក្ខជាតិគ្រាប់ជាតិខ្លាញ់ ក៏ដូចជាការចម្រាញ់យកប្រេងពីរុក្ខជាតិប័រ ជាសកម្មភាពធ្វើដោយស្ត្រី។ ផលិតផលទាំងនេះត្រូវបានគេប្រើប្រាស់ក្នុងពេលខុសៗគ្នា នៅពេលដែលការប្រមូលផលត្រូវបានគេធ្វើតាម

លក្ខណៈគ្រួសារ គឺមិនមានប្រសិទ្ធភាពឡើយ។

- ការលក់អុស មាន់ និងពពែ គឺជាយុទ្ធសាស្ត្រដែលស្ត្រីប្រើប្រាស់ក្នុងការឆ្លើយតបនឹងស្ថានភាពលំបាក។
- ទោះបីជាករណីលើកលែងក៏ដោយ ក៏ជាញឹកញាប់ស្ត្រីនៅក្នុងតំបន់ទីប្រជុំជនព្យាយាមបង្កើតជាសមាគមន៍ ដើម្បីទទួលបានភាពជាម្ចាស់កម្មសិទ្ធិលើដីធ្លី ដោយការជួល ឬទិញ។ ស្ត្រីក៏បានទិញដីពីប្ដីរបស់ខ្លួនសម្រាប់ធ្វើកសិកម្ម និងព្យាយាមទទួលប្រាក់កម្ចី ជាលក្ខណៈខ្នាតមីក្រូពីធនាគារ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ។
- កិច្ចសហការ និងការអនុវត្តនៃសន្និបាតក្នុងសហគមន៍អាចជួយសម្របសម្រួលដល់សិទ្ធិ និងការទទួលបាននូវធនធានធម្មជាតិ ដូច្នេះពួកគេអាចគ្រប់គ្រងលើដីធ្លី។

ទោះបីជាយ៉ាងណាក៏ដោយ CRiSTAL ចូលរួមនូវដំណើរការកត់ត្រានៃមុខសញ្ញាគ្រោះថ្នាក់រយៈពេល៣០ឆ្នាំ៖ ក) ការកើនឡើងភាពញឹកញាប់ និងការកើនឡើងនៃកម្រិតមុខសញ្ញាគ្រោះថ្នាក់ ខ)ភស្តុតាងថ្មីដូចជា ខ្យល់ខ្លាំងពីតំបន់សាហារ៉ា និងភ្លៀងធ្លាក់កាន់តែខ្លាំងដែលបណ្ដាលឱ្យមានទឹកជំនន់។ នៅខែកញ្ញា ឆ្នាំ២០០៧ មានទឹកជំនន់ជាច្រើនកន្លែងនៅក្នុងប្រទេសម៉ាលី បានបង្ហាញភាពងាយរងគ្រោះនៅក្នុងសហគមន៍ដែលជាបាតុភូតថ្មី គ្មានយុទ្ធសាស្ត្រប្រយុទ្ធតាមទម្លាប់អាចឆ្លើយតបនឹងភ្លៀងធ្លាក់ខ្លាំង និងទឹកជំនន់ ។ ក្រៅពីការប្រែប្រួលនៃដីធ្លី មានការខូចខាតដំណាំផ្សេងៗជាច្រើនដែលប៉ះពាល់ដល់ការប្រមូលផលប្រចាំឆ្នាំ។

បទពិសោធន៍ទទួលបាន៖

- កិច្ចសហការគ្នាយ៉ាងល្អរវាងស្ត្រី និងបុរស ជាតម្រូវការឆ្លើយតបនឹងហានិភ័យអាកាសធាតុ។ ការចែករំលែកនៃហានិភ័យផលិតកម្មរវាងសមាជិកទាំងអស់នៅក្នុងគ្រួសារជាយុទ្ធសាស្ត្រមួយឆ្លើយទៅនឹងអសន្តិសុខអាកាសធាតុ។
- ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ កាន់តែមានការលំបាកឡើងសម្រាប់ស្ត្រីនៅក្នុងវិស័យកសិកម្ម ដោយសារតែកង្វះខាតនៃដីមានជីជាតិ។ ដូច្នេះ គួរតែមានការគាំទ្រដល់ស្ត្រី ដើម្បីឱ្យពួកគេអាចទទួលបានធនធានធម្មជាតិ ព្រមទាំងទទួលបានការធ្វើការសម្រេចចិត្តក្នុងការគ្រប់គ្រងដើមឈើ ដូចជាប្រភេទដើមឈើដែលមានអត្ថប្រយោជន៍ច្រើន។
- វិសមភាពយេនឌ័រ មានផលប៉ះពាល់អវិជ្ជមានដល់ការគ្រប់គ្រងដីធ្លី និងកសិរុក្ខកម្ម។ វាមាន សារៈសំខាន់ណាស់ក្នុងការបញ្ជាក់នូវកម្មសិទ្ធិដីធ្លី និងសិទ្ធិជាម្ចាស់កម្មសិទ្ធិនៅក្នុងសហគមន៍ និងទូទាំងប្រទេស។
- សហគមន៍ក្នុងតំបន់យុទ្ធសាស្ត្រ ឆ្លើយតបខ្លះ ទោះបីជាមិនមានការបញ្ជាក់នូវភស្តុតាងបែបវិទ្យាសាស្ត្រក៏ដោយ។ ការគាំទ្របន្ថែមពីរដ្ឋាភិបាល និងសង្គមស៊ីវិល គឺជាការចាំបាច់សម្រាប់ការងារសហគមន៍។
- លទ្ធផលនៃទឹកជំនន់ថ្មីៗ ត្រូវបានគេបង្ហាញសហគមន៍ជនបទមានភាពងាយរងគ្រោះទៅនឹងមុខសញ្ញាគ្រោះថ្នាក់ថ្មីៗ។ ហេតុនេះ គួរតែមានការយកចិត្តទុកដាក់ចំពោះការកាត់បន្ថយនូវគ្រោះមហន្តរាយទាំងថ្នាក់ជាតិ តំបន់ និងសហគមន៍។
- នៅក្នុងប្រទេសម៉ាលី មានក្រសួងពីរទទួលខុសត្រូវការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយ។ កិច្ចសហការរវាងក្រសួង និងក្រសួង និងផ្លាស់ប្ដូរបទពិសោធន៍គ្នាគឺមានសារៈសំខាន់សម្រាប់ធានានូវកិច្ចសហការ និងជៀសវាងការជាន់ការងារគ្នា។ ទោះបីមានការវិភាគយេនឌ័រជាក់លាក់សម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ មានសារៈសំខាន់ក៏ដោយ ក៏សកម្មភាពនៃកម្មវិធីបន្សាំថ្នាក់ជាតិ (NAPA) និងទំនាក់ទំនងថ្នាក់ជាតិ មិនបានបញ្ចូលស្ថានភាពយេនឌ័រទៅក្នុងការវិភាគរបស់ពួកគេទេ។ ការជំរុញឱ្យមានទំនាក់ទំនងរបស់ប្រជាជន ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយនៅថ្នាក់ជាតិគឺជាការចាំបាច់។

ការវិភាគនៅក្នុងប្រទេសម៉ាលី គឺជាផ្នែកនៃវិធីសាស្ត្រនៃកិច្ចសហការគ្នា ព្រមទាំងមានគម្រោងជាច្រើនកំពុងតែប្រើប្រាស់ឧបករណ៍ CRiSTAL សម្រាប់ការយល់ដឹងពីភាពងាយរងគ្រោះនិងត្រួតពិនិត្យមើលយុទ្ធសាស្ត្រឆ្លើយតប និងក៏ត្រូវបានគេប្រើប្រាស់សម្រាប់កែតម្រូវកម្មវិធី និងគម្រោងក្នុងគោលបំណងបង្កើនភាពធន់ទ្រាំ ផ្នែកការរស់នៅព្រមទាំងត្រូវគេស្នើឱ្យបញ្ចូលការវិភាគក្នុងគម្រោង និងកម្មវិធីថ្នាក់ជាតិ។

*ប្រភព៖ ISDR (2008) Gender perspectives: Integrating Disaster Risk Reduction into Climate Change Adaptation. Good Practices and Lessons Learned. Switzerland: UN/ISD*

# តើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមានភាពខុសប្លែកគ្នាឬទេ ?



**គោលបំណង ៖** យល់ដឹងពីភាពខុសប្លែកគ្នានៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើក្រុមមនុស្សផ្សេងៗគ្នា និងតំបន់ផ្សេងគ្នា។

**សម្ភារៈ ៖** **ឯកសារទី១៖** ភាពផ្ទាល់ និងមិនផ្ទាល់នៃហានិភ័យអាកាសធាតុ និងផលប៉ះពាល់មកលើស្ត្រី

**ឯកសារទី២៖** រៀបចំក្រដាសផ្ទាំងធំ និងប៊ិចសម្រាប់ធ្វើទំនាក់ទំនងនៃគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ការប្រែប្រួលអាកាសធាតុ និងយេនឌ័រ។

**ដំណើរការ ៖**

១) បែងចែកអ្នកចូលរួមជា២ក្រុម

២) ផ្តល់ឯកសារទី១ ទៅក្រុម១ និងឯកសារទី២ ទៅក្រុម២

៣) តែងតាំងមេដឹកនាំនៃក្រុមនីមួយៗ

៤) ស្នើមេដឹកនាំក្រុមអានឱ្យឮនូវឃ្លាប្រយោគនៅក្នុងឯកសារ

៥) ស្នើក្រុមឱ្យពិភាក្សាលើព័ត៌មានដែលផ្តល់ឱ្យ។ សំនួរខាងក្រោមនេះអាចជួយដល់លោកអ្នកបាន៖

- តើប្រជាពលរដ្ឋមានស្ថានភាពប្រហាក់ប្រហែលគ្នាក្នុងការឆ្លើយតប និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ?
- តើពួកគេមានជំនាញ និងសមត្ថភាពដូចគ្នាក្នុងការដោះស្រាយបញ្ហានេះទេ?
- តើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុប៉ះពាល់ដូចគ្នាលើប្រជាពលរដ្ឋឬទេ?

៦) ស្នើឱ្យក្រុមនីមួយៗធ្វើបទបង្ហាញពីលទ្ធផលនៃការពិភាក្សា។ ប្រសិនបើអាចធ្វើបានផ្តល់នូវព័ត៌មានបន្ថែមអំពីការបង្ហាញ និងដំណោះស្រាយ។

៧) ជាចុងក្រោយ សួរអ្នកចូលរួមនូវសំនួរ តើពួកគេរៀនអ្វីខ្លះពីលំហាត់នេះ?

**ឯកសារទី១៖** ភាពផ្ទាល់ និងមិនផ្ទាល់នៃហានិភ័យអាកាសធាតុ និងផលប៉ះពាល់មកលើស្ត្រី

| មុខសញ្ញាគ្រោះថ្នាក់ | ឧទាហរណ៍ | ផលប៉ះពាល់ចំពោះស្ត្រី |
|---|---|---|
| **ផលប៉ះពាល់ដោយផ្ទាល់** | | |
| ការកើនឡើងនូវសីតុណ្ហភាពទឹកសមុទ្រ | ការកើនឡើងនូវគ្រោះថ្នាក់ដល់សត្វល្អិតតូចៗក្នុងសមុទ្រដោយសារតែការឡើងកំដៅ | ការបាត់បង់នូវផ្កាថ្ម អាចប៉ះពាល់ដល់ឧស្សាហកម្ម ទេសចរណ៍ ដែលជាវិស័យមួយមានស្ត្រីចំនួន ៤៦% នៃកម្លាំងពលកម្ម។ |
| កង្វះខាតទឹក និងការកើនឡើងនូវភាពរាំងស្ងួត | • ប្រទេសម៉ូរ៉ុកកូ មានបទពិសោធន៍ភាពរាំងស្ងួតចំនួន១០ឆ្នាំ (១៩៨៤-២០០០)<br>• ភាគខាងជើងប្រទេសខេនយ៉ា មានភាពរាំងស្ងួត ចំនួន៤ដង (១៩៨៣-២០០១) | ស្ត្រី និងក្មេងស្រីនៅក្នុងប្រទេសកំពុងអភិវឌ្ឍទទួលខុសត្រូវចម្បងក្នុងការប្រមូល ប្រើប្រាស់ និងចាត់ចែងទឹក។ ការថយចុះនូវបរិមាណទឹកនឹងធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ និងបង្កើននូវការងារបន្ថែមសម្រាប់ពួកគេ ព្រមទាំងប៉ះពាល់ដល់ការសិក្សារបស់ពួកគេ ឬប៉ះពាល់ដល់ឱកាសការរកប្រាក់ចំណូលរបស់ស្ត្រី។ |
| ការកើនឡើងនូវបាតុភូតអាកាសធាតុ | ការកើតឡើងញឹកញាប់នូវព្យុះ (ស៊ីក្លូន ហារីខេន) ទឹកជំនន់ និងកំដៅ | តាមទិន្នន័យពីប្រទេស ១៤១ ក្នុងរយៈពេលពី ១៩៨១-២០០២ បានបង្ហាញថា គ្រោះធម្មជាតិគិតជាមធ្យម សម្លាប់ស្ត្រីច្រើនជាងបុរស ឬសម្លាប់ស្ត្រីនៅអាយុតិចជាងបុរស។ |
| **ផលប៉ះពាល់ដោយប្រយោល** | | |
| ការកើនឡើនូវជំងឺឆ្លង | ការប្រែប្រួលអាកាសធាតុបានដើរតួយ៉ាងសំខាន់នៃការចម្លងជំងឺគ្រុនចាញ់នៅតំបន់ភ្នំអាហ្វ្រិកខាងកើត និងបង់ក្លាដេស មានការចម្លងជំងឺអាសន្នរោគចំនួន៧០% នៃជំងឺឆ្លងសរុប | • ស្ត្រីទទួលបាននូវសេវាសុខភាពមានកំណត់បើប្រៀបធៀបនឹងបុរស ហើយការងាររបស់ពួកគេកាន់តែច្រើននៅពេលគេចំណាយពេលក្នុងការថែទាំអ្នកជំងឺ។<br>• គ្រួសារក្រីក្រដែលឆ្លងមេរោគហ៊ីវ/ជំងឺអេដស៍ កាន់តែមានធនធានតិចតួចក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ការទទួលនូវវិធីសាស្ត្រថ្មីសម្រាប់ ផលិតកម្ម ដាំណាំ ឬការចិញ្ចឹមសត្វ កាន់តែមានការលំបាក សម្រាប់ស្ត្រីជាមេគ្រួសារ និងគ្រួសារដែលមានអ្នកឆ្លងជំងឺ។ |
| ការបាត់បង់នូវប្រភេទសត្វ | នៅឆ្នាំ ២០៥០ ការប្រែប្រួលអាកាសធាតុនឹងធ្វើឱ្យមានការផុតពូជនូវប្រភេទសត្វពី ១៨-៣៥% | ស្ត្រីជារឿយពឹងផ្អែកលើការដាំដំណាំផ្សេងៗ ដើម្បីឆ្លើយតបនឹងការផ្លាស់ប្តូរអាកាសធាតុ ប៉ុន្តែការផ្លាស់ប្តូរសីតុណ្ហភាពជានិរន្តរ៍នឹងកាត់បន្ថយនូវជីវចម្រុះកសិកម្ម និងថ្នាំបូរាណដែលធ្វើឱ្យប៉ះពាល់ខ្លាំងដល់សន្តិសុខ ស្បៀង និងសុខុមាលភាព។ |
| ការថយចុះនូវផលិតកម្មដំណាំ | នៅទ្វីបអាហ្វ្រិកផលិតកម្មដំណាំត្រូវបានគេរំពឹងទុកនឹងថយចុះពី ២០-៥០% ដោយសារស្ថានភាពអាកាសធាតុ | ជាពិសេស ស្ត្រីជនបទដែលទទួលខុសត្រូវពាក់កណ្តាលនៃផលិតកម្មស្បៀងពិភពលោក ហើយផលិតស្បៀងពី ៦០-៨០% នៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ នៅទ្វីបអាហ្វ្រិក ផលប៉ះពាល់នៃអាកាសធាតុធ្វើឱ្យដំណាំខូចខាត ៤៨% នៅប្រទេសបូគីណា និង ៧៣% នៅប្រទេសកុងហ្គោ។ |

**ឯកសារទី២៖** ទំនាក់ទំនងរវាងគោលដៅអភិវឌ្ឍសហស្សវត្សរ៍ការប្រែប្រួលអាកាសធាតុ និងយេនឌ័រ

| គោលដៅសហស្សវត្សរ៍ (MDGs) | ការគំរាមកំហែងដោយការប្រែប្រួលអាកាសធាតុ | ការពាក់ព័ន្ធនឹងយេនឌ័រ |
|---|---|---|
| MDG ១៖ ការកាត់បន្ថយភាពក្រីក្រ និងការអត់ឃ្លាន | • ការកាត់បន្ថយនូវផលិតកម្មកសិកម្មសម្រាប់ការរស់នៅនិងពាណិជ្ជកម្ម<br>• ហានិភ័យចំពោះសន្តិសុខស្បៀង | • ស្ត្រីភាគច្រើននៅក្នុងពិភពលោកស្ថិតនៅក្នុងភាពក្រីក្រដែលមានចំនួន ៧០% នៃ១,៣កោដ្ឋនៃអ្នកក្រីក្រ។<br>• មានការថយចុះ និងបាត់បង់នៃប្រភេទរុក្ខជាតិ និងសត្វ ប្រើប្រាស់ដោយស្ត្រីដែលធានាដល់សន្តិសុខស្បៀងសម្រាប់គ្រួសារ។ ពពកប្រផេះក្នុង បរិយាកាស (ABC) ដែលចេញពីកំប៉ុងស្ព្រាយផ្សេង និងការបញ្ចេញនូវឧស្ម័នផ្ទះកញ្ចក់មានការថយចុះនៅរដូវច្រូតកាត់ (Cramer, 2006)។ អង្ករគឺប្រភពថាមពលចម្បងសម្រាប់ប្រជាជននៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ ស្ត្រីគឺមានបញ្ហាអាហារូបត្ថម្ភ (Ex. 50% នៃស្ត្រីនិងកុមារនៅក្នុងប្រទេសកំពុងអភិវឌ្ឍ គឺមានបញ្ហាកង្វះអាហារូបត្ថម្ភ) ដោយសារតែកត្តាជីវសាស្ត្រសង្គម សេដ្ឋកិច្ចយេនឌ័រ និងបញ្ហាវប្បធម៌ (ការមានផ្ទៃពោះ ការរំលូតកូន ការបែងចែកអាហារមិនស្មើភាព នៅក្នុងគ្រួសារ)<br>• មានការថយចុះនិងផុតពូជនៃប្រភេទសត្វសមុទ្រ ដែលប្រើប្រាស់ដោយស្ត្រីសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារឬសម្រាប់ផលិតកម្មផ្សេងៗ<br>• នៅក្នុងករណីខ្លះ ការដោះដូររវាងការប្រើប្រាស់ និងដើម្បីរស់ ជំរុញឱ្យមានលំអៀងផ្នែកយេនឌ័រនៅក្នុងអាហារូបត្ថម្ភ។ ការសិក្សានៅប្រទេសឥណ្ឌាបានបង្ហាញថា អាហារូបត្ថម្ភរបស់ក្មេងស្រីមានការខ្វះខាតនៅពេលការប្រមូលផលបានតិច និងតម្លៃអាហារឡើងថ្លៃ និងពេលដែលមានភ្លៀងធ្លាក់តិចតួចដែលធ្វើឱ្យមានក្មេងស្រីច្រើនបើប្រៀបធៀបនឹងក្មេងប្រុស (UNDP, 2007) |
| MDG ២៖ ការសម្រេចនូវការអប់រំបឋម | • ការធ្វើការច្រើនហួសសម្រាប់ផលិតកម្មកសិកម្ម និងសកម្មភាពការងារឥតកម្រៃ ការប្រែប្រួលបរិស្ថានទំនងជាជំរុញឱ្យមានទេសន្តរប្រវេសន៍<br>• ការទទួលបានទឹកស្អាតមានតិចតួច | • ជាទូទៅ ស្ត្រី និងក្មេងស្រីជាអ្នកទទួលខុសត្រូវលើការរកអុស និងទឹក។ នៅក្នុងតំបន់ក្រីក្របំផុតនៃពិភពលោក ជាពិសេសនៅអនុតំបន់សាហារ៉ាអាហ្វ្រិក ស្ត្រី និងក្មេងស្រីចំណាយពេលពី៣-៤ ម៉ោងក្នុង១ថ្ងៃ ដើម្បីរកអុសនិងទឹក។ ទឹកជំនន់ រាំងស្ងួត និងតំបន់វាលខ្សាច់កាន់តែធ្វើឱ្យស្ថានភាពនេះលំបាកឡើង ដែលជំរុញឱ្យក្មេងស្រីនៅក្នុងសហគមន៍បោះបង់ការសិក្សា។ ក្នុងចំណោមក្មេង ១១៥ លាននាក់ ដែលមិនបានទៅសាលានៅក្នុងពិភពលោក មាន៣/៥ គឺជាក្មេងស្រី ហើយស្ត្រីមានចំនួន ៧៥% ក្នុងចំណោមអ្នកមិនចេះអក្សរសរុប (Oxfam, 2007)។<br>• បើយោងទៅតាមអង្គការ UNHCR មាន៨០% នៃជនភៀសខ្លួននៅក្នុងពិភពលោកជាស្ត្រី និងកុមារ។ ប្រជាជនដែលធ្វើទេសន្តរប្រវេសន៍បានធ្វើឱ្យមានការប្រែប្រួល និងមហន្តរាយដល់ឱកាសទទួលបាននូវការអប់រំ។<br>• បុរសទំនងជាធ្វើទេសន្តរប្រវេសន៍ទៅតាមរដូវកាល ឬប្រចាំឆ្នាំ។ ស្ត្រីជាមេគ្រួសារដែលនៅចាំផ្ទះ ជារឿយៗក្លាយជាអ្នកក្រីក្រជាងគេ។ មានការងារជាច្រើនសម្រាប់ស្ត្រីទាំងនោះដូចជា មើលថែកូនចៅ និងចាស់ជរា នៅពេលដែលបុរសធ្វើទេសន្តរប្រវេសន៍។ |

| | | |
|---|---|---|
| MDG ៣ ៖ លើកកម្ពស់សមភាពយេនឌ័រនិងផ្តល់ភាពអង់អាចដល់ស្ត្រី | • ការស្លាប់ និងការរងរបួសមានការកើនឡើងខណៈពេលដែលមានវិសមភាព<br>• ស្ថានភាពលំបាកកើតឡើងខណៈពេលដែលមានវិសមភាពយេនឌ័រ<br>• ធ្វើឱ្យមានគោលនយោបាយទីជម្រក និងការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច | • ការសិក្សានៅឆ្នាំ២០០៦ លើប្រទេសចំនួន ១៤១ ដោយសាលាសេដ្ឋកិច្ចនៃទីក្រុងឡុងបង្ហាញថា នៅពេលដែលសេដ្ឋកិច្ចសង្គមត្រូវបានបំពេញសម្រាប់ស្ត្រី និងបុរស ផលប៉ះពាល់ដល់ស្លាប់នៃគ្រោះមហន្តរាយមានចំនួនស្មើគ្នា។ ផ្ទុយមកវិញ នៅពេលដែលស្ត្រីមិនបានទទួលផលពីសេដ្ឋកិច្ចសង្គមដូចបុរសនោះ មានស្ត្រីច្រើនជាងបុរសស្លាប់ដោយសារគ្រោះមហន្តរាយ។ ភាពមិនស្មើគ្នានៃយេនឌ័រនេះ ត្រូវបានបង្ហាញនៅក្នុងគ្រោះមហន្តរាយធំៗដូចជា ហ៊ីរីខេន-មិច ហ៊ីរីខេន កាតទ្រីណា និងព្យុះផ្សេងៗ នៅទ្វីបអាមេរិក ការឡើងកំដៅនៅអឺរ៉ុប និងព្យុះស៊ីក្លូននៅអាស៊ីខាងត្បូង។<br>• ប្រទេសនៅអាមេរិកឡាទីនខ្លះ ដោយសារតែកត្តាសង្គមដែលកំណត់ថាបុរសជាអ្នកដោះស្រាយនៅពេលមានមហន្តរាយកើតឡើង ដូចនេះបុរសទទួលគ្រោះថ្នាក់ខ្លាំងនៅពេលមានគ្រោះមហន្តរាយកើតឡើង ដោយសារតែភាពអង់អាចក្លាហានរបស់ខ្លួន ( Superman Syndrome ) ហេតុនេះបណ្តាលឱ្យមានការស្លាប់ដែលមិនចាំបាច់ដូចជា ហែលឆ្លងទន្លេនៅពេលមានព្យុះ។<br>• ពេលដែលការផ្លាស់ប្តូរបរិស្ថានកើតឡើងភ្លាមៗ វិសមភាពកើតឡើងយ៉ាងរហ័សផងដែរ ជាពិសេសពាក់ព័ន្ធនឹងការប្រើប្រាស់ធនធាន។ ប្រវត្តិសាស្ត្របានបង្ហាញពីគុណវិបត្តិរួមបញ្ចូលទាំងការបែងចែកដីធ្លី ធនធាន ព័ត៌មាន និងការធ្វើសេចក្តីសម្រេច។ ជាលទ្ធផលបង្ហាញថាស្ត្រីមានបន្ទុកយ៉ាងធ្ងន់ធ្ងរបន្ទាប់ពីគ្រោះធម្មជាតិ។<br>• ស្ត្រីនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ភាគច្រើនទទួលខុសត្រូវក្នុងសន្តិសុខស្បៀង ការប្រើប្រាស់ទឹក និងថាមពលសម្រាប់ការចំអិនអាហារ ប្រសិនបើគ្រោះធម្មជាតិកើតឡើង ស្ត្រីនឹងទទួលរងផលប៉ះពាល់យ៉ាងខ្លាំង ជាពិសេសពួកគាត់មិនអាចប្រើប្រាស់ធនធានបានដូចជា ការរកប្រាក់ចំណូល ការទទួលបានការអប់រំ ឬការថែទាំក្រុមគ្រួសាររបស់ពួកគេ។<br>• ស្ត្រីមានការចូលរួមតិចតួច និងខ្វះអ្នកតំណាងរបស់ខ្លួននៅក្នុងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិតដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ ជាលទ្ធផលបង្ហាញថា មិនមានកម្មវិធី និងគោលនយោបាយឆ្លើយតបនឹងតម្រូវការស្ត្រី។ |
| MDG ៤ ៖ កាត់បន្ថយការស្លាប់របស់កុមារ | ផលប៉ះពាល់បរិស្ថានបណ្តាលឱ្យគ្រោះថ្នាក់កាន់តែអាក្រក់ឡើងពិសេសការមានជំងឺ | ការកើនឡើងនូវការងាររបស់ស្ត្រីដោយសារតែតួនាទីរបស់ពួកគេថែទាំនៅក្នុងគ្រួសារ។ ឧទាហរណ៍៖ ការចំណាយពេលលើការថែទាំកូន និងអ្នកជំងឺ។ ការបាត់បង់រុក្ខជាតិដែលប្រើប្រាស់ដោយស្ត្រី។ |
| MDG ៥ ៖ ការធ្វើឱ្យប្រសើរឡើងនូវសុខភាពមាតា | បង្កើននូវប្រេវ៉ាឡង់នៃវិចទ័រនៃប្រភពជំងឺ | • ស្ត្រី និងកុមារ គឺ ១៤ដងច្រើនជាងបុរសស្លាប់ ដោយសារគ្រោះមហន្តរាយ ( Peterson, 2007 )<br>• អត្រាស្លាប់ខ្ពស់របស់ម្តាយ/ស្ត្រី/ប្រពន្ធ ក្នុងពេលគ្រោះមហន្តរាយមានការកើនឡើងដូចជា ចំនួនកុមារកំព្រា និងអត្រាស្លាប់ ការឆាប់រៀបការរបស់ ក្មេងស្រីបណ្តាលឱ្យពួកគេបោះបង់ការសិក្សា ការជួញដូរ និងពេស្យាចារដែលជាកត្តាជំរុញឱ្យមានការកើនឡើងជំងឺអេដស៍ ( Oxfam, 2005 )។ |

| | | |
|---|---|---|
| MGD ៦ ៖ ការបំបាត់នូវជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺឆ្លង | ការកើនឡើងនូវកំដៅ (រលកកំដៅ) | ទេសន្តប្រវេសន៍ធ្វើឱ្យមានហានិភ័យនៃជំងឺអេដស៍ដែលបណ្តាលឱ្យគ្រួសារបែកបាក់ និងជំរុញឱ្យពួកគេរស់នៅតំបន់ដែលមានប្រជាជនច្រើនហួស។ |
| MDG ៧ ៖ ការធានានូវនិរន្តរភាពផ្នែកបរិស្ថាន | • ការផុតពូជនូវប្រភេទសត្វ និងរុក្ខជាតិ<br>• ការប្រែប្រួលផ្នែកបរិមាណ និងគុណភាពនៃធនធានធម្មជាតិអាចបណ្តាលឱ្យមានការកាត់បន្ថយផលិតកម្មប្រព័ន្ធអេកូឡូស៊ី<br>• ទឹកជំនន់គ្រោះរាំងស្ងួត ការឡើងខ្ពស់នូវនីវ៉ូទឹកសមុទ្រនិងការរលាយផ្ទាំងទឹកកកតំបន់ប៉ូល | • ដោយគ្មានការថែរក្សា និងត្រួតពិនិត្យធនធានធម្មជាតិ (ទឹក ដី ដើមឈើ និងការចិញ្ចឹមសត្វ) ស្ត្រីមានបញ្ហាប្រឈមខ្លាំងក្នុងការឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។<br>• ការវាស់វែងនូវការបន្សាំ ដែលពាក់ព័ន្ធនឹងការប្រយុទ្ធនឹងតំបន់វាលខ្សាច់ជារឿយទាក់ទងនឹងកម្លាំងពលកម្ម ហើយស្ត្រីជារឿយៗប្រឈមនឹងការកើនឡើងនូវការមិនរំពឹងទុកដូចជា ការធ្វើការផ្ទះដែលគ្មានប្រាក់កម្រៃ និងការងារសហគមន៍ដែលពាក់ព័ន្ធនឹងការរៀបចំដីធ្លី និងការរកទឹក។<br>• ការថយចុះនូវធនធានព្រៃឈើដែលប្រើប្រាស់ដោយស្ត្រី ជាពិសេសស្ត្រីជនបទក្នុងប្រទេសកំពុងអភិវឌ្ឍដែលពួកគាត់ប្រមូលអនុផលព្រៃឈើ ដូចជាអុសថ្នាំសង្កូវឬចំណីសត្វ។ ការថយចុះ និងការបាត់បង់នូវអនុផលទាំងនេះបណ្តាលឱ្យមានផលប៉ះពាល់ដូចជា សុខុមាលភាពរបស់ពួកគេ និងក្រុមគ្រួសារ។ ស្ត្រីជារឿយៗពឹងផ្អែកលើដំណាំផ្សេងៗ (ជីវចម្រុះ-កសិកម្ម) ដើម្បីប្រឈមមុខនឹងភាពប្រែប្រួលនៃអាកាសធាតុ ក៏ប៉ុន្តែការប្រែប្រួលសីតុណ្ហភាពនឹងកាត់បន្ថយនូវជីវចម្រុះ-កសិកម្ម និងថ្នាំសង្កូវបែបប្រពៃណី។ |
| MDG ៨ ៖ ការអភិវឌ្ឍនូវភាពជាដៃគូសម្រាប់ការអភិវឌ្ឍ | • ការប្រែប្រួលអាកាសធាតុបន្ថែមនូវការលំបាកក្នុងការសម្រេចនូវគោលដៅអភិវឌ្ឍសហស្សវត្សរ៍<br>• បង្កើននូវថវិកាសម្រាប់ការបន្សុំានិងការការពារ | • សហការដោយមានការឆ្លើយតបនឹងយេនឌ័រ នៅក្នុងការផ្ទេរនូវបច្ចេកទេស កម្មវិធី និងគម្រោងនានាដើម្បីបង្កើនសមត្ថភាពសម្រាប់ការបន្សាំ និងទេសន្តប្រវេសន៍។<br>• ជំរុញ សម្របសម្រួល អភិវឌ្ឍដល់កម្មវិធីបណ្តុះបណ្តាល និងអប់រំដោយផ្តោតលើការប្រែប្រួលអាកាសធាតុ និងផ្តោតលើស្ត្រី។<br>• សម្របសម្រួលការទទួលបានជាសាធារណៈនូវទិន្នន័យ និងព័ត៌មានដោយផ្តល់នូវព័ត៌មានអំពីអាកាសធាតុ គោលនយោបាយផ្សេងៗ និងសកម្មភាពមួយចំនួនដែលស្ត្រីត្រូវយល់ដឹង ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដោយផ្តោតលើ៖ គុណភាពនៃការទទួលបានអ៊ីនធឺណេត បញ្ហាអក្ខរកម្ម និងបញ្ហាភាសា។<br>• ជំរុញនូវការចូលរួមរបស់ស្ត្រីក្នុងបម្រែបម្រួលអាកាសធាតុដូចជា ក្នុងកិច្ចពិភាក្សាជាមួយអ្នកសម្របសម្រួលនិងគ្រប់គ្រង។<br>• ការបែងចែកថវិកាត្រូវឆ្លើយតបនឹងយេនឌ័រ ជាពិសេសក្នុងការបន្សាំ និងភាពធន់ទ្រាំ។ |

# ជំពូក ៤

# ការបញ្ជ្រាបយេនឌ័រនៅក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើការបន្សាំ

*យេនឌ័រ និងការប្រែប្រួលអាកាសធាតុអាចជាវដ្តបរិយាកាស (vicious circle) មួយដែលធ្វើឱ្យមានវិសមភាព និងផលប៉ះពាល់កាន់តែធ្ងន់ធ្ងរ។ ការសិក្សាចងក្រងយ៉ាងច្បាស់លាស់មួយបង្ហាញថា ការប្រែប្រួលអាកាសធាតុជះឥទ្ធិពលលើស្ត្រីខ្លាំងជាងបុរស។ នេះដោយសារតែវិសមភាពដែលកំពុងតែមានក្នុងពេលបច្ចុប្បន្ន។ វដ្តបរិយាកាសមានន័យថា បើមានស្ត្រីកាន់តែច្រើនរងផលប៉ះពាល់អវិជ្ជមាន ដោយសារតែការប្រែប្រួលអាកាសធាតុ នោះនឹងធ្វើឱ្យវិសមភាពកាន់តែខ្លាំង។ បើមានវិសមភាពកាន់តែខ្លាំង ផលប៉ះពាល់ក៏មានកាន់តែធ្ងន់ធ្ងរផងដែរ។ វដ្តបរិយាកាសមានផលអាក្រក់យ៉ាងខ្លាំងទៅលើការរីកចម្រើនផ្នែកសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ហើយថែមទាំងអាចពន្យារពេលដល់ការសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សរ៍ផងដែរ (Supachai Panitchapakdi អគ្គលេខាធិការនៃ UNCTAD, 2008)។*

## *សារគន្លឹះ*

- វិធានការបន្សាំ បង្ហាញអំពីចំណែករបស់មនុស្សនៅក្នុងការប្រែប្រួលអាកាសធាតុ។
- ទាំងស្ត្រី និងបុរស រងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដូចគ្នា ប៉ុន្តែវិសមភាពដែលកំពុងមានបានកំណត់ថា នរណាដែលនឹងរងផលប៉ះពាល់ខ្លាំងជាងគេពីគ្រោះធម្មជាតិ?
- បុរស និងស្ត្រីមានតម្រូវការ និងផលប្រយោជន៍ខុសៗគ្នានៅក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើការបន្សាំ។
- ស្ត្រីគឺជាភ្នាក់ងារដ៏សំខាន់ក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរ។ ចំណេះដឹងដ៏ពិសេសរបស់ពួកគេ គឺជាកត្តាដ៏សំខាន់សម្រាប់វិធានការបន្សាំ និងគោលនយោបាយ។
- ការចូលរួមដ៏ពេញលេញ និងប្រកបដោយប្រសិទ្ធភាពរបស់ស្ត្រីមានសារៈសំខាន់ណាស់ដើម្បីប្រើប្រាស់ចំណេះដឹង និងបទពិសោធន៍របស់ពួកគេឱ្យបានប្រសើរបំផុត។

## ៤.១ ការបន្សាំរបស់មនុស្សទៅនឹងការប្រែប្រួលអាកាសធាតុ

នៅក្នុងឆ្នាំថ្មីៗនេះ គំរូសហគមន៍ពិភពលោកអំពីតួនាទីនៃការបន្សាំដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសត្រូវបានរៀបចំឡើងជាថ្មី។ ពីដើមឡើយ ការបន្សាំត្រូវបានមើលឃើញថាជាជម្រើសទីពីរ និងជាជម្រើសរយៈពេលវែងដែលត្រូវរៀបចំផែនការជាថ្មី ប្រសិនបើកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយនោះមិនទាន់គ្រប់គ្រាន់។ នៅពេលមានការបង្ហាញឱ្យឃើញច្បាស់ថា កិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយនោះនៅមិនគ្រប់គ្រាន់ ការបន្សាំត្រូវបានចាត់ទុកជាអាទិភាពចម្បង

**ប្រអប់ទី១៖ និយមន័យនៃការបន្សាំ**

ក្រុមការងារអន្តររដ្ឋាភិបាលស្តីអំពីការប្រែប្រួលអាកាសធាតុបានដាក់និយមន័យការបន្សាំថា "...ជាការសម្របខ្លួននៅក្នុងប្រព័ន្ធអេកូឡូស៊ី សង្គម ឬសេដ្ឋកិច្ច ដើម្បីឆ្លើយតបទៅនឹងសកម្មភាពអាកាសធាតុពិត ឬរំពឹងទុក និងផលប៉ះពាល់របស់វា។ ពាក្យនេះចង់សំដៅទៅលើការប្រែប្រួលនៅក្នុងដំណើរការការអនុវត្ត និងរចនាសម្ព័ន្ធ ដើម្បីកាត់បន្ថយការខូចខាតដែលនឹងអាចកើតមាន ឬដើម្បីទទួលផលពីកាលានុវត្តភាព ដែលពាក់ព័ន្ធជាមួយនឹងការប្រែប្រួលអាកាសធាតុ។" *ប្រភព៖ IPCC, 2011*

មួយ។ ជំនួយមនុស្សធម៌ត្រូវតែរៀបចំជាស្រេចសម្រាប់ផលប៉ះពាល់នៃការឡើងកំដៅសកលលោក ជាពិសេសសម្រាប់សហគមន៍ដែលងាយរងគ្រោះ និងមនុស្សដែលកំពុងតែរស់នៅក្នុងភាពក្រីក្រ។

យុទ្ធសាស្ត្រនៃការបន្សាំសម្រាប់ការប្រែប្រួលអាកាសធាតុនឹងកាន់តែមានប្រសិទ្ធភាព ប្រសិនបើត្រូវបានបង្កើតឡើងនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចដែលមានគ្រប់ភាគីដែលរងផលប៉ះពាល់ទាំងអស់ចូលរួម។ ពាក់ព័ន្ធនឹងយុទ្ធសាស្ត្រនេះ ចំណុចសំខាន់ៗដែលត្រូវពិចារណាមានដូចខាងក្រោមនេះ៖

- ការទទួលបានការគ្រប់គ្រង និងការបែងចែកផលប្រយោជន៍
- ភាពស្ថិតស្ថេរនៃធនធានសហគមន៍និងធនធានធម្មជាតិ
- កម្រិតនៃភាពងាយរងគ្រោះ ភាពធន់ទ្រាំនិងស្វ័យភាពរបស់បុរសនិងស្ត្រីនៅពេល ដែលប្រឈមជាមួយនឹងការគំរាមកំហែងផ្សេងៗ
- សារៈសំខាន់នៃចំណេះដឹងរបស់ប្រជាជននៅមូលដ្ឋាន អំពីការអភិវឌ្ឍផ្នែកសង្គម និងសេដ្ឋកិច្ច
- ការចិញ្ចឹមជីវិត (Subsistence) ក្នុងពេលបច្ចុប្បន្ន និងយុទ្ធសាស្ត្រការបន្សាំផ្អែកលើយេនឌ័រ
- និងការគ្រប់គ្រងនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DDR) ដើម្បីចាត់វិធានការលើមូលហេតុនៃគ្រោះមហន្តរាយ និងកាត់បន្ថយផលប៉ះពាល់។



**ប្រអប់ទី២៖ និយមន័យនៃភាពងាយរងគ្រោះ**

"ភាពងាយរងគ្រោះគឺជាកម្រិត ដែលប្រព័ន្ធមួយងាយរងឥទ្ធិពលទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងមិនអាចសម្របខ្លួនជាមួយនឹងផលប៉ះពាល់នោះ រួមទាំងការ កម្រិតនៃការប្រែប្រួលអាកាសធាតុ និងភាពធ្ងន់ធ្ងរ។ ភាពងាយរងគ្រោះ គឺជាមុខងារមួយ នៃអត្តចរិត ទំហំ និងកម្រិតនៃការប្រែប្រួលអាកាសធាតុ និងការផ្លាស់ប្តូរ ដែលប្រព័ន្ធមួយ ត្រូវប្រឈមនឹងគ្រោះថ្នាក់ភាពងាយខូចខាត និងសមត្ថភាពក្នុងការបន្សាំ។"

*ប្រភព៖ IPCC, 2007*

## ៤.២ វិសមភាពយេនឌ័រពាក់ព័ន្ធជាមួយហានិភ័យ និងភាពងាយរងគ្រោះ

ភាពងាយរងគ្រោះ គឺជាស្ថានភាពមួយដែលប្រជាជនកំពុងតែប្រឈម ឬស្ថិតក្នុងភាពគ្រោះថ្នាក់ពីផលប៉ះពាល់ដោយសារតែបាតុភូតធម្មជាតិ ឬបាតុភូតដែលបង្កឡើងដោយមនុស្ស។ វាមានចលនាខ្លាំង ហើយផ្លាស់ប្តូរទៅតាមពេលវេលាទីកន្លែង និងស្ថានភាពសង្គម សេដ្ឋកិច្ច និងនយោបាយ (Wilches-Chaux, 1998)។

វិធីសាស្ត្រនៃភាពងាយរងគ្រោះ ក្នុងការយល់ដឹងពីទំនាក់ទំនងរវាងមនុស្សនិងបរិយាកាសរបស់ពួកគេ បានឱ្យយើងដឹងថា ភាពងាយរងគ្រោះ និងហានិភ័យ គឺជាស្ថានភាពផ្នែកសង្គម ដែលពាក់ព័ន្ធទៅនឹងដំណើរការនៃការអភិវឌ្ឍ។ គ្រោះមហន្តរាយ ពាក់ព័ន្ធនឹងបាតុភូតធម្មជាតិ ឬ បាតុភូតដែលបង្កឡើងដោយមនុស្ស រួមទាំងការប្រែប្រួលអាកាសធាតុ មិនមែនគ្រាន់តែកើតឡើងដោយបាតុភូតធម្មជាតិតែប៉ុណ្ណោះទេប៉ុន្តែក៏ជាលទ្ធផលកើតចេញពីការធ្វើសេចក្តីសម្រេចដែលធ្វើឡើងនៅក្នុងបរិបទសង្គមសេដ្ឋកិច្ចនិងនយោបាយផងដែរ។ ទំនាក់ទំនងយេនឌ័រនឹងមាននិន្នាការក្លាយទៅជាតួនាទីមួយដ៏សំខាន់នៅក្នុងការបង្កើតបរិបទនេះដូច្នេះនឹងមានសារៈសំខាន់នៅក្នុងការបង្កើតឱ្យមាននូវហានិភ័យ ភាពងាយរងគ្រោះ និងផលប៉ះពាល់របស់វា។

របាយការណ៍អំពីការអភិវឌ្ឍរបស់មនុស្ស (២០០៧-២០០៨) បញ្ជាក់ថា គុណវិបត្តិផ្សេងៗនៃប្រវត្តិសាស្ត្ររបស់ស្ត្រី ដែលទទួលបានធនធាននិងសិទ្ធិមានកម្រិត និងគ្មានសម្លេងនៅក្នុងការធ្វើសេចក្តីសម្រេច ធ្វើឱ្យពួកគេងាយរងគ្រោះ យ៉ាងខ្លាំងពីការប្រែប្រួលអាកាសធាតុ។ យោលទៅលើមានការប្រែប្រួលធំនៅក្នុងចរិតនៃការងាយរងគ្រោះនេះ ដូច្នេះនៅមិនទាន់គ្រប់គ្រាន់ក្នុងការធ្វើឱ្យទៅជាទូទៅ ប៉ុន្តែការប្រែប្រួលអាកាសធាតុនេះអាចនឹងបង្កើនភាពងាយរងគ្រោះផ្នែកយេនឌ័រ ក្នុងពេលបច្ចុប្បន្ន (UNDP, 2007)។

នៅមានភាពខុសគ្នាដ៏ធំខាងផ្នែកសង្គមសេដ្ឋកិច្ចរវាងស្ត្រី និងបុរសដែលត្រូវបានចាក់ឫស ដ៏ជ្រៅនៅក្នុងរចនាសម្ព័ន្ធសង្គមនៅជុំវិញពិភពលោក។ ភាពខុសគ្នាទាំងនេះ រួមមាន ភាពខុសគ្នានៃការទទួលបានធនធានផ្សេងៗដូចជា ដីធ្លី ឥណទាន ការអប់រំ ក៏ដូចជាការទទួលបាននូវឱកាស មិនស្មើគ្នាក្នុងការចូលរួម និងមានឥទ្ធិពលទៅលើដំណើរការនៃធ្វើសេចក្តីការសម្រេច។ ដោយសារតែស្ត្រីប្រើប្រាស់និងគ្រប់គ្រងធនធានធម្មជាតិក្នុងរបៀបមួយ ខុសពីបុរស ហើយការថយចុះនៃធនធានធម្មជាតិក៏មានផលប៉ះពាល់ដល់ពួកគេខុសៗគ្នា ដូច្នេះ ទម្រង់នៃភាពងាយរងគ្រោះអាចនឹងកើនឡើង ដោយសារការប្រែប្រួលឬការបាត់បង់ធនធានធម្មជាតិ ដែលពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍៖ ស្ត្រីៗនៅតាមជនបទក្នុងប្រទេសកំពុងអភិវឌ្ឍគឺជា អ្នកដែលផលិតអាហារដ៏សំខាន់ ហើយវិស័យកសិកម្មងាយនឹងប្រឈមជាមួយនឹងគ្រោះរាំងស្ងួត និងការធ្លាក់ភ្លៀងមិនទៀងទាត់។ នេះមានន័យថា ការប្រែប្រួលអាកាសធាតុនឹងធ្វើឱ្យអន្តរាយដល់សន្តិសុខស្បៀង ក៏ដូចជាសុខុមាលភាពរបស់ក្រុមគ្រួសារ និងសមត្ថភាពក្នុងការរស់រាន មានជីវិតរបស់ពួកគេ (FAO, 2007)។

ដោយសារតែស្ត្រីងាយរងគ្រោះជាង ដូច្នេះការចូលរួមរបស់ស្ត្រីនៅក្នុងគម្រោងនៃការបន្សាំនៃការប្រែប្រួលអាកាសធាតុពិតជាសំខាន់ណាស់។ លើសពីនេះទៅទៀត ការនេះត្រូវបានរំពឹងទុកមកថា តាមរយៈការអភិរក្ស ដី និងទឹក ការកសាងទំនប់ទឹក ដើម្បីទប់ស្កាត់ទឹកជំនន់ និងតាមរយៈការធ្វើការងារក្រៅពីកសិកម្មនោះ ស្ត្រីនឹងចូលរួមចំណែកកាន់តែច្រើន នៅក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីប្រឈមជាមួយនឹងហានិភ័យផ្នែកអាកាសធាតុ។

## ៤.២.១ កត្តាផ្សេងៗដែលជះឥទ្ធិពលឱ្យមានហានិភ័យផ្សេងៗទៅលើស្ត្រីនៅក្នុងគ្រោះមហន្តរាយ

### ១. ទីតាំងរូបវន្ត

ប្រជាជនក្រីក្រ (ដែលភាគច្រើនជាស្ត្រី) ទំនងជាតាំងទីកន្លែងរស់នៅ ដែលងាយរងគ្រោះ ដោយគ្រោះមហន្តរាយ និងនៅក្នុងបរិស្ថានដែលមិនអំណោយផល។ ឧទាហរណ៍៖ នៅតាមទីក្រុង ពួកគេមានផ្ទះសំបែងមិនពេញលេញ រស់នៅតាមតំបន់អនាធិបតេយ្យ និងតាមខ្ទមតូចៗ ដោយមិនសូវបានទទួលសេវាសំខាន់ៗ។ ចំណែកឯ នៅតាមទីជនបទវិញ ពួកគេអាចជាកសិករប្រកបរបរ កសិកម្មតូចតាចរស់នៅតាមជើងភ្នំ ហើយមិនមានទំនប់ការពារទឹក អាចនឹងធ្វើឱ្យបានការប្រោះដីបន្តិចម្តងៗ ដែលជាហេតុធ្វើឱ្យពួកគេប្រឈមជា

**ប្រអប់ទី៣៖ កត្តាដែលមានឥទ្ធិពលលើភាពងាយរងគ្រោះរបស់ប្រជាជន**

កត្តាដែលមានឥទ្ធិពល ទៅលើភាពងាយរងគ្រោះរបស់ប្រជាជនមានដូចជា៖ កត្តាបរិស្ថាន កត្តារូបវន្ត កត្តាសេដ្ឋកិច្ច និងសង្គម រួមទាំងកត្តានយោបាយ ជំនឿ និងវប្បធម៌ ការអប់រំ ស្ថាប័ន និងអង្គការ។

ទស្សនៈយេនឌ័រចំពោះភាពងាយរងគ្រោះត្រូវតែពិចារណាទៅលើគ្រប់ទាំងកត្តាទាំងអស់ និងក្នុងរបៀបជាក់លាក់ ដែលកត្តានីមួយៗមានឥទ្ធិពលទៅលើបុរសនិងស្ត្រី ។

*ប្រភព៖ Wilches-Chaux, 1998*

មួយនឹងការបាត់បង់ប្រភពនៃជីវភាពរស់នៅរបស់ពួកគេ។ ករណីជំពិតជាក់ស្តែងមួយ គឺមានស្ត្រីម្នាក់តំណាងឱ្យប្រទេសបង់ក្លាដេស បានពន្យល់ថា នៅពេលណាដែលមានទឹកជំនន់ ស្ត្រីៗក្រីក្រមិនមានសមត្ថភាពនិងធនធាន ដើម្បីផ្លាស់ទីទៅរកទីទួលសុវត្ថិភាពឡើយ។ ដូច្នេះពួកគាត់បានបាត់បង់អ្វីៗទាំងអស់ដែលពួកគាត់មាន រួមទាំងសត្វពាហនៈរបស់ពួកគាត់ (បានលើកឡើងនៅក្នុងព្រឹត្តិការណ៍ Actionaid, WEDO និង UNDP នៅ COP-13 ខែធ្នូ ឆ្នាំ ២០០៧)។

នៅក្នុងទីក្រុងវិញ ស្ត្រីៗក្រីក្រ ដែលកំពុងតែរស់នៅ និងប្រកបរបរនៅតាមតំបន់ដែលពុំមានការយកចិត្តទុកដាក់ក៏អាចងាយនឹងប្រឈមជាមួយនឹងហានិភ័យផ្នែកបច្ចេកវិទ្យា ឬហានិភ័យ ដែលបង្កឡើងដោយមនុស្ស។ នៅក្នុងតំបន់ខារីប៊ីន ស្ត្រីៗនៅតាមទីក្រុងដែលកំពុងតែរស់នៅលើកោះ St Lucia និងនៅក្នុងទីក្រុងហៃណា នៃប្រទេស សាធារណរដ្ឋដូមីនីកា (Dominican Republic) បានបញ្ជាក់អំពីការប្រឈមមុខជាមួយនឹងហានិភ័យ ដោយសារតែកាកសំណល់ឧស្សាហកម្ម (ចេញពីឧស្សាហកម្មថ្នាំពេទ្យ នៅកន្លែងដែលពួកគេធ្វើការ) និងចេញពីកាកសំណល់ចាក់សម្រាម និងឃ្លាំងឧស្សាហកម្មដែលមានផ្ទុកសម្ភារៈជាតិពុល និងបង្កគ្រោះថ្នាក់ខ្ពស់ ដូចជាឧបករណ៍ហ្គាស (propane gas installations) (Meyreles, 2003)។

100

## ២. ទិដ្ឋភាពសង្គម

ភាពងាយរងគ្រោះខាងសង្គម មានទាក់ទងទៅនឹងកម្រិតនៃសុខុមាលភាពរបស់បុគ្គល សហគមន៍និងសង្គមដែលផុះឡើងពីផ្នែកផ្សេងៗដែលទាក់ទងនឹងការទទួលបានសិទ្ធិមនុស្ស ជាមូលដ្ឋាន ការអប់រំ និងកម្រិតអក្ខរកម្ម អភិបាលកិច្ច ប្រព័ន្ធនៃអង្គភាព គុណតម្លៃ ទំនៀមទម្លាប់ និងជំនឿមនោគមវិជ្ជា។ ដោយសារតែគម្លាតយេនឌ័រ មានស្ត្រីជាច្រើនកំពុងតែទទួលបានសិទ្ធិតិចតួច ដែលជាលទ្ធផលពួកគេកាន់តែងាយរងគ្រោះ ជាហេតុនាំឱ្យពួកគេងាយប្រឈមទៅនឹងហានិភ័យកាន់តែខ្ពស់។

ឧទាហរណ៍ ស្ត្រីងាយនឹងខ្វះអាហារូបត្ថម្ភ ដោយសារតែពួកគេត្រូវការនូវអាហារូបត្ថម្ភដែលពិសេស (ជាពិសេសនៅពេលដែលពួកគេមានផ្ទៃពោះ ឬកំពុងបំបៅដោះ)។ នៅក្នុងតំបន់អាស៊ីប៉ែកខាងត្បូងនិងអាស៊ីអាគ្នេយ៍ស្ត្រីៗ ដែលស្ថិតក្នុងវ័យបន្តពូជពី៤៥%-៦០% មានទម្ងន់ស្រាល ហើយស្ត្រីដែលមានផ្ទៃពោះចំនួន៨០% ខ្វះជាតិដែក (FAO, 2000)។ អំពើហិង្សាទាក់ទងនឹងយេនឌ័រក៏ជាស្ថានភាពផ្នែកសង្គមវប្បធម៌ដែលអាចបង្កើតឱ្យមានហានិភ័យជាក់លាក់សម្រាប់ស្ត្រី និងក្មេងស្រីនៅក្នុងស្ថានភាពដែលពាក់ព័ន្ធនឹងគ្រោះមហន្តរាយផងដែរ។

## ៣. កត្តាសេដ្ឋកិច្ច

ស្ត្រីងាយនឹងរងភាពក្រីក្រ ដោយសារពួកគេមានប្រាក់ចំណូលទាបជាងបុរស ទំនងជាពឹងផ្អែក ផ្នែកសេដ្ឋកិច្ច និងទទួលបានដីធ្លី ហិរញ្ញទាន និងឥណទានមានកម្រិត ក៏ដូចជា នៅក្នុងការគ្រប់គ្រងលើធនធានផលិតកម្ម (Mehta, 2007)។ ស្ត្រីៗនៅក្នុងអាស៊ីប៉ែកខាងត្បូងទទួលបានឥណទាន ធនធានបច្ចេកទេស និងឱកាសការងារតិចតួចណាស់។ សមត្ថភាពរបស់ពួកគេនៅមានកម្រិតក្នុងការរកប្រាក់ចំណូល ហើយការចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេច ក៏នៅមានកម្រិតផងដែរ ដែលជាហេតុធ្វើឱ្យសមត្ថភាពពួកគេនៅមានកម្រិត ក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ។ ឧទាហរណ៍ នៅក្នុងប្រទេសឥណ្ឌា នេប៉ាល់ និងប្រទេសថៃ មានកសិករជាស្ត្រីតិចជាង១០% ដែលមានដីជាកម្មសិទ្ធិ (FAO, 2007)។ លើសពីនេះទៅទៀត ស្ត្រីបានចូលរួមច្រើនលើសលប់នៅក្នុងសេដ្ឋកិច្ចក្រៅផ្លូវប្រព័ន្ធ និងក្នុងវិស័យកសិកម្ម ដែលទទួលបានប្រាក់កម្រៃទាប និងងាយប្រឈមជាមួយនឹងហានិភ័យគ្រោះមហន្តរាយខ្លាំងបំផុត (Mehta, 2007)។

## ៤. ការអប់រំ និងព័ត៌មាន

ទាក់ទងនឹងការអប់រំនិងកម្រិតអក្ខរភាពវិញ ស្ត្រីនិងក្មេងស្រីជួបនឹងឧបសគ្គជាច្រើន ដែលកម្រិតឱកាសទទួលបានការអប់រំរបស់ពួកគេ។ មនុស្សចំនួន៨៧៦លាននាក់នៅក្នុងពិភពលោក ដែលមិនចេះអក្សរ ក្នុងនោះមាន២ភាគ៣ជាស្ត្រី ហើយ៣ភាគ៥នៃកុមារចំនួន ១១៥លាននាក់ ដែលមិនបានទៅសាលារៀនគឺជាកុមារី( Lara, 2004 )។ មានការកត់សំគាល់ដែរថា បន្ទាប់ពីមានគ្រោះមហន្តរាយ ឬក្នុងកំឡុងពេលដ៏តានតឹង មានកុមារីជាច្រើនត្រូវបានបង្ខំឱ្យឈប់រៀន ដើម្បីមកជួយការងារផ្ទះ ឬដើម្បីជួយរកលុយ ( Davis et al. 2005 )។

ការទទួលបានព័ត៌មាន ការអប់រំ និងការប្រាស្រ័យទាក់ទង ដើរតួយ៉ាងសំខាន់ក្នុងការកំណត់នូវប្រសិទ្ធភាពប្រព័ន្ធជូនដំណឹងជាមុន ហើយប្រព័ន្ធនេះពិតជាសំខាន់ក្នុងការកាត់បន្ថយផលប៉ះពាល់នៃទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ ហ៊ីរីខេន ស៊ូណាមី និងគ្រោះមហន្តរាយដទៃទៀត។ ដោយសារតែស្ត្រីមានកម្រិត អក្ខរកម្មទាបជាង ដូច្នេះពួកគេឆ្លើយតបបានតិចតួចទៅនឹងការជូនដំណឹងជាមុន និងសេចក្តីណែនាំជាលាយលក្ខណ៍អក្សរ។ ចំណែកឯការអប់រំទាបវិញ នាំឱ្យមានការចូលរួមតិចតួចនៅក្នុងការធ្វើសេចក្តីសម្រេច ហើយមានអ្នកតំណាងតិច នៅក្នុងការរៀបចំ និងការបណ្តុះបណ្តាលស្តីពីការឆ្លើយតបនឹងគ្រោះមហន្តរាយ ដូចនេះ ការនេះនាំឱ្យពួកគេមានសមត្ថភាពទាប ដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយ។

## ៥. ឆន្ទៈនយោបាយ

កង្វះឆន្ទៈនយោបាយ ក្នុងការបន្សាំទៅនឹងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងការទទួលបានអំណាចខាងនយោបាយនៅមានកម្រិត និងកង្វះតំណាងក្រុមបន្ទាប់បន្សំ បានធ្វើឱ្យស្ត្រីទទួលរងភាពងាយរងគ្រោះ ដោយគ្រោះមហន្តរាយកាន់តែធ្ងន់ធ្ងរទៅ។

## ៤.២.២ ភាពងាយរងគ្រោះនិងសមត្ថភាព

ជាការសំខាន់ដែលត្រូវកត់សំគាល់ថា ភាពខុសគ្នានៅក្នុងមុខតំណែងសង្គមរបស់ស្ត្រី និងបុរស មិនមែនគ្រាន់តែបង្កើតឱ្យមានភាពងាយរងគ្រោះ និងហានិភ័យផ្អែកយេនឌ័រប៉ុណ្ណោះទេ ប៉ុន្តែក៏បង្កើតឱ្យមានសមត្ថភាព ផ្អែកយេនឌ័រ

**ប្រអប់ទី៤៖**

**ភាពខុសគ្នា ដែលធ្វើឱ្យហានិភ័យសម្រាប់ស្ត្រីនៅក្នុងគ្រោះមហន្តរាយមានការកើនឡើង**

- ភាពក្រីក្រមានកម្រិតខ្ពស់
- ទំនួលខុសត្រូវដ៏ធំក្នុងការមើលថែទាំអ្នកដទៃ
- អំពើហិង្សាក្នុងគ្រួសារ
- មុខងារបែបប្រពៃណីរបស់ស្ត្រី

**ភាពខុសគ្នា ដែលធ្វើឱ្យហានិភ័យសម្រាប់បុរសនៅក្នុងគ្រោះមហន្តរាយមានការកើនឡើង**

- ការបែងចែកការងារដាច់ដោយឡែក
- បទដ្ឋានផ្ទៃក្នុងរបស់បុរស
- តួនាទីនៅក្នុងគ្រួសារ និងនៅក្នុងផ្ទះ

**បទពិសោធន៍យេនឌ័រ ដែលអាចបង្កើនសមត្ថភាពក្នុងការគ្រប់គ្រងស្ថានភាពគ្រោះមហន្តរាយ**

**ស្ត្រី**

- បណ្តាញសង្គម
- ភាពប៉ិនប្រសប់ក្នុងការថែទាំ
- ចំណេះដឹងទូលំទូលាយអំពីសហគមន៍
- ការគ្រប់គ្រងធនធានបរិស្ថានធម្មជាតិ
- ការយល់ដឹងអំពីហានិភ័យមានកម្រិតខ្ពស់

**បុរស**

- ទំនាក់ទំនងវិជ្ជាជីវៈ និងការងារ
- សមត្ថភាពបច្ចេកទេស
- ទំនួលខុសត្រូវក្នុងការថែទាំកុមារមានកម្រិត

ផងដែរ។សមត្ថភាពជាក់លាក់ដែលស្ត្រីបានអភិវឌ្ឍនៅក្នុងមុខតំណែងក្នុងសង្គម និងវប្បធម៌ខុសៗគ្នាអាចមានសារៈសំខាន់ណាស់នៅគ្រប់ដំណាក់កាលនៃការគ្រប់គ្រងគ្រោះមហន្តរាយ ក៏ដូចជាសម្រាប់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងសមត្ថភាពនៃការបន្ស៊ាំផងដែរ។ ឧទាហរណ៍ ការសិក្សាស្រាវជ្រាវអំពីហានិភ័យរបស់ស្ត្រី ។កម្រិតមូលដ្ឋានមួយនៅក្នុងតំបន់ខារីប៊ីន (Enarson et al., 2001) បានបង្ហាញថា ស្ត្រីបានចាត់ទុកក្រុមគ្រួសារ និងបណ្ដាញមិត្តភក្ដិជាសមត្ថភាពដ៏សំខាន់របស់ពួកគេក្នុងកំឡុងពេលមានគ្រោះមហន្តរាយ។ ឧទាហរណ៍នៅក្នុងប្រទេសដូមីនីកា (Dominica) យូដមិន ឬក្រុមគ្រួសារ និងបណ្ដាញមិត្តភក្តិ គឺជាតួអង្គដ៏ពិសិដ្ឋ(ibid)។ ស្ត្រីនៅក្នុងសហគមន៍ទំនងជាទទួលបានព័ត៌មានដ៏មានតម្លៃទាក់ទងនឹងសហគមន៍ និងសមាជិកក្រុមគ្រួសារៈ នរណាដែលកំពុងតែបាត់ខ្លួន និងនរណាដែលត្រូវការយកចិត្តទុកដាក់ជាពិសេស។រដ្ឋបាលមូលដ្ឋានគួរតែចាប់ផ្ដើមនូវដំណើរការពីក្រោមទៅលើដើម្បីឱ្យសមត្ថភាពទាំងនេះ និងសមត្ថភាពដទៃទៀតត្រូវបានទទួលស្គាល់ និងត្រូវបានប្រើប្រាស់។ បទពិសោធន៍របស់ប្រជាជនគុយបាក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ គឺជាឧទាហរណ៍មួយដ៏ល្អអំពីវិធីសាស្ត្រផ្ដោតលើសហគមន៍ (Wisner et al., 2006)។



ការសិក្សាអំពីគ្រោះមហន្តរាយមានឧទាហរណ៍ជាច្រើនអំពីការវិភាគលើភាពងាយរងគ្រោះ និងសមត្ថភាពយេនឌ័រដែលអាចជាប្រយោជន៍យ៉ាងខ្លាំងសម្រាប់សមត្ថភាពក្នុងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ (សូមមើល Gomariz, 1999)។

## ៤.២.៣ ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ

ការប្រែប្រួលអាកាសធាតុមិនមែនជាការគំរាមកំហែងមួយដែលរួមផ្សំជាមួយឧបទ្ទវហេតុតែមួយប៉ុណ្ណោះទេ ប៉ុន្តែវានឹងបង្កឱ្យមានហានិភ័យនៃគ្រោះមហន្តរាយជាច្រើនទម្រង់ដែលនឹងលេចឡើងយ៉ាងយឺតៗ។ នៅក្នុងបរិបទនេះជាការសំខាន់ដែលយុទ្ធសាស្ត្រគម្រោង និងគោលនយោបាយនៃការបន្ស៊ាំនិងការកាត់បន្ថយ គួរតែបញ្ចូលនូវការយល់ដឹងអំពីគំនិតនៃការគ្រប់គ្រងហានិភ័យ ជាមួយនឹងវិធីសាស្ត្រយេនឌ័រឬក៏បញ្ចូលវិធីសាស្ត្រយេនឌ័រជាមុន ហើយបញ្ចូលការយល់ដឹងអំពីគំនិតនៃការគ្រប់គ្រងហានិភ័យតាមក្រោយ។

យោងតាម ប៊ូរ៉ន (Buron) ការគ្រប់គ្រងហានិភ័យ គឺជាដំណើរការចម្បងមួយដែលគោលបំណងចុងក្រោយ ដើម្បីកាត់បន្ថយជាអចិន្ត្រៃយ៍ និងគ្រប់គ្រងគ្រោះមហន្តរាយក្នុងសង្គមដែលជាផ្នែកមួយនៃគម្រោងសំណើអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងផ្នែកសង្គម សេដ្ឋកិច្ច និងដែនអធិបតេយ្យភាព(Buron, 2007)។ ក្នុងន័យម្យ៉ាងទៀត ការគ្រប់គ្រងហានិភ័យ គឺជាលទ្ធផលនៃសមត្ថភាពរបស់សង្គម និងអ្នកដែលពាក់ព័ន្ធដើម្បីផ្លាស់ប្ដូរហានិភ័យដោយដោះស្រាយតាមមូលហេតុខាងក្រៅ និងមានគួសបញ្ជាក់។ ទាំងនេះរួមមានវិធីសាស្ត្រ និងមធ្យោបាយអន្តរាគមន៍ដែលមានទំនោរកាត់បន្ថយសម្រាលឬទប់ស្កាត់នូវគ្រោះមហន្តរាយ។

## ប្រអប់ទី៥៖ ឧទាហរណ៍អំពីផលវិបាកនៃការខ្វះការឆ្លើយតបទៅនឹងយេនឌ័រនៅក្នុងប្រព័ន្ធនៃការជូនដំណឹងជាមុន

- ក្នុងកំឡុងពេលព្យុះស៊ីក្លូនបង់ក្លាដេសនៅឆ្នាំ១៩៩១ ស្ត្រីភាគច្រើនមិនបានទទួលសញ្ញាជូនដំណឹងជាមុនឡើយ។ ព័ត៌មាននោះត្រូវបានចែកចាយគ្នានៅតាមទីផ្សារ ហើយដោយសារតែសង្គមបង់ក្លាដេស គឺជាសង្គមមួយដែលមានការបែងចែកភេទខ្ពស់ ដូច្នេះស្ត្រីជាច្រើននាក់មិនមានភាពងាយស្រួលក្នុងការទៅផ្សារឡើយ។
- ការរំពឹងទុកថា បុរសនឹងនាំដំណឹងទៅប្រាប់សមាជិកក្រុមគ្រួសាររបស់ពួកគេ ប៉ុន្តែផ្ទុយទៅវិញ ពួកគេមិនបានធ្វើដូច្នេះឡើយ។ ជាលទ្ធផល ស្ត្រីមិនបានទទួលដំណឹង មិនបានត្រៀមខ្លួន និងមិនអាចឆ្លើយតបទៅនឹងហានិភ័យនៃគ្រោះមហន្តរាយដើម្បីការពារខ្លួន កូនចៅ និងទ្រព្យសម្បត្តិរបស់ពួកគេទេ។
- មានការរាយការណ៍ថា មណ្ឌល និងជម្រកផ្តល់ជំនួយ គឺជាកន្លែងដែលមិនសមស្រប យេនឌ័រ របស់ស្ត្រី និងតម្រូវការជាក់លាក់ខាងវប្បធម៌៖ ក្នុងបរិបទសង្គមដែលមានប្រពៃណីនៃភាពឯកជន មានការរាយការណ៍ថា មណ្ឌលគឺជាកន្លែងដែលមានមនុស្សច្រើន និងខ្វះភាពឯកជនសម្រាប់ស្ត្រីមានផ្ទៃពោះ ស្ត្រីបំបៅដោះកូន និងស្ត្រីដែលមានរដូវ។ មណ្ឌលក៏ខ្វះនូវបង្គន់ដាច់ចេញពីគ្នា និងមិនមានទឹកគ្រប់គ្រាន់ផងដែរ ( UNEP, 1997 )។
- ការសិក្សាបានបង្ហាញថា នៅពេលដែលស្ត្រីទទួលបានប្រព័ន្ធនៃការជូនដំណឹងជាមុន នោះលទ្ធផលដែលសម្រេចបានមានភាពវិជ្ជមាន។ នៅរដ្ឋហារ៉េ ក្នុងកំឡុងឆ្នាំ១៩៩៨ ព្រឹត្តិការណ៍ អិល នីណូ ( El Nino )ស្ត្រីគឺជាគោលដៅដែលត្រូវទទួលព័ត៌មានជាមុនដែលរួមបញ្ចូលទាំងព័ត៌មានដែលទាក់ទងនឹងការដោះស្រាយបញ្ហាទឹកសម្រាប់ផឹក ជាលទ្ធផលការងារនេះបានទទួលជោគជ័យគួរឱ្យកត់សំគាល់ក្នុងការកាត់បន្ថយជម្ងឺរាគ ( Kinoti, 2008 )។
- នៅក្នុងសហគមន៍ដាច់ស្រយាលនៃប្រទេសអែលសាល់វ៉ាឌ័រ ស្ត្រីៗបានទទួលការបង្រៀនអំពីរបៀបប្រើប្រាស់វិទ្យុទាក់ទង ដើម្បីរាយការណ៍អំពីកម្រិតនៃទឹកជំនន់។ វិធីសាស្ត្របែបនេះ បាននាំឱ្យការជូនដំណឹងអំពីគ្រោះថ្នាក់កាន់តែមានប្រសិទ្ធភាពសម្រាប់សហគមន៍ទាំងមូល ( Enarson et al., 2003 )។
- មានតម្រូវការព័ត៌មានទាក់ទងនឹងគ្រោះមហន្តរាយដែលស្ត្រីត្រូវការដឹងជាចាំបាច់។ ការសិក្សាមួយដែលត្រូវបានធ្វើឡើងនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូងបានរាយការណ៍ថា ស្ត្រីដែលជាកសិករចង់ឱ្យមានការផ្សាយព័ត៌មានអំពីការព្យាករណ៍អាកាសធាតុតាមរដូវកាលដោយភ្នាក់ងារផ្សព្វផ្សាយបន្ត ឬតាមរយៈសាលារៀន ជាជាងការផ្សាយតាមវិទ្យុ ពីព្រោះវិទ្យុគឺជាមធ្យោបាយដែលបុរសៗចង់បាន ដោយសារតែបុរសមានវិទ្យុកាន់ច្រើនជាង ក៏ដូចជាមានពេលច្រើនដើម្បីស្តាប់វិទ្យុ ( Kinoti, 2008 )។

ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុគួរតែរៀបចំផែនការដាក់បញ្ចូលគ្នា។ របាយការណ៍នៃវេទិការអំពីគោលនយោបាយ អូសស្លូ បានទទួលស្គាល់ថា "DDR គឺជាធាតុមួយដ៏សំខាន់ដើម្បីសម្រេចការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ" (OPFR, 2008)។ របាយការណ៍នេះបានផ្តល់នូវអនុសាសន៍ជាក់លាក់ផ្សេងៗដែលទាក់ទងនឹងការផ្តល់ជំនួយផែនការអភិវឌ្ឍនៅគ្រប់កម្រិត ការធ្វើសមាហរណកម្ម និងសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងរវាង DRR និងអ្នកជំនាញខាងការប្រែប្រួលអាកាសធាតុ។ របាយការណ៍នេះក៏បានសង្កត់ធ្ងន់លើកិច្ចខិតខំសហប្រតិបត្តិការ និងការពង្រឹងប្រព័ន្ធអន្តរជាតិនៅក្នុងចំណោមសំណើសំខាន់ៗដទៃទៀតដើម្បីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្លាយជាកិច្ចខិតខំប្រឹងប្រែងរួមគ្នា និងគាំទ្រដល់ការអភិវឌ្ឍដែលមាននិរន្តរភាព (ibid)។



ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ អាចមានដំណើរការផ្សាភ្ជាប់គ្នារវាងការធ្វើសេចក្តីសម្រេចចិត្ត ការរៀបចំផែនការ ការអនុវត្ត និងការគ្រប់គ្រងដែលជួយឱ្យស្ត្រី និងបុរសធ្វើការវិភាគទៅលើកត្តាដែលនៅជុំវិញពួកគេ ហើយត្រូវធ្វើសេចក្តីសម្រេច និងបង្កើតនូវគម្រោងសំណើអំពីសកម្មភាពរួមមួយដែលត្រូវបានរចនាឡើងដើម្បីកាត់បន្ថយហានិភ័យដែលកំពុងតែជួបប្រទះ ដោយសារហានិភ័យដែលកើតឡើង ប្រសិនបើមិនបានគ្រប់គ្រងឱ្យបានត្រឹមត្រូវទេនោះនឹងអាចក្លាយទៅជាគ្រោះមហន្តរាយបាន។

ផលប៉ះពាល់ផ្សេងៗគ្នាផ្អែកលើយេនឌ័រ បានបង្ហាញឱ្យឃើញកាន់តែច្បាស់ក្នុងកំឡុងពេលដែលមានស្ថានភាពបន្ទាន់៖

- Neumayer និង Plumper បានធ្វើការវិភាគពីគ្រោះមហន្តរាយនៅក្នុងប្រទេសចំនួន១៤១ ហើយបានរកឃើញថានៅពេលមានទាក់ទងនឹងការស្លាប់ ភាពខុសគ្នានៃយេនឌ័រ គឺមានទាក់ទងផ្ទាល់ទៅនឹងកត្តាសេដ្ឋកិច្ចរបស់ស្ត្រី និងសិទ្ធិក្នុងសង្គម។ នៅក្នុងសង្គមដែលស្ត្រី និងបុរសមានសិទ្ធិស្មើគ្នា គ្រោះមហន្តរាយបានបង្កឱ្យមានចំនួននៃកាស្លាប់ ដូចគ្នាទៅលើបុរសនិងស្ត្រី។ ការវិភាគនេះក៏បានបញ្ជាក់ថាភាពមិនស្របគ្នា គឺជាលទ្ធផលនៃការមានវិសមភាពក្នុងពេលបច្ចុប្បន្ន។ ឧទាហរណ៍៖ ក្មេងប្រុសបានទទួលការព្យាបាល ដ៏ល្អក្នុងកំឡុងពេលនៃការជួយសង្គ្រោះ ហើយក្រោយពេលមានគ្រោះមហន្តរាយ ស្ត្រីនិងក្មេងស្រី បានរងគ្រោះច្រើនដោយសារកង្វះអាហារនិងធនធានសេដ្ឋកិច្ច (Neumayer និង Plumper, 2007)។
- ការសិក្សាបង្ហាញថា ស្ត្រី ក្មេងប្រុស និងក្មេងស្រី មានឱកាសស្លាប់១៤ដង ច្រើនជាងបុរសក្នុងកំឡុងពេលមានគ្រោះមហន្តរាយ (Peterson, 2007)។
- នៅក្នុងឆ្នាំ១៩៩១ ក្នុងកំឡុងពេលមានគ្រោះមហន្តរាយខ្យល់ព្យុះស៊ីក្លូន នៅក្នុងប្រទេសបង់ក្លាដេស មានមនុស្សចំនួន១៤០.០០០នាក់បានស្លាប់ ហើយក្នុងនោះមានស្ត្រី ចំនួន៩០% (Ikeda, 1995)។
- នៅក្នុងប្រទេសឧស្សាហកម្ម មានស្ត្រីច្រើនជាងបុរសដែលបានស្លាប់ក្នុងកំឡុងពេលនៃរលកកំដៅដែលបានជះឥទ្ធិពលដល់ប្រទេសក្នុងទ្វីបអឺរ៉ុបនៅក្នុងឆ្នាំ២០០៣។ នៅក្នុងប្រទេសបារាំង មនុស្សដែលស្លាប់ភាគច្រើន គឺជាស្ត្រីចំណាស់ៗ (Pirard et al., 2005)។

- ក្នុងកំឡុងពេលមានភាពអាសន្នដែលបង្កឡើងដោយព្យុះ ហ៊ីរីខេន កាទ្រីណា នៅក្នុងសហរដ្ឋអាមេរិក ជនរងគ្រោះភាគច្រើនដែលត្រូវជាប់នៅក្នុងរដ្ឋញូវអូលីន (New Orleans) គឺជាស្ត្រីជនជាតិអាហ្វ្រិក អាមេរិក និងកូនចៅរបស់ពួកគេដែលរស់នៅក្នុងតំបន់ដែលមានភូមិសាស្ត្រក្រីក្របំផុតនៅក្នុងផ្នែកមួយនៃប្រទេស (Gault et al., 2005; Williams et al., 2006)។
- នៅក្នុងប្រទេសស្រីលង្កា បុរសងាយស្រួលក្នុងការរស់រានមានជីវិតក្នុងកំឡុងពេលមានស៊ូណាមី ដោយសារតែការចេះហែលទឹក និងការចេះឡើងដើមឈើ។ ជំនាញទាំងនេះ បង្រៀនតែក្មេងប្រុសៗប៉ុណ្ណោះ។ ការប្រកាន់ភាពរើសអើងនៃសង្គមនេះបានធ្វើឱ្យក្មេងស្រី និងស្ត្រីៗនៅក្នុងប្រទេសស្រីលង្កាមានលទ្ធភាពតិចតួចណាស់ក្នុងការរស់រានមានជីវិតពីគ្រោះមហន្តរាយនៅពេលអនាគត (Oxfam, 2005)។
- ក្រោយពេលមានគ្រោះមហន្តរាយ ទំនងដូចជាស្ត្រីនឹងក្លាយជាជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ ហើយពួកគេថែមទាំងមិនចង់ប្រើប្រាស់មណ្ឌល ។យសារតែខ្លាចការរំលោភបំពានផ្លូវភេទ (Davis et al., 2005)។
- លក្ខខណ្ឌនៃអាហារូបត្ថម្ភ កំណត់អំពីសមត្ថភាពដើម្បីដោះស្រាយបញ្ហាគ្រោះមហន្តរាយ (Cannon, 2002)។ ស្ត្រីទំនងជាងាយរងគ្រោះនឹងការខ្វះអាហារូបត្ថម្ភច្រើន ដោយសារតែពួកគេមានតម្រូវការខាងអាហារូបត្ថម្ភជាក់លាក់នៅពេលដែលពួកគេមានផ្ទៃពោះ ឬបំបៅដោះកូន ហើយនៅក្នុងវប្បធម៌ខ្លះមានឋានានុក្រមនៃអាហារ។ ឧទាហរណ៍ នៅក្នុងប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ៤៥%-៦០%នៃស្ត្រីដែលស្ថិតក្នុងវ័យបន្តពូជមានទម្ងន់ក្រោមទម្ងន់ធម្មតា ហើយ៨០%នៃស្ត្រីមានផ្ទៃពោះបានខ្វះសារជាតិដែក។ នៅក្នុងប្រទេសអាហ្វ្រិកតំបន់ជិតវាលខ្សាច់សាហារ៉ា ស្ត្រីៗលើករបស់ធ្ងន់ៗជាងបុរស ប៉ុន្តែបរិភោគអាហារមានជាតិកាល់ឡូរីតិចតួចដោយសារតែច្បាប់នៃវប្បធម៌បានចែងថា បុរសត្រូវទទួលបានអាហារច្រើនជាង (FAO, 2000)។
- នៅក្នុងករណីខ្លះ ភាពខុសគ្នាផ្នែកយេនឌ័រក៏បង្កើននូវមរណភាពរបស់បុរសនៅក្នុងស្ថានភាពនៃគ្រោះមហន្តរាយផងដែរ។ បុរសជាច្រើនប្រឈមជាមួយនឹងស្ថានភាពប្រថុយប្រថាន ហើយអាចថែមទាំងដល់ស្លាប់ដោយសារតែពួកគេជឿថា គេកើតមកមាន "ភេទរឹងមាំ" មិនចាំបាច់មានការប្រុងប្រយ័ត្នឡើយ ហើយដោយសារតែសង្គមរំពឹងថា ពួកគេនឹងបង្ហាញពីសកម្មភាពសង្គ្រោះជាវីរបុរស។ ឧទាហរណ៍ មានបុរសជាច្រើនបានស្លាប់ភ្លាមៗនៅពេលដែលព្យុះហ៊ីរីខេនមីត បានបោកបក់ចូលទ្វីបអាមេរិកកណ្តាល មិនមែនដោយសារតែពួកគេពាក់ព័ន្ធនៅក្នុងសកម្មភាពនៅកណ្តាលវាលនោះទេ ប៉ុន្តែដោយសារពួកគេមានការប្រុងប្រយ័ត្នតិចតួចនៅពេលដែលប្រឈមជាមួយនឹងហានិភ័យ (Bradshaw, 2004)។
- នៅក្នុងប្រទេសខេនយ៉ា ការទៅដងទឹកអាចចំណាយកម្លាំងប្រចាំថ្ងៃរបស់ស្ត្រីរហូតដល់ ៨៥% ហើយនៅក្នុងពេលមានគ្រោះរាំងស្ងួតវិញ បន្ទុកនៃការងារដ៏ធ្ងន់នេះបានធ្លាក់ទៅលើស្ត្រីដែលអ្នកខ្លះចំណាយពេលដល់ទៅប្រាំបីម៉ោងជារៀងរាល់ថ្ងៃដើម្បីចេញទៅស្វែងរកទឹក (Duncan, 2007)។
- ហេតុការណ៍នៃធាតុអាកាសដ៏អាក្រក់ជារឿយៗ បង្កើតឱ្យមានស្ថានភាពដែលបង្កឱ្យមានជម្ងឺឆ្លងផ្សេងៗ។ ភ្លៀងធ្លាក់ខ្លាំងបណ្តាលឱ្យមានសត្វល្អិតនៅលើដី ហើយធ្វើឱ្យប្រភពទឹកស្អាតទៅជាកខ្វក់។ ចំណែកឯគ្រោះរាំងស្ងួត

វិញអាចបង្កឱ្យមានផ្សិត និងបង្កឱ្យមានភ្លើងឆេះព្រៃ។ ស្ត្រី ជាពិសេសស្ត្រីដែលមានផ្ទៃពោះាយរងគ្រោះយ៉ាងខ្លាំងទៅនឹងជម្ងឺដែលមកពីទឹកមិនស្អាត ការក្តៅខ្លាំង និងហេតុការណ៍អាក្រក់ដទៃទៀត។

- នៅក្នុងជំរំជនភៀសខ្លួនដែលមានគ្រោះធម្មជាតិនិងជម្លោះដោយសារមិនសូវមានធនធាន ជនភៀសខ្លួនដែលជាស្ត្រី និងក្មេងស្រីងាយប្រឈមទៅនឹងហានិភ័យខ្ពស់ជាងបើប្រៀបធៀបជាមួយនឹងជនភៀសខ្លួនជាបុរស។ សម្ពាធខាងសង្គមនៅក្នុងស្ថានភាពបែបនេះ ធ្វើឱ្យកម្រិតនៃភាពតានតឹងមានភាពកាន់តែធ្ងន់ធ្ងរនៅក្នុងក្រុមគ្រួសារដែលជាហេតុនាំឱ្យមានអំពើហិង្សាក្នុងគ្រួសារកើតឡើង។
- ការសិក្សាមួយនៅក្នុងប្រទេសយូហ្គានដា បានបង្ហាញអំពីរបៀបដែលមេផ្ទះ ាបុរស និងមេផ្ទះជាស្ត្រីប្រព្រឹត្តខុសគ្នានៅក្នុងស្ថានភាពនៃការផ្លាស់ទីលំនៅ។ ស្ត្រីៗបានយល់ស្របថា "ជាការងារមួយដ៏លំបាកសម្រាប់ពួកគេដោយសារតែកង្វះនូវឧបករណ៍ និងមិនមានបុរស។" ផលប៉ះពាល់នៃការផ្លាស់ទីលំនៅដែលជះឥទ្ធិពលលើសុខភាព ការផ្គត់ផ្គង់តម្រូវការមូលដ្ឋាន ដូចជា ទឹក និងការថែទាំកុមារ ធ្វើឱ្យមេផ្ទះដែលជាស្ត្រីមានការពិបាកកាន់តែខ្លាំង( Katwikirize, 2002 ) ។



**ប្រអប់ទី៦៖ គោលការណ៍ទាំងប្រាំពីរនៅពេលដែលបញ្ចូលទស្សនៈយេនឌ័រនៅក្នុងការកសាងឡើងវិញ និងការស្តារឡើងវិញ៖ ការងារដែលសម្រេចនៅក្នុងស្ថានភាពគ្រោះមហន្តរាយមិនមែនជាអព្យាក្រឹតភាពយេនឌ័រទេ។**

១. គិតឱ្យបានទូលំទូលាយ៖ សមភាពយេនឌ័រ និងគោលការណ៍នៃការកាត់បន្ថយហានិភ័យត្រូវតែណែនាំអំពីគ្រប់ផ្នែកទាំងអស់នៃការកាត់បន្ថយគ្រោះមហន្តរាយ ការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ និងការកសាងឡើងវិញ។ ឱកាសនេះងាយនឹងបាត់បង់ទៅវិញណាស់។

២. ដឹងអំពីការពិត៖ ការវិភាគយេនឌ័រ មិនមែនជាជម្រើសមួយនោះទេ ប៉ុន្តែគឺជាអ្វីមួយដ៏សំខាន់ដើម្បីផ្តល់ជាជំនួយដល់ការរៀបចំផែនការក្នុងការស្តារឱ្យមានសមភាព។

៣. ធ្វើការជាមួយអង្គការស្ត្រី៖ នៅក្នុងសហគមន៍ អង្គការ ស្ត្រីមានព័ត៌មាន ចំណេះដឹង បទពិសោធន៍ បណ្តាញ និងធនធានផ្សេងៗដែលពិតជាសំខាន់ដើម្បីបង្កើននូវភាពធន់ទ្រាំទៅនឹងបញ្ហា នៅពេលប្រឈមជាមួយនឹងគ្រោះមហន្តរាយ។

៤. ធ្វើការជាមួយស្ត្រី និងកសាងសមត្ថភាពរបស់ក្រុមស្ត្រីដែលមានស្រាប់។

៥. ប្រឆាំងទៅនឹងផ្នត់គំនិតសង្គម៖ ផ្អែកលើគំនិតផ្តួចផ្តើមទាំងអស់ដែលទាក់ទងនឹងបរិបទចំណេះដឹងជាក់លាក់ និងភាពខុសគ្នានៃវប្បធម៌នីមួយៗស្ថានភាពសេដ្ឋកិច្ចក៏ដូចជាភាពខុសគ្នាខាងនយោបាយ និងផ្លូវភេទ និងមិនត្រូវផ្អែកលើភាពមិនពិតជាទូទៅនោះទេ។

៦. ប្រើប្រាស់វិធីសាស្ត្រសិទ្ធិមនុស្ស៖ គម្រោងបែបប្រជាធិបតេយ្យ និងមានការចូលរួមពិតជាជួយច្រើនដល់ស្ត្រី និងក្មេងស្រី។ ស្ត្រី និងបុរសមានសិទ្ធិទទួលបានលក្ខខណ្ឌផ្សេងៗដែលពួកគេត្រូវការ ដើម្បីប្រើប្រាស់សិទ្ធិមនុស្សមូលដ្ឋានរបស់ពួកគេក៏ដូចជាដើម្បីរស់រានមានជីវិត។

៧. គោរព និងកសាងសមត្ថភាពរបស់ស្ត្រី។ ជៀសវាងការដាក់បន្ទុកខ្លាំងពេកទៅលើស្ត្រីដែលមានបន្ទុកដ៏ធ្ងន់រួចហើយ និងមានទំនួលខុសត្រូវក្នុងគ្រួសារច្រើន។

*ប្រភព៖ បណ្តាញយេនឌ័រ និងគ្រោះមហន្តរាយ ២០០៥*

ការមិនបញ្ចូលស្ត្រីទៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចអំពីការប្រែប្រួលអាកាសធាតុនេះ មានន័យថាសង្គមកំពុងតែដកសម្លេងរបស់ប្រជាជនពាក់កណ្តាលពិភពលោក ដោយល្មើសនឹងគោលការណ៍ដែលពាក់ព័ន្ធនឹងសិទ្ធិរបស់ពួកគេ ហើយក្នុងពេលនោះក៏កំពុងតែដកហូតនូវជំនាញ បទពិសោធន៍ និងសមត្ថភាពដ៏សំខាន់ចេញពីខ្លួនឯងផងដែរ។ ធនធាន បរិយាកាស ចំណេះដឹង និងការអនុវត្តរបស់ស្ត្រី គឺជាធាតុដ៏សំខាន់នៅក្នុងដំណើរការនៃការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍៖

- កំឡុងពេលនៃគ្រោះរាំងស្ងួតនៅក្នុងកោះដ៏តូចៗនៃសាធារណរដ្ឋមីក្រូនេស៊ី (Micronesia) ចំណេះដឹងរបស់ស្ត្រីដែលមានតាំងពីដីដូនដីតាអំពីជលសាស្ត្រនៃដីកោះបានជួយឱ្យពួកគេងាយស្រួលក្នុងការស្វែងរកកន្លែងដើម្បីជីកអណ្តូងសម្រាប់ទឹកផឹក។ ជាធម្មតា ស្ត្រីមិនចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចឡើយ ប៉ុន្តែព័ត៌មានដែលពួកគេ បានផ្តល់ជូនបានផ្តល់ផលប្រយោជន៍ច្រើនដល់សហគមន៍ទាំងមូល (Anderson, 2002)។

## ៤.៣ តួនាទីរបស់ស្ត្រីនៅក្នុងការបន្សាំការប្រែប្រួលអាកាសធាតុ

### ៤.៣.១ ស្ត្រី និងបុរស ក្នុងនាមជាភ្នាក់ងារនៃការផ្លាស់ប្តូរ

ដូចបានលើកឡើងនៅក្នុងវគ្គទី៣ គឺជាការចាំបាច់ដែលត្រូវបញ្ជាក់ថា ស្ត្រីមិនមែនងាយរងគ្រោះដោយសារតែពួកគេជា “មនុស្សដែលកើតមកខ្សោយពីធម្មជាតិ” នោះទេ ប៉ុន្តែដោយសារតែស្ថានភាពនៃភាពងាយរងគ្រោះដែលបុរស និងស្ត្រីត្រូវប្រឈមមានភាពខុសគ្នា ដោយសារភេទរបស់ពួកគេ។ ស្ត្រីក៏ដូចជាបុរសមាននូវភាពងាយរងគ្រោះ និងសមត្ថភាពដែលកសាងដោយសង្គមដែលត្រូវបានអភិវឌ្ឍតាមរយៈដំណើរការរបស់សង្គម។ ទោះជាយ៉ាងណាក៏ដោយក៏ពួកគេអាចមានសមត្ថភាពធ្វើឱ្យខ្លួនឯងប្រសើរឡើងទទួលនូវភាពអង់អាច ឬផ្លាស់ប្តូរ។ ស្ត្រីមិនអសកម្ម ហើយពួកគេមិនគ្រាន់តែទទួលជំនួយប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ជាភ្នាក់ងារដ៏សកម្មដែលមានសមត្ថភាពខុសៗគ្នាក្នុងការឆ្លើយតបទៅនឹងឧបសគ្គផ្សេងៗដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ។

### ៤.៣.២ ទំនាក់ទំនងខុសៗគ្នារវាងស្ត្រី និងបុរសទៅនឹងបញ្ហាបរិស្ថាន

នៅពេលដែលយើងពិភាក្សាអំពីភាពងាយរងគ្រោះ ឬក៏តួនាទីរបស់ស្ត្រីនិងបុរស ដែលដើរតួជាភ្នាក់ងារនាំមកនូវការផ្លាស់ប្តូរ ចំណុចដំបូងដែលត្រូវធ្វើគឺជាការវិភាគអំពីភាពខុសគ្នានៃទំនាក់ទំនងរបស់ស្ត្រី និងបុរសជាមួយធនធានបរិស្ថាន។ ស្ត្រី និងបុរសមានទំនាក់ទំនងខុសៗគ្នាទៅនឹងបរិស្ថានដោយមានហេតុផលផ្សេងៗដូចខាងក្រោម៖

- កម្រិតនៃភាពពឹងផ្អែកទៅលើធនធានបរិស្ថាន
- ទំនាក់ទំនងមិនស្មើគ្នានៅក្នុងការប្រើប្រាស់ការទទួលបាន និងការគ្រប់គ្រងធនធានផ្សេងៗ និងនៅក្នុងការចែករំលែកផលប្រយោជន៍
- ភាពជាម្ចាស់កម្មសិទ្ធិ និងសិទ្ធិទទួលបានធនធាន និង
- ចំណេះដឹងខុសៗគ្នាអំពីធនធាន ផលិតផល និងបញ្ហាខាងបរិស្ថានរបស់ពួកគេ

ដូចបានពិភាក្សានៅក្នុងចំណុច៤.២នៅពេលដែលប្រព័ន្ធអេកូឡូស៊ីកាន់តែងាយផុយស្រួយ ហើយធនធានធម្មជាតិត្រូវបានបាត់បង់ទាំងស្រុងឬក៏ពិបាកនឹងទទួលបាន ដូច្នេះសហគមន៍ក្រីក្រដែលរស់នៅពឹងផ្អែកលើធនធានទាំងនោះ

សម្រាប់ការរស់រានមានជីវិត នឹងរងផលប៉ះពាល់បំផុត ជាពិសេសស្ត្រី មនុស្សចាស់ និងកុមារ។

ដោយសារតែស្ត្រីប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិតាមរបៀបមួយដែលខុសពីបុរស ហើយការថយចុះនៃធនធានធម្មជាតិផ្តល់ផលប៉ះពាល់ដល់ពួកគេខុសៗគ្នា ដូច្នេះគំរូនៃគុណវិបត្តិទាំងនេះអាចកើនឡើងដោយសារការផ្លាស់ប្តូរ ឬការបាត់បង់ធនធានធម្មជាតិដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍៖ ស្ត្រីនៅតាមជនបទនៅក្នុងប្រទេសកំពុងអភិវឌ្ឍ គឺជាអ្នកផលិតស្បៀងអាហារដ៏សំខាន់។ តួនាទីរបស់ពួកគេនៅក្នុងផលិតកម្មកសិកម្ម គឺពិតជាសំខាន់សម្រាប់ស្ថានភាពអាហារូបត្ថម្ភរបស់ក្រុមគ្រួសារ ក៏ដូចជាការបង្កើតប្រភពប្រាក់ចំណូលផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយជារឿយៗ កសិករដែលជាស្ត្រីត្រូវបានគេមើលរំលង នៅក្នុងការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រកសិកម្ម ឬនៅក្នុងកិច្ចការដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ ជារឿយៗ កសិករត្រូវបានមើលឃើញថាគឺជា "បុរស ដែលជាអ្នកបង្កើតគោលនយោបាយ អ្នករៀបចំផែនការនិងអ្នកផ្តល់សេវាផ្នែកកសិកម្ម។ ដោយសារវិស័យកសិកម្មងាយប្រឈមជាមួយនឹងហានិភ័យនៃគ្រោះរាំងស្ងួត និងការធ្លាក់ភ្លៀងមិនទៀងទាត់ ដូច្នេះមានន័យថាការប្រែប្រួលអាកាសធាតុនឹងបង្កឱ្យមានគ្រោះថ្នាក់ដល់សន្តិសុខស្បៀងក៏ដូចជា សុខុមាលភាពរបស់ក្រុមគ្រួសារ និងសមត្ថភាពក្នុងការរស់រានមានជីវិតរបស់ពួកគេ (FAO, 2007)។

នៅក្នុងសាធារណរដ្ឋដូមីនីកា ស្ត្រីៗដែលរស់នៅតាមទីក្រុងកំពុងតែរស់នៅក្នុងវិស័យបន្ទាប់បន្សំ ឧទាហរណ៍នៅក្នុងទីក្រុងសង់តូ ដូមីញហ្គោ មានស្ត្រីជាច្រើននាក់ដែលដើរតួជាមេគ្រួសារកំពុងតែទទួលខុសត្រូវលើការផ្គត់ផ្គង់ទឹកសម្រាប់ក្រុមគ្រួសារ។ នៅក្នុងតំបន់ដែលគ្មានអណ្តូងបូមទឹកស្អាត ស្ត្រីត្រូវតែធ្វើដំណើរឆ្ងាយដើម្បីបានទឹកឬក៏ទិញទឹក ដូច្នេះធ្វើឱ្យក្រុមគ្រួសារដែលមានប្រាក់ចំណូលទាបមិនអាចទទួលបានទឹកដែលមានគុណភាព (Meyreles, 2004)។ ការប្រែប្រួលអាកាសធាតុអាចមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើស្ថានភាពនៃក្រុមគ្រួសារដែលកំពុងតែរស់នៅក្នុងស្ថានភាពទាំងនេះដែលនឹងជះឥទ្ធិពលលើសុខភាព និងប្រាក់ចំណូលរបស់ពួកគេតាមរបៀបជាច្រើន។

### ៤.៣.៣ តួនាទីរបស់ស្ត្រីនៅក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

ដោយសារតែភាពងាយរងគ្រោះរបស់ស្ត្រីមានកម្រិតខ្ពស់ជាង ដែលជាលទ្ធផលនៃវិសមភាពផ្នែកសង្គមសេដ្ឋកិច្ចជាប្រវត្តិសាស្ត្រ និងកំពុងមានសព្វថ្ងៃ ការចូលរួមរបស់ពួកគេនៅក្នុងគម្រោងនៃការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុពិតជាសំខាន់។ លើសពីនេះទៅទៀត ការនេះអាចត្រូវបានរំពឹងទុកថា នៅក្នុងទំនាក់ទំនងរបស់ស្ត្រីទៅនឹងធនធានធម្មជាតិតាមរយៈការប្រើប្រាស់ដី និងទឹកដោយភាពប្រុងប្រយ័ត្ន ការកសាងទំនប់ដើម្បីជៀសវាងទឹកជំនន់ និងប្រភេទនៃសកម្មភាពដែលពាក់ព័ន្ធដទៃទៀតអាចចូលរួមជាបដិភាគដ៏សំខាន់នៅក្នុងការប្រឈមជាមួយហានិភ័យនៃអាកាសធាតុ។ ឧទាហរណ៍មួយគឺនៅក្នុងសហគមន៍ គីម៉ូសា នៅក្នុងប្រទេសសេណេហ្គាល ដែលការច្រោះដីកំពុងតែធ្វើឱ្យទឹកមានកាន់តែតិចទៅៗ។ ដីជាតិនៅក្នុងដីដែលធ្លាប់ប្រើប្រាស់សម្រាប់ការដាំដំណាំត្រូវបានច្រោះដែលជាហេតុនាំឱ្យយុវជន និងយុវនារីត្រូវធ្វើចំណាកស្រុកទៅធ្វើការនៅតាមទីក្រុង។ អង្គការស្ត្រីបានជួយគ្រប់គ្រងលើការច្រោះ ដីជាតិដីនេះ ដោយកសាងប្រឡាយទឹកនៅក្នុងទ្រង់ទ្រាយជារូបព្រះច័ន្ទពាក់កណ្តាលដើម្បីស្តុកទឹក ស្តារដីកសិកម្ម និងធ្វើឱ្យទិន្នផលកសិកម្មប្រសើរឡើង (សូមមើលករណីសិក្សាទី២ក្នុងវគ្គទី៦)។

**ប្រអប់ទី៧៖** សកម្មភាពដ៏ជោគជ័យរបស់ស្ត្រីនៅក្នុងប្រទេសនីសេរីយ៉ា

នៅក្នុងឆ្នាំ ១៩៩៩ ស្ត្រីនៅក្នុងប្រទេសនីសេរីយ៉ាបានដឹកនាំចលនាពិភពលោកមួយដើម្បីបញ្ឈប់នូវការលេចធ្លាយឧស្ម័នធម្មជាតិ។ ក្រុមហ៊ុនប្រេងអន្តរជាតិនៅក្នុងប្រទេសរបស់គេកំពុងតែដុតឧស្ម័នធម្មជាតិភាគច្រើន ដើម្បីកាត់បន្ថយចំណាយលើការថែទាំ និងជៀសវាងពីការពាក់ព័ន្ធជាមួយឧស្សាហកម្មដទៃទៀត។ ចំនួននៃឧស្ម័នដែលត្រូវបានដុតនោះ មានបរិមាណច្រើនជាងនៅផ្នែកផ្សេងទៀតនៅក្នុងពិភពលោក ហើយបានបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាសច្រើនជាង នៅតំបន់ជិតវាលខ្សាច់សាហារ៉ាទាំងមូលទៅទៀត។ នៅក្នុងឆ្នាំ១៩៩៩ ស្ត្រីនៅតាមដែនដីសណ្ត នីសេរីយ៉ា បានរៀបចំការតវ៉ាព្រមគ្នានៅក្នុងប្រទេសនីសេរីយ៉ា និងនៅចក្រភពអង់គ្លេសដែលជាលទ្ធផលបានធ្វើឱ្យក្រុមហ៊ុនធំនៅក្នុងទីក្រុងឡុងបានបិទទ្វារ និងការបិទអណ្តូងប្រេងជាបណ្តោះអាសន្ន។ នៅពេលដែលការតវ៉ានៅតែបន្តក្រុមហ៊ុនបានប្រើប្រាស់កម្លាំងយោធា ហើយនៅក្នុងការប្រឈមនោះ មានមនុស្សចំនួន ២០០នាក់បានស្លាប់ និងមានស្ត្រីជាច្រើនត្រូវបានគេចាប់រំលោភ។ មានស្ត្រីរាប់រយនាក់ដែលជាសមាជិកនៃអង្គការស្ត្រី Niger Delta សម្រាប់ភាពយុត្តិធម៌បានខឹងសំបារយ៉ាងខ្លាំងចំពោះការចាប់រំលោភនិងការសម្លាប់បែបនេះ។ ពួកគេក៏បានរៀបចំការតវ៉ាមួយ ក៏ដូចជាសិក្ខាសាលាជាច្រើនអំពីការផ្សព្វផ្សាយផ្នែកនយោបាយដល់ស្ត្រី។ ចុងបញ្ចប់ នៅក្នុងខែមករាឆ្នាំ២០០៦ ដោយសារតែសម្ពាធខាងសង្គម តុលាការនៃប្រទេសនីសេរីយ៉ាបានលុបចោលនូវអាជ្ញាប័ណ្ណក្រុមហ៊ុនឧស្ម័ននេះហើយបានបញ្ជាឱ្យបញ្ឈប់ការបញ្ចេញឧស្ម័នធម្មជាតិនៅក្នុងអណ្តូងប្រេង នៅតំបន់ប៉ែកខាងលិចនៃដីសន្ត Nigerdelta។ សកម្មភាពជាអន្តរជាតិដែលមិនធ្លាប់មានពីមុនមកនេះបង្ហាញថា ស្ត្រីគឺជាភ្នាក់ងារដ៏សំខាន់សម្រាប់ការផ្លាស់ប្តូរដែលអាចជួយកាត់បន្ថយដល់ការប្រែប្រួលអាកាសធាតុ។

*ប្រភព៖ ដកស្រង់ចេញពី Turner and Brownhill, 2006*

## ៤.៣.៤ ការគ្រប់គ្រងហានិភ័យ និងការផ្តល់ភាពអង់អាចដល់ស្ត្រី

ដូចបានពណ៌នាខាងលើ ភាគច្រើនស្ត្រីត្រូវបានមើលឃើញថាជាជនរងគ្រោះដោយការប្រែប្រួលអាកាសធាតុ និងមិនមែនជាភ្នាក់ងារនៃការផ្លាស់ប្តូរជាវិជ្ជមានដែលអាចចូលរួមដល់យុទ្ធសាស្ត្រនៃការបន្សាំនោះទេ។ លើសពីនេះទៅទៀត ជារឿយៗស្ត្រីមិនត្រូវបានទទួលស្គាល់ថា គ្រោះមហន្តរាយធម្មជាតិ ក៏អាចឱ្យស្ត្រីទទួលបានឱកាសមួយដ៏ពិសេសដើម្បីជម្រុញ និងផ្លាស់ប្តូរតួនាទីយេនឌ័រនៅក្នុងសង្គម (Enarson, 2000)។ ឧទាហរណ៍ នៅក្នុង ឆ្នាំ១៩៩៨ សហគមន៍ ឡាម៉ាស៊ីកា នៅក្នុងប្រទេសហុងឌូរ៉ាស់ បានទទួលវគ្គបណ្តុះបណ្តាលសហគមន៍ អំពីរញ្ចេចយេនឌ័រទាក់ទងនឹងការជូនដំណឹងជាមុន និងប្រព័ន្ធនៃហានិភ័យ។ នៅក្នុងវគ្គបណ្តុះបណ្តាលនេះ ស្ត្រីនៅក្នុងសហគមន៍បានទទួលខុសត្រូវលើការត្រួតពិនិត្យប្រព័ន្ធនៃការជូនដំណឹងជាមុនដែលត្រូវបានគេបោះបង់ចោល។ ប្រាំមួយខែក្រោយមកក្នុងកំឡុងពេលខ្យល់ព្យុះហ៊ីរីខេនមីត (Hurricane Mitch) របាយការណ៍បានឱ្យដឹងថា គ្មាននរណាម្នាក់បានស្លាប់នៅឡាមេស៊ីកាឡើយ ដោយសារតែរដ្ឋាភិបាលបានជម្លៀសប្រជាជនទាន់ពេល (Sanchez del Valle, 2000)។ ស្ត្រីបានដើរតួយ៉ាងសកម្មៗក្នុងផ្នែកមួយដែលពីដើមត្រូវបានចាត់ទុកថាជាផ្នែករបស់បុរស។ ឧទាហរណ៍មួយទៀតគឺអង្គការក្រៅរដ្ឋាភិបាល Puntos de Encuentro នៅក្នុង Nicaragua បន្ទាប់ពីខ្យល់ព្យុះ ហ៊ីរីខេនមីត បានរៀបចំនូវយុទ្ធនាការព័ត៌មានមួយដែលមានឈ្មោះថា "អំពើហិង្សាលើស្ត្រី គឺជាគ្រោះមហន្តរាយមួយដែលបុរសអាចទប់ស្កាត់បាន។" យុទ្ធនាការបានបង្ហាញអំពីប្រសិទ្ធភាពដែលបុរសបានផ្លាស់ប្តូរអាកប្បកិរិយាចំពោះអំពើហិង្សាទៅលើស្ត្រី និងដោះស្រាយបញ្ហារចនាសម្ព័ន្ធនៃអំណាចដែលមានក្នុងពេលបច្ចុប្បន្ន (Pan American Health Organization, 1998 ដូចបានដកស្រង់នៅក្នុង WEDO, 2008)។

ឧទាហរណ៍មួយទៀតចេញពីប្រទេសបង់ក្លាដេស ដែលអាកាសធាតុបានប្រែប្រួលក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ហើយភ្លៀងបានធ្លាក់កាន់តែខ្លាំងឡើងៗ និងកាន់តែពិបាកក្នុងការព្យាករណ៍។ ទឹកជំនន់នៅឆ្នាំ២០០៤បានបន្សល់ឱ្យមានការខូចខាតយ៉ាងខ្លាំងដោយមានមនុស្សចំនួន២៨០នាក់បានបាត់បង់ជីវិត ហើយមានមនុស្សចំនួនជិតបួនលាននាក់បានជម្លៀសខ្លួនចេញពីផ្ទះសំបែង និងរាប់ពាន់នាក់ផ្សេងទៀតបានភៀសខ្លួនដោយគ្មានអាហារ ឬជម្រក (MASS, 2004)។ នៅក្នុងស្រុកកាបានដា (Gaibandha) ស្ត្រីម្នាក់ឈ្មោះ សាហេណា បានកំពុងព្យាយាមដោះស្រាយបញ្ហាទឹកជំនន់ទាំងនេះ។ នាងបានរៀបចំគណៈកម្មការនៅក្នុងសហគមន៍របស់នាង ដើម្បីរៀបចំស្ត្រីៗពេលដែលទឹកជំនន់មកដល់។ គណៈកម្មការនេះបានបង្រៀនដល់ស្ត្រីឱ្យចេះធ្វើចង្ក្រានឥដ្ឋចល័តលើផ្ទះរបស់ពួកគេ និងអំពីរបៀបប្រើវិទ្យុដើម្បីដឹងព័ត៌មានអំពីទឹកជំនន់ ឬក៏ការប្រែប្រួលអាកាសធាតុ។ ទោះបីជានាងសាហេណា បានប្រឈមមុខនឹងការប្រឆាំងពីសំណាក់ប្តីរបស់នាង និងស្ត្រីនៅក្នុងសហគមន៍ក៏ដោយ ប៉ុន្តែនាងបានក្លាយជាប្រធាននៃគណៈកម្មការ ហើយនាងបានទទួលការគោរពពីសហគមន៍របស់នាង។ កិច្ចខិតខំប្រឹងប្រែងរបស់នាងបានសង្គ្រោះជីវិតមនុស្សជាច្រើន និងបានផ្តល់ភាពអង់អាចដល់ស្ត្រីៗផ្សេងទៀត(Oxfam, 2008)។

ក្នុងកំឡុងពេលនៃព្យុះ ហ៊ីរីខេន ចច នៅក្នុងសាធារណរដ្ឋដូមីនីកា អង្គការស្ត្រីក្នុងស្រុកនៅតាមជនបទ និងតាមទីក្រុងត្រូវតែដោះស្រាយស្ថានភាពនៃទីជម្រកជាមុនសិន។ ដោយសារតែពួកគេធ្វើការជាមួយនឹងដើមរុក្ខជាតិឱសថ ដូច្នេះស្ត្រីៗអាចជួយជាឱសថនិងផ្តល់ការថែទាំមុនពេលដែលបុគ្គលិកពេទ្យបានមកដល់។ អង្គការរបស់គេក៏ជួយជាកម្លាំងក្នុងការកសាងឡើងវិញ ទទួលជំនួយសម្រាប់ការសាងសង់លំនៅស្ថានសម្រាប់សហគមន៍ និងជួយស្ត្រីឱ្យចូលរួមនៅក្នុងគម្រោងប្រាក់ឥណទានសម្រាប់ការសាងសង់ឡើងវិញ។ ការអនុវត្តបែបនេះបានផ្តល់ឱ្យស្ត្រីនូវស្ថានភាពមួយថ្មីនៅក្នុងសហគមន៍របស់ពួកគេ និងបានផ្លាស់ប្តូររបៀបដែលស្ត្រីត្រូវបានគេមើលឃើញ និងតួនាទីរបស់ពួកគេនៅក្នុងការធ្វើសេចក្តីសម្រេច (Meyreles, 2000)។

## ៤.៤ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការទទួលបានធនធានដោយស្មើភាព

ការយល់ដឹងអំពីទំនាក់ទំនងរវាងយេនឌ័រ និងការអភិវឌ្ឍដែលមាននិរន្តរភាព ទាមទារឱ្យមានការវិភាគអំពីបែបផែននៃការប្រើប្រាស់ចំណេះដឹង និងជំនាញដែលទាក់ទងនឹងការគ្រប់គ្រង ការប្រើប្រាស់ និងការអភិរក្សធនធានធម្មជាតិ។ មានតែការអនុវត្តវិធីសាស្ត្រយេនឌ័រតែមួយគត់ដែលធ្វើឱ្យទស្សនៈយល់ដឹងអំពីទំនាក់ទំនងដែលមនុស្សបានកសាងជាមួយនឹងប្រព័ន្ធអេកូឡូស៊ី មានភាពកាន់តែច្បាស់ និងពេញលេញ។ បុរស និងស្ត្រីប្រឈមមុខជាមួយនឹងការពិតនៃសង្គម សេដ្ឋកិច្ច និងបរិស្ថានរបស់ពួកគេតាមរបៀបខុសៗគ្នា។ របៀបដែលពួកគេចូលរួមមានលក្ខណៈខុសគ្នាអាស្រ័យទៅតាមវ័យ កម្រិតនៃស្ថានភាពសង្គមសេដ្ឋកិច្ច និងវប្បធម៌។ ឧទាហរណ៍ ស្ត្រីទទួលបានតែ ៥% ប៉ុណ្ណោះនៃសម្បទានដែលពិភពលោកទាំងមូលទទួលបានដើម្បីគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ។

បន្ថែមពីលើកត្តារុក្ខសាស្ត្រ និងកត្តាថាមពលដែលបានរៀបរាប់នៅក្នុងវគ្គដទៃទៀតនៃសៀវភៅបណ្តុះបណ្តាលនេះ កត្តាធនធានខាងក្រោមពាក់ព័ន្ធទៅនឹងការរកឱ្យឃើញនូវការឆ្លើយតបទៅនឹងការបន្សាំប្រកបដោយសមធម៌ និងទៅនឹងការប្រែប្រួលអាកាសធាតុ។

## ៤.៤.១ ទឹក និងអនាម័យ

មូលហេតុនៃការប្រែប្រួលអាកាសធាតុ បានធ្វើឱ្យកើនឡើងនូវបរិមាណទឹកសម្រាប់ប្រើប្រាស់នៅក្នុងតំបន់ត្រូពិកក្តៅ ហើយសើម និងនៅតាមប្រទេសដែលមានរយៈទទឹងខ្ពស់ ហើយក៏បានធ្វើឱ្យធ្លាក់ចុះនូវបរិមាណទឹក និងធ្វើឱ្យមានការកើនឡើងនូវគ្រោះរាំងស្ងួតនៅតាមប្រទេសដែលមានរយៈទទឹងកណ្តាល និងទាបក្នុងតំបន់ដែលមានទឹកភ្លៀងធ្លាក់តិចតួច។ ការប្រែប្រួលទាំងនេះនាំឱ្យមនុស្សជាងរាប់រយលាននាក់ប្រឈមនឹងការកើនឡើងនៃភាពតានតឹងទាក់ទងនឹងទឹក។ មនុស្សច្រើនជាង១.០០០លាននាក់ នៅក្នុងប្រទេសដែលមានការអភិវឌ្ឍតិចតួចមិនទទួលបានទឹកសម្រាប់ផឹក ហើយមនុស្សចំនួន ២.៤០០លាននាក់ខ្វះនូវសេវាអនាម័យត្រឹមត្រូវ។

នៅផ្នែកភាគច្រើននៃពិភពលោកនៅតាមតំបន់ដាច់ស្រយាល និងទីក្រុង ស្ត្រីៗ និងក្មេងស្រី ត្រូវទទួលខុសត្រូវចេញទៅដងទឹកសម្រាប់ការចំអិនអាហារ សំអាត សុខភាព និងអនាម័យ ហើយប្រសិនបើពួកគេមានដី ពួកគេនឹងត្រូវការទឹកដើម្បីដាំដំណាំ។ ការផ្គត់ផ្គង់ទឹកដែលមានកម្រិត សេវាដឹកជញ្ជូនទឹក និងជាតិបំពុល គឺជាកត្តាដែលបង្កឱ្យមានគ្រោះថ្នាក់ដល់ការរស់រានមានជីវិតរបស់ស្ត្រី និងក្រុមគ្រួសាររបស់ពួកគេ។

## ៤.៤.២ ជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ី

មានការប្រមាណថា គ្រប់ពេលនៃការកើនឡើងសីតុណ្ហភាពដល់១អង្សាសេ ធ្វើឱ្យពពួកសត្វរត់ចេញពីតំបន់ដែលបានរស់នៅរហូតទៅដល់១៦០គីឡូម៉ែត្រ នេះដោយសារតែគ្រាប់ធញ្ញជាតិត្រូវបានបែកខ្ញែក ហើយទីលំនៅក៏ត្រូវផ្លាស់ប្តូរ។ ល្បឿននៃការប្រែប្រួលអាកាសធាតុដែលកំពុងតែកើតឡើងនេះនឹងមិនអនុញ្ញាតឱ្យមានការបន្សាំបែបធម្មជាតិឡើយ ហើយនឹងដាក់ជាការពិសោធន៍ទៅលើភាពងាយស្ទ្រាំរបស់ប្រព័ន្ធសង្គមសេដ្ឋកិច្ច។ លើសពីនេះទៅទៀត ការប្រែប្រួលនៃវិទ្ធសាស្ត្រដើមកំណើត (anthropogenic) នៅក្នុងករណីភាគច្រើនបានកាត់បន្ថយជម្រើសក្នុងការស្វែងរកនូវទីតាំងដ៏សមរម្យដើម្បីធ្វើការបំលាស់ទី។ ប្រសិនបើពពួកសត្វមិនអាចរកឃើញទីលំនៅថ្មីដើម្បីផ្លាស់ប្តូរវដ្តនៃជីវិតរបស់ពួកវាទេ ឬប្រសិនបើពួកវាមិនមានដំណើរការនៃការវិវត្តដែលនាំឱ្យមានលក្ខណៈរូបរាងថ្មីទេនោះ ពួកវាអាចនឹងរងនូវការផុតពូជជាមិនខាន។ បរិស្ថានវិទូបានធ្វើការសន្និដ្ឋានថា រវាងពី១៥-៣៧%នៃពពួកសត្វធម្មជាតិអាចនឹងត្រូវបំផ្លាញនៅឆ្នាំ២០៥០ ដែលជាលទ្ធផលនៃការប្រែប្រួលអាកាសធាតុ និងការផ្លាស់ទីលំនៅ (Thullier, 2007)។ ការសិក្សាបានបង្ហាញថា ពពួកសត្វខ្លះងាយនឹងរងគ្រោះជាងពពួកសត្វផ្សេងទៀត ដោយសារតែលទ្ធផលនៃការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍ គេបានព្យាករថា ប្រសិនបើការសាយភាយ GHG ក្នុងពេលបច្ចុប្បន្ននៅតែបន្តមាន នោះពពួករុក្ខជាតិនៅតាមតំបន់ភ្នំរហូតដល់ទៅ៦០% នឹងអាចត្រូវបំផ្លាញ (Thullier, 2007) ហើយផ្កាថ្មនឹងត្រូវបែកពណ៌ជារៀងរាល់ពីរឆ្នាំ (Donner et al., 2007)។

ការប្រែប្រួលនៃការធ្លាក់ភ្លៀង ការរលាយទឹកកក និងការថយចុះនៃផែនទឹកកកនឹងជះឥទ្ធិពលលើកម្រិតនៃទឹកទន្លេ និងទឹកបឹង ហើយការទទួលបានទឹកសម្រាប់ផឹកក៏មានកម្រិតផងដែរ។ នេះពិតជាសំខាន់ខ្លាំងណាស់សម្រាប់តំបន់ដែលទទួលបានទឹកសម្រាប់ផឹកចេញពីភ្នំព្រិល និងការរលាយទឹកកក ដោយសារមនុស្សចំនួនមួយភាគប្រាំមួយនៃប្រជាជនពិភពលោករស់នៅតាមតំបន់ទាំងអស់នេះ។ អ្នកស្រុកដែលរស់នៅលើដីស្ងួតប្រឈមមុខជាមួយនឹងភាពរាំងស្ងួតកាន់តែញឹកញាប់ និងកាន់តែមានរយៈពេលវែង។ ខណៈពេលដែលស្ថានភាពនេះកាន់តែអាក្រក់ មនុស្សរាប់លាននាក់នឹងត្រូវផ្លាស់ទីលំនៅ នៅពេលពួកគេឃើញប្រភពទឹកកាន់តែខ្សត់ទៅៗ។

មានការរំពឹងទុកដែរថា ការឆ្លើយតបបែបធម្មជាតិរបស់មនុស្សចំពោះការកើនឡើងនូវសីតុណ្ហភាព នឹងត្រូវបង្កើននូវតម្រូវការទឹក សម្រាប់ទីក្រុងនិងសម្រាប់កសិកម្ម។ ការកើនឡើងនេះ នឹងធ្វើឱ្យដីមានសំណើមត្រូវបានប្រើច្រើនជ្រុល ដែលជាហេតុនាំឱ្យមានការថយចុះនូវលំហូរទឹកនៅក្នុងទន្លេ និងស្ទឹង។ ការកើនឡើងសីតុណ្ហភាពនឹងបណ្តាលឱ្យមានការកើនឡើងនូវរំហួតទឹក ការថយចុះទឹកភ្លៀង និងការជ្រាបទឹក ហើយបន្ទាប់មក នឹងធ្វើឱ្យបរិមាណនៃទឹកសាប និងសំណើមដីមានការថយចុះ។ ភ្លើងឆេះព្រៃក៏ជាហានិភ័យមួយដែលអាចនឹងកើនឡើងផងដែរ។

ស្ត្រី និងបុរសមានតួនាទីខុសៗគ្នានៅក្នុងកិច្ចខិតខំអភិរក្សសហគមន៍ ហើយជារឿយៗស្ត្រីចូលរួមនៅក្នុងការជ្រើសរើសពូជ និងការរក្សាទុក។ ស្ត្រីមានចំណេះដឹងយ៉ាងច្រើនអំពីរុក្ខជាតិ និងសត្វនៅក្នុងបរិស្ថានរបស់ពួកគេ និងវិធីសាស្ត្រអភិរក្ស ហើយបានប្រើប្រាស់ធនធានក្នុងស្រុកតាមបែបប្រពៃណីសម្រាប់អាហារ ថ្នាំសង្កូវ និងថាមពល។ មានការរកឃើញថាស្ត្រីទុកលុយពី ៩០-៩៥% ដែលពួកគេទទួលបានពីជីវចម្រុះទៅវិនិយោគដើម្បីធ្វើឱ្យគុណភាពជីវិតក្រុមគ្រួសាររបស់ពួកគេប្រសើរឡើង។ នៅពេលដែលពពួករុក្ខជាតិសត្វបានបាត់បង់ ផលប៉ះពាល់នឹងមានទៅលើក្រុមងាយរងគ្រោះបំផុតដែលជាស្ត្រី។ ខណៈពេលដែលប្រព័ន្ធនៃការគ្រប់គ្រងជីវចម្រុះពឹងផ្អែកលើចំណេះដឹងជំនាញ និងកម្លាំងរបស់ស្ត្រី ជារឿយៗការធ្វើសេចក្តីសម្រេចរួមទាំងការទទួលបានបច្ចេកវិទ្យា ឬព័ត៌មានថ្មីបែរជាមិនបានបញ្ចូលស្ត្រីទៅវិញ (FAO, 1999)។

ការប្រើប្រាស់ថាមពល និងផលិតកម្មនៃថាមពលក៏ជាផ្នែកដែលស្ត្រី និងបុរសមានតួនាទី ព័ត៌មាន និងទស្សនៈខុសគ្នាផងដែរ។សកម្មភាពសន្សំថាមពលនឹងជះឥទ្ធិពលលើសកម្មភាពរបស់ស្ត្រីនៅផ្ទះ ហើយសកម្មភាពអាចស៊ីពេលច្រើនថែមទៀតផង។ នៅក្នុងស្ថានភាពដែលថាមពលមានកម្រិតតិចតួច ជាពិសេសនៅតាមទីក្រុងដែលសកម្មភាពពឹងផ្អែកលើធនធានថាមពលអាចបង្កើតឱ្យមានស្ថានភាពដែលគំរាមកំហែងដល់ជីវិត ដោយសារតែការតភ្ជាប់ភ្លើងខុសច្បាប់ឬមិនត្រឹមត្រូវ។ម៉ាស៊ីនភ្លើង និងបច្ចេកវិទ្យាបង្កើតថាមពលដទៃទៀតអាចបង្កឱ្យមានភាពកខ្វក់ខ្ពស់ជាពិសេសនៅក្នុងផ្ទះដែលមានស្ត្រី និងកុមារ។ នៅក្នុងសាធារណរដ្ឋដូមីនីកានៅរវាងឆ្នាំ១៩៦០ និង២០០០ ភាគច្រើននៃគ្រោះមហន្តរាយតូចៗបានកើតឡើងនៅតាមផ្ទះជនក្រីក្រក្នុងទីក្រុង ដោយសារតែមានអគ្គិភ័យដែលបង្កឡើងដោយការផ្ទុះខ្សែភ្លើង (IFC និង LA RED, 2002)។ ការទទួលបានថាមពលសុវត្ថិភាព និងភាពស្អាតបាត គឺជាផ្នែកមួយដ៏សំខាន់ដើម្បីជៀសវាងស្ថានភាពនៃគ្រោះមហន្តរាយ និងយុទ្ធសាស្ត្របន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

### ៤.៤.៣ កសិកម្ម និងសន្តិសុខស្បៀង

ប្រព័ន្ធអេកូឡូស៊ីផ្អែកកសិកម្ម និងសន្តិសុខស្បៀង មានភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុយ៉ាងខ្លាំង។ ប្រការនេះមានផលប៉ះពាល់អវិជ្ជមានទៅលើម្ចាស់ដីតូចៗ កសិករ និងអ្នកនេសាទ និងការធ្លាក់ចុះ និងឡើងចុះនៃទិន្នផលអាស្រ័យតាមតំបន់។

តាំងពីការអនុវត្តរបរកសិកម្មបានចាប់ផ្តើមពីជាង១២.០០០ឆ្នាំមុន មានរុក្ខជាតិប្រមាណ ៧.០០០ប្រភេទ ដែលត្រូវបានដាំដុះដើម្បីយកមកធ្វើជាអាហារ ហើយ ៩០% នៃអាហាររបស់យើង ក្នុងពេលសព្វថ្ងៃត្រូវបានយកចេញពីរុក្ខជាតិចំនួនតែ១៥ប្រភេទ និងសត្វចំនួនប្រាំបីប្រភេទតែប៉ុណ្ណោះ។ ការអភិរក្សអាហារធម្មជាតិដែលបន្សល់ទុកមកពីដូនតាទាំងនេះ អាចផ្តល់ជាជម្រើស ដូច្នេះនៅពេលអនាគតប្រភេទថ្មីៗអាចត្រូវបានបង្កើតឡើងដែលអាចធន់ទៅនឹងការប្រែប្រួលអាកាសធាតុដ៏ខ្លាំងក្លានេះបាន។ ជាអកុសល អាហារបែបធម្មជាតិជាច្រើននេះកំពុងតែស្ថិតនៅក្នុងគ្រោះថ្នាក់នៃការផុតពូជទៅហើយ។ ឧទាហរណ៍ គេបានព្យាករណ៍ថា មួយភាគបួននៃប្រភេទដំឡូងព្រៃនឹងត្រូវបាត់បង់នៅក្នុង៥០ឆ្នាំខាងមុខ (CBD,

2007)។ មានការទស្សន៍ទាយមួយដែលត្រូវបានធ្វើឡើងដោយ IPCC បានបង្ហាញថា កសិកម្មនៅក្នុងប្រទេសដែលមានជាតុអាកាសក្តៅនឹងងាយរងផលប៉ះពាល់ជាងប្រទេសដែលមានជាតុអាកាសបង្គួរ។

នៅក្នុងវិស័យកសិកម្ម ស្ត្រីតាមជនបទនៅក្នុងប្រទេសអភិវឌ្ឍតិចតួចគឺជាអ្នកដែលផលិតអាហារដ៏សំខាន់បំផុត។ វិស័យនេះងាយប្រឈមនឹងហានិភ័យនៃគ្រោះរាំងស្ងួត និងការប្រែប្រួលនៃការធ្លាក់ភ្លៀងនាពេលខាងមុខ។

វេទិកាគោលនយោបាយ អូស្លូ ផ្តល់ជាអនុសាសន៍អំពីការប្រើប្រាស់ដី សិទ្ធិកាន់កាប់ដីធ្លី និងទិដ្ឋភាពផ្នែកច្បាប់ដែលពាក់ព័ន្ធនឹងការពិចារណាអំពីជនក្រីក្រនៅពេលដែលមើលទៅលើការប្រែប្រួលអាកាសធាតុ។ នៅក្នុងទិដ្ឋភាពទាំងអស់នេះ ស្ត្រីមានស្ថានភាពជាក់លាក់ ដែលអាចនាំឱ្យពួកគេជួបនូវគុណវិបត្តិ (Oslo Policy Forum Report, 2008)។

## ៤.៤.៤ តំបន់ឆ្នេរ

ចំពោះតំបន់ឆ្នេរ និងការកើនឡើងនូវនីវ៉ូទឹកសមុទ្រដែលបណ្តាលមកពីការរលាយទឹកកកនឹងបង្កើតឱ្យមានផលប៉ះពាល់មួយចំនួនដូចជា៖ ទឹកជំនន់នៅតាមតំបន់ឆ្នេរ និងទឹកប្រៃហូរចូលទឹកសាបដូចជា estuaries និង aquifers។ IPCC បញ្ជាក់ថា ប្រទេសកំពុងអភិវឌ្ឍនឹងត្រូវប្រឈមជាមួយនឹងឧបសគ្គធំៗនៅក្នុងការបន្សាំទៅនឹងការប្រែប្រួលទាំងនេះ។ លើសពីនេះទៅទៀត តំបន់ដែលមានដង់ស៊ីតេប្រជាជនច្រើននឹងត្រូវរងផលប៉ះពាល់ដោយបាតុភូតដទៃទៀត ដូចជាព្យុះត្រូពិក។ តំបន់ឆ្នេរងាយនឹងរងការខូចខាតដែលបណ្តាលមកពីទឹកជំនន់ និងខ្យល់ព្យុះ ហើយប្រហែលជា៣០%នៃដីសើមតាមតំបន់ឆ្នេរអាចនឹងត្រូវបាត់បង់។

ស្ត្រីធ្វើការនៅក្នុងវិស័យនេសាទ ជាពិសេសក្នុងការងាររក្សាទុកត្រីបានយូរ ការរៀបចំយកទៅផ្សារ ការនេសាទខ្នាតតូច និងសកម្មភាពដែលនៅជិតច្រាំង។ ដោយសារតែពួកគេផ្តោតទៅលើសកម្មភាពដែលជារឿយៗជាមុខរបរបន្ទាប់បន្សំ ដូច្នេះការងាររបស់ស្ត្រីដែលពាក់ព័ន្ធនឹងការនេសាទ មិនត្រូវបានចាត់ទុកជាអាទិភាពនៅក្នុងការវិភាគផ្នែកសេដ្ឋកិច្ច ឬការវិនិយោគធនធាននោះទេ។ ដោយសារតែការចូលរួម និងភាពជាតំណាងរបស់ស្ត្រីមានកម្រិតនៅក្នុងការធ្វើសេចក្តីសម្រេច ដូច្នេះវាបាននាំឱ្យផលប្រយោជន៍របស់ស្ត្រីមិនត្រូវបានបញ្ចូលទៅក្នុងផែនការតំបន់ឆ្នេរ (CIDA, n.d.)។

## ៤.៤.៥ ការប្រែក្លាយទៅជាវាលខ្សាច់

ការប្រែប្រួលអាកាសធាតុនឹងពន្លឿនដល់ការបាត់បង់ព្រៃឈើ ដូច្នេះវាធ្វើឱ្យដីប្រែទៅជាវាលខ្សាច់។ រដូវភ្លៀងកាន់តែខ្លី ហើយភាពរាំងស្ងួតកាន់តែកើនឡើង ការច្រោះដី និងដីគ្មានជីជាតិនឹងកាន់តែក្លាយជារឿងធម្មតា។ ការថយចុះនៃគម្របព្រៃឈើធ្វើឱ្យការធ្លាក់ភ្លៀងមានការថយចុះ ហើយធ្វើឱ្យទឹកហួតមានការកើនឡើង។ វដ្តដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុនេះក៏ផ្តល់ផលប៉ះពាល់ដល់ជីវភាពរបស់ប្រជាជននៅតាមជនបទផងដែរ។ បន្ថែមពីលើការគំរាមកំហែងលើសន្តិសុខស្បៀង និងទឹកសហគមន៍នៅតាមជនបទត្រូវប្រឈមជាមួយនឹងជម្លោះលើធនធានផ្សេងៗ ហើយត្រូវបង្ខំចិត្តធ្វើចំណាកស្រុក។ នៅក្នុងប្រទេសអាហ្វ្រិក គ្រោះរាំងស្ងួត និងទឹកជំនន់មានភាពកាន់តែក្តៅគគុក និងកាន់តែញឹកញាប់នៅក្នុងទសវត្សរ៍ថ្មីៗនេះ។ គ្រោះរាំងស្ងួត គឺជាកត្តាដ៏ធ្ងន់ធ្ងរបំផុតនៃការខ្វះស្បៀងអាហារដែលបណ្តាលឱ្យមានជំនួយសង្គ្រោះបន្ទាន់លើផ្នែកអាហាររហូតដល់៦០% (GTZ and OSS, 2007)។

តួនាទីបែបប្រពៃណី និងចំណេះដឹងរបស់ស្ត្រីនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការធ្វើកសិកម្មពិតជាសំខាន់ក្នុងការរក្សាទុកអាហារ ទឹក និងថ្នាំសង្កូវ។ នៅតាមតំបន់ដីស្ងួតនៅជុំវិញពិភពលោក ជាពិសេសនៅតំបន់ភាគច្រើននៃប្រទេសអាហ្វ្រិក ស្ត្រីរងផលប៉ះពាល់ដោយសារតែការច្រោះដី និងការថយចុះផលិតផលដំណាំនិងការចិញ្ចឹមសត្វ។ កត្តាផ្សេងទៀត

ដែលបណ្តាលឱ្យមានវិសមភាពស្ត្រីក្នុងការទទួលបានសេវាផ្សេងៗ និងការធ្វើសេចក្តីសម្រេចរួមមាន កង្វះភាពជាម្ចាស់លើដីធ្លី អនក្ខរកម្ម ធន្ទះនយោបាយ និងភាពលំអៀងផ្នែកយេនឌ័រ និងភាពតឹងរឹងខាងវប្បធម៌។

## ៤.៤.៦ សុខភាព

បញ្ហាសុខភាពភាគច្រើនដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុនឹងមានផលប៉ះពាល់អាក្រក់ច្រើន។ មានការប៉ាន់ប្រមាណថាក្នុងឆ្នាំ២០០០ ការប្រែប្រួលអាកាសធាតុបានបង្កឱ្យមានករណីជម្ងឺរាគចំនួន២,៤% នៅទូទាំងពិភពលោក និងជម្ងឺគ្រុនចាញ់ចំនួន៦%។ ជាទូទៅការប្រែប្រួលអាកាសធាតុនឹងមានផលប៉ះពាល់ទៅលើសុខភាពចំនួនបីប្រភេទ៖

១. ផលប៉ះពាល់ដោយផ្ទាល់នៃហេតុការណ៍អាកាសធាតុដ៏ធ្ងន់ធ្ងរ

២. បង្កើតជាជម្ងឺផ្សេងៗដែលបង្កឡើងដោយវិបត្តិបរិយាកាសដោយសារតែការប្រែប្រួលអាកាសធាតុ។

៣. ផលវិបាកផ្សេងទៀតទៅលើសុខភាព (ឧទាហរណ៍៖ ការប៉ះទង្គិចផ្លូវចិត្ត ការឆ្លងមេរោគ ជម្ងឺផ្លូវចិត្ត និងផលប៉ះពាល់អវិជ្ជមានទៅលើសន្តិសុខស្បៀងជាដើម) ដែលបង្កឡើងដោយប្រជាជនផ្លាស់ទីដោយសារតែបញ្ហាសេដ្ឋកិច្ច ការខូចខាតផ្នែកបរិស្ថាន ឬ ការកើតឡើងនូវជម្លោះដោយសារតែការប្រែប្រួលអាកាសធាតុ (អង្គការសុខភាពពិភពលោក ២០០៣)។

ការប្រែប្រួលអាកាសធាតុនឹងនាំឱ្យមានការកើនឡើងនូវកង្វះអាហារូបត្ថម្ភ និងជម្ងឺក្រពះ ជម្ងឺពោះវៀន ជម្ងឺផ្លូវដកដង្ហើម និងជម្ងឺឆ្លង។ រលកកំដៅ ទឹកជំនន់ និងគ្រោះមហន្តរាយនឹងនាំឱ្យមានការកើនឡើងនូវមរណភាព និងការប្រែប្រួលនៅក្នុងការឆ្លងជម្ងឺខ្លះៗ។ បន្ទុកសេវាសុខភាពកើនឡើងដោយសារការកើនឡើងនៃចំនួនអ្នកជម្ងឺ។ កុមារ ជាពិសេសក្មេងស្រី និងមនុស្សចាស់ងាយនឹងរងគ្រោះបំផុតពីកម្រិតនៃកំដៅ និងការរីករាលដាលនៃជម្ងឺ។ នៅក្នុងពេលនៃគ្រោះមហន្តរាយ និងការប្រែប្រួលបរិយាកាស ស្ត្រីនិងក្មេងស្រីត្រូវបានគេរំពឹងទុកឱ្យមើលថែទាំដល់សមាជិកនៃក្រុមគ្រួសារដែលមានជម្ងឺដែលតម្រូវឱ្យពួកគេឈប់សម្រាកពីការរកប្រាក់ចំណូលនិងការសិក្សា។ ស្ត្រី និងក្មេងស្រីអាចមានការលំបាកក្នុងការទទួលបានសេវាសុខភាព ដោយសារតែតម្លៃថ្នាំពេទ្យមានកម្រិតខ្ពស់ និងភាពតឹងរឹងនៃវប្បធម៌ដែលពាក់ព័ន្ធនឹងការដើរហើរ (Brody et al., 2008)។

## ៤.៤.៧ ផលប៉ះពាល់អវិជ្ជមាននៃការផ្តួចផ្តើមបន្សាំទៅលើវិសមភាពយេនឌ័រ និងដំណោះស្រាយដែលអាចមាន

ការវិភាគខាងក្រោម គឺជាវិធានការបន្សាំជាប្រព័ន្ធដោយផ្អែកលើសំណើដែលបង្កើតឡើងដោយ Aguilar et al. (2008)។ ផលប៉ះពាល់អវិជ្ជមាននៃការមិនពិចារណាអំពីទំនាក់ទំនងយេនឌ័រ គឺជាការធ្វើឱ្យមានវិសមភាពដដែល។ សំណើនេះក៏ត្រូវបានបង្កើតឡើងដើម្បីឱ្យយើងយកមកពិចារណានៅពេលដែលធ្វើការរៀបចំ និងអនុវត្តវិធានការទាំងនេះ។

## តារាងទី១៖ វិធានការនៃការបន្សុាំរំញោចយេនឌ័រ

| ១ ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ និងការដោះស្រាយ | | |
|---|---|---|
| **វិធានការ** | **ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន** | **អនុសាសន៍** |
| **សាងសង់បាំងទប់រលក ឬទំនប់មាត់សមុទ្រ និងរបាំងទប់ទឹកជោរ** | អាចបង្កើតប្រភពការងារសម្រាប់កម្មករបុរស ដោយមិនបានផ្តល់ឱកាសដល់ស្ត្រី ឱ្យធ្វើការដែលខ្លួនចូលចិត្ត ឬអាចធ្វើបានការព្រងើយកន្តើយចំពោះផលប៉ះពាល់លើការងារផលិតរបស់ស្ត្រី (ការជីករកសិប្បសត្វជាមួយអ្នកដទៃ) ដោយមិនបានយកចិត្តទុកដាក់ចំពោះផលប៉ះពាល់ | លើកកម្ពស់ការបណ្តុះបណ្តាល និងជួលកម្មករប្រុសស្រី ធានាការទទួលបានឱកាសរកប្រាក់ចំណូលពី សកម្មភាពផលិតដើម្បីជួយឱ្យជីវភាពគ្រួសារប្រសើរឡើង រួមបញ្ចូលលក្ខខណ្ឌផ្អែកលើយេនឌ័រ ក្នុងការប៉ាន់ប្រមាណផលប៉ះពាល់លើបរិស្ថាន |
| **ការតាំងលំនៅជាថ្មី និងផលិតផលការងារក្នុងតំបន់មាត់សមុទ្រ** | អាចបង្កើតប្រភពការងារសម្រាប់កម្មករ បុរស ដោយមិនបានផ្តល់ឱកាសសម្រាប់ស្ត្រីធ្វើការដែលខ្លួនចូលចិត្ត ឬ អាចធ្វើបានការព្រងើយកន្តើយចំពោះផលប៉ះពាល់លើការងារផលិតរបស់ស្ត្រី ដោយមិនបានយកចិត្តទុកដាក់ចំពោះផលប៉ះពាល់ | បញ្ចូលស្ត្រី ក្នុងសកម្មភាពត្រួតពិនិត្យផលប៉ះពាល់នៃការផ្លាស់ប្តូរអាកាសធាតុ បញ្ចូលស្ត្រីក្នុងយុទ្ធសាស្ត្រផ្សេងៗដើម្បីសម្របខ្លួនទៅនឹងការកាត់បន្ថយប្រភេទសត្វសមុទ្រ ឬការគ្រប់គ្រងប្រភេទសត្វសមុទ្រថ្មី បង្កើតគម្រោងថ្មីៗដើម្បីស្តារនិងដាំព្រៃកោងកាងឡើងវិញ។<br>អនុវត្តគោលនយោបាយគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ តាមវិធីសាស្ត្ររួមបញ្ចូលដោយពិចារណាទៅលើវិធីសាស្ត្រគ្រប់គ្រងហានិភ័យ និងយេនឌ័ររួមបញ្ចូលលក្ខខណ្ឌផ្អែកយេនឌ័រក្នុងការប៉ាន់ប្រមាណផលប៉ះពាល់លើបរិស្ថាន |
| **សាងសង់ស្ពានដើម្បីឆ្លងតំបន់ដែលរងគ្រោះដោយទឹកជំនន់** | អាចបង្កើតប្រភពការងារសម្រាប់កម្មករបុរសដោយមិនបានផ្តល់ឱកាសសម្រាប់ស្ត្រី ធ្វើការដែលខ្លួនចូលចិត្ត ឬអាចធ្វើបានមើលរំលងផលប្រយោជន៍ និងតម្រូវការបឋមជាក់លាក់របស់ស្ត្រីនិងបុរស ទាក់ទងនឹងការប្រើប្រាស់កន្លែងទំនេរអាចនឹងពន្យារ ឬធ្វើឱ្យការងាររបស់ស្ត្រីជាច្រើនលំបាក ដោយបង្កើនចម្ងាយប្រសិនបើស្ពាននឹងត្រូវសាងសង់ សម្រាប់តែដឹកជញ្ជូន | យកចិត្តទុកដាក់ទៅលើតម្រូវការនៃការធ្វើចលនា ពីទីតាំងមួយទៅទីតាំងមួយ លើកកម្ពស់ការបណ្តុះបណ្តាល និងជួលបុគ្គលិកទាំងប្រុសនិងស្រីបង្កើតការប្រើប្រាស់ដីធ្លីដោយប្រើយុទ្ធសាស្ត្រយេនឌ័រ រួមបញ្ចូលលក្ខខណ្ឌជ្រើសរើសផ្អែកយេនឌ័រក្នុងការប៉ាន់ប្រមាណផលប៉ះពាល់លើបរិស្ថាន |

| | | |
|---|---|---|
| **បញ្ចូញទឹកសាប ទៅតំបន់ផ្សេង ដែលខ្វះទឹក ទាញទឹកពីអាង ស្តុបទឹកក្រោមដី** | មើលរំលងតម្រូវការទឹកសាបរបស់ស្ត្រីសម្រាប់ការងារផលិត និងការបង្កាត់ពូជរុក្ខជាតិថ្មីអាចអូសបន្លាយ និងរិតបន្តឹងការងារផលិត និងការបង្កាត់ពូជរុក្ខជាតិថ្មីរបស់ស្ត្រី ដោយដាក់ប្រភពទឹកសាបនៅកន្លែងដាច់ស្រយាល ការដាក់អាទិភាពលើទឹកមានន័យថា ការកំណត់ថ្លៃខ្ពស់ បាត់បង់ការផ្គត់ផ្គង់បញ្ហាសុខភាព អំពើពុករលួយ។ល។ ដែលធ្វើឱ្យស្ត្រីក្រីក្រ និងគ្រួសាររបស់ពួកគេកាន់តែពិបាក ក្នុងការទទួលបានទឹកសាប | ប្រើវិធីសាស្ត្រយេនឌ័រនៅពេលកំណត់នូវតម្រូវការ និងរៀបផែនការផ្គត់ផ្គង់ទឹកសាប ក្នុងសហគមន៍ |



## ២ ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី

| **វិធានការ** | **ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន** | **អនុសាសន៍** |
|---|---|---|
| **ណែនាំនូវរុក្ខជាតិ និងសត្វថ្មី ក្នុងតំបន់ដែលធន់នឹងអំបិល ដើម្បីការពារ/កែលម្អតំបន់ឆ្នេរ** | អាចមានផលប៉ះពាល់អវិជ្ជមាន ដល់ផលប្រយោជន៍ និងតម្រូវការរបស់ស្ត្រីក្នុងតំបន់ឆ្នេរសមុទ្រ ប្រសិនបើរុក្ខជាតិ និងសត្វដែលត្រូវណែនាំថ្មីប៉ះពាល់ដល់ធនធានដែលស្ត្រីប្រើអាចបាំងចំណេះដឹង និងការប្រព្រឹត្តិរបស់ស្ត្រី ទាក់ទងនឹងធនធានបរិស្ថានឆ្នេរសមុទ្រដោយមិនបានបញ្ចូលពួកគេ ក្នុងការធ្វើសេចក្តីសម្រេច | វិភាគទំនាក់ទំនងយេនឌ័រទាក់ទងនឹងការប្រើប្រាស់ ការទទួលបាន និងការគ្រប់គ្រងចាត់ចែងធនធាន បរិស្ថាន ឆ្នេរសមុទ្រ លើកកម្ពស់ការបញ្ចូលស្មើភាពរវាងស្ត្រីបុរសនៅពេលណែនាំរុក្ខជាតិ និងសត្វប្រភេទថ្មី បង្កើតការងារដែលចូលរួមដោយស្មើភាពរវាងស្ត្រី និងបុរស |
| **ណែនាំប្រភេទរុក្ខជាតិ និងដំណាំផ្សេងៗ ដែលធន់នឹងអាកាសធាតុក្តៅខ្លាំង** | ជាទូទៅត្រូវការទឹកនិងធនធានផ្សេងៗ ដែលស្ត្រីប្រើប្រាស់សម្រាប់ការងារបណ្តុះពូជថ្មី និងការប្រើប្រាស់ក្នុងលំនៅដ្ឋានអាចអូសបន្លាយថ្ងៃធ្វើការដាំដុះ និងបង្កាត់ពូជថ្មី | វិភាគនូវផលប៉ះពាល់នៃការណែនាំនូវប្រភេទរុក្ខជាតិ និងដំណាំផ្សេងៗ និងលើកកម្ពស់ការងារបង្កាត់ពូជថ្មីដោយស្មើភាពគ្នាសម្របសម្រួលការគ្រប់គ្រង និងចាត់ចែងធនធានក៏ដូចជាការបែងចែកផលប្រយោជន៍ (រួមមានធនធានដែលនឹងផ្តល់ផលច្រើន ការងារការបណ្តុះបណ្តាល និងឥណទានលើកទឹកចិត្តឱ្យមានការផ្លោះប្តូរ ចំណេះដឹង និងការអនុវត្តរវាងស្ត្រី និងបុរសអំពីការគ្រប់គ្រងប្រភេទរុក្ខជាតិ និងដំណាំ |
| **ស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីដែលខូចខាត** | អាចនឹងធ្វើឱ្យមានអសមតុល្យផ្នែកយេនឌ័រកាន់តែខ្លាំងតាមរយៈការលើកទឹកចិត្តការងារស្ម័គ្រចិត្តដែលធ្វើដោយស្ត្រីក្នុងសកម្មភាពស្តារ និងអភិរក្សអាចពង្រឹងតួនាទីការងារបរិស្ថានបែបបុរាណ ឧ. ធ្វើឱ្យស្ត្រីទទួលខុសត្រូវចំពោះការដាំស្ល ការប្រជុំក្នុងសហគមន៍ ការអប់រំផ្នែកបរិស្ថានសម្រាប់ កុមារ និងក្មេងជំទង់ ដោយមិនលើកកម្ពស់តួនាទីដែលមិនមែនតាមបែបបុរាណ | លើកកម្ពស់ទំនួលខុសត្រូវរួម និងការបែងចែកការងារបន្តពូជក្នុងគ្រួសារដើម្បីឱ្យស្ត្រីមានពេលវេលាទំនេរ សម្រាប់សកម្មភាពផ្សេង លើកទឹកចិត្តឱ្យបង់ថ្លៃឈ្នួលដល់ស្ត្រីសម្រាប់ការងារស្តារបរិស្ថានបណ្តុះបណ្តាលស្ត្រី និងបុរសអំពីការងារបែបទំនើបទាក់ទងនឹងការស្តាប្រព័ន្ធ អេកូឡូស៊ី លើកកម្ពស់ឱ្យមានការដឹកនាំ និងការចូលរួមដោយមានប្រសិទ្ធិភាពរបស់ស្ត្រីក្នុងអង្គភាព និងការធ្វើសេចក្តីសម្រេច |

| | | |
|---|---|---|
| **បង្កើតតំបន់ការពារធម្មជាតិ និងតំបន់ជីវសាស្ត្រ** | អាចហាមប្រាមសកម្មភាពចិញ្ចឹមដាំដុះ ដែលជាប្រភពនៃប្រាក់ចំណូល សម្រាប់គ្រួសារ គ្រួសារខ្លះក្រីក្រនិងមានស្ត្រីជាមេគ្រួសារ | ទទួលប្រយោជន៍ និងបង់ថ្លៃឈ្នួលសម្រាប់ពួកគេ ចំពោះចំណេះដឹងអំពីប្រភេទសត្វ និងរុក្ខជាតិក្នុងតំបន់ការពារធម្មជាតិនិងជីវសាស្ត្រ។<br>វិភាគទំនាក់ទំនងយេនឌ័រ ទាក់ទងនឹងការប្រើប្រាស់ការទទួលបាន និងការគ្រប់គ្រងចាត់ចែងធនធានផ្សេងៗ។ |
| **ណែនាំនូវប្រភេទរុក្ខជាតិ និងដំណាំដែលធន់នឹងថ្នាំសម្លាប់សត្វល្អិតចង្រៃ** | អាចប្រើប្រាស់ថ្នាំធម្មជាតិសម្រាប់សម្លាប់សត្វល្អិតដោយមិនចាំបាច់ពិចារណាអំពីភាពជាក់លាក់ផ្នែកយេនឌ័រ នៅពេលប្រើប្រាស់សារធាតុគីមី ដែលធ្វើឱ្យមានរបួសដល់ស្ត្រី និងបុរសតាមរបៀបផ្សេងៗ (ឧ. ពេលមានផ្ទៃពោះ និងបំបៅដោះ) | វិភាគអំពីដំណើរការនៃការដាំដុះ និងយកចិត្តទុកដាក់ចំពោះការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតរបស់មនុស្ស ដែលមានថ្នាំគីមីប្រើប្រាស់ |
| **អនុវត្តការដាំព្រៃឈើឡើងវិញ ឬកាត់បន្ថយការកាប់ព្រៃឈើ ក៏ដូចជាកាត់បន្ថយ ការខូចគុណភាពដី** | អាចប៉ះពាល់ដល់ផលប្រយោជន៍ និងតម្រូវការរបស់ស្ត្រី ប្រសិនបើការអនុវត្តទាំងនេះប៉ះពាល់ ឬកំហិតនូវការទទួលបានធនធានដែលពួកគេប្រើប្រាស់។<br>អាចបាំងចំណេះដឹង និងការប្រព្រឹត្តរបស់ស្ត្រីទាក់ទងនឹងធនធានបរិស្ថាន ឆ្នេរសមុទ្រ ដោយមិនបានបញ្ចូលពួកគេក្នុងការធ្វើសេចក្តីសម្រេច។<br>អាចបង្កើតប្រភពការងារសម្រាប់ក្រុមបុរស ដោយមិនបានផ្តល់ឱកាសដល់ស្ត្រីធ្វើការដែលខ្លួនចូលចិត្តឬអាចធ្វើបាន។ | វិភាគទំនាក់ទំនងយេនឌ័រ ទាក់ទងនឹងការប្រើប្រាស់ការទទួលបាន និងការគ្រប់គ្រងចាត់ចែងធនធានបរិស្ថានផ្សេងៗ។<br>លើកកម្ពស់សមាហរណកម្មដោយស្មើភាព រវាងស្ត្រី និងបុរសក្នុងយុទ្ធសាស្ត្របន្ធូរបន្ថយ។ |
| **បង្កើតវារីកសិកម្ម រួមទាំងវប្បកម្មលំហរសមុទ្រ ដើម្បីបំពេញបង្គ្រប់ចំពោះការបាត់បង់ផលិតផលអាហារដែលបណ្តាលមកពីអាកាសធាតុអាក្រក់** | អាចពង្រឹងការបែងចែកការងារបែបប្រពៃណី និងវិសមភាពក្នុងការទទួលបានធនធាន និងអត្ថប្រយោជន៍ពីការងារផលិតរបស់ពួកគេ ។<br>អាចបាំងការចូលរួមយ៉ាងសកម្មរបស់ស្ត្រីក្នុងដំណើរការការងារ ឧ. ការនេសាទ។ | លើកកម្ពស់សមាហរណកម្មដោយស្មើភាពរវាងស្ត្រី និងបុរសក្នុងសកម្មភាពផលិត និងបណ្តុះពូជ។ |

| ៣ សកម្មភាពផលិតកម្ម | | |
|---|---|---|
| **វិធានការ** | **ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន** | **អនុសាសន៍** |
| **ផ្លាស់ប្តូរធារាសាស្ត្រ ដំណាំ ពេលវេលា ប្រភេទ និងការប្រើប្រាស់** | អាចនឹងដកចេញប្រភពទឹកសម្រាប់ការប្រើប្រាស់ក្នុងតំបន់ ឬផ្លាស់ប្តូរប្រភពទឹកទៅកន្លែងឆ្ងាយ។<br>អាចនឹងពន្យារ ឬធ្វើឱ្យការងារផលិត និងបណ្តុះពូជជួបការលំបាកច្រើន។ | ចាត់ទុកស្ត្រីជាអ្នកប្រើប្រាស់ទឹកទាំងក្នុងផ្ទះ និងការដាំដុះដូចជាដាំដំណាំ និងការចិញ្ចឹមសត្វ។<br>វិភាគការប្រើប្រាស់ដីធារាសាស្ត្ររបស់ស្ត្រី ក្នុងការផ្គត់ផ្គង់អាហារចិញ្ចឹមជីវិត។<br>លើកកម្ពស់បច្ចេកវិទ្យាដែលសមរម្យចំពោះតម្រូវការរបស់ស្ត្រី និងផ្តល់ឱ្យពួកគេនូវវគ្គបណ្តុះបណ្តាលដែលសមស្រប។<br>លើកទឹកចិត្តឱ្យមានសមភាពក្នុងការធ្វើជាម្ចាស់ដីធារាសាស្ត្រ។ |
| **កសិកម្មធំទូស** | ប្រហែលជាមិនបានពិចារណាអំពីការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពកសិកម្ម ដោយមិនបានរួមបញ្ចូលពួកគេក្នុងដំណើរការថ្មីៗ<br>ប្រហែលជាអាចបង្កឱ្យមានឧបសគ្គ ក្នុងការប្រើប្រាស់ ការទទួលបានធនធាន និងការគ្រប់គ្រងចាត់ចែងធនធាន (ដី ឥណទាន និងការបណ្តុះបណ្តាល។ | កសាងសមត្ថភាពថ្មីៗសម្រាប់ស្ត្រី និងបង្កើតប្រភពការងារមិនមែនជាប្រពៃណី។ |

| ៤ ដំណើរការសេដ្ឋកិច្ច សង្គម | | |
|---|---|---|
| **វិធានការ** | **ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន** | **អនុសាសន៍** |
| **ការធ្វើទេសន្តប្រវេសន៍និងអស្ថិរភាពក្នុងសហគមន៍ក្នុងតំបន់រងគ្រោះដោយការប្រែប្រួលអាកាសធាតុ** | វិសមភាពផ្នែកយេនឌ័រ និងសេដ្ឋកិច្ច សង្គមក្នុងការទទួលបានឱកាសការងារ ការអប់រំ ការថែទាំសុខភាព លំនៅដ្ឋាន និងឥណទាន<br>គ្រួសារដែលមានស្ត្រីជាមេគ្រួសារកាន់តែច្រើនក្នុងសង្គមដែលបដិសេធ និងរើសអើងចំពោះស្ត្រីជាមេគ្រួសារ។<br>ស្ត្រីកាន់តែច្រើនកំពុងធ្វើការងារ ដែលតាមទម្លាប់ជាការងាររបស់ "បុរស" ដែលពួកគេត្រូវបានគេកេងប្រវ័ញ្ច និងមិនបានទទួលប្រាក់ឈ្នួលគ្រប់គ្រាន់។<br>ការងារទាំងនេះ ជាការងារមិនទៀង ឬមានតាមរដូវកាល។<br>មានករណីនៃការបៀតបៀន ការរំលោភបំពានផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារកាន់តែច្រើនក្នុងវដ្តនៃការធ្វើទេសន្តប្រវេសន៍ | លើកកម្ពស់ការអនុវត្តសិទ្ធិស្ត្រីលើកទឹកចិត្តឱ្យស្ត្រី និងបុរសទទួលបាន ការងារដែលប្រើជំនាញ និងទទួលប្រាក់ឈ្នួល។<br>ធានាឱ្យស្ត្រី និងបុរសទទួលបានប្រព័ន្ធការពារពលកម្ម។<br>យកចិត្តទុកដាក់ចំពោះការចូលរួមចំណែកជួយដល់គ្រួសារ និងសហគមរបស់ស្ត្រី និងបុរសធ្វើទេសន្តប្រវេសន៍។<br>បង្កើតសេវាគាំពារសម្រាប់សហគមន៍ គ្រួសារ និងឯកត្តបុគ្គលដែលត្រូវបានទុកឱ្យនៅក្នុងសហគមន៍ដើម ដោយសារកត្តាចំណាកស្រុក។ |

## ៤.៥ ការធ្វើផែនការជាតិដែលគិតគូរពីយេនឌ័រ

### ៤.៥.១ កម្មវិធីសកម្មភាពជាតិបន្សាំ និងការប្រែប្រួលអាកាសធាតុ (NAPA)

អនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីអំពីការប្រែប្រួលអាកាសធាតុ (UNFCC) តម្រូវឱ្យប្រទេសដែលមានការអភិវឌ្ឍតិចតួច ដាក់ជូននូវកម្មវិធីអនុវត្តសកម្មភាពថ្នាក់ជាតិ(NAPA) ដែលពិពណ៌នាអំពីអាទិភាព និងយុទ្ធសាស្ត្រក្នុងការដោះស្រាយចំពោះការប្រែប្រួលអាកាសធាតុ។ UNFCC មិនតម្រូវឱ្យ NAPA រួមបញ្ចូលទស្សនវិស័យផ្នែកយេនឌ័រទេ តែយ៉ាងណាមិញមានការផ្តល់អនុសាសន៍ឱ្យបញ្ចូលគោលការណ៍យេនឌ័រ និងជួលក្រុមការងារយេនឌ័រដើម្បីបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីអនុវត្តសកម្មភាពថ្នាក់ជាតិ(Dankelman, 2008)។ អនុសាសន៍ទាំងនេះមិនទាន់បានអនុវត្តនៅឡើយទេ ហេតុដូច្នេះហើយបានជាបញ្ហាយេនឌ័រកម្រត្រូវបានបញ្ចូលជាគោលដៅចម្បងរបស់គម្រោង។ ខណៈពេលដែលប្រទេសជាច្រើនបានសំគាល់ឃើញថា ស្ត្រីជាច្រើនមានកម្រិតនៃភាពងាយរងគ្រោះខ្ពស់ក្នុងការប្រឈមនឹងការប្រែប្រួលអាកាសធាតុក្នុងកម្មវិធីអនុវត្តសកម្មភាពថ្នាក់ជាតិរបស់ពួកគេមានប្រទេសតិចតួចបំផុតដែលចាត់ទុកស្ត្រីជាភ្នាក់ងារអនុវត្តយុទ្ធសាស្ត្រសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។

ទស្សនៈយេនឌ័រពាក់ព័ន្ធនឹងចំណុចគន្លឹះក្នុង NAPA រួមមានអភិបាលកិច្ច ការប្រមូលព័ត៌មាន ការទទួលបានហិរញ្ញវត្ថុ និងបច្ចេកវិទ្យា និងការអនុវត្ត NAPA (WEDO, 2008)។ ខណៈពេលដែលកម្មវិធីអនុវត្តសកម្មភាពថ្នាក់ជាតិត្រូវបញ្ចប់នៅពេលចាប់ផ្តើមកិច្ចសន្យានេះ ការអនុវត្ត និងការបែងចែកថវិកាគឺជាយោបល់ដាក់បញ្ចូលសម្រាប់ការបញ្ជ្រាបយេនឌ័រ។ មុននឹងអនុវត្ត NAPA ត្រូវធ្វើការវិភាគយេនឌ័រក្នុង NAPA ដើម្បីពិនិត្យមើលថាតើការប្រែប្រួលអាកាសធាតុប៉ះពាល់ស្ត្រី និងបុរសខុសគ្នាយ៉ាងណា និងដើម្បីបង្កើនភាពច្នៃប្រឌិតដាក់លាក់បន្ថែមទៀតដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការចូលរួមរបស់ស្ត្រី។ ដើម្បីធានាថាគោលដៅយេនឌ័រត្រូវបានសម្រេច "ក្រុមការងារយេនឌ័រ" អាចទទួលបានការផ្តល់ព័ត៌មានដើម្បីបង្កើតដំណើរការត្រួតពិនិត្យគោលដៅយេនឌ័រនៅគ្រប់កម្រិត។ ការបញ្ជ្រាបយេនឌ័រក្នុង NAPA មិនត្រឹមតែរួមចំណែកសម្រេចជោគជ័យក្នុងការអនុវត្តគោលដៅអភិវឌ្ឍសហស្សវត្សរ៍ប៉ុណ្ណោះទេ ក៏ប៉ុន្តែបានរួមចំណែកកាត់បន្ថយសម្ពាធផ្នែកបរិស្ថានផងដែរ តាមរយៈការប្រើប្រាស់នូវទិន្នន័យប្រជាសាស្ត្រដែលត្រូវបានមើលរំលងកន្លងមកជាភ្នាក់ងារនៃការផ្លាស់ប្តូរដែលមានភាពច្នៃប្រឌិត និងប្រកបដោយសក្តានុពល។

ជំហានបន្ទាប់សម្រាប់ការបញ្ជ្រាបយេនឌ័រ ត្រូវបានដកស្រង់ពី "ការបញ្ជ្រាបយេនឌ័រក្នុងរបបនៃការប្រែប្រួលអាកាសធាតុ" (COP 10, 14 December 2014) និងទទួលបានការគាំទ្រពីសភាស្ត្រី UNEP ដែលបានប្រព្រឹត្តឡើងនៅទីក្រុងណៃរ៉ូប៊ីក្នុងខែតុលា ២០០៤៖

- វិភាគផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុតាមទស្សនៈរបស់ស្ត្រី និងបុរស
- រួមបញ្ចូលទស្សនៈវិស័យរបស់ស្ត្រីនៅពេលបង្កើត និងអនុវត្តគម្រោង
- លក្ខខណ្ឌ និងសូចនាករដែលផ្អែកលើយេនឌ័រគួរតែបង្កើតឡើង និងអនុវត្ត
- នៅពេលប្រមូលទិន្នន័យ និងធ្វើបទបង្ហាញទិន្នន័យត្រូវរួមបញ្ចូលស្ថិតិរបស់ស្ត្រី និងបុរស
- ឆ្លៀតយកប្រយោជន៍ពីទេពកោសល្យ និងការចូលរួមចំណែករបស់ស្ត្រី និងបុរស

- កំណត់គោលដៅឱ្យស្ត្រីចូលរួមក្នុងសកម្មភាពនានា
- ធានាថាស្ត្រីត្រូវបានចូលរួមជាតំណាង ៥០% ក្នុងដំណើរការធ្វើសេចក្ដីសម្រេច
- ដាក់អាទិភាពស្ត្រីទទួលបានព័ត៌មាន ធនធានសេដ្ឋកិច្ច និងការអប់រំដោយស្មើភាព
- ផ្ដោតលើភាពខុសគ្នានៃយេនឌ័រក្នុងសមត្ថភាពប្រឈមសម្របទៅនឹងការប្រែប្រួលអាកាសធាតុនិង ការបន្ធូរបន្ថយផ្នែកអាកាសធាតុ
- ធ្វើការវិភាគយេនឌ័រក្នុងគ្រប់ខ្សែបន្ទាត់ថវិកា និងហិរញ្ញវត្ថុ

NAPA ត្រូវពិចារណាគ្រប់កត្តាសេដ្ឋកិច្ចទាំងអស់ ដូចជាការចាត់ចែងថវិកាមិនត្រឹមតែសម្រាប់គម្រោងបន្ថយ និងបន្សាំការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់បង្កើត NAPA ផងដែរ។ ការសរសេរ NAPA បញ្ជាក់ពីការប្រើប្រាស់ធនធាន ហើយគម្រោងទាំងនេះត្រូវភ្ជាប់ជាមួយនឹងដំណើរការនៃការបញ្ជ្រាបយេនឌ័រ។ NAPA ត្រូវតែផ្អែកនិងរួមបញ្ចូលផែនការអភិវឌ្ឍក្នុងតំបន់ផងដែរ ដោយធានាឱ្យមានវិធីសាស្ត្រពីក្រោមឡើងលើក្នុងគ្រប់ដំណើរការទាំងអស់ ទាំងការត្រួតពិនិត្យនិងការអនុម័ត ហើយត្រូវធានាឱ្យមានការរួមបញ្ចូលចំណេះដឹងអំពីយេនឌ័រនៅតាមទីកន្លែង។

កម្មវិធី NAPA ត្រូវមានទំនាក់ទំនងជាមួយនឹងផែនការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។ កម្មវិធីនេះទាមទារនូវការរួមចំណែករបស់រដ្ឋាភិបាល ផ្នែកឯកជន និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់។ ទំនាក់ទំនងរវាងការអភិវឌ្ឍដែលមាននិរន្តរភាព ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងការសម្របខ្លួននឹងការប្រែប្រួលអាកាសធាតុត្រូវតែជាសកម្មភាពសំខាន់សម្រាប់កម្មវិធី NAPA។ របាយការណ៍វេទិកាគោលនយោបាយអូស្លូបញ្ជាក់យ៉ាងច្បាស់ថា មិនគួរមាន "របៀបវារៈប្រហាក់ប្រហែល" នេះទេ ហើយការធ្វើផែនការអភិវឌ្ឍថវិកាជាតិសម្រាប់ការបន្សាំ ការរៀបចំស្ថាប័ន ការយល់ដឹងជាសាធារណៈបញ្ហាភាពក្រីក្រ និងសន្តិភាព និងជម្លោះគួរតែរួមបញ្ចូលក្នុងរបៀបវារៈទាំងនោះ។ ដំណើរការនេះ គួរតែមានការធានាឱ្យមាននូវទស្សនៈយេនឌ័រដែលរដ្ឋាភិបាលជាច្រើនមិនទាន់មានសមត្ថភាពអនុវត្តនៅឡើយ។ ការភ្ជាប់ដំណើរការបែងចែកថវិកាជាមួយនឹងការបញ្ចូលទស្សនៈយេនឌ័រអាចជួយធានានូវភាពជោគជ័យ។

កម្មវិធី NAPA គួរតែបញ្ជាក់អំពីតម្លៃនៃការសម្របខ្លួន។ ព័ត៌មានអំពីដំណើរការបែងចែក ថវិកាសម្រាប់គម្រោងសម្របខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុត្រូវតែមានភាពច្បាស់លាស់ និងជាក់លាក់។ គម្រោងទាំងនេះត្រូវរួមបញ្ចូលយេនឌ័រ និងថ្លៃចំណាយត្រូវមានចែងឱ្យច្បាស់លាស់ (Oslo Policy Forum Report, 2008 )។

## ៤.៥.២ ផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

យុទ្ធសាស្ត្រអន្តរជាតិនៃអង្គការសហប្រជាជាតិដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (UN/ISDR) បានឈានទៅបញ្ចូលយេនឌ័រក្នុងផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) របស់ខ្លួន ក្រោមក្របខណ្ឌសកម្មភាពយ៉ូហ្គូ (HFA)។ ក្នុងផែនការ DRR យេនឌ័រត្រូវបានបញ្ចូល ដើម្បីធានានូវសមភាពនៃឱកាសទទួលបានការអប់រំ សម្រាប់ស្ត្រីងាយរងគ្រោះបង្កើតប្រព័ន្ធជូនដំណឹងជាមុន ដើម្បីឱ្យមានការពិចារណាលើយេនឌ័រ និងជីវភាព វប្បធម៌ និងដោយប្រើប្រាស់នូវទស្សនៈយេនឌ័រក្នុងដំណើរការនៃកាធ្វើសេចក្ដីសម្រេច នៅពេលអនុវត្តគោលនយោបាយកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ផែនការ DRR ត្រូវយកមកអនុវត្តកក្នុងផែនការសកម្មភាពថ្នាក់ជាតិក្នុងការត្រៀមខ្លួនទប់ទល់ចំពោះ

គ្រោះធម្មជាតិ។ UN/ISDR ពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រ និងបទពិសោធន៍នៅតាមសហគមន៍ ហើយបានប្រើឧទាហរណ៍អំពីស្ត្រីជាភ្នាក់ងារនៃការផ្លាស់ប្តូរដ៏មាននិរន្តរភាព (UN/ISDR, 2008)។ នេះអាចជាឧទាហរណ៍នៃបទពិសោធន៍ និងអាចយកមកប្រើសម្រាប់អ្នករៀបផែនការអភិវឌ្ឍដើម្បីកែសម្រួលគម្រោង និងទាញយកគំនិតយោបល់ដ៏មានសារៈសំខាន់របស់ស្ត្រី និងសក្តានុពលរបស់ពួកគេក្នុងការនាំមកនូវការផ្លាស់ប្តូរ។

DRR អាចត្រូវបានកែសម្រួលដើម្បីលើកកម្ពស់វិធីសាស្ត្រឱ្យមានការយល់ដឹងអំពីយេនឌ័រច្រើនថែមទៀត ដើម្បីដឹកនាំប្រទេសឱ្យមានការអនុវត្តដែលមាននិរន្តរភាព ព្រមទាំងកាត់បន្ថយផលប៉ះពាល់នៃគ្រោះធម្មជាតិ។ យុទ្ធសាស្ត្រថ្មីៗអាចត្រូវបានបង្កើតឡើងផ្តោតលើទស្សនៈយេនឌ័រ ហើយគម្រោងនានាក៏អាចពង្រីកខ្លួនថែមទៀតដើម្បីធានាឱ្យបាននូវការចូលរួមដ៏សំខាន់របស់ស្ត្រីក្នុងគ្រប់ជាន់ថ្នាក់ទាំងអស់ ហើយបណ្តាញស្ត្រីអាចត្រូវបានប្រើប្រាស់ដើម្បីដឹកនាំសហគមន៍របស់គេដែលមិនមែនគ្រាន់តែក្នុងពេលមានគ្រោះមហន្តរាយប៉ុណ្ណោះទេ ប៉ុន្តែក្លាយជាគ្រឹះនៅថ្នាក់មូលដ្ឋានថ្នាក់ជាតិ និងអន្តរជាតិ (UN/ISDR, 2008)។ ការរួមបញ្ចូលទស្សនៈយេនឌ័រក្នុង DRR រួមទាំងទិន្នន័យយេនឌ័រ និងការលើកកម្ពស់ការចូលរួមរបស់ស្ត្រីអាចនាំឱ្យមានទស្សនៈយេនឌ័រទៅក្នុងគ្រប់កម្រិតទាំងអស់ដើម្បីត្រៀមខ្លួនប្រឈមនឹងគ្រោះមហន្តរាយ។

ជំហាននៃការបញ្ជ្រាបយេនឌ័រទៅក្នុង DRR ខាងក្រោមនេះត្រូវបានដកស្រង់ពី "ទស្សនៈយេនឌ័រនៅក្នុងការប្រែប្រួលអាកាសធាតុ" វគ្គលើកទី៥២ នៃគណៈកម្មការអង្គការសហប្រជាជាតិស្តីពី ស្ថានភាពស្ត្រីថ្ងៃទី២៨ កុម្ភៈ ២០០៨ និងដើរតួជាគោលការណ៍ណែនាំដើម្បីដាក់បញ្ចូលស្ត្រីនៅគ្រប់កម្រិតនៃឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ៖

- បញ្ចូលទស្សនៈយេនឌ័រក្នុងកិច្ចខឹតខំប្រឹងប្រែងកាត់បន្ថយគ្រោះមហន្តរាយក្នុងកម្រិតថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិដោយបញ្ចូលក្នុងគោលនយោបាយផែនការសកម្មភាព និងកម្មវិធីនានា
- វិភាគទិន្នន័យការប្រែប្រួលអាកាសធាតុ (ដូចជាការប្រែក្លាយជាតំបន់វាលខ្សាច់ ទឹកជំនន់ ភាពរាំងស្ងួត និងការកាប់បំផ្លាញព្រៃឈើ) ពីទស្សនៈស្ត្រី
- បោះជំហានផ្អែកលើយេនឌ័រ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃគ្រោះធម្មជាតិទៅលើស្ត្រី ជាពិសេសទាក់ទងនឹងតួនាទីដ៏សំខាន់របស់ពួកគេក្នុងការផ្គត់ផ្គង់ទឹក ចំណីអាហារ និងថាមពល
- បង្កើនការចូលរួមរបស់ស្ត្រីក្នុងគ្រប់កម្រិតនៃដំណើរការនៃការធ្វើសេចក្តីសម្រេចទាំងអស់
- កំណត់រកស្ត្រីបង្គោលក្នុងគ្រប់កម្រិតទាំងអស់ដើម្បីធានាថា ទស្សនៈយេនឌ័រត្រូវបានពិចារណានៅពេលរៀបចំយន្តការនៃការជូនដំណឹងជាមុន
- ធានាថាស្ត្រីទាំងអស់ត្រូវបានប្រើជាភ្នាក់ងារនៃការផ្លាស់ប្តូរនៅគ្រប់កម្រិតទាំងអស់ក្នុងការត្រៀមខ្លួនប្រឈមនឹងគ្រោះមហន្តរាយ រួមទាំងប្រព័ន្ធផ្តល់ព័ត៌មានជាមុន បណ្តាញប្រាស្រ័យទាក់ទង និងឱកាសទទួលការអប់រំ
- ពិចារណាទៅលើកម្រិតនៃការទទួលបានបច្ចេកវិទ្យា និងហិរញ្ញវត្ថុរបស់ស្ត្រីក្នុងពេលមានវិបត្តិ និង
- ប្រមូល និងវិភាគទិន្នន័យដែលរួមបញ្ចូលទាំងស្ត្រី និងបុរស

# ឯកសារស្រាវជ្រាវ


Aguilar, L., Araujo, A., Kring, E., Quesada, A. and Zuniga, P. (2008). Guia: Recursos de genero para el cambio climatico. Mexico: UNDP.

Anderson, C. (2002). Gender Matters: implications for climate variability and climate change and for disaster management in the Pacific islands. Retrieved from the World Wide Web: http://www.gencc.interconnection.org/resources.htm

Dankelman, I. (2008). "Mainstreaming gender in climate change policies: urgencies, challenges and perspectives". Paper presented at the Third Global Congress of Women in Politics and Governance on the theme of gender and climate change, organized by CAPWIP, Manila, The Philliphines.

Neumayer, E. and Plumper, T. (2007). The Gendered Nature of Natural Disasters: The Impact of Catastrophic Events on the Gender Gap in Life Expectancy, 1981-2002. Retrieved from the World Wide Web: http://papers.ssrn.com/sol3/papers.cfm?abstract_id=874965

Williams, E., Sorokina, O., Jones-DeWeever, A. and Hartmann, H. (2006). The Women of New Orleans and the Gulf Coast: Multiple Disadvantages and Key Assets for Recovery. Part II. Gender, Race, and Class in the Labor Market. Part 2 of a 2-Part Series. Institute for Women's Policy Research Briefing Paper. Retrieved from the World Wide Web: http://www.iwpr.org/pdf/D465.pdf

Women's Environment and Development Organization (WEDO), ABANTU for Development in Ghana, ActionAid Bangladesh and ENDa Senegal. (2008). Gender, Climate Change and Human Security: Lessons from Bangladesh, Ghana and Senegal. Retrieved from the World Wide Web: http://www.wedo.org/files/HSN%20Study%20Final%20May%2020,%202008.pdf

## កិច្ចការសម្រាប់ជំពូកនេះ

| សកម្មភាព | នីតិវិធី | រយៈពេល |
|---|---|---|
| រួមបញ្ចូលយេនឌ័រក្នុងផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងវិធីសាស្ត្របែបចូលរួម | បច្ចេកទេស **"កិច្ចប្រជុំការធ្វើផែនការជាតិស្តីពីការបន្សាំការប្រែប្រួលអាកាសធាតុ"** | ៤០-៦០ នាទី |
| ការដឹកនាំរបស់ស្ត្រីទាក់ទងនឹងគម្រោងសម្របខ្លួន ដែលផ្តល់យោបល់ដោយអ្នកចូលរួម | បច្ចេកទេស **"សំនួរនិងចម្លើយជាមួយទីប្រឹក្សាផ្នែកយេនឌ័រ"** | ៣០នាទី |

# ករណីសិក្សាផ្សេងៗ

## ករណីសិក្សាទី១

### ស្ត្រីជាអ្នកដឹកនាំនៅក្នុងភាពធន់របស់សហគមន៍ក្នុងទ្វីបអាហ្វ្រិក

ក្នុងទ្វីបអាហ្វ្រិក គម្រោងស្ត្រីជាអ្នកដឹកនាំក្នុងការកាត់បន្ថយហានិភ័យ (G.I.R.R.L Project) មានគោលបំណងកាត់បន្ថយភាពងាយរងគ្រោះផ្នែកសង្គមរបស់ក្មេងស្រី ដែលរងការរើសអើងក្នុងតំបន់សាន់ឌើរតែធើ ដោយប្រើកម្មវិធីកសាងសមត្ថភាពដើម្បីលើកកម្ពស់ភាពធន់របស់បុគ្គលនិងសហគមន៍ រួមទាំងការស្តារឡើងវិញនូវគ្រោះមហន្តរាយ។ គម្រោងនេះត្រូវបានដឹកនាំដោយមជ្ឈមណ្ឌលស្រាវជ្រាវគ្រោះមហន្តរាយទ្វីបអាហ្វ្រិក។

សាន់ឌើរតែធើជាតំបន់ក្រីក្របំផុតមួយនៃខេត្តផ្នែកពាយព្យនៅទ្វីបអាហ្វ្រិកខាងត្បូង។ ពីដើមទីក្រុងអ៊ីកាគែងត្រូវបានចាត់ទុកថាជាតំបន់សម្រាប់ការតាំងទីលំនៅនៃជនជាតិស្បែកខ្មៅប៉ុណ្ណោះ។ អាហ្វ្រិកទាំងមូលកំពុងទទួលរងគ្រោះមហន្តរាយកាន់តែញឹកញាប់ ហើយថែមទាំងធ្វើឱ្យប្រជាជនមានភាពងាយរងគ្រោះកាន់តែខ្លាំងថែមទៀត។ ក្នុងអំឡុងពេលមួយទសវត្សរ៍មកហើយទីក្រុងអ៊ីកាគែងបានពង្រីកខ្លួនយ៉ាងរហ័ស ជាហេតុបណ្តាលឱ្យមានការតាំងទីលំនៅអនាធិបតេយ្យដូចជា តំបន់សាន់ឌើរតែធើដែលមានប្រជាជនក្រីក្រជាងគេរស់នៅក្នុងផ្ទះធ្វើពីស័ង្កសី បិទមិនជិតដោយគ្មានហេដ្ឋារចនាសម្ព័ន្ធត្រឹមត្រូវដូចជា ទឹកម៉ាស៊ីន ប្រព័ន្ធលូ ឬអគ្គិសនី។ ប្រជាពលរដ្ឋ ជាពិសេសក្មេងស្រីៗប្រឈមនឹងភាពក្រីក្រ បទឧក្រិដ្ឋកុមារជាមេគ្រួសារ ជំងឺអេដស៍ (HIV/AIDS, STDs) ថ្នាំញៀន គ្រឿងស្រវឹង ខ្វះការអប់រំ ពេស្យាចារ និងការរំលោភបំពានក្នុងគ្រួសារ កាយ និងផ្លូវភេទ។

វិសមភាពក្នុងសង្គមធ្វើឱ្យស្ត្រី និងក្មេងស្រីបាត់បង់នូវអត្ថប្រយោជន៍មូលដ្ឋានរបស់ពួកគេដូចជា ការទទួលបានព័ត៌មាន ធនធាន ការដើរហើរមិនមានសេរីភាព និងការមិនបានទទួលព័ត៌មានអំពីវិធីសាស្ត្រនៃការរស់រានមានជីវិតក្នុងអំឡុងពេលមានគ្រោះមហន្តរាយ។ គម្រោងនេះ មានគោលបំណងជួយបញ្ចូលកុមារី និងទស្សនៈរបស់គេទៅក្នុងដំណើរការនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងដំណើរការធ្វើសេចក្តីសម្រេច។ ក្មេងស្រីទាំងនោះត្រូវបានជ្រើសរើសផ្អែកលើអនុសាសន៍របស់មន្ត្រីក្នុងសាលារៀន និងចៅសង្កាត់។ បន្ទាប់ពីកុមារីទាំងនេះបានចូលក្នុងគម្រោងក្មេងស្រីទាំងនោះបានទទួលការបណ្តុះបណ្តាលរយៈពេលពីរខែដោយ មានការណែនាំពីអ្នកឯកទេសផ្នែកផ្សេងៗដូចជា ផ្នែក សុខភាព ខ្លួនប្រាណនិងសាធារណៈ សុវត្ថិភាពអគ្គីភ័យ ការប្រឹក្សាយោបល់ និងផែនការសម្រាលគ្រោះមហន្តរាយ។ គោលដៅធំបំផុតនៃគម្រោងនេះ គឺចង់ឃើញក្មេងស្រីទាំងនេះចេះរៀបចំព្រឹត្តិការណ៍ និងធ្វើជាម្ចាស់ព្រឹត្តិការណ៍ក្នុងសហគមន៍ ហើយពួកគេនឹងចែកចាយចំណេះដឹងនៃការកាត់បន្ថយហានិភ័យជាមួយបុរស ស្ត្រី និងក្មេងស្រីដទៃទៀតក្នុងសហគមន៍ដើម្បីរៀបចំផែនការសម្រាប់សហគមន៍កាត់បន្ថយផលប៉ះពាល់គ្រោះមហន្តរាយ។ យេនឌ័រគឺជាចំណុចកណ្តាលនៃកម្មវិធីនេះ ហេតុដូច្នេះហើយបានជាមានសារៈសំខាន់ក្នុងការរួមបញ្ចូលវិធីសាស្ត្រ យេនឌ័រទៅក្នុងការអនុវត្តគម្រោងដូចជា ការប្រើប្រាស់អ្នកសម្របសម្រួលស្ត្រីគំរូ។

ក្នុងគំនិតផ្តួចផ្តើមនេះ ក្មេងស្រីមានអាយុចន្លោះពី១៣ទៅ១៨ឆ្នាំត្រូវបានផ្តល់ភាពអង់អាច និងលើកទឹកចិត្តឱ្យបញ្ចេញយោបល់ដែលធ្វើឱ្យមានការទុកចិត្ត និងការគោរព

ព្រមទាំងនឹងមានអ្វីច្រើនទៀត ដើម្បីរួមចំណែកក្នុងទំនាក់ទំនងក្នុងជីវិតគ្រួសារ និងសហគមន៍របស់គេ។

កុមារីចំនួន២៥នាក់ដែលមានអាយុចន្លោះពី ១៣ ទៅ ១៨ឆ្នាំ នឹងក្លាយជាអ្នកទទួលផលប្រយោជន៍ដំបូងពីកម្មវិធីដោយផ្ទាល់។ កម្មវិធីនេះ មិនមែនបង្កើតឡើងដើម្បីគ្រាន់តែផ្តល់ប្រយោជន៍ដល់ក្មេងស្រីតែ២៥នាក់នេះប៉ុណ្ណោះទេ ប៉ុន្តែបានផ្អែកលើមូលដ្ឋានថា ពួកគេនឹងក្លាយជាអ្នកសម្របសម្រួល ជួយផ្សព្វផ្សាយព័ត៌មាន និងផ្តល់នូវសេវាដល់សហគមន៍របស់គេទាំងមូលផងដែរ។ បុរស ស្ត្រី និងក្មេងស្រីក្នុងសហគមន៍សាន់ឌើរតែជើ (ប្រមាណ៣.០០០ គ្រួសារ) នឹងធ្វើការជាមួយក្មេងស្រីទាំងនេះ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្នុងតំបន់ ដើម្បីបង្កើតផែនការគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងសហគមន៍ឱ្យមានប្រសិទ្ធិភាព។ មន្ត្រី តំណាងអាជ្ញាធរក្នុងតំបន់នឹងទទួលបានគំនិតដ៏មានតម្លៃថ្មីៗ អំពីហានិភ័យក្នុងសហគមន៍របស់ពួកគេ។ ចំណេះដឹងនេះអាចនាំឱ្យមានគោលនយោបាយដ៏ប្រសើរ និងជាជំនួយដល់គម្រោងផ្សេងក្នុងពេលអនាគត និងនាំឱ្យមានវិធីសាស្ត្រកាត់បន្ថយគ្រោះមហន្តរាយ កាន់តែមានប្រសិទ្ធភាព ថែមទៀត។

គម្រោងនេះ ដោះស្រាយភាពងាយរងគ្រោះសង្គមរបស់ស្ត្រី ក្មេងស្រីប្រកបដោយប្រសិទ្ធភាពដោយមានការចូលរួមមិនប្រើបច្ចេកទេសខ្ពស់ និងងាយស្រួលធ្វើតាម។ ក្មេងស្រីស្បែកខ្មៅដែលក្រីក្រ ក្នុងទីក្រុងនៅទ្វីបអាហ្វ្រិកខាងត្បូងទទួលរងសម្ពាធពីមនោគមវិជ្ជធម៌ និងសង្គមដែលផ្តល់ឋានៈពួកគេជាអ្នកទន់ទាប។ វិធីសាស្ត្រនៃគម្រោងនេះ គឺពិនិត្យមើលពីមូលហេតុដែលធ្វើឱ្យពួកគេងាយរងគ្រោះ ជាពិសេសទាក់ទងនឹងផ្នែករាងកាយ ការខ្វះធនធាន ខ្វះព័ត៌មាន និងការដែលមិនមានអំណាចក្នុងការធ្វើសេចក្តីសម្រេច។ គម្រោងនេះទទួលស្គាល់ពីភាពស្មុគស្មាញនៃកត្តាពីខាងក្រៅដែលរួមចំណែកធ្វើឱ្យពួកគេងាយរងគ្រោះ ប៉ុន្តែគម្រោងនេះក៏ផ្តល់ឱ្យពួកគេនូវព័ត៌មាន ដែលមានប្រយោជន៍សមរម្យនឹងអាយុ និងជួយកសាងសមត្ថភាពពួកគេផងដែរ។ សមត្ថភាពនេះ លើកទឹកចិត្តផ្ទាល់ក៏ដូចជាជំរុញឱ្យមានការបញ្ចូលសម្លេងរបស់ក្មេងស្រីទាំងនេះ ទៅក្នុងការធ្វើសេចក្តីសម្រេចក្នុងពេលរៀបផែនការគ្រប់គ្រងគ្រោះមហន្តរាយ ប៉ុន្តែក៏ផ្តល់ឱ្យពួកគេនូវមូលដ្ឋានគ្រឹះ ក្នុងការលើកកម្ពស់ការគោរពកាន់ខ្លាំងថែមទៀត ក្នុងនាមជាសមាជិកស្មើភាពគ្នាក្នុងសហគមន៍។ គម្រោងនេះមិនមានបំណងចង់រក្សាក្មេងស្រីដែលឆ្លាតៗ ទុកនៅដោយឡែកនោះទេ ប៉ុន្តែអភិវឌ្ឍពួកគេឱ្យក្លាយជា អ្នកដឹកនាំគំរូ និងជាអ្នកសម្របសម្រួលដើម្បីជួយកែលម្អស្ថានភាពរបស់បុរស ស្ត្រី និងកុមារា កុមារី ដែលរស់នៅក្នុង សហគមន៍របស់ពួកគេ។

## ករណីសិក្សាទី២

# តួនាទីយេនឌ័រនៅក្នុងគ្រោះមហន្តរាយនៅក្នុងប្រទេសនានាលើកោះ ជាប់មហាសមុទ្រប៉ាស៊ីហ្វិក

ការពិគ្រោះយោបល់នៅសហគមន៍ពីការទប់ស្កាត់គ្រោះមហន្តរាយនៅក្នុងកោះសាម៉ោ កោះសាឡូម៉ូន កោះហ្វីជី និងកោះគីរីបាទី បានបង្ហាញអំពីភាពខុសគ្នាទាក់ទងនឹងរបៀបដែលស្ត្រី និងបុរសយល់ឃើញ និងដោះស្រាយគ្រោះមហន្តរាយ និងការរៀបចំខ្លួន។ ការពិគ្រោះយោបល់នោះគឺជាផ្នែកមួយនៃការសិក្សា ដើម្បីអភិវឌ្ឍនូវការយល់ដឹងអំពីស្ថានភាព តួនាទី និងទំនួលខុសត្រូវរបស់ស្ត្រី និងបុរសនៅតាមក្រុមគ្រួសារ និងសហគមន៍នៅកោះប៉ាស៊ីហ្វិក ដោយមានបំណងរៀបចំយុទ្ធសាស្ត្រ និងកម្មវិធីដែលបញ្ចូលយេនឌ័រ និងជួយបញ្ជ្រាបឱ្យស្ត្រីដឹងអំពីកម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ស្រុក ថ្នាក់ជាតិ និងថ្នាក់តំបន់។

### វិធីសាស្ត្រ

នៅពេលដែល ការបែកចែកការងាររវាង បុរស និងស្ត្រីមានភាពខុសគ្នាគួរឱ្យកត់សំគាល់នៅក្នុង និងរវាងប្រទេសក្នុងកោះប៉ាស៊ីហ្វិក ការពិតដ៏សំខាន់បំផុតអំពីតួនាទីយេនឌ័រដែលបានបង្ហាញដោយការសិក្សានេះគឺថា ខ្សែមួយត្រូវបានគូសបែងចែកនៅក្នុងប្រទេសទាំងអស់ រវាងសិទ្ធិអំណាចបែបឯកជន និងសាធារណៈ ឬផ្លូវការ និងមិនផ្លូវការ។ ដោយមានករណីលើកលែងតិចតួច នៅក្នុងប្រទេសទាំងអស់ស្ត្រីមានទំនួលខុសត្រូវលើកិច្ចការផ្ទះ គាត់ត្រូវដឹងប្រាកដថាតម្រូវការខាងរូបកាយរបស់មនុស្សម្នាក់ៗត្រូវ បានបំពេញ ហើយកុមារ និងមនុស្សចាស់ត្រូវបានមើលថែទាំដោយឱ្យពួកគេមានទឹកប្រេង អាហារមានកន្លែងគេង កន្ទេល ទំនិញ និងសម្លៀកបំពាក់នៅក្នុងផ្ទះគ្រប់គ្រាន់ ហើយត្រូវប្រាកដថារបស់របរនៅក្នុងផ្ទះនិងបរិវេណជុំវិញផ្ទះ មានសោភណភាពស្អាតល្អ។ បុរសៗធ្វើសេចក្តីសម្រេចនៅក្នុងផ្នែកសាធារណៈ (ឧ. ទាក់ទងនឹងទំនាក់ទំនងនៅក្នុងក្រុមគ្រួសារ និងរវាងក្រុមគ្រួសារដទៃទៀត សាច់ញាតិបងប្អូន ភូមិ ស្រុក ខេត្ត និងរាជរដ្ឋាភិបាល)។ នៅក្នុងប្រទេសសាម៉ោ ស្ត្រីៗមានសិទ្ធិអំណាចផ្នែកសាធារណៈច្រើនជាង នៅក្នុងប្រទេសដទៃទៀត ទោះបីជាមាននៅត្រឹមតែការធ្វើសេចក្តីសម្រេច នៅក្នុងផ្នែកទឹក សុខភាព អនាម័យ ការលម្អ និងការរួសរាយរាក់ទាក់ក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ ការកើនឡើងនូវតួនាទីក្នុងការផ្គត់ផ្គង់សេវាទឹក និងអនាម័យ និងការរីកចម្រើននៃមជ្ឈការនៃសេវាសុខភាពមានន័យថា ទំនួលខុសត្រូវរបស់ស្ត្រីនៅក្នុងផ្នែកទាំងនេះកំពុងតែថយចុះ ហើយការផ្គត់ផ្គង់ទឹកកំពុងតែបញ្ចូលបន្តិចម្តងៗ ទៅក្នុងហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិ នៅក្រោមរដ្ឋាករទឹក ហើយបញ្ហាទាំងនេះបានប្តូរពីគណៈថ្នាក់ជាតិនៃមេភូមិ ការប្រជុំប្រចាំខែជាមួយភ្នាក់ងាររដ្ឋាភិបាល។

នៅក្នុងកោះហ្វីជី សាឡូម៉ូន និងគីរីបាទី សមាគមស្ត្រីមិនមានសិទ្ធិអំណាចក្នុងស្រុកច្រើនប៉ុន្មានទេ ប៉ុន្តែសមាគមន៍ខ្លះមានឥទ្ធិពលដែរ។ សមាគមទាំងនោះ គឺជាក្រុមជំនុំដែលធ្វើការនៅក្នុងសហគមន៍ ជារឿយៗចូលរួមជាមួយអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត។ ភាពផ្តាច់ការរបស់បុរសក្នុងការធ្វើសេចក្តីសម្រេចនៅក្រៅផ្ទះ គឺជាការពិតដ៏សំខាន់ដែលត្រូវទទួលស្គាល់សម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ។ ការទប់ស្កាត់គ្រោះមហន្តរាយ នឹងមានប្រសិទ្ធភាពតិចតួចដោយសារតែមិនបានដោះស្រាយដោយវិធានការដាក់ស្តែងសម្រាប់ការត្រៀមខ្លួននៅតាមផ្ទះ។ តាមរយៈការបញ្ចូលស្ត្រីនៅក្នុងការរៀបចំផែនការគ្រប់គ្រងគ្រោះមហន្តរាយ និងការសម្រេចចិត្ត នោះលទ្ធផលនឹងសម្រេចបានកាន់តែប្រសើរ។

នៅពេលដែលបុរស និងស្ត្រីត្រូវបានស្នើ សុំជាផ្លូវការថានរណាត្រូវធ្វើសេចក្តីសម្រេចអំពីការប្រើប្រាស់ធនធានក្នុងផ្ទះដូចជាការបែងចែកការងារទំនិញនិងលុយកាក់ភាគច្រើន

បុរសទំនងជានិយាយថា ការសម្រេចចិត្តត្រូវតែធ្វើដោយមេគ្រួសារ(បុរស)។ ផ្ទុយទៅវិញ ស្ត្រីទំនងជានិយាយថា ប្តីនិងប្រពន្ធធ្វើការសម្រេចចិត្តជាមួយគ្នា។ ជាការពិតប្រសិនបើអាទិភាពរបស់ស្ត្រីមានភាពខុសគ្នាពីអាទិភាពរបស់បុរស អាទិភាពរបស់ស្ត្រីនឹងទំនងជាមិនត្រូវបានបំពេញឡើយ ពីព្រោះពួកគេមានអំណាចខាងសង្គម និងសេដ្ឋកិច្ចតិចតួច។

ស្ត្រីភាគច្រើនបានដឹងថា នៅពេលដែលឮសញ្ញានៃគ្រោះមហន្តរាយ គឺជាការចាំបាច់ដែលត្រូវរក្សាទុកនូវអាហារប្រេង និងទឹក។ ទោះបីជាយ៉ាងណាក៏ដោយ ចំពោះការអនុវត្តពិតៗ អំពីរបៀបដែលត្រូវរក្សាទុករបស់ទាំងអស់នៅក្នុងពេលមួយសប្តាហ៍ ឬពីរសប្តាហ៍ចុងក្រោយអំពីកន្លែង និងរបៀបដែលរបស់របរ និងទ្រព្យសម្បត្តិនៅក្នុងផ្ទះត្រូវរក្សាទុកដាក់ឱ្យមានសុវត្ថិភាព មានមនុស្សតិចតួចណាស់ដែលអាចឆ្លើយសំណួរទាំងនេះ។ ចំណេះដឹងអំពីហានិភ័យខាងសុខភាព និងរបៀបព្យាបាលសុខភាពរបស់ខ្លួនដូចជានៅមានកម្រិត។ មនុស្សនៅលើកោះគីរីបាទីត្រូវបានស្លាប់ដោយសារតែជម្ងឺរាគមួល ប៉ុន្តែរបៀបព្យាបាលដ៏សាមញ្ញ និងមានតម្លៃថោកនៃការព្យាបាលបញ្ចូលទឹកតាមមាត់ជាវិធីសាស្ត្រដែលមានគេប្រើ ប៉ុន្តែមានមនុស្សតិចតួចណាស់ដែលបានឮអំពីវិធីសាស្ត្រនេះ។

សង្ខេបនៅក្នុងរូបភាពខាងក្រោម អំណាចខាងសង្គមតិចតួចរបស់ស្ត្រី បានធ្វើឱ្យក្រុមគ្រួសារងាយនឹងរងគ្រោះទៅនឹងគ្រោះមហន្តរាយកាន់តែកើនឡើង។

អនុសាសន៍មួយចំនួនផ្អែកលើការសិក្សានេះមាន៖

- បុរសត្រូវតែទទួលការលើកទឹកចិត្តឱ្យស្គាល់ពីតម្រូវការ និងគាំទ្រដល់ការធ្វើសេចក្តីសម្រេចរួមគ្នាជាមួយស្ត្រីអំពីការត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយ។
- ទាំងស្ត្រីនិងបុរសត្រូវតែចូលរួមនៅក្នុងការរៀបចំផែនការនៃការគ្រប់គ្រងគ្រោះមហន្តរាយ។
- គណៈកម្មការជាតិនៃការគ្រប់គ្រងគ្រោះមហន្តរាយត្រូវតែបញ្ចូលអ្នកតំណាងពីថ្នាក់ជាន់ខ្ពស់ពីអង្គការស្ត្រីថ្នាក់ជាតិដើម្បីបង្កើនការផ្តោតទៅលើការទប់ស្កាត់ និងការរៀបចំខ្លួន។

**ដកស្រង់ចេញពី៖**

កម្មវិធីកាត់បន្ថយគ្រោះមហន្តរាយ ប៉ាស៊ីហ្វិកខាងត្បូង (SPDRP)។ 2002. ការគ្រប់គ្រងយេនឌ័រ គ្រួសារ និងសហគមន៍ និងគ្រោះមហន្តរាយ៖ ករណីសិក្សាចេញពីតំបន់កោះប៉ាស៊ីហ្វិក។ (SOPAC Technical Report 282). Resource presented at Gendered Dimensions of Disaster Risk Management and Adaptation to Climate Change in the Pacific Islands, AusAID and UNDP Pacific Center Workshop, 20-21 February, 2008, Fiji.





## ករណីសិក្សាទី៣

# យុទ្ធសាស្ត្រវិញ្ញាចយេនឌ័រសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុៈ ដកស្រង់ចេញពីបទពិសោធន៍កសិករឥណ្ឌា

"ប្រសិនបើភ្លៀងធ្លាក់នៅក្នុងខែតុលា (យឺតពេកសម្រាប់ដំណាំសណ្តែកដី) យើងអាចនៅតែសាបព្រួស។ ប្រភេទនៃដំណាំត្រូវបានសម្រេចចិត្តដោយមានការសុំយោបល់ពីស្ត្រីដែលតែងតែចង់មានដំណាំជាអាហារ។"

"អាហារ (ស្រូវមីយេ) ពីមុនមានអាហារូបត្ថម្ភច្រើន យើងត្រូវការទឹកដោះគោច្រើន និងអាហារដែលមានជាតិទឹកដោះ ហើយរបបអាហាររបស់យើងមានតុល្យភាពជាង។"

*ការពិភាក្សាក្រុមគោលដៅជាមួយកសិករស្ត្រី និងបុរស (ជាមធ្យម មានដី២អា)*

*ភូមិមិតាម៉ាឡាប៉ាលី ស្រុក ម៉ាដាណាប៉ាលី ខេត្ត អានដ្រាប្រាដិស*

បុរស និងស្ត្រីនៅតាមតំបន់ដាច់ស្រយាលនៃខេត្ត អានដ្រាប្រាដិស ក្នុងប្រទេសឥណ្ឌាកំពុងតែពិនិត្យមើលការប្រែប្រួលនៃស្ថានភាពអាកាសធាតុ ដែលពួកគេបានដឹងតាមរយៈការធ្វើកសិកម្មជាច្រើនឆ្នាំ ហើយពួកគេបានរាយការណ៍មកថា សីតុណ្ហភាពកាន់តែក្តៅទៅៗ ហើយការធ្លាក់ភ្លៀងក៏កំពុងតែប្រែប្រួលផងដែរ។ ក្នុងពេលដូចគ្នានេះដែរ ហើយប្រហែលជាពាក់ព័ន្ធទៅនឹងការប្រែប្រួលនេះ អាហារដែលពួកគេបរិភោគសព្វថ្ងៃ មិនសូវមានអាហារូបត្ថម្ភដូចមុនឡើយ។

ក្នុងកំឡុងពេលសន្ទនា ជាមួយកសិករអំពីរបៀបដែលពួកគេកំពុងដោះស្រាយ អំពីការប្រែប្រួលអាកាសធាតុនេះ បានជួយយើងឱ្យដឹងច្បាស់ថា បុរស និងស្ត្រីមានសាច់រឿងខុសៗគ្នាដែលត្រូវនិយាយ។ បុរសនិយាយអំពីការចំណាកស្រុកខណៈពេលដែលស្ត្រីវិញនិយាយអំពី សកម្មភាពថ្មីដែលត្រូវធ្វើនៅផ្ទះ។ របាយការណ៍ទាំងនេះ លើកឡើងថាតួនាទីយេនឌ័រទាក់ទងនឹងឥរិយាបថ ការងារ និងទំនួលខុសត្រូវដែលសង្គមកំណត់ថាជារបស់ "បុរស" ឬ "ស្ត្រី" បានរៀបចំសកម្មភាពរបស់កសិករ ស្ត្រី និងបុរសនៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

តើបញ្ហាយេនឌ័ររបស់កសិករ មានឥទ្ធិពលលើការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុបានកម្រិតណា? តើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនេះ ដែលមានទៅលើសន្តិសុខស្បៀងមានភាពខុសគ្នាសម្រាប់ស្ត្រី និងបុរសដែរឬទេ?

មានកិច្ចការងារបន្តិចបន្តួច ត្រូវបានធ្វើដើម្បីឆ្លើយតបទៅនឹងសំណួរទាំងនេះ អំពីភាពភ្ជាប់គ្នារវាងតួនាទីយេនឌ័រ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្រៅពីកិច្ចខិតខំប្រឹងប្រែងដ៏ធំជាអន្តរជាតិ ដើម្បីយល់និងកាត់បន្ថយភាពងាយរងគ្រោះរបស់ជនក្រីក្រ ហើយពិសេសសម្រាប់កសិករដែលប្រឈមមុខនឹងហានិភ័យនៃការប្រែប្រួលអាកាសធាតុរយៈពេលវែង។វិធីសាស្ត្រត្រូវការជាចាំបាច់ដើម្បីរក្សាទុកជាឯកសារស្តីពីអ្វីដែលស្ត្រី និងបុរសត្រូវដឹងអំពីការប្រែប្រួលអាកាសធាតុ និងរបៀបដែលពួកគេត្រូវដោះស្រាយដើម្បីធានាថាសន្តិសុខស្បៀងរបស់បុគ្គល និងគ្រួសារមានគ្រប់គ្រាន់។ឧបករណ៍ត្រូវការជាចាំបាច់ដើម្បីបញ្ចូលចំណេះដឹង និងតម្រូវការស្ត្រីនិងបុរសចូលទៅក្នុងយុទ្ធសាស្ត្រ ដើម្បីដោះស្រាយការប្រែប្រួលរយៈពេលវែង។

ដោយសារកិច្ចសហការជាមួយស្ថាប័ន ឥណ្ឌាចំនួនបី (មជ្ឈមណ្ឌលធនធានយេនឌ័រ សាម៉ាថា (SGRC) សាកលវិទ្យាល័យកសិកម្មអាចារីយាអានជី (ANGRAU) និងមូលនិធិស៊ូស្លូន យេនឌ័រ សមធម៌និងនាយកដ្ឋានការងារសម្រាប់ជនបទ (ESW) នៃFAO កំពុងតែធ្វើគម្រោងសិក្សាស្រាវជ្រាវនៅក្នុងខេត្តអានដ្រាប្រាដិស ដើម្បីធ្វើតេស្តសម្មតិកម្មថា ស្ត្រី និងបុរសរងផលប៉ះពាល់ផ្សេងគ្នា និងត្រូវដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុខុសៗគ្នាផងដែរ។

ការភ្ជាប់ទំនាក់ទំនងជាមួយទីប្រឹក្សាក្នុងស្រុក ដែលមានបទពិសោធន៍នៅក្នុងប្រទេស និងបញ្ហាខាងប្រព័ន្ធអេកូឡូស៊ីកំពុងតែធ្វើការសិក្សាស្រាវជ្រាវនៅក្នុងស្រុកចំនួនបី ដើម្បីប្រមូលទិន្នន័យបែបគុណភាព និងបរិមាណតាមរយៈវិធីសាស្ត្រឱ្យកសិករដែលរស់នៅពឹងផ្អែកលើទឹកភ្លៀងសម្រាប់កសិកម្មចូលរួម។ ដោយផ្សំជាមួយនឹងការវិភាគនៃបរិបទស្ថាប័ន និងនិន្នាការនៃកំណត់ត្រាឧតុនិយម ត្រូវបានប្រើប្រាស់ដើម្បីរក្សាទុកជាឯកសារនូវហានិភ័យនៃអាកាសធាតុដែលកសិករស្ត្រី និងបុរសកំពុងតែប្រឈមមុខនៅក្នុងការធានាសន្តិសុខស្បៀង និងយុទ្ធសាស្ត្រដែលពួកគេកំពុងតែអភិវឌ្ឍដើម្បីដោះស្រាយកត្តាថ្មីៗដែលគំរាមកំហែងដល់ជីវភាពរបស់ពួកគេសព្វថ្ងៃ។

ការសិក្សាស្រាវជ្រាវត្រូវបានបង្កើតឡើង ដើម្បីអភិវឌ្ឍនូវវិធីសាស្ត្រសម្រាប់ការរកឱ្យឃើញនូវទំហំយេនឌ័រ ក្នុងការដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក៏ដូចជាដើម្បីបង្កើតនូវចំណេះដឹងថ្មីអំពីរបៀបដែលជីវភាពរបស់ពួកគេត្រូវបានកែប្រែ និងរបៀបដែលយុទ្ធសាស្ត្រថ្មីត្រូវបានបង្កើតឡើងសម្រាប់សន្តិសុខស្បៀង។ ការរកឃើញនៃករណីសិក្សានេះនឹងមានផលប្រយោជន៍ដល់ FAO នៅក្នុងការផ្តល់ដំបូន្មានដល់អ្នកដែលបង្កើតគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចដែលជាមនុស្សដ៏សំខាន់កំពុងធ្វើការពិភាក្សាអំពីការប្រែប្រួលអាកាសធាតុ។ លទ្ធផលនឹងជាជំនួយមួយដល់ការរៀបចំផែនការសម្រាប់ការបន្សាំទៅនឹង ការប្រែប្រួលរយៈពេលវែង ដែលត្រូវតែបង្កើតឡើងនៅក្នុងចំណេះដឹងរបស់កសិករស្ត្រី និងបុរស និងកិច្ចខិតខំប្រឹងប្រែងធ្វើការដើម្បីឱ្យមានសមភាពយេនឌ័រ។

*ប្រភព៖*

*បណ្ឌិត យីអាណា ឡាំប្រ៊ូ ជាមន្ត្រីជាន់ខ្ពស់*

*ESW FAO*

*ទីក្រុង រ៉ូម*

*Yianna.lambrou@fao.org*

## ករណីសិក្សាទី៤

# ផលប៉ះពាល់នៃគ្រោះថ្នាក់ទៅលើស្ត្រីនិងកុមារ៖ ស្ថានភាពនៅក្នុងអាស៊ីខាងត្បូង

អាស៊ីខាងត្បូងគឺជាទ្វីបមួយ ដែលត្រូវបានគេស្គាល់ថាជាតំបន់ដែលមានប្រជាជនក្រីក្រច្រើនជាងគេបំផុតនៅលើពិភពលោក ហើយក៏ជាតំបន់ដែលងាយរងគ្រោះថ្នាក់ដោយកត្តាធម្មជាតិធ្ងន់ធ្ងរដោយសារស្ថានភាពភូមិសាស្ត្ររបស់ទ្វីបនេះផងដែរ។នៅកំឡុងឆ្នាំ១៩៩០-៩២ប្រទេសបង់ក្លាដេសតែមួយបានរងគ្រោះដោយសារខ្យល់ព្យុះចំនួនបីដង ទឹកជំនន់ចំនួនបួនដង ស៊ូណាមីម្តង និងព្យុះស៊ីក្លូនចំនួនពីរដងដែលបានសម្លាប់មនុស្សជាង ៤.០០០.០០០នាក់ ហើយបានប៉ះពាល់ដល់មនុស្សចំនួន៤២លាននាក់។ ការសិក្សានេះវិភាគផលប៉ះពាល់នៃគ្រោះមហន្តរាយដែលមានទៅលើស្ត្រី និងកុមារ ដោយបញ្ជាក់ថាស្ត្រី និងកុមារងាយទទួលរងគ្រោះខ្លាំងជាងបុរស។ការសិក្សានេះបង្ហាញថាស្ទើរតែមិនអាចទៅរួចឡើយសម្រាប់ស្ត្រីដែលស្ថិតនៅក្នុងក្រុមក្រីក្រ និងក្រុមងាយរងគ្រោះដើម្បីត្រឡប់ទៅរកភាពដើមវិញ បន្ទាប់ពីព្រឹត្តិការណ៍ដ៏អាក្រក់ទាំងនោះ។លទ្ធផលនៅក្នុងសេណារីយ៉ូដ៏អាក្រក់នេះជារឿយៗធ្វើឱ្យស្ត្រី និងកូនគ្មាននៅសល់អ្វីឡើយ។ បញ្ហានេះក៏មានគុណវិបត្តិយ៉ាងច្រើនជាមួយនឹងប្រព័ន្ធច្បាប់ហើយកាន់តែអាក្រក់ជាងនេះទៅទៀត ស្ត្រីភាគច្រើនដែលមិនចេះអក្សរ ឬចេះអក្សរតិចតួចដែលគ្មានធនធានហិរញ្ញវត្ថុយល់ថា ស្ទើរតែមិនអាចទៅរួចក្នុងការសុំការការពារពីផ្នែកច្បាប់។

គុណតម្លៃសង្គមដ៏ខ្ពស់នៃអាពាហ៍ពិពាហ៍ក៏ដើរតួដ៏សំខាន់នៅក្នុងផលប៉ះពាល់នៃគ្រោះមហន្តរាយចំពោះស្ត្រីផងដែរ។ ចេញពីទស្សនៈរបស់ស្ត្រីដែលរងផលប៉ះពាល់ បាននិយាយថាដី និងផ្ទះរបស់ពួកគេត្រូវបានរសាត់ទៅតាមទឹកទន្លេបន្តិចម្តងៗដែលបានបដិសេធ ឬពន្យារពេលដល់ឱកាសអាពាហ៍ពិពាហ៍របស់ពួកគេ។ ការពន្យារពេលអាពាហ៍ពិពាហ៍នៅក្នុងបរិយាកាសគៀបសង្កត់ដ៏ខ្លាំងនៃសង្គមដ៏តឹងរ៉ឹងនេះបានបង្កឱ្យមានបញ្ហាផ្លូវចិត្តជាច្រើនសម្រាប់ក្មេងស្រី ដែលធ្វើឱ្យពួកគេមានអារម្មណ៍ថា ខ្លួនគ្មានតម្លៃ និងមានអារម្មណ៍អាណិតខ្លួន។ ជាការគួរឱ្យស្ងើចសរសើរអំពីរបៀបនៃការរស់នៅក្នុងទំនាក់ទំនងដ៏ងាយរងគ្រោះ ប៉ុន្តែស្ត្រីនៅក្នុងតំបន់អាស៊ីខាងត្បូងបង្ហាញ អំពីកម្លាំង និងសមត្ថភាពដ៏សំបើមដើម្បីឆ្លងកាត់វដ្តនៃគ្រោះមហន្តរាយទាំងមូល និងនៅក្នុងការរៀបចំខ្លួន ដើម្បីប្រឈមជាមួយនឹងគ្រោះចៃដន្យនេះ ចេះគ្រប់គ្រងពេលគ្រោះមហន្តរាយមកដល់ វាយប្រហារ និងកសាងជីវភាពដែលខូចខាតរបស់ពួកគេឡើងវិញ។ ដូចជាការសង្កេតនៅក្នុងករណីសិក្សាដទៃទៀតជារឿយៗ មានតែស្ត្រី កុមារ និងមនុស្សចាស់ប៉ុណ្ណោះដែលស្ថិតនៅក្នុងភូមិ ហើយជាប់នៅក្នុងទឹកជំនន់រហូតដល់ទឹកជំនន់ ស្រក ឬព្យាយាមគ្រប់គ្រងរហូតដល់មានភ្លៀងធ្លាក់នៅក្នុងពេលមានគ្រោះរាំងស្ងួតយូរ។ ក្នុងពេលមានវិបត្តិ ការមើលថែរបស់របរដ៏តិចតួចរបស់ក្រុមគ្រួសារការធានា អំពីអាហារ និងទឹកសម្រាប់សមាជិកគ្រួសារ ការគិតគូរអំពីការកសាងជីវភាពឡើងវិញ ការរក្សាទុកគ្រាប់ពូជ និងសម្ភារៈផលិតកម្មដទៃទៀត ការមើលថែទាំអ្នកជម្ងឺ និងមនុស្សចាស់ជារឿយៗ ស្ត្រីជាអ្នកធ្វើការទាំងអស់នេះ។

*ប្រភព៖ Madhavi Malalgoda Ariyabandu*

*Intermediate Technology Development Group*

*Paper Presented at "Reaching Women and Children in Disasters" Laboratory for Social and Behavioral Research Florida International University U.S.A*

*June 2000*

*Available from the Gender and Disaster Network, Northumbria University, Division of Geography and Environmental Management:*

*http://gdnonline.org/resources/ariyabandu paper.doc*

## ករណីសិក្សាទី៥

# ស្ត្រីនឹងកសាងម៉ាយអាមីឡើងវិញ៖ ករណីសិក្សារបស់ក្រុមស្ត្រីនិយមដែលឆ្លើយតបទៅនឹងគ្រោះមហន្តរាយ

ករណីសិក្សានេះ ផ្តោតទៅលើតួនាទីរបស់ស្ត្រីនៅក្នុងការស្តារឡើងវិញនូវគ្រោះមហន្តរាយ ដោយផ្តោតទៅលើព្រឹត្តិការណ៍ផ្សេងៗដែលកើតឡើងនៅក្នុងឆ្នាំ ១៩៩៤ នៅក្នុងរដ្ឋម៉ាយអាមី បង្កឡើងដោយខ្យល់ព្យុះហ៊ីរីខេន អេនឌ្រូ។ ភាពងាយរងគ្រោះរបស់ស្ត្រីលើផ្នែកយេនឌ័រ ដោយសារគ្រោះថ្នាក់ត្រូវបានរក្សាទុកជាឯកសារបានយ៉ាងល្អ (Wiest et al., 1994; Blaikie et al., 1994) ប៉ុន្តែតួនាទីរបស់ស្ត្រីក្នុងការត្រៀមទុកបន្ទាប់ពីគ្រោះមហន្តរាយត្រូវបានស្រាវជ្រាវតិចតួចប៉ុណ្ណោះ។ ពួកគេបានក្លាយជាជនរងគ្រោះដែលគ្មានទីពឹង ដោយផ្តល់ឱ្យបុរសនូវមុខងារដ៏សំខាន់ក្នុងការស្តារឡើងវិញនូវគ្រោះមហន្តរាយ។ ទំនាក់ទំនងយេនឌ័រនៅក្នុងសតវត្សទី២០ មាននិន្នាការដាក់ស្ត្រីទៅក្នុងតួនាទីដ៏សំខាន់ក្នុងការស្តារឡើងវិញនូវគ្រោះមហន្តរាយ ដោយផ្អែកលើតួនាទីនៃកសាងសហគមន៍បែបប្រពៃណីរបស់គេ។ សង្គមវិទូ និងប្រវត្តិវិទូសង្គមបានរក្សាទុកជាឯកសារអំពីប្រវត្តិរបស់ស្ត្រីជាសកម្មជន ដែលពាក់ព័ន្ធនឹងបញ្ហានេះ។ គ្រោះមហន្តរាយ ក៏អាចបំផ្លាញដល់ហេដ្ឋារចនាសម្ព័ន្ធប្រពៃណីដែលយើងស្គាល់ ដែលនាំឱ្យពួកគេចូលរួមចំណែកនៅក្នុងការផ្តល់ជាជំនួយសង្គ្រោះសម្រាប់គ្រោះមហន្តរាយ។ កិច្ចខិតខំប្រឹងប្រែងធ្វើការងារស្ម័គ្រចិត្តរបស់ស្ត្រីនៅក្នុងការរៀបចំសម្រាប់គ្រោះមហន្តរាយ ធ្វើឱ្យពួកគេក្លាយជាតួអង្គសំខាន់នៅក្នុងភ្នាក់ងារសង្គ្រោះដូចជា ករណីកាកបាទក្រហម។

ព្យុះហ៊ីរីខេនអេនឌ្រូ បានបោកបក់មកលើផ្នែកខាងត្បូងនៃទីក្រុងម៉ាយអេមីក្នុងរដ្ឋ ផ្លរីដា នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ ១៩៩២ ធ្វើឱ្យមនុស្ស ជាង ១៨០.០០០នាក់ ចាកចោលទីលំនៅនិងបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ប្រជាជនចំនួន ៣៧៥.០០០នាក់។ ក្រុមវប្បធម៌ទាំងអស់ត្រូវបានរងផលប៉ះពាល់។ ភ្នាក់ងារផ្តល់សេវា សង្គម និងមនុស្សធម៌ បានពង្រីកធនធានរបស់ពួកគេ ដើម្បីជួយដល់ការស្តារគ្រោះមហន្តរាយនេះ។ ការនេះបាននាំឱ្យមានមូលនិធិមួយឈ្មោះថា "យើងនឹងកសាងឡើងវិញ" ដែលមានបុរសភាគច្រើនគ្រប់គ្រង ទទួលការរិះគន់សម្រាប់វិធីសាស្ត្រ ប្រសិទ្ធភាព និងការគ្រប់គ្រងថវិកា។ ក្នុងឋានៈ ជាអ្នកកសាងឡើងវិញ បានក្លាយទៅជាសម្ព័ន្ធនៃក្រុមស្ត្រីមួយ ដែលផ្តោតទៅលើធនធានដែលខ្លួន មានដើម្បីបំពេញតម្រូវការនៃវិបត្តិរបស់ស្ត្រី និងក្រុមគ្រួសាររបស់ពួកគេ។ សម្ព័ន្ធដែលមានក្រុមស្ត្រីជាង ៥០ក្រុម បានក្លាយទៅជាកម្លាំងមួយដែលផ្តុំឡើងសម្រាប់ការកែលម្អសិទ្ធិរបស់ស្ត្រីឱ្យប្រសើរឡើង នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច សម្រាប់ការសង្គ្រោះនៃគ្រោះមហន្តរាយ។ ពួកគេបានក្លាយជាអ្នកតំណាងស្ត្រីដ៏ធំគួរសមនៅក្នុងគម្រោង យើងនឹងកសាងឡើងវិញ ក៏ដូចជាការបង្កើតនូវគណៈកម្មការចំនួនពីរ (ក្រុមគ្រួសារ គ្រួសារ និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ) នៅក្នុងចំណោមកិច្ចការដទៃទៀត។

"ស្ត្រីនឹងកសាងឡើងវិញ" បានទទួលជោគជ័យក្នុងការបង្រួបបង្រួមសហគមន៍ ស្ត្រីដ៏ធំនៅជុំវិញបញ្ហាតែមួយ ក្នុងពេលមានវិបត្តិ។ ទោះបីជាយ៉ាងណាក៏ដោយសម្ព័ន្ធ ស្ត្រីបានទទួលការរិះគន់យ៉ាងខ្លាំងពីសំណាក់ អង្គការផ្តោតលើបុរសថា មិនអាចផ្តល់និងមានគុណតម្លៃស្ត្រី ដែលជាផ្នែកមួយនៃហេដ្ឋារចនាសម្ព័ន្ធ ប៉ះទង្គិចដល់គោលដៅរបស់ពួកគេ។

*ប្រភព៖ Elaine Enarson and Betty Hearn Morrow*

*Available through: Chapter 17 in Enarson and Morrow (Eds), The Gendered Terrain of Disaster. Downloadable at:*

*http://www.crid.or.cr/digitalizacion/pdf/eng/doc-12898doc12898.pdf*

# ការប្រជុំផែនការថ្នាក់ជាតិអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ





**គោលបំណង ៖** ស្វែងរកវិធីសាស្ត្រក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងការរៀបចំផែនការបន្សាំ តាមរយៈវិធីសាស្ត្រនៃការចូលរួម

**សម្ភារៈ ៖** ថតចម្លងឯកសារ NAPA ចែកជូនដល់សិក្ខាកាមម្នាក់ៗនៅក្នុងក្រុមតូច ជាមួយនឹងតួនាទីខុសៗគ្នា ក្រដាសផ្ទាំងធំ និងក្រដាសសម្រាប់ក្រុមនីមួយៗ និងប៊ិច ហ្វឺត។

**ដំណើរការ ៖**

១) បែងចែកមនុស្សទៅជាក្រុមតូចៗ កំណត់ប្រទេសមួយសម្រាប់ពួកគេ និងចែកឯកសារ NAPA របស់ប្រទេសនោះដល់ពួកគេ។

២) ចាត់មនុស្សទៅកាន់ក្រុមតំណាងឱ្យប្រទេសមួយ ដោយមានតួនាទីខុសៗគ្នាសម្រាប់សិក្ខាកាមនីមួយៗ ដោយហុចឱ្យពួកគេនូវ table tent:

ក. គណៈអធិបតីនៃគណៈកម្មការថ្នាក់ជាតិនៃការប្រែប្រួលអាកាសធាតុ (នេះគួរតែជាមនុស្សម្នាក់ដែលអ្នកគិតថាគាត់ជាមនុស្សដែលពូកែសម្របសម្រួល)។

ខ. ប្រធាននៃបណ្តាញស្ត្រីនៅជនបទ

គ. រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

ឃ. រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងថាមពល

ង. បុគ្គលិកវិស័យក្រៅប្រព័ន្ធ

ច. នាយកនៃ “សាមគ្គីភាពសម្រាប់ព្រៃឈើ” (NGO)

ឆ. នាយកនៃវិទ្យាស្ថានជាតិសុខភាព

ជ. ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម

ឈ. ជនបង្គោលថ្នាក់ជាតិនៃ UNFCCC

ញ. អ្នកកាសែតសម្រាប់ព័ត៌មានជាតិ

Table Tent នឹងអានឧទាហរណ៍ដូចជា៖ អ្នកកាសែតសម្រាប់ព័ត៌មានជាតិ/ម៉ាឡាវី។ ចូរប្រើតួនាទីទាំងនេះតាមលំដាប់អាទិភាព ដោយអាស្រ័យលើចំនួនសិក្ខាកាមនៅក្នុងក្រុមតូច។ សិក្ខាកាមស្ត្រី និងបុរសអាចមានតួនាទីណាមួយ ហើយនៅក្នុងករណីខ្លះអាចមានប្រយោជន៍ក្នុងការចាត់តួនាទីមួយដល់ក្រុមយេនឌ័រមិនមែនប្រពៃណី។

៣) សុំឱ្យម្នាក់ៗអានម្នាក់ឯងនូវ NAPA ដែលបានចាត់តាំងសម្រាប់ក្រុមរបស់ពួកគេអំពីទស្សនៈ នៃតួនាទីនៅលើ table tent របស់ពួកគេ។

៤) នៅក្នុងក្រុមតូច ចូរពិភាក្សាអំពីរបៀបផ្សេងៗដែលស្ត្រី និងបុរសអាចរងឥទ្ធិពលខុសៗគ្នាពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសនោះ។

៥) ចូរប្រមូលគំនិតអំពីសកម្មភាពផ្សេងៗ ដែលអាចធ្វើបានដោយតួនាទីនីមួយៗនៅក្នុងក្រុម។ នៅលើក្រដាសផ្ទាំងធំចូរពង្រាងអំពីផែនការអនុវត្តដែលដាក់បញ្ចូលតួនាទីរបស់មនុស្សគ្រប់គ្នា។

៦) ជ្រើសរើសអ្នករាយការណ៍ម្នាក់ដើម្បីធ្វើបទបង្ហាញអំពីផែនការនៅក្នុងការប្រជុំនៅក្នុងតួនាទីដែលបានចាត់តាំង។ គ្រប់គ្នាបង្ហាញ table tents របស់ពួកគេ ហើយក្រុមតូចនីមួយៗធ្វើបទបង្ហាញ។

# សំណួរ និងចម្លើយ ជាមួយនឹងទីប្រឹក្សាយេនឌ័រ




**គោលបំណង ៖** បង្ហាញថាថ្នាក់ដឹកនាំស្ត្រីពិតជាសំខាន់ដើម្បីទទួលបានយុទ្ធសាស្ត្រនៃការបន្សាំដែលមានប្រសិទ្ធភាព និងបង្ហាញថា ការបញ្ចូលទស្សនៈយេនឌ័រនៅក្នុងការបន្សាំអាចសម្រេចបានដោយវិធីសាស្ត្រធ្វើការបញ្ជ្រាបបើចាំបាច់។

**សម្ភារៈ ៖** ក្រដាសផ្ទាំងធំជាច្រើន ក្រដាស និងប៊ិច

**ដំណើរការ ៖**

១) នៅក្នុងការប្រជុំដោយមានទីប្រឹក្សាផ្នែកយេនឌ័រនៅក្នុងក្រុមដែលអាចផ្តល់ជាការណែនាំ ស្នើសុំឱ្យសិក្ខាកាមពណ៌នាដោយសង្ខេបៗអំពីកម្មវិធីគម្រោងឬគោលនយោបាយដែលពួកគេបានធ្វើឬបានឮ អំពីវិស័យដែលពាក់ព័ន្ធនឹងការបន្សាំ ឧទាហរណ៍នៅក្នុងវិស័យ ដូចជា៖

ក. ទឹក និងអនាម័យ

ខ. ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី

គ. កសិកម្ម និងសន្តិសុខស្បៀង

ឃ. តំបន់ឆ្នេរ

ង. ការប្រែក្លាយជាតំបន់វាលខ្សាច់

ច. ថាមពល

ឆ. សុខាភិបាល។

២) បន្ទាប់ពីវិស័យបីទៅដល់ប្រាំនៃចំណុចទាំងនេះត្រូវបានសរសេរហើយ (នៅក្នុងបន្ទាត់មួយលើក្រដាសតូចមួយផ្សេងៗគ្នានៅលើក្រដាសផ្ទាំងធំច្រើន ដើម្បីឱ្យគ្រប់គ្នាអាចឃើញបានទាំងអស់) អ្នកសម្របសម្រួល ឬក៏សមាជិកក្រុមគួរតែចូលដល់វគ្គសំណួរចម្លើយដោយមានមនុស្សម្នាក់ធ្វើការណែនាំអំពីគម្រោងនីមួយៗ និងប្រមូលគំនិតពីក្រុមទាំងមូលអំពីជំហាន សក្តានុពលដើម្បីបញ្ចូលថ្នាក់ដឹកនាំស្ត្រីទៅក្នុងគម្រោង។

៣) ប្រសិនបើមានពេល ចូរធ្វើការប្រៀបធៀបករណីសិក្សាផ្សេងៗ និងទាញយកនូវគោលការណ៍វិភាគយេនឌ័រទូទៅ។

# ជំពូក ៥

## ប្រសិនបើមានពេល ចូរធ្វើការប្រៀបធៀបករណីសិក្សាផ្សេងៗ និងទាញយកនូវគោលការណ៍វិភាគយេនឌ័រទូទៅ

នៅក្នុងប្រទេសអ្នកមានជាច្រើន វិបត្តិអាកាសធាតុដែលកំពុងលេចឡើង គឺជាបញ្ហាមួយនៃក្តីកង្វល់ ខណៈដែលវាមានការប៉ះពាល់ដល់សុខុមាលភាព សេដ្ឋកិច្ច និងជីវិតរបស់ប្រជាជន។ ផ្ទុយទៅវិញ នៅប្រទេសអាហ្វ្រិក គឺជាតំបន់មួយដែលបានរួមចំណែកយ៉ាងខ្លាំងដល់ការប្រែប្រួលអាកាសធាតុ-ការបំភាយឧស្ម័នផ្ទះកញ្ចក់ គឺមានបញ្ហាតិចតួចនៅពេលធ្វើការប្រៀបធៀបជាមួយប្រទេសឧស្សាហកម្ម-វានឹងជាបញ្ហាមួយនៃការរស់នៅ និងការបាត់បង់ជីវិត (Wangari Maathai. 2008)។

### *សារសំខាន់ៗ*

- ស្ត្រីមានការខកខានយ៉ាងច្រើនពីការពិភាក្សាថ្នាក់អន្តរជាតិស្តីពីការកាត់បន្ថយការប្រែប្រួលអាកាសធាតុ
- ទាក់ទងនឹងធនធាន និងបច្ចេកវិទ្យាថាមពលស្អាត តួនាទីរបស់ស្ត្រីមិនអាចប៉ាន់ប្រមាណបានគ្រប់ជ្រុងជ្រោយបានទេ នៅពេលពួកគេទទួលខុសត្រូវយ៉ាងសំខាន់ក្នុងការធានាការផ្គត់ផ្គង់ថាមពល និងសុវត្ថិភាពនៅកម្រិតគ្រួសារ។
- ទាក់ទងនឹងការចាប់យក ការបំពេញបន្ថែម ឬការញែកយកកាបូន វាមានសារៈសំខាន់ក្នុងការបង្ហាញពីតួនាទីរបស់ស្ត្រីនៅក្នុងការងារព្រៃឈើ។
- ការប្រើប្រាស់ដែលមាននិរន្តរភាព គឺជាបញ្ហាយេនឌ័រដ៏ធ្ងន់ធ្ងរមួយ ភាគច្រើនស្ត្រីជាអ្នកធ្វើសេចក្តីសម្រេចលើការប្រើប្រាស់។

អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) និងពិធីសារទីក្រុងក្យូតូ គឺជាមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ។ ពិធីសារក្យូតូបានកំណត់ឱ្យប្រទេសឧស្សាហកម្មនានាសម្រេចឱ្យបាននូវកម្រិតដ៏ជាក់លាក់មួយនៃការកាត់បន្ថយការបំភាយកំហាប់ឧស្ម័នផ្ទះកញ្ចក់ (GHG) (ជាមធ្យម ៥,២%) ទាក់ទងនឹងទិន្នន័យមូលដ្ឋាន (ករណីភាគច្រើនបំផុតកម្រិតឆ្នាំ១៩៩០) ក្នុងដំណាក់កាលប្តេជ្ញាចិត្តលើកដំបូង (ឆ្នាំ២០០៨-២០១២)។

ការបង្ហាញនៅក្នុងការវិភាគស្ថានភាពការប្រែប្រួលអាកាសធាតុរបស់ IUCN ( Drexhange, 2006) ភាគីនានានៃពិធីសារអាចកាត់បន្ថយការបំភាយ GHGs នៅក្នុងលក្ខណៈបែបណាក៏ដោយតាមដែលពួកគេជ្រើសរើសដែលស្របទៅនឹងពិធីសារទីក្រុងក្យូតូ។ ពួកគេអាចប្រើប្រាស់សកម្មភាពញែកយកកាបូននៅក្នុងការប្រើប្រាស់ដី ការប្រែប្រួល ការប្រើប្រាស់ដី និងព្រៃឈើ (LULUCF) ដែលផ្អែកតាមគោលការណ៍ជាក់លាក់មួយ ហើយគឺជាសេរីភាពក្នុងការប្រើប្រាស់យន្តការទីផ្សារអន្តរជាតិផងដែរដូចជា ការអនុវត្តរួមគ្នា (JI) យន្តការការអភិវឌ្ឍភាពស្អាត (CMD) និងវិជ្ជាជីវៈការបំភាយអន្តរជាតិ គឺជាមធ្យោបាយមួយនៃចំណុចដៅរបស់កិច្ចប្រជុំនៃទីក្រុងក្យូតូរបស់ពួកគេ។

អស់រយៈពេលជាយូរ គណៈកម្មាធិការអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC 2001) ប៉ាន់ស្មានថា ការកាត់បន្ថយការបំភាយឧស្ម័នជាង ៦០% គឺជាការចាំបាច់ដើម្បីរក្សាលំនឹងកំហាប់ឧស្ម័នផ្ទះកញ្ចក់ឱ្យបាននៅត្រឹមឆ្នាំ២០០១។ ប្រការនេះទាមទារនូវ "ការស្រូបយកកាបូន" ឱ្យបានច្រើនរាប់បញ្ចូលទាំងការចាប់យកការរក្សាកាបូននៃសេដ្ឋកិច្ចសកល និងការផ្លាស់ប្តូរដ៏គួរឱ្យកត់សម្គាល់នូវប្រព័ន្ធដែលត្រូវបានប្រើប្រាស់ក្នុងការផលិតនិងចែកចាយថាមពលផលិតទំនិញប្រើប្រាស់ និងជម្រុញដល់ការដឹកជញ្ជូន។

ការឆ្លើយតបផ្សេងទៀត ចំពោះការប្រឈមនានានៃការប្រែប្រួលអាកាសធាតុត្រូវបានបង្ហាញនៅក្នុងឆាកអន្តរជាតិផ្សេងៗ។ ឧទាហរណ៍ សម័យប្រជុំលើកទី១៥ នៃគណៈកម្មការសហប្រជាជាតិស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព(CSD) ដែលបានសម្រេចនៅខែឧសភា ឆ្នាំ២០០៧ ដែលបានផ្តោតលើវឌ្ឍនភាពថាមពលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ការអភិវឌ្ឍផ្នែកឧស្សាហកម្ម ការបំពុលខ្យល់/បរិយាកាស និងការប្រែប្រួលអាកាសធាតុ។ សុន្ទរកថាសង្ខេបរបស់ប្រធានគណៈកម្មការ (CSD, 2007) បានសង្កត់ធ្ងន់លើតម្រូវការក្នុងការផ្តល់ថាមពលសម្រាប់គ្រប់គ្នា ការលើកកម្ពស់ប្រសិទ្ធផលថាមពល ការពង្រឹងកិច្ចអភិវឌ្ឍ ការប្រើប្រាស់ និងការចែករំលែកបច្ចេកវិទ្យាថាមពលស្អាត និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុរាប់បញ្ចូលទាំងការកាត់បន្ថយ និងការបន្សាំខ្លួនទៅនឹងអាកាសធាតុ។ សេចក្តីសង្ខេបក៏បានកត់សម្គាល់ផងដែរថា "សារៈសំខាន់នៃការបញ្ជ្រាបនូវការគិតគូរអំពីយេនឌ័រ ជាពិសេសតួនាទីរបស់ស្ត្រីនៅក្នុងការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិតទាំងអស់ត្រូវបានមើលឃើញថា ជាការចាំបាច់មួយសម្រាប់ការអនុវត្ត បញ្ហាអន្តរទំនាក់ទំនងនានានៃថាមពលសម្រាប់កិច្ចអភិវឌ្ឍប្រកបដោយចីរភាព ការអភិវឌ្ឍឧស្សាហកម្ម ការបំពុលខ្យល់/បរិយាកាស និងការប្រែប្រួលអាកាសធាតុ"។[៤១]

## ៥.១ យេនឌ័រ និងកិច្ចប្រឹងប្រែងក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ៖ ការបង្កើតការទំនាក់ទំនង

នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយគឺជា "កិច្ចអន្តរាគមន៍នវិទ្យាមួយក្នុងការកាត់បន្ថយប្រភពនៃឧស្ម័នផ្ទះកញ្ចក់ ឬធ្វើឱ្យប្រសើរឡើងនូវការលេចធ្លាយនៃឧស្ម័ននេះ" (IPCC, 2001)។ វាត្រូវបានផ្តោតលើការដាក់កម្រិតការបំភាយសុទ្ធ ដើម្បីកាត់បន្ថយការប្រែប្រួលជាបណ្តើរៗ និងជាយថាហេតុនូវការកើនឡើងនៅក្នុងការប្រមូលផ្តុំបរិយាកាសនៃកំហាប់ឧស្ម័នផ្ទះកញ្ចក់។

មានចំណុចពិតប្រាកដនានានៅក្នុងសកម្មភាពកាត់បន្ថយកំពុងចាប់ផ្តើមស្នើឡើង ឬកំពុងអនុវត្តនៅពេលដែលស្ត្រីបានបង្ហាញអស់ពេលជាច្រើនឆ្នាំ (និងនៅក្នុងកំណត់ហេតុមួយចំនួន) ដែលថាស្ត្រីជាមនុស្សសំខាន់។ កំណត់ហេតុបែបនេះគឺជាករណីដែលទាក់ទងនឹងការអភិរក្សព្រៃឈើ និងការដាំដើមឈើឡើងវិញ ការគ្រប់គ្រងធនធានមូលដ្ឋាន ការប្រើប្រាស់ និងថាមពលក្នុងចំណោមកំណត់ហេតុផ្សេងទៀត។ នៅក្នុងចំណុចអន្តរាគមន៍ដែលបានស្នើឡើងសម្រាប់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុនោះ គឺការខ្វះខាតការលើកកម្ពស់ការយល់ដឹង ការទទួលស្គាល់តួនាទី និងធាតុចូលដែលស្ត្រីជនបទ និងទីប្រជុំជនដែលមកពីប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍបានផ្តល់ និងកំពុងបានផ្តល់។ នៅពេលដែលមានការរក



៤១. សម័យប្រជុំលើកទី១៥នៃ CSD សន្ទរកថាសង្ខេបរបស់ប្រធានគណៈកម្មការ ចំណុចទី៨

ឃើញមួយចំនួននៃទំនាក់ទំនងរវាងការផ្លាស់ប្តូរចំពោះការប្រែប្រួលអាកាសធាតុ និងសមភាពយេនឌ័ររួចរាល់ហើយនោះ ទិដ្ឋភាពយេនឌ័រនៃការកាត់បន្ថយ នៅតែជាដំណាក់កាលផ្តួចផ្តើមនៅឡើយ។ នៅពេលដែលបញ្ហានេះ បានបង្ហាញដោយ Brody (2008) ករណីនេះទំនងជាបណ្តាលមកពីលក្ខណៈ "បច្ចេកទេស" ឬ "វិទ្យាសាស្ត្រ" នៃការកាត់បន្ថយដែលចាប់ផ្តើមនិយាយអំពីការកាត់បន្ថយកំហាប់ឧស្ម័នផ្ទះកញ្ចក់។ដោយសារការពិតថាស្ត្រីជារឿយៗត្រូវបានគេមើលឃើញត្រឹមតែជាជនរងគ្រោះ ឬជាសមាជិកក្រុមងាយរងគ្រោះប៉ុណ្ណោះ ដោយមិនបានចាត់ទុកពួកគេថាជាអ្នកជំនាញ ឬជាអ្នកដឹកនាំនោះឡើយ ដូច្នេះបណ្តាលឱ្យពួកគេបានពាក់ព័ន្ធជាស្រេចជាមួយការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។

ការពន្យល់ដែលជាមូលដ្ឋានផ្សេងទៀតចំពោះការខ្វះខាតការគិតគូរអំពីយេនឌ័រនៅក្នុងការកាត់បន្ថយ (និងស្ថិតក្នុងចំណុចទូទៅនៃវេទិកាអាកាសធាតុ) គឺជាការពិតដែលថាស្ត្រីមានតំណាងតិចតួចនៅក្នុងដំណើរការធ្វើផែនការ និងសមត្ថភាពរបស់ពួកគេនៅមានកម្រិតសម្រាប់ការចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចផ្នែកនយោបាយ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ដូចបានបង្ហាញដោយ Hemmati (2008) សូចនាករនៃការចូលរួមរបស់ស្ត្រីនៅក្នុងវេទិកាជជែកពិភាក្សាការប្រែប្រួលអាកាសធាតុនៅកម្រិតសកលនោះ គឺជាចំណែករបស់ពួកគេនៅក្នុងជួរគណៈប្រតិភូនៃរដ្ឋភាគី ដែលធ្វើជាតំណាង ឬជាប្រធានគណៈប្រតិភូ។ បើទោះជាសេចក្តីសម្រេចរបស់ COP មួយត្រូវបានព្រមព្រៀងនៅក្នុង Marrakesh (2001) ស្តីពីការលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងកិច្ចប្រជុំ និងលេខាធិការដ្ឋាន UNFCCC ក៏ដោយក៏ការចូលរួមរបស់ស្ត្រីនៅក្នុងគណៈប្រតិភូផ្លូវការ គឺនៅមានកម្រិតនៅឡើយ ជាពិសេសស្ត្រីដែលធ្វើជាប្រធានគណៈប្រតិភូ។

ក្រាហ្វិកខាងក្រោមបង្ហាញថា បើទោះជាអំឡុងពេលឆ្នាំ១៩៩៦-២០០៦ (COP 2-COP 13) ចំណែករបស់ស្ត្រីនៅក្នុងគណៈប្រតិភូ COP មានការកើនឡើងយ៉ាងច្រើន (ពី២០,៥ ដល់ ២៨%) ក៏ដោយក៏ភាគរយនៃស្ត្រីជាប្រធានគណៈប្រតិភូជាក់ស្តែងមានការធ្លាក់ចុះនៅក្នុងអំឡុងពេលដូចគ្នានេះពី១៣,៥ ទៅ ១២%។



នៅកម្រិតថ្នាក់ជាតិ គឺមានរូបភាពស្រដៀងគ្នា។ ការដាក់បញ្ចូលស្ត្រីទំនងជាទទួលបានជោគជ័យ នៅកម្រិតថ្នាក់តំបន់ និងថ្នាក់ក្រោមជាតិ ប៉ុន្តែក៏មានការលើកលែងជាជាងការដាក់កម្រិត។ នៅក្នុងចំណុចនេះ មានតម្រូវការសម្រាប់រៀបចំសកម្មភាព ដែលនឹងផ្តល់ភាពអង់អាចដល់ស្ត្រីក្នុងការចូលរួមពាក់ព័ន្ធនៅក្នុងដំណើរការធ្វើការសម្រេច (ឧៈ ការបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ ការទទួលបាននូវព័ត៌មាន ការអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចពិភាក្សាថ្នាក់ជាតិ)។

សកម្មភាពដែលពាក់ព័ន្ធនឹងការកាត់បន្ថយត្រូវបានរៀបដាក់ជាក្រុមចំនួនពីរផ្នែក៖ ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការចាប់យកការបំពេញ និងការញែកយកកាបូន។ នៅក្នុងករណីនីមួយៗ ដំណោះស្រាយឬការផ្តួចផ្តើមនានា គឺមានការខុសគ្នាទៅតាមប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍ ដូច្នេះការគិតគូរអំពីយេនឌ័រត្រូវបានលើកឡើងឱ្យបានច្បាស់លាស់។

ការផ្តល់នូវការទទួលខុសត្រូវដ៏ជាក់លាក់របស់ពួកគេ និងការធ្វើឱ្យមានភាពខុសគ្នានូវសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយត្រូវបានអនុវត្តនៅក្នុងប្រទេសអភិវឌ្ឍ ហើយសកម្មភាពផ្លាស់ប្តូរនានា ត្រូវបានអនុវត្តនៅប្រទេសដែលមានការអភិវឌ្ឍតិចតួចជាមួយនឹងការលើកលែងមួយចំនួនដែលគួរឱ្យកត់សម្គាល់។ ទោះជាយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ក្នុងការភ្ជាប់នូវទិដ្ឋភាពទាំងពីរនេះទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ក៏ដូចជាការដាក់ឱ្យទិដ្ឋភាពទាំងនេះពាក់ព័ន្ធទៅនឹងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រដែលជាអាទិភាពរបស់ប្រទេសដែលមានការអភិវឌ្ឍតិចតួច។

**ប្រអប់ទី១៖ ទំនាក់ទំនង របៀបវារៈនៃការបន្សាំខ្លួន និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ**

ទំនាក់ទំនងដែលមានប្រសិទ្ធភាពនៃរបៀបវារៈនៃការកាត់បន្ថយ និងការបន្សាំខ្លួនទៅនឹងអាកាសធាតុ គួរតែសមស្របទៅនឹងយុទ្ធសាស្ត្រអនុវត្តន៍ល្អ/ គ្មានការស្តាយក្រោយ ឧទា៖ សកម្មភាពកាត់បន្ថយ ការបំភាយដែលជួយដល់ប្រទេស/តំបន់/សហគមន៍នានា ក្នុងការបន្សាំខ្លួននឹងការប្រែប្រួលអាកាសធាតុ តាមរយៈការប្រើប្រាស់នូវការអនុវត្តនានា (រួមមានបច្ចេកវិទ្យា និងចំណេះដឹង)។ គម្រោង ដែលដោះស្រាយនូវការអភិវក្ស ការចិញ្ចឹមជីវិតដែលមាននិរន្តរភាព និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព (ឧៈ សហគមន៍ព្រៃឈើ ភាពជើរល្បាត) នឹងឆ្លើយតបទៅនឹងការអធិប្បាយនេះ ហើយបង្កើតនូវផលប្រយោជន៍ដល់ទាំងសងខាង។ ថាមពលដែលបង្កើតឡើងវិញតាមបែបវិមជ្ឈការនៅតំបន់ជនបទ រួមចំណែកផងដែរ ដល់ការកាត់បន្ថយ និងការបន្សាំខ្លួននឹងអាកាសធាតុ។ យើងរំពឹងថា អាចមើលឃើញនូវសកម្មភាពជាច្រើននៅក្នុងចំណុចទាំងនេះនៅក្នុងទសវត្សរ៍បន្ទាប់។

*ប្រភព៖ Drexhage, 2006។*

សំណាងល្អ សមាសធាតុជាច្រើននៃការផ្លាស់ប្តូរដែលចាំបាច់នានាអាចបំពេញដល់មធ្យោបាយដែលរួមចំណែកដល់គោលដៅអភិវឌ្ឍដ៏ទូលំទូលាយផងដែរ ឧទាហរណ៍ ការផ្តល់ថាមពលស្អាតដល់ស្ត្រីជួយកែលម្អផងដែរនូវគុណភាពបរិស្ថាននៅតាមមូលដ្ឋាន។ ការធ្វើយុទ្ធសាស្ត្រនៅក្នុងផ្លូវនេះ ការប្រឈមនឹងត្រូវកាត់បន្ថយ ហើយបង្កើនបាននូវការការពារបរិស្ថាន និងជម្រុញកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការរៀបចំឡើងវិញនូវសង្គម និងសេដ្ឋកិច្ចរបស់យើងឆ្ពោះទៅរកផ្លូវអភិវឌ្ឍប្រកបដោយចីរភាពមួយ។

## ៥.១.១ ការចាប់ ការបំពេញ ឬការញែកយកកាបូន

ការផ្តួចផ្តើមឬគម្រោងនានាដែលបានដាក់បញ្ចូលនៅក្នុងប្រភេទនៃវិធានការទាំងនេះមានគោលបំណងក្នុងការបង្កើនការរក្សាទុកនៃឧស្ម័នផ្ទះកញ្ចក់តាមមធ្យោបាយនៃ “ការស្រូបយក”។ កសិកម្ម ព្រៃឈើដែលមានចីរភាព (ការដាំដុះ ការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ និងការដាំដើមឈើឡើងវិញ) និងការអភិរក្សធម្មជាតិ មានប្រសិទ្ធភាពសម្រាប់ការស្រូបយកកាបូន។ ខុសគ្នាពីយុទ្ធសាស្ត្រកាត់បន្ថយផ្សេងទៀត សកម្មភាពទាំងនេះបានចង្អុលផ្លូវជាបឋមនៅតាមបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច ហើយភាគច្រើនប្រទេសដែលមានប្រព័ន្ធបរិស្ថានធម្មជាតិដែលទប់ស្កាត់ ឬចាប់យកកាបូនដូចជាព្រៃឈើ ដើមកោងកាង និងវាលភក់ល្បាប់។

ក្នុងចំណោមភាពស្មុគស្មាញនៃសេវាកម្មនានា ដែលព្រៃឈើផ្តល់នូវការកាត់បន្ថយសម្រាប់ការប្រែប្រួលអាកាសធាតុនោះ ជាការចាំបាច់ក្នុងការស្វែងយល់អំពីតួនាទីរបស់ស្ត្រីនៅក្នុងដំណើរការទាំងនេះ។ បច្ចុប្បន្ន យុទ្ធសាស្ត្រនានាកំពុងផ្លាស់ប្តូរទៅរក៖ ការស្វែងយល់ និងការគិតគូរអំពីផលប្រយោជន៍ខុសៗគ្នាដែលស្ត្រី និងបុរសស្រូបយកពីសេវាកម្មព្រៃឈើ ការទទួលស្គាល់ភាពខុសគ្នាផ្នែកយេនឌ័រនៅក្នុងការទទួលបានការគ្រប់គ្រង និងចំណេះដឹងលើធនធានព្រៃឈើ និងការកំណត់អំពីភាពខុសគ្នាសំខាន់ៗនៅក្នុងការទទួលបានរបស់ស្ត្រី និងបុរសចំពោះព្រៃឈើដែលទាក់ទងនឹងការធ្វើសេចក្តីសម្រេចច្បាប់ សំខាន់ៗ និងឱកាសផ្នែកសេដ្ឋកិច្ច។

ពាក់ព័ន្ធទៅនឹងការគ្រប់គ្រង ឬការអភិរក្សព្រៃឈើ វាមានសារៈសំខាន់ក្នុងការស្វែងយល់ជាដំបូងថា ស្ត្រី និងបុរសមានភាពខុសគ្នានៅក្នុងតួនាទីផលិតកម្ម និងតួនាទីដាំដុះឡើងវិញដែលទាក់ទងនឹងធនធានព្រៃឈើ។ ពួកគេចូលរួមខុសៗគ្នានៅក្នុងការដាំដុះ ការការពារ ឬការថែទាំពូជ និងដើមឈើតូចៗ ក៏ដូចជាការដាំដុះ និងការថែរក្សានូវដីព្រៃឈើសម្រាប់ប្រើប្រាស់ជាលក្ខណៈគ្រួសារ និងការដាំដុះលើដីសាធារណៈ។ បុរសទំនងជាមានការពាក់ព័ន្ធច្រើនក្នុងការទាញយកផលប្រយោជន៍ពីផលិតផលព្រៃឈើ និងអនុផលព្រៃឈើសម្រាប់គោលបំណងអាជីវកម្ម។ ជាធម្មតា ស្ត្រីប្រើប្រាស់ឈើសម្រាប់ដុតសម្រាប់ធ្វើរបង សម្រាប់ចំណីអាហារប្រចាំគ្រួសារ ធ្វើចំណីសម្រាប់សត្វ និងវត្ថុធាតុដើមសម្រាប់ធ្វើថ្នាំធម្មជាតិក្នុងគោលបំណងបង្កើនប្រាក់ចំណូលគ្រួសារ។ ឧទាហរណ៍ នៅក្នុងប្រទេសកាមីរ៉ូនភាគអាគ្នេយ៍ នៅពេលដែលប្រជាជនបាកា(Baka) បានពិភាក្សាអំពីចក្ខុវិស័យសម្រាប់អនាគតរបស់ពួកគេ ស្ត្រី និងបុរសបានបង្កើតនូវចក្ខុវិស័យខុសៗគ្នា។ ស្ត្រីចង់បាន សហគមន៍ព្រៃឈើធំៗ ដើម្បីឱ្យពួកគេមានលទ្ធភាពក្នុងការគ្រប់គ្រងព្រៃឈើ និងអនុផលព្រៃឈើរបស់ខ្លួន-ពួកគេជានិច្ចជាកាល ជាអ្នកចូលព្រៃរកអុស ផ្លែឈើព្រៃ ឫសឈើ ដំឡូងផ្វា និងវត្ថុធាតុដើមសម្រាប់ផលិតសម្ភារៈសិប្បកម្ម/កន្ត្រក់/កន្ទេល ផងដែរ (Aguilar et al ឆ្នាំ២០០៧)។

ក្រុមស្ត្រីបានបង្ហាញនូវកស្តុតាងសំខាន់ៗសម្រាប់ការអភិរក្សព្រៃឈើនៅជុំវិញពិភពលោក។ នៅក្នុងតំបន់អ៊ុតតារាខ័ននៃស្រុកហ៊ីម៉ាឡាយ៉ាស់ ដែលជាចលនាជីបកូ ដែលតំបន់នោះមានគម្រោងស្វយ័តតាមមូលដ្ឋាន និងតាមបែបវិមជ្ឈការរាប់រយ។ មេដឹកនាំ និងអ្នកអនុវត្តសកម្មភាពរបស់ខ្លួនគឺភាគច្រើនជាស្ត្រី។ ចលនានេះបានបង្ហាញថា ស្ត្រី អាចបង្កើតនូវភាពខុសគ្នាក្នុងការការពារព្រៃឈើ និងការបង្កើតគម្រោងដាំដុះព្រៃឈើ។កម្មវិធីដាំដុះព្រៃឈើរបស់ពួកគេមិនគ្រាន់តែកាត់បន្ថយការបាក់ដីប៉ុណ្ណោះទេ ប៉ុន្តែកម្មវិធីនេះបានដោះស្រាយបញ្ហាឥន្ធនៈ និងស្មៅស្ងួតផងដែរ។ ស្ត្រីបានថែទាំដើមឈើយ៉ាងប្រុងប្រយ័ត្នដែលអត្រាគង់វង្សមានរវាងពី៦០ទៅ៨០ភាគរយ (Joshi ឆ្នាំ២០០៧)។ សមិទ្ធិផលសំខាន់ៗផ្សេងទៀតមួយចំនួននៃចលនាជីបកូរួមមាន បម្រាមរយៈពេល១៥ឆ្នាំស្តីពីការបំផ្លាញភាពបៃតងនៅក្នុងព្រៃហ៊ីម៉ាឡាយ៉ាស (Himalayas) នៅ

ក្នុងឧតាប្រាដេស (Uttar Pradesh)។ បម្រាមលើការបំផ្លាញព្រៃឈើនៅក្នុងតំបន់ហ្គាត (Ghats) ភាគខាងលិច និង តំបន់វីនយ៉ាស (Vindhyas) និងសម្ពាធដ៏ធ្ងន់ធ្ងរសម្រាប់គោលនយោបាយធនធានធម្មជាតិដែលជាចំណុចរសើបបន្ថែមទៀតចំពោះតម្រូវការរបស់មនុស្ស និងតម្រូវការផ្នែកបរិស្ថានវិទ្យា។

កសិកម្មដែលបញ្ចូលរបៀបថ្មី អាចដើរតួនាទីសំខាន់ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ជាពិសេស រុក្ខកម្ម។ រុក្ខកម្ម ត្រូវបានមើលឃើញយ៉ាងទូលំទូលាយផងដែរថាជាយុទ្ធសាស្ត្រសំខាន់ក្នុងការកាត់បន្ថយបញ្ហាខូចខាតផ្នែកបរិស្ថាន និងការលើកកម្ពស់កិច្ចអភិវឌ្ឍជនបទ តាមរយៈការប្រើប្រាស់ដើមឈើ សេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយការអនុវត្តផ្នែករុក្ខកម្ម ត្រូវបានបែងចែករវាងស្ត្រី និងបុរស ផ្អែកតាមតួនាទីយេនឌ័រ។ ឧទាហរណ៍ ការសិក្សាមួយដែលបានអនុវត្តនៅក្នុងប្រទេសនីហ្សេរីយ៉ា បង្ហាញថា ស្ត្រីមិនបានចូលរួមអ្វីទាំងអស់នៅក្នុងការអនុវត្ត ហើយភាពខុសគ្នាក្នុងការគិតទាក់ទងនឹងការអនុវត្តផ្នែករុក្ខកម្មនៅតែមានរវាងស្ត្រី និងបុរស (Aboh និង Akpabio ឆ្នាំ២០០៨)។

**ប្រអប់ទី២៖** ប្រទេសឥណ្ឌា៖ គម្រោងការព្រែកយកកាបូន

គម្រោងរុក្ខកម្មដែលបញ្ចូលរបៀបថ្មី និងឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ នៅក្នុងតំបន់ហ្គូឌីបានដាតាលូក (Gudibanda Taluk) រដ្ឋកាណាតាកា ប្រទេសឥណ្ឌា (ដែលអនុវត្តដោយអង្គការស្ត្រីសម្រាប់ កិច្ចអភិវឌ្ឍប្រកបដោយចីរភាព [WSD]) គាំទ្រដល់កសិករជាស្ត្រី និងបុរសក្នុងការដាំដុះដើមស្វាយ អំពិល និងដើមខ្នុរសម្រាប់ប្រមូលផល និងការព្រែកយកកាបូន។ គម្រោងគាំទ្រការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចដោយមានការគិតគូរអំពីលក្ខខ័ណ្ឌពិសេសរបស់ស្ត្រីទាក់ទងទៅនឹងឧបសគ្គផ្នែកវប្បធម៌ និងតារាងពេលវេលារបស់ពួកគេនៅពេលបង្កើតវេទិកាសាធារណៈ។ គម្រោងបានបង្កើតទីផ្សារកាបូនគំរូសម្រាប់លក់សម្ភារៈកាត់បន្ថយការបំភាយឧស្ម័ននៃសេវាកម្មផ្នែកបរិស្ថានសកលដែលមានការចូលរួមពីស្ត្រី និងបុរសក្រីក្រនៅតាមតំបន់ជនបទ។ កសិករដែលមានប្រាក់ចំណូលមធ្យមប្រចាំឆ្នាំប្រមាណតិចជាង១០០ដុល្លារក្នុងមួយឆ្នាំ មិនអាចលៃលកដាំដុះដើមឈើហូបផ្លែដោយគ្មានជំនួយផ្នែកហិរញ្ញវត្ថុបាននោះទេ។ ភាពជោគជ័យត្រូវការនូវការផ្លាស់ប្តូរជាពសាស្ត្រ និងឧបករណ៍ដាំដុះដែលមានតម្លៃថ្លៃ។ ខណៈដែលការប្រមូលផលនឹងអាចធ្វើឡើងក្នុងរយៈពេលបួនឆ្នាំទៀតបន្ទាប់ពីការដាំដុះ ដូច្នេះក្នុងដំណាក់កាលនេះ កសិករទាំងនោះពឹងផ្អែកលើការលក់កាបូនពីដើមស្វាយរបស់ខ្លួនរហូតដល់ស្វាយនោះឱ្យផលបាន។ នៅពេលដែលដើមឈើចាប់ផ្តើមផ្តល់ផលក្នុង១អា នឹងបង្កើននូវចំណូលប្រចាំឆ្នាំរបស់ពួកគេយ៉ាងហោចណាស់ចំនួនបីដង។ អាយុកាលរបស់គម្រោងនេះ គឺមានរយៈពេល៣៥ឆ្នាំ ជាមួយនឹងព្យាករណ៍មួយសម្រាប់ការព្រែកយកកាបូនចំនួន២៣តោនក្នុងមួយអា។ គោលដៅគម្រោងគឺ៣៥.០០០អា ដូច្នេះការព្រែកយកកាបូនសរុបគឺមានចំនួន ៥៧៥.០០០តោន។

*ប្រភព៖ ធនាគារពិភពលោក ឆ្នាំ២០០៩*

នៅក្នុងកិច្ចប្រជុំ COP លើកទី១៣នៅបាលី រដ្ឋភាគីទាំងអស់ទទួលស្គាល់ថាមានតម្រូវការបន្ទាន់មួយសម្រាប់ ប្រទេសកំពុងអភិវឌ្ឍក្នុងការចាត់នូវវិធានការជាក់លាក់មួយសម្រាប់កាត់បន្ថយនូវការបំភាយឧស្ម័នពីការបំផ្លាញព្រៃឈើ ការខូចខាតព្រៃឈើ ហើយអនុវត្តន៍នូវការផ្តួចផ្តើមការដាំដុះព្រៃឈើ។[៤២]

---

៤២. UNFCCC ឆ្នាំ២០០៨

ឧទាហរណ៍ ការដាំដើមឈើឡើងវិញ និងការដាំដុះដើមឈើទាំងពីរនេះត្រូវបានធ្វើសមារណកម្មជាកម្មវិធីការកាត់បន្ថយការប្រែប្រួលអាកាសធាតុផ្នែកតាមព្រៃឈើទៅក្នុងការគ្រប់គ្រងការប្រែប្រួលអាកាសធាតុអន្តរជាតិ (ពិធីសារក្យូតូ)។ ការអនុវត្តទាំងពីរនេះ តម្រូវឱ្យធ្វើការផ្លាស់ប្តូរពីដីគ្មានព្រៃឈើទៅជាដីមានព្រៃឈើតាមរយៈការដាំដុះ ការបណ្តុះពូជ និង/ឬការជម្រុញឱ្យមានជង្រុក និងប្រភពពូជ ។ ការដាំដុះព្រៃឈើអនុវត្តចំពោះតំបន់ដែលមិនមានព្រៃឈើអស់រយៈពេលយ៉ាងហោចណាស់៥០ឆ្នាំ ខណៈដែលការដាំព្រៃឈើឡើងវិញត្រូវអនុវត្តនៅលើដីដែលប្រើប្រាស់សម្រាប់ដាំព្រៃឈើ ប៉ុន្តែដីនោះត្រូវបានបង្វែរទៅជាដីប្រើប្រាស់ក្នុងគោលបំណងផ្សេង។ បច្ចុប្បន្ន មានកិច្ចពិភាក្សាមួយស្តីពីសារៈសំខាន់នៃការដោះស្រាយការកាត់បន្ថយការបំភាយឧស្ម័នចេញពីការកាប់បំផ្លាញព្រៃឈើ និងការខូចដី (REDD)។ គេបានព្យាករណ៍ថា ជិតមួយភាគបីនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ទាំងអស់ គឺបណ្តាលមកពីការកាប់បំផ្លាញព្រៃឈើ និងបណ្តាលមកពីប្រភេទស្រដៀងគ្នានៃការខូចដី។ យុទ្ធសាស្ត្រ REDD ដែលមានប្រសិទ្ធភាពគួរត្រូវបានប្រើប្រាស់ក្នុងការជម្រុញការពារព្រៃឈើបច្ចុប្បន្ន។

ស្ត្រីដើរតួនាទីសំខាន់ទាក់ទងនឹងការកាត់បន្ថយការបំភាយឧស្ម័នចេញពីការកាប់បំផ្លាញព្រៃឈើ និងការខូចដី (REDD) ការចរចាថ្នាក់អន្តរជាតិ ឬការគ្រប់គ្រងដែលគិតគូរអំពី REDD ត្រូវមានការប្រុងប្រយ័ត្នអំពីការអនុលោមទៅនឹងការប្តេជ្ញាចិត្តថ្នាក់ជាតិ និងថ្នាក់អន្តរជាតិស្តីពីសមភាព និងសមធម៌យេនឌ័រ ពួកគេត្រូវធានាតាំងពីដំបូងអំពីការចូលរួម និងការដាក់បញ្ចូលស្ត្រីឱ្យបានពេញលេញក្នុងការរៀបចំគោលនយោបាយថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ និងនៅក្នុងការអនុវត្តខុសៗគ្នានៃ REDD។

ទាក់ទងទៅនឹងការចំណាយសម្រាប់សេវាបរិស្ថាន (PES) សម្រាប់ការរក្សាទុកកាបូន និងការស្រូបយកកាបូនថ្មី គួរតែមានសមធម៌ក្នុងការទទួលបាន និងការបែងចែកផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលបានមកពីសេវាកម្មព្រៃឈើដែលផ្តល់ឱ្យសម្រាប់កាត់បន្ថយការប្រែប្រួលអាកាសធាតុ។ កម្មវិធីគួរលើកកម្ពស់ការទទួលបានរបស់ស្ត្រីដោយស្មើភាពចំពោះភាពជាម្ចាស់ដីធ្លី និងធនធានចាំបាច់ផ្សេងៗសម្រាប់ការចូលរួមផ្នែកសេដ្ឋកិច្ច-សង្គមនៅក្នុងការគ្រប់គ្រងព្រៃឈើ និងយុទ្ធសាស្ត្រកាត់បន្ថយការប្រែប្រួលអាកាសធាតុ (ឧ: ដី ថវិកា ជំនួយបច្ចេកទេស បច្ចេកវិទ្យា សម្ភារៈ បរិក្ខារ ទីផ្សារ និងពេលវេលា)។ ឧទាហរណ៍ ទាំងស្ត្រី និងបុរសត្រូវធ្វើការបណ្តុះបណ្តាលអំពីវិធីសាស្ត្រក្នុងការបង្កើនការញែកយកកាបូនតាមរយៈបច្ចេកវិទ្យារុក្ខកម្មថ្មី រាប់បញ្ចូលទាំងបច្ចេកទេសបណ្តុះកូនឈើ ការជ្រើសរើសទីតាំង និងការជ្រើសរើសពូជ ការរៀបចំដី ការដាំដុះ ការដករុក្ខជាតិតូចចេញ និងការថែទាំ។

នៅពេលដែលប្រជាពលរដ្ឋពាក់កណ្តាលមិនត្រូវបានដាក់បញ្ចូល ឬត្រូវបានហាមឃាត់ពីការចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចច្បាប់ និងកម្មវិធីដែលទាក់ទងទៅនឹងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ពួកគេទំនងជាមិនមានអារម្មណ៍ “ភាពជាម្ចាស់” នៃគោលនយោបាយផ្នែកព្រៃឈើឡើយ។ យុទ្ធសាស្ត្រកាត់បន្ថយការប្រែប្រួលអាកាសធាតុ តំណាងឱ្យឱកាសតែមួយសម្រាប់ដាក់បញ្ចូលស្ត្រីនៅក្នុងកម្មវិធីព្រៃឈើ ហើយទទួលស្គាល់ថាទំនាក់ទំនងយេនឌ័រនឹងមានឥទ្ធិពលលើទិដ្ឋភាពនៃកម្មវិធីព្រៃឈើ និងអភិបាលកិច្ចដែលបានស្នើឡើងសម្រាប់កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។

**ប្រអប់ទី ៣៖** ការគិតគូរអំពីយេនឌ័រនៅពេលលើកកម្ពស់ការចំណាយលើសេវាកម្មផ្នែកបរិស្ថាន(PES)

**ការទទួលបាន និងការគ្រប់គ្រងធនធាន៖** សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ នយោបាយ និងបរិស្ថានផ្នែកច្បាប់មានឥទ្ធិពលលើសិទ្ធិរបស់ស្ត្រី និងបុរសក្នុងការគ្រប់គ្រងធនធានព្រៃឈើ និងកម្មសិទ្ធិដីធ្លី។ ទោះបីជាស្ត្រីមានសិទ្ធិធ្វើជាម្ចាស់ដីធ្លីក៏ដោយការទទួលបានផលិតផលព្រៃឈើ និងឱកាសក្នុងការបង្កើនប្រាក់ចំណូលពីព្រៃឈើរបស់ពួកគេអាចបង្កើតបាននូវសិទ្ធិមិនផ្លូវការក្នុងការប្រើប្រាស់នូវផ្នែកផ្សេងៗគ្នានៃព្រៃឈើ ឬសូម្បីតែដើមឈើ - ស្ត្រីអាចទទួលបានត្រឹមតែស្លឹក ប៉ុន្តែមិនមែនដើមឈើនោះឡើយ។ ភាពខុសគ្នាតាមយេនឌ័រនេះ មានការពាក់ព័ន្ធមួយចំនួនធំជាមួយភាពជាម្ចាស់ និងសិទ្ធិអាស្រ័យផលចំពោះព្រៃឈើ និងផលិតផលរបស់វា។ វាមានឥទ្ធិពលលើដំណើរការនៃការធ្វើសេចក្តីសម្រេច និងការគ្រប់គ្រងលើព្រៃឈើ។ ដូច្នេះ មូលដ្ឋានគ្រឹះដែលប្រព័ន្ធចំណាយលើសេវាកម្មផ្នែកបរិស្ថាន (PES) គិតគូរអំពីទិដ្ឋភាពនៃភាពជាម្ចាស់លើដីធ្លីជាផ្លូវការ និងមិនមែនផ្លូវការដើម្បីជៀសវាងការបង្កើតឡើងវិញនូវតួនាទីតាមបែបប្រពៃណី (ផ្តល់ផលប្រយោជន៍សម្រាប់តែ "ម្ចាស់ដែលជាបុរស")។ ឧទាហរណ៍ នៅប្រទេសកូស្តារីកា មូលនិធិដែលបានផ្តល់ដល់ក្រសួងបរិស្ថានសម្រាប់ការចំណាយលើសេវាកម្មផ្នែកបរិស្ថាន ត្រូវបានប្រើប្រាស់ក្នុងការគាំទ្រក្រុមស្ត្រីសម្រាប់ទិញដីធ្លីស្ថិតក្រោមឈ្មោះរបស់ពួកគេដើម្បីឱ្យពួកគេអាចទទួលផលប្រយោជន៍ពីកម្មវិធី PES។

**មូលដ្ឋានចំណេះដឹង៖** ចំណេះដឹងយេនឌ័រ អាចខុសគ្នាទៅតាមកម្រិតអាយុ និងសាសន៍ ដែលគូសបញ្ជាក់នូវភាពស្មុគស្មាញ។ ឧទាហរណ៍ ស្ត្រីកុលសម្ព័ន្ធនៅប្រទេសឥណ្ឌា ចេះផលិតឱសថចេញពីពូជដើមឈើ ស្ទើរតែ៣០០ប្រភេទ។ នៅផ្នែកផ្សេងទៀតនៃពិភពលោក បុរសវ័យចំណាស់ៗនៃក្រុមជនជាតិភាគតិចអាចមានការអនុវត្តខុសៗគ្នាក្នុងការប្រើប្រាស់ដីព្រៃឈើ និងដើមឈើប្រកបដោយចីរភាពជាងក្មេងជំនាន់ក្រោយដែលរស់នៅក្រៅពីសហគមន៍ដើមរបស់ខ្លួន។ ការស្វែងយល់អំពីវិសាលភាពនៃចំណេះដឹងដែលស្ត្រី និងបុរសមាននៅក្នុងកាលៈទេសៈផ្នែកសេដ្ឋកិច្ច-សង្គមខុសៗគ្នាជួយក្នុងការកំណត់គោលនយោបាយព្រៃឈើឱ្យបានសមស្រប និងប្រកបដោយប្រសិទ្ធភាព។

**វចនាសម្ព័ន្ធនៃការធ្វើសេចក្តីសម្រេច៖** មានតម្រូវការមួយក្នុងការធានាការធ្វើសេចក្តីសម្រេចដែលមានសមភាពយេនឌ័រសម្រាប់ដាក់បញ្ចូលទស្សនៈ និងកង្វល់របស់ស្ត្រីនៅក្នុងការរៀបចំការអនុវត្ត និងការវាយតម្លៃគោលនយោបាយ និងលទ្ធផលរំពឹងទុកដែលទាក់ទងនឹង PES។ ដើម្បីសម្រេចនូវគោលបំណងនេះ ជួនកាលស្ត្រីត្រូវការការអភិវឌ្ឍជំនាញដើម្បីឱ្យពួកគេបានចូលរួមយ៉ាងពេញលេញ (ដូចជា ការបង្រៀនពួកគេអំពីរបៀបក្នុងការនិយាយនៅក្នុងកិច្ចប្រជុំ)។

**ការទទួលបានផលប្រយោជន៍ដោយស្មើភាព៖** វាគឺជាមូលដ្ឋានគ្រឹះក្នុងការធានាថាមានការបែងចែងនូវផលប្រយោជន៍ដែលបានមកពី PES ប្រកបដោយសមធម៌។ ទិន្នន័យបែងចែកតាមភេទ គួរត្រូវបានប្រមូលពាក់ព័ន្ធទៅនឹងការវិភាគថវិកាដើម្បីកំណត់ការបែងចែកមូលនិធិ។

ការឆ្លើយតបលើការកាត់បន្ថយការប្រែប្រួលអាកាសធាតុ គួរជៀសវាងលក្ខណៈវិនិច្ឆ័យតូចចង្អៀតដែលនាំឱ្យមានផលវិបាកផ្នែកបរិស្ថាន និងសង្គម។ ការឆ្លើយតបទាំងនេះ គួរមានគោលដៅទូលំទូលាយក្នុងគោលបំណងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ការការពារធនធានធម្មជាតិ លើកកម្ពស់សុខុមាលភាពសង្គម លើកកម្ពស់សមភាព និងទទួលស្គាល់ថាស្ត្រីជាភ្នាក់ងារសំខាន់ក្នុងដំណើរការប្រែប្រួលអាកាសធាតុ។

## ៥.១.២. ការកាត់បន្ថយការបំភាយឧស្ម័នតាមរយៈប្រភពថាមពលស្អាត និងបច្ចេកវិទ្យា

នៅប្រទេសកំពុងអភិវឌ្ឍ ជាពិសេសតំបន់ជនបទ មានការពាក់ព័ន្ធគ្នាដោយផ្ទាល់រវាងការផ្គត់ផ្គង់ថាមពល និងតួនាទីយេនឌ័រ។ បច្ចុប្បន្ន ការបំភាយឧស្ម័នផ្ទះកញ្ចក់គឺមានតិចតួចនៅក្នុងតំបន់ទាំងនេះ ពីព្រោះមានការប្រើប្រាស់អគ្គិសនី ឬមានការប្រើប្រាស់គ្រឿងយន្តតិចតួចនៅខាងក្រៅតំបន់ទីប្រជុំជន។ ការដុតជីវម៉ាសសម្រាប់ចម្អិនអាហារគ្រួសារ ការកំដៅ និងការបំភ្លឺ មានភាគរយខ្ពស់នៅក្នុងប្រទេសជាច្រើន។ ឧទាហរណ៍ នៅម៉ាលី ការប្រើប្រាស់អុស និងធ្យូង មានចំនួន ៨០% នៃថាមពលថ្នាក់ជាតិ។ មានការរំពឹងទុកកម្រិតស្រដៀងគ្នាលើជីវម៉ាស ត្រូវបានរកឃើញនៅប្រទេសក្រីក្រមួយចំនួននៅទ្វីបអាហ្វ្រិក និងអាស៊ី។

នៅក្នុងតំបន់ទាំងនេះ ការផ្តល់ឥន្ទនៈដែលជាតម្រូវការសម្រាប់ការរស់នៅប្រចាំថ្ងៃត្រូវបានមើលឃើញថា ជាការទទួលខុសត្រូវមួយរបស់ស្ត្រី។ ខណៈដែលស្ត្រីបានចាត់ចែងជាស្រេចនូវការផ្គត់ផ្គង់ថាមពលជីវម៉ាស់តាមបែបប្រពៃណី ពួកគេអាចជាមនុស្សសំខាន់ក្នុងការផ្លាស់ប្តូរបច្ចេកវិទ្យាថាមពល ដែលកាត់បន្ថយនូវការបំភាយឧស្ម័នផ្ទះកញ្ចក់។ ទោះជាយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ណាស់ដែលស្ត្រីចូលរួមនៅក្នុងការរៀបចំ និងការអនុវត្តគម្រោងថាមពល ហើយសកម្មភាពផ្លាស់ ដែលបានស្នើឡើងអាចលៃលកបានប្រើប្រាស់បាននិងត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការថាមពលពិតប្រាកដរបស់ស្ត្រី។

**ប្រអប់ទី ៤៖ ស្ត្រី និងបុរសប្រើប្រាស់ថាមពលនៅក្នុងមធ្យោបាយខុសៗគ្នា**

ទោះបីជាអ្នកធ្វើសេចក្តីសម្រេច អាចមើលឃើញជម្រើសដែលទាក់ទងនឹងថាមពល ថាជាអព្យាក្រឹតភាពយេនឌ័រក៏ដោយ ក៏ស្ត្រី និងបុរសមានផលប៉ះពាល់ពីគោលនយោបាយថាមពលខុសៗគ្នា មិនថាក្នុងផ្ទះ កន្លែងធ្វើការ និងតួនាទីសហគមន៍។ នៅប្រទេសឡាវ ថាមពលត្រូវបានចាត់ទុកថាជាគ្រោះថ្នាក់ និងហានិភ័យទាក់ទងនឹងភ្លើងអគ្គិសនី នៅក្នុងគ្រួសារឯកជន និងអគារសាធារណៈ។ ក្មេងប្រុសត្រូវបានរំពឹងថា មានការប្រឈមមុខទៅនឹងគ្រោះថ្នាក់ទាំងនេះ។ ដោយសារតែពួកគេ ត្រូវបានជម្រុញលើកទឹកចិត្តឱ្យទទួលចំណេះដឹងផ្នែកអគ្គិសនី មួយជំហានម្តងៗ ក្មេងស្ត្រីត្រូវបានរក្សាឱ្យនៅឆ្ងាយ មិនថាតែថាមពលអគ្គិសនីទេ ប៉ុន្តែចំណេះដឹងផ្នែកថាមពលផងដែរ។ ជាបឋមបុរសត្រូវបានចាត់ទុកថា ជាអ្នកទទួលខុសត្រូវលើផ្នែកបច្ចេកទេស និងការវិនិយោគនៅក្នុងការរៀបចំខ្សែភ្លើងក្នុងផ្ទះ ផ្ទាំងអគ្គិសនី និងការតម្លើងឧបករណ៍ទឹកក្តៅ។ ការតម្លើងឧបករណ៍ អគ្គិសនី បំពង់ទឹក ឬបំពង់ឧស្ម័ន និងការតម្លើងប្រព័ន្ធកំដៅ គឺជាការងាររបស់បុរស។



មានឥន្ទនៈស្អាត និង/ឬប្រព័ន្ធថាមពលដែលមានប្រសិទ្ធភាពច្រើនមួយចំនួនដែលអាចផ្តល់ដំណោះស្រាយឈ្នះៗ ដោយការកាត់បន្ថយការបំភាយឧស្ម័ន ក៏ដូចជាការបំពុលខ្យល់នៅក្នុងអគារផ្សេងៗ ដែលជាប្រភពដ៏ធំមួយនៃជំងឺផ្លូវដង្ហើមសម្រាប់ស្ត្រីដែលចម្អិនអាហារជាមួយភ្លើងដែលមានផ្សែង។ ការផ្លាស់ថាមពលរបៀបថ្មីកាត់បន្ថយផងដែរនូវពេលវេលា និងកិច្ចខិតខំប្រឹងប្រែងផ្នែករូបវន្តដែលស្ត្រីត្រូវការចំណាយក្នុងការប្រមូល ដឹកជញ្ជូនជីវៈម៉ាស់ជាលក្ខណៈប្រពៃណី ការធ្វើដូច្នេះបង្កើតបានយ៉ាងច្រើននូវឱកាសថ្មីសម្រាប់ការអប់រំ សកម្មភាពផលិត និងការរីកចំរើនផ្នែកសង្គម និងសេដ្ឋកិច្ច។

បើទោះជានៅក្នុងតំបន់ដែលមានបណ្តាញអគ្គិសនី អាចរកបាន ក៏គ្រួសារជាច្រើននៅតែប្រើប្រាស់អុស និងធ្យូងសម្រាប់

ចម្អិនអាហារ និងកំដៅ។ វិធីសាស្ត្រដែលបានព្រមព្រៀងគ្នានាពេលថ្មីៗនេះ ត្រូវបានបង្កើតឡើងដែលនឹងអនុញ្ញាតឱ្យមានគម្រោងចង្ក្រានទំហំធំដែលបានកែលម្អសម្រាប់ទទួលបាននូវចំណូលពីកាបូន តាមរយៈការលក់ឥណទានកាត់បន្ថយការបំភាយឧស្ម័ន។ ដោយការបង្កើនប្រសិទ្ធភាពនៃចំហេះឥន្ធនៈ ចង្ក្រាន ដែលបានកែលម្អមានសក្តានុពលក្នុងការកាត់បន្ថយកម្រិតបំភាយឧស្ម័នកាបូន និងអភិរក្សនូវការបាត់បង់ព្រៃឈើបណ្តើរៗ។ ផ្ទុយទៅវិញ កិច្ចប្រឹងប្រែងកាលពីអតីតកាលមួយចំនួនក្នុងការណែនាំពីបច្ចេកវិទ្យាចង្ក្រានថ្មី បានបរាជ័យដោយសារពួកគេសង្កត់ធ្ងន់ជាចម្បងលើផលប្រយោជន៍ផ្នែកបរិស្ថាន ហើយមិនសមស្របទៅនឹងទំនៀមទម្លាប់តាមមូលដ្ឋាន។ ការដាក់ឱ្យស្ត្រីពាក់ព័ន្ធនៅក្នុងការរៀបចំចង្ក្រានដែលបានកែលម្អ និងការអនុវត្តគម្រោង នឹងបង្កើនឱកាសយ៉ាងច្រើនដែលថាឧបករណ៍ត្រូវបានប្រើប្រាស់យ៉ាងពិតប្រាកដ ដូច្នេះការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលបានរំពឹងទុកត្រូវបានសម្រេចយ៉ាងជាក់លាក់។

ឡជីវៈឧស្ម័ន និងចង្ក្រានប្រើប្រាស់ពន្លឺព្រះអាទិត្យ គឺជាបច្ចេកវិទ្យាផ្សេងទៀតដែលផ្តល់ជម្រើសបំភាយឧស្ម័នទាបក្នុងការចម្អិនអាហារ និងផលប្រយោជន៍ដែលមានសក្តានុពលសម្រាប់ស្ត្រី ប្រសិនបើ ឧបករណ៍ទាំងនោះមានការស្របគ្នាជាមួយទម្លាប់ប្រចាំថ្ងៃ និងបន្ទុកការងាររបស់ស្ត្រី ហើយប្រែប្រួលទៅតាមបរិបទមូលដ្ឋាន។ គម្រោងឡជីវៈឧស្ម័នទំហំធំ ត្រូវបានឯកភាពរួចជាស្រេចសម្រាប់ស្វែងរកមូលនិធិស្ថិតនៅក្រោមយន្តការអភិវឌ្ឍស្អាត (CDM) (សូមមើលករណីសិក្សាទី៣)។ ឡជីវៈឧស្ម័ន ឧស្ម័នមេតាន បានបញ្ចេញជាកាកសំណល់កសិកម្ម ជីលាមកសត្វ និងសម្ភារៈរលួយតាមបែបធម្មជាតិផ្សេងទៀត។ បន្ទាប់មក ហ្គាសបានបង្ហូរតាមបំពង់ចូលក្នុងផ្ទះសម្រាប់ប្រើប្រាស់ក្នុងការចម្អិនអាហារ និងការបំភ្លឺ។ រហូតដល់ពេលនេះជីវៈឧស្ម័នមានការពេញនិយមបំផុតនៅក្នុងតំបន់ដែលមានប្រជាពលរដ្ឋចិញ្ចឹមសត្វនិងតំបន់ដែលសម្បូរទឹកប្រើប្រាស់។ ចង្ក្រានពន្លឺព្រះអាទិត្យ ត្រូវបានប្រើប្រាស់ច្រើនបំផុតនៅក្នុងតំបន់ដែលមានការខូចដី និងការកាប់បំផ្លាញព្រៃឈើ។

នៅតំបន់ដែលមិនមានបណ្តាញភ្លើងអគ្គិសនី ជម្រើសថាមពលបង្កើតឡើងវិញ ដូចជាខ្យល់ ថាមពល ពន្លឺព្រះអាទិត្យ និងបច្ចេកវិទ្យាវារីអគ្គិសនីតូចៗ គឺជំនួសដោយការប្រើប្រាស់នូវគ្រឿងយន្ត និងម៉ាស៊ីនភ្លើងដែលប្រើប្រេងម៉ាស៊ូតជាប្រភពអគ្គិសនីដែលមានការបំភាយទាប និង/ឬថាមពលម៉ាស៊ីនសម្រាប់ឧបករណ៍សំខាន់ៗដូចជា ម៉ាស៊ីនបូមទឹក និងម៉ាស៊ីនកិនគ្រាប់ធញ្ញជាតិ។ ខណៈដែលពេលវេលាជាច្រើនរបស់ស្ត្រីនៅជនបទ ត្រូវចំណាយក្នុងការដងទឹក និងរៀបចំម្ហូបអាហារសម្រាប់គ្រួសាររបស់ពួកគេ ឧបករណ៍ការប្រើប្រាស់គ្រឿងយន្ត ធ្វើឱ្យមានការធូរស្រាលយ៉ាងច្រើនចំពោះការងារកំប៉ិកកំប៉ុកនៃទម្លាប់ប្រចាំថ្ងៃរបស់ពួកគេ និងបង្កើនពេលវេលាសម្រាប់ពួកគេក្នុងការអនុវត្តសកម្មភាពផ្សេងៗ។

ផលិតផលជីវៈឥន្ធនៈរាវដែលបានមកពីរុក្ខជាតិ និងសម្ភារៈកាកសំណល់ អាចផ្តល់ឱកាសថ្មីសម្រាប់ស្ត្រី និងសហគមន៍ ក្នុងការទទួលបានការប្រើប្រាស់ថាមពលដោយមិនមានការបន្ថែមការបំភាយឧស្ម័នកាបូនសកល។ មានភាពផ្ទុយគ្នាជាច្រើនជាមួយការណែនាំ/ប្រឹក្សានិងនិរន្តរភាពនៃការបង្កើតចំការរុក្ខជាតិជីវឥន្ធនៈវប្បកម្មធំៗ ឬការប្រើប្រាស់ កសិផលចំណីអាហារសម្រាប់ឥន្ធនៈ និងនៅក្នុងករណីជាច្រើនដែលធ្វើឱ្យស្ត្រីរងផលប៉ះពាល់យ៉ាងច្រើនចំពោះអសន្តិសុខស្បៀង ការបាត់បង់ការទទួលបានដីធ្លី និងធនធានសម្រាប់ឥន្ធនៈជីវម៉ាស់តាមបែបប្រពៃណី។ មានសំណួរផងដែរអំពីថាតើប្រតិបត្តិការផ្នែកជីវៈម៉ាស់ជាក់ស្តែងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដែរឬទេនៅពេលធនធានថាមពលទាំងអស់ដែលត្រូវការសម្រាប់ប្រតិបត្តិការទំហំធំ ត្រូវបានយកមកគិតគូរនោះ។ ជាលទ្ធផល ផលិតផលជីវៈឥន្ធនៈមិនទាន់ត្រូវបានឯកភាពនៅឡើយសម្រាប់ឥណទានកាត់បន្ថយការបំភាយកាបូន។ ផ្ទុយទៅវិញ ការធ្វើផែនការបានត្រឹមត្រូវ គោលនយោបាយដែលមានយេនឌ័រ ស្តីពីផលិតផលជីវៈឥន្ធនៈមានសក្តានុពលក្នុងការផ្លាស់ប្តូរតួនាទីបច្ចុប្បន្នរបស់ស្ត្រីក្នុងនាមជាអ្នកផ្គត់ផ្គង់ថាមពល

ទៅក្នុងការចិញ្ចឹមជីវិតប្រកបដោយចីរភាពដែលបង្កើតបាននូវភាពជឿនលឿននៅក្នុងកិច្ចអភិវឌ្ឍជនបទ និងការពឹងពាក់លើខ្លួនឯង។

នៅពេលដែលក្រុមស្ត្រីបានចូលរួមពាក់ព័ន្ធនៅក្នុងការទទួលបាន និងការប្រតិបត្តិប្រព័ន្ធថាមពលប្រភេទថ្មី ពួកគេអាចអភិវឌ្ឍជំនាញថ្មី និងជីវភាពរស់នៅផងដែរដែលជាអ្នកគ្រប់គ្រងអាជីវកម្ម និងសហគ្រិនភាពផ្នែកថាមពល។ នៅក្នុងមធ្យោបាយនេះ ពួកគេអាចកែលម្អជីវិតរស់នៅផ្ទាល់របស់ពួកគេ និងឱកាសផ្នែកសេដ្ឋកិច្ច ក៏ដូចជាការបម្រើជាអ្នកចូលរួមសកម្មនៅក្នុងការផ្លាស់ប្ដូរពិភពលោកចំពោះការផលិត និងការប្រើប្រាស់ថាមពលប្រកបដោយចីរភាពតាមបែបបរិស្ថាន។ ទោះជាយ៉ាងណាក៏ដោយ មកដល់ពេលបច្ចុប្បន្ននេះ វាមានការលំបាកចំពោះប្រភេទនៃគម្រោងទំហំតូចៗ ដែលស្ត្រីទោរទន់ទៅរកការពាក់ព័ន្ធនៅក្នុងការទទួលបានការប្រើប្រាស់យន្តការអភិវឌ្ឍស្អាត (CDM) និងទីផ្សារឥណទានកាបូនស្ម័គ្រចិត្ត ជាពិសេសនៅក្នុងប្រទេសតូចៗ។ ការងារជាច្រើន ត្រូវការពង្រីកការចូលរួមរបស់ស្ត្រីនៅក្នុងឱកាសទាំងនេះ។

ផ្ទុយទៅវិញ ការកាត់បន្ថយការបំភាយតាមរយៈប្រភពថាមពលស្អាត និងបច្ចេកវិទ្យា មិនគួរផ្ដោតតែនៅក្នុងប្រទេសកំពុងអភិវឌ្ឍនោះឡើយ។ ស្ត្រីដែលមកពីប្រទេសអភិវឌ្ឍនានា មានតួនាទីសំខាន់មួយផងដែរក្នុងការប្រតិបត្តិនៅពេលដែលតួនាទីនេះ ចាប់ផ្ដើមប្រើប្រាស់នូវបច្ចេកវិទ្យាថ្មី និងការប្រើប្រាស់ធនធានថាមពលដូចជា ការណែនាំនូវសម្ភារៈសាងសង់បរិក្ខារអគ្គិសនីប្រើប្រាស់ក្នុងផ្ទះ អំពូលភ្លើង សម្ភារៈដឹកជញ្ជូន និងបច្ចេកវិទ្យាដែលមានប្រសិទ្ធភាព និងមានការបំផ្លិចបំផ្លាញបរិស្ថានតិចតួចផ្សេងទៀតទាំងនៅក្នុង និងក្រៅគ្រួសារ។



## ៥.១.៣ ការកាត់បន្ថយការបំភាយឧស្ម័នៈ ការជាប់ទាក់ទងជាមួយយេនឌ័រ[៤៣]

ដើម្បីកាត់បន្ថយការបំភាយឧស្ម័ន សកម្មភាពនានា មានបំណងធ្វើឱ្យប្រទេសអភិវឌ្ឍមានការពាក់ព័ន្ធបន្ថែមទៀត ខណៈដែលការបំភាយឧស្ម័ននៅក្នុងប្រទេសទាំងនេះត្រូវបានទទួលស្គាល់ពាសពេញពិភពលោកថា ជាប្រទេសទទួលខុសត្រូវចម្បងចំពោះការបំភាយឧស្ម័នផ្ទះកញ្ចក់។ នៅក្នុងបរិបទនេះ អង្គការផ្សេងៗបានប្ដេជ្ញាចិត្តក្នុងការលើកកម្ពស់សមភាពនៅក្នុងប្រទេសទាំងនេះ បានធ្វើការវិភាគការជាប់ពាក់ព័ន្ធផ្នែកយេនឌ័រចេញពីតួនាទីខុសគ្នាសំខាន់ៗចំនួនពីរ។

តួនាទីទីមួយ គឺថាមានតិចតួចក្នុងការទទួលបានដោយការចាប់យកយេនឌ័រជាមូលដ្ឋានគ្រឹះក្នុងការវិភាគ ការទទួលខុសត្រូវលើការបំភាយឧស្ម័ន។ ក្រុមនេះចាត់ទុកថា រហូតមកដល់ពេលនេះមិនមានការសិក្សាជាក់លាក់ណាមួយត្រូវបានសិក្សាអំពីថាតើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះឧស្ម័នកាបូន ហើយការងារនេះធ្វើឱ្យវាមានភាពបន្ទាន់ច្រើនសម្រាប់ការវិភាគខុសៗគ្នាដែលត្រូវរៀបចំឡើងសម្រាប់កំណត់លក្ខខ័ណ្ឌផ្នែកសង្គម នយោបាយ និងការរៀបចំផែនការនៅក្នុងមធ្យោបាយខុសៗគ្នាតាមតំបន់ និងតាមប្រទេសដែលមានឥទ្ធិពលលើការកាត់បន្ថយការបំភាយឧស្ម័នដែលអាចធ្វើទៅបាន (Wamukoya និង Skutch ឆ្នាំ២០០២)។

តួនាទីទីពីរ បង្ហាញថាមានការគិតគូរអំពីយេនឌ័រដែលទាក់ទងនឹងការបំភាយឧស្ម័ន។ ការសិក្សាបឋមមួយចំនួនត្រូវបានអនុវត្តឡើងនៅអឺរ៉ុប ជាពិសេសការសិក្សាមួយដែលបានលើកកម្ពស់ដោយរដ្ឋាភិបាលប្រទេសស៊ុយអែត (Johns-

---

៤៣. The discussion on point 5.1.3 draws heavily upon: Aguilar et al.(2008a). Guía: Recurso de género para el cambio climatic. Mexico: UNDP

son-Latham ឆ្នាំ២០០៧) បានសិក្សាអំពីភាពខុសគ្នារវាង (ស្លាកស្នាមនៃបរិស្ថានវិទ្យា) ស្ត្រី និងបុរសលើកម្រិតសេដ្ឋកិច្ច-សង្គមខុសៗគ្នា រាប់បញ្ចូលទាំងរបៀបរស់នៅរបស់ពួកគេ និងការរួមចំណែកដែលពួកគេ អនុវត្តក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់។

ឧទាហរណ៍ ការវិភាគមួយត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងវិសាលភាពយេនឌ័រនៅក្នុងផ្នែកនយោបាយ និងការដឹកជញ្ជូនដោយគ្មានការសង្ស័យអំពីផ្នែកដែលមានសារៈសំខាន់មួយនៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយការប្រែប្រួលអាកាសធាតុ ហើយថាតើការបំភាយដែលទាក់ទងនឹងការដឹកជញ្ជូនមានភាពខុសគ្នាដូចម្តេចជាមួយផ្នែកយេនឌ័រ?

ប្រព័ន្ធដឹកជញ្ជូនបច្ចុប្បន្នត្រូវបានរៀបចំឡើងជាមួយទស្សនៈងាយៗមួយសម្រាប់ "មនុស្សស្ថិតក្នុងវ័យកណ្តាល-បុរសធ្វើការពេញម៉ោង" ខណៈដែលការមិនយកចិត្តទុកដាក់លើការពឹងផ្អែករបស់ស្ត្រីលើសេវាដឹកជញ្ជូនសាធារណៈ គឺមានកម្រិតខ្ពស់ បើទោះជាពួកគេទាំងនោះប្រើសេវាដឹកជញ្ជូនសាធារណៈច្រើនក៏ដោយ។ សម្រាប់ការងារ និងការកំសាន្ត ស្ត្រីធ្វើដំណើរតាមរថយន្តពុំសូវញឹកញាប់ និងក្នុងចម្ងាយផ្លូវជិតៗ ប្រើប្រាស់រថយន្តតូចៗជាមួយបច្ចេកវិទ្យាសន្សំសំចៃឥន្ធនៈ ហើយស្ត្រីធ្វើដំណើរតាមយន្តហោះពុំសូវញឹកញាប់ដូចបុរសទេ។

ការទទួលស្គាល់ភាពខុសគ្នានៃតួនាទីដែលបានបរិយាយខាងលើស្តីពីការបំភាយឧស្ម័ន និងយេនឌ័រ ភាពខុសគ្នាទាំងនោះ បានបង្ហាញថាស្ត្រី និងបុរស មានគំនិត និងទស្សនៈខុសគ្នាចំពោះការប្រែប្រួលអាកាសធាតុ។ នៅឆ្នាំ២០០៧ ក្នុងចក្រភពអង់គ្លេស អង្គការមួយក្រុមបានដាក់បង្ហាញនូវ "សេចក្តីថ្លែងការណ៍របស់ស្ត្រីស្តីពីការប្រែប្រួលអាកាសធាតុ" ដែលក្នុងនោះពួកគេស្នើថាការទទួលខុសត្រូវសម្រាប់ការបំភាយឧស្ម័ន ជួនកាលមើលទៅហាក់ដូចជាមានទំនាក់ទំនងជាមួយការបែងចែកកម្លាំងពលកម្មផ្អែកតាមយេនឌ័រ អំណាចសេដ្ឋកិច្ច និងការប្រើប្រាស់ខុសៗគ្នារបស់ស្ត្រី និងបុរស និងទម្លាប់នៃកំសាន្ត។ ការសិក្សាបានរកឃើញផងដែរថា ស្ត្រីមានការបារម្ភអំពីការប្រែប្រួលអាកាសធាតុច្រើនជាងបុរស និងធ្វើការស្នើឱ្យមានការផ្លាស់ប្តូររបៀបនៃការរស់នៅ និងឥរិយាបថក្នុងការប្រើប្រាស់ដែលបុរសបានពេញចិត្តដំណោះស្រាយតាមបែបបច្ចេកវិទ្យាច្រើនសម្រាប់ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ (បណ្តាញបរិស្ថានរបស់ស្ត្រី និងសហព័ន្ធជាតិនៃវិទ្យាស្ថានស្ត្រី ឆ្នាំ២០០៧)។ សេចក្តីថ្លែងការណ៍ ស្នើឱ្យរដ្ឋាភិបាលអង់គ្លេសចាត់វិធានការណ៍កាត់បន្ថយ និងការពារបរិស្ថាន ហើយស្នើថាវិធានការណ៍នេះត្រូវអនុវត្តនៅក្នុងមធ្យោបាយមួយដែលនឹងធានាឱ្យមានសមភាពយេនឌ័រ។

ការចាប់យក និងការអភិវឌ្ឍកាបូន និងការទទួលបានថាមពលស្អាតតែឯង មិនអាចនាំទៅដល់ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់បានទេ តម្រូវឱ្យមានការបញ្ឈប់ និងផ្លាស់ប្តូរកំដៅជាសកលដែលជាគោលការណ៍បន្សល់ទុកនូវទម្រង់នៃការកាត់បន្ថយជាមួយនឹងផលប៉ះពាល់ដែលមានសក្តានុពលច្រើនប្រសិនបើមានការបង្ខិតបង្ខំ។

នៅពេលក្រុមហ៊ុននានាផលិតទំនិញ និងលើកកម្ពស់ការអនុវត្តដែលមានការទទួលខុសត្រូវបំផុតលើការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ផ្នែកយេនឌ័ររបស់ខ្លួននោះ ស្ត្រីត្រូវធ្វើជាអ្នកដឹកនាំក្នុងចលនាក្នុងការបង្កើតចំណុចដៅនានាដែលអាចបង្គាប់បាន និងការបង្កើតគោលការណ៍សម្រាប់ទប់ស្កាត់ការបំភាយឧស្ម័នផ្ទះកញ្ចក់។

ទោះបីជាការសិក្សា និងឧទាហរណ៍ដែលបានលើកឡើងខាងលើ រឿងនៃការកាត់បន្ថយការបំភាយឧស្ម័ន និងការពាក់ព័ន្ធផ្នែកយេនឌ័រ គឺជាចំណុចមួយនៃចំណុចនានាដែលត្រូវការស្រាវជ្រាវ និងការវិភាគបន្ថែមនៅក្នុងឆ្នាំជាបន្តបន្ទាប់។

## ៥.១.៤ ការប្រើប្រាស់ ៖ បញ្ហាយេនឌ័រ

នៅក្នុងទសវត្សរ៍នេះ ថ្នាក់អ្នកប្រើប្រាស់ជាសកល ត្រូវបានរីកដុះដាលយ៉ាងគំហុក ដូចជារបបអាហារ ប្រព័ន្ធដឹកជញ្ជូន និងរបៀបរស់នៅនៃប្រទេសអ្នកមានរបស់ពិភពលោកបានសាយភាយជុំវិញពិភពលោក។ ផ្អែកតាមវិទ្យាស្ថានឃ្លាំមើលពិភពលោកឆ្នាំ២០០៨ បច្ចុប្បន្ន មានសមាជិក "ថ្នាក់អ្នកប្រើប្រាស់" ចំនួនច្រើនជាង១,៧ ពាន់លាននាក់ - ពួកគេទាំងនោះជិតពាក់កណ្តាលរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ ផ្ទុយទៅវិញ នៅពេលថ្នាក់អ្នកប្រើប្រាស់មានការលូតលាស់នោះធ្វើឱ្យមានគម្លាតកាន់តែធំ។ ប្រជាពលរដ្ឋពិភពលោកចំនួន១២% ដែលរស់នៅក្នុងប្រទេសអាមេរិកភាគខាងជើង និងនៅក្នុងអឺរ៉ុបខាងលិចចំនួន ៦០% នៃអ្នកប្រើប្រាស់ឯកជនដែលបានចំណាយលើការប្រើប្រាស់ ខណៈដែលប្រជាជន១ភាគ៣ដែលរស់នៅអាស៊ីខាងត្បូង និងអនុតំបន់អាហ្វ្រិកសាហារ៉ាចំនួនត្រឹមតែ ៣,២% ប៉ុណ្ណោះដែលបានចំណាយ។

ការប្រមើលមើលផ្នែកបរិស្ថានជាសកលលើកទី៤ ៖ របាយការណ៍អភិវឌ្ឍបរិស្ថាន (GEO-4) បានផ្តល់មូលហេតុបន្ថែមសម្រាប់សេចក្តីបារម្ភដែលបង្ហាញថា មនុស្សកំពុងប្រើប្រាស់ដ៏លើសលប់នូវសេវាប្រព័ន្ធបរិស្ថានរបស់ផែនដី នៅក្នុងអត្រាមួយដែលកំពុងរត់ពីមុខសមត្ថភាពរបស់ធម្មជាតិក្នុងការបង្កើតឡើងវិញ និងបំពេញបន្ថែមនូវសមត្ថភាពទាំងនោះ (UNEP ឆ្នាំ២០០៧)។

**ប្រអប់ទ៥:** និយមន័យនៃការប្រើប្រាស់ដែលមានចីរភាព

ការប្រើប្រាស់ដែលមានចីរភាព គិតគូរអំពីវិសាលភាពផ្នែកសង្គម សេដ្ឋកិច្ច បរិស្ថាន និងសីលធម៌នៃផលិតផល និងរបៀបដែលពួកគេផលិតក៏ដូចជា ផលប៉ះពាល់ផ្នែកបរិស្ថានរបស់ពួកគេ។

ជាលទ្ធផលនៃការបរិយាយខាងលើ ដំណោះស្រាយការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ត្រូវការផងដែរនូវការចូលរួមពាក់ព័ន្ធរបស់អ្នកប្រើប្រាស់ ខណៈដែលពួកគេជាមនុស្សសំខាន់ក្នុងការជម្រុញការផលិតដែលមានចីរភាព និងជាអ្នកដើរតួនាទីនៅចំកណ្តាលមួយក្នុងការអភិវឌ្ឍដែលមាននិរន្តរភាព។

យោងតាមការសិក្សានានាដែលមានរៀបចំដោយ OECD (២០០៨a និង២០០៨b) យេនឌ័រមានឥទ្ធិពលយ៉ាងច្រើនលើការប្រើប្រាស់ដែលមាននិរន្តរភាព (សូមមើលប្រអប់ទី៥) ដោយសារគំរូនៃការប្រើប្រាស់ដែលមានការខុសគ្នារវាងស្ត្រី និងបុរស។

- នៅក្នុងប្រទេស OECD មួយចំនួន ស្ត្រីមានចំនួនច្រើនជាង៨០%នៃការធ្វើសេចក្តីសម្រេចក្នុងការប្រើប្រាស់។
- ស្ត្រីជាអ្នកប្រើប្រាស់ដែលមាននិរន្តរភាព ៖ ពួកគេចង់ទិញម្ហូបអាហារដែលមានស្លាកយីហោបែបធម្មជាតិ ឬម្ហូបអាហារដែលគ្មានជាតិគីមីដែលមានភាពលំអៀងទៅរកការប្រើប្រាស់ម្តងទៀត និងការផ្តល់តម្លៃបន្ថែមលើថាមពលដែលមានប្រសិទ្ធភាពខ្ពស់ជាងបុរស។
- ស្ត្រីយកចិត្តទុកដាក់ជិតស្និទ្ធជាងនៅក្នុងការជាវរបស់ពួកគេចំពោះបញ្ហាក្រមសីលធម៌ដូចជា ពលកម្មកុមារ និងការរកស៊ីដោយស្មើភាព។

សេចក្តីសង្ឃឹមចំពោះសកម្មភាព គឺជាឧទាហរណ៍ដ៏ល្អមួយចំពោះអ្វីដែលអាចធ្វើបានដោយស្ត្រីនៅក្នុងប្រទេសអភិវឌ្ឍនៅតាមកម្រិតគ្រួសារ។ អង្គការនេះ កំណត់គំរូនៃការប្រើប្រាស់នៅក្នុងសហរដ្ឋអាមេរិកដែលបានគិតគូរអំពីតួនាទីរបស់ស្ត្រី

នៅក្នុងការធ្វើសេចក្ដីសម្រេចរបស់អ្នកប្រើប្រាស់។ យុទ្ធសាស្ត្ររបស់ពួកគេមានការរៀបចំ “ពិព័រណ៍បរិស្ថាន” ដែលធ្វើការប្រមូលផ្ដុំស្ត្រីនៅជិតខាងគ្នា និងសហគមន៍ ហើយធ្វើការផ្ដល់នូវប្រឹក្សាផ្នែកអនុវត្តស្ដីពីការកាត់បន្ថយការប្រែប្រួលអាកាសធាតុតាមរយៈការប្រើប្រាស់ដែលមាននិរន្តរភាព ( www.hopetoaction.org )។

ដូច្នេះ យុទ្ធនាការ និងកិច្ចខិតខំប្រឹងប្រែងអប់រំបានដឹកនាំទៅរកគំរូអ្នកប្រើប្រាស់ដែលមានការផ្លាស់ប្ដូរ និងគោលការណ៍សហប្រតិបត្តិការនៃការប្រើប្រាស់ដែលមាននិរន្តរភាព នៅពេលដែលយុទ្ធសាស្ត្រកាត់បន្ថយការប្រែប្រួលអាកាសធាតុ ស្ត្រីត្រូវបានចាត់ទុកថាជាក្រុមគោលដៅមួយដ៏សំខាន់។ លើសពីនេះទៀត ស្ត្រីនៅក្នុងប្រទេសជាច្រើននៅតែជាអ្នកទទួលខុសត្រូវលើការផ្ទេរការអប់រំ និងគោលការណ៍បរិស្ថានដល់កូនចៅរបស់ពួកគេ។

## ឯកសារស្រាវជ្រាវ


Agarwal, B. ( 2002 ). “Participatory Exclusions, Community Forestry, and Gender: An Analysis for South Asia and a Conceptual Framework”. World Development 29( 10 ): 1623–1648.

Aguilar, L., Araujo, A. and Quesada-Aguilar, A. ( 2007 ). Reforestation, Afforestation, Deforestation, Climate Change and Gender. Fact Sheet. Costa Rica: IUCN.

Brody, A., Demetriades, J. and Esplen, E. ( 2008 ). Gender and climate change: mapping the linkages. UK: BRIDGE, Institute of Development Studies (IDS).

ENERGIA. ( 2007 ). Where Energy is Women’s Business: National and Regional Reports from Africa, Asia, Latin America and the Pacific. Retrieved from the World Wide Web from: www.energia.org/csd_book.html

FAO. ( 2008 ). Gender and food security: forestry. http://www.fao.org/gender/ en/fore-e.htm

Gurung, J., Lama, K. and Khadkha, M. ( 2006 ). Empowered Women and the Men behind Them: A Study of Change within the HMG/IFAD Hills Leasehold Forestry and Forage Development Project in Nepal. IFAD Case Study. Italy: IFAD.

Johnsson-Latham, G. ( 2007 ). A Study on Gender Equality as a Prerequisite for Sustainable Development. Sweden: The Environment Advisory Council Ministry of the Environment.

UNDP. ( 2007 ). Gender Mainstreaming in Environment and Energy: Training Manual. Retrieved from the World Wide Web from: http://www.undp.org:80/energyandenvironment/gender.htm

UNDP and ENERGIA. ( 2004 ). Gender and Energy for Sustainable Development: A Toolkit and Resource Guide. Retrieved from the World Wide Web from: www.undp.org/energy/genenergykit/genderengtoolkit.pdf

## កិច្ចការសម្រាប់ជំពូកនេះ

| សកម្មភាព | នីតិវិធី | ពេលវេលា |
|---|---|---|
| បង្កើតទំនាក់ទំនងជាមួយយេនឌ័រ និងកិច្ចប្រឹងប្រែងកាត់បន្ថយការប្រែប្រួលអាកាសធាតុ | បច្ចេកទេស **“បង្កើតករណីសិក្សា”** | ៦០ នាទី |
| គំនិត/ទស្សនៈសម្រាប់ការផ្លាស់ប្តូរទៅមុខស្តីពីការបញ្ជ្រាបយេនឌ័រនៅក្នុងកិច្ចប្រឹងប្រែង/គំនិតផ្តួចផ្តើមកាត់បន្ថយការប្រែប្រួលអាកាសធាតុ | បច្ចេកទេស **“ការផ្លាស់ប្តូរទៅមុខ”** | ៦០ នាទី |

# ករណីសិក្សា

## ករណីសិក្សាទី១

### ការផលិតជីវៈឥន្ធនៈនៅតំបន់ជនបទនៃប្រទេសឥណ្ឌា

គម្រោង Clean Star Trust Project នៅក្នុងប្រទេសឥណ្ឌា ត្រូវបានបង្កើតឡើងសម្រាប់តម្រូវការបន្ទាន់ក្នុងការជ្រើសរើសការចិញ្ចឹមជីវិតប្រកបដោយចីរភាពតាមបែបបរិស្ថានសម្រាប់ជនក្រីក្រ ដែលរស់នៅពឹងផ្អែកលើធនធានធម្មជាតិតាមបែបប្រពៃណីដែលបច្ចុប្បន្នកំពុងមានផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ដើម្បីធានាថាយុទ្ធវិធីរបស់យុទ្ធនាការមានឥទ្ធិពលច្រើន លើការកាត់បន្ថយការប្រែប្រួលអាកាសធាតុ គម្រោង កំពុងប្រើប្រាស់ស្តង់ដារស្ម័គ្រចិត្តដែលបង្កើតឡើងដោយសម្ព័ន្ធសហគមន៍អាកាសធាតុ និងជីវៈចម្រុះដែលជម្រុញលើកទឹកចិត្តការបង្កើត “គម្រោងដែលជួយតបតយ៉ាងវិសេសចំពោះការប្រែប្រួលអាកាសធាតុ ជម្រុញការអភិវឌ្ឍប្រកបដោយចីរភាព និងអភិរក្សឬបង្កើតឡើងវិញនូវជីវៈចម្រុះ” (CCBA ឆ្នាំ២០០៥)។

មហារ៉ាស្សត្រា ភាគកណ្តាលនៅក្នុងប្រទេសឥណ្ឌាភាគកណ្តាល គឺជាតំបន់ដែលមានភាពរាំងស្ងួតញឹកញាប់ និងជាតំបន់រុំព័ទ្ធពីប្រទេសផ្សេងៗដែលគ្មានឆ្នេរសមុទ្រដែលទីនោះធនធានធម្មជាតិ ត្រូវបានបំផ្លិចបំផ្លាញយ៉ាងច្រើន។ ការកើនឡើងនៃការខ្វះទឹក ចំណែកនៃខ្យល់មូសសុងមិនទៀងទាត់ និងសំណឹកធ្ងន់ធ្ងរបានបង្ខំឱ្យប្រជាជនប្រមាណ ៧០% ចាកចេញពីតំបន់ជនបទ ទុកស្រែចម្ការចោល និងធ្វើឱ្យសាលារៀនគ្មានសិស្សរៀន។ ការកាន់កាប់ដីធ្លី គឺមានតិចតួច ហើយ ២ភាគ៣ នៃដីទាំងនោះ គឺមិនសមស្របសម្រាប់ផលិតផលកសិកម្មឡើយ។ ដីដែលអាចដាំដំណាំបានគឺមានតិចទៅៗ។ នៅពេលដែលស្ថានភាពអាកាសធាតុ និងសេដ្ឋកិច្ចសង្គមកាន់តែអាក្រក់ទៅៗ គ្រួសារជាច្រើនកំពុងមានបំណុលពីព្រោះពួកគេមិនអាចលៃលក់រស់បាន។ គ្រួសារដែលអស់សង្ឃឹមជាង ១.២០០នាក់ បានធ្វើអត្តឃាតកាលពីពីរឆ្នាំមុននៅក្នុងតំបន់នេះ។

ផ្អែកតាមសហគមន៍ខ្លួនឯង ពួកគេត្រូវការឱកាសចិញ្ចឹមជីវិតថ្មីដែលផ្តល់ឱ្យពួកគេនូវប្រាក់ចំណូលដែលទៀងទាត់ គឺមាននិរន្តរភាព និងអាចភ្ជាប់ពួកគេទៅនឹងទីផ្សារដែលលូតលាស់យ៉ាងលឿន។ នៅឆ្នាំ២០០៤ អតីតសិស្សថ្នាក់អនុបណ្ឌិតនៃសាកលវិទ្យាអ័រហ្វត ផ្នែកសហគ្រិនភាពផ្នែកសង្គមមួយក្រុមតូច បានចាប់ផ្តើមគម្រោងសាវជ្រាវមួយស្តីពីការផលិតជីវៈឥន្ធនៈ ដែលមាននិរន្តរភាពចេញពីគ្រាប់រុក្ខជាតិដែលមានជាតិប្រេងនៅលើដីទំនេរ នៅក្នុងតំបន់មហារ៉ាស្សត្រាភាគកណ្តាលដែលមានការជួយពីសហគមន៍មូលដ្ឋាន។ បន្ទាប់ពីការសាកល្បងរយៈពេលពីរឆ្នាំ ប្រធានក្រុមការងារក្នុងកិច្ចសហការជាមួយអ្នកជំនាញដែលមានជំនាញ នៅក្នុងចាំត្រូហ្វា និងផុនហ្គាមៀ និងជីកសិកដ្ឋានដែលហួតហែងមានលទ្ធភាពក្នុងការបង្កើតសំណុំនៃការអនុវត្តការដាំព្រៃដែលទាក់ទងនឹងការពង្រីករុក្ខជាតិដែលមានផ្លែជាតិប្រេង ហើយបានចាប់ផ្តើមប្រើប្រាស់បច្ចេកទេសសាកល្បងកែច្នៃផ្លែរុក្ខជាតិដែលមានជាតិប្រេងទៅជាជីវឥន្ធនៈ ដែលអាចប្រើប្រាស់បាន។ នៅត្រឹមឆ្នាំ ២០០៦ ដើមឈើចំនួន១០០.០០០ ដើមត្រូវបានដាំ។

ជំនួសឱ្យការចាប់ផ្តើមអង្គការ សម្រាប់ស្វែងរកចំណូលមួយ ក្រុមបានសម្រេចប្រើប្រាស់ចំណេះដឹងតាមមូលដ្ឋានរបស់ខ្លួនសម្រាប់ផ្តល់ប្រយោជន៍ ធំទូលាយដល់សហគមន៍។ បច្ចុប្បន្ន គម្រោងជំនឿតារាបរិសុទ្ធបានបង្កើតសហគ្រាសខ្នាតមីក្រូនៅតាមភូមិសម្រាប់បង្កើតដំណោះស្រាយ ថាមពលដោយអ្នកក្រីក្រសម្រាប់អ្នកក្រីក្រ។ យុទ្ធនាការផ្តោតជាបឋម (ប៉ុន្តែមិនផ្តាច់មុខឡើយ) លើការដាំដុះរុក្ខជាតិ ជីវឥន្ធនៈ ( តំបន់ចាំត្រូហ្វា និងផុនហ្គាមៀ) ពីព្រោះមានតែដើមឈើមួយចំនួនប៉ុណ្ណោះ ដែលអាចផ្តល់ផលបាននៅលើដីដែលអាចដាំបានរុក្ខជាតិទាំងនេះមិនអាចផ្លាស់ប្តូរឬមិនអាចប្រកួត

ប្រជែងជាមួយផលិតផលចំណីអាហារបានទេ ប៉ុន្តែតម្រូវការសម្រាប់ថាមពលនៅក្នុងតំបន់នេះ គឺមានកម្រិតខ្ពស់។

គម្រោង Clean Star Trust Project បានបង្កើតវេទិកាសហគមន៍ដែលជាកន្លែងស្ត្រីបានរៀបចំក្រុមជួយខ្លួនឯង (SHG) ក្នុងការរៀបចំ និងអនុវត្តផែនការសម្រាប់បង្កើនប្រភពចំណូលថ្មីចេញពីធនធានដែលមានស្រាប់ តាមរយៈការចាត់ចែង/គ្រប់គ្រងបានល្អប្រសើរ។ ក្រុមស្ត្រីទាំងនេះកំពុងទទួលខុសត្រូវលើការចាត់ចែងអាជីវកម្មរបស់ពួកគេផងដែរ។ ក្នុងនាមជាក្រុម ពួកគេធ្វើជាម្ចាស់លើទ្រព្យសម្បត្តិទាំងអស់ដែលទទួលបានអំឡុងពេលបង្កើតគម្រោង (ដើមឈើ និងសម្ភារៈកែច្នៃ)។

កាលពីជាងបីឆ្នាំមុន តម្រូវការគ្រាប់រុក្ខជាតិមានជាតិប្រេងដែលមិនអាចបរិភោគបាន ត្រូវបានទទួលយកនៅក្នុងទីផ្សារតាមមូលដ្ឋាន (មែនឪស) ដែលធ្វើឱ្យអាជីវកម្មរបស់ស្ត្រីមានការរីកចម្រើនលូតលាស់។ ផែនការរបស់រដ្ឋាភិបាលក្នុងការជម្រុញឱ្យមានសម្ភារៈកែច្នៃជីវឥន្ធនៈ បានគាំទ្រអាជីវកម្មទាំងនេះនៅពេលមានការវិនិយោគពីផ្នែកឯកជនដូចជា ការកសាងរោងចក្រស្លជីវប្រេងម៉ាស៊ូតថ្មីៗ នៅក្នុងតំបន់គោលដៅ។ បច្ចុប្បន្ន អ្នកកែច្នៃជីវឥន្ធនៈភាគច្រើនបំផុត ជួបប្រទះការខ្វះខាតវត្ថុធាតុដើមយ៉ាងធ្ងន់ធ្ងរ (ទាំងគ្រាប់ និងប្រេង) សម្រាប់សម្ភារៈកែច្នៃរបស់ពួកគេ ហើយដូច្នេះពួកគេកំពុងស្វែងរកអ្នកផ្គត់ផ្គង់យ៉ាងច្រើន។ ស្ត្រីកំពុងអភិវឌ្ឍអាជីវកម្មដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនេះ។

CleanStarTrustProject ផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេសដែលកំពុងបន្តដល់ម្ចាស់អាជីវកម្មតូចៗ នៅក្នុងចំណុចដូចខាងក្រោម៖

១. ការប្រមូលទិញគ្រាប់រុក្ខជាតិព្រៃ ការបណ្តុះបណ្តាលដែលពាក់ព័ន្ធនឹងការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការប្រមូលទិញ ការរក្សាទុក និងការលក់គ្រាប់រុក្ខជាតិដែលមានជាតិប្រេងដល់អ្នកទិញដោយផ្ទាល់។

២. ការដាំដើមឈើជីវឥន្ធនៈ ប្រាក់កម្ចីខ្នាតតូចដែលពាក់ព័ន្ធ និងគាំទ្របច្ចេកទេសសម្រាប់ការដាំដើមឈើ និងការគ្រប់គ្រងទីជម្រាលនៅពេលធ្វើការដាំដុះ។ មូលនិធិត្រូវបានផ្តល់ឱ្យជាប្រចាំរហូតដល់ ដើមឈើឱ្យផល (អាយុ៣ឆ្នាំ) បន្ទាប់មកធ្វើការលក់គ្រាប់ដែលមានជាតិប្រេងដើម្បីបង្កើនចំណូលប្រចាំឆ្នាំ។

៣. ការកែច្នៃគ្រាប់មានជាតិប្រេងដែលប្រើប្រាស់ទុន និងជំនាញបច្ចេកទេសរបស់គម្រោង Clean Star Trust Project ដែលពាក់ព័ន្ធក្នុងការទិញ និងបង្កើតសម្ភារៈកែច្នៃគ្រាប់មានជាតិប្រេង។ បន្ទាប់ពីធ្វើការកែច្នៃ (៣០% នៃគ្រាប់) ប្រេងត្រូវបានលក់ទៅឱ្យអ្នកកែច្នៃជីវប្រេងម៉ាស៊ូត និងបំណែក (ដែលនៅសល់ចំនួន ៧០%) ត្រូវបានលក់នៅតាមមូលដ្ឋានជាដុំជីវធ្យូងថ្ម ឬជាជីធម្មជាតិ ដើម្បីជួយបង្កើនទិន្នផលដំណាំ និងផ្លាស់ប្តូរហ្វូស៊ីលប្រេង ដូចជាប្រេងម៉ាស៊ូត និងប្រេងកាត។

៤. រុក្ខកម្មលើទីជម្រាលដែលផ្គត់ផ្គង់កម្ចីខ្នាតតូចពាក់ព័ន្ធសម្រាប់ការដាំដំណាំចន្លោះជួរនូវដើមឈើ ជីវឥន្ធនៈជាមួយឈើហូបផ្លែ និងដំណាំបន្លែ ឬស្មៅស្ងួត។

គម្រោងបានទទួលនូវការគាំទ្រពីអាជ្ញាធរមូលដ្ឋាន នៅក្នុងស្រុកបីដ (Beed) នៃតំបន់មហារ៉ាស្សត្រាភាគកណ្តាល និងបានបង្កើតដៃគូជាមួយអង្គការមូលដ្ឋានចំនួនពីរ។ នៅក្នុងឆ្នាំ ២០០៧ ទីភ្នាក់ងារសហរដ្ឋសម្រាប់កិច្ចអភិវឌ្ឍអន្តរជាតិ (USAID) វិទ្យាស្ថានធនធានពិភពលោក (WRI) និងសម្ព័ន្ធឧស្សាហកម្មឥណ្ឌា (CII) បានប្រកាសថាគម្រោងនេះគឺជាគម្រោងលេខមួយក្នុងចំណោមគម្រោងល្បីៗ របស់ប្រទេសឥណ្ឌា។

គោលដៅសម្រាប់ឆ្នាំ២០០៨ គឺត្រូវដាំដើមឈើចំនួន១លានដើមនៅក្នុងភូមិចំនួន១៥នៃស្រុក បីដ និងបង្កើតនូវថ្នាលបណ្តុះកូនឈើមួយដែលមានកូនឈើចំនួន៥០០.០០០ដើមសម្រាប់ចែកចាយនៅក្នុងភូមិ។

*ប្រភព៖ គេហទំព័រ៖ www.cleanstar.in/trust*

*CCBA. (២០០៥). គម្រោងសហគមន៍អាកាសធាតុ និងជីវចម្រុះ ការរៀបចំស្តង់ដារ (ការនិពន្ធលើកទី១) USA.CCBA. A.CCBA.*

## ករណីសិក្សាទី២

# ដើមឈើរាប់ពាន់លានដើមសម្រាប់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

អ្នកស្រីវ៉ាន់ហ្គារី ម៉ាអាថៃ (Wangari Maathai) បានទទួលរង្វាន់ណូប៉ែលសន្តិភាពនៅឆ្នាំ ២០០៤ សម្រាប់ការងារដែលអ្នកស្រីបានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៧៧នៅពេលដែលអ្នកស្រីចាប់ផ្តើមចលនាតំបន់បៃតង។ ត្រឹមឆ្នាំ២០០៤ ចលនានេះបានដាំដើមឈើជាង៣០លានដើម ដែលផ្តល់ឥន្ទនៈចំណីអាហារ ទីជម្រក និងប្រាក់ចំណូលដល់សហគមន៍ជនបទនៅក្នុងប្រទេសខេនយ៉ា។

នៅក្នុងបទអន្តរាគមន៍រង្វាន់ណូប៉ែលរបស់គាត់ លោកស្រីបានបង្ហាញថានៅពេលលោកស្រីបានផ្តួចផ្តើមចលនាតំបន់បៃតងនៅក្នុងខេនយ៉ា: "ខ្ញុំបានឆ្លើយតបជាអន្លើៗចំពោះតម្រូវការដែលបានកំណត់ដោយស្ត្រីជនបទ មានដូចជាកង្វះអុសដុត ទឹកស្អាត របបអាហារដែលមានតុល្យភាព ទីជម្រក និងប្រាក់ចំណូល។

នៅទូទាំងទ្វីបអាហ្វ្រិក ស្ត្រីជាអ្នកថែទាំ ទទួលខុសត្រូវជាចម្បងចំពោះការគាស់កាយដី និងចិញ្ចឹមគ្រួសារ។ ជាលទ្ធផល ពួកគេជារឿយៗបានដឹងមុនគេអំពីការបំផ្លិចបំផ្លាញបរិស្ថានដែលជាធនធានកម្រ និងមិនអាចទ្រទ្រង់គ្រួសាររបស់ពួកគេបានយូរអង្វែងបាន។

ស្ត្រីដែលយើងបានធ្វើការជាមួយបានប្រាប់ថា មិនដូចពីមុន ពួកគេមិនមានលទ្ធភាពក្នុងការឆ្លើយតបចំពោះតម្រូវការជាមូលដ្ឋានរបស់ពួកគេបានឡើយ.... ខ្ញុំបានដឹងថានៅពេលដែលបរិស្ថានត្រូវបានបំផ្លាញ លួចប្លន់ ឬមិនមានការគ្រប់គ្រងនោះ យើងបំផ្លាញនូវគុណភាពជីវិតរស់នៅរបស់យើង និងអនាគតរបស់មនុស្សជំនាន់ក្រោយ"។

នៅក្នុងខែឧសភា ឆ្នាំ២០០៧ កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ (UNEP) បានបង្កើតយុទ្ធនាការរុក្ខជាតិសម្រាប់ភពផែនដី៖ យុទ្ធនាការ ដើមឈើរាប់ពាន់លានដើម យុទ្ធនាការដាំដើមឈើពេសពេញពិភពលោក បានរំឭកអំពីការងាររបស់សកម្មជន គឺលោកស្រីវ៉ាន់ហ្គារី ម៉ាអាថៃ និងបានការគាំទ្រពីព្រះអង្គម្ចាស់អាល់ប៊ឺតទី២ របស់ប្រទេសម៉ូណាកូ និងមជ្ឈមណ្ឌលវុក្ខកម្មពិភពលោក (មជ្ឈមណ្ឌលអន្តរជាតិសម្រាប់សាវជ្រាវរុក្ខកម្ម (ICRAF))។

យុទ្ធនាការរុក្ខជាតិសម្រាប់ភពផែនដី៖ យុទ្ធនាការដើមឈើរាប់ពាន់លានដើមជម្រុញលើកទឹកចិត្តការដាំដើមឈើនៅតំបន់សំខាន់ៗចំនួនបួនដូចជា៖ i) តំបន់ព្រៃធម្មជាតិដែលបានខូចខាត និងតំបន់ទីរហោឋាន ii) កសិដ្ឋាន និងទេសភាពជនបទ iii) ចំការដែលមានការគ្រប់គ្រងប្រកបដោយចីរភាព និង iv) បរិស្ថានទីប្រជុំជន។ ដើមឈើត្រូវធ្វើការតម្រូវទៅតាមល័ក្ខខណ្ឌមូលដ្ឋាន ហើយល្បាយនៃពូជឈើត្រូវជ្រើសរើសឱ្យស្របទៅតាមវប្បកម្មតែមួយ។ ដើមឈើជាច្រើនមានផលប្រយោជន៍រួមគ្នា ជាពិសេសសម្រាប់អ្នកក្រីក្រ ហើយភាពជាម្ចាស់សិទ្ធទទួលបាន និងប្រើប្រាស់មានសារៈសំខាន់ដូចចំនួនដើមឈើដែរ។

កាបូននៅក្នុងជីវម៉ាស់ព្រៃឈើមានការធ្លាក់ចុះ នៅក្នុងទ្វីបអាហ្វ្រិក អាស៊ី និងអាមេរិកខាងត្បូងអំឡុងពេលឆ្នាំ ១៩៩០-២០០៥។ សម្រាប់ពិភពលោកទាំងមូល កាបូនដែលមាននៅក្នុងជីវម៉ាសព្រៃឈើ បានធ្លាក់ចុះជារៀងរាល់ឆ្នាំចំនួន ១,១កោដ្ឋតោននៃកាបូន (ស្មើនឹង៤ពាន់លានបារ៉ែលដែលមានទំងន់២៥គក្រ)។ ការបាត់បង់ព្រៃឈើធម្មជាតិនៅជុំវិញពិភពលោក រួមចំណែកដល់ការបំភាយឧស្ម័នជាសកលជារៀងរាល់ឆ្នាំច្រើនជាង ការបំភាយផ្នែកដឹកជញ្ជូន។ ដូច្នេះ ការទប់ស្កាត់ការបំផ្លាញព្រៃឈើ គឺជាមធ្យោបាយដែលមានប្រសិទ្ធភាពខ្ពស់ ក្នុងការកាត់បន្ថយការបំភាយឧស្ម័ន។ ដំណោះស្រាយផ្សេងទៀត រាប់បញ្ចូលការបង្កើនប្រសិទ្ធផលថាមពល កាត់បន្ថយតម្រូវការថាមពល ការដឹកជញ្ជូនបានល្អប្រសើរ និងការប្រើប្រាស់ថាមពលបៃតង។

ដើមឈើស្រូបយកឧស្ម័នកាបូន ហើយវាដាក់ន្លែងដែលស្រូបយកកាបូនដ៏សំខាន់។ វាត្រូវបានប៉ាន់ស្មានថាព្រៃឈើរបស់ពិភពលោក រក្សាទុកនូវកាបូនចំនួន២៨៣កោតតោននៅក្នុងជីវម៉ាស់របស់វាតែឯង ហើយកាបូនបានរក្សាទុកនៅក្នុងជីវម៉ាស់ព្រៃឈើ ដើមឈើងាប់ សម្រាមនិងដីរួមគ្នាប្រមាណជា ៥០% ច្រើនជាងកាបូននៅក្នុងបរិយាកាស។

សាស្ត្រាចារ្យ ម៉ាអាថៃ នាពេលថ្មីៗនេះបានបង្ហាញថា "ធនធានធម្មជាតិ នឹងផ្តល់នូវទ្រនាប់ការពារមួយពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ហើយសកម្មភាពដ៏សំខាន់បំផុតមួយនៃសកម្មភាពនានាដែលយើងអាច និងគួរតែអនុវត្តន៍នោះ គឺការផ្តល់អាទិភាពក្នុងការការពារ និងស្តារឡើងវិញនូវព្រៃឈើរបស់យើង។ ជាពិសេស ប្រព័ន្ធអេកូបរិស្ថានព្រៃភ្នំទាំងប្រាំ (នៅក្នុងប្រទេសខេនយ៉ា) ដែលកំណត់នូវលំហូរ និងទំហំទឹកទន្លេ ដំណក់ទឹកភ្លៀង និងការផ្គត់ផ្គង់នូវទឹកក្រោមដីរបស់យើង។

ការបំភាយ ឧស្ម័នផ្ទះកញ្ចក់នៃទ្វីបអាហ្វ្រិក គឺមានតិចតួចប្រៀបធៀបនឹងប្រទេសឧស្សាហកម្មនានា និងការផុសឡើងនៃមហាសេដ្ឋកិច្ចនៃប្រទេសចិន និងឥណ្ឌា។ ប៉ុន្តែការទទួលខុសត្រូវរបស់យើង ក្នុងការធ្វើសកម្មភាពគួរមិនមានតិចតួចដូចគ្នានោះឡើយ។ យើងគឺដែលជាអ្នកត្រូវបង់ថ្លៃសម្រាប់វិនាសកម្មរបស់យើង។ ពួកយើងភាគច្រើនមានការចំណាយរួចរាល់ ហើយការព្យាករអំពីអ្វីដែលត្រូវរក្សាទុក គឺមានភាពស្ងាត់ស្ងៀម"។

ស្ថិតក្រោមយុទ្ធនាការរុក្ខជាតិ សម្រាប់ភពផែនដី៖ យុទ្ធនាការដើមឈើរាប់ពាន់លានដើម បុគ្គលម្នាក់ៗ កុមារយុវវ័យ សហគមន៍ សាលារៀន អង្គការក្រៅរដ្ឋាភិបាល អាជីវកម្ម និងឧស្សាហកម្ម កសិករ អាជ្ញាធរមូលដ្ឋាន និងរដ្ឋាភិបាលថ្នាក់ជាតិ ត្រូវបានជម្រុញឱ្យមានការដាំដើមឈើជាជំហានតូចៗ ប៉ុន្តែជាជំហានអនុវត្តន៍ក្នុងការឆ្លើយតបទៅនឹងអ្វីដែល UNEP បាននិយាយ គឺប្រហែលជាការប្រឈមដែលជាគន្លឹះ សម្រាប់សតវត្សរ៍ទី ២១។ ការសន្យាអាចចូលទៅមើលតាមគេហទំព័រ៖ www.unep.org/billiontreecampaign។ ការសន្យានីមួយៗ អាចជាអ្វីមួយចេញពីដើមឈើមួយដើម រហូតដល់ដើមឈើ១០លានដើម។

"យើងដឹងពីវិទ្យាសាស្ត្រ យើងដឹងពីទិន្នន័យ [នៅពីក្រោយកំដៅជាសកល]" ប្រសាសន៍របស់សាស្ត្រាចារ្យម៉ាអាថៃ។ " ប៉ុន្តែអ្វីដែលសំខាន់ពិតប្រាកដនោះ គឺអ្វីដែលយើងធ្វើ។ ការដាំដើមឈើមួយដើម គឺអ្វីដែលយើងគ្រប់គ្នាអាចធ្វើបាន"។

*ប្រភព៖*

*គេហទំព័រនៃយុទ្ធនាការដើមឈើរាប់ពាន់លានដើម៖*

*www.unep.org/billiontreecampaign/FactsFigures/QandA/index.asp*

*Xan Rice. (2006). "ជ័យលាភីណូប៉ែល ជម្រុញពិភពលោកឱ្យដាំដើមឈើរាប់ពាន់លានដើម" UK: អ្នកថែរក្សា, ថ្ងៃទី៩ ខែ វិច្ឆិកា Maathai, w. ( 2004 ). សន្ទរកថារង្វាន់ណូប៉ែល*

## ករណីសិក្សាទី៣

# គម្រោងជីវឧស្ម័នថ្នាក់ជាតិនៃប្រទេសណេប៉ាល់៖ កាត់បន្ថយការបំភាយឧស្ម័នខណៈពេលដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍

គម្រោងនេះ ជម្រុញការប្រើប្រាស់ជីវឧស្ម័ននៅក្នុងប្រទេសនេប៉ាល់សម្រាប់ចម្អិនអាហារ និងការបំភ្លឺនៅតាមគ្រួសារក្នុងតំបន់ជនបទដោយផ្តល់សម្ភារៈជីវឧស្ម័នក្នុងតម្លៃទាប។ សកម្មភាពគម្រោងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដោយធ្វើការផ្លាស់ប្តូរនូវប្រភពឥន្ទនៈ (ភាគច្រើនបំផុតដូចជា អុស លាមកសត្វ និងប្រេងកាត) ជាមួយជីវឧស្ម័នដែលផលិតចេញពីកាកសំណល់សត្វ និងមនុស្ស។ ត្រឹមតែ១០-១៥% នៃប្រជាជនដែលរស់នៅតំបន់ជនបទនៃប្រទេសណេប៉ាល់មានលទ្ធភាពប្រើប្រាស់ភ្លើងអគ្គិសនី។

នៅក្នុងគ្រួសារដែលមានសម្ភារៈជីវឧស្ម័ន ស្ត្រីទទួលបានផលប្រយោជន៍តាមរយៈការកាត់បន្ថយពេលវេលា និងការខំប្រឹងប្រែងក្នុងការប្រមូល និងការចាត់ចែងការផ្គត់ផ្គង់អុស។ ពួកគេមានការប៉ះពាល់ផងដែរចំពោះហានិភ័យសុខភាពដែលពាក់ព័ន្ធនឹងការបំពុលខ្យល់នៅក្នុងផ្ទះពីផ្សែងភ្លើង និងចង្កៀងប្រេងកាត។ គម្រោងប៉ាន់ប្រមាណថា ស្ត្រីសន្សំសម្ចៃពេលវេលាបានបីម៉ោងជារៀងរាល់ថ្ងៃក្នុងមួយគ្រួសារខណៈពេលពួកគេប្រើប្រាស់ជីវឧស្ម័នសម្រាប់ចម្អិនអាហារលឿនជាងការប្រើប្រាស់អុស។ ស្ត្រីរាយការណ៍ថា ពួកគេប្រើប្រាស់ពេលវេលាដែលបានសន្សំសម្រាប់ការងារ បង្កើនប្រាក់ចំណូល ការចូលរួមរៀនសូត្រ ការងារសង្គម និងការកំសាន្ត។

នៅពេលគ្រួសារភ្ជាប់បង្គន់អនាម័យដោយផ្ទាល់ ជាមួយសម្ភារៈផលិតជីវឧស្ម័ននោះពួកគេ និងសហគមន៍សប្បាយរីករាយយ៉ាងច្រើនជាមួយសុខភាព និងអនាម័យ។ លើសពីនេះទៀតមានឱកាសការងារថ្មីជាមួយការផលិតឡជីវឧស្ម័ន និងការចែកចាយ។

ការងារនេះ គឺជាគម្រោងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់លើកដំបូងនៅក្នុងប្រទេសនេប៉ាល់ ដែលបានផ្តល់ហិរញ្ញវត្ថុ ស្ថិតក្រោមយន្តការអភិវឌ្ឍភាពស្អាតដែលបានបង្កើតឡើងដោយមមជ្ឈមណ្ឌលលើកកម្ពស់ថាមពលឆ្លាស់។ គម្រោងកំពុងទទួលបានហិរញ្ញវត្ថុសម្រាប់ការឧបត្ថម្ភធនក្នុងការចែកចាយសម្ភារៈជីវឧស្ម័នតាមរយៈការលក់សម្ភារៈកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់សរុបចំនួន ១លានតោនដល់មូលនិធិអភិវឌ្ឍកាបូនសហគមន៍ដែលបានចាត់ចែងដោយធនាគារពិភពលោក។ គម្រោងព្យាករណ៍ថា សម្ភារៈជីវឧស្ម័នក្នុងមួយគ្រួសារនឹងកាត់បន្ថយឧស្ម័នកាបូន ជិតប្រាំតោនក្នុងមួយឆ្នាំ។ ការលក់ឥណទានកាត់បន្ថយការបំភាយឧស្ម័នធ្វើឱ្យគម្រោងបង្កើនមូលនិធិរយៈពេលវែងដោយគ្មានការស្វះស្វែងរកជំនួយពីម្ចាស់ជំនួយ។

ការពឹងផ្អែករបស់ប្រទេសលើអុស បានរួមចំណែកយ៉ាងច្រើនដល់ការបំផ្លិចបំផ្លាញព្រៃឈើ ដូច្នេះគម្រោងនឹងកាត់បន្ថយសម្ពាធលើព្រៃឈើផងដែរ។ លើសពីនេះទៀត កាកសំណល់ចេញពីឡជីវឧស្ម័នអាចប្រើប្រាស់ជាជីធម្មជាតិដែលធ្វើឱ្យផលិតផលចំណីមានលូតលាស់បានល្អ ហើយអាចជៀសវាងការចំណាយលើការទិញជីគីមី។

*ប្រភព៖*

*http://carbonfinance.org/Router.cfm?page=CDCF&-FID=9709&ItemID=Projects&ProjID=9596*

*http://listsery.repp.org/pipemail/digestion listsery.repp.org/2006-May/000418.html*

# ការបង្កើតករណីសិក្សា



គោលបំណង៖ ស្វែងយល់អំពីផលប្រយោជន៍នៃការបញ្ជ្រាបយេនឌ័រនៅក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការចាប់យក បំពេញបន្ថែម និងការព្រែកយកកាបូន។

សម្ភារៈ ៖ ថតចម្លងឯកសារបង្រៀន ហ្វឺត ស្កុត ក្រដាសផ្ទាំងធំ និងម្ហូលខ្មាស់។

និតិវិធី ៖

១. រៀបចំគំនិត/ទស្សនៈ សំណួរជាគន្លឹះ និងធ្វើការណែនាំក្រុមនីមួយៗដើម្បីជួយពួកគេក្នុងការងារនេះ។ គិតអំពីថាតើអ្នកចង់សម្រសម្រួលការពិភាក្សាចុងក្រោយ និងរៀបចំធ្វើសេចក្តីសន្និដ្ឋានមួយចំនួនដោយរបៀបណា?។

២. បែងចែកអ្នកចូលរួមជាប្រាំក្រុម ហើយចាត់តាំងពួកគេឱ្យធ្វើកិច្ចការដូចខាងក្រោម៖

- ក្រុមទី១ មើលចំណុច ៥.១
- ក្រុមទី២ មើលចំណុច ៥.១.១
- ក្រុមទី៣ មើលចំណុច ៥.១.២

- ក្រុមទី៤ មើលចំណុច ៥.១.៣
- ក្រុមទី៥ មើលចំណុច ៥.១.៤

៣.ពន្យល់ថាលំហាត់នេះផ្តោតលើទិដ្ឋភាពខុសៗគ្នានៃសារៈសំខាន់ និងអន្តរផ្នែករវាងបញ្ហាយេនឌ័រ និងការកាត់បន្ថយ។ ពន្យល់ថាចំណេះដឹងដែលទទួលបានពីជំពូកមុនៗ គួរត្រូវប្រើប្រាស់សម្រាប់ជំពូកនេះ។ ផ្តល់នូវការណែនាំដោយសង្ខេបដោយបង្ហាញគោលបំណងសម្រាប់លំហាត់នេះ។ ពន្យល់ថាក្រុមនីមួយៗនឹងធ្វើការពិភាក្សាអំពីចំណុចខុសៗគ្នា ហើយពួកគេនឹងទទួលខុសត្រូវលើការធ្វើបទបង្ហាញអំពីលទ្ធផលនៃក្រុមពិភាក្សាដល់ក្រុមធំនៅចុងបញ្ចប់។

៤.ចាត់តាំងប្រធានក្រុមម្នាក់ក្នុងមួយក្រុម។ សុំឱ្យអ្នកចូលរួមអាននូវផ្នែកដែលបានកំណត់នៃជំពូកនេះរួមជាមួយនឹងករណីសិក្សា ហើយបន្ទាប់មកធ្វើការពិភាក្សា និងរៀបចំ "ចំណុចការពារ" ផ្អែកលើសំណួរដូចខាងក្រោម៖

- តើមានចំណុចសំគាល់អ្វីខ្លះអំពីតួនាទីរបស់ស្ត្រីក្នុងបរិបទនេះ?
- តើមានផលប្រយោជន៍ដែលមានសក្តានុពលអ្វីខ្លះចំពោះការបញ្ជ្រាបការគិតអំពីយេនឌ័រ?
- តើមានឧបសគ្គអ្វីខ្លះ?
- តើអាចមានការបាត់បង់អ្វីខ្លះប្រសិនបើការគិតគូរអំពីយេនឌ័រមិនត្រូវបានដាក់បញ្ចូលនោះ?

៥.សុំឱ្យក្រុមសរសេរអំពីលទ្ធផលនៃការពិភាក្សាលើសំណួរនីមួយៗនៅលើក្រដាសផ្ទាំងធំ។ ជួយប្រធានក្រុមក្នុងការសម្របសម្រួលការពិភាក្សារបស់ពួកគេ ហើយធ្វើការបញ្ជាក់អំពីបញ្ហាដែលជាគន្លឹះ។

៦.សុំឱ្យក្រុមនីមួយៗបង្ហាញអំពី "ចំណុចការពារ" របស់ពួកគេ។ សមាជិកក្រុមទាំងអស់អាចចូលរួមនៅក្នុងការបង្ហាញនេះ។ ប្រសិនបើអាច ពួកគេអាចផ្តល់ព័ត៌មានបន្ថែមនៅលើបញ្ហាដែលជាគន្លឹះ និងមធ្យោបាយដែលអាចដោះស្រាយបញ្ហាទាំងនោះបាន។

៧. អនុញ្ញាតឱ្យអ្នកចូលរួមពីក្រុមផ្សេងមានសំណួរ និងមានសំណូមពរ។

# ការផ្លាស់ប្តូរឆ្ពោះទៅមុខ





គោលបំណង៖ កំណត់សកម្មភាពដែលអាចធ្វើទៅបានក្នុងការសម្របសម្រួលការបញ្ជ្រាបយេនឌ័រនៅក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយ។

សម្ភារ៖ ថតចម្លងឯកសារបង្រៀន ហ្វឹត ក្រដាសកាត់តូចៗដែលមានបួនពណ៌ខុសៗគ្នា (ប្រមាណជា៤០សន្លឹកក្នុងមួយពណ៌ ផ្អែកតាមចំនួនអ្នកចូលរួម) ស្កុត ក្រដាសផ្ទាំងធំ កាតប៉ុស្តាល់ (ម្នាក់មួយ) និងម្ជុលខ្ទាស់។
សរសេរនូវអត្ថបទខាងក្រោមលើក្រដាសកាត់តូចៗដែលមានពណ៌ខុសៗគ្នា៖

ពណ៌ក្រហម៖ កាត់បន្ថយការបំភាយឧស្ម័ន

ពណ៌ខៀវ៖ ការប្រើប្រាស់

ពណ៌បៃតង៖ ការចាប់យកការបំពេញបន្ថែម ឬការញែកយកកាបូន

ពណ៌លឿង៖ ប្រភពថាមពលស្អាត

និតិវិធី៖

១. បិទក្រដាសតូចៗដែលមានបួនពណ៌ខុសគ្នាដែលមានអត្ថបទនៅជញ្ជាំង ឬនៅលើក្រដាសផ្ទាំងធំ។
២. ផ្តល់ឱ្យអ្នកចូលរួមនូវក្រដាសតូចៗដែលមានបួនពណ៌ខុសគ្នា និងប៊ិចសរសេរដើម្បីឱ្យពួកគេអាចសរសេរអំពីធាតុ ចូលរបស់ពួកគេសម្រាប់ប្រធានបទនីមួយៗ។ សុំឱ្យពួកគេគិត អំពីសកម្មភាពនានា ឬចំណុចដែលត្រូវការសម្រាប់សិក្សា ឬដាក់បញ្ចូល ដើម្បីជម្រុញការដាក់បញ្ចូលការគិតគូរអំពីយេនឌ័រទៅក្នុងប្រធានបទនីមួយៗ។
៣. ផ្តល់ពេលវេលាចំនួន១០នាទី ដើម្បីឱ្យអ្នកចូលរួមអាចសរសេរអំពីគំនិតរបស់ពួកគេ។ រំលឹកអ្នកចូលរួមក្នុងការកម្រិតធាតុចូលរបស់ពួកគេថាក្នុងមួយកាត/ក្រដាសតូចសរសេរបានតែគំនិតមួយតែប៉ុណ្ណោះ ហើយសរសេរក្នុងលក្ខណៈមួយដែលអ្នកគ្រប់គ្នាអាចអានបាន។
៤. សុំឱ្យអ្នកចូលរួមម្នាក់ចាប់ផ្តើមអាន ហើយធ្វើការបិទគំនិតរបស់ពួកគេនោះសម្រាប់ប្រធានបទដំបូង។ បន្ទាប់មកឱ្យអ្នកចូលរួមផ្សេងទៀតអាន ហើយស្នើឱ្យពួកគេបិទចម្លើយរបស់ពួកគេ។ ប្រសិនបើអ្នកចូលរួមមួយចំនួនមានគំនិតដូចគ្នានោះពួកគេនឹង "ផ្លាស់ប្តូរ"។ អនុញ្ញាតឱ្យមានការពិភាក្សានៅចុងក្រោយប្រសិនបើនៅខ្វះព័ត៌មាន។
៥. អនុវត្តន៍ដូចគ្នាសម្រាប់ប្រធានបីទៀតដែលនៅសល់។
៦. ចុងក្រោយ សុំឱ្យអ្នកចូលរួមធ្វើការប្តេជ្ញាចិត្តដោយខ្លួនឯងក្នុងការអនុវត្តនូវគំនិតមួយក្នុងចំណោមគំនិតនានានៅពេលដែលពួកគេត្រឡប់ទៅកន្លែងធ្វើការរបស់ពួកគេវិញ។ ចែកកាតប៉ុស្តាល់ដល់ពួកគេដើម្បីឱ្យពួកគេគ្រប់គ្នាសរសេរអំពីការប្តេជ្ញាចិត្តរបស់ខ្លួន ពួកគេត្រូវសរសេរឈ្មោះ និងអាស័យដ្ឋាន។ ប្រាប់ពួកគេថាអ្នកនឹងទទួលបាននូវកាតក្នុងរយៈពេលបីខែជាការរំលឹក។ អនុញ្ញាតឱ្យអ្នកចូលរួមចែករំលែកការប្តេជ្ញាចិត្តរបស់ពួកគេដល់អ្នកផ្សេងទៀតបាន ប្រសិនបើមានអ្នកណាម្នាក់ចង់ចែករំលែក។

# ជំពូក ៦

# យុទ្ធសាស្ត្រនៃការយល់ដឹងពីយេនឌ័រទៅលើការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យាដើម្បីគាំទ្រដល់សកម្មភាពនៃការកាត់បន្ថយគ្រោះមហន្តរាយ និងភាពបន្សុំា

បច្ចេកវិទ្យា គឺជាដំណោះស្រាយមួយផ្នែកដ៏ល្អបំផុតប៉ុន្តែវាក៏អាចជាផ្នែកមួយនៃបញ្ហា។ ដើម្បីគាំទ្រទៅដល់គោលបំណងនៃការកាត់បន្ថយគ្រោះមហន្តរាយ និងការបន្សុំាខ្លួនទៅនឹងការការប្រែប្រួលអាកាសធាតុបច្ចេកវិទ្យាត្រូវតែចាក់ឫសគល់ទៅក្នុងសកម្មភាពដែលមានវិសាលភាពធំទូលាយដែលទាក់ទងទៅនឹងការកសាងសមត្ថភាពដល់អ្នកប្រើប្រាស់បច្ចេកវិទ្យា និងអ្នកសម្រេចចិត្តក្នុងការបង្កើតស្ថាប័នបរិស្ថាន។ តម្រូវការខាងបច្ចេកវិទ្យារបស់ស្ត្រីក៏ជាបញ្ហាមួយដ៏សំខាន់ ដូច្នេះបច្ចេកវិទ្យាគួរតែត្រូវបានបង្កើតឡើងឱ្យស្របទៅនឹងតម្រូវការរបស់ស្ត្រីផងដែរ។



## *សារសំខាន់ៗ*

- ការវិភាគយេនឌ័រគឺជាសមាសភាពដ៏ចាំបាច់មួយក្នុងគោលនយោបាយបច្ចេកវិទ្យាសម្រាប់ឆ្លើយតមទៅនឹងការប្រែប្រួលអាកាសធាតុ
- ស្ត្រីគួរតែមានវត្តមាននៅក្នុងជួរថ្នាក់ដឹកនាំក្នុងការធ្វើសេចក្តីសម្រេច នៅក្នុងការដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុ
- យន្តការក្នុងការផ្តល់ជំនួយខាងបច្ចេកវិទ្យាដើម្បីឆ្លើយតបនូវការប្រែប្រួលអាកាសធាតុត្រូវតែមានកិច្ចខិតខំប្រឹងប្រែងជាពិសេស ដើម្បីជំរុញដល់ការអភិវឌ្ឍនៃបច្ចេកទេសដែលឆ្លើយតបនឹងយល់ដឹងអំពីយេនឌ័រ
- រាល់ទិដ្ឋភាពនៃការអន្តរាគមន៍ខាងផ្នែកបច្ចេកវិទ្យាដែលរួមមានតម្រូវការព័ត៌មានបរិយាកាសអំណោយផលការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាត្រូវតែមានសមាសភាពយេនឌ័រដែលនឹងមានឥទ្ធិពលទៅលើលទ្ធផលចុងក្រោយ
- ទាំងបច្ចេកវិទ្យាសម្រាប់កាត់បន្ថយគ្រោះមហន្តរាយ និងបច្ចេកវិទ្យាសម្រាប់បន្សុំាខ្លួននឹងមានឥទ្ធិពលខុសប្លែកពីគ្នាទៅលើស្ត្រីនិងបុរសទាំងនេះ គឺជាកត្តាដ៏ចាំបាច់សម្រាប់អ្នករៀបចំនិងបង្កើតនូវបច្ចេកវិទ្យាក្នុងការកត់សំគាល់នូវបញ្ហានេះផងដែរ។

## ៦.១ តើបច្ចេកវិទ្យាមានន័យដូចម្តេច?

ក្នុងអំឡុងសតវត្សទី២០ពាក្យថាបច្ចេកវិទ្យាបានវិវឌ្ឍន៍ពីអត្ថន័យធម្មតាដែលមានន័យថាជាឧបករណ៍ឬម៉ាស៊ីនទៅជាគោលគំនិតមួយដែលធំទូលាយជាងនេះដែលរួមបញ្ចូលនូវបរិបទចំណេះដឹង ដំណើរការសកម្មភាព និងវប្បធម៌សង្គម។ បើទោះបីជាពាក្យថាបច្ចេកវិទ្យានៅតែបន្តធ្វើឱ្យនឹកឃើញទៅដល់សញ្ញាណនៃឧបករណ៍ និងម៉ាស៊ីនយ៉ាងណាក្តីក៏បច្ចេកវិទ្យានៅតែត្រូវបានគេយល់ថា ជាមូលដ្ឋានគ្រឹះនៃជីវិតប្រចាំថ្ងៃព្រមទាំងបានផ្សាភ្ជាប់ទៅនឹងទិដ្ឋភាពភាគច្រើននៃជីវិតរបស់ស្ត្រីនិងបុរស។ ឧទាហរណ៍កំណើនជាសកលក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការទំនាក់ទំនងព័ត៌មានរួមទាំងទូរស័ព្ទចល័តបានផ្លាស់ប្តូរការប្រាស្រ័យទាក់ទងរបស់មនុស្សជាងពីរទសវត្សរ៍មកហើយ។

បច្ចេកវិទ្យា ពុំមានអព្យាក្រិតភាពយេនឌ័រនៅឡើយ។ ស្ត្រី និងបុរសមានឥរិយាបថនិងទំនាក់ទំនងខុសៗគ្នាទៅលើបច្ចេកវិទ្យា។ បច្ចេកវិទ្យាក្នុងបរិបទប្រពៃណីដែលសង្កត់ធ្ងន់លើឧបករណ៍ និងម៉ាស៊ីនត្រូវបានគេចាត់ទុកថាជាការត្រួតត្រារបស់បុរស ហើយទើបតែបច្ចុប្បន្ននេះទេដែលក្មេងស្រី និងស្ត្រីត្រូវបានលើកទឹកចិត្តឱ្យសិក្សាផ្នែកគណិតវិទ្យា និងវិស្វកម្ម។

បើទោះបីជាពួកគេមានភាពប្រសព្វ និងសមត្ថភាពក្នុងការច្នៃប្រឌិតនូវវត្ថុដែលពួកគេមាននៅក្នុងដៃយ៉ាងណាក៏ដោយក៏ស្ត្រីនៅតំបន់ជាច្រើនក្នុងពិភពលោកនៅតែពុំទាន់មានការចេញមុខ ក្នុងការបង្កើតជាផ្លូវការនូវបច្ចេកវិទ្យាថ្មីៗនៅឡើយ។ តម្រូវការជាក់លាក់របស់ស្ត្រីនៅក្នុងការអភិវឌ្ឍបច្ចេកវិទ្យា ការទទួលបាននូវព័ត៌មានបច្ចេកទេសឧបករណ៍ និងម៉ាស៊ីនគឺមានភាពខុសគ្នាពីបុរស។ កត្តាទាំងអស់នេះហើយដែលជះឥទ្ធិពលដល់របៀបដែលពួកគេទទួលនិងប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ។

**តារាងទី១៖ បច្ចេកវិទ្យាពុំមានអព្យាក្រិតភាពយេនឌ័រឡើយ**

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ការទទួលបាននូវបច្ចេកវិទ្យាសម្រាប់ទំនាក់ទំនងនិងទទួលព័ត៌មានរបស់ក្មេងស្រីនិងស្ត្រីជួបនឹងបញ្ហាប្រឈមជាច្រើនដូចជា៖

- ភាពលំអៀងនៃសង្គមនិងវប្បធម៌
- កង្វះខាតហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យានៅតាមតំបន់ជនបទ
- កម្រិតអប់រំទាបរបស់ស្ត្រី (ជាពិសេសផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា) និងភាពភ័យខ្លាច ឬពុំមានចំណាប់អារម្មណ៍លើបច្ចេកវិទ្យា
- ពុំមានចំនូលគ្រប់គ្រាន់សម្រាប់ទិញសេវាកម្មបច្ចេកវិទ្យា

*ប្រភព៖ ធនាគារពិភពលោកឆ្នាំ២០០៤*

កត្តាវប្បធម៌ក៏សំខាន់ផងដែរ។ ឧទាហរណ៍នៅក្នុងសហគមន៍ជនបទខ្លះអាងស្តុកទឹកត្រូវបានគ្រប់គ្រងដោយបុរស (ដោយការព្រួយបារម្ភណ៍ជាចម្បងរបស់ពួកគេគឺការផ្តល់ទឹកសម្រាប់សត្វចិញ្ចឹមដែលជាប្រភពចំនូលរបស់ពួកគេ)។ អាងស្តុកទឹកទាំងនោះពុំមានវ៉ានបិទបើកទឹកសម្រាប់ឱ្យស្ត្រីអាចបង្ហូរទឹកចេញបានឡើយ ដូច្នេះជាលទ្ធផលស្ត្រីត្រូវបានបង្ខំចិត្តទៅប្រមូលទឹកពីបំពង់ទឹកសម្រាប់សត្វផឹក។

## ៦.២ តើបច្ចេកវិទ្យាមានទំនាក់ទំនងអ្វីខ្លះជាមួយនឹងការប្រែប្រួលអាកាសធាតុ ?

គម្រោងការនៃអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការការប្រែប្រួលអាកាសធាតុ (UNFCCC) បានដាក់បច្ចេកវិទ្យាស្អាត ជាចំណុចកណ្តាលនៃទំនួលខុសត្រូវជាសកលលើការប្រែប្រួលអាកាសធាតុ។ បច្ចេកវិទ្យាស្អាតនឹងជួយក្នុងការប៉ាន់ប្រមាណការត្រួតពិនិត្យ និងគ្រប់គ្រងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលបណ្តាលមកពីធម្មជាតិនិងមនុស្ស ប៉ុន្តែដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ បច្ចេកវិទ្យាទាំងនេះត្រូវតែមានភាពយល់ដឹងអំពីយេនឌ័រ ទាំងគោលគំនិត និងការប្រើប្រាស់។ ក្នុងបរិបទនៃការប្តេជ្ញារបស់អង្គការសហប្រជាជាតិ (UN) ក្នុងការបញ្ជ្រាបយេនឌ័រកិច្ចខិតខំប្រឹងប្រែងជាបន្តត្រូវតែធ្វើឱ្យប្រាកដថាការយល់ដឹងពីយេនឌ័រត្រូវបានបញ្ចូលក្នុងការអភិវឌ្ឍការផ្ទេរ និងការប្រើប្រាស់នៃបច្ចេកវិទ្យាក្នុងការប្រែប្រួលអាកាសធាតុ។

យន្តការ និងគម្រោងការងារមួយចំនួនរបស់ UN បានលើកឡើងពីបញ្ហាការប្រែប្រួលអាកាសធាតុ និងបច្ចេកវិទ្យា។ ឧទាហរណ៍មូលនិធិបរិស្ថានពិភពលោក (GEF) គឺជាយន្តការហិរញ្ញវត្ថុមួយរបស់ UNFCCC ដែលបានផ្តល់និងចំណាយទឹកប្រាក់ប្រមាណ២៥០លានដុល្លារក្នុងមួយឆ្នាំដល់គម្រោងប្រសិទ្ធភាពថាមពលការប្រើប្រាស់ថាមពលសារជាថ្មី និងគមនាគមន៍

ដែលឋិតថេរ។ គម្រោងនេះគាំទ្រដល់ការកាត់បន្ថយនូវការខូចខាតដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ តាមរយៈការកាត់បន្ថយគ្រោះថ្នាក់ ឬផលប៉ះពាល់ជាអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។ GEF ក៏បានផ្តល់នូវឱកាសសម្រាប់កម្មវិធីតូចមួយដែលរួមមានសមភាពយេនឌ័រដែលជាផ្នែកថ្មីមួយ ប៉ុន្តែនេះពុំទាន់ត្រូវបានយកចិត្តទុកដាក់ប៉ុន្មានទេ។ មកទល់បច្ចុប្បន្ន GEF បានមើលរំលងនូវកម្រិតនៃភាពខុសគ្នានៅក្នុងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើស្ត្រី និងបុរស។

នៅក្នុងការធ្វើសន្និសីទភាគីពាក់ព័ន្ធលើកទី៧នៅ Marrakesh ក្នុងឆ្នាំ២០០១ UNFCCC បានទទួលយកនូវគម្រោងការងារបច្ចេកវិទ្យានិងបង្កើតឱ្យមានក្រុមអ្នកជំនាញមួយសម្រាប់ការផ្ទេរបច្ចេកវិទ្យា។ ក្រុមអ្នកជំនាញនេះមានទំនួលខុសត្រូវក្នុងការធ្វើឱ្យមានការអភិវឌ្ឍនិងការផ្ទេរនូវសកម្មភាពបច្ចេកវិទ្យា។ ក្រុមនេះបានតាមដានលើការអភិវឌ្ឍ ការត្រៀមខ្លួន ការទទួលយក ការសាយភាយនិងការផ្ទេរបច្ចេកវិទ្យាសម្រាប់ការពារបរិស្ថានទៅដល់ប្រទេសកំពុងអភិវឌ្ឍដោយគិតគូរទៅដល់ភាពខុសគ្នាក្នុងការបញ្ចូល និងអនុវត្តបច្ចេកវិទ្យាសម្រាប់កាត់បន្ថយមហន្តរាយនិងការបន្សាំខ្លួន។

យន្តការអភិវឌ្ឍស្អាត (CDM) ដែលជាលទ្ធផលពី Kyoto Protocol អនុញ្ញាតឱ្យប្រទេសឧស្សាហកម្មវិនិយោគក្នុងគម្រោងកាត់បន្ថយការសាយភាយឧស្ម័នពុលទៅក្នុងបរិយាកាសនៅប្រទេសកំពុងអភិវឌ្ឍ ជំនួសឱ្យការកាត់បន្ថយដែលមានតម្លៃខ្ពស់ក្នុងប្រទេសពួកគេ។ យន្តការអភិវឌ្ឍស្អាតបានផ្តល់ជំនួយសម្រាប់សកម្មភាពខ្នាតតូច និងសក្តានុពលសម្រាប់ការផ្ទេរបច្ចេកវិទ្យាមួយចំនួនដល់ស្ត្រីនៅប្រទេសភាគខាងត្បូង។ វាបានផ្តល់នូវឱកាសក៏ល្អមួយដើម្បីស្គាល់ និងទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាខ្នាតតូចដែលស្ត្រីកំពុងតែប្រើប្រាស់ដូចជាការប្រើប្រាស់ថាមពលក្នុងផ្ទះការកែច្នៃម្ហូបអាហារនិងកសិកម្មការគ្រប់គ្រងព្រៃឈើការបូមទឹក -ល- នៅតំបន់ជនបទព្រមទាំងគ្រឿងប្រើប្រាស់អគ្គិសនីក្នុងផ្ទះ និងឧបករណ៍កែច្នៃផ្សេងៗនៅតាមទីក្រុង( Wamuknoja and Skrutch, 2001 )។

លើសពីនេះទៅទៀតវាពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការផ្តោតការយកចិត្តទុកដាក់ទៅលើការសិក្សាដ៏ច្រើនរាប់មិនអស់ដែលបានបង្ហាញពីការពិតដែលមិនអាចប្រកែកបានថា ការបញ្ចូលសមភាពរបស់ស្ត្រី និងបុរសទៅគ្រប់ផ្នែកនៃគម្រោងការប្រែប្រួលអាកាសធាតុនឹងទទួលបាននូវជោគជ័យខ្ពស់។ ឧទាហរណ៍ ធនាគារពិភពលោកបានធ្វើការពិនិត្យឡើងវិញនូវគម្រោងផ្គត់ផ្គង់ទឹកនៅតាមជនបទចំនួន១២១គម្រោង ហើយបានរកឃើញថា ចំនួនវត្តមានរបស់ស្ត្រីពិតជាមានឥទ្ធិពលលើប្រសិទ្ធភាពនៃគម្រោងមែន។ ម្យ៉ាងទៀតក៏មានការរកឃើញផងដែរថាការមិនយកចិត្តទុកដាក់ទៅលើភាពខុសគ្នា និងវិសមភាព យេនឌ័រអាចធ្វើឱ្យគម្រោងទទួលបរាជ័យ( Narayan, 1995 )។

យោងតាមព័ត៌មាននៅគេហទំព័ររបស់ខ្លួន យន្តការអភិវឌ្ឍស្អាត ដូចជាពុំមានការគិតគូរណាមួយទៅដល់លក្ខណៈយេនឌ័រនៃបច្ចេកវិទ្យា។ស្ត្រីគឺពុំសូវមានតួនាទីក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីបច្ចេកវិទ្យាដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនោះទេ។ នៅចុងឆ្នាំ២០០៨ ក្នុងចំណោមសមាជិក១៩នាក់នៃក្រុមជំនាញលើការផ្ទេរបច្ចេកវិទ្យារបស់ UNFCCC មានស្ត្រីតែ២នាក់ប៉ុណ្ណោះហើយនៅក្នុងជួរថ្នាក់ដឹងនាំរបស់យន្តការអភិវឌ្ឍស្អាត ក្នុងចំណោមសមាជិក១០នាក់មានបុរសចំនួន៩នាក់ទៅហើយ។ នៅខណៈពេលដែលវត្តមានរបស់ស្ត្រីនៅក្នុងជួរថ្នាក់ដឹកនាំនិងគណៈកម្មាការនៃបច្ចេកវិទ្យា សម្រាប់ការប្រែប្រួលអាកាសធាតុមិនអាចសម្រេចដោយខ្លួនឯងក្នុងការផ្តោតលើសមភាពយេនឌ័រ វាគឺជាចំណុចចាប់ផ្តើមដ៏ចាំបាច់មួយ។ នៅពេលដែលមានស្ត្រីត្រឹមតែពីរ ឬបីនាក់នៅក្នុងជួរដឹកនាំពួកគេទំនងជាមិនអាចជំរុញឱ្យមានការលើកឡើងនូវបញ្ហាសមភាពយេនឌ័របានឡើយ ដោយខ្លាចថាវានឹងមានការគាំទ្រតិចតួចប៉ុន្តែនៅពេលដែលមានការកើនឡើងទៅដល់ ៣០% ឬក៏លើសពីនេះបញ្ហាទាំងនោះនឹងត្រូវបានលើកឡើង។

ទោះជាយ៉ាងណាក៏ដោយគួរតែមានការចាប់អារម្មណ៍ផងដែរថា មិនមែនគ្រប់ស្ត្រីទាំងអស់សុទ្ធតែមានការយល់ដឹងពីបញ្ហាសមភាពយេនឌ័រនោះទេ ដូច្នេះគួរតែមានការខំប្រឹងប្រែងដាក់បញ្ចូលស្ត្រីជាសមាជិកក្នុងតួនាទីធ្វើសេចក្តីសម្រេចដែលអាចដោះស្រាយបញ្ហាវិសមភាពយេនឌ័រ និងតំណាងឱ្យមាននិន្នាការខិតខំបង្កើនភាពអង់អាចដល់ស្ត្រី។

## ៦.៣ តើបច្ចេកវិទ្យាសម្រាប់ការប្រែប្រួលអាកាសធាតុមានទំនាក់ទំនងអ្វីនឹងយេនឌ័រ?

ដោយសារតែបច្ចេកវិទ្យាពុំមានអព្យាក្រិតភាពយេនឌ័រ យុទ្ធសាស្ត្រផ្អែកលើបច្ចេកវិទ្យាសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ និងបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុជួនកាលផ្តល់នូវផលវិបាកសម្រាប់ស្ត្រី និងបុរស។ ភាពខុសគ្នាទាំងនេះត្រូវតែកត់សំគាល់និងការដាក់បញ្ចូលទៅក្នុងការគិតពិចារណារបស់យើងពីការប្រែប្រួលអាកាសធាតុ។ ប្រសិនបើបច្ចេកវិទ្យានឹងត្រូវបានប្រើប្រាស់ដោយស្ត្រី និងបុរសទាំងនេះគួរត្រូវតែបង្កើតឡើងដើម្បីឆ្លុះបញ្ចាំងពីគ្រប់លក្ខខ័ណ្ឌ និងចំណង់ចំណូល ចិត្តរបស់គេទទាំងពីរ។ នេះគឺជាការពិតដែលនៅក្នុងករណីបច្ចេកវិទ្យា មានគោលបំណងជួយទៅលើការងារដែលជាញឹកញាប់ធ្វើឡើងដោយស្ត្រី។ នៅពេលដែលការចូលរួមរបស់ស្ត្រី នៅក្នុងការធ្វើសេចក្តីសម្រេចអំពីបច្ចេកវិទ្យាពុំធានាបាននូវការយល់ដឹងអំពីយេនឌ័រវាជាចំណុចមួយយ៉ាងសំខាន់ក្នុងការជំរុញឱ្យមានការបង្កើតបច្ចេកវិទ្យាដែលមានអត្ថប្រយោជន៍ និងផ្តល់ផលទាំងបុរសទាំងស្ត្រី។

មានឧទាហរណ៍ជាច្រើន ជាពិសេសនៅក្នុងវិស័យកសិកម្មដែលលើកឡើងពីបច្ចេកវិទ្យាដែលបង្កើតឡើងដើម្បីសំរាលបន្ទុកធ្ងន់ៗរបស់ស្ត្រីនៅតាមជនបទ ប៉ុន្តែបានអភិវឌ្ឍដោយគ្មានការចូលរួមរបស់ពួកគេ ហើយនៅទីបញ្ចប់គឺបរាជ័យក្នុងការទទួលយក។ បច្ចេកវិទ្យាត្រូវបានបង្កើតឡើងដោយពុំបានគិតគូរពីតម្រូវការជាក់លាក់របស់ស្ត្រីទេ ហើយការទទួលបានធនធានរបស់ពួកគេ ដូចជាមូលធនកម្លាំងពលកម្មពេលវេលា ឬសូម្បីតែសិទ្ធិក្នុងការធ្វើសេចក្តីសម្រេច គឺនៅមានកម្រិតនៅឡើយ។

## ៦.៤ តំបន់ដែលត្រូវយកចិត្តទុកដាក់សម្រាប់អន្តរាគមន៍នៃបច្ចេកវិទ្យា

មាត្រា៤.៥ របស់ UNFCCC បានថ្លែងថា៖

*បណ្តាលប្រទេសអភិវឌ្ឍជាដៃគូនិងក្រុមដៃគូអភិវឌ្ឍផ្សេងៗទៀតដែលមានក្នុងឧបសម្ព័ន្ធទី២ គួរតែធ្វើយុទ្ធនាការ*

**តារាងទី២៖ ឥទ្ធិពលនៃសិទ្ធិកាន់កាប់ដីទៅលើការទទួលយកបច្ចេកវិទ្យាថ្មីៗនៅសង្កាត់Kabaleប្រទេសយូហ្គានដា**

NGO Africare នៅក្នុងសង្កាត់ Kabale បានណែនាំឱ្យធ្វើការអនុវត្តការកាត់បន្ថយការអិលបាក់ដីនៅតំបន់ដែលមានជំរាលចោតដោយការធ្វើជំរាលជាថ្នាក់ៗហើយដាំដើមឈើតូចៗ ឬស្មៅដើម្បីទប់ដី ប៉ុន្តែស្ត្រីមានការស្ទាក់ស្ទើរក្នុងការទទួលយកបច្ចេកវិទ្យានេះ ដោយសារតែពួកគេគ្មានសិទ្ធិប្រើប្រាស់ដី។ បុរសមានសិទ្ធិប្រើប្រាស់ដី ប៉ុន្តែដោយសារតែបុរសពុំសូវមានវត្តមានក្នុងកសិដ្ឋានការងារ ក្នុងកសិដ្ឋានភាគច្រើនត្រូវបានដឹកនាំដោយស្ត្រី។ ទន្ទឹមនឹងនោះដែរ ក្នុងនាមជាស្ត្រីពួកគេពុំមានទំនោរក្នុងការទទួលយកបច្ចេកវិទ្យានេះឡើយ។ ជាលទ្ធផលអត្រានៃការទទួលយកមានកម្រិតទាប។មានបញ្ហាស្រដៀងគ្នានេះដែរទៅលើការដាំដើមឈើស្ត្រីមានការស្ទាក់ស្ទើរក្នុងការដាំឈើហូបផ្លែនៅលើដីដែលពួកគេគ្មានសិទ្ធិប្រើប្រាស់។

បញ្ហាទាំងនេះត្រូវបានដោះស្រាយតាមរយៈកិច្ចពិភាក្សារវាងក្រុមការងារគម្រោងនិងសហគមន៍ (ដែលមានទាំងស្វាមី ឬចាស់ទុំក្នុងភូមិនិងភរិយា) ដោយមានការពន្យល់ណែនាំពីគោលបំណងនៃការវិនិយោគទាំងនេះ និងអត្ថប្រយោជន៍ដែលគ្រួសារនីមួយៗនិងសហគមន៍ទទួលបាន។

*ប្រភព៖ ធនាគារពិភពលោកឆ្នាំ២០០៤*

*ដែលអាចធ្វើទៅបានទាំងអស់ដើម្បីជំរុញ សំរួល និងផ្តល់ហិរញ្ញវត្ថុដល់ការផ្ទេរនិងប្រើប្រាស់បច្ចេកវិទ្យាដែលជួយដល់បរិស្ថាន និងការបង្កើនចំណេះដឹងទៅដល់ដៃគូផ្សេងៗ ជាពិសេសដៃគូនៅប្រទេសកំពុងអភិវឌ្ឍដើម្បីឱ្យពួកគេអាចមានលទ្ធភាពក្នុងការអនុវត្តនូវអនុសញ្ញាដែលបានផ្តល់ឱ្យ។ នៅក្នុងដំណើរការនេះដែរ ដៃគូក្នុងប្រទេសអភិវឌ្ឍគួរតែគាំទ្រដល់ការអភិវឌ្ឍ និងធ្វើឱ្យមានភាពកាន់តែប្រសើរឡើងនូវសមត្ថភាព និងបច្ចេកវិទ្យារបស់ដៃគូនៅប្រទេសកំពុងអភិវឌ្ឍ។ ដៃគូនិងអង្គការផ្សេងៗដែលពាក់ព័ន្ធក្នុងដំណើរការនេះអាចជួយសំរបសំរួលដល់ការផ្ទេរនូវបច្ចេកវិទ្យានេះ។*

ក្នុងអំឡុងពេលសន្និសីទលើកទី៧នោះ ដៃគូទាំងអស់បានទទួលយកគម្រោងការងារដែលមានសកម្មភាពដ៏មានអត្ថន័យ និងប្រសិទ្ធភាពដើម្បីធ្វើឱ្យការអនុវត្តនៃមាត្រានេះកាន់តែប្រសើរឡើង។ មាត្រានេះត្រូវបានសំគាល់ដោយចំណុចទាំងប្រាំខាងក្រោមដែលចំណុចនីមួយៗអាចនឹងត្រូវបានអនុវត្តក្នុងទំរង់ភាពយល់ដឹងពីយេនឌ័រ។

## ៦.៤.១ តម្រូវការបច្ចេកវិទ្យានិងការប៉ាន់ប្រមាណតម្រូវការ

ការធ្វើការប៉ាន់ប្រមាណតម្រូវការបច្ចេកវិទ្យាគួរតែចាប់ផ្តើមពីការកត់សំគាល់ថាតម្រូវការបច្ចកវិទ្យារបស់ស្ត្រី និងបុរសគឺពុំដូចគ្នាឡើយ។ ឧទាហរណ៍នៅក្នុងវិស័យកសិកម្មមានតែការសង្កត់ធ្ងន់លើការអភិវឌ្ឍនូវវិធីទប់ស្កាត់នូវគ្រោះរាំងស្ងួតនិងទឹកជំនន់ដើម្បីបង្កើននូវសុវត្ថិភាពស្បៀងអាហារ។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងប្រទេសកំពុងអភិវឌ្ឍភាគច្រើនការកែច្នៃផលិតផលកសិកម្មគឺជាការងារមួយ ដែលចំណាយពេលវេលានិងកម្លាំងពលកម្មច្រើន ហើយការងារទាំងនោះភាគច្រើនគឺស្ត្រី។ វាគឺជារឿងដ៏ត្រឹមត្រូវមួយក្នុងការផ្តោតអារម្មណ៍ទៅលើចំណុច ដែលផ្តល់ភាពងាយស្រួលដល់ដំណើរការ និងការវិនិយោគក្នុងការអភិវឌ្ឍឧបករណ៍ដ៏ត្រឹមត្រូវមួយសម្រាប់ស្ត្រីដូចជា ឧបករណ៍បោកបែនស្រូវសាមញ្ញដើម្បីបន្ថែមលើការស្គាល់ពីបច្ចេកវិទ្យាដែលនឹងជួយបង្កើនទិន្នផលឱ្យកាន់តែច្រើន។ ការប៉ាន់ប្រមាណនូវតម្រូវការបច្ចេកវិទ្យាគួរតែគិតពិចារណាទៅដល់អ្នកប្រើប្រាស់ចុងក្រោយដែលភាគច្រើនជាកសិករស្រីដែលប្រឈមនឹងបញ្ហាពេលវេលាការទទួលប្រាក់ឥណទាននិងព័ត៌មាន ព្រមទាំងភាពក្រីក្រនិងភាពគ្មានដីស្រែ។

នៅក្នុងប្រទេសឧស្សាហកម្ម ការផ្តោតអារម្មណ៍លើការអភិវឌ្ឍយានយន្តដែលប្រើប្រាស់ប្រេងតិចមានការកើនឡើងជាលំដាប់។ នៅខណៈដែលស្ត្រីនិងបុរសអាចមានរថយន្តផ្ទាល់ខ្លួនជាពិសេសប្រទេសនៅភាគខាងជើងការគ្រប់គ្រងរថយន្តទាំងមូលគឺ មានភាពលំអៀងទៅខាងបុរសហើយស្ត្រីភាគច្រើនពឹងផ្អែកលើមធ្យោបាយធ្វើដំណើរសាធារណៈ។

**តារាងទី៣៖ ការបង្កើនភាពអង់អាចដល់ស្ត្រី៖ ជំរុញការផ្ទេរជំនាញតាមរយៈបច្ចេកវិទ្យាព័ត៌មានវិទ្យា និងទំនាក់ទំនង (ICT)**

ការជ្រើជ្រែងរបស់សហគមន៍ក្នុងការបណ្តុះបណ្តាលស្ត្រីពីជំនាញ ICT អាចផ្លាស់ប្តូរផ្នត់គំនិតផ្ទាល់ខ្លួនរបស់ស្ត្រីក៏ដូចជាផ្នត់គំនិតរបស់សហគមន៍ចំពោះស្ត្រីដែរ។ អ្វីដែលជាចំណុចសំខាន់នោះ គឺការផ្សព្វភ្ជាប់ជំនាញរបស់ស្ត្រីនៅក្នុងបច្ចេកវិទ្យាព័ត៌មានវិទ្យា និងទំនាក់ទំនងទៅនឹងតម្រូវការក្នុងសហគមន៍។ MS Swaminathan Research Foundation ដែលមានបទពិសោធន៍នៅក្នុងសាកលវិទ្យា Pondicherry និង Tilonia Barefoot ដែលបណ្តុះបណ្តាលស្ត្រីនិងបុរសដើម្បីប្រើប្រាស់ GIS សម្រាប់ការគ្រប់គ្រងទឹកបានបង្ហាញ ការពិតថាការបណ្តុះបណ្តាលដល់ស្ត្រីពី ICT មិនត្រឹមតែអាចឱ្យស្ត្រីដើរតួនាទីយ៉ាងសំខាន់ជាភ្នាក់ងារផ្លាស់ប្តូរនោះទេ ប៉ុន្តែថែមទាំងអាចជួយឱ្យបោះជំហានទៅក្នុងគន្លងនៃការបង្កើនភាពអង់អាចផ្ទាល់ខ្លួនបានទៀត។

*ប្រភព៖ Gurumurthy ឆ្នាំ២០05*

ប្រព័ន្ធដឹកជញ្ជូនដែលល្អសម្រាប់ស្ត្រី គួរបន្ថែមការផ្តោតអារម្មណ៍ទៅលើការបង្កើតតារាងពេលវេលាដែលបង្កភាពងាយស្រួលដល់តម្រូវការស្ត្រី ឬក៏អាចផ្តល់ជាការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ចដល់អ្នកប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនជាសាធារណៈ។ ស្រដៀងគ្នានេះដែរនៅបណ្តាប្រទេសឧស្សាហកម្ម ស្ត្រីជាធម្មតារកប្រាក់ចំណូលបានតិចជាងបុរសហើយការជ្រើសរើសបច្ចេកវិទ្យារបស់ពួកគេជារឿយៗជួបបញ្ហាប្រឈមទៅនឹងប្រាក់ចំណូលជាពិសេសស្ត្រីដែលជាមេគ្រួសារ។ ជាឧទាហរណ៍ស្ត្រីជួបការលំបាកក្នុងការចំណាយទៅលើការផ្លាស់ប្តូរប្រព័ន្ធកំដៅក្នុងផ្ទះទៅជាប្រព័ន្ធសំអាតផ្ទះ ដូច្នេះគួរតែមានការផ្តោតអារម្មណ៍ក្នុងការស្វែងរកការផ្លាស់ប្តូរដែលមានតម្លៃទាបដែលសមស្របសម្រាប់មេផ្ទះដែលមានប្រាក់ចំណូលទាប។

## ៦.៤.២ ព័ត៌មានអំពីបច្ចេកវិទ្យា

ប៉ុស្តិ៍ទូរទស្សន៍ដែលមានស្រាប់សម្រាប់ផ្សាយពីព័ត៌មានបច្ចេកទេសដូចជា ការផ្សព្វផ្សាយពីប្រព័ន្ធកសិកម្មជារឿយៗបានមើលរំលងស្ត្រី ដូច្នេះគួរតែមានកិច្ចខិតខំប្រឹងប្រែងជាពិសេសដើម្បីឱ្យការផ្សាយទាំងនោះបានទៅដល់ស្ត្រីផងដែរ។

សមាជិកក្នុងគ្រួសារដែលជាបុរសពុំដែលបានចែករំលែកពីព័ត៌មានអំពីបច្ចេកវិទ្យាដែលចាំបាច់ថ្មីៗជាមួយនឹងស្ត្រីឡើយ ជាពិសេសស្ត្រីដែលធ្វើការងារស្រែចំការដោយខ្លួនឯងផ្ទាល់ជាជាងធ្វើលើដីស្រែរបស់ស្វាមីខ្លួន។ ដូច្នេះវាគឺជាការចាំបាច់ណាស់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយកសិកម្ម ក្នុងការជួលបុគ្គលិកស្រីដែលអាចផ្តល់ព័ត៌មានដោយផ្ទាល់ដល់ស្ត្រី ជាជាងការរំពឹងទៅលើសមាជិកគ្រួសារជាបុរស។ យេនឌ័រគួរតែត្រូវបានបញ្ជ្រាបទៅក្នុងសេវាផ្សព្វផ្សាយកសិកម្មហើយគួរតែមានកិច្ចខិតខំប្រឹងប្រែងជាច្រើនក្នុងការបង្កើតនូវភាពយល់ដឹងអំពីយេនឌ័រ ព្រមទាំងបណ្តុះបណ្តាលក្រុមផ្សព្វផ្សាយដែលមានស្រាប់ និងថ្មីៗពីយេនឌ័រ និងការខ្វាយខ្វល់ពីបច្ចេកវិទ្យាថ្មីៗសម្រាប់ការប្រែប្រួលអាកាសធាតុ។

ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗជាពិសេសវិទ្យុ និងទូរទស្សន៍គួរតែត្រូវបានប្រើប្រាស់ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីបច្ចេកវិទ្យាទៅដល់ស្ត្រី។

## ៦.៤.៣ ការជួយដល់បរិស្ថានសម្រាប់ទទួលយកការផ្ទេរបច្ចេកវិទ្យា

ការជួយដល់បរិស្ថានសម្រាប់ទទួលយកការផ្ទេរបច្ចេកវិទ្យា ទាមទារឱ្យមានជំនាញបច្ចេកទេស ជំនួញ ការគ្រប់គ្រង និងច្បាប់។ វត្តមាននៃដៃគូទាំងអស់ដែលរួមមានវិស័យឯកជន ទីភ្នាក់ងារសាធារណៈ អង្គការក្រៅរដ្ឋាភិបាល គឺមានសារៈសំខាន់ណាស់សម្រាប់ការផ្ទេរបច្ចេកវិទ្យាដ៏មានប្រសិទ្ធភាព។ ស្ត្រីគួរតែមានវត្តមាននៅក្នុងដៃគូទាំងនេះ ហើយការបញ្ចេញមតិយោបល់របស់ពួកគេគួរតែត្រូវបានទទួលស្គាល់។ ក្នុងករណីខ្លះ វាគឺជាការចាំបាច់ណាស់ក្នុងការនិយាយជាមួយស្ត្រីដាច់ដោយឡែកដោយសារតែវាជារឿងដែលមិនសមរម្យទៅលើផ្នែកវប្បធម៌ចំពោះស្ត្រីក្នុងការនិយាយជាសាធារណៈនៅចំពោះមុខបុរស។

## ៦.៤.៤ ការកសាងសមត្ថភាពសម្រាប់ការផ្ទេរបច្ចេកវិទ្យា

ដូចគ្នានេះដែរការកសាងសមត្ថភាពសម្រាប់ការផ្ទេរបច្ចេកវិទ្យាត្រូវតែផ្តល់ឱកាសស្មើគ្នាសម្រាប់ស្ត្រី និងបុរសក្នុងទទួលបាននូវការបណ្តុះបណ្តាលព័ត៌មាន និងឱកាសចូលរួមក្នុងទស្សនកិច្ចសិក្សានិងទទួលបានការងារធ្វើ។ កិច្ចខិតខំប្រឹងប្រែងត្រូវតែធ្វើឡើងដើម្បីឱ្យប្រាកដថាស្ត្រីទទួលបានប្រាក់កម្ចី ការបណ្តុះបណ្តាល និងឱកាសកសាងជំនាញ។

### ៦.៤.៤ យន្តការសម្រាប់ការផ្ទេរបច្ចេកវិទ្យា

យន្តការនេះគួរតែបញ្ចូលនូវវិធីសាស្ត្រយល់ដឹងពីយេនឌ័រ និងរបបគំហើញថ្មីៗដែលបានអភិវឌ្ឍបន្ទាប់ពីមានការប្រឹក្សាយោបល់ជាមួយនឹងតំណាងនៃអ្នកប្រើប្រាស់ទាំងអស់ និងបន្ទាប់ពីការសុំទិន្នន័យពីអ្នកប្រើប្រាស់ដើម្បីបញ្ចូលទៅក្នុងផែនការ និងដំណើរការអាទិភាពទាំងអស់។

## ៦.៥ បច្ចេកវិទ្យាកាត់បន្ថយគ្រោះមហន្តរាយៈ ទិដ្ឋភាពយេនឌ័រ

គោលបំណងសំខាន់នៃយុទ្ធសាស្ត្រកាត់បន្ថយមហន្តរាយនៃការប្រែប្រួលអាកាសធាតុគឺការកាត់បន្ថយ និងលុបបំបាត់ការសាយភាយនូវឧស្ម័នផ្ទះកញ្ចក់។ ការសាយភាយឧស្ម័នកាបូនឌីអុកស៊ីតជាសកលពីចំហេះឥន្ធនៈគឺបណ្ដាលមកពីឧស្សាហកម្មអគារយានយន្តដឹកជញ្ជូន និងកសិកម្ម ហើយវិស័យជាយុទ្ធសាស្ត្រទាំងនេះត្រូវតែក្លាយទៅជាគោលដៅសម្រាប់កាត់បន្ថយការសាយភាយនូវឧស្ម័នផ្ទះកញ្ចក់។

ថាមពលគឺជាប្រភពដ៏សំខាន់មួយ ហើយថាមពលដែលអាចប្រើឡើងវិញបានត្រូវបានគេចាត់ទុកថាជាបច្ចេកវិទ្យាកាត់បន្ថយមហន្តរាយដ៏សំខាន់មួយ។ ការប្រើប្រាស់ជីវឥន្ធនៈមានការកើនឡើងបើទោះបីជាជីវឥន្ធនៈនេះត្រូវបានប្រើប្រាស់ដោយស្ត្រីសម្រាប់ជាប្រភពថាមពលមួយនៅក្នុងតំបន់ជាមួយនឹងធនធានពីព្រៃរបោះ។ ការដាំដំណាំសម្រាប់ជីវឥន្ធនៈមានការជាប់ទាក់ទងជាមួយនឹងស្ត្រីនៅក្នុងប្រទេសកំពុងអភិវឌ្ឍដោយសារតែមានការប្រជែងគ្នាក្នុងការរកជីវឥន្ធនៈ ដែលមានស្រាប់ មានការកើនឡើងខ្លាំងនិងដោយសារតែដីកសិកម្មដែលពីមុនប្រើប្រាស់សម្រាប់ដាំដុះផលិតកម្មចំណីអាហារ ត្រូវបានបំលែងទៅជាដីដាំដំណាំសម្រាប់ជីវឥន្ធនៈដូចជាពោតអំពៅជាដើម។ ការដាំដុះដំណាំសម្រាប់ទាញយកថាមពលប្រើប្រាស់ជាធម្មតា ត្រូវការបរិមាណទឹកច្រើនព្រមទាំងស្រូបយកធនធានទឹកក្នុងតំបន់ដែលកំពុងតែជួបការខ្វះខាត។ ជាលទ្ធផលស្ត្រីត្រូវតែចំណាយពេលវេលានិងកម្លាំងច្រើនជាងមុនដើម្បីប្រមូលទឹកសម្រាប់ប្រើប្រាស់ក្នុងផ្ទះ នៅខណៈពេលដែលពួកគេពុំបានទទួលផលប្រយោជន៍ពីដំណើរការដាំដុះដំណាំសម្រាប់ទាញយកថាមពលនេះសោះ (Rossi and Lambrou, 2008)។

ការសិក្សាមួយពីប្រទេសចំនួន១៩ ក្នុងទ្វីបអាហ្វ្រិកនិងអាស៊ីបានបង្ហាញថាជីវឥន្ធនៈដែលមានលក្ខណៈប្រពៃណីដូចជាអុសធ្យូង និងកាកសំណល់កសិកម្ម ជាទូទៅត្រូវបានគ្រប់គ្រងដោយស្ត្រី ហើយសរបញ្ជាក់ឱ្យឃើញពីអត្រាដ៏ខ្ពស់នៃការផ្គត់ផ្គង់ថាមពលពីធម្មជាតិ។ ឧទាហរណ៍ នៅក្នុងប្រទេសម៉ាលីអុសនិងធ្យូងត្រូវបានប្រើប្រាស់ជាចម្បងសម្រាប់ការដាំស្លដែលស្មើនឹង ៨០% នៃការប្រើប្រាស់ថាមពលក្នុងប្រទេសទាំងមូល ហើយស្ត្រីបានចំណាយពេលមួយភាគបីនៃពេលវេលាសរុបដែលពួកគេមានដើម្បីប្រមូលអុសទុកសម្រាប់ប្រើប្រាស់ (Karlsson, 2008)។ ដូច្នេះការរុករកនូវធនធានថាមពលជំនួសដ៏ត្រឹមត្រូវមិនត្រឹមតែមានសារៈប្រយោជន៍ដល់បរិស្ថាននោះទេ ថែមទាំងជាគន្លឹះមួយសម្រាប់សំរាលនូវបន្ទុកការងាររបស់ស្ត្រីទៀតផង។

ដំណោះស្រាយក្នុងការប្រើប្រាស់ថាមពលមួយចំនួនធំនៅសហគមន៍ដែលមានស្រាប់រួចមកហើយនោះ រួមមាន ចង្ក្រានដាំស្លជីវឧស្ម័នប្រព័ន្ធថាមពលព្រះអាទិត្យកម្រិតទាបនិងថាមពលដែលប្រើកម្លាំងទឹកនិងខ្យល់។ ដំណោះស្រាយទាំងនេះពុំទាន់ត្រូវបានផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅឡើយទេ ហើយតម្លៃសម្រាប់អនុវត្តនៅមានកម្រិតខ្ពស់សម្រាប់ជនក្រីក្រ។ តម្រូវការជាបន្ទាន់សម្រាប់ការងារជាបន្តទៅលើបច្ចេកវិទ្យាទាំងនេះត្រូវបានធ្វើឡើងដើម្បីឱ្យមានភាពងាយស្រួលសម្រាប់ស្ត្រី នៅតាមជនបទមានលទ្ធភាពក្នុងការទទួលយកនិងសំរបខ្លួនបាន។ ការអភិវឌ្ឍការប្រើប្រាស់ថាមពលមិនបាត់បង់ដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ គឺជាវង្វាស់វង្វាល់មួយសម្រាប់វាស់ភាពជឿនលឿននៃផ្នែកសង្គមសេដ្ឋកិច្ចរបស់ស្ត្រី (Makhabane, 2002)។

ការប្រើប្រាស់ធនធានទឹក គឺជាប្រធានបទមួយទៀត ដែលត្រូវការយុទ្ធសាស្ត្រកាត់បន្ថយមហន្តរាយតាមរយៈការយល់ដឹងពីយេនឌ័រ។ ដោយសារតែជាធម្មតាស្ត្រីនៅក្នុងប្រទេសកំពុងអភិវឌ្ឍមានទំនួលខុសត្រូវជាចម្បង ក្នុងការប្រមូលទឹកសម្រាប់ប្រើប្រាស់ក្នុងផ្ទះ ដូច្នេះបច្ចេកវិទ្យាដែលបង្កើតឡើងក្នុងគោលបំណងធ្វើឱ្យការប្រើប្រាស់ទឹកកាន់តែមានប្រសិទ្ធភាពគួរតែមានសមាសភាពយេនឌ័រក្នុងនោះដែរ។ ឧទាហរណ៍ ប្រសិនបើការបូមទឹក ឬប្រព័ន្ធធារាសាស្ត្រដែលមានប្រសិទ្ធភាពជាងមុន ត្រូវបានបង្កើតឡើងគឺវាគួរតែមានការពិចារណាថា តើស្ត្រីនៅតាមជនបទនឹងអាចទទួលបានដែរឬទេ។ ដោយសារតែស្ត្រីគឺជាអ្នកប្រើប្រាស់ធនធានធម្មជាតិដ៏សំខាន់មួយ ពួកគេគួរតែត្រូវបានជំរុញឱ្យមានការចូលរួមនៅក្នុងការស្តារតំបន់ដីសើមក្នុងគោលបំណងដើម្បីពង្រឹងគុណភាពទឹក និងកាត់បន្ថយគ្រោះថ្នាក់ពីទឹកជំនន់។ ស្រដៀងគ្នានេះដែរប្រការទាំងនេះគួរតែត្រូវបានធ្វើឡើងនៅក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រ កាត់បន្ថយការរអិលបាក់ដី។

ការដាំដើមឈើឡើងវិញ ត្រូវបានគេធ្វើការតស៊ូមតិក្នុងគោលបំណងដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ ចាប់តាំងពីឆ្នាំ១៩៧៧ គម្រោងមួយរបស់ប្រទេសកេនយ៉ា ដែលមានឈ្មោះថាការរំកិលខ្សែក្រវាត់បៃតង (Green Belt Movement) បានជំរុញឱ្យស្ត្រីក្រីក្រនៅតាមជនបទជាង ៣០.០០០នាក់ ចូលរួមក្នុងសកម្មភាពដាំដើមឈើឡើងវិញ ព្រមទាំងដាំដើមឈើបានជាង៣០លានដើម។ ស្ត្រីបានប្រើប្រាស់ដើមឈើទាំងនោះ ជាប្រភពនៃអុសសម្រាប់ដុតព្រមទាំងបានសិក្សាពីជំនាញដាំនិងថែរក្សាដើមឈើការកែច្នៃម្ហូបអាហារ និងការចិញ្ចឹមឃ្មុំយកទឹកហើយសកម្មភាពទាំងនេះបានក្លាយជាប្រភពចំណូលសម្រាប់គ្រួសារផងដែរ។

**តារាងទី៤៖ ផលិតកម្មនៃថាមពលមិនបាត់បង់ក្នុងតំបន់**

នៅប្រទេសហ្គាណា សេវាកម្មបច្ចេកវិទ្យាឧស្សាហកម្មត្រឹមត្រូវក្នុងតំបន់នៃប្រទេសហ្គាណា GRATIS បានជំរុញឱ្យមានផលិតកម្ម និងការប្រើប្រាស់ប្រេងល្ហុងខ្វងដើម្បីផលិតជាប្រេងម៉ាសូតនៅក្នុងសង្កាត់ Mamprusi ភាគខាងលិច។ ក្រុមស្ត្រីត្រូវបានលើកទឹកចិត្តឱ្យបង្កើតនិងគ្រប់គ្រង ការដាំល្ហុងខ្វង ការប្រមូលផលកែច្នៃគ្រាប់ និងផលិតជាប្រេងម៉ាសូតដែលអាចយកមកប្រើក្នុងម៉ាស៊ីនកែច្នៃប័រ ម៉ាស៊ីនកិនពោត និងក្នុងចង្កៀងបំភ្លឺតាមផ្ទះ (www.gratis-ghana.com)។ នៅប្រទេស Tanzania, ក្រុមហ៊ុនKAKUTE Ltd (Kampuni ya KusambazaTe-knolojia) បានគាំទ្រដល់ផលិតកម្មគ្រាប់ល្ហុងខ្វងសម្រាប់ជីវភាពស្ថិតស្ថេរ និងជីវសហគ្រាសនៅតាមជនបទ ។ KAKUTE បានបណ្តុះបណ្តាលប្រជាជនរាប់រយនាក់ក្នុងការដាំល្ហុងខ្វងជាដំណាំបន្ទាប់បន្សំលើដីដែលសេសសល់តិចតួច និងបានធ្វើការជាមួយក្រុមស្ត្រីតាមភូមិក្នុងការផលិតគ្រាប់និងកាត់ដើមសម្រាប់ដាំដុះ។ ប្រេងដែលបានចម្រាញ់ចេញពីគ្រាប់ត្រូវបានប្រើប្រាស់ក្នុងចង្កៀងបំភ្លឺ និងចង្ក្រានដាំស្លដែលផ្តល់ឱ្យដោយគម្រោង។

(www.jatropha.de/tanzania/Kakute/kakute.htm)

*ប្រភព៖ Karlsson ឆ្នាំ២០០៨*

នៅពេលដែលគម្រោងបច្ចេកវិទ្យាកាត់បន្ថយគ្រោះមហន្តរាយត្រូវបានបង្កើតចេញពីទស្សនៈសមភាពយេនឌ័រ គម្រោងទាំងនោះអាចបំពេញនូវគោលបំណងផ្សេងៗដូចជា ការកាត់បន្ថយគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងជួយសំរាលនូវបន្ទុកការងាររបស់ស្ត្រី ក្នុងការរកប្រាក់ចំណូល ។ល។ ការបង្កើតករណីសិក្សាដូចជាដំណោះស្រាយថាមពលកម្រិតសហគមន៍ដែលមិនប៉ះពាល់ដល់បរិស្ថាននិងផ្តល់នូវអត្ថប្រយោជន៍ដ៏មានប្រសិទ្ធភាពនិងសន្សំសំចៃសម្រាប់ស្ត្រី (និងបុរស) ត្រូវតែមានការអភិវឌ្ឍ ដ៏ចំបាច់មួយសម្រាប់វិធីសាស្ត្រ និងយុទ្ធសាស្ត្រផ្សព្វផ្សាយដែលលើកឡើងដោយជាក់លាក់ពី

ការចូលរួមរបស់ស្ត្រីក្នុងការប្រើប្រាស់ និងអត្ថប្រយោជន៍ដែលទទួលបាន។ វាគឺជារឿងដែលសំខាន់ផងដែរក្នុងការពង្រឹងសមត្ថភាពដល់កសិករដែលមានដីធ្លីតិចតួចដើម្បីឱ្យបានចូលរួមនៅក្នុងផលិតកម្មជីវឥន្ធនៈតាមរយៈការប្រើប្រាស់ដី មូលធន និងបច្ចេកវិទ្យាឱ្យបានល្អជាងមុន ឧទាហរណ៍ដូចជាតាមរយៈកិច្ចសហការណ៍គ្នា (Rossi and Lambrou, 2008)។

## ៦.៦ បច្ចេកវិទ្យាសម្រាប់ការបន្សាំខ្លួនៈ ទិដ្ឋភាពយេនឌ័រ

ការបន្សាំជាប់ពាក់ព័ន្ធទៅនឹងបន្ទុំសកម្មភាពកាត់បន្ថយភាពងាយរងគ្រោះក្នុងការប្រែប្រួលអាកាសធាតុ។ ស្ត្រីក្រីក្រនៅក្នុងសហគមន៍តាមជនបទត្រូវបានគេស្គាល់តាមរយៈការចិញ្ចឹមជីវិតរបស់ពួកគេដោយពឹងផ្អែកលើទឹកអុសក្នុងតំបន់និងដីកសិកម្ម។ វិធីបន្សាំភាគច្រើនទាក់ទងទៅនឹងទំរង់មួយចំនួននៃបច្ចេកវិទ្យាដែលរួមមានបច្ចេកវិទ្យាកម្រិតស្រាលដោយពឹងផ្អែកលើគម្រោងជានារ៉ាប់រងវិធីដាំដំណាំឆ្លាស់គ្នា ឬចំណេះដឹងតាមបែបប្រពៃណី។ វាអាចនឹងរួមបញ្ចូលផងដែរនូវបច្ចេកវិទ្យាកម្រិតធ្ងន់ដូចជា ប្រព័ន្ធធារាសាស្ត្រ ការច្នៃគ្រាប់ពូជដែលធននឹងភាពរាំងស្ងួត ឬទឹកប្រៃ ។ ឧទាហរណ៍ដូចជាប្រព័ន្ធផ្តល់ព័ត៌មានទុកជាមុនគឺជាធម្មតាពឹងផ្អែកលើការរួមបញ្ចូលគ្នារវាងទំរង់បច្ចេកវិទ្យាទាំងកម្រិតស្រាល និងកម្រិតធ្ងន់។

ដើម្បីឱ្យទទួលបាននូវប្រសិទ្ធភាពខ្ពស់ ការបន្សាំខ្លួននេះគួរតែបានទៅដល់អ្នកដែលត្រូវការវាបំផុតដូចជាប្រជាជនក្រីក្រ និងជនដែលងាយរងគ្រោះ។ ស្ត្រីត្រូវបានគេរកឃើញថាមានវត្តមានដ៏លើសលប់ក្នុងប្រភេទបច្ចេកវិទ្យាទាំងនេះ ដូចនេះការងារគោលដៅត្រូវតែធ្វើឱ្យប្រាកដថា ទី១ ៖ មានការយល់ដឹងពីស្ថានភាពខុសគ្នារវាងស្ត្រីនិងបុរស ទី២៖ បច្ចេកវិទ្យាទាំងនោះត្រូវតែបង្កើតឡើងឱ្យស្របទៅនឹងលក្ខខណ្ឌជីវភាពរបស់ពួកគេ ទី៣៖ ពួកគេមានឱកាសពេញលេញក្នុងការទទួលបាននូវចំណេះដឹងព័ត៌មាន និងបច្ចេកវិទ្យាដែលពាក់ព័ន្ធនឹងការបន្សាំ។

នៅក្នុងតំបន់កសិកម្មកិច្ចខិតខំប្រឹងប្រែងផ្សេងទៀត ត្រូវតែបង្កើតឡើងដើម្បីផលិតនូវប្រភេទគ្រាប់ពូជថ្មីៗដែលអាចធន់នឹងទឹកជំនន់ ភាពរាំងស្ងួត និងសារជាតិប្រៃ។ នៅប្រទេសភាគច្រើន ស្ត្រីគឺជាអ្នកទុកដាក់ និងរក្សានូវគ្រាប់ពូជ ដូច្នេះចំណេះដឹង និងជំនាញរបស់ពួកគេគួរតែត្រូវបានបញ្ចូលទៅក្នុងដំណើរការនៃការបង្កាត់គ្រាប់ពូជ។ ប្រទេសដែលងាយរងគ្រោះដោយទឹកជំនន់កំពុងតែផ្តោតអារម្មណ៍លើការអភិវឌ្ឍនៃប្រព័ន្ធឃ្លាំមើលសម្រាប់ធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធឱ្យដំណឹងជាមុនពីការមកដល់នៃខ្យល់ព្យុះ និងទឹកជំនន់។ ជាថ្មីម្តងទៀត វាគឺជាការចាំបាច់មួយក្នុងការស្ថាបនានូវប្រព័ន្ធនេះដើម្បីឱ្យជនក្រីក្របំផុតអាចទទួលដំណឹងទាន់ពេលវេលា និងអាចទទួលបានជំនួយក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រក្នុងការដោះស្រាយ។

នៅក្នុងប្រទេសឧស្សាហកម្មឥទ្ធិពលយេនឌ័រទៅលើបច្ចេកវិទ្យាសម្រាប់បន្សាំខ្លួន មានគម្លាតតិចតួចបំផុត ប៉ុន្តែក៏នៅតែមានកត្តាសំខាន់ៗជាច្រើនទៀតដែលត្រូវពិចារណាផងដែរ។ កត្តាទី១គឺស្ត្រីពុំមានតំណាងនៅក្នុងក្រុមធ្វើសេចក្តីសម្រេចអំពីការប្រែប្រួលអាកាសធាតុ។ ទី២ការប្រើប្រាស់បច្ចេកវិទ្យារបស់ពួកគេមានភាពខុសគ្នាពីបុរស។ ទី៣ឥរិយាបថរបស់ពួកគេចំពោះស្ថិរភាពបរិស្ថានមានភាពខុសគ្នាពីបុរស។ ឧទាហរណ៍ ថាមពលនុយក្លេអ៊ែរត្រូវបានគេឱ្យយោបល់ថាជាយុទ្ធសាស្ត្របន្សាំមួយក្នុងការកាត់បន្ថយការប្រើប្រាស់ប្រេងឥន្ធនៈ។ ការសិក្សាមួយនៅប្រទេសស៊ុយអែតនៅចុងទសវត្សរ៍ទី៩០បានរកឃើញថាបុរសវ័យក្មេងមានចំនូលចិត្តក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែររយៈពេលវែងជាងក្មេងស្រី។ ស្ត្រីបានប្រឆាំងនឹងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរនេះ ដោយបានលើកយកពីបញ្ហាសុវត្ថិភាពជាការព្រួយបារម្មណ៍ចម្បងរបស់ពួកគេ (Puranen, 2000, cited in Clancy et al., 2004)។ ផ្ទុយទៅវិញ បុរសទំនងជាពុំសូវបានខ្វាយខ្វល់ពីបញ្ហាកាកសំណល់នុយក្លេអ៊ែរ ដែលបានបញ្ចេញចោលនៅក្នុងសហគមន៍នោះទេ។ ចំណុចដែលគួរឱ្យចាប់អារម្មណ៍នោះគឺស្ត្រីដែលទទួលបានការអប់រំកាន់តែខ្ពស់ មានទំនោរកាន់តែខ្លាំងក្នុងការបដិសេធនូវការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ ក្នុងខណៈដែលបុរសមានទស្សនៈផ្ទុយគ្នាទៅវិញ។

ឥរិយាបថអវិជ្ជមានរបស់ស្ត្រីជនជាតិអឺរ៉ុប ចំពោះថាមពលនុយក្លេអ៊ែរនេះ ពីព្រោះដោយសារតែការទទួលរងនូវឥទ្ធិពលនៃគ្រោះមហន្តរាយ Chernobyl ឆ្នាំ១៩៨៦ ដែលនាំឱ្យមានភាពភ័យខ្លាចយ៉ាងខ្លាំងពីគ្រោះថ្នាក់នៃថាមពលនុយក្លេអ៊ែរមកលើបរិស្ថាននិងសុខភាព។ ស្រដៀងគ្នានេះដែរនៅសហរដ្ឋអាមេរិកការវិភាគរបស់ Culley and Angelique នៅឆ្នាំ២០០៣ ទៅលើឥទ្ធិពលនៃការរងគ្រោះថ្នាក់មកពីថាមពលនុយក្លេអ៊ែរនៅលើកោះទំហំបីម៉ាយ ទៅលើសកម្មជនស្ត្រីបានផ្តល់យោបល់ថាពួកគេត្រូវបានជំរុញឱ្យមានការប្រឆាំងក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ ដោយសារតែទស្សនៈអវិជ្ជមានចំពោះបញ្ហាសុខភាព និងសុវត្ថិភាពរបស់ពួកគេ។ បុរសទំនងជាមានការលើកទឹកចិត្តច្រើនក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ ដោយផ្អែកលើកត្តាចំណេញក្នុងវិស័យសេដ្ឋកិច្ច។ សរុបសេចក្តីមកវាបានបញ្ជាក់យ៉ាងច្បាស់ថាឥរិយាបថមានភាពខុសគ្នា ដូច្នេះវាគឺជារឿងចាំបាច់ខ្លាំងណាស់សម្រាប់រដ្ឋាភិបាលក្នុងការកត់សំគាល់នូវបញ្ហានេះនៅពេលដែលបង្កើត ឬឯកភាពឱ្យមានបច្ចេកវិទ្យាសម្រាប់ការប្រែប្រួលអាកាសធាតុដ៏សមស្របមួយ។

នៅភាគខាងជើង ការឡើងថ្លៃនៃថាមពលអាហារ ការដឹកជញ្ជូនការថែទាំសុខភាព-ល-បានជះឥទ្ធិពលខ្លាំងដល់ស្ត្រីជាពិសេសស្ត្រីក្នុងគ្រួសារដែលមានប្រាក់ចំណូលទាប។ វាគួរតែមានតម្រូវការមួយសម្រាប់ការសិក្សាស្រាវជ្រាវពីការយល់ដឹងផ្អែកយេនឌ័រទៅលើតម្រូវការប្រើប្រាស់ និងឥរិយាបថរបស់ស្ត្រី និងបុរស ប៉ុន្តែដោយសារតែស្ត្រីទាំងអស់ មានប្រាក់ចំណូលតិចវាអាចបញ្ជាក់បានថាបច្ចេកវិទ្យាសម្រាប់ការបន្ស៊ាំខ្លួនរបស់ពួកគេត្រូវតែមានប្រសិទ្ធភាពទាំងតម្លៃនិងការទទួលបាន។

ជាចុងបញ្ចប់នៅក្នុងប្រធានបទនៃយុទ្ធសាស្ត្របន្ស៊ាំ និងកាត់បន្ថយគ្រោះមហន្តរាយតម្រូវឱ្យមានការកត់សំគាល់ការកត់ត្រាទុកនិងឱ្យតម្លៃទៅលើចំណេះដឹងក្នុងតំបន់ព្រមទាំងរួមផ្សំវាជាមួយនឹងការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ។

ឧទាហរណ៍នៅប្រទេសភាគច្រើនក្នុងទ្វីបអាហ្វ្រិកអាស៊ី និងអាមេរិកឡាទីនស្ត្រីគឺជាអ្នកដែលរក្សាទុកនូវគ្រាប់ពូជដើម្បីប្រើប្រាស់ក្នុងពេលអនាគត។ ពួកគេមានចំណេះដឹងយ៉ាងជ្រាលជ្រៅពីជីវចម្រុះនៅមូលដ្ឋាននិងយុទ្ធសាស្ត្រពីដើមកំណើតសម្រាប់គ្រប់គ្រងគ្រាប់ពូជក្នុងអំឡុងពេលជួបគ្រោះរាំងស្ងួត ឬទឹកជំនន់។ ពួកគេក៏មានការយល់ដឹងខ្ពស់អំពីរុក្ខជាតិថ្នាំនិងការផ្សំថ្នាំពីរុក្ខជាតិផងដែរ។ ចំណេះដឹងទាំងនេះគួរត្រូវបានគេមើលឃើញថាជាមូលដ្ឋានគ្រឹះនៃដំណោះស្រាយសម្រាប់ការប្រែប្រួលអាកាសធាតុនិងត្រូវបានឱ្យតម្លៃដោយអ្នកវិទ្យាសាស្ត្រ និងអ្នករៀបចំគោលនយោបាយផងដែរ។

# ឯកសារស្រាវជ្រាវ


Karlsson, G. ( 2008 ). "Engaging women in small-scale production of biofuels for

rural energy". Presentation summary for Stockholm Environment Institute side event at WIREC: North-South-South Forum on Biofuels, Climate and Sustainable

Development. ENERGIA. Retrieved from the World Wide Web from: http://www.energia.org/pubs/papers/2008_karlsson_sei-wirec_pres-sum.pdf

Sathaye, J. ( 2002 ). Climate change mitigation: barriers, opportunities and

technology transfer. USA: Lawrence Berkeley National Laboratory, University of California. Retrieved from the World Wide Web from: http://72.14.205.104/search?q=cache:vODISqDFQJAJ:ies.lbl.gov/ppt/ccmbott.pdf+what+are+climate+change+mitigation+technologies&hl=en&ct=clnk&cd=9

UNFCCC. ( n.d. ). Fact sheet on technology. Retrieved from the World Wide Web from: http://unfccc.int/files/press/backgrounders/application/pdf/fact_sheet_

on_technology.pdfWamukonja, N. and Skrutch, M. ( 2001 ). "Is there a gender angle to the climatechange negotiations ?" Prepared for ENERGIA for distribution at CSD-9, New York. Retrieved from the World Wide Web from: http://www.energia.org/pubs/papers/wamukonya_skutsch.pd

# ករណីសិក្សា

## ករណីសិក្សាទី ១

## ការប្រែប្រួលអាកាសធាតុ និងសមភាពយេនឌ័រនៅប្រទេសចិន

គោលដៅមួយក្នុងចំណោមគោលដៅជាច្រើនរបស់គម្រោងកិច្ចសហប្រតិបត្តិការកាណាដាចិន លើការប្រែប្រួលអាកាសធាតុ (C5) (ផ្តល់ជំនួយដោយមូលនិធិអភិវឌ្ឍការប្រែប្រួលអាកាសធាតុកាណាដា CCCDF និងគ្រប់គ្រងដោយភ្នាក់ងារអភិវឌ្ឍអន្តរជាតិកាណាដា CIDA) គឺបង្កើននូវការឧបត្ថម្ភដល់ស្ត្រីដោយបង្កើនភាពអង់អាចដល់ពួកគេ ក្នុងការចូលរួមដោយស្មើភាពនៅក្នុងដំណើរការអភិវឌ្ឍ និងអនុវត្តកម្មវិធី និងគោលនយោបាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុតាមរយៈភ្នាក់ងាររដ្ឋាភិបាលចិន និងអង្គភាពស្រាវជ្រាវនានា។

គោលបំណងជាក់លាក់រួមមាន៖

- បង្កើនការយល់ដឹងពីវិសមភាពយេនឌ័រ និងគាំទ្រដល់ការចូលរួមយ៉ាងពេញលេញក្នុងការធ្វើសេចក្តីសម្រេច និងសកម្មភាពបច្ចេកទេសនានាដែលពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុ
- បង្កើនសមត្ថភាពក្នុងការវិភាគ បញ្ហាសមភាពយេនឌ័រដែលទាក់ទងនឹងគម្រោង និងដាក់បញ្ចូលលទ្ធផលនៃការវិភាគទៅក្នុងសកម្មភាពរបស់គម្រោង
- អភិវឌ្ឍនិងអនុវត្តគោលដៅដ៏ត្រឹមត្រូវសម្រាប់ការចូលរួមរបស់ស្ត្រី និងបុរសនៅក្នុងសកម្មភាពគម្រោងដោយពឹងផ្អែកលើគំរូស្រាវជ្រាវ បែងចែកតាមភេទដែលមានការរំពឹងទុកជាអប្បរមាត្រឹម៣០%នៃវត្តមានរបស់ស្ត្រី
- បង្កើនការយល់ដឹងសមត្ថភាពភាពជឿជាក់លើខ្លួនឯង និងការជំរុញទឹកចិត្តដល់ការងារស្ត្រីក្នុងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ។

CIDA ក៏បានផ្តល់មូលនិធិដល់គម្រោងសហប្រតិបត្តិការកាណាដា ចិន ក្នុងផលិតកម្មសំអាតផងដែរ ដែលបានកំណត់គោលដៅទៅលើការសាយភាយឧស្ម័នចេញពីរោងចក្រកិនផលិតក្រដាសផលិត ជី ចង់ផ្លាស់ស្ទិក និងផលិតស្រា។ គម្រោងនេះបង្កប់នូវសមាធាតុជាក់លាក់មួយដើម្បីបង្កើនវត្តមានស្ត្រីឱ្យក្លាយជាកម្មករអ្នកបច្ចេកទេស និងអ្នកគ្រប់គ្រង។ ស្ត្រីទទួលបានការបណ្តុះបណ្តាលក្នុងការអភិវឌ្ឍដំណើរការ ការអនុវត្តសវនកម្មតាមដានសម្ភារៈកុំព្យូទ័រ និងផ្នែកបច្ចេកទេសផ្សេងៗទៀតសម្រាប់ការងាររបស់ពួកគេ។ នៅក្នុងពេលជាមួយគ្នានោះដែរមេរៀនការយល់ដឹងពីសមភាពយេនឌ័រក៏បានចាប់ផ្តើមឡើងដើម្បីកែប្រែឥរិយាបថទាំងស្ត្រីនិងបុរស។ ស្ត្រីមិនត្រឹមតែបានអនុវត្តបច្ចេកទេសផលិតកម្មសំអាតថ្មីៗ ទៅក្នុងការងាររបស់គេប៉ុណ្ណោះទេពួកគេ ថែមទាំងបានផ្តើមគំនិតរបស់ពួកគេផ្ទាល់ក្នុងការជួយសំអាតបរិស្ថានទៀតផង។ គម្រោងនេះបានក្លាយជាកាតាលីករមួយ សម្រាប់ការបង្កើតនូវអង្គភាពថ្មីមួយទៀតគឺបណ្តាញបរិស្ថាន និងស្ត្រី(WEN)។

*ប្រភព៖ បានមកពី www.cccsu.org.cn*

## ករណីសិក្សាទី ២

# ភាពងាយរងគ្រោះរបស់ស្ត្រីនៅក្នុងសហគមន៍ជនបទនៅ គឺ មូស្សា (Keur Moussa)

សហគមន៍ជនបទគឺ ម៉ូសា (Keur Moussa) មានទីតាំងស្ថិតនៅចន្លោះ Dakar និង Thiès ដែលមានភូមិចំនួន៣៧ ដែលភាគច្រើននៅលើទំរជញ្ជាំង Ndiass។ Ndiass គឺជាខ្ពង់រាបមួយដែលមានកម្ពស់អតិបរមា១២០ម៉ែត្រ។ ត្រូវបានហ៊ុំព័ទ្ធជុំវិញដោយជួរភ្នំភូមិ ហើយអ្វីដែលនៅជុំវិញពួកគេស្ថិតក្នុងស្ថានភាពទឹកហូរច្រោះខ្លាំងដោយសារតែជំរាលដ៏ចោតជាច្រើន។ ការហូរច្រោះនៃទឹកគឺជាបញ្ហាយ៉ាងធ្ងន់ធ្ងរនៅទីនេះ ព្រមទាំងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើបរិស្ថាន (ការបំផ្លាញនូវធនធានផ្សេងៗ ធ្វើឱ្យដីមានជាតិអាស៊ីត ការហូរច្រោះនៃទឹកតាមជ្រលងភ្នំ) និងទៅលើសហគមន៍ (មានគ្រោះថ្នាក់ដល់ជីវិត ការលំបាក់ផ្ទះមិនអាចប្រើប្រាស់ធនធាននានា)។

ស្ត្រីមានការលំបាកខ្លាំងក្នុងការប្រើប្រាស់ទឹក ព្រមទាំងជួបបញ្ហាគ្រប់បែបយ៉ាងក្នុងផលិតកម្មកសិកម្ម។ ពួកគេមិនអាចដាំបន្លែខុសរដូវកាលបានឡើយ។ ដីមានជីជាតិដែលដាំដុះបានត្រូវបានបាត់បង់ ដោយសារតែការហូរច្រោះបំផ្លាញដីហើយដីដែលនៅសល់ គឺជាដីដែលគ្មានជីជាតិដោយសារតែផ្ទៃទឹកបានហូរច្រោះអស់។ ដូច្នេះទិន្នផលកសិកម្មមានការថយចុះហើយចំណូលក៏កាន់តែតិចទៅៗ។ ប្រជាជនវ័យក្មេងបានធ្វើចំណាកស្រុកដោយទុកឱ្យស្ត្រី និងចាស់ជរាចិញ្ចឹមជីវិតដោយខ្លួនឯង។ ជាឧទាហរណ៍នៅក្នុងភូមិឡានឌូមានចំនួនស្ត្រីប្រហែល១១៨នាក់ និងបុរសត្រឹមតែ២០នាក់ប៉ុណ្ណោះ។

ភាពចោទខ្លាំងនៃជំរាលភ្នំធ្វើឱ្យមានភាពលំបាកយ៉ាងខ្លាំងដល់ផ្ទៃទឹកក្នុងការជ្រាបចូលទៅក្នុងដីដើម្បីបំពេញជាតិទឹកក្នុងដី។ កត្តានេះធ្វើឱ្យបញ្ហាកង្វះទឹកកាន់តែយ៉ាប់យ៉ឺនឡើង ជាពិសេសនៅតំបន់ដែលមានអណ្តូងទឹករីងស្ងួតរយៈពេលពីរខែក្នុងរដូវរងារ។ តំបន់ខ្លះដែលស្ថិតនៅជុំវិញជួរភ្នំប្រភពទឹកក្រោមដីមានជំរៅទាបជាងនីវ៉ូទឹកសមុទ្រដល់ទៅ៣០ម៉ែត្រ ដូច្នេះធ្វើឱ្យមានការជ្រាបចូលនៃទឹកប្រៃនិងធ្វើឱ្យខូចនូវឧបករណ៍ប្រើប្រាស់ទឹកដូចជា ម៉ាស៊ីនខួងអណ្តូងជាដើម។

អង្គការមួយចំនួនបានជួយដល់ស្ត្រីក្នុងការគ្រប់គ្រងនូវការហូរច្រោះទាំងនេះក្នុងគោលបំណងរក្សាទឹក និងដីទុក និងជួយធ្វើឱ្យដីមានជីជាតិឡើងវិញ ដើម្បីទទួលបានទិន្នផលប្រសើរឡើង។ ពួកគេទទួលបាននូវបច្ចេកទេស និងចំណេះដឹងថ្មីៗក្នុងការប្រយុទ្ធប្រឆាំងទៅនឹងការបំផ្លាញដីដោយបង្កើនគុណភាពដីនិងអត្រាផលិតកម្មរបស់វា។

ភូមិចំនួន១៧ ក្នុងចំណោមភូមិ៣៧ ដែលបានផ្តុំគ្នាបង្កើតជាសហគមន៍មួយឈ្មោះគឺ ម៉ូសា Keur Moussa ទទួលការរងគ្រោះ ពីការហូរច្រោះ និងការបំផ្លាញដីដែលបណ្តាលឱ្យទិន្នផលកសិកម្មពុំគ្រប់គ្រាន់។ ភូមិបី (Santhie Sérère, Kessoukhatte and Landou) ត្រូវបានជ្រើសរើសជាភូមិគោលដៅក្នុងការគ្រប់គ្រងការហូរច្រោះនៅក្នុងគម្រោងការងារកម្មវិធី Agrobio Niayes ដែលឧបត្ថម្ភដោយ ENDA PRONAT។ គម្រោងនេះ ត្រូវបានចាប់ផ្តើមធ្វើឡើងដោយប្រជាជនក្នុងស្រុកនិងស្ត្រីជាពិសេសដោយធ្វើតាមការប្រឹក្សាយោបល់ពីបញ្ហានិងដំណោះស្រាយនៃការហូរច្រោះការបាត់បង់ដីមានជីជាតិការរលើងឫសនៃដំណាំ និងដើមឈើកង្វះខាតទឹកប្រើប្រាស់ និងភាពលំបាកចូលទៅដល់ភូមិ។ គណៈកម្មការជាច្រើនត្រូវបានបង្កើតឡើង ដោយផ្អែកលើភាពចាំបាច់។ គណៈកម្មការមួយក្នុងចំណោមគណៈកម្មការទាំងនោះ គឺគណៈកម្មការទប់ស្កាត់ការហូរច្រោះដែលមានស្ត្រីសកម្មបំផុត។

ដើម្បីគ្រប់គ្រងការហូរច្រោះនៃទឹក ពួកគេបានសាងសង់ជាទំនប់ និងបានដាំដើមឈើដើម្បីទប់។

ទំនប់ត្រូវបានសាងសង់នៅតាមជាយអាងស្តុកទឹកភ្លៀងដែលមានព្រំខ័ណ្ឌជាថ្មប្រទ្បាយរាងចំណិតលោកខែមែកឈើប្រទ្បាយភ្លោះសម្រាប់ស្តុកទឹក និងរណ្តៅចំហរដែលជួយបន្ថយល្បឿនទឹកហូរ និងការប្រមូលទឹកទៅកាន់កន្លែងស្តុកទុក។

ស្ត្រីមានការចាប់អារម្មណ៍យ៉ាងខ្លាំង ក្នុងការដោះស្រាយបញ្ហាការហូរច្រោះនេះ ពីព្រោះតែបញ្ហានេះមិនត្រឹមតែផ្តល់ផលប៉ះពាល់ទៅលើផលិតផលកសិកម្មប៉ុណ្ណោះទេ វាថែមទាំងធ្វើឱ្យមានភាពលំបាកក្នុងការទទួលបានទឹកស្អាតសម្រាប់បរិភោគទៀតផង។ ប្រសិនបើពួកគេត្រូវបានផ្តល់ឱ្យនូវជំរើសមួយសម្រាប់ជ្រើសរើស នោះពួកគេនឹងជ្រើសរើសយកនូវប្រភពទឹកបន្ថែមទៀត។ ពួកគេធ្វើការយ៉ាងសកម្មក្នុងការសាងសង់ទំនប់ថ្ម។ កិច្ចខិតខំប្រឹងប្រែងធ្វើការងាររបស់ពួកគេទទួលបានលទ្ធផលភ្លាមៗដូចជា ប្រភពទឹកក្រោមដីត្រូវបានដើរតួនាទីដើម្បីបំពេញប្រព័ន្ធទឹក និងត្រូវបានបង្កើតឡើងដើម្បីឱ្យដីដែលមានលំនឹងល្បឿនទឹកហូរមានសភាពសមស្របសម្រាប់ដំណាំដាំដុះដែលបង្កើតឡើងឱ្យមានលក្ខណៈចម្រុះ។

ប្រធានសហគមន៍បានរៀបរាប់ថា ឥឡូវនេះ យើងមានទឹកយ៉ាងច្រើននៅក្នុងអណ្តូងរបស់យើងហើយឆ្នាំនេះ ពួកយើងចំណាយពេលតិចតួចបំផុតក្នុងការដងទឹកដោយប្រើពេលត្រឹមតែ១ទៅ១:៣០ម៉ោងប៉ុណ្ណោះក្នុងការបំពេញអណ្តូងបើធៀបទៅនឹងឆ្នាំមុនយើងត្រូវប្រើពេល២ទៅ៣ម៉ោង។ យើងនឹងបន្តនូវយុទ្ធនាការប្រឆាំងការហូរច្រោះនេះដើម្បីទទួលបាននូវលទ្ធផលកាន់តែប្រសើរ។ ទិន្នផលកសិកម្មបានកើនឡើង ហើយស្ត្រីបានចាប់ផ្តើមដួញដូររុក្ខជាតិថ្នាំ និងដំណាំផ្សេងៗដែលពួកគេពុំធ្លាប់បានធ្វើជាយូរណាស់មកហើយ។

*ប្រភពបានមកពី៖*

*The Women's Environment and Development Organization (WEDO) with ABANTU for Development in Ghana, ActionAid Bangladesh and ENDA in Senegal. (2008). Gender, Climate Change and Human Security: Lessons from Bangladesh, Ghana and Senegal. Retrieved from the World Wide Web from:* http://www.wedo.org/files/HSN%20Study%20Final%20May%2020,%202008.pdf

## ករណីសិក្សាទី ៣

## ការផ្តល់ពន្លឺនៃក្តីសង្ឃឹមក្នុងសហគមន៍នៅប្រទេសនីការ៉ាហ្គា (Nicaraqua)

ក្រុមហ៊ុនសាជីវកម្មមួយ ដែលផលិតនិងលក់ផលិតផលប្រើថាមពលព្រះអាទិត្យដែលធ្វើឡើងពីបន្ទះស្រូបថាមពលព្រះអាទិត្យដែលសមស្របនឹងតម្រូវការក្នុងស្រុក។

"ការផ្តល់ពន្លឺនៃក្តីសង្ឃឹម និងសហគមន៍" បានឈ្នះពានរង្វាន់ SEED មួយក្នុងចំណោមពានប្រាំសម្រាប់ការងារគំរូរបស់ពួកគេក្នុងការបង្កើតមុខជំនួញលក់ផលិតផលប្រើប្រាស់ថាមពលកកើតឡើងវិញ។

Mujeres Solares de Totogalpa គឺជាក្រុមលើកទឹកចិត្តស្ត្រីមួយ ដែលប្តេជ្ញាចិត្តក្នុងការបង្កើនគុណភាពជីវិតរបស់ពួកគេ និងក្រុមគ្រួសាររបស់គេនៅតំបន់ជនបទភាគពាយព្យនៃប្រទេសនីការ៉ាហ្គា។ ដោយធ្វើកិច្ចសហការជាដៃគូជាមួយមជ្ឈមណ្ឌលស្រាវជ្រាវរបស់សាកលវិទ្យាល័យ NGO និងក្រុមអ្នកជំនាញលើបច្ចេកវិទ្យាថាមពលព្រះអាទិត្យពួកគេមានគោលបំណងក្នុងការបង្កើតនូវសហគ្រាសសាជីវកម្មមួយឈ្មោះថា " ការផ្តល់ពន្លឺនៃក្តីសង្ឃឹមនិងសហគមន៍ "ដើម្បីផលិតក្តារបំលែងថាមពលព្រះអាទិត្យដោយប្រើប្រាស់ឡើងវិញនូវបន្ទះស្រូបថាមពលព្រះអាទិត្យ ចង្ក្រាន និងម៉ាស៊ីនសម្ងួតប្រើថាមពលព្រះអាទិត្យ ផលិតផលចំអិន និងសម្ងួតអាហារ និងរុក្ខជាតិថ្នាំនានាដោយប្រើថាមពលព្រះអាទិត្យ។ ផលិតផលទាំងនេះនឹងត្រូវបានផលិត និងដាក់លក់នៅមជ្ឈមណ្ឌលថាមពលព្រះអាទិត្យថ្មីមួយនៅក្នុងសហគមន៍។

### ការបង្កើននូវឥទ្ធិពល

ក្នុងនាមផ្នែកមួយនៃពានរង្វាន់ SEED កំពុងតែគាំទ្រ"ការផ្តល់ពន្លឺនៃក្តីសង្ឃឹម និងសហគមន៍" ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់វាដើម្បីការរីកចំរើន។ នៅក្នុងរយៈពេល៥ឆ្នាំទៀតគម្រោងសង្ឃឹមថា មជ្ឈមណ្ឌលផលិតកម្មនឹងអាចដំណើរការបានដោយខ្លួនឯងទាំងស្រុង និងអាចពង្រីកខ្លួនជួយគាំទ្របន្តទៅដល់គម្រោងអភិវឌ្ឍសហគមន៍ដទៃទៀត។

គម្រោងក៏មានគោលបំណង ក្នុងការគាំទ្រទៅដល់ការផ្តល់ជំនួយក្នុងស្រុក រួមទាំងក្នុងតំបន់ក៏ដូចជា ក្នុងប្រទេស និងការខិតខំអប់រំដើម្បីពាំនាំយកមកនូវគំរូអភិវឌ្ឍថាមពលកកើតឡើងវិញនេះទៅកាន់សហគមន៍ដទៃទៀត។

សកម្មភាពដែលបានរៀបចំរួច រួមមាន៖

- ផ្តល់ហេដ្ឋារចនាសម្ព័ន្ធ និងជំនួយការសម្រាប់ផលិតកម្មនៃបច្ចេកវិទ្យាថាមពលថ្មីៗតាមរយៈការផ្លាស់ប្តូរគំនិតយោបល់ជាបន្តជាមួយសាកលវិទ្យាល័យអ្នកវិទ្យាសាស្ត្រសង្គមវិទូក៏ដូចជាអ្នកជំនាញស្ម័គ្រចិត្តជាតិនិងអន្តរជាតិនានា។
- ធ្វើការងារជាមួយនឹងសហគមន៍ជនបទក្នុងនាមជាដៃគូស្មើភាពដើម្បីអភិវឌ្ឍនូវយុទ្ធសាស្ត្រ ថាមពលជំនួសក្នុងគោលបំណងបំពេញតាមតម្រូវការ និងលក្ខខ័ណ្ឌក្នុងស្រុក។
- ដាក់ឱ្យដំណើរការនូវកិច្ចសហប្រតិបត្តិការមិនរកប្រាក់ចំណេញមួយដើម្បីផលិតនិងលក់ផលិតផលប្រើប្រាស់ថាមពលព្រះអាទិត្យ ដោយប្រើប្រាស់សមាជិកសហគមន៍ក្នុងស្រុកដែលមានឯកទេសខាងសាងសង់នូវក្តារបន្ទះស្រូបថាមពលព្រះអាទិត្យ ចង្ក្រាន និងម៉ាស៊ីនសម្ងួតប្រើថាមពលព្រះអាទិត្យ ព្រមទាំងរៀបចំនូវផលិតផលចំអិន និងសម្ងួតអាហារ និងរុក្ខជាតិថ្នាំនានាដោយប្រើថាមពលព្រះអាទិត្យ។
- ផ្តល់ឱ្យនូវវគ្គអប់រំអំពីបច្ចេកវិទ្យា ថាមពលព្រះអាទិត្យទៅដល់សហគមន៍ ព្រមទាំងបង្កើតវគ្គបណ្តុះបណ្តាលជាផ្លូវការមួយដើម្បីបង្កើននូវចំនួនអ្នកបច្ចេកទេសដែលមានជំនាញសម្រាប់ផ្គត់ផ្គង់នូវកំណើននៃតម្រូវការ។

### អំពី SEED Initiative

SEED Initiative មានតួនាទីកំណត់នូវទម្រង់ និងគាំទ្រសហគ្រាសដែលបង្កើតឡើងក្នុងស្រុកដ៏ជោគជ័យ និងកំពុងធ្វើការជាដៃគូ ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅក្នុងការដោះស្រាយបញ្ហាភាពក្រីក្រ ព្រមទាំងគ្រប់គ្រងនូវស្ថិរភាពធនធានធម្មជាតិនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។

SEED អភិវឌ្ឍឧបករណ៍សិក្សាសម្រាប់សហគមន៍នៃសហគ្រិនសង្គម និងបរិស្ថានក្នុងទំរង់ជាអ្នករៀបចំគោលនយោបាយ និងអ្នកធ្វើសេចក្ដីសម្រេចព្រមទាំងមានគោលបំណងក្នុងការបង្កើតនិន្នាការច្នៃប្រឌិតថ្មីៗដល់សហគ្រាសដើម្បីការអភិវឌ្ឍដ៏ឋិតថេរមួយ។

SEED គឺជាបណ្ដាញសកលមួយដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១២ ដោយ IUCN UNDP និង UNEP សម្រាប់បំរើឱ្យគោលដៅអភិវឌ្ឍសហស្សវត្សរ៍របស់អង្គការសហប្រជាជាតិ និងគណៈកម្មការដទៃទៀតដែលបានបង្កើតនៅក្នុងកិច្ចប្រជុំពិភពលោក Johannesburg ទៅលើការអភិវឌ្ឍប្រកបដោយចីរភាព។

ដៃគូក្នុងគម្រោង SEED Initiative រួមមានសហព័ន្ធអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ (IUCN) កម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ (UNDP) កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ (UNEP) ព្រមទាំងរដ្ឋាភិបាលរបស់ប្រទេសអាល្លឺម៉ង់ ហូឡង់ អាហ្វ្រិកខាងត្បូង អេស្ប៉ាញ ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក។

*ប្រភពបានមកពី៖*

*Seed Initiative. (2008). "2008 Seed Award Winners".*

*Retrieved from the World Wide Web from: http://www.seedinit.org/mainpages2/awards/2008/nicaragua.pdf?PHPSESID=41cb460d88d21b1d93854d92d76c81dc*

## តើបច្ចេកវិទ្យាមានអត្ថន័យយ៉ាងដូចម្ដេចចំពោះអ្នក ?





គោលបំណង ៖ ស្រាយបំភ្លឺថាបច្ចេកវិទ្យាពុំទាន់មានអព្យាក្រិតភាពយេនឌ័រនៅឡើយ ព្រមទាំងបំភ្លឺថាពល់អន្តរាគមន៍នៃបច្ចេកវិទ្យាត្រូវបានយល់ឃើញខុសៗគ្នាក្នុងការប្រើប្រាស់ និងចំណូលចិត្តផ្សេងៗគ្នាព្រមទាំងផ្ដល់ឥទ្ធិពលខុសៗគ្នាទៅលើស្ត្រី និងបុរស។

សម្ភារៈ ៖ ប៊ិច ហ្វឺត ស្កុត ក្រដាសផ្ទាំងធំ និងម្មុលខ្ទាស់

ដំណើរការ ៖

១. ពន្យល់ដោយសង្ខេបថា តើបច្ចេកវិទ្យាមានអត្ថន័យយ៉ាងដូចម្ដេចចំពោះអ្នក? ការពន្យល់នេះអាចសរសេរក្នុងក្រដាសរៀងៗខ្លួន ឬជាការនិយាយពិភាក្សាក្នុងក្រុម។

២. បន្ទាប់មកផ្ដល់ឱ្យពួកគេនូវអត្ថបទ "តំបន់ដែលត្រូវយកចិត្តទុកដាក់សម្រាប់អន្តរាគមន៍នៃបច្ចេកវិទ្យា" ចាប់ពីចំណុច៦.៤ នៃជំពូកនេះ ហើយឱ្យពួកគេអានរៀងៗខ្លួន។

៣. ចែកពួកគេជា២ក្រុម ១ក្រុមជាក្រុមស្រប និង១ក្រុមទៀតជាក្រុមប្រឆាំងសម្រាប់កិច្ចពិភាក្សាតទល់រយៈពេល១៥នាទីទៅលើប្រធានបទមួយគឺ “ទាំងបច្ចេកវិទ្យាសម្រាប់កាត់បន្ថយគ្រោះមហន្តរាយ និងបច្ចេកវិទ្យាសម្រាប់បន្សាំខ្លួននឹងផ្តល់នូវឥទ្ធិពលខុសគ្នាទៅដល់ស្ត្រី និងបុរស ហើយវាមានភាពចាំបាច់សម្រាប់អ្នករៀបចំផែនការ និងផលិតបច្ចេកវិទ្យាក្នុងការកត់សំគាល់ពីបញ្ហានេះ“ ។

៤. កត់ត្រាទុកនូវចំណុចសំខាន់ៗដែលបានលើកឡើងក្នុងពេលកំពុងដំណើរការកិច្ចពិភាក្សា

៥. ដោយយោងទៅតាមការកត់ត្រានេះរៀបចំនូវកថាខ័ណ្ឌដើម្បីបិទកិច្ចពិភាក្សានេះ។

# ២. ការវិភាគករណីសិក្សា



គោលបំណង ៖ ធ្វើការបញ្ជាក់ថាបច្ចេកវិទ្យាសម្រាប់បន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុមិនបានគិតគូរដល់បញ្ហាយេនឌ័រទេព្រមទាំងបង្ហាញថា កត្តានេះហើយដែលនាំឱ្យស្ត្រីពុំបានទទួលផលអ្វីសោះ ជាពិសេសស្ត្រីក្រីក្រ។

សម្ភារៈ ៖ ប៊ិច ហ្វឺត ស្កុត ក្រដាសផ្ទាំងធំ ម្ជុលខ្ទាស់ និងអត្ថបទករណីសិក្សា

ដំណើរការ ៖

១. បែកពួកគេជាក្រុមដើម្បីឆ្លើយនឹងសំនួរដែលទាក់ទងនឹងករណីសិក្សា “ភាពងាយរងគ្រោះរបស់ស្ត្រីនៅក្នុងសហគមន៍ជនបទនៅកី ម៉ូសា“ ៖

- តើបញ្ហាសង្គមអ្វីខ្លះដែលស្ត្រីប្រឈមមុខ ?
- តើស្ត្រីដោះស្រាយបញ្ហាប្រឈមទាំងនេះដោយរបៀបណា ?
- តើពួកគេប្រើប្រាស់បច្ចេកវិទ្យាយ៉ាងដូចម្តេចដើម្បីដោះស្រាយបញ្ហារបស់ពួកគេ ?

- តើអ្នកគិតថាមានវិធីអ្វីផ្សេងទៀតដែលពួកគេគួរតែធ្វើ?

២. ស្នើឱ្យក្រុមនីមួយៗបង្ហាញនូវចម្លើយរបស់ពួកគេ

៣. បែងចែកក្រុមជាពីរ ១ក្រុមជាក្រុមស្រប និង១ក្រុមទៀតជាក្រុមប្រឆាំង។ ផ្តល់ពេលវេលាសម្រាប់ពួកគេក្នុងការរៀបចំ។ ណែនាំឱ្យពួកគេប្រើប្រាស់អត្ថបទដែលមាននៅក្នុងជំពូកនេះ។

៤. ផ្តល់ពេល៥-១០នាទី ដើម្បីពិភាក្សាតទល់ពីប្រធានបទដូចខាងក្រោម៖

ដំណោះស្រាយផ្នែកបច្ចេកវិទ្យាសម្រាប់ការប្រែប្រួលអាកាសធាតុនឹងមានភាពខុសប្លែកគ្នាខ្លាំងប្រសិនបើមានស្ត្រីច្រើនស្ថិតក្នុងតំណែងថ្នាក់ដឹកនាំនិងការធ្វើសេចក្តីសម្រេច។

# ជំពូក ៧

# ការបញ្ជ្រាបយេនឌ័រនៅក្នុងយន្តការហិរញ្ញប្បទាននៃការប្រែប្រួលអាកាសធាតុ

*នៅជំហានទីមួយ ការឆ្លើយតប និងសមត្ថភាពរបស់ស្ត្រីនៅក្នុងការជំនះលើបញ្ហាការប្រែប្រួលអាកាសធាតុ គឺត្រូវពឹងផ្អែកយ៉ាងសំខាន់លើភាពមាំមួននៃសុខភាពជាមូលដ្ឋាន និងសុខុមាលភាពរបស់ពួកគេ ព្រមជាមួយគ្នានឹងព្រំដែនបណ្តាញទំនាក់ទំនងសង្គមរបស់ពួកគេ។ នៅក្នុងជំហានទីពីរ សមត្ថភាពរបស់ស្ត្រីនៅក្នុងការសម្របខ្លួនទៅតាមតម្រូវការនានានៃការប្រែប្រួលអាកាសធាតុត្រូវពឹងផ្អែកលើភាពស៊ីជម្រៅរបស់ពួកគេទៅលើ ការគ្រប់គ្រងធនធានសេដ្ឋកិច្ច និងលទ្ធភាពរបស់ពួកគេនៅក្នុងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ ( Williams, personal communication )។*

## *សារសំខាន់ៗ*

- ធនធានសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ស្ត្រីត្រូវបានបំផ្លិចបំផ្លាញយ៉ាងធំធេង ច្រើនជាងបុរសដោយបញ្ហាការប្រែប្រួលអាកាសធាតុ
- គោលនយោបាយផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុមិនបានគិតគូរដល់ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុទៅលើសុវត្ថិភាពសេដ្ឋកិច្ចរបស់ស្ត្រីនោះទេ។ គោលនយោបាយនេះគួរតែផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់បណ្តាវិនិយោគនានាទៅលើគម្រោងតូចៗ និងការយកពន្ធឧស្ម័នកាបូនកម្រិតថ្នាក់ជាតិដែលអាចនឹងផ្តល់អត្ថប្រយោជន៍ដល់ស្ត្រីបានច្រើនជាងនេះ
- ការបញ្ចេញមតិ កង្វល់នានា និងអាទិភាពផ្សេងៗរបស់ស្ត្រីមិនអាចបន្តមិនយកចិត្តទុកដាក់នៅក្នុងគម្រោងថ្នាក់ជាតិ និងអន្តរជាតិនានាដែលមានស្រាប់ចំពោះការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុតទៅទៀតនោះទេ
- ការផ្តល់ហិរញ្ញប្បទានក្នុងការបន្សាំខ្លួនគួរតែផ្តោតការយកចិត្តទុកដាក់លើវិធានការដែលមានប្រសិទ្ធភាពខ្ពស់នៅក្នុងវិស័យកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិដែលស្ថិតនៅក្នុងជួរតែមួយជាមួយសកម្មភាពលើបញ្ហាការប្រែប្រួលអាកាសធាតុ និងសកម្មភាពពាក់ព័ន្ធនានារបស់ស្ត្រី
- ការផ្តល់ហិរញ្ញប្បទានលើការកាត់បន្ថយការប្រែប្រួលអាកាសធាតុគួរតែបំពេញបន្ថែមនូវការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ( GHG ) ជាមួយនឹងគម្រោងនានាដែលពង្រឹងជីវភាព និងសិទ្ធិរបស់ស្ត្រី
- ការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុនៃវិស័យឯកជនគួរតែទទួលខុសត្រូវ និងសម្រាលនូវផលប៉ះពាល់ជាអវិជ្ជមានផ្សេងៗចំពោះសកម្មភាពទីផ្សារទៅលើលទ្ធភាពរបស់ស្ត្រីចំពោះធនធាននានាដូចជា ដីធ្លីជាដើម។

## ៧.១ តើការផ្តល់ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុគឺជាអ្វី?

កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីដោះស្រាយការលំបាកនៃបញ្ហាការប្រែប្រួលអាកាសធាតុបានចេញលទ្ធផលជាសកម្មភាពផ្សេងៗជាច្រើននៅគ្រប់កម្រិតនៃសេដ្ឋកិច្ច។ គោលដៅ ទិសដៅ ទំរង់បែបបទ គម្រោង និងកម្មវិធី

នានា ដែលកើតចេញពីគោលនយោបាយលើបញ្ហាអាកាសធាតុជុំវិញយុទ្ធសាស្ត្របន្សាំ និងកាត់បន្ថយ និងតម្រូវឱ្យមានធនធានដ៏សំខាន់ជាច្រើនដើម្បីទូទាត់លើថ្លៃទំនិញ សេវាកម្ម និងបច្ចេកវិទ្យាផ្សេងៗដែលនឹងត្រូវការដោយបណ្តាប្រទេសកំពុងអភិវឌ្ឍ និងអភិវឌ្ឍនៅក្នុងការចុះអនុវត្តយុទ្ធនាការផ្សេងៗនៃបញ្ហាការប្រែប្រួលអាកាសធាតុ។

គេបានធ្វើការវាយតម្លៃថា កញ្ចប់ថវិកាសម្រាប់ចំណាយលើបញ្ហាការប្រែប្រួលអាកាសធាតុ គឺមានតម្លៃប្រហាក់ប្រហែលនឹង ២០% នៃ GDP សកល។

ការលំបាកនៃការផ្តល់ហិរញ្ញប្បទានទៅលើកម្មវិធី និងគម្រោងនានាដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងដើម្បីអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយ បានធ្វើឱ្យមានសហគមន៍សកលមួយស្ថិតនៅក្រោមការទំនុកបំរុងរបស់អនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីបញ្ហាការប្រែប្រួលអាកាសធាតុ (UNFCCC) ក្នុងការបង្កើតប្រព័ន្ធនៃការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុដោយវិធីសាស្ត្រ និងយន្តការនានាជាច្រើន។ វិធីសាស្ត្រផ្សេងៗនៃការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុត្រូវបានបែងចែកតាមរយៈផែនការយុទ្ធសាស្ត្រ (យុទ្ធសាស្ត្រជាមួយនឹងយុទ្ធសាស្ត្រកាត់បន្ថយ និងការផ្ទេរបច្ចេកវិទ្យា) ហើយត្រូវបានបង្កើតឡើងជាពិសេសដើម្បីតម្រូវទៅតាមកម្រិតផ្សេងៗគ្នានៃការអភិវឌ្ឍសេដ្ឋកិច្ចនៃបណ្តាប្រទេសផ្សេងៗនៃសេដ្ឋកិច្ចសកល។

ដូច្នេះ ការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុបានគ្របដណ្តប់លើតួនាទី និងសកម្មភាពផ្សេងៗនៃបណ្តាស្ថាប័នហិរញ្ញវត្ថុ និងអ្នកធ្វើសេចក្តីសម្រេចលើការផ្តល់ហិរញ្ញប្បទាន នៅក្នុងវិស័យសាធារណៈ និងវិស័យឯកជនដោយគោរពទៅតាមការស្រុះស្រួលគ្នារវាងអ្នកឧបត្ថម្ភ និងបណ្តារដ្ឋាភិបាលដែលជាអ្នកទទួល អ្នកសន្សំ និងអ្នកវិនិយោគ អ្នកឱ្យគេខ្ចី និងអ្នកដែលត្រូវគេខ្ចី។ គោលបំណងនៃការធ្វើឱ្យមានការស្រុះស្រួលគ្នានេះគឺដើម្បីគ្រប់គ្រងហានិភ័យនៃយុទ្ធសាស្ត្រ កាត់បន្ថយ និងដើម្បីដោះស្រាយបញ្ហានៃការបាត់បង់ និងការបំផ្លិចបំផ្លាញនានាដែលពាក់ព័ន្ធទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្ត្រកាត់បន្ថយ។

## ៧.២ តើការផ្តល់ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុមានទំនាក់ទំនងដូចម្តេចជាមួយយេនឌ័រ?

កត្តាជាច្រើនដែលជះឥទ្ធិពលលើការផ្តល់ភាពអង់អាចដល់ស្ត្រី និងការគ្រប់គ្រងរបស់ស្ត្រីទៅលើធនធានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺមានការទទួលស្គាល់ជាទូទៅ ហើយបានក្លាយជាការពិតមួយដែលមិនមានលក្ខណៈប្រាកដនិយម។ កត្តាទាំងនេះរួមមាន៖ វិសមភាពយេនឌ័រជុំវិញលទ្ធភាពផ្សេងៗចំពោះសម្បត្តិធម្មជាតិ និងសង្គម គម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ ប្រាក់ចំណូល ការប្រើប្រាស់ពេលវេលា និងការលំហែ ព្រមទាំងការបែងចែកតួនាទី និងទំនួលខុសត្រូវផ្សេងៗនៃយេនឌ័រនៅក្នុងគ្រួសារ សហគមន៍ និងទីផ្សារកម្លាំងពលកម្ម។ នៅក្នុងសំណេរដោយផ្អែកតាមគោលដៅអភិវឌ្ឍសហស្សវត្សរ៍ (MDG) កត្តាទាំងនេះអាចបែងចែកជាក្រុមទៅតាមលក្ខណៈនៃឥទ្ធិពលចំពោះសមត្ថភាពរបស់ស្ត្រី លទ្ធភាពរបស់ស្ត្រីក្នុងការប្រើប្រាស់ធនធាន និងលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានឱកាស និងសុវត្ថិភាព។ ការស្រាវជ្រាវដែលសំអាងលើការពិសោធន៍មួយក៏បានបង្ហាញអំពីភាពរស់រវើកនៃការបែងចែកយេនឌ័រដែលបានដើរតួនាទី នៅក្នុងលំដាប់ដ៏ទូលំទូលាយក្នុងសកម្មភាពសង្គម និងសេដ្ឋកិច្ច ដោយរាប់បញ្ចូលទាំងវិស័យកសិកម្ម សេវាកម្ម ផលិតកម្ម ការចែកចាយនិងទទួលបានការប្រើប្រាស់ទឹក និងថាមពល ការដឹកជញ្ជូន និងការគ្រប់គ្រងគ្រោះមហន្តរាយ។

នៅក្នុងករណីទីមួយ ការឆ្លើយតប និងសមត្ថភាពរបស់ស្ត្រីនៅក្នុងការបន្សាំទៅនឹងបញ្ហាការប្រែប្រួលអាកាសធាតុគឺត្រូវពឹងផ្អែកយ៉ាងសំខាន់លើភាពមាំមួននៃសុខភាពជាមូលដ្ឋាន និងសុខុមាលភាពរបស់ពួកគេ ព្រមជាមួយគ្នានឹងភាពស៊ីជម្រៅនៃការគ្រប់គ្រងរបស់ពួកគេលើធនធានសង្គម និងសេដ្ឋកិច្ច។ កត្តានេះរួមបញ្ចូលនូវការគ្រប់គ្រងរបស់ស្ត្រី "ទៅលើដីធ្លី

ផលិតផល និងរបស់របរប្រើប្រាស់ សុខភាពល្អ និងបំលាស់ទីផ្ទាល់ខ្លួន អំណាចនៅក្នុងក្រុមគ្រួសារ និងសុវត្ថិភាពផ្ទាល់ខ្លួន លំនៅដ្ឋានរឹងមាំនៅក្នុងទីដែលមានសុវត្ថិភាព សេរីភាពរួចផុតពីអំពើហិង្សា” (Brody et al., 2008)។ ប្រសិនបើកត្តាទាំងនេះមិនត្រូវបានបង្កើតឡើងឱ្យបានសមរម្យទេនោះ ក្រុមស្ត្រីដែលទទួលរងនូវឥទ្ធិពលនឹងបាត់បង់អត្ថប្រយោជន៍ដ៏ធំធេង។

បញ្ហាការប្រែប្រួលអាកាសធាតុមានជាប់ពាក់ព័ន្ធទៅនឹងបញ្ហាកង្វះស្បៀងអាហារ ការកើនឡើងនូវជម្ងឺផ្លូវដង្ហើម និងការកើនឡើងនូវភាពនឿយហត់ អស់កម្លាំងដោយសារតែការធ្វើដំណើរឆ្ងាយទៅៗដើម្បីស្វែងរកទឹក។ ការបង្កឱ្យទៅជាស្ថានភាពស្មុគស្មាញចំពោះស្ត្រីជាច្រើននោះក៏ជាសញ្ញាមួយដែលបង្ហាញឱ្យឃើញថា បញ្ហាការប្រែប្រួលអាកាសធាតុក៏នឹងនាំឱ្យមាននូវបញ្ហាថ្មីៗផ្សេងទៀតដូចជា ការកើនឡើងនូវកំដៅ និងការកើនឡើងនូវជម្ងឺដែលរាតត្បាតនានាតាមរយៈទឹក (Brody et al., 2008)។ កត្តាដ៏ស្មុគស្មាញទាំងនេះក៏បានបន្តកែប្រែសមត្ថភាពរបស់ស្ត្រីក្នុងការបំពេញតួនាទីឱ្យបានត្រឹមត្រូវ។ នៅក្នុងករណីខ្លះកត្តាជះឥទ្ធិពលអំពីការប្រែប្រួលអាកាសធាតុអាចនឹងតម្រូវឱ្យមានជំនាញថ្មីៗ ដើម្បីជាការសង្គ្រោះបន្ទាន់ដូចជា ជំនាញក្នុងការឡើងដើមឈើ និងជំនាញក្នុងការហែលទឹកដែលមិនមែនជាទង្វើដែលត្រឹមត្រូវតាមប្រពៃណីទំនៀមទម្លាប់សម្រាប់ស្ត្រីមួយចំនួនដែលរស់នៅក្រោមជម្រកវប្បធម៌ និងលក្ខខណ្ឌសាសនាតាមតំបន់ខ្លះនោះទេ។ កត្តាការប្រែប្រួលអាកាសធាតុក៏បានពង្រីកផងដែរនូវផលវិបាកដែលបណ្តាលមកពីវិសមភាពយេនឌ័រដែលមានពីមុនមកដូចជា ការទទួលបានព័ត៌មានមិនស្មើគ្នារវាងស្ត្រី និងបុរស។ ខណៈដែលទំរង់ចាស់នៃភាពមិនស្មើគ្នានេះបានធ្វើឱ្យមានបញ្ហាគ្រាំគ្រែងមួយចំនួនដូចជា ភាពក្រីក្រនៅតាមតំបន់ជនបទ ឬតំបន់ដាច់ស្រយ៉ាលជាដើមនោះ ថ្មីៗដូចជា ការចែករំលែកព័ត៌មានបញ្ហាថ្មីៗដែលទាក់ទងមួយចំនួនទៀតមិនបានជិតដល់ទាក់ទងនឹងការដាស់តឿនទុកជាមុន និងការត្រៀមខ្លួនចំពោះគ្រោះមហន្តរាយដែលប៉ះពាល់ជីវិត និងសេចក្តីស្លាប់មួយផងដែរ។

ដើម្បីដោះស្រាយឱ្យបានជោគជ័យចំពោះបញ្ហាហានិភ័យនៃការគ្រប់គ្រង ការត្រៀមខ្លួនចំពោះគ្រោះមហន្តរាយ និងបញ្ហាអាកាសធាតុដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ គឺតម្រូវឱ្យមានធនធានច្រើនលើសពីធនធានដែលមានធម្មតាផ្តល់ឱ្យសម្រាប់ឆ្លើយតបទៅនឹងតម្រូវការមួយថ្ងៃៗដល់បុគ្គល និងក្រុមគ្រួសារដែលមានជីវភាពមធ្យម។ ឧទាហរណ៍អាចនឹងតម្រូវឱ្យមានធនធានដើម្បីសាងសង់លំនៅដ្ឋានជាអចិន្ត្រៃយ៍ ឬ រឹងមាំជាងមុនសម្រាប់ក្រុមគ្រួសារ កន្លែងរក្សាទុកប្រភពធនធានទឹកដែលធានា និងប្រសើរជាងមុន និងការចំណាយលើប្រព័ន្ធបច្ចេកវិទ្យាដែលសន្សំសំចៃថាមពល ដូចជាចង្ក្រានប្រើថាមពលពន្លឺព្រះអាទិត្យជាដើម។ បើតាមការកត់សម្គាល់ដោយអង្គការសហប្រជាជាតិ ផ្តល់ភាពអង់អាច និងវិនិយោគទៅលើស្ត្រីគឺជាគន្លឹះ ក្នុងការប្រឆាំងនឹងឥទ្ធិពលនៃការវិវឌ្ឍទៅកេភាពខ្សត់ខ្សោយ និងគ្រួសត្រាយផ្លូវសម្រាប់ការកាត់បន្ថយភាពក្រីក្រក្នុងតំបន់ដាច់ស្រយាលនៅក្នុងបណ្តាប្រទេសជាច្រើននៅលើសកលលោកដែលមានការអភិវឌ្ឍតិចតួច (Srabani, 2008)។ ស្ត្រីក៏បានដើរតួយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍប្រព័ន្ធថាមពលផងដែរ។ ប៉ុន្តែ ស្ថិតនៅក្នុងវិធីសាស្ត្រនៃការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុបច្ចុប្បន្ន ស្ត្រីមិនមានលទ្ធភាពងាយស្រួល និងគ្រប់គ្រាន់ ក្នុងការទទួលបានប្រាក់ជំនួយដើម្បីដោះស្រាយលើការខាតបង់ផ្សេងៗដែលបណ្តាលមកពីកត្តាអាកាសធាតុ ឬដើម្បីបង់សេវានៃការប្រើបច្ចេកវិទ្យានៃយុទ្ធសាស្ត្រ បន្សាំនឹងការកាត់បន្ថយនោះទេ។ សកម្មភាពជាច្រើនដែលជាធម្មតាត្រូវបានធ្វើឡើងដោយស្ត្រីដែលគេអាចរាប់បញ្ចូលថា ជាសកម្មភាពនៃយុទ្ធសាស្ត្របន្សាំនឹងការកាត់បន្ថយដូចជា ការដាំដើមឈើជាដើមនោះ មិនត្រូវបានទទួលស្គាល់នៅក្នុងទីផ្សារពាណិជ្ជកម្មកាបូនសកល ឬ អាចនិយាយបានថា ត្រូវបានមើលរំលងពីសំណាក់ក្រុមអ្នកផ្តល់ជំនួយផ្សេងៗ។ ជាងនេះទៅទៀត ការបង្កជាភាពស្មុគស្មាញចំពោះប្រាក់ឧបត្ថមផ្សេងៗលើកត្តាការប្រែប្រួលអាកាសធាតុ និងដំណើរការដ៏ស្មុគស្មាញនៃការប្រើប្រាស់ថវិកាទាំងនោះបានធ្វើឱ្យស្ត្រី និងបណ្តាសហគមន៍នានាអាចនឹងមានការលំបាកនៅក្នុងការទទួលបាន និងទាញយកប្រយោជន៍ពីប្រាក់ឧបត្ថម្ភ ដែលបានគ្រោងសម្រាប់គម្រោងដែលមាន

ដើមទុន និងទ្រង់ទ្រាយធំ។ ចុងក្រោយ យន្តការនៃការចែកចាយក្នុងការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុនេះអាចនឹងមិនសូវបានផលចំពោះកម្រិតដែលកំពុងមាន និងបណ្តុំនៃប្រតិបត្តិការ ដែលអនុវត្តដោយស្ត្រី ទាំងនៅក្នុងការធ្វើស្រែចម្ការ កត្តាជំនួញ និងកត្តាក្រុមគ្រួសារ។ ដើម្បីបានការបញ្ជាក់ដែលមានហេតុផលច្បាស់លាស់ទៅលើបញ្ហាទាំងនេះ គឺមានតែធ្វើការបញ្ជាក់តាមរយៈការត្រួតពិនិត្យឱ្យបានដិតស្និតទៅលើប្រតិបត្តិការនានានៃការបង្កើតការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុដោយរួមបញ្ចូលវិធីសាស្ត្រ និងយន្តការផ្សេងៗនៃការធ្វើហិរញ្ញប្បទាននេះនោះទេ។

### ប្រអប់ទី១ ភាពតឹងរឹង និងបញ្ហាប្រឈម នៅក្នុងទីផ្សារហិរញ្ញប្បទាន ថ្នាក់ជាតិ និងសកល

មានភាពតឹងតែង និងបញ្ហាប្រឈម ជាច្រើនដែលមានការទទួលស្គាល់នៅក្នុងទីផ្សារហិរញ្ញប្បទានថ្នាក់ជាតិ និងសកល ដែលបានរារាំង និងធ្វើឱ្យបាត់បង់នូវលទ្ធភាពរបស់ស្ត្រីនៅក្នុងការទទួលបានធនធានសេដ្ឋកិច្ច ឥណទាន និងហិរញ្ញវត្ថុ នៅក្នុងទីផ្សារឥណទាន និងប្រាក់កាស។ ស្ត្រីត្រូវទទួលបានតំណាងថ្នាក់ក្រោមនៅក្នុងសម័យកាល(fora)នៃការធ្វើការសម្រេចទៅលើបញ្ហាការប្រែប្រួលអាកាសធាតុ។ កង្វល់ អាទិភាព និងបញ្ហានានារបស់ស្ត្រីមិនសូវមានការយកចិត្តទុកដាក់នៅក្នុងប្រតិបត្តិការរបស់អ្នកធ្វើការសម្រេចចិត្តលើការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុនោះទេ។

ហេតុដូច្នោះហើយ ផលវិបាកដែលជាលទ្ធផលនៃការធ្វើការសម្រេច ក្នុងលក្ខខណ្ឌដែលថាតើគម្រោង និងកម្មវិធីនានាត្រូវបានផ្តល់ប្រាក់ដោយបែបណានោះ ក៏ត្រូវបានរែកពុនដោយស្ត្រីផងដែរ។

ជាករណីដែលប្រភេទដូចគ្នានៃការរារាំងដោយកត្តាយេនឌ័រ (ដូចជា វិសមភាពនៃសិទ្ធលើអចលនទ្រព្យ) ដែលបានបង្កជាបញ្ហាចំពោះស្ត្រីនៅក្នុងនិយ័តទីផ្សារហិរញ្ញប្បទានដែលអាចនឹងកើតមានតាមរយៈការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុផងដែរ។ កត្តារារាំងទាំងនេះត្រូវបានផ្សាភ្ជាប់គ្នាទៅវិញទៅមកជាមួយនឹងបទដ្ឋាននៃការរើសអើងនៅក្នុងទីផ្សារហិរញ្ញវត្ថុដែលនឹងជះឥទ្ធិពលលើភាពគ្មានប្រសិទ្ធភាពនៅក្នុងការប្រើប្រាស់ធនធាន។

បើទោះបីជាមានការធ្វើការស្រាវជ្រាវតិចតួចលើបញ្ហាយេនឌ័រនៃការធ្វើហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុក៏ពិតមែនប៉ុន្តែប្រសិនបើវិយោគកម្មយេនឌ័រដែលមានលក្ខណៈធម្មតានៅក្នុងនិយ័តទីផ្សារហិរញ្ញប្បទាននៅតែបន្តកើតមាននោះវានឹងអាច៖

- ស្ត្រីនឹងសុំខ្ចីប្រាក់ក្នុងចំនួនតិចជាងបុរស (នៅក្នុងការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុ បញ្ហានេះអាចនឹងត្រូវបានស្តែងចេញតាមរយៈភាពលុបនៃស្ត្រីនៅក្នុងបណ្តាគម្រោងទ្រង់ទ្រាយតូច)
- ស្ត្រីនឹងផ្តល់ឥណទានឱ្យស្ត្រី ដូច្នេះដោយសារការពិចារណាលើ យេនឌ័រ និងលក្ខណៈវិនិច្ឆ័យផ្សេងៗមិនមានសារៈសំខាន់ចំពោះការពិនិត្យសារឡើងវិញទៅលើសំណើរគម្រោង និងការធ្វើការសម្រេចលើការយល់ព្រម និងចេញប្រាក់ឧបត្ថម្ភទើបធ្វើឱ្យភាគរយនៃគម្រោងរបស់ស្ត្រីដែលត្រូវបានគេជ្រើសយកអាចនឹងទាបជាង
- ស្ត្រីនឹងខ្ចីពីកម្មវិធីពិសេសៗផ្សេងៗ ដែលមានកំណត់កម្ចីទាបជាង
- ស្ត្រីប្រឈមនឹងអត្រាការប្រាក់ខ្ពស់ជាង ឬថ្លៃចំណាយលើប្រតិបត្តិការធំជាង (ដោយសារតែទំហំនៃគម្រោងរបស់ពួកគេ)
- ស្ត្រីនឹងមានលទ្ធភាពតិចជាង និងមានតម្រូវការហួសកំណត់ចំពោះឥណទាន (នៅក្នុងករណីនេះ ស្ត្រី និងក្រុមស្ត្រីជាច្រើនអាចនឹងមានគម្រោងច្រើនដែលតម្រូវឱ្យមានការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុ ប៉ុន្តែត្រូវប្រឈមនឹងការផ្គត់ផ្គង់ហិរញ្ញប្បទានដែលមានកំណត់។

## ៧.៣ តើការផ្តល់ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុមានឧបករណ៍ យន្តការ និងគំរូបែបបទអ្វីខ្លះ ?

គោលបំណងធំនៃការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុបច្ចុប្បន្ន គឺដើម្បីលើកកម្ពស់ និងធានាឱ្យបាននូវសកម្មភាពនៃការបន្សាំនឹងការកាត់បន្ថយ។ គោលបំណងដោយឡែកផ្សេងៗរួមមានធ្វើឱ្យមានស្ថិរភាព ឬ កាត់បន្ថយការសាយភាយនៃឧស្ម័នផ្ទះកញ្ចក់ ( GHG ) និងការបង្កើតឱ្យមានសេដ្ឋកិច្ចដែលមានកាបូនទាប។

បើតាមការកត់សម្គាល់នាពេលថ្មីៗនេះរចនាសម្ព័ន្ធនៃការគ្រប់គ្រងដែលសំខាន់បំផុតចំពោះគោលនយោបាយការប្រែប្រួលអាកាសធាតុអន្តរជាតិនោះគឺ UNFCCC។ ដូច្នេះហើយ វិធីសាស្ត្រនៃការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុដែលមានបច្ចុប្បន្នត្រូវបានបង្កើតឡើងនៅក្រោមការទំនុកបំរុងរបស់ UNFCCC និងដំណើរការផ្សេងៗដែលពាក់ព័ន្ធ ដូចជាពិធីសារទីក្រុងក្យូតូជាដើម។ ការបង្កើតវិធីសាស្ត្រនៃការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំជាច្រើនស្រទាប់ និងបង្កើតបានជាមូលដ្ឋាន៤ ព្រមទាំងបានចងក្រងគ្រឹះនៃបណ្តាញហិរញ្ញវត្ថុសាធារណៈដែលត្រូវបានបំពេញបន្ថែមដោយបណ្តាញវិស័យឯកជននៃអ្នកដើរតួនាទី និងអ្នកផ្តើមគំនិត។ អ្នកចូលរួមជាសាធារណៈនៃការបង្កើតការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុរួមមាន៖ ១) អង្គការសហប្រជាជាតិ ( តាមរយៈ UNFCCC / GEF ) ២) ធនាគារពិភពលោក ៣) ស្ថាប័នហិរញ្ញវត្ថុពហុភាគី និងស្ថាប័នអភិវឌ្ឍផ្សេងៗទៀត និង ៤) បណ្តាអ្នកឧបត្ថម្ភទ្វេភាគីជាច្រើនផ្សេងទៀត។ បណ្តាញវិស័យឯកជនរួមមានមូលនិធិជួយក្រុមហ៊ុនទើបបង្កើតថ្មីដែលជួបហានិភ័យ ( venture capital funds ) មូលនិធិកាបូនឯកជន និងបណ្តាញនៃពាណិជ្ជកម្មផ្សេងៗ ( a network of exchanges )។

យន្តការនៃការផ្តល់ហិរញ្ញប្បទានមានវិធានការថ្នាក់ជាតិ (ប្រអប់ទី២) និងយន្តការដោយផ្អែកលើទីផ្សារ (ប្រអប់ទី៤ ទី៥ និងទី៦)។ ខាងផ្នែកផ្គត់ផ្គង់សាធារណៈធនាគារពិភពលោក ធនាគារអភិវឌ្ឍតំបន់និងបណ្តាអ្នកឧបត្ថម្ភទ្វេភាគី និងរដ្ឋាភិបាលជាតិ បានប្រើប្រាស់តារាងនៃជម្រើសដោយរាប់ចាប់ពីប្រាក់ចេញថ្លៃពន្ធ ជំនួញក្នុងស្រុក ប្រព័ន្ធធានារ៉ាប់រងកម្មវិធីឥណទានផ្តល់អត្រាការប្រាក់ទាប ប្រាក់ជំនួយឧបត្ថម្ភ ការផ្តល់ប្រាក់សម្បទាន សហហិរញ្ញប្បទានរហូតដល់កម្មវិធីផ្សេងៗទៀតដែលបានកំណត់ទុក។ ពួកគេក៏មានលទ្ធភាពក្នុងការប្រើប្រាស់យន្តការដោយផ្អែកលើទីផ្សារដែលងាយរងគ្រោះ និងដែលមិនងាយរងគ្រោះផងដែរ។ វិស័យឯកជនប្រើប្រាស់វិធីសាស្ត្រដូចជា វិនិយោគផ្ទាល់របស់បរទេស ជម្រើសសមភាពអាជីវកម្ម និងអាជីវកម្មផ្តាច់មុខ និងប្រព័ន្ធផ្អែកលើទីផ្សារជាច្រើនផ្សេងទៀត។

ផ្នែកតម្រូវការនៃការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុ គឺពឹងផ្អែកជាចម្បងលើគោលនយោបាយនៃកត្តាការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ តំបន់ និងអន្តរជាតិ និងកញ្ចប់ថវិកាដែលត្រូវបានបង្កើតឡើង ដើម្បីជួយជ្រោមជ្រែងនៅក្នុងយុទ្ធសាស្ត្រនៃការបន្សាំនឹងការកាត់បន្ថយ។ តម្រូវការចាំបាច់រួមមាននៅក្នុងវិស័យដូចជា វិស័យថាមពល វិស័យកសិកម្ម ព្រៃឈើ និងវិស័យសុខាភិបាល រួមបញ្ចូលទាំងការខាតបង់ផ្សេងៗលើវិស័យកសិកម្មតាមរយៈកត្តាអាកាសធាតុ និងការផ្តល់ប្រាក់លើបច្ចេកវិទ្យាការកាត់បន្ថយ និងការបន្សាំ។ អ្នកដែលត្រូវការមូលនិធិសម្រាប់សកម្មភាពនៃការបន្សាំសំខាន់ៗគឺបណ្តាប្រទេសកំពុងអភិវឌ្ឍ ដែលបានធ្វើឱ្យតម្រូវការរបស់ពួកគេមានភាពចាំបាច់តាមរយៈការរៀបចំសកម្មភាពនៃកម្មវិធីបន្សាំថ្នាក់ជាតិ ( NAPAs )។

**ប្រអប់ទី២ យុទ្ធសាស្ត្រផ្ដល់ហិរញ្ញប្បទានថ្នាក់ជាតិ (ប្រាក់លើកទឹកចិត្ត)**

- ការបង់ប្រាក់ដោយផ្ទាល់
- ការកាត់បន្ថយថ្លៃពន្ធ
- ការគាំទ្រតម្លៃ
- ការកាត់ពន្ធនាំចូល
- ប្រាក់ឧបត្ថម្ភលើកម្មវិធីផ្សេងៗ
- ប្រាក់កម្ចីលើកម្មវិធីផ្សេងៗ
- មូលប្បទានប័ត្រ
- ប្រាក់ឧបត្ថម្ភលើការផលិត
- កម្មវិធីបញ្ជាទិញរបស់រដ្ឋាភិបាល
- សមភាពអាជីវកម្ម រួមបញ្ចូលទាំងប្រាក់ឧបត្ថម្ភជួយដល់ក្រុមហ៊ុនទើបបង្កើតថ្មីដែលជួបហានិភ័យ
- កម្មវិធីធានារ៉ាប់រង

*ប្រភព៖ Tirpak et al., 2008.*

ថ្មីៗនេះ ការផ្ដល់ហិរញ្ញប្បទាន លើបញ្ហាការប្រែប្រួលអាកាសធាតុមានភាពលំអៀង ចំពោះយុទ្ធសាស្ត្រកាត់បន្ថយដូច្នេះការផ្ដល់ប្រាក់ឧបត្ថម្ភចំពោះគម្រោងនៃការបន្សាំគឺមិនមានការត្រៀមទុកបានល្អនោះទេ បើប្រៀបធៀបជាមួយការផ្ដល់ប្រាក់ឧបត្ថម្ភសម្រាប់គម្រោងនៃការកាត់បន្ថយ ។ ចំពោះគម្រោងកាត់បន្ថយ អ្នកដើរតួសំខាន់ៗអាចជាបណ្ដាប្រទេសអភិវឌ្ឍ និងបណ្ដាប្រទេសដែលមានសេដ្ឋកិច្ចទីផ្សារលេចធ្លោដូចជា ប្រទេសប្រេស៊ីល ឥណ្ឌា និងចិនជាដើម។ ប៉ុន្តែ បណ្ដាប្រទេសកំពុងអភិវឌ្ឍជាច្រើនក៏កំពុងតែមានការកើនឡើងនៅក្នុងការបង្ហាញពីតម្រូវការរបស់ខ្លួនកាន់តែខ្លាំងឡើងចំពោះគម្រោងកាត់បន្ថយផងដែរ។

សន្និសីទនៃភាគីពាក់ព័ន្ធ (COP) បានបង្កើត GEF ជាផ្នែកហិរញ្ញវត្ថុរបស់ខ្លួន។ GEF ត្រូវបានរក្សាសិទ្ធិធ្វើការត្រួតពិនិត្យសារឡើងវិញរៀងរាល់៤ឆ្នាំម្ដង និងមានការទទួលខុសត្រូវចំពោះ COP។ គម្រោង GEF ត្រូវបានគ្រប់គ្រងដោយភ្នាក់ងារត្រួតពិនិត្យប្រតិបត្តិការចំនួន ៣ រួមមាន UNEP UNDP និងធនាគារពិភពលោក ព្រមទាំងមានភ្នាក់ងារប្រតិបត្តិចំនួន៧។ គម្រោង GEF ភាគច្រើនមានភាគីសហហិរញ្ញប្បទាន។ បណ្ដាប្រទេសដែលចូលរួមត្រូវរៀបចំវិធីសាស្ត្រទំនាក់ទំនងថ្នាក់ជាតិមួយក្រុម ដែលនឹងរាប់បញ្ចូលនូវការពិចារណាលើតម្រូវការ និងអាទិភាពរបស់ពួកគេទៅលើបញ្ហាការប្រែប្រួលអាកាសធាតុ។ សន្និសីទនៃបណ្ដាភាគីពាក់ព័ន្ធ (COP) បានបង្កើតមូលនិធិសំខាន់ៗបីរួមមានមូលនិធិពិសេសសម្រាប់បញ្ហាការប្រែប្រួលអាកាសធាតុ (SCCF) និងមូលនិធិសម្រាប់ប្រទេសដែលមានការអភិវឌ្ឍតិច (LDCF) ដែលស្ថិតនៅក្រោម UNFCCC និងមូលនិធិសម្រាប់យុទ្ធសាស្ត្របន្សាំ (AF) ដែលស្ថិតនៅក្រោមពិធីសារក្យូតូ។ GEF គ្រប់គ្រងលើមូលនិធិពីររបស់ UNFCCC ព្រមទាំងគ្រប់គ្រងលើមូលនិធិដ៏គួរជឿទុកចិត្តនៃអាទិភាពជាយុទ្ធសាស្ត្រចំពោះការបន្សាំ។

SCCF គឺជាមូលនិធិដែលងាយរងគ្រោះមួយដែលអាស្រ័យលើការបរិច្ចាករបស់អ្នកផ្ដល់ជំនួយឧបត្ថម្ភត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីដោះស្រាយរាល់បញ្ហានានានៃការបន្សាំ និងការអភិវឌ្ឍដោយរួមបញ្ចូលទាំងការផ្ទេរបច្ចេកវិទ្យា ហើយវាកំពុងស្ថិតនៅក្នុងតម្រូវការដ៏ធំធេងពីសំណាក់បណ្ដាប្រទេសកំពុងអភិវឌ្ឍ។ LDCF ក៏ត្រូវបានផ្ដល់មូលនិធិដោយផ្អែកជាមូលដ្ឋានលើភាពងាយរងគ្រោះផងដែរនឹងផ្ដោតការយកចិត្តទុកដាក់លើតំបន់អាទិភាពនៃ NAPA (ប្រអប់ ទី៣) ដែលរួមបញ្ចូលទាំងបញ្ហានានានៃការអភិវឌ្ឍសហគមន៍ និងការបន្សាំ។ ក៏មានផងដែរនូវកម្មវិធីដែលមានកញ្ចប់ថវិកាឧបត្ថម្ភតូចៗ (SGP) ដែលបានបង្កើតឡើងសម្រាប់បណ្ដាប្រទេសដែលមានសមត្ថភាពតិចតួច។ ធ្វើប្រតិបត្តិការឆ្លងកាត់

តំបន់គោលដៅរបស់ GEF។ កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងលក្ខណៈជាកម្មវិធីដែលបត់បែនខ្លាំងមួយដែលនឹងឆ្លើយតបទៅតាមតម្រូវការរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍ។

យោងតាមពិធីសារទីក្រុងក្យូតូបណ្តាប្រទេសដែលនឹងសម្រេចបាននូវគោលដៅរបស់ពួកគេ ដោយផ្អែកជាចម្បងលើវិធានការថ្នាក់ជាតិ អាចមានការពឹងផ្អែកលើយន្តការអាស្រ័យទីផ្សារចំនួនបី។ យន្តការទាំងបីនេះរួមមាន ការផ្សព្វផ្សាយពាណិជ្ជកម្ម (ឬ ពាណិជ្ជកម្ម/ទីផ្សារ កាបូន) យន្តការអភិវឌ្ឍភាពស្អាត (CDM) និងការអនុវត្តប្រតិបត្តិការរួមគ្នា (JI)។ ពិធីសារទីក្រុងក្យូតូក៏បានបង្កើតមូលនិធិសម្រាប់យុទ្ធសាស្ត្របន្សាំ (AF) ដើម្បីផ្តល់ហិរញ្ញប្បទានដល់បណ្តាកម្មវិធី និងគម្រោងបន្សាំនានាដែលមានលក្ខណៈប្រាកដនិយមនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍដែលជាភាគីពាក់ព័ន្ធក្នុងពិធីសារទីក្រុងក្យូតូផងដែរ។ មូលនិធិដែលត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាមូលនិធិបន្សាំនេះ (AFB, established at COP 13) ត្រូវបានផ្តល់ហិរញ្ញប្បទានចាប់ពី ២% ដោយមិនគិតពន្ធលើគម្រោង CDM ក៏ដូចជាពីប្រភពផ្សេងៗទៀតផងដែរ។

## ការផ្តល់ហិរញ្ញប្បទានលើការបន្សាំ - The state of play

ផែនការសកម្មភាព Bali បានផ្តោតការយកចិត្តទុកដាក់លើតំបន់ដែលមិនមានការគិតគូរពីការបន្សាំនៅក្នុងវិធីសាស្ត្រនៃការផ្តល់មូលនិធិលើបញ្ហាការប្រែប្រួលអាកាសធាតុកម្រិតអន្តរជាតិ។ ផែនការសកម្មភាព Bali បានបែងចែកជាសមាសភាពផ្តល់ហិរញ្ញប្បទាន និងសមាសភាពពាក់ព័ន្ធនឹងហិរញ្ញប្បទានចំនួន ៤ នៃយុទ្ធសាស្ត្របន្សាំ រួមមានផែនការជាតិសម្រាប់ការបន្សាំ ការសម្រួល និងបង្កើនការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកវិទ្យា ការពង្រឹងការចែករំលែកចំណេះដឹង និងគម្រោងរបស់ស្ថាប័ននានាសម្រាប់ការបន្សាំ ហើយបានបន្តសង្កត់ធ្ងន់លើ “ការពង្រឹងសកម្មភាពលើការបន្សាំ” ដោយរួមបញ្ចូលទាំងផ្នែកដទៃទៀតបានធ្វើការពិចារណាទៅលើ ៖

- ការគ្រប់គ្រងហានិភ័យ និងយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ ដោយរួមបញ្ចូលទាំងយន្តការនៃការផ្លាស់ប្តូរ និងការចែករំលែកពីហានិភ័យ ដូចជាការធានារ៉ាប់រងជាដើម
- យុទ្ធសាស្ត្រកាត់បន្ថយគ្រោះមហន្តរាយ និងមធ្យោបាយ ដើម្បីដោះស្រាយការខាតបង់ និងខូចខាតពាក់ព័ន្ធនឹងផលប៉ះពាល់ដែលកើតឡើងពីបញ្ហាការប្រែប្រួលអាកាសធាតុនៅបណ្តាប្រទេស កំពុងអភិវឌ្ឍ ដែលជាក់ស្តែងងាយនឹងទទួលរងផលប៉ះពាល់ ដោយឥទ្ធិពលអវិជ្ជមាននៃបញ្ហាការប្រែប្រួលអាកាសធាតុ។

### ប្រអប់ទី៣ សកម្មភាពនៃកម្មវិធីបន្សាំថ្នាក់ជាតិ

សកម្មភាពនៃកម្មវិធីបន្សាំថ្នាក់ជាតិបានផ្តល់វិធីសាស្ត្រដ៏សំខាន់ក្នុងការផ្តល់អាទិភាពដល់តម្រូវការនៃការបន្សាំជាបន្ទាន់សម្រាប់បណ្តាប្រទេសដែលមានការអភិវឌ្ឍតិច (Article 4.9)។ ពួកគេបានប្រើប្រាស់ព័ត៌មានដែលមានស្រាប់ និងអ្វីដែលមានក្នុងកម្រិតសហគមន៍ ដើម្បីបញ្ជាក់ថា គម្រោងបន្សាំកំពុងតែត្រូវការក្នុងពេលនេះ ដើម្បីឱ្យបណ្តាប្រទេសទាំងនេះ អាចដោះស្រាយទាន់ពេលវេលានូវផលប៉ះពាល់ដែលកើតឡើងភ្លាមៗតាមរយៈបញ្ហាការប្រែប្រួលអាកាសធាតុ។ NAPA ផ្តល់អាទិភាពលើផ្នែកមួយចំនួនដូចជា ធនធានទឹក សុវត្ថិភាព ស្បៀង អាហារ សុខាភិបាល ការត្រៀមខ្លួនចំពោះគ្រោះមហន្តរាយ និងការគ្រប់គ្រងហានិភ័យ។

មានតម្រូវការដ៏ធំធេងមួយសម្រាប់ការចូលរួមប្រកបដោយប្រសិទ្ធភាពពីភាគីស្ត្រី និងការបញ្ចូលគ្នានៃការវិភាគយេនឌ័រនៅក្នុងការដោះស្រាយបញ្ហាភាពងាយរងគ្រោះជាមួយនឹងការគ្រប់គ្រងហានិភ័យកើតចេញពីទស្សនៈ។

សកម្មភាពនៃការបន្សាំតម្រូវឱ្យមានការផ្ដល់ប្រាក់ឧបត្ថម្ភសម្រាប់ការផ្ទេរបច្ចេកវិទ្យា និងធានារ៉ាប់រងក៏ដូចជាធនធានផ្សេងៗទៀត ដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងបង្កើនភាពរឹងមាំរបស់សហគមន៍ដើម្បីទប់ទល់នឹងការកើនឡើងដ៏ច្រើននូវហេតុការណ៍ធ្ងន់ធ្ងរ។ ការជួយឧបត្ថម្ភលើការបន្សាំភាគច្រើនបានទៅលើគម្រោងទ្រង់ទ្រាយធំនៅអាហ្វ្រិក អាស៊ី អាមេរិកឡាទីន ដោយប្រើប្រាស់លើវិស័យ កសិកម្ម និងព្រៃឈើ ការផ្គត់ផ្គង់ទឹក និងតំបន់ឆ្នេរ។ មានតិចតួចប៉ុណ្ណោះ ដែលបានលើគម្រោងបន្សាំដែលនៅតាមសហគមន៍។ លំហូរប្រាក់ជំនួយឧបត្ថម្ភសម្រាប់បញ្ហាលំនឹងជីវភាពដែលជាកង្វល់ដ៏ធំមួយរបស់កសិករដែលជាស្ត្រី និងអាចប៉ះពាល់ដល់តម្រូវការសុវត្ថិភាពស្បៀងអាហារនៃគ្រប់ស្ត្រីនោះ មិនទាន់ត្រូវបានដោះស្រាយឱ្យបានគ្រប់គ្រាន់នៅឡើយទេ។

## ការធ្វើហិរញ្ញប្បទានលើការកាត់បន្ថយ - The state of play

ការយកចិត្តទុកដាក់លើការផ្ដល់ហិរញ្ញប្បទាន លើការកាត់បន្ថយគឺដើម្បីលុបបំបាត់ឧបសគ្គនៃការអភិរក្ស ថាមពល ការប្រើថាមពលកែច្នៃឡើងវិញ និងការផ្ទេរបច្ចេកវិទ្យា។ សកម្មភាពនៃការកាត់បន្ថយបានទទួលប្រាក់ឧបត្ថម្ភភាគច្រើនពីកញ្ចប់ថវិកានៃការផ្ដល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុសកល។ មូលនិធិកាត់បន្ថយត្រូវបានផ្ដល់ឱ្យគម្រោងដែលលុបបំបាត់ឧបសគ្គនៃការអភិរក្សថាមពល និងលើកកម្ពស់ប្រសិទ្ធភាពថាមពល និងការសម្រេចប្រើប្រាស់ថាមពលកែច្នៃឡើងវិញ ។ ទោះបីជាមធ្យោបាយដឹកជញ្ជូនដែលមាននិរន្តរភាព និងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីដែលត្រូវបានរួមបញ្ចូលគ្នា ជាផ្នែកអាទិភាពចម្បងក៏ដោយក៏ការផ្ដល់ហិរញ្ញប្បទានលើការកាត់បន្ថយហាក់ដូចជា មានភាពលំអៀងចំពោះបញ្ហាថាមពល ហើយម្យ៉ាងវិញទៀតគម្រោងជាច្រើនផ្សេងទៀតដែលត្រូវបានផ្ដល់ហិរញ្ញប្បទានគឺជាគម្រោងទ្រង់ទ្រាយធំដែលចំណាយដើមទុនច្រើនលើសលុប។ បញ្ហានេះ ធ្វើឱ្យប៉ះពាល់ដល់លទ្ធភាព និងភាពជាម្ចាស់ទ្រព្យនៃដីធ្លីរបស់ប្រជាជនក្នុងស្រុកក៏ដូចជា ស្ត្រីផងដែរ។នៅក្នុងការវិភាគបញ្ចប់វិធីសាស្ត្រក្នុងការផ្ដល់ហិរញ្ញប្បទានបច្ចុប្បន្នហាក់ដូចជា មិនបានពិចារណាលើកត្តាសង្គម និងតម្លៃសមភាពនៃបញ្ហាការប្រែប្រួលអាកាសធាតុនោះទេ។

កម្មវិធីផ្ដល់ជំនួយលើការកាត់បន្ថយសំខាន់ៗចំនួនពីរ គឺមាននៅក្នុងគម្រោង UNFCCC គឺ CDM (សូមមើល

**ប្រអប់ទី៤ រូបភាពមួយនៃការវិវត្តន៍នៃមូលនិធិរបស់ធនាគារពិភពលោកមួយចំនួន**

ជំនាន់ដំបូងនៃការផ្ដល់ហិរញ្ញប្បទាន លើបញ្ហាការប្រែប្រួលអាកាសធាតុដែលស្ថិតនៅក្រោមគម្រោងថាមពលស្អាតសម្រាប់ការអភិវឌ្ឍ និងវិនិយោគរបស់ធនាគារពិភពលោកបានអនុវត្តដោយប្រើ "យុទ្ធសាស្ត្រ +៥០, ៣x៥"- ៥០% នៃប្រាក់ជំនួយឧបត្ថម្ភ លើបញ្ហាការប្រែប្រួលអាកាសធាតុលើ៣ផ្នែកមានដូចជា (ថាមពលសម្រាប់អនុតំបន់សាហារ៉ានៅអាហ្វ្រិក) គន្លងអភិវឌ្ឍកាបូនទាប និងការបន្សាំ) ឆ្លងកាត់វិស័យចំនួន៥ (ការដឹកជញ្ជូន វិស័យ កសិកម្ម ទឹក ថាមពល និងទីក្រុង។

ប្រាក់ឧបត្ថម្ភនៅក្នុងជំនាន់ទីពីរ គឺត្រូវបានធ្វើឡើងក្រោមមូលនិធិវិនិយោគលើអាកាសធាតុ (CFI)។ ប្រាក់ឧបត្ថម្ភទាំងនេះត្រូវបានផ្ដោតការយកចិត្តទុកដាក់លើហិរញ្ញវត្ថុនៃការអភិវឌ្ឍជារួម និងហិរញ្ញវត្ថុនៃបញ្ហាការប្រែប្រួលអាកាសធាតុដែលត្រូវបានអនុវត្តតាមរយៈបណ្ដាញនៃធនាគារអភិវឌ្ឍក្នុងតំបន់ ឬ ពហុភាគី (ធនាគារអភិវឌ្ឍអាហ្វ្រិក ធនាគារអភិវឌ្ឍអាស៊ីធនាគារអភិវឌ្ឍអន្តរអាមេរិក និងធនាគារអភិវឌ្ឍអឺរ៉ុប ។ មូលនិធិរបស់ CIF ទាំងអស់ត្រូវបានចំណាយលើការកាត់បន្ថយ និងត្រូវបានចែកជាមូលនិធិបន្ទាប់បន្សំចំនួន២ រួមមាន មូលនិធិបច្ចេកវិទ្យាស្អាត ដែលត្រូវបានរៀបចំសម្រាប់ប្រទេសប្រេស៊ីល ឥណ្ឌា និងចិន និងមូលនិធិយុទ្ធសាស្ត្រអាកាសធាតុ (SCF)។

ប្រអប់ទី៥) និង REDD។ ធនាគារពិភពលោកក៏ដឹកនាំ ឬ ចាត់ចែងមូលនិធិបន្ទាប់បន្សំធំៗនៃការកាត់បន្ថយទាំងមូលផងដែរ។

ការកាត់បន្ថយការសាយភាយឧស្ម័នដែលបណ្តាលមកពីការកាប់បំផ្លាញព្រៃឈើ និងការបាត់បង់ព្រៃឈើនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ ហៅកាត់ថា REDD គឺជាយន្តការផ្តល់ហិរញ្ញប្បទានដ៏ថ្មីស្រឡាង និងសំខាន់បំផុតចំពោះបញ្ហាការប្រែប្រួលអាកាសធាតុ។ វាបានផ្តល់ការលើកទឹកចិត្តជាវិជ្ជមានក្នុងទំរង់ជាការផ្ទេរហិរញ្ញប្បទានទៅឱ្យបណ្តាប្រទេសកំពុងអភិវឌ្ឍ ដើម្បីកាត់បន្ថយអត្រានៃការកាប់បំផ្លាញព្រៃឈើ និងការបាត់បង់ព្រៃឈើ ដើម្បីកាត់បន្ថយការសាយភាយនៃឧស្ម័នផ្ទះកញ្ចក់ GHGs (ការកាត់បន្ថយ)។ គោលនយោបាយ និងវិធានការដែលស្ថិតនៅក្រោម REDD រួមមានការបង់ថ្លៃការប្រើប្រាស់សេវាបរិស្ថាន(PES) ការគ្រប់គ្រងកសិកម្ម និងនិរន្តរភាពព្រៃឈើ។

## ៧.៤ ប្រព័ន្ធដោយផ្អែកលើទីផ្សារ និងវិស័យឯកជនសម្រាប់ផ្តល់ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ

ពិធីសារទីក្រុងក្យូតូនៅក្នុងការបង្កើតយន្តការនៃការអនុវត្តស្របគ្នាចំនួន ៣ រួមមានប្រតិបត្តិការរួម (JI) ការធ្វើអាជីវកម្មលើការសាយភាយឧស្ម័ននិងCDMបានជួយជំរុញទីផ្សារសម្រាប់ពាណិជ្ជកម្មកាបូន។ ទីផ្សារពាណិជ្ជកម្មកម្រិតខ្ពស់គឺធ្វើឡើងក្នុងគោលបំណងដើម្បីជួយសំរួលដល់ការទិញការសាយភាយឧស្ម័នពីបណ្តាប្រទេសដែលកំពុងអភិវឌ្ឍ (សូមមើលប្រអប់ទី៦)។ ជាពិសេស នេះគឺជាទីផ្សារមួយដែលងាយរងគ្រោះដែលមានការចូលរួមដ៏សកម្មនៃបណ្តាក្រុមហ៊ុនឯកជននៅលើពិភពលោក។ ហេដ្ឋារចនាសម្ព័ន្ធនៃទីផ្សារមានលក្ខណៈស្រដៀងគ្នាទៅនឹងកន្លែងទិញលក់ភាគហ៊ុន និងទីផ្សារភាគហ៊ុន។ វាត្រូវបានត្រួតត្រាដោយបណ្តាញនៃឈ្មួញកណ្តាល កន្លែងទិញ-លក់ភាគហ៊ុន និងបណ្តាក្រុមហ៊ុនដែលជាពិសេសក្រុមហ៊ុនដែលកំពុងរកឱកាសដើម្បីបង្កើតសកម្មភាពលើបញ្ហាការប្រែប្រួលអាកាសធាតុ។ ទីផ្សារនេះ មានតួនាទីជាច្រើនដែលស្រដៀងនឹងទីផ្សារភាគហ៊ុន។ យន្តការនៃការកំណត់តម្លៃរបស់វានឹងដើរតួធ្វើជាសញ្ញាមួយបង្ហាញទៅកាន់បណ្តាវិនិយោគិន និងម្ចាស់ជំនួយឱ្យជួយណែនាំពីការធ្វើការសម្រេចចិត្តវិនិយោគ។ ជាពិសេសវាគួរតែជួយជំរុញឱ្យមានការដាក់ទុនដ៏មានប្រសិទ្ធភាពក្នុងវិស័យនានា និងបណ្តាប្រទេសនានា។ វាបានផ្តល់នូវវិធីសាស្ត្រសម្រាប់ការគ្រប់គ្រងហានិភ័យ ក៏ដូចជាការដើរតួជាយានមួយក្នុងការទម្លាក់តម្លៃប្រតិបត្តិការ។

ការចូលរួមនៅក្នុងទីផ្សារអាចកើតឡើងនៅក្នុងកម្រិតខុសគ្នា។ កម្រិតនីមួយៗបញ្ជាក់អំពីតម្រូវការនៃការចូលរួមដ៏ជាក់លាក់ក៏ដូចជា ឧបសគ្គនានាដែលរាំងស្ទះដល់ការចូលរួម។ គន្លឹះនៅក្នុងការចូលរួមនោះ គឺលទ្ធភាពនៅក្នុងការយល់ដឹងចំណេះដឹង និងបទពិសោធន៍។ នៅពីក្រោយចំណុចចាប់ផ្តើមទាំងនេះ លទ្ធភាព និងការគ្រប់គ្រងលើដើមទុន និងធនធានសេដ្ឋកិច្ចផ្សេងៗទៀតនឹងក្លាយជាកត្តាបញ្ជាក់ ឬ រារាំងទៅដល់ការចូលរួមក្នុងកម្រិតទូលំទូលាយជាងនេះ។

### ប្រអប់ទី៥ យន្តការទីផ្សារ ក្រោមពិធីសារក្យូតូ

- អាជីវកម្មលើការសាយភាយឧស្ម័ន៖ ដោយមានចែងនៅក្នុងមាត្រាទី១៧ នៃពិធីសារក្យូតូ ការធ្វើអាជីវកម្មលើការបញ្ចេញឧស្ម័នបានអនុញ្ញាតឱ្យបណ្តាប្រទេសនានាដែលមានអង្គភាពបញ្ចេញឧស្ម័នអាចប្រើបានដោយមិនគិតថ្លៃទៅតាមការកំណត់ ប៉ុន្តែមិនត្រូវប្រើដើម្បីលក់សមត្ថភាពដែលនៅសល់ទៅឱ្យបណ្តាប្រទេសដែលប្រើហួសពីការកំណត់របស់ពួកគេឡើយ។ ហេតុដូច្នេះហើយ ទំនិញថ្មីមួយត្រូវបានបង្កើតឡើងក្នុងទំរង់ជាការកាត់បន្ថយ ឬ ការលុបបំបាត់ការសាយភាយឧស្ម័ន។ ដោយសារតែ ឧស្ម័នកាបូន ឌីអុកស៊ីត គឺជាឧស្ម័នផ្ទះកញ្ចក់ដ៏ចម្បង ទើបមនុស្សទូទៅនិយាយជាធម្មតាលើការធ្វើអាជីវកម្មលើឧស្ម័នកាបូន។ ឧស្ម័នកាបូនពេលនេះត្រូវបានគេស្គាល់ និងធ្វើអាជីវកម្ម ដូចជាទំនិញផ្សេងៗទៀតដែរ។ វាត្រូវបានគេស្គាល់ថាជា "ទីផ្សារកាបូន"។
- យន្តការអភិវឌ្ឍស្អាត (CDM)៖ ដូចដែលបានចែងនៅក្នុងមាត្រាទី១២ នៃពិធីសារប្រទេសដែលមានធន្ទះនៅក្នុងការកាត់បន្ថយការសាយភាយឧស្ម័នពុល ឬ ការកំណត់ការបញ្ចេញចោល ដែលស្ថិតនៅក្រោម ពិធីសារក្យូតូ (ឧបសម្ព័ន្ធ B Party) អាចដាក់អនុវត្តគម្រោងកាត់បន្ថយការបញ្ចេញចោលនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។ គម្រោងបែបនេះអាចសន្សំឥណទាននៃការកាត់បន្ថយការបញ្ចេញចោលដែលមានការអនុញ្ញាត (CER) ដែលអាចលក់បានគម្រោងនីមួយៗមានតម្លៃស្មើនឹងកាបូនឌីអុកស៊ីតចំនួនមួយតោនដែលអាចរាប់បានថាជាការសម្រេចបាននូវគោលដៅរបស់ពិធីសារក្យូតូ។ សកម្មភាពនៃគម្រោង CDM អាចរួមបញ្ចូលឧទាហរណ៍ដូចជា គម្រោងដាក់ឱ្យប្រើប្រាស់អគ្គិសនីនៅតាមតំបន់ដាច់ស្រយាលដោយប្រើប្រាស់បន្ទះសូឡា ឬ ការបំពាក់នូវឧបករណ៍ផលិតចរន្តអគ្គិសនីដោយចំហាយទឹកដែលសន្សំសំចៃថាមពលបានច្រើន។
- ការអនុវត្តរួមគ្នា (JI)៖ បើតាមយន្តការដែលត្រូវបានគេស្គាល់ថាជា "ការអនុវត្តរួមគ្នា" ដែលមានចែងនៅក្នុងមាត្រាទី៦ នៃពិធីសារក្យូតូ ប្រទេសដែលមានធន្ទះនៅក្នុងការកាត់បន្ថយ និងកំណត់ការបញ្ចេញឧស្ម័នពុលដែលស្ថិតនៅក្រោម ពិធីសារក្យូតូ (ឧបសម្ព័ន្ធ B Party) អាចទទួលបានអត្ថប្រយោជន៍សម្រាប់អង្គភាពកាត់បន្ថយការបញ្ចេញចោលឧស្ម័នពុលពីគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នពុល ឬ លុបបំបាត់ការបញ្ចេញឧស្ម័នពុលនៅក្នុងចំណុចមួយទៀតនៃឧបសម្ព័ន្ធ B Party ដែលគម្រោងនីមួយៗទទួលបានអត្ថប្រយោជន៍ មានតម្លៃស្មើនឹងកាបូនឌីអុកស៊ីតចំនួន១តោនដែលរាប់បានថា ជាការសម្រេចបាននៅគោលដៅរបស់ពិធីសារក្យូតូ។ JI បានផ្តល់ឱ្យភាគីនីមួយៗនូវមធ្យោបាយដ៏បត់បែន និងសន្សំសំចៃប្រាក់ នៅក្នុងការបំពេញផ្នែកមួយនៃធន្ទះរបស់ពួកគេនៅក្នុងពិធីសារក្យូតូ ចំណែកភាគីធំៗវិញអាចទទួលបានអត្ថប្រយោជន៍ពីវិនិយោគបរទេស និងការផ្ទេរបច្ចេកវិទ្យា។

*ប្រភព៖ UNFCCC database*

## ប្រអប់ទ៦ ទីផ្សារហិរញ្ញវត្ថុកាបូន

បច្ចុប្បន្ននេះ ទីផ្សារកាបូនត្រូវបានគ្រប់គ្រងដោយបណ្ដាក្រុមភាគហ៊ុនសាន្តដូចជា ការប្រែប្រួលអាកាសធាតុនៅអឺរ៉ុបជាដើម។ ការប្រែប្រួលអាកាសធាតុនៅអឺរ៉ុប គឺជាទីផ្សារចម្លងមួយសម្រាប់ទ្វីបអឺរ៉ុប ហើយជាក្រុមហ៊ុនដែលធំជាងគេ។ ក្រុមហ៊ុននេះ និងក្រុមហ៊ុនតូចៗដូចជា ក្រុមហ៊ុនកម្មវិធីផ្លាស់ប្ដូរអាកាសធាតុឈីកាកូ ទីផ្សារសម្រាប់អាកាសធាតុឈីកាកូ (CCX) គឺស្ថិតនៅក្នុងចង្កោមនៃបណ្ដាក្រុមហ៊ុនសកល។ ទីផ្សារអនាគតសម្រាប់អាកាសធាតុឈីកាកូ (CCFE) គឺជាអនាគតក្រុមហ៊ុននៃការចម្លងបរិស្ថាន (វិធីសាស្ត្រផ្ដល់ហិរញ្ញប្បទានលើឧស្ម័នកាបូន (CFI)) កម្មវិធីផ្ដួចផ្ដើមឧស្ម័នផ្ទះកញ្ចក់ថ្នាក់តំបន់ (RGGI) ការកាត់បន្ថយឧស្ម័នដែលបានបញ្ជាក់ (CER) និងថវិកាអឺរ៉ុប ។ ក្រុមហ៊ុន TCX គឺជាក្រុមហ៊ុនរួមទុនជាមួយនឹងក្រុមហ៊ុនសាជីវកម្មប្រេងជាតិរបស់ប្រទេសចិន និងក្រុមហ៊ុន City of Tianjin ។ ក្រុមហ៊ុន MCeX គឺជាក្រុមហ៊ុនរួមទុនជាមួយនឹងក្រុមហ៊ុន Montreal Exchange ។ ក្រុមហ៊ុន India Climate Exchange™ កំពុងស្ថិតនៅក្នុងការអភិវឌ្ឍ។ គម្រោងមួយត្រូវតែគោរពទៅតាមស្តង់ដានៃសិទ្ធិចូលរួម និងឆ្លងកាត់ការបញ្ជាក់ដោយឯករាជ្យ ដើម្បីទទួលបានផ្លាកសញ្ញាពាណិជ្ជកម្មលើកម្មវិធី CCX Offsets Program ។ Verified offset projects ដែលផ្តាច់ ឬ លុបបំបាត់ឧស្ម័នផ្ទះកញ្ចក់នឹងទទួលអត្ថប្រយោជន៍ជា CFIs ដែលមានភាពងាយស្រួលនៅក្នុងការក្លាយជាសមាជិករបស់ CCX ។

ឧបសគ្គនៃការចូលរួមនៅក្នុងកម្មវិធី CCX Offsets Program រួមមាន កត្តាតម្លៃ (ការបញ្ជាក់ លទ្ធភាព និងប្រតិបត្តិការ) និងកង្វះចំណេះដឹងអំពីទីផ្សារ (ការចុះបញ្ជី ការបញ្ជាក់ ដំណើរការ)។ បណ្ដាក្រុមហ៊ុនដែលជាសមាជិកនៃ offset (Offset aggregators) គឺបណ្ដាអង្គភាពដែលបំរើការជាតំណាងរដ្ឋបាលក្នុងនាមជាពហុម្ចាស់នៃគម្រោង (offset generating projects)។ នៅពេលបណ្ដាក្រុមហ៊ុនសមាជិក រួមបញ្ចូលគ្នានូវគម្រោងតូចៗជាច្រើន ពួកគេនឹងធ្វើយ៉ាងណាឱ្យចំណាយពេលវេលា និងថវិកាតិចបំផុត និងប្រើប្រាស់ចំណេះដឹងលើទីផ្សារ និងដំណើរការនៃទីផ្សាររបស់ពួកគេ។ តម្លៃប្រតិបត្តិការអាចនឹងខ្ពស់ខ្លាំងសម្រាប់អ្នកទិញក្នុងការដោះស្រាយជាមួយម្ចាស់គម្រោងមួយៗ។ មានក្រុមហ៊ុនសមាជិក offset (offset aggregators) ជាង៧៥ កំពុងធ្វើប្រតិបត្តិការក្នុងពេលបច្ចុប្បន្ននេះ។

គន្លឹះនៅក្នុងការទៅកាន់ទីផ្សារកាបូនគឺ ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ និងការបង្កើតយ៉ាងទូលំទូលាយ (តួនាទីនៃពេលវេលា និងការយល់ដឹង)។ ការបង្កើតកម្មវិធីត្រូវមានលក្ខណៈទូលំទូលាយ អនុញ្ញាតឱ្យមានការទទួលយកនូវការកាត់បន្ថយនានាពីក្រៅតំបន់ និងលើកទឹកចិត្តដល់ការផ្លាស់ប្តូរការប្រព្រឹត្តនៅខាងក្រៅឧស្សាហកម្ម។ ហេដ្ឋារចនាសម្ព័ន្ធទីផ្សារកំពុងតែស្ថិតនៅក្នុងការអភិវឌ្ឍ។

ការផ្តុំគ្នា និងគំរូរបស់ក្រុមហ៊ុនសមាជិក គឺជាវិធីមួយនៅក្នុងការអនុញ្ញាតឱ្យមានការចូលរួមប្រកបដោយអត្ថន័យសម្រាប់បណ្ដាក្រុមហ៊ុនតូចៗនៅក្នុងកម្មវិធី CCX Offsets Program ។ វាបានផ្ដល់នូវលទ្ធភាពក្នុងការទទួលបាននូវការកាត់បន្ថយមួយដែលមានការសន្សំសំចៃពីបណ្ដាគម្រោងនានាតាមរយៈការចែករំលែកនូវហានិភ័យ ការចំណាយ និងអត្ថប្រយោជន៍។ ឧទាហរណ៍នៃគម្រោង offset នៅមុនពេលលេចជារូបរាងរួមមាន៖

- កន្លែងចាក់សំរាម កសិកម្ម និង coal mine methane destruction;
- ការគ្រប់គ្រងកាបូន ៖ ការដាំដើមឈើឡើងវិញ ការដាំកូនឈើ ជីកសិកម្ម
- ការកែច្នៃថាមពលដើម្បីប្រើប្រាស់ឡើងវិញ
- ការផ្លាស់ប្តូរការប្រើប្រាស់ឥន្ទនៈ និងការសន្សំសំចៃថាមពល។

*ប្រភព៖ GCCA, 2008.*

ចំពោះធនធាន សាធារណៈនៃការផ្ដល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុ កត្តាសំខាន់ៗដើម្បីទាក់ទាញការចាប់អារម្មណ៍ពីសំណាក់ហិរញ្ញវត្ថុឯកជនរួមមាន ការយល់ដឹង សញ្ញាតម្លៃដែលមានតម្លាភាព ក្បួនច្បាប់ដែលមានស្ដង់ដាតឹងរឹង និងច្បាស់លាស់ និងការលើកទឹកចិត្ត។ កត្តាទាំងនេះធ្វើឱ្យការអភិវឌ្ឍមានការជឿជាក់ ប្រសិទ្ធភាព និងលទ្ធភាព និងតម្លៃប្រតិបត្តិការទាបនៃការផ្ដល់ប្រាក់លើជម្រើសដ៏មានអត្ថប្រយោជន៍មួយក្រុមសម្រាប់ការវិនិយោគ។

បណ្ដាភ្នាក់ងារដែលចាប់អារម្មណ៍លើវិស័យសាធារណៈ ក៏ចូលរួមនៅក្នុងទីផ្សារកាបូនផងដែរ។ ឧទាហរណ៍ធនាគារពិភពលោកគ្រប់គ្រងជាង ២ ពាន់លានដុល្លារ លើមូលនិធិ និងការសម្របសម្រួលចំនួន១២។ ធនាគារនេះទទួលបានមូលនិធិរបស់ខ្លួនពីរដ្ឋាភិបាលចំនួន១៦ និងក្រុមហ៊ុនឯកជនចំនួន៦៦។ គម្រោងអាស្រ័យទីផ្សារ ឬ គម្រោងកាបូនថ្មីចំនួន ២ របស់ធនាគារនេះមានកម្មវិធីភាពជាដៃគូសម្រាប់កាបូនដែលភាយចេញពីព្រៃឈើ (FCPF) និងកម្មវិធីភាពជាដៃគូនៃកាបូន (CPF)។

គម្រោង FCPF ផ្ដោតការយកចិត្តទុកដាក់លើការកាប់បំផ្លាញព្រៃឈើ ចំណែកឯ គម្រោង CPF ផ្ដោតការយកចិត្តទុកដាក់លើការគ្រប់គ្រងថាមពល និងសំណល់។ គម្រោង FCPF បានស្វែងរកមធ្យោបាយដើម្បីទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ តាមរយៈការផ្សាភ្ជាប់សមត្ថភាព និងការប៉ះប៉ូវសងជម្ងឺចិត្តដល់ប្រទេសកំពុងអភិវឌ្ឍចំពោះការកាត់បន្ថយការបញ្ចេញឧស្ម័នពុលដែលបណ្ដាលមកពីការកាប់បំផ្លាញព្រៃឈើ និងការបាត់បង់ព្រៃឈើ។ សកម្មភាពរបស់ CPF រួមមាន ការលើកកម្ពស់ការសន្សំសំចៃថាមពល ចំហេះឧស្ម័ន ការដឹកជញ្ជូន និងការអភិវឌ្ឍតំបន់ទីក្រុង។ នៅក្នុងផែនការទីផ្សារកាបូន European Union's Emission Trading scheme (ETS) បានទទួលខុសត្រូវលើទឹកប្រាក់ជាង ៦០ ពាន់លានដុល្លារ ដែលប្រហាក់ប្រហែលនឹង ៧០% នៃតម្លៃទីផ្សារកាបូនសកល។



## ៧.៥ បញ្ហាសង្គម អភិវឌ្ឍ និងយេនឌ័រ និងតួនាទីរដ្ឋក្នុងការធ្វើហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ

មានបញ្ហាប្រឈមជាច្រើនចំពោះការអភិវឌ្ឍយេនឌ័រ និងសង្គម ជុំវិញមូលនិធិ និងមូលនិធិបន្ទាប់បន្សំនៃបញ្ហាការប្រែប្រួលអាកាសធាតុផ្សេងៗ វិធីសាស្ត្រ និងយន្តការចែកចាយការបង្កើតការផ្ដល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុសកល។ រចនាសម្ព័ន្ធគ្រប់គ្រងនៃការផ្ដល់ហិរញ្ញប្បទានបានរកមធ្យោបាយដើម្បីលើកកម្ពស់ការធ្វើឱ្យបរិស្ថានល្អ ដើម្បីការពាររូបភាពមិនល្អនៃការខូតខាតដែលកើនឡើងយ៉ាងឆាប់រហ័ស និងដែលមិនអាចត្រលប់ក្រោយបាននៅក្នុងតុល្យភាពសេដ្ឋកិច្ច និងបរិស្ថាននៃភពផែនដី។ មានកង្វល់ធ្ងន់ធ្ងរជាច្រើនបានលើកឡើងថាតើសកម្មភាព គម្រោង និងគោលនយោបាយ ដែលកំពុងតែបង្កើតឱ្យមាននេះនឹងប៉ះពាល់ទៅលើបញ្ហារយៈពេលវែងនៃការលុបបំបាត់ភាពក្រីក្រ និងសមភាពសង្គម និងយេនឌ័រយ៉ាងណា។ តើបញ្ហាទាំងនេះ នឹងបំពេញឱ្យគ្នាទៅវិញទៅមកដែរឬទេ ឬ តើវានឹងប្រកួតប្រជែង និងប៉ះទង្គិចគ្នាខ្លាំងក្លាលើរបៀបវារៈណាមួយដែរឬទេ?

បើតាមទស្សនៈនៃការអភិវឌ្ឍ សង្គម និងយេនឌ័រ យ៉ាងហោចណាស់មានតំបន់អាទិភាពធំៗ៥នៃកង្វល់នៅក្នុងបញ្ហានេះ។

ទី១ នឹងមានកង្វល់អំពីសភាពនៃការបែងចែកគ្នានៃប្រព័ន្ធផ្ដល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុ។

ជាបន្តបន្ទាប់ នឹងមានការទទួលស្គាល់ទៅលើតម្រូវការក្នុងការធ្វើឱ្យយន្តការសហប្រតិបត្តិការបានប្រសើរជាងមុន ដែលជាភាពងាយស្រួល និងធ្វើឱ្យមានស្តង់ដានៃមូលនិធិ គោលនយោបាយ និងនីតិវិធីផ្សេងៗ។

ការបង្កឱ្យមានភាពងាយស្រួល និងទំនាក់ទំនងល្អប្រសើរជាងមុននៃដំណើរការនេះនឹងធ្វើឱ្យបណ្តាប្រទេសកំពុងអភិវឌ្ឍដែលក្រីក្រនឹងចូលរួមឱ្យបានកាន់តែមានប្រសិទ្ធភាពនៅក្នុងប្រព័ន្ធតាមរយៈលក្ខខណ្ឌផ្ទាល់របស់ពួកគេ។

វានឹងបន្តជួយទៅដល់ការទទួលខុសត្រូវ តម្លាភាព នៅក្នុងយេនឌ័រ និងគោលបំណងសមភាពសង្គម។

ទីពីរ មានភាពតានតឹង និងផ្ទុយគ្នារវាងការជំរុញឱ្យមានបច្ចេកវិទ្យាដែលងាយស្រួលសម្រាប់អាកាសធាតុដែលកាត់បន្ថយការបញ្ចេញឧស្ម័នពុល និងដំណាក់កាលនៃការបញ្ចេញឧស្ម័នពុលខ្លាំងនៃការអភិវឌ្ឍដែលបណ្តាប្រទេសកំពុងអភិវឌ្ឍជាច្រើនកំពុងតែប្រឈម។ មានការលំអៀងចំពោះការបរិច្ចាគដែលត្រូវបានធ្វើឡើងក្នុងទំរង់ជាការទទួលខុសត្រូវចំពោះបញ្ហានៃការធ្វើឱ្យមានការប្រែប្រួលអាកាសធាតុដោយខ្លួនឯង។ តើសេដ្ឋកិច្ច និងការកើនឡើងឌីណាមីករបស់ប្រទេសណាដែលត្រូវបន្ថយល្បឿន ជាមួយនឹងប្រទេសដែលនឹងត្រូវទទួលបានផលប្រយោជន៍ពីដំណើរការនៃដំណោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុដែលអាស្រ័យទីផ្សារ និងបច្ចេកវិទ្យាខ្ពស់? ដូច្នេះ តើយន្តការនៃការផ្តល់ហិរញ្ញប្បទានត្រូវផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់ការបំលែងខ្លួនទៅជាសេដ្ឋកិច្ចដែលមានកាបូនទាប ឬ ទៅលើទំរង់ផ្សេងៗទៀតនៃការកាត់បន្ថយការសាយភាយឧស្ម័នពុល។ បើតាមគោលបំណងនៃការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុ ដំណោះស្រាយគឺមិនស្ថិតនៅក្នុងករណីទាំងពីរនេះទេ គឺត្រូវផ្តោតការយកចិត្តទុកដាក់លើការប៉ះប៉ូវសងចំពោះការខូតខាតជាអាទិភាព ដែលបានបង្កឡើងដោយបណ្តាប្រទេសភាគឦសាន្ត ឬត្រូវយកចិត្តទុកដាក់លើការស្វែងរក និងការពង្រឹងចំណេះដឹងបែបប្រពៃណី បទពិសោធន៍ និងជំនាញនៃការបន្សាំ និងការកាត់បន្ថយ ដែលបានកើតឡើងអស់រយៈពេលជាយូរមកហើយនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។ ការផ្ទុកនូវចំណេះដឹងបែបនេះមាននៅក្នុងបណ្តាសហគមន៍ និងក្នុងគ្រួសារក្នុងតំបន់ជាច្រើននៃតំបន់ទក្សិណទាំងមូល។ ស្ត្រីនៅក្នុងសហគមន៍ជាច្រើនក៏ជាអ្នកថែរក្សា និងជាអ្នកអនុវត្តនៃចំណេះដឹងបែបនេះដែរ។

ទី៣ យន្តការនៃការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុក៏អាចនឹងត្រូវបានបង្ហាញឱ្យឃើញនៅក្នុងការបន្តកើនឡើងនូវបំណុលឯករាជ្យនៅក្នុងបរិបទដែលបណ្តាប្រទេសកំពុងអភិវឌ្ឍជាច្រើន ដោយរាប់បញ្ចូលទាំងប្រទេសដែលមានប្រាក់ចំនូលទាប និងមធ្យម កំពុងតែជាប់បំណុលខ្ពស់ស្រាប់ទៅហើយ និងត្រូវប្រតិបត្តិការជាមួយនឹងភាគរយនៃនិរន្តរភាពបំណុលដែលមានការសង្ស័យ។ កត្តាដែលបង្កជាបញ្ហាសំខាន់នៅទីនេះគឺយន្តការផ្តល់ហិរញ្ញប្បទានដែលជាប់ពាក់ព័ន្ធយ៉ាងច្បាស់នៅក្នុងការឱ្យខ្ចីក៏ដូចជា បំណុលទាំងឡាយដែលបានគាំទ្រដោយ ឌីណាមីក នៃសហហិរញ្ញប្បទាន។ បញ្ហាសំខាន់មួយទៀតដែលត្រូវលើកមកនិយាយនៅទីនេះ គឺការគំរាមគំហែងនៃការជំនួសការផ្តល់ហិរញ្ញប្បទានអភិវឌ្ឍដោយការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ដល់សមភាពសង្គម និងយេនឌ័រ។ តាមប្រវត្តិសាស្ត្រការជៀតជ្រែកនៃការអភិវឌ្ឍសង្គម និងសមភាពយេនឌ័រនៅតាមបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួចជាច្រើនបានពឹងផ្អែកខ្ពស់ទៅលើជំនួយ និងលំហូរហិរញ្ញវត្ថុសាធារណៈជាបន្តបន្ទាប់។

ទី៤ បច្ចុប្បន្ននេះមានឱនភាពប្រជាធិបតេយ្យខ្លាំងនៅក្នុងប្រព័ន្ធនៃការគ្រប់គ្រងហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ។ យន្តការ និងមូលនិធិភាគច្រើនមិនបានធានានូវសម្លេង និងការចូលរួមរបស់ម្ចាស់ភាគហ៊ុនសំខាន់ៗនៅក្នុងការបង្កើត

ការរៀបចំ ការអនុវត្ត តាមដានលើគម្រោង និងកម្មវិធីនានាដែលបានផ្តល់ហិរញ្ញប្បទាននោះទេ។ សំខាន់ជាងនេះទៅទៀត មូលនិធិ និងយន្តការទាំងឡាយជាដំណើរការដែលមានប្រសិទ្ធភាពបំផុតចំពោះការអភិវឌ្ឍ ការកាត់បន្ថយភាពក្រីក្រ និងដើមទុន និងលទ្ធផលដែលមិនរើសអើង យេនឌ័រនោះគឺត្រូវបានទទួលធនធានតិចតួច និងងាយរងគ្រោះខ្លាំង។ ឧទាហរណ៍ មូលនិធិបន្សាំគឺមិនត្រូវបានទទួលធនធានគ្រប់គ្រាន់នោះទេ ហេតុនេះហើយវាត្រូវប្រឹងប្រែងដើម្បីបំពេញតួនាទី ផ្នែករដ្ឋបាលរបស់ខ្លួន។

ជាអកុសលការអនុវត្តដែលមានហិរញ្ញប្បទានតិចតួច ជាពិសេសការអនុវត្តនៅក្នុងយុទ្ធសាស្រ្តកាត់បន្ថយ បានលើកទឹកចិត្តដល់ការចូលរួមថ្នាក់តំបន់ និងខ្លួនឯងផ្ទាល់ ពឹងផ្អែកលើដំណើរការនៃការចាប់ផ្តើមចេញពីចំណុចធំមកមុន។ ឧទាហរណ៍ បើតាមការកត់សម្គាល់ដោយសកម្មជនយុត្តិធម៌នៃបញ្ហា អាកាសធាតុ គម្រោងផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុរបស់ធនាគារពិភពលោកត្រូវពឹងផ្អែកលើភាគរយនៃ GDP ដូច្នេះត្រូវបដិសេធចំពោះធនធានរបស់ប្រទេសក្រីក្រដែលជាប់មកជាមួយ។ លើសពីនេះទៅទៀតការដាក់អនុវត្តន៍ និងត្រួតពិនិត្យលើដំណើរការនៃការប្រើប្រាស់មូលនិធិដែលផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុភាគច្រើនហាក់ដូចជាមានភាពស្មុគស្មាញបន្តិច និងតម្រូវឱ្យមានការបែងចែកមូលនិធិក្នុងកម្រិតខ្ពស់ មិនមានការលើកទឹកចិត្តចំពោះលទ្ធភាពមិនមែនរដ្ឋបាលឱ្យទទួលប្រើប្រាស់មូលនិធិ។

វិធីសាស្រ្តនេះត្រូវបានប្រើប្រាស់ ជាពិសេសសម្រាប់អង្គការក្រៅរដ្ឋាភិបាលតូចៗ និងដែលត្រូវការធនធានជាចាំបាច់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។ មានការលំអៀងលើស្ថាប័នដោយគាំទ្រលើអង្គការក្រៅរដ្ឋាភិបាលនៃតំបន់ភាគឦសាន្តដោយបង្កើតប្រតិបត្តិការដែលមានហិរញ្ញប្បទានច្រើន និងទ្រង់ទ្រាយធំ។ ហេតុដូច្នេះ វាមិនទាន់គ្រប់គ្រាន់នៅឡើយទេបើយើងនិយាយថា នៅក្នុងគម្រោងនេះ សម្លេង អាទិភាព និងកង្វល់នានានៃមនុស្ស និងស្រ្តី នៅក្នុងតំបន់ជាញឹកញាប់ត្រូវដឹងក្រោយគេ ហើយត្រូវបានឆ្លើយតបតិចតួចបំផុតនោះ។

ទី៥ ដូចដែលបានកត់សម្គាល់ខាងលើ មាននិន្នាការដែលផ្តល់ភាពលំអៀងទៅលើប្រព័ន្ធនៃការកាត់បន្ថយដើម្បីបង្រួមតូចនូវសិទ្ធិ និងជីវភាពរបស់ស្រ្តី មនុស្សក្នុងតំបន់ ដោយគាំទ្រគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗដែលមានបច្ចេកវិទ្យាខ្ពស់។ ជាទូទៅ បញ្ហានេះមិនមែនមានបំណងរើសអើស ឬ ចង់បង្រួមឱ្យតូចនោះទេ គឺដោយសារមិនបានដឹង និងគ្មានឆន្ទៈនៅក្នុងការរាប់បញ្ចូលនូវបញ្ហាស្ថានភាពប្រវត្តិសាស្រ្ត ឬ លទ្ធផលនៃការរើសអើងផ្នែកយេនឌ័រដែលបានជះឥទ្ធិពលដល់ស្ថានភាពបច្ចុប្បន្នរបស់ស្រ្តី និងមនុស្សក្នុងតំបន់ ទាក់ទងនឹងការអប់រំ ដីធ្លី ព្រៃឈើ និងធនធានសេដ្ឋកិច្ចផ្សេងៗទៀត។

ហេតុនេះហើយបានជាទស្សនៈនៃយេនឌ័រ និងសិទ្ធិមនុស្សត្រូវតែចាត់ទុកជាបញ្ហាចម្បង និងត្រូវរួមបញ្ចូលគ្នាទៅជាផែនការយុទ្ធសាស្រ្តនៃមូលនិធិសម្រាប់ការបន្សាំ និងការកាត់បន្ថយជាពហុភាគី ដែលត្រូវបានដាក់អនុវត្តដោយធនាគារពិភពលោក និង GEF-UN។ បញ្ហានេះក៏ពាក់ព័ន្ធផងដែរជាមួយនឹងទីផ្សារកាបូន។ សរុបមក ដើម្បីឱ្យការផ្តល់ហិរញ្ញប្បទានលើបញ្ហាការប្រែប្រួលអាកាសធាតុមានឥទ្ធិពលវិជ្ជមានលើមនុស្សក្នុងតំបន់ និងលើកកម្ពស់សេដ្ឋកិច្ចរបស់ស្រ្តី និងការពង្រឹងអំណាចសង្គម នោះបញ្ហាសំខាន់នៃតម្លាភាព និងទំនួលខុសត្រូវនៅក្នុងកម្រិតពហុភាគី ទ្វេភាគី និងថ្នាក់ជាតិ ទំនួលខុសត្រូវសង្គមដែលមានកិច្ចសហការណ៍ការបង្កើនសមត្ថភាព និងការគាំទ្រចំពោះជំនួយឧបត្ថម្ភត្រូវតែទទួលបានការដោះស្រាយ។ ផ្នែកបន្ទាប់នឹងបរិយាយពីបញ្ហាទាំងនេះដោយផ្តោតការយកចិត្តទុកខ្លាំងលើស្រ្តី។

## ៧.៦ យេនឌ័រ និងតួនាទីរដ្ឋក្នុងការធ្វើហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ

ដូចដែលបានកំណត់ក្នុងផ្នែកខាងលើ វាមានភាពលម្អៀងជាក់លាក់មួយចំនួននៅក្នុងការងារក្នុងវិស័យប្រតិបត្តិការនៃការធ្វើហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ ដែលភាពលម្អៀងទាំងនោះមានទាំងខាងរចនាសម្ព័ន្ធ និងខាងស្ថាប័ន។

១/ វិស័យសាធារណៈ និងវិស័យឯកជនលម្អៀងលើ និងផ្តល់អាទិភាពលើការកាត់បន្ថយច្រើនជាងការសម្របសម្រួលខ្លួន។ ដូច្នេះ វាមិនសូវមានប្រាក់សម្រាប់ការសម្របសម្រួលនោះទេ។

២/ មានសេចក្តីលម្អៀងលើវិស័យថាមពល និងគម្រោងធំៗ។ ជាលទ្ធផលនៃសេចក្តីលម្អៀងទាំងពីរនេះ បណ្តាក្រុមសហគមន៍ អង្គការក្រៅរដ្ឋាភិបាលមកពីភាគខាងត្បូង និងសូម្បីតែក្រុមស្ត្រី ត្រូវគេសង្កេតឃើញថាមានកម្រិតសកម្មភាពក្នុងការធ្វើហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុតិចតួច។

៣/ មានសេចក្តីលម្អៀងខាងបុរសគ្រប់ទីកន្លែងដែលជ្រៀតចូលគ្រប់ផ្នែកនៃរចនាសម្ព័ន្ធការធ្វើហិរញ្ញប្បទាន ការប្រែប្រួលអាកាសធាតុ។

ភាពលម្អៀងខាងបុរសកើតចេញពីសេចក្តីលម្អៀងនៃគោលនយោបាយគ្រឹះនៃការប្រែប្រួលអាកាសធាតុ។ គោលនយោបាយបរិយាកាសមានទិន្នាការ ស្វែងរកការប្រែប្រួលអាកាសធាតុដែលមានលក្ខណៈជាការខិតខំខ្នះខ្នែងបែបវិទ្យាសាស្ត្រ បច្ចេកទេស យេនឌ័រ និងអព្យាក្រឹតសុទ្ធសាធ។ ប៉ុន្តែ ការដោះស្រាយលើការប្រែប្រួលអាកាសធាតុ គឺត្រូវផ្លាស់ប្តូរ និងកែតម្រូវអាកប្បកិរិយាមនុស្ស ត្រូវធ្វើឱ្យមានតុល្យភាពរវាងប្រភេទផ្សេងៗគ្នានៃសកម្មភាពសេដ្ឋកិច្ច សង្គម និងត្រូវធ្វើការសម្រេចថា តើសកម្មភាពណាខ្លះមានប្រយោជន៍ដល់ទិន្នផលសេដ្ឋកិច្ចសរុប។ ដូចដែលបានកំណត់ក្នុងជំពូកទី១ ទាំងនេះ គឺត្រូវផ្អែកលើការវិនិច្ឆ័យ តម្លៃដែលមានលក្ខខណ្ឌកំណត់លើមនោគមវិជ្ជាយេនឌ័រ និងប្រព័ន្ធយេនឌ័រទូទៅក្នុងកម្រិតថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ ការរើសអើងយេនឌ័រ និងជំនឿយេនឌ័រ មានគ្រប់ក្នុងកម្រិតទាំងនេះ និងគ្រប់ស្ថាប័ន រដ្ឋាភិបាលទាំងអស់។ ករណីនេះ មានច្រើនគ្រប់ទីកន្លែងនៅក្នុងអ្វីដែលគេហៅថា វិស័យបច្ចេកទេស មិនថានៅក្នុងគោលនយោបាយម៉ាក្រូ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ នៅក្នុងវិទ្យាសាស្ត្រឡើយ។

**ប្រអប់ទី៧** គំនិតខុសលើយេនឌ័រដែលពង្រឹងទីផ្សារហិរញ្ញវត្ថុ

- ស្ត្រីមានសមត្ថភាពជោគជ័យខាងសេដ្ឋកិច្ចតិចជាងបុរស
- ស្ត្រីជាឥណវន្ត (អ្នកខ្ចី) ប្រកបដោយហានិភ័យ
- ស្ត្រីខ្ចីសម្រាប់ចំណាយដោយគ្មានសមត្ថភាពសងវិញ។

ប៉ុន្តែ ការពិតគឺថា៖

- ស្ត្រីនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍមានអត្រាសងប្រាក់វិញខ្ពស់ជាងបុរស (ខ្ពស់ជាង ៩៧%)
- ស្ត្រីខ្ចីក្នុងគោលបំណងសន្ទនិយភាពរយៈពេលខ្លី ហើយមានលំហូរសាច់ប្រាក់សងវិញរយៈពេលវែង
- ទំនិញប្រើប្រាស់ជាទូទៅត្រូវបម្លែងទៅជាទ្រព្យសម្ភារៈបរិក្ខារនៅក្នុងគ្រួសារ និងវិស័យក្រៅផ្លូវការ (ឧទាហរណ៍៖ ទូទឹកកក និងចង្ក្រាន ជាទូទៅត្រូវប្រើដើម្បីផលិតនិងលក់ទឹកកកទៅឱ្យអ្នកជិតខាង និងដើម្បីធ្វើម្ហូបលក់នៅក្នុងវិស័យក្រៅផ្លូវការ-ល-)។

ដូចដែលបានពិភាក្សាក្នុងផ្នែកទី១នៃជំពូកនេះ ទីផ្សារហិរញ្ញវត្ថុបង្ហាញពីនិន្នាការដូចគ្នា ចំពោះភាពមិនសូវសំខាន់នៃយេនឌ័រ ពោលគឺការប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវគំនិតខុសលើយេនឌ័រអំពីស្ត្រី តួនាទី និងការចូលរួមរបស់ពួកគេនៅក្នុងវិស័យសេដ្ឋកិច្ច (ប្រអប់៧)។ អាស្រ័យហេតុនេះ វាគ្មានការភ្ញាក់ផ្អើលទេដែលថា បញ្ហាទាំងនេះនៅតែបន្តមានលើសលប់នៅក្នុងហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុគ្រប់កម្រិតទាំងអស់នោះ។ វាជារឿងធម្មតាទៅហើយដែលថា វិស័យឯកជនមិនយកចិត្តទុកដាក់លើបញ្ហាយេនឌ័រទាល់តែសោះ។ ដូច្នេះ ទីផ្សារមានទំនោរមិនអើពើចំពោះផលប៉ះពាល់នៃសកម្មភាពរបស់ខ្លួនមកលើជម្រើសនៃការប្រើប្រាស់ដីធ្លី ចំណូលការប្រកបរបរចិញ្ចឹមជីវិត លទ្ធភាពចំណាយលើស្បៀងអាហាររបស់ស្ត្រី និងការចំណាយលើការរស់នៅពាក់ព័ន្ធផ្សេងៗ ក្នុងនោះរួមមានតម្លៃដីធ្លីផងដែរ។ គួរឱ្យស្តាយបញ្ហានេះ ក៏មានពិតជាក់ស្តែងនៅក្នុងគម្រោងដែលអនុវត្តដោយធនាគារពិភពលោកផងដែរ បើទោះបីជាមានការសិក្សាស្រាវជ្រាវជាច្រើនដែលថា ធនាគារពិភពលោកបានធ្វើការលើបញ្ហាយេនឌ័រ និងការអភិវឌ្ឍក៏ដោយ។

ជាការពិតណាស់ វាជាករណីមួយដែលថា ការធ្វើហិរញ្ញប្បទាន ការប្រែប្រួលអាកាសធាតុកើតឡើង នៅក្នុងបរិបទដែលសូម្បីតែនៅពេលដែលហិរញ្ញប្បទាននេះបានគិតគូរពិចារណាលើស្ត្រីក៏ដោយ ស្ត្រីនៅតែជាក្រុមងាយរងគ្រោះជំនួសក្រុមបរិស្ថាន និងកសិកម្មធំៗនៅក្នុងពិភពលោក។ ប៉ុន្តែគួរឱ្យស្តាយ ផ្នត់គំនិតរបស់កសិករប្រុស ពាណិជ្ជករជាបុរស និងមេគ្រួសារជាបុរស នៅតែបន្តមានលើសលប់នៅក្នុងគំនិតរបស់ក្រុមអ្នកធ្វើការសម្រេចលើការផ្តល់ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍ ក្នុងករណីនៃយន្តការធ្វើហិរញ្ញប្បទានដូចជា REDD ជាដើម វាសំខាន់ណាស់ក្នុងការវាយតម្លៃលើផលប៉ះពាល់យេនឌ័រ និងសង្គមដើម្បីធានាថា ស្ត្រីមិនបាត់ភាពជាម្ចាស់កម្មសិទ្ធិ និងការគ្រប់គ្រងដីធ្លី និងព្រៃ។ គោលបំណងសំខាន់មួយបង្កើតនៅក្នុងគម្រោងបែបនេះ គឺថាគម្រោងនេះមិនត្រូវបង្កផលប៉ះពាល់ដោយដេញ និងដកហូតកម្មសិទ្ធិរបស់ស្ត្រី និងប្រជាជនក្រីក្រក្នុងការគ្រប់គ្រងធនធានទាំងនេះតាំងពីដូនតា ពួកគេនោះឡើយដែលនេះជារឿងអាក្រក់បំផុត។ ប៉ុន្តែ ជារឿងល្អបំផុត គម្រោងបែបនេះគួរតែសំដៅលើកកម្ពស់ឋានៈក្នុងវិស័យសេដ្ឋកិច្ច និងសង្គមរបស់ស្ត្រី-បុរស។

ក្នុងករណីនៃទីផ្សារកាបូន បន្ទុកផ្ទាល់ៗខ្លួន គឺស្ថិតក្នុងកម្រិតសំខាន់មួយដែលស្ត្រី និងបុរសមានបរិមាណនៃការប្រើប្រាស់ និងបញ្ចេញកាបូនដូចគ្នា ។ អាស្រ័យហេតុនេះបញ្ហានៃសមធម៌នៃការចែករំលែកបន្ទុក មិនមានលើកឡើងឡើយ។ ប៉ុន្តែ សមធម៌នៃការចែករំលែកបន្ទុក ពិតជាបញ្ហាដ៏ធ្ងន់មួយដោយសារគេដឹងថា ស្ត្រី និងប្រជាជនក្រីក្រមានទំហំដីធ្លីគ្រប់គ្រងតិចជាង។ វិធីសាស្ត្រត្រូវបង្កើតឡើងដើម្បីពិចារណាលើចំណុចនេះ។ ឧទាហរណ៍ករណីនេះអាចរាប់បញ្ចូលគ្រឿងលើកទឹកចិត្តរបស់រដ្ឋាភិបាលដូចជា ការផ្អាកយកពន្ធ ការធ្វើសម្បទាន និងកម្មវិធីសម្បទានសម្រាប់ក្រុមស្ត្រី និងក្រុមជនជាតិភាគតិច។ នៅក្នុងបរិបទនៃទីផ្សារនេះ ការដាក់បញ្ចូលមូលនិធិរួមគ្នាដើម្បីបង្កើតវិធីសាស្ត្រ ផ្តល់មូលនិធិដែលផ្តោតសំខាន់លើស្ត្រី គឺជាជំហានមួយនៅក្នុងទិសដៅដ៏ត្រឹមត្រូវ។ ប៉ុន្តែ ការកែប្រែថ្មីនេះនឹងលេចចេញឡើងពីការយល់ដឹងកាន់តែច្រើន និងការអប់រំ និងការបណ្តុះបណ្តាលលើឌីណាមិចនៃទីផ្សារកាបូន ពីតួនាទី និងផលប៉ះពាល់របស់ទីផ្សារនេះ ព្រមទាំងកាលានុវត្តភាព និងកម្រិតព្រំដែននៃទីផ្សារនេះ។

### ប្រអប់ទី៨ អ្នកប្រមូលសរុប (Aggregators) និងយេនឌ័រ

គំនិត "រចនាសម្ព័ន្ធទីផ្សារផ្តុំគ្នា" ជាមួយនឹង "អ្នកប្រមូលសរុប" ដែលផ្សាភ្ជាប់ប្រតិបត្តិការតូចៗ ឬ លក្ខណៈមីក្រូទៅនឹងទីផ្សារកាបូន បង្ហាញពីលទ្ធភាពសម្រាប់គម្រោងទូទាត់សង (offset projects)ដើម្បីសម្រេចបានកម្មវិធីបរិស្ថាន និងសង្គម។ ឧទាហរណ៍ នៅក្នុងរដ្ឋកឺរ៉ាឡា ប្រទេសឥណ្ឌា (អង្គការក្រៅរដ្ឋាភិបាល Andhyodaya កំពុងលើកកម្ពស់ការទាញយកឧស្ម័នមេតាន និងការប្រើប្រាស់ឡជីវឧស្ម័នតាមគ្រួសារតូចៗនៅជនបទ។ ឧស្ម័នមេតាន ជំនួសប្រេងកាត ឬអុសសម្រាប់ចម្អិនអាហារ។ កតិកាសញ្ញានានាត្រូវបានចេញ ដោយផ្អែកលើការជំនួសការបញ្ចេញឥន្ទនៈផូស៊ីល។ គម្រោងនេះមានលក្ខណៈតូចពេកក្នុងកម្រិតតាមគ្រួសារនីមួយៗហួតដល់វាមិនអាចមានឱកាសចូលដល់ទីផ្សារកាបូនដោយគ្មានអ្នកប្រមូលសរុប។ ប៉ុន្តែ នៅក្នុងរចនាសម្ព័ន្ធទីផ្សារផ្តុំគ្នា គម្រោងនេះក្លាយជាទស្សនទានដ៏ទាក់ទាញមួយ។ ដំណាក់កាលទី១នៃគម្រោងនេះ មានគ្រួសារជនបទក្រីក្រចំនួន ១៥.០០០ គ្រួសារនៅភាគខាងត្បូងនៃប្រទេសឥណ្ឌា។ ចំណូលដុលប្រមាណជា ១,២ លានដុល្លារអាមេរិក ត្រូវបានបង្វែរសរុបមកកាន់អ្នកចូលរួមទាំងអស់។

បញ្ហាប្រឈមនៅទីនេះ គឺត្រូវធានាថា ការធ្វើការសម្រេចចិត្ត គឺស្ថិតក្នុងកណ្តាប់ដៃរបស់សហគមន៍ដែលយល់ដឹងពីយេនឌ័រ ឬ បណ្តាអង្គការស្ត្រីដែលពាក់ព័ន្ធ។

*ប្រភព៖ GCCA, 2008*

## សំណួរ និងបញ្ហាប្រឈមសំខាន់ៗកំពុងកើតមាន រួមមាន៖

- តើអង្គការស្ត្រីមានស្ថិរភាពហិរញ្ញវត្ថុយ៉ាងដូចម្តេច? ថវិកាអង្គការស្ត្រីភាគច្រើន មានលក្ខណៈតិចតួចដោយចំណូលប្រចាំឆ្នាំមានតិចជាង ៥០.០០០ ដុល្លារអាមេរិក (អង្គការសហប្រជាជាតិ ឆ្នាំ ២០០៧)។
- មូលនិធិមិនគ្រប់គ្រាន់សម្រាប់យេនឌ័រ និងការអភិវឌ្ឍ។ តើយើងត្រូវធានាយ៉ាងដូចម្តេចថា ក្រុមស្ត្រីមានសមត្ថភាពចូលរួមក្នុងកិច្ចពិភាក្សាគោលនយោបាយប្រកបដោយប្រសិទ្ធភាពដើម្បីផ្លាស់ប្តូរបរិស្ថានជំនួយ? តើយើងត្រូវធានាយ៉ាងដូចម្តេចថា ក្រុមស្ត្រីមានឱកាសទទួលបានព័ត៌មាន សំឡេង អាទិភាព ផលប្រយោជន៍ និងចំណេះដឹងរបស់ពួកគេបង្កើតឱ្យមានឥទ្ធិពល? តើពួកគេអាចរកបានមូលនិធិអាកាសធាតុកាន់តែច្រើនយ៉ាងដូចម្តេច?
- កំណែទម្រង់បញ្ហាយេនឌ័រនៃ GEF។
- ការវិភាគយេនឌ័រនៃហិរញ្ញវត្ថុសាធារណៈ។

ខណៈដែលបញ្ហាទាំងនេះគឺជាបញ្ហាដ៏ធំដោយមានកិច្ចសហការពីអ្នកជំនាញក្នុងវិស័យរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ ការយកពន្ធហិរញ្ញវត្ថុយេនឌ័រ វិស័យជារួមនៃយេនឌ័រ ម៉ាក្រូសេដ្ឋកិច្ច និងពាណិជ្ជកម្ម វាអាចមានលទ្ធភាពក្នុងការដោះស្រាយបញ្ហាទាំងនេះបានមួយចំនួន និងមានវត្ថុធាតុដើមអចិន្ត្រៃយ៍ទៅក្នុងការស្ថាបនាឡើងវិញនូវរបបហិរញ្ញប្បទានក្រោយឆ្នាំ ២០១២។

## ៧.៧ យេនឌ័រ និងរបបហិរញ្ញប្បទានប្រែប្រួលអាកាសធាតុក្រោយឆ្នាំ ២០១២

ការផ្លាស់ប្តូររំពឹងទុកមុនក្នុងរបបហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុសកល នឹងត្រូវដឹងដោយយោងតាមលទ្ធផលនៃការសន្និដ្ឋានចុងក្រោយនៃការពិភាក្សាសម្រេចនៅក្នុងសន្និសីទនៃភាគីពាក់ព័ន្ធ (COP-15) នៅរដ្ឋធានី Copenhagen កាលពីឆ្នាំ ២០០៩។ សេចក្តីសម្រេចនឹងត្រូវធ្វើឡើងដោយពិនិត្យលើទស្សនទានរួមគ្នាសម្រាប់ការប្រែប្រួលអាកាសធាតុសកល យុទ្ធសាស្ត្រ ទិសដៅ និងវិធានការសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នាពេលអនាគត (ចំនួន ២០% ត្រឹមឆ្នាំ ២០២០ ឬ ៥០% ត្រឹមឆ្នាំ ២០៣០ ឬ បទបញ្ញត្តិផ្សេងៗទៀតនៅអំឡុងឆ្នាំ ២០៥០) នៅក្រោយឆ្នាំ ២០១២។ ករណីទាក់ទងនឹងការធ្វើហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ ការសម្រេច និងការប្តេជ្ញានឹងត្រូវធ្វើឡើងផងដែរ អំពីប្រភេទនៃការគាំទ្រដែលមានសារៈសំខាន់ចំពោះដំណើរការ និងវិធានការរបស់រដ្ឋាភិបាលដូចជា NAPAs និងគំនិតផ្តួចផ្តើម និងបច្ចេកវិទ្យាកាត់បន្ថយហានិភ័យ។

កិច្ចប្រជុំនៅរដ្ឋធានី Copenhagen ក៏នឹងត្រូវផ្តល់នូវសមាសភាគសម្រាប់ពង្រីកប្រតិបត្តិការ និងទំនងជាធានាឱ្យមានការផ្តល់មូលនិធិកាន់តែច្រើនសម្រាប់វិធីសាស្ត្រ ហិរញ្ញវត្ថុជាក់លាក់ណាមួយ ដូចជា REDD។ នាពេលនោះផងដែរ ស្ថិតលើគោលការណ៍តែមួយ វានឹងមានវិសាលភាពក្នុងការពិចារណាឡើងវិញនូវវិធីសាស្ត្រដូចជា CDM ការដោះដូរការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងឥណទានកាបូន ដែលទាំងនេះនឹងត្រូវអស់សុពលភាពក្នុងឆ្នាំ ២០១២។



បន្ទាប់ពីកិច្ចប្រជុំនៅ Copenhagen នឹងមានការបន្ថែមមូលនិធិទៅក្នុងវិធីសាស្ត្រហិរញ្ញវត្ថុដែលមានស្រាប់ (ឧទាហរណ៍ ដំណើរការបញ្ចប់ម្តងទៀត លើកទី៥របស់ GEF) និងកម្លាំងជម្រុញឆ្ពោះទៅរកមូលនិធិជំនាន់ទី២ និង ទី៣ សម្រាប់ការសម្របសម្រួលខ្លួន និងការកាត់បន្ថយ។ គេសង្ឃឹមថា គំរូចាស់ដូចគ្នានឹងមិនត្រូវគេយកមកប្រើដដែលដោយស្វ័យប្រវត្តិឡើយ ប៉ុន្តែសង្ឃឹមថានឹងមានការបង្កើតនូវគំរូអំពីបញ្ហាយេនឌ័រថ្មី។ ជាការពិតណាស់ រយៈពេលនាំទៅរកកិច្ចប្រជុំនៅរដ្ឋធានី Copenhagen និងសេចក្តីសម្រេច COP-15 ផ្ទាល់នឹងផ្តល់ឱកាសសម្រាប់បង្កើតដំណើរការ យន្តការ និងនីតិវិធីទាំងអស់ដែលទាក់ទងនឹងបញ្ហាយេនឌ័រ និងផ្តល់ប្រយោជន៍ដល់ការពង្រឹងអំណាចសេដ្ឋកិច្ច និងសង្គមរបស់ស្ត្រី។

ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ ការងារគឺត្រូវធានាថា បញ្ហាកង្វល់ និងអាទិភាពរបស់ស្ត្រី ជាពិសេសស្ត្រីក្រីក្រ ត្រូវស្ថិតក្នុងចំណុចសំខាន់នៃរបៀបវារៈហិរញ្ញប្បទាន។ បញ្ហាកង្វល់ និងអាទិភាពរបស់ស្ត្រី ជាពិសេសស្ត្រីក្រីក្រ គួរតែក្លាយជាចំណុចសំខាន់ៗនៅក្នុងរបៀបវារៈ COP-15។

***ដំណើរទៅមុខនៃការបង្កើតហិរញ្ញប្បទាន***

ជាការសំខាន់ណាស់នៅក្នុងរយៈពេលបណ្តោះអាសន្ននេះ ដើម្បីជម្រុញយ៉ាងខ្លាំងលើវេទិកាដែលស្វែងរកការដោះស្រាយបញ្ហាហិរញ្ញវត្ថុវិស័យសាធារណៈ និងហិរញ្ញប្បទានវិស័យឯកជន ក្នុងបរិបទនៃកម្មវត្ថុសមភាពយេនឌ័រ។ ប្រការនេះនឹងនាំឱ្យមានគោលនយោបាយពាក់ព័ន្ធរយៈពេលខ្លី និងរយៈពេលវែង និងរបៀបវារៈសកម្មជនដោយផ្អែកលើសមាសភាគសំខាន់ៗយ៉ាងណាស់ ៦ ធាតុ៖

- ការបកស្រាយអំពីគំនិតទស្សនៈ និងវិធីសាស្ត្រនៃការធ្វើហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ និងការលើកកម្ពស់តម្លៃនៃនីតិវិធីបញ្ហាយេនឌ័រ និងគាំទ្រស្ត្រី។ បញ្ហានេះអាចធ្វើទៅបានតាមរយៈដំណើរការលើកកម្ពស់ការយល់ដឹងទូលំទូលាយដែលផ្តោតសំខាន់លើក្រុមស្ត្រី យេនឌ័រ និងអ្នកតាក់តែងគោលនយោបាយ ព្រមទាំងស្ថាប័នគ្រប់លំដាប់ថ្នាក់ដែលទទួលបន្ទុកអនុវត្តគំនិតផ្តួចផ្តើមហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ។
- ព័ត៌មាន និងការបណ្តុះបណ្តាលអំពីវិធីសាស្ត្របង្កើនចំណេះដឹង និងការអនុវត្តទាក់ទងនឹងគម្រោង និងកម្មវិធីសម្រាប់ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុអំពីបញ្ហាយេនឌ័រ ទាំងវិស័យសាធារណៈ និងឯកជន។
- ដោះស្រាយបញ្ហាសំខាន់ៗ មានជាអចិន្ត្រៃយ៍ និងជារចនាសម្ព័ន្ធមានគ្រប់ទីកន្លែងដែលនៅតែមាន និងបង្កលក្ខណៈកាន់ធ្ងន់ធ្ងរលើបញ្ហាវិសមភាពយេនឌ័រ វិសមភាពផ្សេងៗ និងសេចក្តីលម្អៀង។ ប្រការនេះតម្រូវឱ្យមាននីតិវិធីរួមមួយដែលបន្តបង្រៀនពីការការពារក្នុងក្របខ័ណ្ឌកាន់តែទូលាយនៃការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ការលុបបំបាត់ភាពក្រីក្រ និងកំណែទម្រង់ជនបទ និងកសិកម្ម។ នីតិវិធីបែបនេះផ្តោតលើអធិបតេយ្យភាពស្បៀងអាហារ និងអនុវត្តលើទំនាក់ទំនងរវាងមីក្រូ មេសូ (meso) និងម៉ាក្រូ។
- ដាក់បញ្ចូលកម្មវិធីរួមគ្នាដែលនឹងជម្រុញ និងសម្រួលដល់បណ្តាអង្គការស្ត្រី និងអង្គការក្នុងសហគមន៍ (CBOs)ដើម្បីព្រាងធ្វើការប៉ាន់ស្មាន និងចាត់ចែងគំនិតផ្តួចផ្តើមកម្រិតថ្នាក់មូលដ្ឋាន ជាតិ តំបន់ និងសកល។ ករណីនេះ តម្រូវឱ្យមានការបញ្ចុះបញ្ចូល និងការគាំទ្រទាំងនៅក្នុងវិស័យឯកជន ទាំងសាធារណៈ ដើម្បីពង្រីកការផ្តល់ហិរញ្ញវត្ថុ និងឥណទានដល់ស្ត្រី (សម្របសម្រួលហិរញ្ញប្បទាន ឬយេនឌ័រ?)។
- ការងារសកម្មនិយមដើម្បីធានាក្នុងកម្រិតថ្នាក់ជាតិ និងសកលនូវការបង្កើនការផ្តល់មូលនិធិថ្មី ជាពិសេសមូលនិធិសម្រាប់ការពង្រឹងអំណាចស្ត្រី និងអន្តរាគមន៍សមភាពយេនឌ័រ នៅក្នុងផ្នែកការប្រែប្រួលអាកាសធាតុ។
- របៀបវារៈការសិក្សាស្រាវជ្រាវតាមបែបចូលរួមដែលផ្តោតលើការបង្ហាញភស្តុតាងអំពីផលប៉ះពាល់នៃយន្តការហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុលើឋានៈស្ត្រី។ ក្នុងបរិបទនេះ វាអាចនឹងមានការបង្កើតសវនកម្មយេនឌ័រលើគម្រោងហិរញ្ញប្បទាន ការវាយតម្លៃផលប៉ះពាល់យេនឌ័រ និងភាពរីកចម្រើនឆ្ពោះទៅរកការអភិវឌ្ឍសន្ទស្សន៍ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុអំពីយេនឌ័រ។

កាលានុវត្តភាព និងការបើកជាយុទ្ធសាស្ត្រ សម្រាប់ផ្លាស់ប្តូរ និងធ្វើកំណែទម្រង់លើក្របខ័ណ្ឌក្នុងស្ថាប័នដែលមានស្រាប់ វិធីសាស្ត្រ និងយន្តការដូចជា ធនាគារពិភពលោក GEF, NAPAs និង REDD។

- ធនាគារពិភពលោក៖ ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍរបស់ធនាគារ ត្រូវគេរំពឹងថានឹងដោះស្រាយបញ្ហាទិដ្ឋភាពសង្គម និងមនុស្ស ក្នុងនោះមានយេនឌ័រ និងសមាសភាពសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបរិស្ថានផងដែរ។ នីតិវិធីដដែលនេះ គួរត្រូវដាក់ឱ្យអនុវត្តចំពោះអង្គការដៃគូថ្មីរបស់ធនាគារពិភពលោកថ្មីពីរ គឺ the FCPF និង the CPF។ ការបញ្ចុះបញ្ចូលគួរត្រូវធ្វើឡើងដើម្បីធានាថា ធនាគារពិតជាដាក់បញ្ចូលការវិភាគយេនឌ័រ និងគោលការណ៍ណែនាំផ្ទាល់របស់ខ្លួនទៅក្នុងកម្មវិធីទាំងនេះ។ ជាការប្រសើរបំផុត ធនាគារគួរតែទទួលយកអនុសាសន៍ទូលំទូលាយពីក្រុមស្ត្រី ដើម្បីលើកម្ពស់យេនឌ័រឱ្យកាន់ខ្លាំងនៅក្នុងកម្មវិធីការងារនៃមូលនិធិដែលធនាគារនេះគ្រប់គ្រង។

- GEF៖ ចំណុចខ្សោយពីរយ៉ាងរបស់ GEF គឺនិន្នាការយេនឌ័រ និងនិន្នាការការសម្របសម្រួលខ្លួន។ និន្នាការទាំងនេះ ចាំបាច់ត្រូវរួមបញ្ចូលគ្នាដើម្បីពង្រឹងគ្នាទៅវិញទៅមក។ សវនកម្មយេនឌ័រលើកម្មវិធីរបស់ GEF ត្រូវធ្វើឡើងឱ្យត្រូវពេលជាក់លាក់មួយ។
- NAPAs៖ ដំណើរការអំពីការធ្វើការលើរចនាសម្ព័ន្ធ និងលក្ខណៈវិនិច្ឆ័យចុងក្រោយសម្រាប់ការផ្តល់មូលនិធិគម្រោងសម្រាប់ NAPA បច្ចុប្បន្ន កំពុងពិភាក្សា។ ដូច្នេះ វាដល់ពេលសម្រាប់ការបញ្ចុះបញ្ចូលសកម្ម ដើម្បីធានាថា បញ្ហាកង្វល់យេនឌ័រ និងអាទិភាពរបស់ស្ត្រី ត្រូវបានគេដាក់បញ្ចូលរួមគ្នាជាមួយសំណុំលក្ខណៈវិនិច្ឆ័យថ្មីណាមួយ។

## ប្រអប់ទី៩ The GEF និងការចូលរួម

GEF ធ្វើការជាមួយបណ្តាអង្គការក្រៅរដ្ឋាភិបាល និងអង្គការក្នុងសហគមន៍ (BCOs) តាមរយៈគណៈកម្មាធិការជាតិអចិន្ត្រៃយ៍។ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងអ្នកសម្របសម្រួលថ្នាក់ជាតិ ត្រូវផ្តល់ភារកិច្ចដាក់បញ្ចូលបញ្ហាយេនឌ័រទៅក្នុងការអនុវត្តកម្មវិធី។ នៅពេលប្រើប្រាស់មេរៀនក្នុងវគ្គបណ្តុះបណ្តាលដែលរៀបចំឡើងដោយ GEF សមាជិក និងអ្នកសម្របសម្រួលត្រូវបានគេស្នើឱ្យធ្វើការពិនិត្យ និងវាយតម្លៃកម្រិតថ្នាក់ជាតិថាតើគោលនយោបាយយេនឌ័រមានលក្ខណៈយ៉ាងដូចម្តេច។ បន្ទាប់ពីវគ្គបណ្តុះបណ្តាល សមាជិកគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ត្រូវបានគេស្នើឱ្យសរសេរជាលាយលក្ខណ៍អក្សរនូវអ្វីដែលពួកគេនឹងធ្វើ និងវិធីដែលពួកនឹងអនុវត្តនិន្នាការយេនឌ័រ។ មានទិន្នន័យមូលដ្ឋានអំពីរបៀបណាដែលពួកគេអាចអនុវត្តតាមដំណើរការដាក់បញ្ចូលយេនឌ័រ។ តាមរយៈដំណើរការបណ្តុះបណ្តាលនេះ គ្រប់សមាជិកគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ទាំងអស់នឹងទទួលបានចំណេះដឹងពីបញ្ហាយេនឌ័រ ដូច្នេះពួកគេដឹងពីរបៀបក្នុងការបញ្ជ្រាបយេនឌ័រ។

បច្ចុប្បន្ន ប្រទេសចំនួន ១០៣ ប្រទេសនៅក្នុងកម្មវិធីរបស់ GEF មានស្ត្រីជាអ្នកសម្របសម្រួលថ្នាក់ជាតិកាន់តែច្រើន និងផ្តល់ឱកាសឱ្យស្ត្រីទទួលបានភាពជាអ្នកដឹកនាំ។ នៅដំណាក់កាលផ្តួចផ្តើមដំបូង ស្ត្រី និងបុរស ត្រូវបានគេរាប់បញ្ចូល ហើយពួកគេសម្រេចលើអ្វីដែលពួកគេចង់ធ្វើការលើ និងវិធីក្នុងការដោះឥទ្ធិពលលើការវាយតម្លៃ។

*ប្រភព៖ GCCA, 2008*

## កិច្ចការសម្រាប់ជំពូកនេះ

| សកម្មភាព | នីតិវិធី | ពេលវេលា |
|---|---|---|
| បង្រៀនពីទស្សនៈនៃហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ | បច្ចេកទេស **"តើហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុមានអត្ថន័យយ៉ាងដូចម្តេចចំពោះអ្នក"?** | ១ ម៉ោង |
| រកសេចក្តីលម្អៀងនៅក្នុងហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ និងបង្ហាញថា គោលនយោបាយហិរញ្ញវត្ថុការប្រែប្រួលអាកាសធាតុរឹតត្បិតលើការយកចិត្តទុកលើបញ្ហាកង្វល់របស់ស្ត្រី និងការចូលរួមរបស់ស្ត្រីតិចបំផុត | បច្ចេកទេស **"វិភាគលើករណីសិក្សា"** | ៤៥ នាទី |

# ករណីសិក្សា

## ករណីសិក្សាទី១

### ស្ត្រី Amihan និងផលប៉ះពាល់នៃការផ្តល់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ

Ahmihan គឺជាអង្គការក្រៅរដ្ឋាភិបាលថ្នាក់ជាតិនៃស្ត្រីជាកសិករក្រីក្រជនជាតិហ្វីលីពីន ដែលមានសមាជិកសរុបទាំងអស់ចំនួន៣២ខេត្តនៅទូទាំងប្រទេសហ្វីលីពីន។ សក្ខីភាពនៃការប្រែប្រួលអាកាសធាតុ គឺបង្ហាញឱ្យឃើញពីការប្រែប្រួលនៃការធ្លាក់ភ្លៀង និងការកើតមានភ្លៀងធ្លាក់ខ្លាំងជាច្រើនផង មានការកើតឡើងនូវខ្យល់មូសុងខុសប្រក្រតីដែលធ្វើឱ្យប៉ះពាល់ដល់រដូវដាំដុះ យ៉ាងធ្ងន់ធ្ងរទៅលើការបង្កបង្កើនផល។ កត្តាទាំងអស់នេះ ហើយដែលបានចោទឡើងជាបញ្ហាយ៉ាងធ្ងន់ធ្ងរទៅលើការរស់នៅប្រចាំថ្ងៃ និងសន្តិសុខសេដ្ឋកិច្ចរបស់ស្ត្រីដែលរស់នៅក្នុងតំបន់ ទទួលរងការប៉ះពាល់។ ការប្រែប្រួលនេះកំពុងតែធ្វើឱ្យអាក្រក់ថែមទៀត ទៅលើវិបត្តិកសិកម្មដែលមានស្រាប់ដែលពាក់ព័ន្ធទៅនឹងកង្វះថវិកាក្នុងការអភិវឌ្ឍនៅតាមជនបទ សេរីភាពក្នុងការដោះដូរនៅក្នុងវិស័យ កសិកម្ម និងគោលនយោបាយដោះដូរដីធ្លីដែលបញ្ហាទាំងអស់នេះបានធ្វើឱ្យប៉ះពាល់ទៅលើការរស់ និងប្រាក់ចំណូលប្រចាំថ្ងៃរបស់ប្រជាជននៅតាមជនបទ និងបណ្តាលឱ្យស្ត្រីជាច្រើននាក់ទៅធ្វើជាស្ត្រីបម្រើការតាមផ្ទះ ឬធ្វើចំណាកស្រុកទៅក្រៅប្រទេសដែលជារឿយៗមិនស្របច្បាប់ ដើម្បីស្វែងរកឱកាសការងារ។

Ahmihan កត់សម្គាល់ឃើញថា វិបត្តិនៃការប្រែប្រួលអាកាសធាតុបានប៉ះពាល់យ៉ាងធំទៅលើស្ត្រីជា កសិករយ៉ាងហោចណាស់ ៣ យ៉ាងគឺ ទី១ ដោយសារស្ត្រីភាគច្រើនមានធនធានកាន់តែតិចទៅៗ ជាពិសេសដីធ្លីតិចជាងបុរស ដូច្នេះពួកគេជាស្ត្រីមានទ្រព្យសម្បត្តិតិចតួចសម្រាប់លក់នៅពេលដែលពួកគេទើបប្រទះនឹងបរាជ័យក្នុងការប្រមូលផលដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួតផងដែរ។ ទី២ ស្ត្រីភាគច្រើនធ្លាក់ខ្លួនជាប់បំណុលដោយសារការខូចខាតផលដំណាំបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ ចំណុចនេះហើយដែលបានធ្វើឱ្យស្ត្រីស្ថិតនៅក្រោមសម្ពាធកាន់តែខ្លាំងឡើងៗក្នុងនាមជាអ្នកគ្រប់គ្រងផលិតកម្ម និងចាត់ចែងការចំណាយនៅក្នុងគ្រួសារ។ លើសពីនេះ បើយោងតាមការសិក្សាស្រាវជ្រាវមួយបានបង្ហាញថា ស្ត្រីប្រហែល ៩៤ភាគរយដែលធ្វើដំណាំស្រូវបានខ្ចីប្រាក់ពីអ្នកចងការប្រាក់ស្ថាប័នផ្សេងៗ ឬ បងប្អូនដើម្បីយកទៅបង្កបង្កើនផល និងផ្គត់ផ្គង់ទៅលើការចំណាយក្នុងគ្រួសារ។ ទី៣ នៅពេលដែលកើតមានវិបត្តិកង្វះស្បៀងអាហារដែលបណ្តាលមកពីការប្រមូលផលមិនបាន ស្ត្រីផ្តល់អាទិភាពលើតម្រូវការអាហាររបស់សមាជិកគ្រួសារជាបុរស និងកូនៗរបស់ខ្លួន។

សំយោគទៅលើចំណេះដឹងជាប្រពៃណីដែលមាននៅក្នុងតំបន់ ប្រជាជននៅតាមទីជនបទបានចាប់ផ្តើមសម្របទៅនឹងការប្រែប្រួលអាកាសធាតុទៅតាមយុទ្ធសាស្ត្រ ជាច្រើនបែប។ យុទ្ធសាស្ត្រសម្របទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យកសិកម្មរួមមាន ការអនុវត្តការដាំដុះដោយប្រែប្រួលទៅតាមអាកាសធាតុ ដាំដុះដំណាំទាំងឡាយណាដែលអាចទប់ទល់នឹងគ្រោះរាំងស្ងួត ទឹកជំនន់ និងសត្វល្អិត ដាំដុះនៅតំបន់ខ្ពស់ ដាំដុះនៅទីជម្រាលភ្នំ ដាំឫស្សី ដើម្បីការពារសំណឹកដី និងធ្វើប្រឡាយបង្ហូរទឹកចេញ។ យុទ្ធសាស្ត្រសម្របសម្រួលទៅលើហិរញ្ញវត្ថុរួមមាន ការរួមចំណែកក្នុងការងារមិនមែនកសិកម្ម ស្វែងរកប្រភពចំណូលនៅក្នុងតំបន់ ឬ ក្រៅប្រទេស ខ្ចីប្រាក់ពីអ្នកចងការប្រាក់ បងប្អូន និងមិត្តភ័ក្តិ លក់បសុសត្វ ស្វែងរកជំនួយផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាល លក់ ឬ ជួលដីស្រែចម្ការ និងបន្ថយលើការហូបចុក។

ជាមួយធនធាន និងការគាំទ្រនៅមានកម្រិត ស្ត្រីជាកសិករកំពុងរៀបចំយុទ្ធសាស្ត្រ ដើម្បីធានាឱ្យបានល្អនូវការរស់នៅប្រចាំថ្ងៃ និងអាចទទួលបាននូវតម្រូវការចាំបាច់។ ជាពិសេសសមាជិករបស់ Mahan នៅខេត្ត Rizal, Quezon, និង South Catabata បានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងគំនិតផ្តួចផ្តើមការដាំដុះបែបសរីរាង្គ កម្មវិធីគ្រប់គ្រងការរំខានដោយសត្វល្អិត កសិរុក្ខកម្ម និងគម្រោងដាំដើមឈើឡើងវិញ។

ស្ត្រីជាកសិករដែលជាសមាជិក Amihan នៅខេត្ត Montalban និង Rizal បានចាប់ផ្តើមធ្វើកសិកម្មបែបប្រពៃណីការធ្វើស្រែតាមបែបសាមញ្ញដែលមិនតម្រូវឱ្យប្រើជីគីមី ឬថ្នាំសម្លាប់សត្វល្អិត។ ស្ត្រីក៏បានចាប់ផ្តើមដាំដុះដំណាំហូបផ្លែ និងបន្លែបង្ការនៅតាមជាយស្រែ។ ដោយសារការអនុវត្តកសិកម្មតាមបែបនេះ អាចធ្វើទៅបានតែម្តងក្នុងមួយឆ្នាំ តែការធ្វើបែបនេះ គឺស្របទៅតាមបទដ្ឋានបរិស្ថាន និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិចជាងការធ្វើកសិកម្មបែបទំនើប។

តាមទស្សនៈរបស់ប្រជាជនក្រីក្រ និងស្ត្រីតាមជនបទការគាំពារលើការរស់នៅប្រចាំថ្ងៃ និងប្រភពទ្រទ្រង់ជីវិត គឺជាវិធានការសម្របសម្រួលខ្លួនដ៏ឧត្តមតម្រូវឱ្យមានជាចាំបាច់ដែលវិធានការទាំងនោះ អាចទប់ទល់នឹងផលប៉ះពាល់បរិយាកាសមកលើវិស័យកសិកម្ម និងជលផល ធានានូវឱកាសទទួលបានការប្រើប្រាស់ទឹកស្អាត និងតម្រូវការចាំបាច់ផ្សេងៗទៀត និងផ្តល់នូវធានារ៉ាប់រង និងការពារសង្គម ក្នុងចំណោមប្រជាជនផ្សេងៗទៀត។

Amihan ក៏បានអំពាវនាវសុំការគាំទ្រ និងមូលនិធិ ពីសំណាក់រដ្ឋាភិបាលសម្រាប់សហគមន៍នៅតាមជនបទ និងជាពិសេសសម្រាប់ស្ត្រីនៅតាមជនបទ មានការផ្តល់ជាគ្រាប់ពូជសរីរាង្គ ជីធម្មជាតិ និងថ្នាំសម្លាប់សត្វល្អិត ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តស្រប ទៅតាមបច្ចេកទេសកសិកម្មបច្ចុប្បន្ន និងទទួលបានកម្ចីឥណទានកសិកម្មក្នុងអត្រាការប្រាក់ទាប។ លើសពីនេះ Amihan កំពុងបញ្ចូលសហភាពឱ្យលុបច្បាប់ជីវឥន្ទនៈឆ្នាំ ២០០៦ ចោល។ Amihan ក៏បានកត់សម្គាល់ឃើញថា ការដាំដុះល្ហុងខ្វងជាដំណាំជីវឥន្ទនៈដ៏សំខាន់ គឺតម្រូវឱ្យប្រើប្រាស់សារធាតុគីមីច្រើនដែលបណ្តាលឱ្យខូចគុណភាពដី។ កត្តានេះជម្រុញឱ្យ Amihan ធ្វើសំណើកំណែទម្រង់ក្សេត្រសំដៅលើកកម្ពស់កំណែទម្រង់គុណភាពដីដោយបង្កើតភាពប្រាកដប្រជានៃសិទ្ធិកាន់កាប់ដីធ្លី និងលើកទឹកចិត្តដល់កសិករឱ្យវិនិយោគការការពារបរិយាកាស (ព្រមទាំងដោះស្រាយបញ្ហាគោលនៃយុត្តិធម៌ និងសមធម៌)។

លើសពីនេះទៀត Amihan កំពុងចាប់ផ្តើមធ្វើការការពារជុំវិញបញ្ហាការប្រែប្រួលអាកាសធាតុក្នុងកម្រិតថ្នាក់សកល។

គោលនយោបាយរដ្ឋាភិបាលហ្វីលីពីន ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ គឺពឹងផ្អែកលើយុទ្ធសាស្ត្រធំៗ៤គឺ ទី១ ជម្រុញឱ្យមានការវិនិយោគទុនលើគម្រោងស្រាវជ្រាវថាមពលកកើតឡើងវិញដូចជា សំណង់ទំនប់វារីអគ្គិសនី ទី២ បង្កើតឱ្យមានគម្រោងយន្តការអភិវឌ្ឍស្អាត និងធ្វើការវាស់វែងពិសោធ និងបង្កើតនូវប្រព័ន្ធបម្លែងជាតិកាបូន។ ទី៣ ពង្រីក ODA កម្ចី និងជំនួយពីប្រទេសម្ចាស់ជំនួយព្រមទាំងស្ថាប័នហិរញ្ញវត្ថុជាតិ និងអន្តរជាតិនៅក្នុងតំបន់។ ទី៤ យកកម្រៃជាពន្ធទៅលើម្ចាស់សហគ្រាសដែលអាជីវកម្មពួកគេបានប៉ះពាល់លើបរិស្ថាន។

មានគម្រោងសម្របសម្រួលខ្លួនពីរគម្រោង ដែលផ្តោតលើវិស័យកសិកម្មផងដែរ។ ឧទាហរណ៍ដំណាក់កាលទី១ នៃគម្រោង សម្របសម្រួលខ្លួននឹងការប្រែប្រួលអាកាសធាតុហ្វីលីពីន មានរួមបញ្ចូលការបង្កើតវិធានការសម្របសម្រួលខ្លួនប្រកបដោយប្រសិទ្ធភាពនូវការគ្រប់គ្រងកសិកម្ម និងធនធានធម្មជាតិ។ ខណៈដែលផលប្រយោជន៍នៃហានិភ័យទុនរួមគ្នា និងធានារ៉ាប់រងសម្រាប់គ្រោះថ្នាក់ពាក់ព័ន្ធបរិយាកាសដើម្បីគាំទ្រកិច្ចខិតខំប្រឹងប្រែងការសម្របសម្រួលខ្លួនត្រូវសហគមន៍អន្តរជាតិឱ្យតម្លៃកាន់តែច្រើនឡើងៗ បញ្ហានេះ នៅតែជាចំណុចកំពុងអភិវឌ្ឍតិចតួចនៅក្នុងប្រទេស

ហ្វីលីពីន មួយផ្នែកធំដោយសារគ្មានផលប្រយោជន៍ដល់វិស័យឯកជន។ សាជីវកម្មធានារ៉ាប់រងដំណាំរបស់រដ្ឋាភិបាលហ្វីលីពីន (PCIC) បានផ្តល់សេវាកម្មធានារ៉ាប់រងដំណាំដែលខូចខាតដោយសារអាកាសធាតុ ប៉ុន្តែកសិករមួយចំនួនតូចមានឱកាសតែត្បិតក្នុងការទទួលបានសេវាកម្មនេះដោយសារពួកគេគ្មានលទ្ធភាព។ ធនាគារពិភពលោក និងគម្រោងវាយតម្លៃហានិភ័យបរិយាកាសកសិកម្ម ដែលផ្តល់ មូលនិធិដោយ Provention Consortium នឹងរិះរកពីលទ្ធភាពនៃការវាស់វែងលើប្រព័ន្ធធានារ៉ាប់រងដំណាំផ្អែកលើអាកាសធាតុ។

មានបញ្ហាសំខាន់ៗជាមួយនឹងការឆ្លើយតបគោលនយោបាយរបស់រដ្ឋាភិបាលហ្វីលីពីន និងហិរញ្ញប្បទានការកាត់បន្ថយ និងការសម្របសម្រួលខ្លួនរបស់រដ្ឋាភិបាល។

ទី១ ទំនុកចិត្តរដ្ឋាភិបាលលើឧបករណ៍បំណុលកាន់តែច្រើន ផ្តល់ហិរញ្ញប្បទានដល់បញ្ហាប្រឈមការប្រែប្រួល នឹងបន្ថែមលើបន្ទុកបំណុលខ្ពស់ដែលមានស្រាប់។ វាគ្មានការទទួលស្គាល់ថា គម្រោងលើថាមពលប្រើប្រាស់ឡើងវិញទម្រង់ធំដែលមានឧបត្ថម្ភធន ដូចជាទំនប់វារីអគ្គិសនីធំៗអាចមិនអំណោយផលដល់យេនឌ័រ និងបញ្ហាសង្គមនានាដែលពាក់ព័ន្ធ។ ដើម្បីសម្រេចលើជម្រើសនេះ រដ្ឋាភិបាលមិនអើពើនឹងគម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (GHG) ផ្សេងៗទៀត ដូចជាការគ្រប់គ្រងព្រៃសហគមន៍ និងផែនការកសិរុក្ខកម្ម ដោយមានលទ្ធផលកាត់បន្ថយភាពក្រីក្រដ៏មានសក្តានុពល។ រដ្ឋាភិបាលក៏មិនបានយកចិត្តទុកដាក់លើវិធានការសម្របសម្រួលខ្លួនផងដែរ ដែលអាចទប់ទល់នឹងបរិយាកាសនៅក្នុងវិស័យកសិកម្ម និងផលផល និងដែលធានានូវការទទួលបានទឹកប្រើប្រាស់ និងតម្រូវការចាំបាច់ផ្សេងៗទៀត។

ទី២ រដ្ឋាភិបាលបានសម្រេចបង្កើតប្រព័ន្ធដោះដូរកាបូនជំនួសការបន្ថែមពន្ធកាបូនក្នុងស្រុក និងបែបបទផ្សេងៗនៃពន្ធលើការបំពុលបរិយាកាសដែលប្រព័ន្ធនេះអាចកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG) និងរៃអង្គាសមូលនិធិសាធារណៈសម្រាប់ការសម្របសម្រួលខ្លួន។ ការសិក្សាស្រាវជ្រាវបង្ហាញថា ពន្ធកាបូនជាតិហ្វីលីពីន មិនត្រឹមតែអាចកាត់បន្ថយភាពក្រីក្រ និងបង្កើនឧបត្ថម្ភធនប៉ុណ្ណោះទេ ថែមទាំងនឹងអាចបង្កើនចំណូលសម្រាប់ការសម្របសម្រួលខ្លួនដែលអាចលើកកម្ពស់សមភាពយេនឌ័រ ជាពិសេសបើសិនហិរញ្ញប្បទានការសម្របសម្រួលខ្លួនត្រូវប្រើប្រាស់ដើម្បីគាំទ្រការអភិវឌ្ឍតំបន់ជនបទ។

ជាទីបញ្ចប់ ការដាក់តម្លៃអ្នកប្រើប្រាស់សម្រាប់សេវាកម្មបរិស្ថាន អាចមានផលប៉ះពាល់បំណែងចែកវណ្ណៈ (ពន្ធសេវាកម្ម) និងរារាំងស្ត្រីជនបទមិនឱ្យមានឱកាសទទួលបានសេវាកម្មទាំងនេះ។

*ប្រភព៖*

*Perlata, A. (2008). Gender and Climate Change Finance - A Case study from the Philippines. New York, USA: WEDO.*

# តើ "ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ" មានអត្ថន័យចំពោះអ្នកដូចម្តេច?





**គោលបំណង ៖** បង្រៀនពីទស្សនៈនៃហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ និងរកប្រភេទនៃឧបករណ៍ហិរញ្ញប្បទាន ដែលអាចសមស្របចំពោះ "សហគមន៍" ចេញពីទស្សនៈរបស់ស្ត្រី និងបុរស។

**សម្ភារៈ ៖** ហ្វឺតសរសេរ ស្កុត ផ្ទាំងក្រដាសធំ និងម្ជុល។

**ដំណើរការ ៖**

១. ពន្យល់សង្ខេបពីអ្វីដែលអ្នកយល់លើឃ្លា "ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ"។ ម្នាក់ៗនៅក្នុងក្រុមត្រូវនិយាយឱ្យខ្លាំងៗពាក្យ ឬឃ្លា ឬ សំនួនដែលតំណាង ឬបញ្ជាក់ពីអត្ថន័យរបស់ពាក្យនោះចំពោះពួកគេ។

២. ឱ្យក្រុមពិចារណាអំពីបញ្ហាការប្រែប្រួលអាកាសធាតុនៅក្នុងសហគមន៍ ឬប្រទេសរបស់ពួកគេ (កំណត់នីតិវិធីបែបណាទាក់ទងនឹងការសម្របសម្រួលខ្លួន ឬការកាត់បន្ថយ)។ តើគម្រោងដោះស្រាយបញ្ហានេះនឹងមានលក្ខណៈយ៉ាងដូចម្តេច? ចូរពិភាក្សាបញ្ហានេះរយៈពេល ១៥ នាទី។

៣. ឥឡូវ ឱ្យអ្នកចូលរួមពិនិត្យលើការពិភាក្សាឡើងវិញ៖ តើអ្វីខ្លះជាឧបករណ៍ យន្តការ និងបែបបទនៃហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ? (ផ្នែក ៧.៣)។

៤. បែងចែកក្រុមជាក្រុមបុរសសុទ្ធ និងក្រុមស្ត្រីសុទ្ធ។ ឱ្យពួកគេព្រាងសំណើតូចមួយសុំមូលនិធិ ដើម្បីអនុវត្តគម្រោងដែលពួកគេបានពិភាក្សាក្នុងចំណុចលេខ (២) ខាងលើ។

៥. ឱ្យពួកគេពិភាក្សាថាតើ ពួកគេត្រូវដាក់ជូនគម្រោងនោះទៅកាន់យន្តការផ្តល់មូលនិធិណាខ្លះ ហើយថាតើពួកគេគិតថា អ្វីជាចម្លើយតបដែលអាចបានមកចំពោះគម្រោងនោះ។

# ការវិភាគលើករណីសិក្សា



**គោលបំណង ៖** រកសេចក្តីលម្អៀងនៅក្នុងហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ និងបង្ហាញថា គោលនយោបាយហិរញ្ញវត្ថុការប្រែប្រួលអាកាសធាតុរឹតត្បិតលើការយកចិត្តទុកលើបញ្ហាកង្វល់របស់ស្ត្រី និងការចូលរួមរបស់ស្ត្រីតិចបំផុត។

**សម្ភារៈ ៖** ហ្វឺតសរសេរ ស្កុត ផ្ទាំងក្រដាសធំ ម្ជុលម្ជូក និងឯកសារចម្លងករណីសិក្សា។

**ដំណើរការ ៖**

១. បែងចែកអ្នកចូលរួមជាក្រុមៗ និងឱ្យពួកគេឆ្លើយសំណួរខាងក្រោមអំពីករណីសិក្សារបស់ Amihan ៖

- តើស្ត្រីជួបប្រទះនឹងបញ្ហាប្រឈមការប្រែប្រួលអាកាសធាតុអ្វីខ្លះ?
- តើអ្វីខ្លះជាការឆ្លើយតបរបស់ស្ត្រីចំពោះបញ្ហាប្រឈមនេះ?
- តើអ្វីខ្លះជាយុទ្ធសាស្ត្រហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រដោះស្រាយផ្សេងៗទៀតរបស់ពួកគេ?

- តើស្ត្រីបានធ្វើការការពារអ្វីខ្លះ ដើម្បីមានឥទ្ធិពលលើគោលនយោបាយ?
- តើអ្វីខ្លះជាការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះបញ្ហាប្រឈមការប្រែប្រួលអាកាសធាតុជារួម និងចំពោះបញ្ហាពាក់ព័ន្ធបរិយាកាសនៅក្នុងវិស័យកសិកម្ម?
- តើករណីនេះបានដោះស្រាយបញ្ហាកង្វល់របស់ស្ត្រីដែរទេ?
- តើអ្នកនឹងចាត់វិធានការរយៈពេលវែងអ្វីខ្លះ?
- បើសិនស្ត្រីកំពុងធ្វើគោលនយោបាយហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ តើនឹងមានអ្វីខុសប្លែកខ្លះ?

២. ចូរពិភាក្សាក្នុងក្រុមតូចរបស់អ្នក ហើយបន្ទាប់មករាយការណ៍ទៅកាន់ក្រុមពិភាក្សាទាំងអស់វិញ។

# ឧបសម្ព័ន្ធ ១៖ ឯកសារយោងបន្ថែម[៤៤]

ឧបសម្ព័ន្ធនេះ មានរួមបញ្ចូលការជ្រើសរើសការបោះពុម្ពផ្សាយសំខាន់ៗ ស្តីពី ប្រធានបទការប្រែប្រួលអាកាសធាតុដែលចេញផ្សាយមកទល់នឹងពេលបច្ចុប្បន្ន (តុលា ២០០៨)។

រាល់ឯកសារយោងនីមួយៗត្រូវបានបង្ហាញផ្អែកលើមេរៀនសម្រង់ចេញពី សមាគមចិត្តសាស្ត្រអាមេរិក (APA) ដែលរួមមាន ឈ្មោះអ្នកនិពន្ធ ចំណងជើង ទីកន្លែងបោះពុម្ព អ្នកបោះពុម្ព និងលទ្ធភាពយកបានតាមប្រព័ន្ធអ៊ិនធឺណេត។ សម្រង់នីមួយៗ មានការបរិយាយសង្ខេប និងប្រយោគវាយតម្លៃកំណត់ចំណាំ។

ព័ត៌មានត្រូវបានបង្ហាញ ជាពីរផ្នែកតាមលំដាប់តួអក្សរ៖

### ក. ឯកសារយោងមូលដ្ឋាន

១. ការប្រែប្រួលអាកាសធាតុ៖ ក្របខ័ណ្ឌយោង

៣. ការប្រែប្រួលអាកាសធាតុ និងយេនឌ័រ

៥. ថាមពល និងយេនឌ័រ

៦. ការកាត់បន្ថយ និងការបន្សាំ

### ខ. ប្រភពផ្សេងៗ

១. ការណែនាំ និងមេរៀន

២. ព័ត៌មាន និងតារាងតថភាព

៣. គេហទំព័រ

៤. ផ្សេងៗ

---

៤៤. This appendix has been improved from: Aguilar et al. (2008). **Guía: Recursos de Género para el Cambio Climático.** UNDP, Mexico.

## ក. ឯកសារយោងមូលដ្ឋាន

### ១. ការប្រែប្រួលអាកាសធាតុ៖ ក្របខ័ណ្ឌយោង

| ឯកសារយោង | បរិយាយ |
|---|---|
| Epstein, P.R. និង Mills, E. (Eds) ឆ្នាំ២០០៥ ). **អនាគតការប្រែប្រួលអាកាសធាតុ៖ សុខភាព ទំហំប្រព័ន្ធអេកូឡូស៊ី និងសេដ្ឋកិច្ច។** មជ្ឈមណ្ឌលសុខភាព និងបរិស្ថានពិភពលោក Harvard Medical School,United Nations Development Programme (UNDP) និង SwissRe. ដកស្រង់ពីគេហទំព័រ៖ http://www.undp.org/biodiversity/pdfs/CCF_Report_2005_final.pdf | ការប៉ាន់ប្រមាណ ជាលក្ខណៈពហុទំហំនៃការប្រែប្រួលអាកាសធាតុ ដោះស្រាយនូវទំនោរ ករណីសិក្សា សេណារីយ៉ូ ដោយសង្កត់ធ្ងន់លើបញ្ហាសុខភាព។ វាបានរកឃើញថា ការប្រែប្រួលអាកាសធាតុ ប៉ះពាល់ដល់សុខភាពមនុស្ស ក៏ដូចជាប្រព័ន្ធអេកូឡូស៊ី និងប្រភេទពូជដែលអាស្រ័យទៅលើវា។ ផលប៉ះពាល់លើសុខភាពទាំងនេះ នឹងនាំមកនូវផលវិបាកសេដ្ឋកិច្ចផងដែរ។ |
| Fuentes, R. និង Seck, P. (ឆ្នាំ២០០៧) **ផលប៉ះពាល់ការអភិវឌ្ឍមនុស្សរយៈពេលវែង និងខ្លី នៃភាពតក់ស្លុតទាក់ទងនឹងអាកាសធាតុ៖ ភស្តុតាងពិសោធន៍។** Occasional Paper for the HumanDevelopment Report 2007/2008. ដកស្រង់ពីគេហទំព័រ៖ http://hdr.undp.org/en/reports/global/hdr2007-2008/papers/backgound_ricardo_papa_2007.pdf | ឯកសារនេះដើរតួជាឯកសារសាវតាសម្រាប់ របាយការណ៍អភិវឌ្ឍមនុស្ស ឆ្នាំ២០០៧/២០០៨ ‘ប្រយុទ្ធនឹងការប្រែប្រួលអាកាសធាតុ៖ សាមគ្គីភាពមនុស្សក្នុងពិភពលោកដែលមានការបែងចែក។’ វាធ្វើការវិភាគទៅលើភាពចាញ់ប្រៀបសម្រាប់ការអភិវឌ្ឍមនុស្ស ដែលបណ្តាលមកពីផលប៉ះពាល់នៃគ្រោះមហន្តរាយទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ វាវិភាគលើទិន្នន័យលើលំនៅដ្ឋាននៅក្នុងប្រទេស៤ ដែលរងផលប៉ះពាល់ពីមហន្តរាយអាកាសធាតុដែលកើតឡើងជារឿយៗ ដូចជា ទឹកជំនន់ និងភាពរាំងស្ងួត។ |
| Holdren, J. (2007). **ជួបជាមួយនឹងការប្រឈមការប្រែប្រួលអាកាសធាតុ៖ ជៀសវាងការមិនអាចគ្រប់គ្រងបាន និងគ្រប់គ្រងការមិនអាចជៀសវាង។** ដកស្រង់ពីគេហទំព័រ៖ http://www.un.org/esa/sustdev/csd/csd15/statements/holdren_9may.Pdf | បទបង្ហាញជា PowerPoint នេះត្រូវបានបង្ហាញនៅក្នុងកិច្ចពិភាក្សាតុមូលថ្នាក់ខ្ពស់ នៅកិច្ចប្រជុំទី១៥ របស់គណៈកម្មាការអង្គការសហប្រជាជាតិស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព( CSD-15 )។ វាបានលំអិតពីអនុសាសន៍យុទ្ធសាស្រ្តកាត់បន្ថយ និងបន្សុំា។ |

| ឯកសារយោង | បរិយាយ |
|---|---|
| IPCC [Core Writing Team and Watson, R.T. (Eds)]. ( ឆ្នាំ២០០១ ). **ការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១១ ៖ Climate Change 2001: របាយការណ៍សំយោគ ។** A contribution of Working Groups I, II and III to the Third Assessment Report of the Intergovernmental Panel on Climate Change(IPCC). Cambridge University Press, Cambridge, UK, and New York, NY, USA, 398 pp. ដកស្រង់ពីគេហទំព័រ ៖ http://www.ipcc.ch/pdf/climate-changes-2001/synthesis-spm/synthesis-spm-en.pdf | បង្ហាញពីការងាររយៈពេល៣ឆ្នាំ ដោយអ្នកនិពន្ធចម្បងប្រមាណ ៤៥០រូប និងអ្នកនិពន្ធគាំទ្រប្រមាណ ៨០០រូប។ វាក៏ភ្ជាប់ជាមួយនូវយោបល់របស់អ្នកជំនាញ និងតំណាងរដ្ឋាភិបាលប្រមាណ១០០រូប។ របាយការណ៍ឆ្លើយសំនួរចំនួន៩ ស្តីពីវិទ្យាសាស្ត្រ សំនួរបច្ចេកទេស និងសេដ្ឋកិច្ច សង្គមកិច្ច ស្តីពីការប្រែប្រួលអាកាសធាតុ។ |
| IPCC [Core Writing Team, Canziani, O.F.,-Dokken, D.J., Leary, N.A., McCarthy, J.J. និង White, K.S. (Eds)]. (ឆ្នាំ២០០១).**ការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១១៖ ផលប៉ះពាល់ បន្សាំ និងភាពងាយរងគ្រោះ ។** Part of the contribution of Working Group II tothe IPCC Third Assessment Report. ដកស្រង់ពីគេហទំព័រ ៖ http://www.ipcc.ch/ipccreports/tar/wg2/index.htm | ការបោះពុម្ពនេះ ដែលជាផ្នែកនៃរបាយការណ៍ប៉ាន់ប្រមាណទី៣ ( TAR ) ដែលបានរៀបចំដោយ Working Group II (WGII) of the IPCC និងផ្តោតលើ លទ្ធផលបរិស្ថាន សេដ្ឋកិច្ច និងសង្គមនៃការប្រែប្រួលអាកាសធាតុ និងការឆ្លើយតបបន្សាំដាក់លាក់។ វាមាន ១៩ជំពូក គ្របដណ្តប់លើ ភាពងាយរងឥទ្ធិពល លទ្ធភាពបន្សាំ និងភាពងាយគ្រោះនៃប្រព័ន្ធមនុស្ស និងធម្មជាតិលើកការប្រែប្រួលអាកាសធាតុ និងជម្រើសបន្សាំ និងផលប៉ះពាល់ជាក់លាក់ នៅកម្រិតតំបន់ និងពិភពលោក។ |
| IPCC [Core Writing Team, Houghton, J.T., Ding,Y., Griggs, D.J., Noguer, M., van der Linden, P.J.,Dai, X., Maskell, K. និង Johnson, C.A.(Eds)]. ( ឆ្នាំ២០០១ ). ការប្រែប្រួលអាកាសធាតុ ឆ្នាំ២០០១៖ មូលដ្ឋានវិទ្យាសាស្ត្រ។ Part of the contribution of Working Group I to the IPCC Third Assessment Report. Cambridge University Press, Cambridge, UKand New York, NY, USA, 881 pp. ដកស្រង់ពីគេហទំព័រ ៖ http://www.ipcc.ch/ipccreports/tar/wg1/index.htm | បរិយាយពីភាពជឿនលឿនដែលកើតមានក្នុងការស្វែងយល់ ពីកត្តាមនុស្ស និងធម្មជាតិ ផ្សាភ្ជាប់នឹងការប្រែប្រួលអាកាសធាតុ។ វាផ្អែកលើការប៉ាន់ប្រមាណ IPCC នៅឆ្នាំ២០០១ និងរួមបញ្ចូលគម្រើញការស្រាវជ្រាវវិទ្យាសាស្ត្រ រយៈពេល៦ឆ្នាំកន្លងមក។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| UK Parliamentary Office of Science and-Technology. (ឆ្នាំ២០០៦) **បន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងប្រទេសកំពុងអភិវឌ្ឍ។** ដកស្រង់ពីគេហទំព័រ៖ http://www.parliament.uk/documents/upload/postpn269.pdf | អត្ថបទបរិយាយសង្ខេបដែលគ្របដណ្ដប់បញ្ហាកំពុងកើតមានសម្រាប់ប្រទេសកំពុងអភិវឌ្ឍ ខណៈពួកគេធ្វើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ |
| អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ (UNFCCC). (ឆ្នាំ២០០៥). **ពិធិសារក្យូតូ។** ដកស្រង់ពីគេហទំព័រ៖ http://unfccc.int/resource/docs/convkp/kpeng.pdf | ពិធីសារក្យូតូ នៃ UNFCCC ជាការធ្វើវិសោធនកម្មលើសន្ធិសញ្ញាស្ដីពីការប្រែប្រួលអាកាសធាតុ ដែលតម្រូវឱ្យរដ្ឋហត្ថលេខី ដើម្បីកាត់បន្ថយការសាយភាយ។ វាចូលជាធរមាននៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០៥។ |
| អង្គការសហប្រជាជាតិ (ឆ្នាំ១៩៩៤). **អនុសញ្ញាក្របខ័ណ្ឌស្ដីពីការប្រែប្រួលអាកាសធាតុ** (UNF-CCC). ដកស្រង់ពីគេហទំព័រ៖ http://unfccc.int/resource/docs/convkp/conveng.pdf | អត្ថបទ UNFCCC ដែលចូលជាធរមាននៅថ្ងៃទី ២១ ខែមីនា ឆ្នាំ១៩៩៤ និងបានបង្កើតឱ្យមានជាក្របខ័ណ្ឌអន្តរជាតិសម្រាប់រដ្ឋាភិបាល ធ្វើការរួមគ្នាក្នុងការរៀបចំសេចក្ដីស្នើគោលនយោបាយ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងបន្សាំនឹងការគំរាមកំហែងរបស់វា។ |
| UNDP. (ឆ្នាំ២០០១) **ថាមពលដែលមានចីរភាព ការអភិវឌ្ឍ និងបរិស្ថាន ៖ គំនិតផ្ដួចផ្ដើមការប្រែប្រួលអាកាសធាតុUNDP។** ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/indexAction.cfm?-module=Library&action=GetFile & Docu-mentAttachmentID=1019 | ខិតប័ណ្ណ៨ទំព័រនេះ បរិយាយពីការប្ដេជ្ញាចិត្តរបស់ UNDP ក្នុងការគាំទ្រគំនិតផ្ដួចផ្ដើមរបស់ប្រទេសកំពុងអភិវឌ្ឍ ក្នុងការឆ្លើយតបទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដោយដាក់នូវការផ្ដោតពិសេសលើការលើកកម្ពស់ជីវភាពអ្នកដែលស្ថិតក្នុងភាពក្រីក្រធ្ងន់ធ្ងរ។ |
| UNDP. (ឆ្នាំ២០០៧). **របាយការណ៍ អភិវឌ្ឍមនុស្ស ឆ្នាំ២០០៧/២០០៨។ ប្រយុទ្ធនឹងការប្រែប្រួលអាកាសធាតុ៖ សាមគ្គីភាពមនុស្សក្នុងពិភពលោកដែលមានការបែងចែក។** ដកស្រង់ពីគេហទំព័រ៖ http://hdr.undp.org/en/reports/global/hdr2007-2008/ | របាយការណ៍នេះព្រមានថា ការប្រែប្រួលអាកាសធាតុ គំរាមកំហែងដល់ការអភិវឌ្ឍមនុស្ស និងអាចនាំឱ្យមានការថយក្រោយក្នុងវិស័យសុខភាព អប់រំ និងការកាត់បន្ថយភាពក្រីក្រ ដែលធ្វើឱ្យមានវិសមភាពកាន់តែអាក្រក់។ ឯកសារនេះ ក៏បានចង្អុលពីទំនួលខុសត្រូវរួម តែខុសៗគ្នានៃប្រទេសនីមួយៗយកចិត្តទុកដាក់នូវបញ្ហាប្រឈមនេះ និងអនុលោមតាមគោលដៅអភិវឌ្ឍសហស្សវត្សរ៍ (MDGs)។ |

| ឯកសារយោង | បរិយាយ |
|---|---|
| UNDP/Global Environment Facility (GEF). (ឆ្នាំ២០០៤). **មេរៀនសម្រាប់អនាគត៖ ជួបជាមួយនឹងបញ្ហាប្រឈមការប្រែប្រួលអាកាសធាតុចីរភាពជីវភាព**។ ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/indexAction.cfm?module=Library&action=GetFile&DocumentAttachmentID=1115 | ខិតបណ្ណ UNDP/GEF នេះបង្ហាញនូវឧទាហរណ៍នៃសកម្មភាព ដែលដោះស្រាយជាមួយនឹងការប្រែប្រួលអាកាសធាតុទាក់ទងនឹងផ្នែកអាទិភាពទាំង៥ របស់ GEF៖ ប្រែក្លាយគោលនយោបាយទីផ្សារទៅជាការលើកកម្ពស់ផលិតផល និងដំណើរការ ប្រសិទ្ធភាពថាមពល; បង្កើនការទទួលបានធនធានមូលដ្ឋានការធ្វើហិរញ្ញប្បទានដល់ថាមពលកើតឡើងវិញ និងប្រសិទ្ធភាពថាមពល លើកកម្ពស់គោលនយោបាយវិស័យថាមពលដើម្បីគាំទ្រថាមពលកើតឡើងវិញសម្រាប់កាត់បន្ថយភាពក្រីក្រ និងជម្រុញការដឹកជញ្ជូនទីក្រុង និងការប្រើប្រាស់បច្ចេកវិទ្យាប្រេងឥន្ធនៈ និងយានយន្ត ‘ស្អាត’។ |

## ២. ការប្រែប្រួលអាកាសធាតុ និងយេនឌ័រ

| ឯកសារយោង | បរិយាយ |
|---|---|
| BRIDGE (development – gender). (ឆ្នាំ២០០៨). **យេនឌ័រ និងការប្រែប្រួលអាកាសធាតុ៖ ដៅការភ្ជាប់។ ការសិក្សាវិសាលភាព ចំណេះដឹងនិងគម្លាត**។ Institute of Development Studies, Brighton, UK. ដកស្រង់ពីគេហទំព័រ៖ http://siteresources.worldbank.org/EXTSOCIALDEVELOPMENT/Resources/DFID_Gender_Climate_Change.pdf | ដាក់ជាមួយគ្នានូវកិច្ចខិតខំពីមុនដើម្បីភ្ជាប់យេនឌ័រ និងការប្រែប្រួលអាកាសធាតុដើម្បីពង្រឹងការស្រាវជ្រាវអនាគត។ វាព្យាយាមកំណត់ទិដ្ឋភាពបច្ចុប្បន្នដែលមិនមែនជាផ្នែកដែលបានលើកឡើង។ |
| ភ្នាក់ងារ អភិវឌ្ឍអន្តរជាតិប្រទេសកាណាដា (CIDA). (n.d.). **សមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ៖ ហេតុអ្វីគិតគូរពីសមភាពយេនឌ័រនៅពេលធ្វើសកម្មភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ?** ដកស្រង់ពីគេហទំព័រ៖ http://www.acdicida.gc.ca/INET/IMAGES.NSFvLUImages/Climate%20change3/$-file/Gender-2.pdf | វិភាគពីទំនាក់ទំនងសមធម៌យេនឌ័រ និងការប្រែប្រួលអាកាសធាតុទាក់ទងនឹងសំនួរ៖ ហេតុគិតគូរពីសមធម៌ យេនឌ័រនៅពេលធ្វើសកម្មភាពលើការប្រែប្រួលអាកាសធាតុ? ធ្វើការទាក់ទងនឹងបញ្ហាដែលមានសារៈសំខាន់ទាំងនេះដូចជា សន្តិសុខស្បៀង ធនធានដែលផ្សំនឹងទឹក និងផលប៉ះពាល់ការប្រែប្រួលអាកាសធាតុលើសុខភាពមនុស្ស។ |

| ឯកសារយោង | បរិយាយ |
|---|---|
| CAPWIP, ISDR, WEDO, GGCA, UNDP, UNEP, IUCN, UNIFEM, ADB and IPU. (ឆ្នាំ២០០៨). **សេចក្តីថ្លែងការណ៍ទីក្រុងម៉ានិលដើម្បីសកម្មភាពសកលស្តីពីយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យ។** Third Global Congress of Women in Politics and Governance. ដកស្រង់ពីគេហទំព័រ៖ http://www.capwip.org/3rdglobalcongress.htm | អ្នកចូលរួមនៅក្នុងសន្និបាតពិភពលោកស្ត្រីលើកទី៣ ស្តីពីស្ត្រីក្នុងនយោបាយ និងអភិបាលកិច្ច យេនឌ័រក្នុងការបន្សុំាការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយដែលជួបជុំគ្នានៅទីក្រុងម៉ានិល ប្រទេសហ្វីលីពីន ថ្ងៃទី១៩-២២ ខែតុលា ឆ្នាំ២០០៨ ដើម្បីព្រាងសេចក្តីថ្លែងការណ៍ក្នុងការស្វែងរកការគាំទ្រមតិសម្រាប់ដាក់បញ្ចូលការគិតគូរយេនឌ័រ នៅក្នុង UNFCCC COP-14 (Poznan), COP-15 (Copenhagen), ផ្នែកទី២នៃវេទិកា ការកាត់ បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយពិភពលោក។ |
| Dankelman, I. (ឆ្នាំ២០០២). **ការប្រែប្រួលអាកាសធាតុ៖ រៀនពីការវិភាគយេនឌ័រ និងបទពិសោធន៍របស់ស្ត្រីក្នុងរៀបចំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។** *នៅក្នុង៖ យេនឌ័រ និងការអភិវឌ្ឍ,* Vol.10, pp. 21–29. ដកស្រង់ពីគេហទំព័រ៖ http://www.informaworld.com/smpp/content~content=a741921472~db=all~order=page | ស្វែងរកទំនាក់ទំនងជាក់លាក់ និងបច្ចុប្បន្ន រវាងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងភាពទាក់ទងច្បាស់លាស់សម្រាប់យេនឌ័រនៃនិន្នាការនេះ។ វាក៏បានផ្តល់នូវឧទាហរណ៍ ដែលស្ត្រីបានរៀបចំដើម្បីធ្វើការផ្លាស់ប្តូរលើបញ្ហានេះ ដែលទាក់ទងនឹងការអភិវឌ្ឍប្រកបដោយចីរភាព ជាពិសេស ការរៀបចំ សន្និសីទកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព។ វាបង្ហាញដែលការចូលរួមរបស់ស្ត្រីអាចនាំមកនូវលទ្ធផលរំញោចកាន់តែខ្លាំងលើប្រធានបទយេនឌ័រ។ |
| Dankelman, I., Alam, K., Bashir Ahmed, W., Diagne Gueye, Y., Fatema, N. and Mensah-Kutin, R. (ឆ្នាំ២០០៨). **យេនឌ័រ ការប្រែប្រួលអាកាសធាតុ និងសន្តិសុខមនុស្ស៖ មេរៀនពីប្រទេស Bangladesh, Ghana និង Senegal.** WEDO, ABANTU for Development in Ghana, ActionAid Bangladeshand ENDA in Senegal. | របាយការណ៍នេះ រួមមានការពិនិត្យមើលអត្ថបទទូទៅស្តីពី យេនឌ័រ ការប្រែប្រួលអាកាសធាតុ និងសន្តិសុខមនុស្ស និងផ្តល់ជាឧទាហរណ៍លើករណីសិក្សាផ្សេងៗគ្នានៅក្នុងប្រទេសសេណេហ្គាល ហ្គាណា និងបង់ក្លាដេស ។ |
| Dennison, C. (ឆ្នាំ២០០៣) **ពីប៉េកាំង ទៅកាន់ក្យូតូ៖ ការដាក់បញ្ចូលយេនឌ័រទៅក្នុងដំណើរការចរចាការប្រែប្រួលអាកាសធាតុអន្តរជាតិ។** ដកស្រង់ពីគេហទំព័រ៖ http://www.pugwash.org/reports/pac/53/dennison.htm | ក្រៅពីកិច្ចខិតខំប្រឹងប្រែងរបស់អង្គការសហប្រជាជាតិក្នុងការបញ្ជ្រាបបរិបទយេនឌ័រ សកម្មភាព កិច្ចពិភាក្សាតទល់ និងការចរចាអំពីការងារការប្រែប្រួលអាកាសធាតុស្ថិតនៅជំហរអព្យាក្រិត។ ឯកសារនេះលើកឡើងថា ការចរចារថ្នាក់អន្តរជាតិនឹងមិនត្រឹមត្រូវតាមច្បាប់ ឬមានប្រសិទ្ធិភាពទេប្រសិនបើការចរចារនេះមិនពិចារណារទៅលើបរិបទសមភាពយេនឌ័រ។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| DDenton, F. (ឆ្នាំ២០០១). **ការប្រែប្រួលអាកាសធាតុ យេនឌ័រ និងភាពក្រីក្រ – Academic Babble or Realpolitik?** ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/FatmaDenton.pdf | តើអ្វីដែលយេនឌ័រត្រូវធ្វើជាមួយនឹងបញ្ហាទាំងនេះ? វាជាសំនួរដែលអត្ថបទចាប់ផ្ដើម។ មិនមានចម្ងល់ទេ ដែលការប្រែប្រួលអាកាសធាតុ និងធាតុនានារបស់វានឹងមានឥទ្ធិពលដ៏មហិមាលើជីវិតបុរស និងស្ត្រី។ ការប្រែប្រួលអាកាសធាតុ ត្រូវបានកំណត់ជានិន្នាការគន្លឹះក្នុងយុគសម័យរបស់យើង–ក្រុមនៃព្រឹត្តិការណ៍ដែលអាចប្រែក្លាយជីវិតរបស់មនុស្សជាទូទៅ។ឯកសារនេះបង្ហាញថាការប្រែប្រួលអាកាសធាតុនឹងធ្វើឱ្យកាន់តែមានគម្លាតរបស់អ្នកមាន និងអ្នកក្រនៅក្នុងពិភពលោក លើសអ្វីទាំងអស់ វានឹងនាំឱ្យមានគម្លាតយេនឌ័រកាន់តែធំ។ |
| Denton, F. (ឆ្នាំ២០០៤). **យេនឌ័រ និងការប្រែប្រួលអាកាសធាតុ៖ ផ្ដល់ជូនអ្នកដែលមកយឺតនូវការចាប់ផ្ដើមនាំមុខ។** In: *IDS Bulletin*, 2004;35(3):42-49. ដកស្រង់ពីគេហទំព័រ៖http://www.ids.ac.uk/ids/bookshop/bulletin/bull353abs.htm#gender | ផ្ដោតការយកចិត្តទុកដាក់លើបញ្ហាសំខាន់ៗ៣លើប្រធានបទការប្រែប្រួលអាកាសធាតុ- កសិកម្ម ទឹកនិងថាមពល និងគិតគូរថាតើយុទ្ធសាស្ត្របន្សាំត្រូវបានរៀបចំដើម្បីជួយស្ត្រីនិងបុរសនៅក្នុងវិស័យទាំងនេះ កាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ការស្នើយោបល់ រួមបញ្ចូលគម្រោងគ្រប់គ្រងព្រៃឈើដែលធ្វើការកសាងសមត្ថភាព បង្កើនផលិតផល គុណភាពដី និងអភិរក្សទឹក។ |
| Duddly, J. (ឆ្នាំ២០០៥). **តើការប្រែប្រួលអាកាសធាតុ ជាបញ្ហាយេនឌ័រឬ?** AWID. ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/Is%20climate%20change%20a%20gender%20issue.pdf | គូសបញ្ជាក់ពីភាពធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុដែលរៀបចំដោយសហគមន៍វិទ្យាសាស្ត្រ ប៉ុន្តែមើលរំលងដោយអ្នកធ្វើគោលនយោបាយអន្តរជាតិ។ វារាយការណ៍ពីភាពងាយរងគ្រោះរបស់សហគមន៍ Inuit ជាមួយនឹងការគិតគូរពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដោយសង្កត់ធ្ងន់លើផលប៉ះពាល់ដែលមានលើស្ត្រី។ |
| EDNA/IRADE. (ឆ្នាំ២០០៦). **តើទិដ្ឋភាពយេនឌ័រនៃការប្រែប្រួលអាកាសធាតុត្រូវបានបំភ្លេច ឬ?** ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/cop8_gender.pdf | សង្ខេបកិច្ចប្រជុំ របស់ UNFCCC COP 8 ស្ដីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។ វារួមបញ្ចូល អនុសាសន៍ តារាងអ្នកចូលរួម និងសំណើសំខាន់ៗ ដើម្បីដោះស្រាយបញ្ហាយេនឌ័រ ក្នុងកិច្ចជជែកពិភាក្សានេះ។ |

| ឯកសារយោង | បរិយាយ |
|---|---|
| EGender CC. ( ឆ្នាំ២០០៨ ). **Gender CC Contribution on REDD.** Submitted at UNFCCC COP 14, Poznan, 2008. Retrieved from the ដកស្រង់ពីគេហទំព័រ៖ http://www.gender-cc.net/fileadmin/inhalte/Dokumente/UNFCCC_conferences/COP14/Gendercc_submission_REDD.pdf | ឯកសារនេះសង្ខេបពីគោលជំហរលើ REDD ដែលបានបង្ហាញ និងដាក់ជូនដោយ Gender CC នៅ UNFCCC COP 14 ក្នុង Poznan, ឆ្នាំ២០០៨។ |
| Global Environment Facility. ( ឆ្នាំ២០០៨ ). **បញ្ជ្រាបយេនឌ័រនៅ GEF.** ដកស្រង់ពីគេហទំព័រ៖ http://www.gefweb.org/uploadedFiles/Publications/mainstreaming-gender-at-the-GEF.pdf | ឯកសារនេះវិភាគលើការងារដែលបានធ្វើនៅ GEF ទាក់ទងនឹងការបញ្ជ្រាបយេនឌ័រក្នុងវិស័យគោល៦ ដែលរួមបញ្ចូល ការប្រែប្រួលអាកាសធាតុផងដែរ។ វាបានផ្តល់នូវឧទាហរណ៍នៃគម្រោង កំណត់ជាការអនុវត្តល្អបំផុតនិងបទពិសោធន៍។ |
| Gurung, J., Mwanundu, S., Lubbock, A., Harti, M. and Firmian, I. (ឆ្នាំ២០០៦ ).**យេនឌ័រ និងការបោះបង់ដី៖ ពង្រីកតួនាទីស្ត្រីដើម្បីស្តារដីស្ងួត។** IFAD. ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/gender_desert.pdf | អ្នកនិពន្ធបានលើកឡើងថានៅក្នុងតំបន់ស្ងួតក្នុងពិភពលោកចំណេះដឹងស្ត្រី ក៏ដូចជាតួនាទីជាប្រពៃណីដែលពួកគេអនុវត្ត ក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងសន្តិសុខស្បៀង មានសារៈសំខាន់។ ទោះបីជាយ៉ាងណាក៏ដោយ ស្ត្រី ត្រូវបានគេដកចេញពីការចូលរួមអភិរក្សដី ក្នុងគម្រោងអភិវឌ្ឍ និងការធ្វើគោលនយោបាយ។ |
| Hartmann, B. (2007). **Género, militarismy cambio climático.** IADE. ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/generomilitar.pdf | វិធីសាស្រ្តយេនឌ័រ ក្នុងកិច្ចពិភាក្សាទាក់ទងនឹងការប្រែប្រួលអាកាសធាតុជាដើមហេតុនៃកង្វល់។ ការសិក្សាថ្មីៗ និងយុទ្ធនាការស្ត្រី ប្រឈមនឹងភាពមើលមិនឃើញនៃយេនឌ័រ ជាពិសេស ការចង្អុលបង្ហាញពីភាពខុសគ្នាយេនឌ័រក្នុងងាយរងគ្រោះនិងការបន្សុាំទៅនឹងការឡើងកំដៅផែនដី។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| Hemmati, M. (2005). យេនឌ័រ និងការប្រែប្រួលអាកាសធាតុនៅតំបន់ខាងជើង៖ បញ្ហាចំណុចចូល និង យុទ្ធសាស្ត្រសម្រាប់ដំណើរការក្រោយឆ្នាំ ២០១២។ Genanet. ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/Genderkyotopost.pdf | អ្នកនិពន្ធដែលជាជនបង្គោល Genanet សម្រាប់យុត្តិធម៌យេនឌ័រ និងចីរភាព គិតដល់ទិដ្ឋភាពទាក់ទងនៃប្រធានបទយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ជាទូទៅក្នុងប្រទេសឧស្សាហកម្ម។ លោកស្រីព្យាយាមបង្កើនការយកចិត្តទុកដាក់ជាយុទ្ធសាស្ត្រសម្រាប់អង្គការស្ត្រីនៅប្រទេស Germany, អឺរ៉ុប និងតំបន់ជាទូទៅក្នុងក្របខណ្ឌនៃការរៀបចំដែលកំពុងបង្កើតសម្រាប់ការចរចាពិភពលោកស្តីពីការប្រែប្រួលអាកាសធាតុ ក្រោយឆ្នាំ២០១២។ |
| Hoddinott, J. and Kinsey, B. (ឆ្នាំ២០០០). សុខភាពមនុស្សជំទង់ ក្នុងពេលរាំងស្ងួត។ ការស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ។ Institute Discussion Paper.ដកស្រង់ពីគេហទំព័រ http://www.ifpri.org/divs/fcnd/dp/papers/dp79.pdf | ឯកសារនេះ វិភាគពីផលប៉ះពាល់នៃភាពរាំងស្ងួតនៅឆ្នាំ១៩៩៤-១៩៩៥ លើសុខភាពមនុស្សវ័យជំទង់ក្នុងតំបន់ជនបទក្នុងប្រទេសស៊ីមបាវេ។ |
| IPADE. (n.d.). **El cambio climático y losObjetivos de Desarrollo del Milenio.** ដកស្រង់ពីគេហទំព័រ៖ http://www.pobrezacero.org/objetivos/documentos/cambio_climatico_odm.pdf | បកស្រាយពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងគោលដៅអភិវឌ្ឍសហស្សវត្សរ៍ និងការការពារបរិស្ថាន និងប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ លើសពីអ្វីទាំងអស់ រាល់គោលដៅនីមួយៗមានទំនាក់ទំនងជាក់លាក់ទៅនឹងការប្រែប្រួលអាកាសធាតុដោយសារវាមានទំនាក់ទំនងផ្ទាល់លើលទ្ធភាពក្នុងការសម្រេចបានគោលដៅទាំងនោះ។ ដូច្នោះ ការសម្រេចបាន MDGs កំពុងរងឥទ្ធិពលដោយការផ្លាស់ប្តូរអាកាសធាតុ និងផលប៉ះពាល់ផ្សេងៗទៀត ហើយវាធ្វើឱ្យកាន់តែអាក្រក់ទៅលើភាពក្រីក្រនៃក្រុមជនដែលងាយរងគ្រោះបំផុត។ |
| Lambrou, Y. and Piana, G. (ឆ្នាំ២០០៦). យេនឌ័រ៖ ជាតុដែលបាត់បង់ការឆ្លើយតបការប្រែប្រួលអាកាសធាតុ។ ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/pe1_051001d1_en.pdf | របាយការណ៍នេះ បង្ហាញថា យេនឌ័រ ក៏ដូចជាភាពក្រីក្រ ជាបញ្ហាកាត់ឆ្លងក្នុងការប្រែប្រួលអាកាសធាតុ និងត្រូវតែទទួលស្គាល់។ សេចក្តីសន្និដ្ឋាន បង្ហាញថាការគិតគូរពីយេនឌ័រ ជាទូទៅ ត្រូវបានមើលរំលងដោយគោលនយោបាយអន្តរជាតិស្តីពីអាកាសធាតុ។ ទើបតែប៉ុន្មានឆ្នាំចុងក្រោយ ជាមួយនឹងកិច្ចប្រជុំ UNFCCC COP 8 (ធ្វើនៅ New Delhi ក្នុងខែតុលា ឆ្នាំ២០០២) និង COP 9 (ធ្វើនៅ Milan ខែធ្នូ ឆ្នាំ២០០៣) ដែលយេនឌ័រដោយចៃដន្យត្រូវបានដោះស្រាយ។ |

| ឯកសារយោង | បរិយាយ |
|---|---|
| Laub, R. and Lambrou, Y. (ឆ្នាំ២០០៤). គោលគំនិតយេនឌ័រលើអនុសញ្ញាស្តីពីជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ និងការបោះបង់ដី។- FAO Gender and Population Division. ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/genderconventions.pdf | បកស្រាយហេតុអ្វីនៅក្នុងអនុសញ្ញាស្តីពីជីវៈចម្រុះការប្រែប្រួលអាកាសធាតុ និងការបោះបង់ដីធ្លី ក៏ដូចជានៅក្នុងយន្តការអនុវត្ត គោលគំនិតយេនឌ័រមិនត្រូវបានគិតគូរដោយសមភាព។ គោលបំណងនៃឯកសារនេះ គឺអះអាងជាថ្មីការអនុម័តគោលគំនិតយេនឌ័រនៅក្នុងកិច្ចព្រមព្រៀងបរិស្ថានពហុភាគី (MEA)។ |
| Masika, R. (Ed.) (ឆ្នាំ២០០២). យេនឌ័រ ការអភិវឌ្ឍ និងការប្រែប្រួលអាកាសធាតុ។ ដកស្រង់ពីគេហទំព័រ៖ http://publications.oxfam.org.uk/oxfam/display.asp?K=9780855984793&sf_01 | សៀវភៅនេះ គិតគូរពីទិដ្ឋភាពយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុ។ វាបង្ហាញថា ការវិភាគយេនឌ័រ និងទំនាក់ទំនងជិតស្និទនៃប្រធានបទនេះជាមួយនឹងភាពក្រីក្រ ត្រូវបានពិចារណានៅក្នុងកិច្ចពិភាក្សាអន្តរជាតិ។ វាបង្ហាញពីសារៈសំខាន់នៃការដាក់បញ្ចូលប្រធានបទយេនឌ័រ នៅពេលធ្វើការស្វែងយល់ផលប៉ះពាល់ការប្រែប្រួលបរិស្ថានពិភពលោកមកលើសហគមន៍មនុស្ស។ |
| Neumayer, E. និង Plümper, T. (ឆ្នាំ២០០៧). លក្ខណៈយេនឌ័រនៃគ្រោះមហន្តរាយធម្មជាតិ៖ ផលប៉ះពាល់នៃព្រឹត្តិការណ៍មហន្តរាយលើគម្លាតយេនឌ័រក្នុងអាយុរំពឹងរស់ឆ្នាំ១៩៨១-២០០២។ ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/schooleconomis.pdf | មហន្តរាយមិនផលប៉ះពាល់មនុស្សគ្រប់រូបដូចៗគ្នានោះទេ។ ទស្សនទាននៃភាពងាយរងគ្រោះបង្ហាញថាវិសមភាពជាលក្ខខណ្ឌហានិភ័យការទទួលបានធនធាន និងឱកាស និងលទ្ធភាពមានភាពខុសៗគ្នាសម្រាប់ស្ត្រី និងបុរស។ ប្រធានបទរួមនៃឯកសារនេះ ជាការវិភាគនៃភាពងាយរងគ្រោះរបស់ស្ត្រី និងក្មេងស្ត្រីដែលអាចនឹងរងគ្រោះកាន់តែច្រើនពីលទ្ធផលអវិជ្ជមាននៃមហន្តរាយ។ |
| BothENDS.(ឆ្នាំ២០០៧).បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ៖ អ្វីដែលត្រូវការក្នុងប្រទេសក្រីក្រ និងអ្នកណាជាអ្នកផ្តល់ឱ្យ។ ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/bpadapting_to_climate_change-0708.pdf | ការប្រែប្រួលអាកាសធាតុបង្ខំឱ្យសហគមន៍ក្នុងប្រទេសក្រីក្របន្សាំនឹងផលប៉ះពាល់ដែលពុំធ្លាប់មានពីមុន។ ប្រទេសអ្នកមាន ដែលទទួលខុសត្រូវការស្តីបន្ទោសភាគច្រើនលើបញ្ហាត្រូវតែបញ្ឈប់ការធ្វើឱ្យមានការខូចខាត = ដោយកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ = និងចាប់ផ្តើមជួយផ្តល់ជាមូលនិធិសម្រាប់ការបន្សាំនឹងការផ្លាស់ប្តូរ។ OXFAM ព្យាករណ៍ថា នៅក្នុងប្រទេសកំពុងអភិវឌ្ឍការបន្សាំបែបនេះចំណាយជាអប្បបរមា ៥០.០០០លានដុល្លារក្នុងមួយឆ្នាំ។ តួលេខនេះអាចកើនឡើងគួរឱ្យកត់សម្គាល់ ប្រសិនបើការបញ្ចេញឧស្ម័ននៅលើពិភពលោកមិនត្រូវបានកាត់បន្ថយឱ្យទាន់ពេលវេលា។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| Rivero, R. (ឆ្នាំ២០០២). **ការធ្វើឱ្យមានយេនឌ័រក្នុងការឆ្លើយតបលើ ElNiño នៅ Rural Peru។** នៅក្នុង៖ Gender & Development, Vol. 10, pp. 60–69. ដកស្រង់ពីគេហទំព័រ៖ http://www.informaworld.com/smpp/content~content=a741921478~db=all~order=page | ឆ្លុះបញ្ចាំងលើបទពិសោធន៍ពីវិធីសាស្ត្រយេនឌ័រនៅ Centre for Andean Advancement and Development (CEPRODA MINGA)។ ឆ្លុះបញ្ចាំងនេះធ្វើឡើងកំឡុងពេលអ្នកនិពន្ធធ្វើការជាមួយសហគមន៍ក្រីក្រក្នុងតំបន់ Piura, Peru, បន្ទាប់ពីព្រឹត្តការណ៍ El Niño ក្នុងឆ្នាំ១៩៩៧-៨។ វាផ្តោតលើមធ្យោបាយជាប្រពៃណីដែលសហគមន៍ជនបទ និងជាពិសេស ស្ត្រី មិនត្រូវបានដាក់បញ្ចូលការរៀបចំគោលនយោបាយ និងគិតគូរថាពួកគេអាចក្លាយជាអ្នកពាក់ព័ន្ធសង្គម និងនយោបាយដ៏មានឥទ្ធិពលក្នុងការបង្កើតយុទ្ធសាស្ត្រកាត់បន្ថយ និងអភិវឌ្ឍប្រកបដោយចីរភាពរបស់ពួកគេ។ |
| Röhr, U. (ឆ្នាំ២០០៤). **ទំនាក់ទំនងយេនឌ័រក្នុងការចរចាការប្រែប្រួលអាកាសធាតុអន្តរជាតិ ។** Genanet. ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/Gender_climate_policy_en_updated.pdf | សមធម៌យេនឌ័រមិនត្រូវបានលើកឡើងក្នុង UNFCCC ទោះបីវាជាផ្នែករួមនៃរបៀបវារៈ២១ក៏ដោយ។ វាមិនត្រូវបានបញ្ចូលរហូតដល់ឧបករណ៍ពិធីសារក្យូតូ ត្រូវបានបង្កើតជាពិសេសយន្តការអភិវឌ្ឍស្អាត (CDM) ដែលការគិតគូរយេនឌ័រចាប់ផ្តើមទាក់ទាញចំណាប់អារម្មណ៍អ្នកជំនាញលើប្រធានបទនេះ។ ចាប់ពីពេលនោះមក ការយកចិត្តទុកដាក់លើគោលជំហរភាគច្រើន ដែលអនុម័ត និងការវិភាគដែលធ្វើឡើងពីទស្សនទានយេនឌ័រ ផ្តោតជាពិសេសលើស្ត្រីក្នុងប្រទេសកំពុងអភិវឌ្ឍ។ នៅក្នុងប្រទេសទាំងនេះហើយ ដែលគម្រោង CDM កំពុងបានអនុវត្ត និងបណ្តាញស្ត្រីក្នុងផ្នែកថាមពលកាន់តែច្រើន។ |
| Röhr, U., Alber, G., Skutsch, M., Rose, J. និង van der Heul R. (ឆ្នាំ២០០៤) **បញ្ជ្រាបយេនឌ័រនៅក្នុងជំនាន់ការប្រែប្រួលអាកាសធាតុ។** ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/Gender_and_climate_change_COP10.pdf | សេចក្តីថ្លែងការណ៍របស់ក្រុមស្ត្រីនៅក្នុងកិច្ចប្រជុំ UNFCCC COP 10 ដែលធ្វើឡើងនៅទីក្រុងBuenos Aires, ប្រទេសអាហ្សង់ទីន។ អ្នកនិពន្ធបញ្ជាក់ថា អង្គការសហប្រជាជាតិបានធ្វើការប្តេជ្ញាចិត្តជាផ្លូវការក្នុងការបញ្ជ្រាបវិធីសាស្ត្រយេនឌ័រ ទៅក្នុងគ្រប់កម្មវិធី និងគោលនយោបាយរបស់ខ្លួន; ទោះបីជាយ៉ាងណាក៏ដោយអង្គការនេះនៅតែមិនទាន់យល់ថាហេតុអ្វីយេនឌ័រជាកត្តាដែលគួរគិតគូរនៅក្នុងការប្រែប្រួលអាកាសធាតុ ឬមធ្យោបាយដែលវាគួរតែត្រូវបានដាក់បញ្ចូល។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| Röhr, U. និង Hemmati, M. (ឆ្នាំ២០០៦). **ហេតុអ្វីធ្វើឱ្យវាខុសគ្នា៖យេនឌ័រ និងការប្រែប្រួលអាកាសធាតុ នៅកិច្ចប្រជុំ COP11/MOP1. Results from UNFCCC COP 11.** ដកស្រង់ពីគេហទំព័រ៖ http://www.wecf.de/cms/articles/2006/01/montreal.php | បង្ហាញពីការវិភាគនៃលទ្ធផលដែលទទួលបានពីក្រុមស្ត្រីនៅសន្និសីទ UNFCCC Conference of the Parties នៅទីក្រុងម៉ុងទ្រាល (Montreal) (COP-11/MOP1)។ វាចាត់ទុកប្រធានបទយេនឌ័រនៅក្នុងកិច្ចពិភាក្សា និងការចរចាស្ដីពីការប្រែប្រួលអាកាសធាតុ។ |
| Röhr, U., Spitzner, M., Stiefel, E., និង Winterfeld, U. (ឆ្នាំ២០០៨). **យុត្តិធម៌យេនឌ័រ ជាមូលដ្ឋានសម្រាប់គោលនយោបាយអាកាសធាតុប្រកបដោយចីរភាព។** ដកស្រង់ពីគេហទំព័រ៖ http://www.gendercc.net/fileadmin/inhalte/Dokumente/UNFCCC_conferences/COP14/Gender_Justice_CC_enfinal.pdf | វាពិនិត្យមើលប្រធានបទយុត្តិធម៌យេនឌ័រ និងអាកាសធាតុ ដោយមើលទិដ្ឋភាពដូចជា៖ ទស្សនទាននៃយុត្តិធម៌ដែលមិនសមរម្យទាក់ទងនឹងយេនឌ័រ ប៉ុន្តែជាការបង្ហាញពីតថភាពដែលកំណត់ដោយឋានានុក្រមយេនឌ័រ។ ដូច្នោះ ការវិភាគស្ត្រីនិយមដ៏សំខាន់មួយត្រូវបានស្នើ ជាមួយគ្នានេះ ពិនិត្យថាតើវិធីសាស្ត្រមានគោលបំណងសម្រេចបានយុត្តិធម៌ អាចនឹងចូលរួមការបន្ត ឬ ការផ្លាស់ប្ដូរក្នុងទំនាក់ទំនងទូទៅ។ |
| Skutsch, M. (ឆ្នាំ២០០២).**ពិធីសារ សន្ធិសញ្ញា និងសកម្មភាព៖ដំណើរការការប្រែប្រួលអាកាសធាតុពិនិត្យមើលតាមរយៈទស្សនីយភាពយេនឌ័រ។** នៅក្នុង៖ Gender & Development, Vol. 10, pp. 30–39. ដកស្រង់ពីគេហទំព័រ៖ http://www.informaworld.com/smpp/content~content=a741921471~b=all~order=page | ការស្រាវជ្រាវនេះ ចាប់ផ្ដើមដោយការវាយតម្លៃវិសាលភាពដែលយេនឌ័រត្រូវបានគិតគូរក្នុងដំណើរការអន្តរជាតិ ក្នុងការរៀបចំគោលនយោបាយការប្រែប្រួលអាកាសធាតុ។ វាស្វែងរកថាតើមានការគិតគូរយេនឌ័រគ្រប់គ្រាន់ក្នុងទំនាក់ទំនងលើ (ក) ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (ខ) ភាពងាយរងគ្រោះការប្រែប្រួលអាកាសធាតុ និង (គ) ការចូលរួមក្នុងគម្រោងដែលធ្វើហិរញ្ញប្បទានកិច្ចខិតខំទាក់ទងនឹងអាកាសធាតុ។ វាធ្វើសេចក្ដីសន្និដ្ឋានដោយស្នើលើផ្នែកដែលចាប់អារម្មណ៍ ដែលគោលគំនិតយេនឌ័រគួរបង្កើនប្រសិទ្ធភាពអន្តរាគមន៍ទាក់ទងនឹងអាកាសធាតុ និងបានផ្ដល់អត្ថប្រយោជន៍ដល់ស្ត្រីផងដែរ។ |

| ឯកសារយោង | បរិយាយ |
|---|---|
| ធនាគារពិភពលោក.(ឆ្នាំ២០០៤) ដាក់បញ្ចូលយេនឌ័រក្នុងបច្ចេកវិទ្យាទំនាក់ទំនង និងព័ត៌មាន។ ដកស្រង់ពីគេហទំព័រ៖ http://siteresources.worldbank.org/INTGENDER/Seminar-Series/20260878/ictbrochure.pdf | ឯកសារនេះ បង្កើតនូវទំនាក់ទំនងរវាង ICT និងសមភាពយេនឌ័រ។ វាបង្ហាញពីមធ្យោបាយដែល ICT អាចលើកកម្ពស់សមភាពយេនឌ័រ តាមរយៈការផ្ដល់ឧទាហរណ៍គម្រោងជាក់លាក់។ វាស្នើនូវអនុសាសន៍លើមូលដ្ឋានបទពិសោធន៍ការងាររបស់ធនាគារពិភពលោក។ |
| fUNDP. (ឆ្នាំ២០០៨). Guía: Recursos de Géneropara el Cambio Climático. Mexico. ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/guiaccpnud.pdf | ការណែនាំនេះស្នើឱ្យមានសុខដមនីកម្មនៃរបៀបវារៈអន្តរជាតិ ស្តីពីសមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងស្នើនូវទស្សនៈនៃកិច្ចពិភាក្សាចម្រុះ ការស្រាវជ្រាវ និងការអនុវត្ត ទាក់ទងនឹងយេនឌ័រ និងការប្រែប្រួលអាកាសធាតុជាវិន័យរួម។ ការណែនាំនេះ ជាឧបករណ៍ដែលព្យាយាមចាកចេញពីសកម្មភាពឯកា ទៅកាន់ផែនការច្បាស់លាស់ ដែលនឹងឱ្យមានការចូលរួមក្នុងបញ្ហាការប្រែប្រួលអាកាសធាតុ ពីគោលគំនិតយេនឌ័រកាន់តែមានប្រសិទ្ធភាព។ |
| Villagrasa, D. (ឆ្នាំ២០០២). **ការចរចាពិធីសារក្យូតូ៖ ការឆ្លុះបញ្ចាំងលើតួនាទីស្ត្រី។** នៅក្នុង៖ Gender & Development, Vol. 10, pp. 40–44. ដកស្រង់ពីគេហទំព័រ៖ http://www.informaworld.com/smpp/content~content=a741921479~db=all~order=page | វិភាគដោយសង្ខេបសហគមន៍ចំនួន៣ ដែលសម្រេចពិធីសារក្យូតូ ក្របខ័ណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) និងតួនាទីវិធីសាស្ត្រយេនឌ័រក្នុងកិច្ចពិភាក្សាទាំងនេះ។ សហគមន៍ទី១ គឺជា តំណាងរដ្ឋាភិបាលដែលជាភាគីចរចាដ៏សំខាន់បំផុត។ ទី២ រួមមានតំណាងពាណិជ្ជកម្ម និងទី៣ មានអង្គការក្រៅរដ្ឋាភិបាលធ្វើការទាក់ទងនឹងបរិស្ថាន។ |
| Wamukonya, N. និង Rukato, H. (ឆ្នាំ២០០១). **ការទាក់ទងនឹងការប្រែប្រួលអាកាសធាតុសម្រាប់តំបន់ខាងត្បូងអាហ្វ្រិក៖ គោលគំនិតយេនឌ័រ។** ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/wamukonyarukato.pdf | សមត្ថភាពប្រទេសអាហ្វ្រិកខាងត្បូងក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ អាស្រ័យថាតើ ធនធាន ទាំងមនុស្ស និងហិរញ្ញវត្ថុ មានគ្រប់គ្រាន់ឬទេ។ ភូមិសាស្ត្រ និងស្ថានភាពនយោបាយរបស់វា អាចមានផលប៉ះពាល់លើសមត្ថភាពក្នុងការឆ្លើយតប។ ឯកសារនេះ វិភាគពីការទាក់ទងនៃការប្រែប្រួលអាកាសធាតុសម្រាប់ប្រទេសនេះ ផ្អែកលើទស្សនៈយេនឌ័រ។ |

| ឯកសារយោង | បរិយាយ |
|---|---|
| Wamukonya, N. and Skutsch, M. (2002). **មុំយេនឌ័រលើការចរចាការប្រែប្រួលអាកាសធាតុ។** នៅក្នុង៖ *Energy & Environment*, Vol. 13, No. 1, pp.115–124 (10). ដកស្រង់ពីគេហទំព័រ៖ http://www.ingentaconnect.com/content/mscpene/2002/00000013/00000001/art00007 | តំបន់ខាងត្បូង ដោយសារស្ថានភាពងាយរងគ្រោះរបស់វា និងការខ្វះខាតធនធានក្នុងការបន្សាំទៅនឹងការផ្លាស់ប្តូរងាយទទួលរងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុជាងតំបន់ខាងជើង។ ប៉ុន្តែ តើមានអត្ថប្រយោជន៍ខុសគ្នារវាងស្ត្រី និងបុរសទាក់ទងនឹងការប្រែប្រួលអាកាសធាតុ មានទិដ្ឋភាពខាងជើង-ខាងត្បូង? |
| Women in Europe for a Common Future (WECF). (ឆ្នាំ២០០៥) **សិក្ខាសាលាស្រាវជ្រាវយេនឌ័រ និងការប្រែប្រួលអាកាសធាតុ៖ អ្វីយើងដឹង? អ្វីដែលយើងត្រូវរក?** ដកស្រង់ពីគេហទំព័រ៖ http://www.siyanda.org/static/wecf_gender_climatechange_workshop.htm | ដំណើរការពិភាក្សារវាងអ្នកជំនាញ ទាំងស្ត្រី និងបុរស លើបញ្ហាយេនឌ័រ និងការស្រាវជ្រាវការប្រែប្រួលអាកាសធាតុ។ ការផ្តោតលើតួនាទីរបស់ស្ត្រី និងផលប៉ះពាល់របស់ពួកគេលើគោលនយោបាយយេនឌ័រ ក្នុង UNFCCC។ |
| អង្គការអភិវឌ្ឍ និងបរិស្ថានស្ត្រី (WEDO). (ឆ្នាំ២០០៣). **បណ្តាញដែលមិនភ្ជាប់៖ យេនឌ័រ ទឹក និងភាពក្រីក្រ។** ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/untapped.pdf | រួមបញ្ចូនការវិភាគ ថាតើប្រធានបទទឹក យេនឌ័រ និងភាពក្រីក្រ ត្រូវបានបញ្ចូលក្នុងសន្ធិសញ្ញាអន្តរជាតិ ផែនការសកម្មភាពរដ្ឋាភិបាល ក៏ដូចជា ការទាក់ទងនៅថ្នាក់មូលដ្ឋាន។ ករណីសិក្សាលើប្រធានបទក៏ត្រូវបានបង្ហាញផងដែរ។ |
| ទស្សនាវដ្តីអន្តរជាតិស្ត្រីនិងបរិស្ថាន (ឆ្នាំ២០០៧) **ស្ត្រី និងការប្រែប្រួលអាកាសធាតុសកល។** No. 74/75 Spring/Summer 2007 ដកស្រង់ពីគេហទំព័រ៖ http://www.weimag.com/ | ទស្សនាវដ្តីអន្តរជាតិ ស្ត្រី និងបរិស្ថាន ពិនិត្យ ឈរលើទស្សនៈស្ត្រី ថាតើស្ត្រីទាក់ទងនឹងបរិស្ថានរបស់ពួកគេ – ធម្មជាតិ ការកសាង និងសង្គម។ ការបោះពុម្ពនេះ ឧទ្ទិសដល់ប្រធានបទ ស្ត្រី និងការប្រែប្រួលអាកាសធាតុ៖ វារួមមានព័ត៌មានលើបញ្ហាដែលទាក់ទង ដូចជា សុខភាព ភាពរាំងស្ងួត ការបន្សាំ និងការកាត់បន្ថយ ថាមពល និងករណីសិក្សាលើប្រធានបទនេះ។ |

| ឯកសារយោង | បរិយាយ |
|---|---|
| សេចក្តីថ្លែងការណ៍ក្រុមស្ត្រីស្តីពី យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ដែលបានបង្ហាញនៅកិច្ចប្រជុំ UNFCCC ក្នុងទីក្រុង Montreal. (ឆ្នាំ២០០៥). **ការឡើងកំដៅផែនដី៖ ស្ត្រីសំខាន់!** ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/genderstatementUNFCCC.pdf | បរិយាយពីគោលជំហរ ក្រុមស្ត្រី និងការប្រែប្រួលអាកាសធាតុដែលបានបង្ហាញនៅកិច្ចប្រជុំ UNFCCC ធ្វើឡើងនៅទីក្រុង ក្នុងខែវិច្ឆិកា ឆ្នាំ២០០៥។ |
| វេទិកាសេដ្ឋកិច្ចពិភពលោក (ឆ្នាំ២០០៧). **របាយការណ៍គម្លាតយេនឌ័រ។** ដកស្រង់ពីគេហទំព័រ៖ http://www.weforum.org/pdf/gendergap/report2007.pdf | មានទិន្នន័យដែលបង្ហាញពីកម្រិត សមភាពរវាង យេនឌ័រនៅក្នុងវិស័យផ្សេងៗក្នុងសង្គម។ វាគ្របដណ្តប់ប្រទេសចំនួន ១២៨ តំណាងឱ្យ ៩០% នៃប្រជាជនពិភពលោកសរុប។ |

## ៣. ថាមពល និងយេនឌ័រ

| ឯកសារយោង | បរិយាយ |
|---|---|
| Annecke, W. (ឆ្នាំ២០០២) **ការប្រែប្រួលអាកាសធាតុ សកម្មភាពទាក់ទងនឹងថាមពល និងផលប៉ះពាល់សង្គម ដែលអាចមានមកលើស្ត្រីក្នុងអាហ្វ្រិក។** នៅក្នុង៖ International Journal of Global Environmental Issues (IJGENVI), Vol. 2, No. 3-4. ដកស្រង់ពីគេហទំព័រ៖ http://www.inderscience.com/search/index.php?action=record&rec_id=2400&prevQuery=&ps=10&m=or | ស្វែងរកការបង្កើតទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុការប្រើប្រាស់ថាមពល និងលទ្ធផលផលប៉ះពាល់ និងទំនាក់ទំនងយេនឌ័រទៅលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ស្ត្រីនៅអាហ្វ្រិក។ មានវិធីសាស្រ្តដ៏ទូលាយព្យាយាមផ្តល់ទស្សនទានលើភាពស្មុគស្មាញនៃកត្តាដែលបានគិតគូរក្នុងការវិភាគ។ ការយកចិត្តទុកដាក់មានលើភាពខុសគ្នារវាងការវិធីសាស្រ្តប្រើប្រាស់ថាមពលក្នុងប្រទេសអភិវឌ្ឍនិងកំពុងអភិវឌ្ឍ និងដោយបុរសនិងស្ត្រី៖ ផលប៉ះពាល់នៃការប្រើប្រាស់ថាមពលលើការប្រែប្រួលអាកាសធាតុត្រូវបានស្វែងរក។ អនុវិស័យថាមពលដែលងាយរងគ្រោះបំផុតគឺ ជីវម៉ាស ដែលប្រើប្រាស់ដោយក្រុមអ្នកប្រើប្រាស់ដ៏ធំបំផុត៖ ស្ត្រីក្រីក្រ។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| Brew-Hammond, A. និង Crole-Rees, A. (ឆ្នាំ២០០៤). កាត់បន្ថយភាពក្រីក្រជនបទតាមរយៈបង្កើនការទទួលបានសេវាថាមពល៖ ការពិនិត្យលើគម្រោងវេទិកាពហុមុខងារ នៅ Mali។ ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/index.cfm?module=Library & page=Document & DocumentID=5110 | ការពិនិត្យលើបទពិសោធន៍គម្រោងពហុមុខងារនៅ Mali។ វិភាគឯកសារមធ្យោបាយដែលសេវាថាមពលទំនើប ប៉ះពាល់ ជីវិតស្ត្រីនៅជនបទ ទាក់ទងនឹង ចំណូល ការអប់រំ និងលក្ខខណ្ឌសង្គម ក៏ដូចជា សុខភាពរបស់ពួកគេ។ វាក៏បានសង្កេតវិភាគពីកត្តាសំខាន់ដែលប៉ះពាល់ទំនាក់ទំនងរវាង សេវាថាមពល និងលទ្ធផលការអភិវឌ្ឍ។ វាពិនិត្យលើសារៈសំខាន់នៃទស្សនៈពហុមុខងារសម្រាប់គោលនយោបាយជាតិ និងតំបន់កាន់តែទូលំទូលាយ - នៅក្នុងក្របខ័ណ្ឌថាតើ ការអភិវឌ្ឍ និងថាមពលអាចកាត់បន្ថយភាពក្រីក្រនៅអាហ្វ្រិកដោយរបៀបណា។ |
| Ebrahimian, E. (ឆ្នាំ២០០៣). សកម្មភាពសហគមន៍ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ៖ ករណីសិក្សាការតភ្ជាប់ការប្រើប្រាស់ថាមពលប្រកបដោយចីរភាពជាមួយនឹងជីវភាពកាន់តែប្រសើរ។ GEF-UNDP Small Grants Programme(SGP).ដកស្រង់ពីគេហទំព័រ៖http://sgp.undp.org/download/SGP CaseStudiesBook.complete.pdf | ការបោះពុម្ពនេះសង្ខេបព័ត៌មានគន្លឹះៗពីគម្រោងថាមពល និងការប្រែប្រួលអាកាសធាតុ គាំទ្រដោយ GEF Small Grants Programme រវាងឆ្នាំ១៩៩២ និងឆ្នាំ២០០៣។ |
| GEF-UNDP SGP. (ឆ្នាំ២០០៥). ថាមពលព្រះអាទិត្យសម្រាប់ ភាពជឿនលឿនសេដ្ឋកិច្ច-សង្គមកិច្ច របស់ស្ត្រីក្នុងសហគមន៍ដែលបានជ្រើសរើស នៅតំបន់ខាងជើង។ Ghana. ដកស្រង់ពីគេហទំព័រ៖ http://sgp.undp.org/index.cfm?Module=Projects&Page=ShowProject&ProjectID=7466 | គម្រោងនេះណែនាំអគ្គិសនីព្រះអាទិត្យនៅក្នុងតំបន់ ផ្តល់ឱ្យស្ត្រីនូវជម្រើសប្រភពថាមពលដើម្បីអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ច។ ស្ត្រីមួយចំនួនត្រូវបានបង្រៀនពីការកសាង និងប្រើប្រាស់វិធីសម្ងួតព្រះអាទិត្យលើ shea butter.ថាមពលព្រះអាទិត្យត្រូវបានប្រើប្រាស់ដើម្បីបង្កើតមជ្ឈមណ្ឌលព័ត៌មានជនបទ ដែលស្ត្រី កុមារា និងកុមារី ចូលរៀនថ្នាក់អក្ខរកម្មពេលយប់។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| GEF-UNDP SGP. (ឆ្នាំ២០០៥). **Estación microhidroeléctricapara el procesamiento de fibranatural (lanas) en Agua Blanca, Bolivia** (Microhydroelectricstation to process natural fibre(wool) in Agua Blanca, Bolivia). ដកស្រង់ពីគេហទំព័រ៖ http://sgp.undp.org/index.cfm?Module=Projects&Page=ShowProject&ProjectID=7229 | គោលបំណងគម្រោង គឺដើម្បីផ្តល់ថាមពលដល់សហគមន៍ Agua Blanca ដោយកសាងស្ថានីយ៍ថាមពលអគ្គិសនីពីកំដៅទឹកហូរ។ ថាមពលដែលផលិតឡើងត្រូវបានប្រើប្រាស់លើសង្វាក់ផលិតកម្ម និងដំណើរការម៉ាស៊ីនសម្ងួត និងម៉ាស៊ីនជ្រលក់ពណ៌ក្រឡាត់។ គម្រោងបានជួយក្រុមស្ត្រីលើការងាររបស់ពួកគេដោយផ្តល់នូវសម្ភារៈ និងលក្ខខណ្ឌផលិតកម្មកាន់តែប្រសើរដោយអនុញ្ញាតឱ្យពួកគេវិនិយោគពេលវេលាកាន់តែច្រើនលើការងាររបស់ពួកគេ និងបង្កើតជាមីក្រូសហគ្រាសសហគមន៍។ មីក្រូសហគ្រាសអនុញ្ញាតឱ្យពួកគេទទួលប្រាក់ចំណូលកាន់តែច្រើន ក៏ដូចជាធ្វើឱ្យកាន់តែប្រសើរនូវជីវភាពគ្រួសាររបស់ពួកគេ។ |
| GEF-UNDP SGP. (ឆ្នាំ២០០៥). **ពង្រីកការអនុវត្តការចិញ្ចឹមចិត្តជាជីវភាពដែលមានចីរភាពបង្កើនភាពអង់អាចដល់ស្ត្រីតាមរយៈ ឥណទានក្រុមជួយខ្លួនឯង និងជម្រើសប្រភពឥន្ធនៈ/ថាមពល។** India. ដកស្រង់ពីគេហទំព័រ៖http://sgp.undp.org/index.cfm?Module=Projects&Page=ShowProject&ProjectID=9240 | គោលបំណងចម្បងនៃគម្រោង គឺលើកកម្ពស់ជីវៈឧស្ម័ន ជាឥន្ធនៈជម្រើសសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងកាត់បន្ថយសម្ពាធលើព្រៃឈើក៏ដូចជាការសាយភាយកាបូន។ វាផ្តោតផ្ទាល់ទៅលើស្ត្រីដោយសារពួកគេធ្វើការជាប្រពៃណី និងប្រើប្រាស់អុសចំអិនអាហារ។ រុក្ខជាតិជីវៈម៉ាស ត្រូវបានធ្វើឡើង និងវាត្រូវបានគ្រប់គ្រងដោយស្ត្រីនិងបុរស។ ដោយសារការប្រើប្រាស់អុសតិចសម្រាប់ឥន្ធនៈ គម្រោងបានជួយអភិរក្សជីវៈចម្រុះនិងកាត់បន្ថយការកាប់ស្ការព្រៃឈើ។ វាក៏បានជួយស្ត្រីជនបទបង្កើនចំណូលរបស់ពួកគេដោយការចិញ្ចឹមសត្វផងដែរ។ |
| GEF-UNDP SGP. (ឆ្នាំ២០០៥). **ការប្រើប្រាស់ថាមពលព្រះអាទិត្យសម្រាប់សម្ងួតទិន្នផលកសិកម្មនៅភូមិ Khuza'a ដោយចែកចាយ ឧបករណ៍សម្ងួតទិន្នផលទៅឱ្យស្ត្រី៦០រូប។** Palestine. ដកស្រង់ពីគេហទំព័រ៖http://sgp.undp.org/index.cfm?Module=Projects&Page=-ShowProject&ProjectID=7414 | ទទួលផលដោយផ្ទាល់ពីគម្រោងនេះ និងស្ត្រី៣៦០ផ្សេងទៀតទទួលផលដោយប្រយោល។ ពួកគេរកចំណូលមធ្យម២០០ដុល្លារក្នុងមួយរដូវ អាស្រ័យលើប្រភេទទិន្នផលកសិកម្ម ដែលខុសប្លែករុក្ខជាតិឱសថបន្លែ និងធនជាតិ។ លទ្ធផលនៃសិក្ខាសាលាត្រូវបានរក្សាបន្ទាប់គម្រោងបានបញ្ចប់។ ឧបករណ៍សម្ងួតតាមរស្មីព្រះអាទិត្យចំនួន៧០ ដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយផ្សេងទៀតបានបង្កើតឡើងនៅទីក្រុងកាហ្សា។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| Genanet. (n.d). **បណ្ដាញដ៏មានឥទ្ធិពលមួយ៖ យេនឌ័រ និងការកកើតឡើងវិញ។ គោលគំនិតយេនឌ័រ នៅប្រទេសឧស្សាហកម្ម** ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/leaflet_gender_and_renewables.pdf | ស្វែងរកការគិតគូរពីយេនឌ័រក្នុងផលិតកម្មថាមពលកកើតឡើងវិញ និងគំនិតផ្ដួចផ្ដើមដែលកំពុងអនុវត្ត។<br>បង្កើតឱ្យមានអនុសាសន៍ជាច្រើន។ |
| Misana, S. និង Karlsson, G. ( ឆ្នាំ២០០១ ) **បង្កើតឱកាស៖ ករណីសិក្សា ស្ដីពី ថាមពល និងស្ត្រី។** In: Newsletter of the network for genderand sustainable energy, Vol. 4. 2001. ដកស្រង់ពីគេហទំព័រ៖http://www.energyandenvironment.undp.org/undp/index.cfm?module=Library&page=Document & Document ID=5030 | *Generating Opportunities* គឺជាសៀវភៅរៀបរាប់អំពីករណីសិក្សាចំនួន៨អំពីស្ត្រី និងថាមពល នៅទ្វីបអាហ្វ្រិក និងអាស៊ី។ សៀវភៅនេះផ្ដល់ឧទាហរណ៍ជាក់លាក់អំពីការផ្ដល់សេវាសេដ្ឋកិច្ច និងថាមពលដល់ស្ត្រី។ យោងតាមមេរៀនដែលផ្ដល់ឲ្យតាមរយៈករណីសិក្សានេះ ចំណុចសំខាន់ជាងគេនៅក្នុងសៀវភៅនេះ គឺរបៀបក្នុងការរៀបចំនយោបាយ និងកម្មវិធីដើម្បីបង្កើនសិទ្ធិស្ត្រីក្នុងការទទួលបាននូវការផ្គត់ផ្គង់បែបទំនើប។ |
| Modi, V., McDade, S., Lallement, D. និង Saghir,J. (ឆ្នាំ២០០៥ ) **សេវាថាមពល សម្រាប់គោលដៅអភិវឌ្ឍសហស្សវត្សរ៍។ គម្រោងសហស្សវត្សរ៍អង្គការសហប្រជាជាតិ។** ដកស្រង់ពីគេហទំព័រ៖www.generoyambiente.org/admin/admin_biblioteca/documentos/MP_Energy_Low_Res.pdf | ក្នុងក្របខ័ណ្ឌ MDGs ឯកសារនេះ ពិភាក្សាលើប្រធានបទសេវាថាមពលដើម្បីសម្រេចបានគោលដៅទាំងនេះ។ វាក៏បានស្នើឡើងនូវយុទ្ធសាស្ត្រជាក់ស្ដែងក្នុងការផ្ដល់សេវាថាមពលដល់ប្រជាជនដែលក្រីក្របំផុត។ |
| Rossi, A. និង Lambrou, Y. (ឆ្នាំ២០០៨). **បញ្ហាយេនឌ័រ និងសមធម៌ក្នុងផលិតកម្មជីវៈឥន្ធនៈរាវ៖ កាត់បន្ថយហានិភ័យដើម្បីបង្កើនឱកាស។** FAO. ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/Gender%20and%20Equity%20Issues%20in%20Liquid%20Biofuels%20Production.2008%20FAO.pdf | សៀវភៅនេះបង្ហាញពីហានិភ័យដែលខុសគ្នាអាស្រ័យលើយេនឌ័រ និងទាក់ទងនឹងផលិតកម្មទ្រង់ទ្រាយធំជំនាន់ដំបូងនៃ ជីវៈឥន្ធនៈរាវក្នុងប្រទេសកំពុងអភិវឌ្ឍ។ គោលបំណងរបស់វាគឺបើកកិច្ចពិភាក្សាលើហានិភ័យ និងកំណត់ការស្រាវជ្រាវ និងយុទ្ធសាស្ត្រគោលនយោបាយដើម្បីប្រឈមមុខជាមួយពួកគេដើម្បីទទួលអត្ថប្រយោជន៍អតិបរមានូវឱកាសដែលជីវៈឥន្ធនៈផ្ដល់ឱ្យ។ |

| ឯកសារយោង | បរិយាយ |
|---|---|
| UNDP/UN-DESA/World Energy Council. (ឆ្នាំ២០០០). **ការប៉ាន់ប្រមាណថាមពលពិភពលោក៖ ថាមពល និងការប្រឈមនៃចីរភាព។** ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/index.cfm?module=Library&page=Document&DocumentID=5037 | ការបោះពុម្ពនេះផ្តល់នូវព័ត៌មានដ៏ល្អស្តីពីទិដ្ឋភាពសង្គមសេដ្ឋកិច្ច និងបរិស្ថាន ក៏ដូចជាលើ សំនួរសន្តិសុខដែលភ្ជាប់នឹងថាមពល។ វាវិភាគវិធីដែលថាមពលដើរតួជាឧបករណ៍ក្នុងការទទួលបានការអភិវឌ្ឍមនុស្សដោយចីរភាព។ |
| UNDP, វិទ្យាស្ថានអន្តរជាតិដើម្បីសេដ្ឋកិច្ចបរិស្ថានឧស្សាហកម្ម (IIIEE) និងគំនិតផ្តួចផ្តើមថាមពលអន្តរជាតិ. (ឆ្នាំ២០០២).**ថាមពលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព៖ របៀបវារៈគោលនយោបាយ។** ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/index.cfm?module=Library&page=Document&DocumentID=5028 | ជាជំហានតាមដានលើការប៉ាន់ប្រមាណថាមពលពិភពលោក ការបោះពុម្ពនេះផ្តោតការយកចិត្តទុកដាក់លើការបង្កើតគោលនយោបាយ និងការអនុវត្តដោយប្រសិទ្ធភាពរបស់វាក្នុងការពន្លឿនកំណើននៃប្រព័ន្ធថាមពលដែលគាំទ្រការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព។ |
| UNDP. (ឆ្នាំ២០០៤) **ការប៉ាន់ប្រមាណថាមពលពិភពលោក៖ ទិដ្ឋភាពទូទៅ។** ដកស្រង់ពីគេហទំព័រ៖ http://www.undp.org/energy/docs/WEAOU_full.pdf | បង្ហាញពីទំនាក់ទំនងរវាងថាមពល និង MDGs។ បរិយាយពីកិច្ចពិភាក្សា និងលទ្ធផល CSD-9 និងសន្និសីទកំពូលសម្រាប់ការអភិវឌ្ឍសង្គម។ វាក៏បានរួមបញ្ចូលផងដែរនូវព័ត៌មាន និងនិន្នាការបច្ចុប្បន្នភាពស្តីពីបច្ចេកវិទ្យាទាក់ទងនឹងវិស័យ ថាមពល និងជម្រើសគោលនយោបាយថាមពលសម្រាប់អនាគតប្រកបដោយចីរភាព។ |
| UNDP. (ឆ្នាំ២០០៥). **ធ្វើឱ្យខ្លាំងក្លាគោលដៅអភិវឌ្ឍសហស្សវត្សរ៍** ដកស្រង់ពីគេហទំព័រ៖ http://www.undp.org/pei/pdfs/Energizing_the_MDGs.pdf | បកស្រាយថាអ្នកក្រីក្រចំណាយពេលវេលារបស់គេភាគច្រើនលើសកម្មភាពទាក់ទងនឹងថាមពល ដូចជា ប្រមូលអុស បើទោះណាជាសេវាកម្មថាមពលទំនើបមានដើម្បីសម្រាលបន្ទុករបស់ពួកគេក៏ដោយ។ ការបោះពុម្ពនេះ ពិនិត្យមើលទំនាក់ទំនងរវាងថាមពលនិងការអភិវឌ្ឍ និង ពិភាក្សាពីមធ្យោបាយដែលថាមពលទាក់ទងនឹង MDGs។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| UNDP Ghana. (2006). **ឧស្ម័នប្រេងរាវ (LPG) ជំនួសឱ្យប្រេងឈើ។** ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/index.cfm?module=Library&page=Document & DocumentID=5743 | គម្រោងនេះ លើកទឹកចិត្ត និងសម្របសម្រួលឱ្យមានការប្រើប្រាស់ឧស្ម័នប្រេងរាវជំនួសឱ្យប្រេងឈើ និងធ្យូង។ វាក៏គាំទ្រផងដែរ ការរកទីផ្សារ និងធ្វើឱ្យមាន LPG ដើម្បីផ្គត់ផ្គង់តម្រូវការថាមពលសហគមន៍ នៅតំបន់ចំនួន៣នៅផ្នែកខាងជើងប្រទេសហ្គាណា។ ជាលទ្ធផល អ្នកប្រើប្រាស់ក្នុងស្រុក ៦០០ ត្រូវបានបណ្ដុះបណ្ដាល (ក្នុងការប្រើប្រាស់ LPG) ដែល ៥០០ ជាស្ត្រី៖ សមាគមអ្នកប្រើប្រាស់ LPG ៤ ត្រូវបានបង្កើតឡើង ដែលមានសមាជិក ៤៨០រូប ដែលស្ត្រីមាន២៨៩៖ ៥៤ក្រុមហ៊ុន ប្រើប្រាស់ថាមពលត្រូវបានសម្គាល់ ដែល ៤៣ ត្រូវបានដំណើរការដោយ ឬជាកម្មសិទ្ធស្ត្រី៖ ការបណ្ដុះបណ្ដាលផ្ដល់ឱ្យស្ត្រី និងបុរស ៤៥រូប ជាអ្នកលក់អាហារពាណិជ្ជកម្ម។ |
| UNDP. (ឆ្នាំ២០០៧) **ទិដ្ឋភាពទស្សនទានទូទៅ។ ការបញ្ជ្រាបយេនឌ័រ៖ កត្តាជម្រុញគន្លឹះនៃការអភិវឌ្ឍលើបរិស្ថាន និងថាមពល។** ដកស្រង់ពីគេហទំព័រ៖ www.energyandenvironment.undp.org/undp/indexAction.cfm?module=Library&action=GetFile&DocumentAttachmentID=2315 | ឯកសារនេះស្នើនូវវិធីសាស្រ្តដំបូងក្នុងការដាក់បញ្ចូលគោលគំនិតយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីរបស់ UNDP ក្នុងផ្នែកសំខាន់ៗទាក់ទងនឹងថាមពល និងបរិស្ថាន។ (១) គ្រប់គ្រងធនធានទឹក (២) ទទួលបានសេវាកម្មថាមពល (៣) ការគ្រប់គ្រងដីប្រកបដោយចីរភាព (៤) ជីវចម្រុះ និង (៥) គ្រប់គ្រងវត្ថុធាតុបំផ្លាញប្រព័ន្ធអូស៊ូន និងជាតុបំពុលសេរីរាង្គ។ |
| UNDP. (ឆ្នាំ២០០៧) **ការបញ្ជ្រាបយេនឌ័រ៖ កត្តាជម្រុញគន្លឹះនៃការអភិវឌ្ឍលើបរិស្ថាន និងថាមពល៖ Portfolio។** ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/indexAction.cfm?module=Library&action=GetFile & Document AtachmentID=2342 | របាយការណ៍នេះបង្ហាញពីសេចក្ដីសន្និដ្ឋានការសិក្សាដែលធ្វើឡើងចន្លោះពីខែវិច្ឆិកា ឆ្នាំ២០០៥ ដល់ ខែមេសា ឆ្នាំ២០០៦ ដើម្បីប៉ាន់ប្រមាណពីលក្ខណៈ និងវិសាលភាពគោលគំនិតយេនឌ័រក្នុង portfolio ថាមពល និងបរិស្ថានរបស់ UNDP ដោយរួមបញ្ចូល GEF និងកម្មវិធីជំនួយខ្នាតតូច។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| UNDP. (ឆ្នាំ២០០៧) ការបញ្ជ្រាបយេនឌ័រ៖ កត្តាជម្រុញគន្លឹះនៃការអភិវឌ្ឍលើបរិស្ថាន និងថាមពល៖ឯកសារបណ្ដុះបណ្ដាល - ផ្នែកទី១។ ដកស្រង់ពីគេហទំព័រ៖ [http://www.energyandenvironment.undp.org/undp/index.cfm?module=Library&page=Document&DocumentID=6514](http://www.energyandenvironment.undp.org/undp/index.cfm?module=Library&page=Document&DocumentID=6514) | ឯកសារនេះជាផ្នែកមួយនៃបណ្ដុំការបោះពុម្ពដែលមានឈ្មោះថា *ការបញ្ជ្រាបយេនឌ័រ៖ កត្តាជម្រុញគន្លឹះនៃការអភិវឌ្ឍលើបរិស្ថាន និងថាមពល*។ វាត្រូវបានរៀបចំជាជំនួយការស្វែងយល់ពីសារៈសំខាន់ក្នុងការដាក់បញ្ចូលទិដ្ឋភាពយេនឌ័រសម្រាប់ចីរភាពនៃបរិស្ថាន និងថាមពល។ |
| UNDP. (ឆ្នាំ២០០៧) ការបញ្ជ្រាបយេនឌ័រ៖ កត្តាជម្រុញគន្លឹះនៃការអភិវឌ្ឍលើបរិស្ថាន និងថាមពល៖ ឯកសារបណ្ដុះបណ្ដាល - ផ្នែកទី២ សម្រាប់អ្នកសម្របសម្រួល។ ដកស្រង់ពីគេហទំព័រ៖ [http://www.energyandenvironment.undp.org/undp/index.cfm?module=Library&page=Document&DocumentID=6523](http://www.energyandenvironment.undp.org/undp/index.cfm?module=Library&page=Document&DocumentID=6523) | ឯកសារនេះជាផ្នែកមួយនៃបណ្ដុំការបោះពុម្ពដែលមានឈ្មោះថា *ការបញ្ជ្រាបយេនឌ័រ៖ កត្តាជម្រុញគន្លឹះនៃការអភិវឌ្ឍលើបរិស្ថាន និងថាមពល*។ ឯកសារនេះគាំទ្របណ្ដុះបណ្ដាលជាពិសេសដល់អ្នកសម្របសម្រួលក្នុងការដាក់បញ្ចូលវិធីសាស្ត្រយេនឌ័រក្នុងប្រធានបទថាមពលនិងបរិស្ថាន។ |
| NUNDP. (ឆ្នាំ២០០៧) សេវាកម្មថាមពលប្រកបដោយចីរភាព៖ មូលហេតុ និងវិធីសាស្ត្រការបញ្ជ្រាបយេនឌ័រក្នុងសេវាកម្មថាមពលប្រកបដោយចីរភាព។ ដកស្រង់ពីគេហទំព័រ៖[http://www.energyandenvironment.undp.org/undp/index.cfm?module=Library&page=Document&DocumentID=6460](http://www.energyandenvironment.undp.org/undp/index.cfm?module=Library&page=Document&DocumentID=6460) | ឯកសារនេះជាផ្នែកមួយនៃបណ្ដុំការបោះពុម្ពដែលមានឈ្មោះថា *ការបញ្ជ្រាបយេនឌ័រ៖ កត្តាជម្រុញគន្លឹះ នៃការអភិវឌ្ឍលើបរិស្ថាននិងថាមពល*។ ឯកសារការណែនាំនេះ បកស្រាយពីសារៈសំខាន់នៃវិធីសាស្ត្រយេនឌ័រក្នុងកម្មវិធី និងគោលនយោបាយថាមពលប្រកបដោយចីរភាព។ |
| Wamukonya, N. (ឆ្នាំ២០០២) ការពិនិត្យមើលដ៏សំខាន់លើការបញ្ជ្រាបយេនឌ័រ និងថាមពលនៅអាហ្វ្រិក៖ ឯកសារព្រាង។ ដកស្រង់ពីគេហទំព័រ៖ [http://www.generoyambiente.org/admin/admin_biblioteca/documentos/Njeripaper.pdf](http://www.generoyambiente.org/admin/admin_biblioteca/documentos/Njeripaper.pdf) | ឯកសារដែលផ្ដល់ឱ្យនៅព្រឹត្តិការណ៍ដែលស្របគ្នាទៅនឹងកិច្ចប្រជុំ Pre Com III អំពាវនាវឱ្យមានការដាក់បញ្ចូលទស្សនទានយេនឌ័រក្នុងការអភិវឌ្ឍប្រកបដោយចីរភាព ដែលរៀបចំដោយ UNDESA/DAW និង WEDO។ វាពិនិត្យមើលដ៏សំខាន់លើប្រធានបទការបញ្ជ្រាបយេនឌ័រ និងថាមពលនៅអាហ្វ្រិក។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| Women's Major Group. (ឆ្នាំ២០០៦). **ការបញ្ចូលយេនឌ័រនៅក្នុងរបៀបវារៈការប្រែប្រួលអាកាសធាតុ និងថាមពល។** Discussion paper for CSD-14. ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/CSD14WMG.pdf | របាយការណ៍នេះត្រូវបានរៀបចំរួមគ្នាដោយបណ្តាញយេនឌ័រលើយេនឌ័រ និងថាមពលប្រកបដោយចីរភាព (ENERGIA), បណ្តាញបរិស្ថានស្ត្រី (LIFE), WECF សហភាពអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ (IUCN) និង WEDO ភ្ជាប់ការប្រឹក្សាយោបល់ជាមួយនឹងអង្គការស្ត្រីជុំវិញពិភពលោក ក្នុងក្របខ័ណ្ឌនៃ CSD-14។ វាដោះស្រាយទំនាក់ទំនងរវាងថាមពល និងការប្រែប្រួលអាកាសធាតុលើបញ្ហាដែលទាក់ទងនឹងយេនឌ័រ ក្នុងបរិបទដែលស្នើសម្រាប់សកម្មភាពអន្តរជាតិ។ |

## ៤. ការកាត់បន្ថយ និងការបន្សាំ

| ឯកសារយោង | បរិយាយ |
| --- | --- |
| All India Disaster Mitigation Institute. (ឆ្នាំ២០០៥) **ស៊ូណាមីយេនឌ័រ និងការស្តារឡើងវិញ។** In: *Bulletin No. 6. Special edition for the International Day for Natural Disaster Reduction.* ដកស្រង់ពីគេហទំព័រ៖ http://www.southasiadisasters.net/whatsnew.htm | ការបោះពុម្ពពិសេសនេះ ចាត់ទុកប្រធានបទយេនឌ័រនៅក្នុងផែនការស្តារឡើងវិញ ស៊ូណាមីដែលប៉ះពាល់អាស៊ី ក្នុងឆ្នាំ២០០៥។ ផែនការទាំងនេះបានផ្តល់ជាការវិភាគដ៏សំខាន់ដោយសារវាខ្វះការគិតគូរយេនឌ័រ ដែលផែនការទាំងនេះអាចមានផលប៉ះពាល់អវិជ្ជមានដល់ស្ត្រី។ |
| Boyd, E. (ឆ្នាំ២០០២) **គម្រោង Noel Kempff នៅ Bolivia៖ យេនឌ័រ អំណាច និងការធ្វើសេចក្តីសម្រេចក្នុងការកាត់បន្ថយអាកាសធាតុ។** នៅក្នុង៖ *Gender & Development*, Vol. 10, Issue 2. ដកស្រង់ពីគេហទំព័រ៖ http://www.informaworld.com/smpp/content~content=a741921481~b=all~order=page | ចាប់តាំងពីពិធីសារក្យូតូចំណុចកណ្តាលនៃការពិភាក្សាអន្តរជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ត្រូវបានផ្តោតការយកចិត្តទុកដាក់លើការប្រើប្រាស់ដី និងព្រៃឈើដើម្បីកាត់បន្ថយ កាបូន dioxide នៅក្នុងបរិយាកាស។ គម្រោងបច្ចេកទេសនេះ ព្យាយាមផ្តល់នូវអត្ថប្រយោជន៍នៃការអភិវឌ្ឍប្រកបដោយចីរភាពដល់ប្រជាជនដែលពឹងអាស្រ័យលើព្រៃឈើក៏ដូចជាការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ អ្នកនិពន្ធរកឃើញនូវទ្រឹស្តីនេះដោយគិតគូរពីហេតុផលដែលគម្រោងកាត់បន្ថយអាកាសធាតុនៅ Bolivia មានលទ្ធផលផ្សេងៗគ្នាសម្រាប់ស្ត្រី និងបុរស និងទំនាក់ទំនងដំណើរការធ្វើគោលនយោបាយពិភពលោក និងផលប៉ះពាល់មូលដ្ឋានរបស់ពួកគេផងដែរ។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| Cannon, T. (ឆ្នាំ២០០២). **យេនឌ័រ និងគ្រោះថ្នាក់អាកាសធាតុ នៅ Bangladesh។** នៅក្នុង: *Gender & Development,* Vol.10, pp. 45-50. ដកស្រង់ពីគេហទំព័រ៖ http://www.informaworld.com/smpp/content~content=a741921480~db=all~order=page | ប្រទេសបង់ក្លាដេស ថ្មីៗនេះជួបប្រទះនូវមហន្តរាយដ៏ធំមួយ រួមបញ្ចូល ព្យុះស៊ីក្លូន ដ៏អាក្រក់ និងទឹកជំនន់ជាប្រចាំ។ ភាពក្រីក្រធ្វើឱ្យមានភាពងាយរងគ្រោះ និងជាលទ្ធផលនៃហានិភ័យ និងផលប៉ះពាល់នៃគ្រោះថ្នាក់ផងដែរ។ កន្លងមកមិនមានភស្តុតាងរួមណាមួយដែលថាផលប៉ះពាល់នៃគ្រោះថ្នាក់ មានចំពោះស្ត្រីច្រើនជាងបុរសឡើយ និងភស្តុតាងមានភាពខុសគ្នាផ្អែកលើវិធីសាស្ត្រដែលការវិភាគត្រូវបានធ្វើឡើង។ ទោះបីជាយ៉ាងណាក៏ដោយឯកសារនេះលើកឡើងថា ភាពងាយរងគ្រោះអាស្រ័យលើយេនឌ័រដែលអាចកាត់បន្ថយតាមរយៈការផ្លាស់ប្តូរសង្គម។ |
| Castro, C.and Reyes, L. (ឆ្នាំ២០០៦). **Desastres Naturales y Vulnerabilidad de las Mujeres enMéxico.** México. ដកស្រង់ពីគេហទំព័រ៖ http://cedoc.inmujeres.gob.mx/php_general/muestra_docto.php?ID=100834 | វាស្ថិតនៅក្នុងចំណោមការស្រាវជ្រាវដំបូងដែលធ្វើឡើងលើប្រធានបទនៅក្នុងប្រទេសម៉ិចស៊ិចកូ។ វាស្វែងរកការបញ្ចូលទស្សនទានការគ្រប់គ្រងហានិភ័យមហន្តរាយបញ្ចូលគ្នា និងសមធម៌យេនឌ័រក្នុងគោលនយោបាយសាធារណៈ និងក្នុងសកម្មភាពការពារស៊ីវិល។ |
| CATHALAC, UNDP/GEF. (ឆ្នាំ២០០៧). **ការកសាងសមត្ថភាពសម្រាប់ដំណាក់កាលទី២ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅអាមេរិកកណ្តាល ប្រទេស Mexico និង Cuba។** ដកស្រង់ពីគេហទំព័រ៖ http://www.gefweb.org/Documents/Council_Documents/GEF_C18/Regional_Capacity_Building_for_Stage_II_Adaptation.pdf | គោលបំណងនៃគម្រោងនេះគឺ ដើម្បីពង្រឹងសមត្ថភាពបុគ្គល ស្ថាប័ន និងប្រព័ន្ធ អ្នកពាក់ព័ន្ធសំខាន់ៗដើម្បីប៉ាន់ប្រមាណភាពងាយរគ្រោះ និងធ្វើការបន្សាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ រួមបញ្ចូលភាពខុសគ្នាអាកាសធាតុរហូតដល់ព្រឹត្តការណ៍ហានិភ័យ និងធ្ងន់ធ្ងរនៅក្នុងប្រព័ន្ធតំបន់ ជាតិ និងមូលដ្ឋាន។ វាក៏បានពង្រឹងផងដែរនូវសមត្ថភាពជាប្រព័ន្ធរបស់បុគ្គល និងស្ថាប័ននៃអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រ អនុវត្តគោលនយោបាយ និងធ្វើការរៀបចំសម្រាប់ការបន្សាំនៅមូលដ្ឋាន ជាតិ និងតំបន់។ |
| Denton, F. (ឆ្នាំ២០០២). **ភាពងាយរងគ្រោះ ភាពងាយរងគ្រោះ និងការបន្សាំ ការប្រែប្រួលអាកាសធាតុ៖ហេតុអ្វីគិតគូរពី យេនឌ័រ?** នៅក្នុង: *Gender & Development,* Vol. 10, pp.10-20. ដកស្រង់ពីគេហទំព័រ៖ http://www.informaworld.com/smpp/content~content=a741921483~db=all~order=page | បកស្រាយថា ប្រសិនបើគោលនយោបាយការប្រែប្រួលអាកាសធាតុស្វែងរកការធានាឱ្យមានអនាគតប្រកបដោយចីរភាពដោយបញ្ចូលគ្នាសំនួរការអភិវឌ្ឍ និងការអភិវឌ្ឍ តម្រូវការគួរត្រូវបានគិតគូរនៃក្រុមដែលមានចំណាប់អារម្មណ៍ផ្សេងៗគ្នា។ វាក៏បានស្នើថា មូលនិធិពិភពលោកបរិស្ថាន នៃពិធីសារក្យូតូ អាចដើរតួយ៉ាងសំខាន់ក្នុងការធានាការអភិវឌ្ឍប្រកបដោយចីរភាព និងគួរត្រូវអនុវត្តដូច្នោះដែលវាមិនមានជាលទ្ធផលមានផលវិបាកដល់ស្ត្រី ឬក្រុមប្រជាជនក្រីក្របំផុត។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| Gross, R., Dougherty, B. និង Kumarsingh,K. (ឆ្នាំ២០០៤) ប៉ាន់ប្រមាណតម្រូវការបច្ចេកវិទ្យាសម្រាប់ការប្រែប្រួលអាកាសធាតុ UNDP. ដកស្រង់ពីគេហទំព័រ៖ http://www.eneryandenvironment.undp.org/index.cfm?module = Library & page = Document & DocumentID=5232 | ឯកសារបណ្តុះបណ្តាលនេះបង្ហាញពីវិធីសាស្ត្របត់បែនដើម្បីកំណត់អាទិភាពតម្រូវបច្ចេកវិទ្យា និងទម្រង់ការអនុវត្តនិងកំណែទម្រង់ដែលត្រូវការដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ គោលបំណងចម្បងរបស់វា គឺប្រទេសកំពុងអភិវឌ្ឍ។ |
| Hannan, C. (ឆ្នាំ២០០២). បញ្ហាបទស្សនទានយេនឌ័រ ក្នុងការគ្រប់គ្រងបរិស្ថាន និងការកាត់បន្ថយគ្រោះមហន្តរាយធម្មជាតិ។ Division for the Advancement of Women (DAW). ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/presnat.PDF | ការពិភាក្សា ក្នុងន័យទូលំទូលាយ វិធីដែលស្ត្រីចូលរួមក្នុងការគ្រប់គ្រងបរិស្ថាន និងដំណើរការកាត់បន្ថយគ្រោះមហន្តរាយធម្មជាតិ។ វាវិភាគការបញ្ជ្រាបយេនឌ័រក្នុងយុទ្ធសាស្ត្រកាត់បន្ថយ និងបន្សាំការវិភាគហានិភ័យ និងការឆ្លើយតបទៅនឹងការគ្រប់គ្រងការសង្គ្រោះបន្ទាន់។ |
| Herrmann, T., Ronneberg, E., Brewster, M. និង Dengo, M. (ឆ្នាំ២០០៥). ទិដ្ឋភាពសេដ្ឋកិច្ចនិងសង្គមកិច្ច នៃការកាត់បន្ថយមហន្តរាយភាពងាយរងគ្រោះ និងការគ្រប់គ្រងហានិភ័យនៅកោះតូចនៃរដ្ឋកំពុងអភិវឌ្ឍ។ ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/smallislands.pdf | ការស្រាវជ្រាវនេះបកស្រាយពីផលប៉ះពាល់នៃមហន្តរាយលើស្ត្រី ក៏ដូចជាតួនាទីរួមរបស់ពួកគេក្នុងវប្បធម៌ជាច្រើនក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ។ វាពិភាក្សាថាស្ត្រីជាកម្លាំងជម្រុញដ៏សំខាន់សម្រាប់ការផ្លាស់ប្តូរ ដូច្នោះហើយ ត្រូវការពង្រឹងសមត្ថភាពរបស់ពួកគេ។ |

| ឯកសារយោង | បរិយាយ |
|---|---|
| វិទ្យាស្ថានអន្តរជាតិសម្រាប់ការអភិវឌ្ឍ ប្រកបដោយចីរភាព (IISD). (ឆ្នាំ២០០៣) **ជីវភាព និងការប្រែប្រួលអាកាសធាតុ៖ ការបញ្ចូលការកាត់បន្ថយហានិភ័យហមហន្តរាយ ការគ្រប់គ្រងធនធានធម្មជាតិ និងការបន្ស៊ាំការប្រែប្រួលអាកាសធាតុ ក្នុងវិធីសាស្ត្រថ្មីដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងភាពក្រីក្រ។** IUCN, IISD, Stockholm Environment Institute (SEI), the Swiss Agency for Development Cooperation (SDC) and Intercooperation (the Swiss Foundation for International Development and Cooperation). ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/iisd2003.pdf | ឯកសារនេះព្យាយាមផ្តល់ជាក្របខ័ណ្ឌសម្រាប់ការស្រាវជ្រាវ និងការធ្វើគោលនយោបាយ និងក្រុមសហគមន៍ដែលព្យាយាមអនុម័តការសម្រេចចិត្តស្តីពីការបន្ស៊ាំ។ |
| IISD. (ឆ្នាំ២០០៧). **CRiSTAL: ពិនិត្យលើហានិភ័យសហគមន៍–ការបន្ស៊ាំ និងជីវភាព។** IISD, IUCN, SEI-US and Inter cooperation. ដកស្រង់ពីគេហទំព័រ៖ http://www.iisd.org/pdf/2007/brochure_cristal.pdf | CRiSTAL ជាឧបករណ៍គាំទ្រ ដែលអភិវឌ្ឍរួមគ្នាដោយ IISD, IUCN, SEI-US និង Intercooperation ឧបករណ៍នេះផ្អែកលើការប៉ាន់ប្រមាណផលប៉ះពាល់បរិស្ថាន (EIA) និងគំរូការរស់នៅប្រកបដោយចីរភាព (SLF)។ គោលបំណងចម្បងរបស់វា គឺផ្តល់ជាហេតុផល និងដំណើរការងាយស្រួលដែលអាចជួយអ្នកប្រើប្រាស់កាន់តែយល់ទំនាក់ទំនងរវាងហានិភ័យទាក់ទងនឹងអាកាសធាតុ ជីវិតរស់នៅរបស់ប្រជាជន និងសកម្មភាពគម្រោង។ |
| Jones, R., Hassell, D., Hudson, D., Wilson, S., Jenkins, G. និង Mitchell, J. (ឆ្នាំ២០០៤). **Generating High Resolution Climate Change Scenarios Using PRECIS. Handbook.** UNDP/GEF National Communications Support Unit. ដកស្រង់ពីគេហទំព័រ៖ http://ncsp.undp.org/docs/652.pdf | ឯកសារនេះ ជាផ្នែកនៃកញ្ចប់ដែលបានរៀបចំក្នុងកិច្ចសហការជាមួយនឹង Hadley Centre រួមបញ្ចូល គំរូអាកាសធាតុតំបន់ និងឯកសារបណ្តុះបណ្តាលបច្ចេកទេស។ គោលបំណងបញ្ចប់នៃការណែនាំនេះ គឺបង្ហាញពីជំហានដែលត្រូវការដើម្បីរៀបចំដោយប្រើប្រាស់ PRECIS, high-resolution climate change scenarios។ |

| ឯកសារយោង | បរិយាយ |
|---|---|
| Lim, B. (2005). ក្របខ័ណ្ឌគោលនយោបាយបន្សាំសម្រាប់ការប្រែប្រួលអាកាសធាតុ៖ រៀបចំយុទ្ធសាស្ត្រគោលនយោបាយ និងវិធីសាស្ត្រ។ UNDP-GEF. ដកស្រង់ពីគេហទំព័រ៖ www.undp.org/gef/05/kmanagement/pub_practitioner.html | ឯកសារត្រូវបានរៀបចំដើម្បីគាំទ្រដំណើរការការរៀបចំគោលនយោបាយបន្សាំក្នុងប្រទេស ដូច្នោះគឺដើម្បីការពារ និងបង្កើនសុខមាលភាពមនុស្សក្នុងតថភាពការប្រែប្រួលអាកាសធាតុ។ |
| Malone, E.L., Smith, J.B., Brenkert, A.L. និង Hurd, B. (ឆ្នាំ២០០៤). រៀបចំ Scenarios សេដ្ឋកិច្ច - សង្គមកិច្ចសម្រាប់ការប្រើប្រាស់ក្នុងការបោះពុម្ពការប៉ាន់ប្រមាណបន្សាំ និងភាពងាយរងគ្រោះ។ UNDP. ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/index.cfm?module=Library & page = Document & DocumentID=5233 | គោលបំណងនៃឯកសារនេះ គឺដើម្បីជួយប្រទេសក្នុងការរៀបចំ Scenarios សេដ្ឋកិច្ច-សង្គមកិច្ច ក្នុងទំនាក់ទំនងក្របខ័ណ្ឌគោលនយោបាយបន្សាំ (UNDP, ឆ្នាំ២០០៤)។ វាដើម្បីវិភាគភាពងាយរងគ្រោះ និងការបន្សាំ ដែលជាផ្នែកទំនាក់ទំនងថ្នាក់ជាតិ។ |
| Nelson, V., Meadows, K., Cannon, T., Morton, J. និង Martin, A. (ឆ្នាំ២០០២). ការទស្សន៍ទាយមិនច្បាស់លាស់ ផលប៉ះពាល់ដែលមើលមិនឃើញ និងតម្រូវការបញ្ជ្រាបយេនឌ័រទៅក្នុងការបន្សាំការប្រែប្រួលអាកាសធាតុ។ នៅក្នុង: *Gender & Development*, Vol. 10, pp. 51–59.ដកស្រង់ពីគេហទំព័រ៖ http://www.informaworld.com/smpp/content~content=a741921482~db=all~order=page | ភាពងាយរងគ្រោះ ការធ្លាក់ចុះបរិស្ថាន និងភាពគ្រោះថ្នាក់ធម្មជាតិត្រូវបានលើកឡើងជាមួយទិដ្ឋភាពសង្គម យេនឌ័រ និងភាពក្រីក្រ។ ដោយសារផ្នែកជាច្រើននៃគោលនយោបាយអភិវឌ្ឍ និងការអនុវត្តមិនបានបញ្ចូលក្នុងទស្សនទាន យេនឌ័រដោយប្រសិទ្ធភាព ផលប៉ះពាល់ជាក់លាក់នៃការប្រែប្រួលអាកាសធាតុលើទំនាក់ទំនងយេនឌ័រដែលមិនបានសិក្សា និងមិនអាចមើលឃើញ។ អត្ថបទនេះគូសបញ្ជាក់ពីការទស្សន៍ទាយស្តីពីការប្រែប្រួលអាកាសធាតុ និងស្វែងរកផលប៉ះពាល់រយៈពេលវែងរបស់វាលើកសិកម្ម ប្រព័ន្ធអេកូឡូស៊ី និងទំនាក់ទំនងយេនឌ័រ។ វាស្នើឱ្យមានការវិភាគយេនឌ័របញ្ចូនក្នុងការរៀបចំគោលនយោបាយសាធារណៈ។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| Oxfam. (ឆ្នាំ២០០៥) **ផលប៉ះពាល់ Tsunami លើស្ត្រី។** Briefing Note. ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/tsunami-women.pdf | ផ្តល់ជាឧទាហរណ៍ នៃផលប៉ះពាល់សង្គមនៃ tsunami ឆ្នាំ២០០៤ ក្នុងប្រទេសឥណ្ឌូនេស៊ី ឥណ្ឌា និងស្រីលង្កា ។ ទោះបីវាមិនបានបង្កដោយការប្រែប្រួលអាកាសធាតុ វាមានផលប៉ះពាល់ដ៏សម្បើមជាពិសេសមកលើស្ត្រី។ រួមបញ្ចូលសកម្មភាពជាអនុសាសន៍លើការធ្វើសកម្មភាពដើម្បីធានាថាតម្រូវការស្ត្រី និងបុរសត្រូវបានបំពេញ និងថាទំហំនៃផលប៉ះពាល់លើស្ត្រីបានគិតគូរក្នុងដំណើរការស្តារឡើងវិញ។ |
| Oxford University's Refugee Studies Centre និង United Nations Environment Programme (UNEP). (ឆ្នាំ២០០៨) **ការប្រែប្រួលអាកាសធាតុ និងការផ្លាស់ប្តូរ។** Forced Migration Review, issue 31, October 2008, 80 pp. ដកស្រង់ពីគេហទំព័រ៖ http://www.fmreview.org/climatechange.htm | ដើម្បីឆ្លើយតបនឹងសម្ពាធលើទេសភាព និងជីវភាពដែលកំពុងកើនឡើង ប្រជាជនកំពុងផ្លាស់ប្តូរទីលំនៅ សហគមន៍កំពុងបន្សាំ។ នេះជាបញ្ហានៃកិច្ចពិភាក្សា FMR លើចំនួន និយមន័យ និងគំរូ – និងភាពតានតឹងរវាងតម្រូវការសម្រាប់ការស្រាវជ្រាវនិងតម្រូវការការធ្វើសកម្មភាព។ មានអត្ថបទចំនួន៣៨ ដោយ UN, គ្រឹះស្ថានអប់រំ អ្នកពាក់ព័ន្ធថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ ដើម្បីស្វែងរកវិសាលភាពការផ្លាស់ប្តូរវិបត្តិជាក់លាក់ការបន្សាំសហគមន៍និងយុទ្ធសាស្ត្រដោះស្រាយ និងស្វែងរកដំណោះស្រាយ។ |
| UNDP-GEF SGP. (ឆ្នាំ២០០៣) **ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ការបង្កើតអត្ថប្រយោជន៍សហគមន៍។** ដកស្រង់ពីគេហទំព័រ៖ http://sgp.undp.org/download/SGPCC.pdf | ការបោះពុម្ពនេះបង្ហាញពីបទពិសោធន៍ និងមេរៀនដែលបានសិក្សាពី SGP portfolio នៃគម្រោងសហគមន៍ ស្តីពីការប្រែប្រួលអាកាសធាតុ។ |
| UNDP-GEF SGP. (ឆ្នាំ២០០៧) **ការដឹកជញ្ជូនប្រកបដោយចីរភាពបរិស្ថាន និងការប្រែប្រួលអាកាសធាតុ៖ បទពិសោធន៍ និងការមេរៀនដែលបានសិក្សាពីគំនិតផ្តួចផ្តើមសហគមន៍ ។** ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/index-Action.cfm?module=Library&action=GetFile&DocumentAttachmentID=2037 | ជាលទ្ធផលដែលកើតចេញពីការធ្វើជាប្រព័ន្ធនូវបទពិសោធន៍នៃគម្រោងសហគមន៍ការដឹកជញ្ជូនប្រកបដោយចីរភាពដែលផ្តល់ហិរញ្ញប្បទានដោយកម្មវិធីជំនួយខ្នាតតូចរបស់មូលនិធិបរិស្ថានពិភពលោក ។ ការបោះពុម្ពនេះបកស្រាយពីបទពិសោធន៍ និងមេរៀនដែលបង្ហាញពីតួនាទីដ៏សំខាន់ដែលធ្វើឡើងដោយគំនិតផ្តួចផ្តើមសហគមន៍ ក្នុងការស្វែងរកដំណោះស្រាយសម្រាប់តម្រូវការដឹកជញ្ជូន។ |

| ឯកសារយោង | បរិយាយ |
|---|---|
| UNDP, UNEP, World Bank, ADB, AfDB, GTZ, DFID, OECD និង EC. (ឆ្នាំ២០០៣). ភាពក្រីក្រ និងការប្រែប្រួលអាកាសធាតុ៖ កាត់បន្ថយភាពងាយរងគ្រោះនៃប្រជាជនក្រីក្រតាមរយៈ ការបន្សាំ។ ដកស្រង់ពីគេហទំព័រ៖ http://ec.europa.eu/development/icenter/repository/env_cc_varg_poverty_and_climate_change_en.pdf | ឯកសារនេះផ្តោតលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើការប្រឆាំងនឹងភាពក្រីក្រក្នុងបរិបទភាពរីកចម្រើនដែលធ្វើឡើងដើម្បីសម្រេចបានគោលដៅអភិវឌ្ឍសហស្សវត្សរ៍ និងជំហានតាមដាន។ វាពិភាក្សាពីការភ្ជាប់ និងដាក់បញ្ចូលការបន្សាំការប្រែប្រួលអាកាសធាតុ ក្នុងការប្រយុទ្ធប្រឆាំងភាពក្រីក្រនិងកិច្ចខិតខំដើម្បីសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព។ |
| Roy, M. និង Venema, H. (ឆ្នាំ២០០២) កាត់បន្ថយហានិភ័យ និងភាពក្រីក្រលើការប្រែប្រួលអាកាសធាតុនៅប្រទេសឥណ្ឌា៖ វិធីសាស្ត្រសមត្ថភាព។ នៅក្នុង *Gender& Development*, Vol. 10, pp. 78–83. ដកស្រង់ពីគេហទំព័រ៖ http://www.informaworld.com/smpp/content~content=a741921476~db=all~order=page | បង្ហាញថាសមត្ថភាពរបស់ស្ត្រីក្នុងការបន្សាំទៅនឹងសម្ពាធការប្រែប្រួលអាកាសធាតុអាចនឹងប្រសើរឡើង ប្រសិនពួកគេមានសមត្ថភាពទៅនឹងកិច្ចខិតខំអភិវឌ្ឍដោយផ្ទាល់។ ដោយប្រើប្រាស់វិធីសាស្ត្រនេះ ស្ត្រីនឹងបង្កើនជីវភាពរបស់ពួកគេ និងមានលទ្ធភាពរៀបចំក្នុងនាមជាភ្នាក់ងារនៃការផ្លាស់ប្តូរនៅក្នុងសហគមន៍របស់ពួកគេ។ ការលើកឡើងនេះ ផ្អែកលើការស្រាវជ្រាវកន្លងមកស្តីពីយេនឌ័រ និងស្ថានភាពរស់នៅ និងលើការសិក្សាដែលធ្វើឡើងក្នុងតំបន់ជនបទ ក្នុងប្រទេសឥណ្ឌា។ |
| UNDP/GEF. (ឆ្នាំ២០០២) បង្កើតអនាគតកាបូនតិច។ ធ្វើឱ្យមានចីរភាពជីវភាព៖ បទពិសោធន៍ ពីគម្រោង UNDP-GEF Projects ក្នុងតំបន់ហិនហោចប្រព័ន្ធ Ozone និងការប្រែប្រួលអាកាសធាតុ។ ដកស្រង់ពីគេហទំព័រ៖ http://www.undp.org/gef/undp-gef_publications/publications/climate_change_brochure.pdf | ខិតបណ្ណនេះជាផ្នែកនៃ UNDP/GEF series មេរៀនសម្រាប់អនាគត។ វាផ្តល់នូវឧទាហរណ៍ដ៏ឆ្លាតវៃនៃគម្រោង UNDP/GEF ស្តីពីការប្រែប្រួលអាកាសធាតុ និងការហិនហោចស្រទាប់ ozone នៅប្រទេសប្រេស៊ីល ជ័រដេន ហ្គាណា និងហ្គាតេម៉ាឡា។ |
| UNDP Energy and Environment Group. (ឆ្នាំ២០០៦) យន្តការអភិវឌ្ឍស្អាត៖ ការប៉ាន់ប្រមាណវឌ្ឍនភាព។ ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/indexAction.cfm?module=Library&action=GetFile&DocumentAttachmentID=1859 | របាយការណ៍នេះពិនិត្យលើបទពិសោធន៍ជាមួយ CDM កំឡុងពេលឆ្នាំអនុវត្តដំបូងរបស់វា (ពីឆ្នាំ២០០២ ដល់ពាក់កណ្តាល ឆ្នាំ២០០៦) និងប៉ាន់ប្រមាណវិធីដែលវារីកចម្រើន និងការវិវត្តន៍មកដល់ពេលបច្ចុប្បន្ន។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| UNDP. (ឆ្នាំ២០០៧) **ការបន្សាំការប្រែប្រួលអាកាសធាតុ៖ អង្កេតតម្រូវការចំណេះដឹង។** ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/indexAction.cfm?module=Library&action=GetFile&DocumentAttachmentID=2357 | ការអង្កេតនេះ បានចែកចាយក្នុងចំណោមភ្នាក់ងាររដ្ឋាភិបាលភ្នាក់ងារ អង្គការសហប្រជាជាតិ គ្រឹះស្ថានស្រាវជ្រាវ សាកលវិទ្យាល័យ អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន ចង្អុលបង្ហាញពីតម្រូវការបង្កើតគោលនយោបាយ បន្សាំជាតិដើម្បីកាត់បន្ថយហានិភ័យមកលើប្រជាជន។ វាក៏បាននិយាយថាផែនការអភិវឌ្ឍជាតិគួរពិចារណាលក្ខខណ្ឌ ការបន្សាំការប្រែប្រួលអាកាសធាតុ។ សមត្ថភាពក្នុងការរៀបចំគោលនយោបាយបន្សាំជាតិ ត្រូវបានចាត់ទុកថាជាកត្តាប្រឈមដ៏សំខាន់ ជាងការស្វែងរកតម្រូវការមូលនិធិក្នុងគោលបំណងនេះ។ លទ្ធផលនៃការអង្កេតនេះ នឹងនាំមកនូវយន្តការសិក្សាបន្សាំ – ALM – គម្រោងលើកកម្ពស់ការផ្លាស់ប្ដូរបទពិសោធន៍បន្សាំ ដោយប្រើប្រាស់វេទិកាយុទ្ធនាការបើកទូលាយ។ |
| UNDP. (ឆ្នាំ២០០៧) **ពាក់កណ្ដាលផ្សេងទៀតនៃអាកាសធាតុ។** របាយការណ៍នេះ វិភាគផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅប្រទេស Indonesia។ **Change: Why Indonesia Must Adapt to Protect Its Poorest People.** ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/index.cfm?module=Library&page=Document&DocumentID=6509 | របាយការណ៍នេះ វិភាគលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅប្រទេសឥណ្ឌូនេស៊ី។ |
| UNDP Mexico. (ឆ្នាំ២០០៧). **វិធីសាស្រ្តអភិវឌ្ឍរីកចម្រើនលើបញ្ហាយេនឌ័រ និងការកាត់បន្ថយគ្រោះមហន្តរាយ – កសាងសមត្ថភាពប្រជាជនជាតិដើមភាគតិច ដើម្បីដោះស្រាយវិសមភាពយេនឌ័រ និងគ្រោះមហន្តរាយ**ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/indexAction.cfm?module=Library&action=GetFile&DocumentAttachmentID=2296 | បង្ហាញពីករណីសិក្សានៃកម្មវិធីការគ្រប់គ្រងហានិភ័យមូលដ្ឋាន ដែលធ្វើឡើងក្នុងភូមិជនជាតិដើមភាគតិចផ្សេងៗនៅប៉ែកខាងត្បូងប្រទេសម៉ិចស៊ិចកូ៖ វាត្រូវបានចាត់ទុកថាជាការអនុវត្តល្អ ដោយសារក្នុងចំណោមអ្វីផ្សេងៗទៀត វាប្រើប្រាស់វិធីសាស្រ្តរួម។ កម្មវិធីនេះ ផ្ដល់ឱ្យស្រ្តី ជាពិសេសសហគមន៍ ជនជាតិដើមភាគតិចក្នុងតំបន់នូវឱកាស និងជម្រើសការគ្រប់គ្រងកាន់តែប្រសើរ សម្រាប់ទាំងមនុស្ស និងរបស់ពួកគេ។ |

## ខ. ប្រភពផ្សេងៗ

## ១. ការណែនាំ និងឯកសារបណ្តុះបណ្តាល

| ឯកសារយោង | បរិយាយ |
| --- | --- |
| Braatz, B.V. និង Doorn, M. (ឆ្នាំ២០០៥). គ្រប់គ្រងស្តុកឧស្ម័នផ្ទះកញ្ចក់ជាតិ។ (UNDP-GEF) National Communications Support Group. ដកស្រង់ពីគេហទំព័រ៖ ncsp.undp.org/docs/461.pdf | ឯកសារនេះ ផ្អែកលើគោលការណ៍ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ។ វាចង្អុលពីសារៈសំខាន់នៃចងក្រងឯកសារ និងបំពេញស្តុកជាតិ ក៏ដូចជា វិធីសាស្ត្រធ្វើឱ្យទៅជាស្ថាប័ន។ |
| សម្ព័ន្ធអាកាសធាតុ (ឆ្នាំ២០០៥) **ឧបករណ៍អាកាសធាតុសម្រាប់ការផ្លាស់ប្តូរ។** ដកស្រង់ពីគេហទំព័រ៖ http://www.siyanda.org/static/climate_alliance_toolkit.htm | បរិយាយពីឧបករណ៍ការពារទាក់ទងនានា ដំណើរការ និងនីតិវិធីស្តីពីអាកាស និងជាពិសេសស្តីពីការប្រែប្រួលអាកាសធាតុ ដែលអាចជួយលើកកម្ពស់និងគាំទ្រស្ត្រីក្នុងដំណើរការធ្វើសេចក្តីសម្រេច។ |
| ENERGIA. (2005). **Training Manual to Increase Understanding of Gender Aspects of Energy Use and Planning.** ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/genderfaceEnergy.pdf | រៀបចំឡើងដើម្បីផ្សព្វផ្សាយដល់ដៃគូអភិវឌ្ឍ និងអ្នកគ្រប់គ្រងគម្រោង ដើម្បីបង្កើនសមត្ថភាពរបស់ពួកគាត់អំពីយេនឌ័រ និងថាមពល នៅក្នុងការរៀបចំផែនការ។ សៀវភៅបណ្តុះបណ្តាលនេះបញ្ចូលឧបករណ៍យេនឌ័រមួយចំនួនដើម្បីជួយដល់អ្នកប្រើប្រាស់ ក្នុងការកំណត់ទិដ្ឋភាពយេនឌ័រនៅក្នុងបញ្ហាថាមពល។ |
| Lu, X. (2006). **Guidance on the Development of Regional Climate Scenarios for Vulnerability and Adaptation Assessments.** National Communications Support Programme. ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/indexAction.cfm?module=Library&action=GetFile&DocumentAttachmentID=2259 | ឯកសារនេះ បញ្ជាក់ពីសារៈសំខាន់នៃការរៀបចំផែនការសម្រាប់កំណត់តម្រូវការព័ត៌មានក្នុងបរិបទអាកាសធាតុ។ ឯកសារនេះ រួមមានបញ្ជីប្រភពក្នុងការរៀបចំគំរូ ឧបករណ៍ ទិន្នន័យ និងមគ្គុទេសក៍។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| Rannauro-Melgarejo, E. (2007). **Manual:- Convención sobre la eliminación de todas lasformas de discriminación contra las mujeresy su protocolo facultativo CEDAW** (Manual: Convention on the Elimination of All Forms of Discrimination against Women and its Optional Protocol CEDAW). SRE/UNIFEM/UNDP, México. ដកស្រង់ពីគេហទំព័រ៖ http://www.sre.gob.mx/substg/temasglobales/bibliotecav.htm | ឯកសារនេះរៀបរាប់អំពីកត្តាសំខាន់នៃសន្និសីទ និងការពង្រាងអនុសារណៈ ក៏ដូចជាការណែនាំដែលអនុវត្តដោយគណៈកម្មការអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ)។ ឯកសារនេះមានការណែនាំសម្រាប់ការអនុវត្តមាត្រា និងដំណាក់កាលជាច្រើនក្នុងការផ្សព្វផ្សាយការបំពាន និងនីតិវិធីស៊ើបអង្កេតដែលបានបញ្ជាក់នៅក្នុងការពង្រាងអនុសារណៈ។ |
| The World Bank. (2009). **Engendering ICTToolkit.** ដកស្រង់ពីគេហទំព័រ៖ http://web.worldbank.org/WBSITE/EXTERNAL/TOPICS/EXTGENDER/EXTICTTOOLKIT/0,,menuPK:542826~pagePK:64168427~piPK:64168435~theSitePK:542820,00.html | ឯកសារនេះចែកចេញជា១០ផ្នែក ហើយវាមានបញ្ជីត្រួតពិនិត្យឧបករណ៍វាយតម្លៃ ឧទាហរណ៍នៃការអនុវត្តល្អៗ និងធនធានដែលអាចបញ្ចូលយេនឌ័រក្នុងគម្រោង ICT និងសមាសភាគគម្រោង។ វាត្រូវបានរៀបចំឡើងសម្រាប់ចែកចាយដល់អ្នកស្រាវជ្រាវ អ្នកអប់រំ និងអ្នកអនុវត្ត។ |
| UNDP. (2004). **Energy and Gender for Sustainable Development: A Toolkit and Resource Guide.** ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/genderengtoolkit.pdf | ឯកសារបណ្តុះបណ្តាល និងឯកសារយោងនេះរួមមានឧបករណ៍ជួយក្នុងការសម្រេចនូវលទ្ធផលក្នុងបរិបទថាមពលដោយផ្តោលើតម្រូវការជាក់របស់ស្ត្រី។ |
| UNDP. (2005). **Energizing the Millennium-Development Goals: A Guide to Energy's Role in Reducing Poverty.** ដកស្រង់ពីគេហទំព័រ៖ http://www.undp.org/pei/pdfs/Energizing_the_MDGs.pdf | ឯកសារនេះរំលឹកឡើងវិញនូវបញ្ហាដែលទាក់ទងនឹងការអភិវឌ្ឍន៍និងថាមពល និងជួយដល់អ្នកបច្ចេកទេសអភិវឌ្ឍន៍ក្នុងការស្វែងយល់ពីតួនាទីសេវាថាមពលដោយការសួយសំណួរ និងផ្តល់នូវចម្លើយនិងឧទាហរណ៍ក្បោះក្បាយ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍសហស្សវត្សរ៍។ |

| ឯកសារយោង | បរិយាយ |
|---|---|
| UNDP. (2006). **Guíatrans versalización degénero en proyectos de desarrollo.** ដកស្រង់ពីគេហទំព័រ៖ http://www.undp.org.mx/Doctos/Publicaciones/GUIA%20TRANSVERSALIZACION%20DE%20GENERO.pdf | ឧបករណ៍ពិគ្រោះយោបល់ដាក់លាក់ដើម្បីបញ្ជ្រាបវិធីសាស្ត្រយេនឌ័រ ក្នុងការរៀបចំ អនុវត្ត និងប៉ាន់ប្រមាណគម្រោងអភិវឌ្ឍ។ វាផ្ទុកនូវប្រធានបទទស្សនទាន ការគិតគូរប្រតិបត្តិការ និងអនុសាសន៍ជាក់លាក់សម្រាប់គម្រោងអភិវឌ្ឍ។ វាអនុវត្តតាមលទ្ធផលគម្រោង UNDP រួមបញ្ចូលការកំណត់បញ្ហានិងឱកាសដើម្បីបង្កើនប្រសិទ្ធភាពក្នុងន័យការបញ្ជ្រាបយេនឌ័រ។ |
| UNDP និងសម្ព័ន្ធភាពទឹក និងយេនឌ័រ (ឆ្នាំ២០០៦). **យេនឌ័រក្នុងការគ្រប់គ្រងទឹក៖ ធនធានណែនាំ** ដកស្រង់ពីគេហទំព័រ៖ http://www.genderandwater.org/page/2414 | ធនធានណែនាំ ជាឯកសារយោងដើម្បីជួយអ្នកជំនាញ និងអ្នកអនុវត្តក្នុងផ្នែកយេនឌ័រ និងទឹក ក៏ដូចជាអ្នកដែលទទួលខុសត្រូវសម្រាប់បញ្ជ្រាបវិធីសាស្ត្រយេនឌ័រក្នុងស្ថាប័ន គម្រោង ឬកម្មវិធី និងអ្នកផ្សេងទៀត ឬ ស្ថាប័នដែលមានចំណាប់អារម្មណ៍ ក្នុងផ្នែកយេនឌ័រ និងទឹក។ |
| កម្មវិធីគាំទ្រទំនាក់ទំនងជាតិ UNDP-UNEP-GEF (ឆ្នាំ២០០៦) NCSP **ធនធាន៖ ដំណើរការទំនាក់ទំនងជាតិ។** ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/indexAction.cfm?module=Library&action=GetFile&DocumentAttachmentID=2263 | កញ្ចប់ធនធាន ដែលផ្តល់ជាការណែនាំដល់ប្រទេសក្នុងដំណើរការទំនាក់ទំនងជាតិ ដាក់បញ្ចូលបច្ចេកទេសការទុកដាក់ស្តុកឧស្ម័នផ្ទះកញ្ចក់ និងប៉ាន់ប្រមាណការកាត់បន្ថយ។ |
| UNDP. (ឆ្នាំ២០០៣) **បញ្ជ្រាបយេឌ័រក្នុងការគ្រប់គ្រងទឹក៖ដំណើរដាក់លាក់ទៅកាន់ចីរភាព៖ កញ្ចប់ធនធាន។** ដកស្រង់ពីគេហទំព័រ៖ http://www.undp.org/water/docs/resource_guide.pdf | ឯកសារនេះត្រូវបានរៀបចំដើម្បីគាំទ្រការដាក់បញ្ចូលយេនឌ័រទៅក្នុងបរិបទការគ្រប់គ្រងរួមនៃធនធានទឹក (IMHR)។ វិធីសាស្ត្រជាមូលដ្ឋានគ្រឹះក្នុងការគាំទ្រការសម្រេចបាន MDGs ក៏ដូចជាការអនុវត្តផែនការ Johannesburg។ |

## ២. ព័ត៌មាន/តារាងតថភាព

| ឯកសារយោង | បរិយាយ |
|---|---|
| Aguilar, L. (ឆ្នាំ២០០៤) **ការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយគ្រោះមហន្តរាយ។** ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/Climate.pdf | ជាផ្នែកនៃបណ្តុះតារាងតថភាពយេនឌ័រធ្វើឱ្យមានការផ្លាស់ប្តូរនៃការិយាល័យ IUCN ទីប្រឹក្សាជាន់ខ្ពស់ស្តីពីយេនឌ័រ។ វាវិភាគលើវិធីសាស្ត្រ ស្តីពីប្រធានបទការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយ។ |
| Aguilar, L. (ឆ្នាំ២០០៤) **ថាមពល។** IUCN-Community Conservation Coalition. ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/Energy.pdf | ជាផ្នែកនៃបណ្តុះតារាងតថភាពយេនឌ័រធ្វើឱ្យមានការផ្លាស់ប្តូរនៃការិយាល័យ IUCN ទីប្រឹក្សាជាន់ខ្ពស់ ស្តីពីយេនឌ័រ។ បង្ហាញពីទំនាក់ទំនងរវាងយេនឌ័រ និងថាមពលទាំងក្នុងគំនិតផ្តួចផ្តើមគំនិតវិស័យថាមពល និងក្នុងទំនាក់ទំនងដែលស្ត្រីប្រើប្រាស់ទម្រង់ផ្សេងៗនៃថាមពល។ |
| Aguilar, L, Araujo, A. និង Quesada Aguilar, A.(ឆ្នាំ២០០៧). **យេនឌ័រ និងការប្រែប្រួលអាកាសធាតុ។** ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/Factsheet%20ClimateChange.pdf | តារាងតថភាពបានបង្ហាញនៅ UNFCCC COP 13 ធ្វើឡើងនៅទីក្រុង Bali នៅខែធ្នូ ឆ្នាំ២០០៧។ ការប្រែប្រួលអាកាសធាតុ មិនប៉ះពាល់ស្ត្រីនិងបុរសដូចគ្នានោះទេ។ វានឹងបន្តមានផលប៉ះពាល់ផ្សេងៗគ្នាអាស្រ័យយេនឌ័រ។ ដូច្នេះ គ្រប់ទិដ្ឋភាពទាក់ទងនឹងប្រែប្រួល (ឧទាហរណ៍៖ ការកាត់បន្ថយ ការបន្សាំ ការអភិវឌ្ឍគោលនយោបាយ) ត្រូវតែបញ្ចូលទស្សនទានយេនឌ័រ។ |
| Aguilar, L, Araujo, A. និង Quesada Aguilar, A. (ឆ្នាំ២០០៧) **ការជាំដុះ និងការកាប់បំផ្លាញ ការប្រែប្រួលអាកាសធាតុ និងយេនឌ័រ។** ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/Factsheet%20Foretry.pdf | តារាងតថភាពបានបង្ហាញនៅ UNFCCC COP 13 ធ្វើឡើងនៅទីក្រុង Bali នៅខែធ្នូ ឆ្នាំ២០០៧។ វាជាការចាំបាច់ក្នុងការយល់ដឹងពីតួនាទីដែលធ្វើឡើងដោយស្ត្រីនៅពេលគិតគូរភាពសាំញ៉ាំនៃសេវាកម្មដែលផ្តល់ដោយព្រៃនិងព្រៃទឹកភ្លៀងដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ យុទ្ធសាស្ត្រត្រូវបានរៀបចំដើម្បីពង្រីកនិងគិតគូរនូវអត្ថប្រយោជន៍ផ្សេងៗ ដែលស្ត្រី និងបុរសទទួលបានពីសេវាកម្មព្រៃឈើ; ទទួលស្គាល់ភាពខុសគ្នាយេនឌ័រក្នុងការទទួលបាន និងគ្រប់គ្រងចំណេះដឹងស្តីពីធនធានព្រៃឈើ និងកំណត់ភាពខុសគ្នាគ្រប់គ្រាន់ដែលស្ត្រី និងបុរសទទួលបានការធ្វើសេចក្តីសម្រេច ឱកាសសេដ្ឋកិច្ច និងស្ថាប័នទាក់ទងនឹងព្រៃឈើ។ |

| ឯកសារយោង | បរិយាយ |
|---|---|
| Araujo, A. និង Quesada Aguilar, A. In collaboration with: Aguilar, L., Athanas, A. and McCormick,N. (ឆ្នាំ២០០៧). **យេនឌ័រ និងជីវៈឧស្ម័ន។** ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/Fact-sheet%20BioEnergy.pdf | តារាងតថភាពបានបង្ហាញនៅ UNFCCC COP 13 ធ្វើឡើងនៅទីក្រុង Bali នៅខែធ្នូ ឆ្នាំ២០០៧។ ថាមពលជាមធ្យោបាយដើម្បីតម្រូវការ។ ទាំងស្ត្រីនិងបុរស អាស្រ័យលើថាមពលប្រើប្រាស់ថាមពលប្រចាំថ្ងៃរបស់ពួកគេ ប៉ុន្តែពួកគេមានតួនាទី និងតម្រូវការផ្សេងៗគ្នា បន្ថែមសេវាថាមពលផ្សេងៗគ្នា មានផលប៉ះពាល់ផ្សេងៗគ្នាមកលើបុរស និងស្ត្រី។ កន្លងមក ថាមពលដែលស្ត្រីត្រូវការនិងជីវភាពរស់នៅរបស់ពួកគេ ត្រូវបានមើលរំលង។ ទាំងសេវាកម្មថាមពលទំនើប និងប្រេងជាប្រពៃណីមានកំណត់ដែលអាចបង្កើនបញ្ហាស្ត្រីជួបប្រទះ។ |
| Araujo, A. and Quesada Aguilar, A. Incollaboration with: Aguilar, L. and Pearl, R. (ឆ្នាំ២០០៧) **សមភាពយេនឌ័រ និងការបន្ស៊ាំ** ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/Factsheet%20Adaptation.pdf | តារាងតថភាពបានបង្ហាញនៅ UNFCCC COP 13 ធ្វើឡើងនៅទីក្រុង Bali នៅខែធ្នូ ឆ្នាំ២០០៧។ ភាពងាយរងគ្រោះត្រូវបានកសាងក្នុងសង្គម និងខុសៗគ្នាសម្រាប់ក្រុមមនុស្សខុសៗគ្នា។ ស្ត្រីអាចងាយរងគ្រោះជាង លើផលប៉ះពាល់អវិជ្ជមាននៃគ្រោះមហន្តរាយធម្មជាតិ ដោយសារស្ថានភាពសេដ្ឋកិច្ច-សង្គម របស់ពួកគេ។ |
| Genanet. (n.d.). **ថាមពល ពីទស្សនទានយេនឌ័រ។** ដកស្រង់ពីគេហទំព័រ៖ http://www.genanet.de/fact_sheets.html?&L=1 | ជាផ្នែកនៃតារាងតថភាព*យេនឌ័រ និងចីរភាព*។ វាពិភាក្សាលើប្រធានបទជាក់លាក់ចំនួន៣៖ ឥរិយាបថចំពោះថាមពលនុយក្លេអ៊ែរ តើការងារក្នុងវិស័យថាមពលត្រូវបានបែងចែកសកម្មភាពដោយវិធីណា; និងការចូលរួមសេដ្ឋកិច្ចរបស់ស្ត្រី និងបុរសក្នុងវិស័យថាមពល។ |
| Genanet. (n.d.). **យុត្តិធម៌យេនឌ័រក្នុងកិច្ចការពារអាកាសធាតុ** ដកស្រង់ពីគេហទំព័រ៖ http://www.genanet.de/fact_sheets.html?&L=1 | ជាផ្នែកនៃតារាងតថភាព*យេនឌ័រ និងចីរភាព*។ វាវិភាគពីភាពទាក់ទងគ្នានៃយេនឌ័រក្នុងការកាត់បន្ថយ និងបន្ស៊ាំការប្រែប្រួលអាកាសធាតុជុំវិញពិភពលោក។ |
| PAHO. (n.d.). **Género y desastres naturales.** ដកស្រង់ពីគេហទំព័រ៖http://www.paho.org/Spanish/AD/GE/genderdisasterssp.PDF | អង្គការ Pan-American Health បង្ហាញពីការវិភាគលើយេនឌ័រ និងគ្រោះមហន្តរាយ បង្ហាញពីផ្នែកគោលក្នុងការបង្កើតសហគមន៍ឆ្លើយតបនឹងគ្រោះមហន្តរាយក្នុងការដាក់បញ្ចូលក្រុមជនងាយរងគ្រោះបំផុត -- ក្នុងករណីនេះ ស្ត្រី។ |

| ឯកសារយោង | បរិយាយ |
|---|---|
| UNDP. (ឆ្នាំ២០០៦) **ដាក់បញ្ចូលការគិតគូរពីថាមពលទៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយជាតិ។** តារាងតថភាព។ ដកស្រង់ពីគេហទំព័រ៖http://www.energyandenvironment.undp.org/undp/index.cfm?module=Library&page=Document&DocumentID=5774 | ការពិព័រណ៍ 'បង្កើនពន្លឿនគោលដៅអភិវឌ្ឍសហស្សវត្សរ៍' ធ្វើឡើងនៅកិច្ចប្រជុំទី១៤នៃគណៈកម្មការ ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព (CSD-14) ធ្វើនៅទីក្រុងញ៉ូយ៉ក នៅខែឧសភា ឆ្នាំ២០០៦។ នេះជាសេវាមួយនៃសេវាកម្មថាមពលទាំង១២ គោលដៅអភិវឌ្ឍសហស្សវត្សរ៍។ |
| UNDP. (ឆ្នាំ២០០៥) **ទទួលបានថាមពលប្រកបដោយចីរភាព។** ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/index.cfm?module=Library&page=Document&DocumentID=5543 | តារាងតថភាពនេះផ្តល់នូវព័ត៌មានពីសកម្មភាពគម្រោងថាមពលរបស់ UNDP និងវិធីសាស្ត្ររបស់វាក្នុងការផ្តល់សេវាថាមពលដែលអាចទទួលយក និងទុកចិត្តក្នុងការសម្រេចបាន MDGs។ |
| UNDP. (2005). **Effective Water Governance.** ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/index.cfm?module=Library&page=Document&DocumentID=5541 | តថភាពនេះឆ្លុះបញ្ចាំងពីសារៈសំខាន់ការគ្រប់គ្រងទឹកដោយប្រើប្រាស់វិធីសាស្ត្ររួមដែលទទួលស្គាល់តម្លៃរបស់វាក្នុងការកាត់បន្ថយភាពក្រីក្រសម្រាប់សុខភាពមនុស្សនិងប្រព័ន្ធអេកូឡូស៊ី។ |
| UNDP-GEF SGP. (2005). **ការប្រែប្រួលអាកាសធាតុ តារាងតថភាព៖ ភាពជាដៃគូក្នុងការសម្រួលគោលនយោបាយជាតិ។** ដកស្រង់ពីគេហទំព័រ៖sgp.undp.org/downloads/CC%20Policy%20-%20ENGLISH.pdf | គម្រោង SGP ត្រូវបានរៀបចំដើម្បីគាំទ្រសកម្មភាពដែលជួយកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងដល់ការអភិវឌ្ឍមូលដ្ឋាន។ វាលើកកម្ពស់ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍសេដ្ឋកិច្ច សន្តិសុខថាមពល និងការការពារបរិស្ថានមូលដ្ឋាន។ |
| Thaxton, M. (2004). **ទឹក។** IUCN/Community Conservation Coalition. ដកស្រង់ពីគេហទំព័រ៖ http://www.generoyambiente.org/admin/admin_biblioteca/documentos/Water.pdf | ជាផ្នែកនៃបណ្តុំតារាងតថភាពយេនឌ័រធ្វើឱ្យមានការផ្លាស់ប្តូរនៃការិយាល័យ IUCN ទីប្រឹក្សាជាន់ខ្ពស់ស្តីពីយេនឌ័រ។ ដោយចាត់ទុកប្រធានបទសមធម៌យេនឌ័រក្នុងការគ្រប់គ្រងទឹក ក៏ដូចជា ទំនាក់ទំនងរវាងស្ត្រីលើធនធាននេះ។ |

| ឯកសារយោង | បរិយាយ |
|---|---|
| UNDP. (2004). **Water Governance for Poverty Reduction: Key Issues and the UND PResponse to the Millennium Development-Goals.** ដកស្រង់ពីគេហទំព័រ៖ www.undp.org/water/pdfs/241456%20UNDP_Guide_Pages.pdf | ឯកសារនេះគូសបង្ហាញពីបញ្ហាទឹកចម្បងដែលជួបប្រទះ ក្នុងប្រទេសកំពុងអភិវឌ្ឍ និងផ្តល់ជាឧទាហរណ៍ការអនុវត្តល្អ ផ្អែកលើបទពិសោធន៍របស់ UNDP និងដៃគូពាក់ព័ន្ធ។ វាក៏ផ្តល់ជាអនុសាសន៍ផងដែរ។ |
| UNDP. (2005). **Sustainable Energy Services: The Gender Dimension.** ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/indexAction.cfm?module=Library&action=GetFile&DocumentAttachmentID=2024 | តារាងតថភាពនេះបង្ហាញពីសារៈសំខាន់នៃការដាក់បញ្ចូលនូវទិដ្ឋភាពយេនឌ័រក្នុងការទទួលបានសេវាថាមពលដែលផ្តល់ឱ្យស្ត្រីនិងក្មេងស្រីនូវឱកាសកាន់តែច្រើនសម្រាប់អនាគតកាន់តែប្រសើរ។ |
| UNDP. (2005) **អភិបាលកិច្ចទឹក៖ ទិដ្ឋភាពយេនឌ័រ។** ដកស្រង់ពីគេហទំព័រ៖http://www.energyandenvironment.undp.org/undp/indexAction.cfm?module=Library&action=GetFile&DocumentAttachmentID=2025 | តារាងតថភាពនេះចង្អុលបង្ហាញថាការបង្កើនសេវាកម្មទឹក និងអនាម័យមានផលប៉ះពាល់ដ៏សំខាន់លើជីវភាពរស់នៅរបស់ស្ត្រី និងក្មេងស្រី។ |
| UNDP. (2006) **ថាមពលសម្រាប់ស្ត្រី ថាមពលសម្រាប់ MDGs។** ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/indexAction.cfm?module=Library&action=GetFile&DocumentAttachmentID=1659 | តារាងតថភាពនេះរកឃើញនូវទំនាក់ទំនងរវាងយេនឌ័រ និងថាមពល និងចង្អុលបង្ហាញពីសារៈសំខាន់នៃការធានាឱ្យស្ត្រីនូវការទទួលបានសេវាកម្មថាមពល ប្រសិនបើ MDGs ត្រូវបានសម្រេចបាន។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| UNDP. (2007) តារាងព័ត៌មានសង្ខេប៖ UNDP និងការប្រែប្រួលអាកាសធាតុ។ ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/index.cfm?module=Library&page=Document&DocumentID=6506 | បង្ហាញពីផ្នែកចម្បងៗរបស់ UNDP នៃកិច្ចសហការលើការប្រែប្រួលអាកាសធាតុ និងវិធីដែលវាគាំទ្រប្រទេសកំពុងអភិវឌ្ឍក្នុងការបន្សុំាការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយភាពងាយរងគ្រោះ កសាងសមត្ថភាពមូលដ្ឋាននិងជាតិ លើកកម្ពស់លក្ខខណ្ឌទីផ្សារមានការចូលចិត្តសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ គៀរគរធនធានដើម្បីបង្កើនការកាត់បន្ថយ និងបន្សុំា និងលើកកម្ពស់ការទទួលបានថាមពលប្រកបដោយចីរភាពអនុលោមតាមគោលដៅអភិវឌ្ឍសហស្សវត្សរ៍។ |

## ៣. គេហទំព័រ

| ឯកសារយោង | បរិយាយ |
| --- | --- |
| ធ្វើកម្មវិធីការបន្សុំាការប្រែប្រួលអាកាសធាតុ http://www.undp.org/gef/adaptation/index.htm | បង្ហាញពីព័ត៌មានថ្មីៗពីគំរូការធ្វើហិរញ្ញប្បទាន GEF ចំនួន៣ ក្នុងការធ្វើសកម្មភាពបន្សុំា។ វាក៏បានផ្តល់ទំនាក់ទំនងទៅកាន់ធនធានផ្សេងៗទាក់ទងនឹងការប្រែប្រួលអាកាស និងការសង្ខេបទូទៅនៃការងារបន្សុំារបស់ UNDP ដែលរួមបញ្ចូលឧទាហរណ៍នៃគម្រោងដែលកំពុងអនុវត្ត និងការណែនាំលើការរៀបចំសំណើ។ |
| បណ្តាញអាហ្វ្រិកនៃអ្នកសារព័ត៌មានបរិស្ថាន http://www.anejmedia.org/home.html | បណ្តាញអាហ្វ្រិកនៃអ្នកសារព័ត៌មានបរិស្ថាន មាននូវព័ត៌មាន និងអត្ថបទស្តីពីការប្រែប្រួលអាកាសធាតុ ទាំងក្នុងបរិបទតំបន់អាហ្វ្រិក និងអន្តរជាតិ។ |
| សម្ព័ន្ធភាពអាកាសធាតុ http://www.klimabuendnis.org/ | សម្ព័ន្ធភាពអាកាសធាតុ ជាកិច្ចផ្តួចផ្តើមអឺរ៉ុប គ្របដណ្តប់លើប្រធានបទការប្រែប្រួលអាកាសធាតុ ពីទស្សនទានផ្សេងៗគ្នាដូចជា គោលនយោបាយអន្តរជាតិ សកម្មភាពមូលដ្ឋាន និងក្រុមជនអន្តោប្រវេសន៍។ គេហទំព័រ មានព័ត៌មានជាច្រើនលើប្រធានបទនេះ ក៏ដូចជាឯកសារយោងទៅកាន់គេហទំព័រផ្សេងទៀត។ |
| ការប្រែប្រួលអាកាសធាតុ http://www.undp.org/climatechange/ | គេហទំព័រ របស់ UNDP ស្តីពីការប្រែប្រួលអាកាសធាតុ ដែលបង្ហាញពីព័ត៌មានថ្មីៗនៃកម្មវិធី និងគំនិតផ្តួចផ្តើមទាក់ទងនឹងប្រធានបទនេះ។ |

| ឯកសារយោង | បរិយាយ |
|---|---|
| វិបត្តិអាកាសធាតុ<br>http://www.climatecrisis.net/ | គេហទំព័រផ្លូវការរបស់លោក Al Gore ដែលទទួលបានពានរង្វាន់ Academy of Motion PictureArts and Sciences of the United States សម្រាប់ភាពយន្តឯកសារ "AnInconvenient Truth"។ វាផ្តល់នូវទិន្នន័យមូលដ្ឋានស្តីពីការប្រែប្រួលអាកាសធាតុ និងព័ត៌មានដែលទាក់ទង។ |
| អាកាសធាតុសម្រាប់ផ្លាស់ប្តូរ – សមភាពយេនឌ័រ និងគោលនយោបាយអាកាសធាតុ<br>http://www.climateforchange.net/ | គម្រោងរបស់អឺរ៉ុបនេះ ព្យាយាមលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចស្តីពីការប្រែប្រួលអាកាសធាតុដោយផ្តោតលើកម្រិតមូលដ្ឋាន។ ការងារនេះធ្វើឡើងជាមួយនឹងអ្នកជំនាញឆ្លុះបញ្ចាំងក្នុងការបោះពុម្ព *អាកាសធាតុសម្រាប់ផ្លាស់ប្តូរ*។ |
| នយោបាយអាកាសធាតុ<br>http://opendemocracy.net/ | ផ្តល់នូវអត្ថបទជាច្រើនដោយអ្នកតំណាងនយោបាយថ្នាក់ខ្ពស់ និងសកម្មជនមូលដ្ឋានលើការប្រែប្រួលអាកាសធាតុ រួមបញ្ចូលផ្នែកវិទ្យាសាស្ត្រ និងបរិស្ថាន ថាមពលមានការច្នៃប្រឌិត និងទីក្រុងគ្មានកាបូន។ |
| ច្រកផ្លូវការអភិវឌ្ឍ – បរិស្ថាន និងការអភិវឌ្ឍ<br>http://topics.developmentgateway.org/environment/highlights/default/show-More.do | នៅក្នុងផ្នែកនៃប្រធានបទសំខាន់ៗនេះមានអត្ថបទជាច្រើនស្តីពីការប្រែប្រួលអាកាសធាតុក៏ដូចជា ប្រធានបទផ្សេងទៀតពីបរិស្ថាន និងការអភិវឌ្ឍ។ |
| មូលដ្ឋានធនធានគោល ការប្រែប្រួលអាកាសធាតុ DFID<br>http://www.dfid.gov.uk/pubs/files/climatechange/keysheetsindex.asp | មានការជ្រើសរើសល្អៗជាច្រើនលើតារាងតថភាពស្តីពីការប្រែប្រួលអាកាសធាតុ និងភាពក្រីក្រ។ វាក៏រួមបញ្ចូលនូវឯកសារស្តីពីការប្រែប្រួលអាកាសធាតុ ការធ្វើគោលនយោបាយស្តីពីការកាត់បន្ថយភាពក្រីក្រ ផលប៉ះពាល់តំបន់នៃការប្រែប្រួលអាកាសធាតុ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនានា។ |
| **ENERGIA**<br>http://www.energia.org/ | បណ្តាញអន្តរជាតិស្តីពីយេនឌ័រ និងថាមពលប្រកបដោយចីរភាព ដោយរួមបញ្ចូលអត្ថបទស្រាវជ្រាវ ករណីសិក្សា និងយុទ្ធសាស្ត្រសម្រាប់សកម្មភាព។ |
| **Energy Saving Trust**<br>http://www.energysavingtrust.org.uk/ | ផ្តល់នូវការសង្ខេបខ្លីៗនៃចំណុចគន្លឹះស្តីពីការប្រែប្រួលអាកាសធាតុ។ វាបង្ហាញថា និន្នាការនេះនឹងជាកត្តារាំងកាន់តែខ្លាំងឡើងដើម្បីអភិវឌ្ឍសហគមន៍ ដែលរងផលប៉ះពាល់ខ្លាំង។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| បរិស្ថាន និងថាមពល http://www.undp.org/energyandenvironment/gender.htm | យេនឌ័រជាបញ្ហាអន្តរវិស័យនៅគ្រប់ការងារទាំងអស់របស់ UNDP។ UNDP បានទទួលស្គាល់ថាសមភាពយេនឌ័រជាបេះដូងនៃការអភិវឌ្ឍមនុស្ស និងសិទ្ធិមនុស្ស ដែលវិសមភាពធ្វើឱ្យការខានការវិវត្តន៍ក្នុងការអភិវឌ្ឍមនុស្ស ការសម្រេចបាន MDGs និងទទួលបានការទទួលស្គាល់ជាអន្តរជាតិនូវសិទ្ធិមនុស្ស។ |
| គណៈកម្មាការបរិស្ថានអឺរ៉ុប http://ec.europa.eu/environment/life/ | គាំទ្រគម្រោងបរិស្ថាន និងគំនិតផ្តួចផ្តើមនៅអឺរ៉ុបនិងប្រទេសជិតខាង។ រួមមានព័ត៌មាននៃគោលនយោបាយអឺរ៉ុប និងអន្តរជាតិ ករណីសិក្សា និងការបន្សាំលើការប្រែប្រួលអាកាសធាតុ។ |
| Genanet http://www.genanet.de/index.php?id=2&L=1 | គម្រោងអង្គការ LIFE។ លើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍបច្ចេកវិទ្យាអេកូឡូស៊ី និងគម្រោងស្តីពីការអភិរក្សបរិស្ថាន និងសមធម៌ រៀបចំគោលគំនិតលក្ខណៈអប់រំ និងសម្របសម្រួលទំនាក់ទំនង រវាងអ្នកនយោបាយ អ្នកស្ត្រីនិយម និងអ្នកអភិរក្ស។ |
| យេនឌ័រ និងការប្រែប្រួលអាកាសធាតុ http://www.gencc.interconnection.org/ | បង្ហាញពីព័ត៌មានមូលដ្ឋានស្តីពីទំនាក់ទំនងរវាងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ដោយរួមបញ្ចូលប្រធានបទនៃការកាត់បន្ថយ និងការបន្សាំ។ |
| បណ្តាញគ្រោះមហន្តរាយ និងយេនឌ័រ http://www.gdnonline.org | បណ្តាញគ្រោះមហន្តរាយ និងយេនឌ័រ ជាគម្រោងអប់រំ ដែលចាប់ផ្តើមដោយស្ត្រី និងបុរសក្នុងទំនាក់ទំនងយេនឌ័រក្នុងបរិបទគ្រោះមហន្តរាយ។ |
| សម្ព័ន្ធភាពទឹកនិងយេនឌ័រ http://www.genderandwater.org | ស្វែងរកការលើកកម្ពស់សមធម៌យេនឌ័រលើការទទួលព័ត៌មាន និងការគ្រប់គ្រងសុវត្ថភាពធនធានទឹក។ បង្ហាញពីបណ្តុំព័ត៌មាននិងឧបករណ៍ការងារលើប្រធានបទក៏ដូចជា ករណីសិក្សា គម្រោង និងគោលនយោបាយ។ |
| INSTRAW: ការកាត់បន្ថយ និងការគ្រប់គ្រងគ្រោះមហន្តរាយ។ http://www.un-instraw.org/en/index.php?option=content&task=category&sectionid=6&id=52&Itemid=80 | ផ្តល់ជាការណែនាំ និងយុទ្ធសាស្ត្រលើការបញ្ជ្រាបជាតុយេនឌ័រនៅក្នុងការគ្រប់គ្រងហានិភ័យ និងការប្រែប្រួលអាកាសធាតុ។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| Intergovernmental Panel on Climate Change<br>http://www.ipcc.ch/ | បង្ហាញពីព័ត៌មានទាក់ទងស្តីពីបច្ចេកទេស វិទ្យាសាស្ត្រ និងការប៉ាន់ប្រមាណសេដ្ឋកិច្ច-សង្គមកិច្ច ការប្រែប្រួលអាកាសធាតុ ដែលបង្កឡើងដោយមនុស្ស។ ក៏មានបញ្ចូលផងដែរនូវរបាយការណ៍បច្ចេកទេស ផ្តោតផ្ទាល់លើរដ្ឋភាគី UNFCCC និងសហគមន៍ពិភពលោក។ |
| IUCN – យេនឌ័រ និងបរិស្ថាន<br>www.generoyambiente.org | គេហទំព័រនេះមានជំនាញក្នុងការភ្ជាប់វិធីសាស្ត្រយេនឌ័រ និងបរិស្ថាន។ វាបង្ហាញពីបណ្តុំព័ត៌មានដែលរួមមានអត្ថបទស្តីពី |
| Latin America GENERA<br>www.americalatinagenera.org | វេទិកាចំណេះដឹងគាំទ្រដោយ UNDP ដើម្បីជម្រុញសមធម៌យេនឌ័រក្នុងតំបន់ LatinAmerican។ វាប្រមូលការបោះពុម្ព ឧបករណ៍ និងបទពិសោធន៍ពីអ្នកពាក់ព័ន្ធផ្សេងៗគ្នា នៅក្នុងតំបន់ (រដ្ឋាភិបាល ក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រព័ន្ធ UN និងដៃគូអភិវឌ្ឍ)។ វាបានរៀបចំថ្នាក់រៀន (virtual classroom) វេទិកាពិសេស និងលំហទំនាក់ទំនង/អប់រំ។<br><br>វាជាគំនិតផ្តួចផ្តើមរួមគ្នាជាមួយ UNDP Bureau for Crisis Prevention and Recovery ដែលស្វែងរកការដាក់បញ្ចូលវិធីសាស្ត្រយេនឌ័រក្នុងការគ្រប់គ្រងហានិភ័យ។ ដើម្បីសម្រេចបាន វាផ្តល់ជាគំនិតផ្តួចផ្តើមទីមួយដែលនាំមានការភ្ជាប់ចំណេះដឹង និងយុទ្ធនាការរវាងផ្នែកទាំងពីរ ដោយបង្កើតជាសហគមន៍ (virtual community) រៀបចំក្របខ័ណ្ឌទស្សនទាន ឧបករណ៍វិធីសាស្ត្រ និងសមត្ថភាពអ្នកពាក់ព័ន្ធ (មេរៀន virtual)។ |
| Oxfam: ការប្រែប្រួលអាកាសធាតុ<br>http://www.oxfam.org.uk/what_we_do/issues/climate_change/bp104_climate.htm | ផ្ទុកនូវព័ត៌មានដ៏ល្អទាក់ទងនឹងការប្រែប្រួលអាកាសធាតុជុំវិញពិភពលោកក៏ដូចជាមានការបោះពុម្ពទាក់ទងបញ្ហាយេនឌ័រការអភិវឌ្ឍ និងការប្រែប្រួលអាកាសធាតុ។ |
| ពិភពលោកមិនអាចរង់ចាំ<br>womentoact.com<br>www.womentoact.com/en/ | បណ្តាញដែលស្ត្រីមានការប្តេជ្ញាក្នុងការធ្វើសកម្មភាពផ្ទាល់ខ្លួន និងជំនាញដើម្បីប្រឆាំងនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ |

| ឯកសារយោង | បរិយាយ |
|---|---|
| ផ្នែកពិសេសការប្រែប្រួលអាកាសធាតុ របស់ The Guardian http://www.guardian.co.uk/environment/climatechange | ទទួលបានការជ្រើសរើសដ៏គួរឱ្យចាប់អារម្មណ៍នៃអត្ថបទការប្រែប្រួលអាកាសធាតុ ប្រជាប្រិយភាពទីផ្សារកាបូនការលើកកម្ពស់ប្រធានបទ (ការស្វែងរកការគាំទ្រមតិ និងសកម្មភាព។ ផ្ទុកនូវរបាយការណ៍ពិសេសស្តីពីករណីសិក្សា។ |
| មជ្ឈមណ្ឌល Pew ការប្រែប្រួលអាកាសធាតុ http://www.pewclimate.org/ | ផ្តល់នូវព័ត៌មានដ៏ច្រើនស្តីពីការប្រែប្រួលអាកាសធាតុនៅថ្នាក់តំបន់ជាតិ និងអន្តរជាតិ។ ផ្តល់នូវព័ត៌មានទាក់ទងនឹងការបង្កើតយុទ្ធសាស្ត្រអន្តរវិស័យ និងគំនិតផ្តួចផ្តើមទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ |
| UNDP. ថាមពលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព៖ ទិដ្ឋភាពទូទៅ http://www.undp.org/energy/ | ដោយប្រើប្រាស់វិធីសាស្ត្រអភិវឌ្ឍរួម ការងាររបស់ UNDP ជួយបង្កើតក្របខ័ណ្ឌនយោបាយ រៀបចំសមត្ថភាពមូលដ្ឋាន និងផ្តល់ជំនួយបច្ចេកទេសដើម្បីពង្រីកការទទួលបានសេវាថាមពលរបស់អ្នកដែលក្រីក្របំផុត។ វាឆ្លើយតបទៅនឹង MDG1 ៖ កាត់បន្ថយចំនួនប្រជាជនរស់នៅក្នុងភាពក្រីក្រ។ |
| UNEP http://www.unep.org/themes/climatechange/ | ផ្ទុកនូវព័ត៌មានវិទ្យាសាស្ត្រ ស្តីពីការប្រែប្រួលអាកាសធាតុ ក៏ដូចជាព័ត៌មានស្តីពីគោលនយោបាយអន្តរជាតិ និងរបាយការណ៍ផ្លូវការ។ ផ្តល់នូវព័ត៌មានលើសកម្មភាពដែលបានអនុវត្តដោយ UNEP និងតួនាទីរបស់វាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ |
| យុទ្ធសាស្ត្រអន្តរជាតិសហប្រជាជាតិ សម្រាប់កាត់បន្ថយគ្រោះមហន្តរាយ (ISDR) http://www.unisdr.org/ | ស្វែងរកការបង្កើតសហគមន៍កាន់តែច្រើនដែលមានការរៀបចំដើម្បីប្រឈមនឹងគ្រោះធម្មជាតិ។ ដើម្បីកាត់បន្ថយការបាត់បង់អាយុជីវិតមនុស្ស ក៏ដូចជា បាត់បង់បរិស្ថាន សេដ្ឋកិច្ច និងសង្គម វាបានលើកកម្ពស់ ជាធាតុការអភិវឌ្ឍប្រកបដោយចីរភាពរួម ការធ្វើយុទ្ធនការពីសារៈសំខាន់នៃការកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយ។ |
| United Nations System Portal on Climate Change www.un.org/climatechange/ | ផ្ទុកនូវព័ត៌មានបច្ចុប្បន្នភាពស្តីពីការប្រែប្រួលអាកាសធាតុពីភ្នាក់ងារក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ។ វាផ្តល់ព័ត៌មានលម្អិតស្តីពីអនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ និងសកម្មភាពជាក់លាក់ដោយអង្គការសហប្រជាជាតិលើប្រធានបទនេះ។ វាក៏ផ្តល់នូវព័ត៌មានអត្ថបទ និងការព្រឹត្តិការណ៍អន្តរជាតិទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ |

| ឯកសារយោង | បរិយាយ |
|---|---|
| **WEDO**<br>http://www.wedo.org/ | ផ្តល់ព័ត៌មាន និងអត្ថបទជាច្រើនលើប្រធានបទ យេនឌ័រ ការអភិវឌ្ឍ និងគោលនយោបាយពិភពលោក។ វាក៏ផ្ទុកនូវព័ត៌មានដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងយេនឌ័រ ផងដែរ។ |
| **WECF**<br>http://www.wecf.de/ | កិច្ចខិតខំដ៏មហិមាក្នុងការចងក្រងបរិស្ថានប្រកបដោយផាសុកភាពសម្រាប់ទាំងអស់គ្នា។ វាប្រើប្រាស់នូវសក្តានុពលស្ត្រីដើម្បីអភិរក្សបរិស្ថាន សុខភាព និងសេដ្ឋកិច្ច។ សកម្មភាព WECF ពឹងផ្អែកលើសមាជិករបស់វា ទាំងស្ត្រី និងបុរស និងភាពចាំបាច់និងទស្សនៈរបស់ពួកគេ។ ដូច្នេះហើយ វាអនុវត្តដំណោះស្រាយមូលដ្ឋាន និងជះឥទ្ធិពលលើគោលនយោបាយអន្តរជាតិ។ របាយការណ៍ និងឯកសាររបស់វា អាចរកបានក្នុងគេហទំព័រនេះ។ |
| **Women's Environmental Network**<br>www.wen.org.uk | បណ្តាញនេះ ស្វែងរកការអប់រំ បង្កើតភាពអង់អាច និងប្រាប់ស្ត្រី និងបុរសដែលមានការព្រួយបារម្ភពីបរិស្ថាន។ វាក៏បានរៀបចំ តាមរយៈទស្សនៈស្ត្រី នូវយុទ្ធនាការស្តីពីបរិស្ថាន និងសុខភាព។ |



## ៤. ផ្សេងៗ

| ឯកសារយោង | បរិយាយ |
|---|---|
| Calisiti, N. (ឆ្នាំ២០០៧). **Peruanas bajo el temblor.** Artemisa noticias, from Pisco. 22 August, 2007. ដកស្រង់ពីគេហទំព័រ៖ http://www.artemisanoticias.com.ar/site/notas.asp?id=2&idnota=4792 | របាយការណ៍ ដែលភាគច្រើនស្ត្រីដែលជាអ្នកទាមទារថាជំនួយមនុស្សធម៌ ត្រូវបែងចែកដោយស្មើភាព។ ពួកគេអមអ្នកធ្វើការក្នុងការស្វែងរកសាកសព និងរកកុមារពីគ្រោះមហន្តរាយរញ្ជួយផែនដីដែលកើតនៅប្រទេសប៉េរូ ក្នុងខែសីហា ឆ្នាំ២០០៧។ |
| ENERGIA. (ឆ្នាំ២០០៥) **យេនឌ័រ ថាមពលនិង MDGs.** Energy News, Vol. 8, issue 2, Dec. 2005. ដកស្រង់ពីគេហទំព័រ៖ http://www.energia.org/resources/newsletter/en-122005.pdf | ENERGY – ព្រឹត្តិប័ត្រព័ត៌មានបណ្តាញថាមពល និងការអភិវឌ្ឍប្រកបដោយចីរភាព។ ការចេញផ្សាយនេះ ផ្តោតលើប្រធានបទថាមពលប្រកបដោយចីរភាពនិងយេនឌ័រ។ វាបង្ហាញទាំងករណីសិក្សានិងកាតវិភាគលក្ខណៈទ្រឹស្តី។ |

| ឯកសារយោង | បរិយាយ |
|---|---|
| Falconi, C. (ឆ្នាំ២០០៦) គាំទ្រការបន្សាំការប្រែប្រួលអាកាសធាតុរបស់ UNDP។ Latin America Regional Workshop on Adaptation, 18–20 April2006, Lima, Peru. ដកស្រង់ពីគេហទំព័រ៖ http://unfccc.int/files/adaptation/adverse_effects_and_response_measures_art_48/application/pdf/undps_support_for_climate_change_adaptation_-_cecilia_falconi_undp.pdf | របាយការណ៍ ដែលភាគច្រើនស្ត្រីដែលជាអ្នកទាមទារថាជំនួយមនុស្សធម៌ ត្រូវបែងចែកដោយស្មើភាព។ ពួកគេអមអ្នកធ្វើការក្នុងការស្វែងរកសាកសព និងរកកុមារពីគ្រោះមហន្តរាយរញ្ជួយផែនដី ដែលកើតនៅប្រទេសប៉េរូ ក្នុងខែសីហា ឆ្នាំ២០០៧។ |
| OAS. (ឆ្នាំ២០០៦) យុទ្ធសាស្ត្រអន្តរជាតិសម្រាប់កាត់បន្ថយមហន្តរាយ នៅ Latin America និង Caribbean. ដកស្រង់ពីគេហទំព័រ៖ http://www.eird.org/esp/revista/no_13_2006/art16.htm | OAS មាននិងបង្ហាញលទ្ធផលនៃសិក្ខាសាលាស្តីពីការគ្រប់គ្រងមហន្តរាយធម្មជាតិសម្រាប់កិច្ចប្រជុំអន្តរអាមេរិកាំងទីមួយនៃរដ្ឋមន្ត្រី និងអាជ្ញាធរជាន់ខ្ពស់ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព។ |
| Poverty - Environment Partnership. (ឆ្នាំ២០០៦) ភ្ជាប់ការកាតបន្ថយភាពក្រីក្រ និងការគ្រប់គ្រងទឹក។ ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/indexAction.cfm?module=Library&action=GetFile&DocumentAttachmentID=1580 | ឯកសារនេះបកស្រាយពីមធ្យោបាយផ្សេងៗគ្នាដែលភាពរីកចម្រើនក្នុងការគ្រប់គ្រងទឹក ជួយកាត់បន្ថយភាពក្រីក្រ។ |
| កាកបាទក្រហម. (ឆ្នាំ២០០៧) ការប្រែប្រួលអាកាសធាតុនឹងមានការខូចខាតធ្ងន់ធ្ងរបំផុតសម្រាប់ប្រជាជនក្រីក្រ និងងាយរងគ្រោះ។ Red Cross,- Guayaquil. Information bulletin.Number 5, May 2007. ដកស្រង់ពីគេហទំព័រ៖ http://www.ifrc.org/Docs/pubs/events/interamerican07/daily-bulletin-05-sp.pdf | ព្រឹត្តិប័ត្រនេះបកស្រាយថា ផលប៉ះពាល់សម្បើមបំផុតនៃការប្រែប្រួលអាកាសធាតុ នឹងមានមកលើប្រជាជនក្រីក្រ និងងាយរងគ្រោះជាពិសេសស្ត្រី។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| Röhr, U. (ឆ្នាំ២០០៦) **យេនឌ័រ និងការប្រែប្រួលអាកាសធាតុ។** ដកស្រង់ពីគេហទំព័រ៖ http://www.wecf.de/cms/articles/2006/01/climatechange_docs.php | បង្ហាញឯកសារចំនួន៥ លើបញ្ហាទាក់ទងនឹងយេនឌ័រ និងការប្រែប្រួលអាកាសធាតុក្នុងក្របខ័ណ្ឌ UNFCCC COP11/MOP1។ |
| ធនាគារពិភពលោក (ឆ្នាំ២០០៨) **Gender and the Digital Divide Seminar Series.** ដកស្រង់ពីគេហទំព័រ៖ http://web.worldbank.org/WBSITE/EXTERNAL/TOPICS/EXTGENDER/0,,contentMDK:20207786~menuPK:489311~pagePK:148956~piPK:216618~theSitePK:336868,00.html | ធនាគារពិភពលោក បានចាប់ផ្តើមសិក្ខាសាលា យេនឌ័រ និង ICTs ក្នុងឆ្នាំ២០០០។ តាមរយៈកម្មវិធីនេះ អ្នកអនុវត្ត អ្នកធ្វើគោលនយោបាយ និងអ្នកសិក្សាត្រូវបានអញ្ជើញដើម្បីពិភាក្សាលើផលប៉ះពាល់នៃ ICT លើទំនាក់ទំនងយេនឌ័រ និងមធ្យោបាយដែល ICT អាចប្រើប្រាស់ក្នុងការជំនះវិសមភាពយេនឌ័រ។ ទំព័រនេះផ្តល់នូវសម្ភារៈបទបង្ហាញពីសិក្ខាសាលារួមទាំងវីដេអូ។ |
| UNDP. (ឆ្នាំ២០០៦) **សម្ព័ន្ធភាពទឹក និងយេនឌ័រ។** ដកស្រង់ពីគេហទំព័រ៖http://www.energyandenvironment.undp.org/undp/indexAction.cfm?module=Library&action=GetFile&DocumentAttachmentID=2028 | បេសកកម្ម GWA គឺលើកកម្ពស់ការទទួលបានស្មើគ្នានិងការគ្រប់គ្រងរបស់ស្ត្រីនិងបុរស លើទឹកសមរម្យ និងសុវត្ថិភាព សម្រាប់ផ្គត់ផ្គង់ក្នុងស្រុក អនាម័យ សន្តិសុខស្បៀង និងចីរភាពបរិស្ថាន។ |
| UNDP-Cap-Net. (ឆ្នាំ២០០៦) **ហេតុអ្វីគិតគូរពីយេនឌ័រ៖ ការបង្ហាត់សម្រាប់អ្នកគ្រប់គ្រងទឹក។** ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/indexAction.cfm?module=Library&action=GetFile&DocumentAttachmentID=1869 | ការបង្ហាត់នេះ បង្ហាញពីមធ្យោបាយក្នុងឆ្លើយតបសំនួរទាក់ទងនឹងយេនឌ័រ លើការប្រើប្រាស់ទឹកកាន់តែមានប្រសិទ្ធភាពក្នុងការជួយអភិរក្សបរិស្ថាន ក៏ដូចជាលើកកម្ពស់អត្ថប្រយោជន៍សង្គមនិងសមធម៌ក្នុងការប្រើប្រាស់ធនធានទឹក។ វាក៏ជួយកសាងសមត្ថភាពផងដែរដើម្បីបញ្ចូលសំនួរទាក់ទងនឹងយេនឌ័រ ក្នុងវគ្គបណ្តុះបណ្តាល និងកម្មវិធីអប់រំ។ វាត្រូវបានរៀបចំរួមគ្នាដោយ Cap-Net និង GWA. |
| UNDP. (ឆ្នាំ២០០៧) **ម្តាយផែនដី៖ ស្ត្រីនិងការគ្រប់គ្រងដី ប្រកបដោយចីរភាព។** ដកស្រង់ពីគេហទំព័រ៖http://www.undp.org/gef/05/documnts/publications/Women&SustLandManagement_web.pdf | ការបោះពុម្ពនេះជាផ្នែកនៃ UNDP series ដែលរួមបញ្ចូលនូវទស្សនទាន។ វាផ្តល់នូវការណែនាំជាក់លាក់ពីមធ្យោបាយក្នុងការបញ្ចូលទស្សនទានយេនឌ័រនៅពេលបង្កើតគោលនយោបាយគ្រប់គ្រងដីប្រកបដោយចីរភាព។ |

| ឯកសារយោង | បរិយាយ |
| --- | --- |
| UNDP. (ឆ្នាំ២០០៧) ការគ្រប់គ្រងដីប្រកបដោយចីរភាព៖ ហេតុអ្វី និងមធ្យោបាយ ការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងដីប្រកបដោយចីរភាព។ ដកស្រង់ពីគេហទំព័រ៖ http://www.energyandenvironment.undp.org/undp/indexAction.cfm?module=Library&action=GetFile&DocumentAttachmentID=2322 | ឯកសារនេះជាផ្នែកនៃបណ្តុំការបោះពុម្ពមានចំណងជើងថា ការបញ្ជ្រាបយេនឌ័រ៖ កត្តាជំរុញគន្លឹះនៃការអភិវឌ្ឍបរិស្ថាន និងថាមពល។ ការណែនាំនេះ បកស្រាយពីសារៈសំខាន់នៃវិធីសាស្ត្រយេនឌ័រក្នុងការរៀបចំគោលនយោបាយ និងកម្មវិធីការគ្រប់គ្រងដីប្រកបដោយចីរភាព។ |
| Women's Environmental Network. (ឧសភា ឆ្នាំ២០០៧) សេចក្តីថ្លែងការណ៍ស្ត្រី ស្តីពីការប្រែប្រួលអាកាសធាតុ។ ស្ត្រីទាមទារសកម្មភាពកាន់តែច្រើនលើការប្រែប្រួលអាកាសធាតុ។ Press release. ដកស្រង់ពីគេហទំព័រ៖ http://www.wen.org.uk/general_pages/Newsitems/pr_manifest15.5.07.htm | តាមរយៈសេចក្តីថ្លែងការណ៍ ដែលធ្វើឡើងដោយអង្គការស្ត្រីដ៏មានឥទ្ធិពល២ សកម្មភាពកាន់តែច្រើនត្រូវបានទាមទារ នៅពេលដោះស្រាយជាមួយការប្រែប្រួលអាកាសធាតុ ជំហានដែលមានការយកចិត្តទុកដាក់កាន់តែច្រើនធ្វើឡើងដើម្បីកាត់បន្ថយការបញ្ចេញ $CO_2$ និងការចូលរួមកាន់តែច្រើនក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងបរិស្ថាន។ |

Empowered lives.
Resilient nations.

Canada

CANADA-UNDP
Climate Change Adaptation Facility

gef